ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
(គ.ជ.ប)

បទបញ្ជា និងនីតិវិធី
សម្រាប់
ការបោះឆ្នោតជ្រើសរើស
ក្រុមប្រឹក្សាឃុំ សង្កាត់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ១៤០ គ.ជ.ប.ស.ស.រ

សេចក្តីសម្រេច
ស្តីពី
ការដាក់ឱ្យប្រើបទបញ្ជា និងនីតិវិធី
សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩២៦/០១៥ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៨៩ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ០២៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

មហាវិថីសម្តេចសុធាវស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ, កម្ពុជា
Samdach Sothearos Blvd, Sangkat Tonle Bassac, Khan Chamkar Morn, Phnom Penh, Cambodia
ទូរស័ព្ទ : (+855) 23 23 52 53
អ៊ីម៉ែល : info@nec.gov.kh

- បានឃើញសេចក្តីសម្រេចលេខ ២០០៧ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥ ស្តីពីការកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទទួលការឯកភាពពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងកិច្ចប្រជុំនាថ្ងៃទី១៨ ខែសីហា និងថ្ងៃទី១ ខែតុលា ឆ្នាំ២០២៦

សម្រេច

ប្រការ១.-

ត្រូវបានដាក់ឱ្យប្រើជាផ្លូវការនូវបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ប.ន.ឃ.ស) ដែលមាន ១៤ជំពូក ១៩៩ប្រការ និងឧបសម្ព័ន្ធទាំង៩។

ប្រការ២.-

បទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់ឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ឬចៅសង្កាត់ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ត្រូវយកទៅអនុវត្តចាប់ពីការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់អាណត្តិទី៦ តទៅ។

ប្រការ៣.-

អគ្គលេខាធិការ គ.ជ.ប និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០២៦
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ប្រាជ្ញ ចន្ទ

អនុគ្រោះទទួលៈ
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ខុទ្ទកាល័យឯកឧត្តមប្រធាន គ.ជ.ប
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ

មាតិកា

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ១

ជំពូកទី២ ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ៤

- សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត ៤
- អំណាច មុខងារ និងភារកិច្ចរបស់ គ.ជ.ប ៤
- សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបការងាររបស់ គ.ជ.ប ៥
- ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឬ មន្ត្រីបោះឆ្នោត ៦
- សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបការងាររបស់ គធ.ខប ៦
- បែបបទ នីតិវិធី និងលក្ខណៈនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ.ខប ៦
- សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបការងាររបស់ គឃ.សប ៧
- បែបបទ នីតិវិធី និងលក្ខណៈនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គឃ.សប ៧
- សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ ៧
- បែបបទ នីតិវិធី និងលក្ខណៈនិច្ឆ័យក្នុងការជ្រើសរើស និងការស្នើសុំតែងតាំងសមាសភាព គ.ក.ប/គ.ក.រ ៩
- បែបបទ និងនីតិវិធីនៃការជ្រើសរើសសមាសភាព គធ.ខប គឃ.សប និង គ.ក.ប/គ.ក.រ ១២
- ប្រាក់កម្រៃរបស់មន្ត្រីបោះឆ្នោត ១២
- អាណត្តិរបស់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ១២
- ការតែងតាំងក្នុងរយៈពេលមានកំណត់ ១៣
- គោលការណ៍នៃការប្រើប្រាស់សម្ភារ និងបរិក្ខារបស់ គ.ជ.ប ១៣
- ប្រតិទិនសម្រាប់ការបោះឆ្នោត ១៤
- ការងារសន្តិសុខបោះឆ្នោត ១៤

ជំពូកទី៣ ការចុះឈ្មោះបោះឆ្នោត បញ្ជីបោះឆ្នោត និងការបោះឆ្នោត ២០

- ការបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការសម្រាប់ប្រើនៅពេលបោះឆ្នោត ២១
- នីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ២២
  - ការផ្គត់ផ្គង់សម្ភារ បរិក្ខារ កុំព្យូទ័រ ២២
  - នីតិវិធីនៃការស្នើសុំ ឯ.អ ២២
  - បែបបទ និងនីតិវិធីនៃការចេញ ឯ.អ ២៣

ជំពូកទី៤ ប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសនៈ ២៥

- ប្រព័ន្ធបោះឆ្នោត ២៥

- ការបែងចែកអាសនៈ ២៥
- ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយនៅពេលដែល គជ.ខប បែងចែកអាសនៈរួច ៣៦
- ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួនមានមធ្យមភាគខ្ពស់បំផុតស្មើគ្នា នៅពេល គជ.ខប បែងចែកអាសនៈរួច ៤៨
- ការចាប់ឆ្នោតជាសាធារណៈដើម្បីទទួលបានអាសនៈ ៥២
- ការចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈក្នុង កបយ.ស នៅពេលដែល គជ.ខប ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត ៥៤
- ការស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបយ.ស ៥៨
- ការកំណត់ឈ្មោះសមាជិក កបយ.ស ជាប្រធាន កបយ.ស ជាមេឃុំ ឬចៅសង្កាត់ ដំទប់ទី១ ឬចៅសង្កាត់រងទី១ និងដំទប់ទី២ ឬចៅសង្កាត់រងទី២ ..... ៥៩
- ការបាត់បង់សមាជិកភាព កបយ.ស ៦៤
- ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយនៅក្នុងអាណត្តិនៃ កបយ.ស ៦៤
- ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួនមានមធ្យមភាគខ្ពស់បំផុតស្មើគ្នា ក្នុងពេលបែងចែកអាសនៈទំនេរនៅក្នុងអាណត្តិនៃ កបយ.ស ៦៦
- ការចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយនៅក្នុងអាណត្តិនៃ កបយ.ស ៦៧

ជំពូកទី៥ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ៧១

- ការកំណត់ទីតាំងការិយាល័យបោះឆ្នោត ៧១
- ការផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ៧៣
- ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ៧៣
- វិធានការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ៧៤
- វិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ ៧៧

ជំពូកទី៦ ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ៧៩

- ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន ៧៩
- មូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធិបោះឆ្នោត ៧៩
- ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន ៨០

- ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស ៨០
- ការដាក់ឱ្យប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ៨៣
- ការទទួលពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយដោយ គយ.សប ៨៤
- ការពិនិត្យ និងសម្រេចរបស់ គយ.សប លើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ៨៥
- ការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរ ឈ្មោះបោះឆ្នោត ៩៣

ជំពូកទី៧ ការឃោសនាបោះឆ្នោត ៩៧

- បទប្បញ្ញត្តិទូទៅនៃការឃោសនាបោះឆ្នោត ៩៧
- សម្ភារអប់រំអ្នកបោះឆ្នោត ១១០
- រូបភាព និងសម្ភារឃោសនាបោះឆ្នោត ១១២
- កិច្ចសហការ និងតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាមួយ គ.ជ.ប ១២០

ជំពូកទី៨ ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន ១២១

ផ្នែកទី១ ភ្នាក់ងារគណបក្សនយោបាយ ១២១

- ភ្នាក់ងារគណបក្សនយោបាយ ១២១
  - សិទ្ធិ និងការកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ ១២៤
  - បម្រាមចំពោះគណបក្សនយោបាយ និងភ្នាក់ងារគណបក្សនយោបាយ ១២៥

ផ្នែកទី២ អ្នកសង្កេតការណ៍បោះឆ្នោត ១២៩

- អ្នកសង្កេតការណ៍បោះឆ្នោត ១២៩
- អ្នកសង្កេតការណ៍បោះឆ្នោតជាតិ ១៣០
- អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ ១៣៣
  - សិទ្ធិរបស់អ្នកសង្កេតការណ៍បោះឆ្នោត ១៣៤
  - ការកិច្ចរបស់អ្នកសង្កេតការណ៍បោះឆ្នោត ១៣៥
  - បម្រាមចំពោះអ្នកសង្កេតការណ៍បោះឆ្នោត ១៣៦

ផ្នែកទី៣ អ្នកសារព័ត៌មាន ១៣៨

- អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ១៣៨

ជំពូកទី៩ ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ១៤២

- ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ១៤២
- ការផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារ ឧបករណ៍ចាំបាច់សម្រាប់ការបោះឆ្នោត ១៤៣
- ការទទួលខុសត្រូវ និងការកិច្ចរបស់ គ.ក.ប/គ.ក.រ ១៤៤

- ការត្រៀមសម្ភារ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត ១៥២
- ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ១៥៨
- ការប្រព្រឹត្តទៅនៃការបោះឆ្នោត ១៥៨

ជំពូកទី១០ ការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រមូល ប្រគល់ ទទួលសម្ភារបោះឆ្នោត ១៧៧

- ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ១៧៧
- ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត ១៨១
- សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ..... ១៩២
- ការរៀបចំ និងការវេចខ្ចប់កញ្ចប់សុវត្ថិភាព “ក” ដាក់កំណត់ហេតុនៃការបោះឆ្នោត តារាងកត់ត្រាសំឡេងឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ.....១៩៥
- កិច្ចប្រតិបត្តិការរបស់ គយ.សប ក្នុងការស្នែន និងបញ្ជូនរូបភាពកំណត់ហេតុនៃការបោះឆ្នោត តារាងកត់ត្រាសំឡេងឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតទៅ គ.ជ.ប សម្រាប់ផ្សាយជាលទ្ធផលបឋមនៃការបោះឆ្នោត ១៩៨
- ការបញ្ជូនស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទៅទីស្នាក់ការ គយ.សប ១៩៩
- ការរាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គយ.សប ឬនៅទីតាំងសុវត្ថិភាពណាមួយក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ.....២០៣
- ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតទៅ គយ.សប ២០៧
- ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងភាពមិនប្រក្រតីនៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោតទៅ គយ.សប ២១២
- កិច្ចប្រតិបត្តិការរបស់ គយ.សប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ២១៤

ជំពូកទី១១ លទ្ធផលបណ្តោះអាសន្ន លទ្ធផលផ្លូវការ និងការជំទាស់ ចំពោះលទ្ធផលនៃការបោះឆ្នោត ២៣១

- ការសម្របសម្រួលសកម្មភាពរបស់ និងបញ្ជូនទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត.....២៣១
- ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នៃ គធ.ខប ២៣១

- ការប្រគល់ និងការទទួលកញ្ចប់ “គ ពិសេស” ស្បោង “គ” ស្បោងដាក់បញ្ជីបោះឆ្នោតនៃ
ឃុំ សង្កាត់ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតនៅ លគធ.ខប.....២៣៧
- ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់នៅ គធ.ខប ទាក់ទងនឹងលទ្ធផល
បណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយ ឬ
ច្រើនក្នុងឃុំ សង្កាត់..... ២៤០
- កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត
នៅឃុំ សង្កាត់.....២៤៣
- ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលគ្មាន
ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប និងនៅ គធ.ខប..... ២៤៥
- ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមាន
ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប មានការបើក
កញ្ចប់សុវត្ថិភាព“ក” ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅ
គឃ.សប និងដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដាក់នៅ គធ.ខប ២៤៩
  - ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់..... ២៥៤
- ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមាន
សំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន
ហើយមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ២៥៩
- ការកំណត់ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
ក្នុងឃុំ សង្កាត់ និងការស្រង់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើស កបយ.ស..... ២៦១
- ការពិនិត្យ និងចុះហត្ថលេខាលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើស
កបយ.ស ២៦៥
- ការវេចខ្ចប់ និងបញ្ជូនលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើស កបយ.ស និង
រាល់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប.....២៦៧
- ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ដែល
បដិសេធលើពាក្យបណ្តឹងទៅ គ.ជ.ប ២៧៣
- ការបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ និង
ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណសម្បត្តិបម្រើការត្រួតពិនិត្យ
និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបយ.ស ២៧៥

- ការប្រគល់ និងការទទួលស្បោង "ឃ" ស្បោងដាក់បញ្ជីបោះឆ្នោត និងកញ្ចប់ "ឃ ពិសេស" ដាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើស កបឃ.ស និងសម្ភារ ឯកសារ បោះឆ្នោតពាក់ព័ន្ធនៅទីស្តីការ គ.ជ.ប ២៨២
- កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ក្នុងការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស ២៨៦
- ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ណាមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែល គធ.ខប បានសម្រេចព្យួរ លទ្ធផលបណ្តោះអាសន្ន ២៨៩
- ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលគ្មាន ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ២៩៥
- ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមាន ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ហើយដែលមានកញ្ចប់សុវត្ថិភាព "ក" មួយ ឬច្រើនត្រូវបានបើកត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ៣០១
- ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានលម្អៀង សំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ហើយមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ឬ/និង គ.ជ.ប ៣០៧
- ការរៀបចំ និងការផ្សព្វផ្សាយសេចក្តីប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើស កបឃ.ស ៣០៩
- ការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបានអនុវត្តសិទ្ធិបោះឆ្នោត ៣១០

ជំពូកទី១២ ការបិទការិយាល័យបោះឆ្នោតក្នុងគ្រាមានអាសន្ន និងការបោះឆ្នោតសាជាថ្មី ៣១១

- ការបិទការិយាល័យបោះឆ្នោតក្នុងគ្រាមានអាសន្ន ៣១១
- ការបោះឆ្នោតសាជាថ្មីក្នុងករណីកាលៈទេសៈមានអាសន្ន ៣១៤
- ការបោះឆ្នោតសាជាថ្មីក្នុងករណីបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ៣១៤

ជំពូកទី១៣ ការបោះឆ្នោតឡើងវិញ ៣១៧

ជំពូកទី១៤ ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ចំពោះគ្រប់អំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.ទ.ច.ប ពាក់ព័ន្ធនឹងការបោះឆ្នោត និងសមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការដោះស្រាយពាក្យបណ្តឹង ព្រមទាំង បែបបទ និងនីតិវិធីនៃការអនុវត្តទណ្ឌកម្មរបស់ គ.ជ.ប ៣២១

ផ្នែកទី១ ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.ទ.ច.ប ពាក់ព័ន្ធនឹងការបោះឆ្នោត ៣២១

- ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ៣២១
  - ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គយ.សប ៣២២
    ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គយ.សប ៣២២
    ការដោះស្រាយពាក្យបណ្តឹងនៅ គយ.សប ៣២៣
  - ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ៣២៦
    ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប ៣២៦
    ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ៣២៧
  - ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ៣៣០
    ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប ៣៣០
    ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ៣៣២
- ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត ៣៣៤

ផ្នែកទី២ សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការដោះស្រាយពាក្យបណ្តឹង ៣៣៥

- សមត្ថកិច្ចដោះស្រាយពាក្យបណ្តឹងក្នុងការបោះឆ្នោត ៣៣៥
- សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ៣៣៥
- ការប្តឹងតវ៉ា ឬការប្តឹងជំទាស់ ៣៣៧
- ការដកពាក្យបណ្តឹង ៣៣៩
- ការរួមបញ្ចូលរឿងក្តី ៣៣៩
- សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីវិវាទ ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ៣៤០
- សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ៣៤១
- នីតិវិធីប្រជុំផ្សះផ្សា នីតិវិធីប្រជុំសម្រេច ឬនីតិវិធីសវនាការ ៣៤២
  - ប្រភេទសវនាការ ៣៤២

- ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ ៣៤៣
- ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ៣៤៣
- ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ៣៤៥
- ពេលវេលាដោះស្រាយពាក្យបណ្តឹង ៣៤៦
- ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា បើកអង្គប្រជុំសម្រេច ឬបើកសវនាការ ៣៤៦
  ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេចនៅ គឃ.សប ៣៤៦
  ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការនៅ គធ.ឧប ៣៤៦
  ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប ៣៤៧
- ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ ៣៤៧
- ការប្រកាសសេចក្តីសម្រេច ៣៤៨
- ការបំពេញ និងប្រើប្រាស់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ៣៤៨
- ការបញ្ជូនសម្រង់សេចក្តីសម្រេច (ទ.១២០៣) ៣៤៩
- ទម្រង់បែបបទផ្សេងៗទៀតសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ ៣៥០
- ការបញ្ជូនសំណុំរឿង ៣៥១

ផ្នែកទី៣ បែបបទ និងនីតិវិធីនៃការអនុវត្តទណ្ឌកម្មគ្រប់អំពើល្មើសលើនោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.ទ.ច.ប ៣៥១

- ប្រភេទនៃទណ្ឌកម្មចំពោះគ្រប់អំពើល្មើសច្បាប់បោះឆ្នោត ៣៥១
- សមត្ថកិច្ច និងនីតិវិធីនៃការអនុវត្តទណ្ឌកម្មចំពោះគ្រប់អំពើល្មើសច្បាប់បោះឆ្នោត ៣៥២
  - ការអនុវត្តទណ្ឌកម្មរដ្ឋបាល ៣៥២
  - ការអនុវត្តទណ្ឌកម្មផាកពិន័យជាប្រាក់ ៣៥៣
  - ការអនុវត្តទណ្ឌកម្មលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពបេក្ខជន ឬលុបបេក្ខភាពគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ៣៥៣
  - ការបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាចំពោះជនបរទេស ៣៥៣
- ការទទួលបានវិញនូវសិទ្ធិពេញលេញដោយពេញច្បាប់ ៣៥៤

ឧបសម្ព័ន្ធ

១- ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត ៣៥៨
២- ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត ៣៧៣

៣- ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត ៣៩០
៤- ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងដំណើរការបោះឆ្នោត ៤០១
៥- ក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារ
សន្តិសុខបោះឆ្នោតក្នុងដំណើរការបោះឆ្នោត ៤១០
៦- សម្ភារ ឯកសារបោះឆ្នោតដែលត្រូវប្រគល់ជូន គជ.ខប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការ
បោះឆ្នោតទាំងមូល ៤២២
៧- សម្ភារ ឯកសារបោះឆ្នោតដែលត្រូវប្រគល់ជូន គឃ.សប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការ
បោះឆ្នោតទាំងមូល ៤២៤
៨- សម្ភារ ឯកសារបោះឆ្នោតដែលត្រូវប្រគល់ជូន គ.ក.ប/គ.ក.រ សម្រាប់ប្រើប្រាស់
ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល ៤២៦
៩- រូបមន្តរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់កម្រិតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ
រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ៤២៨

អក្សរកាត់

១-	គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត	គ.ជ.ប
២-	គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ	គ.ស.អ
៣-	គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត	គធ.ខប
៤-	លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត	លគធ.ខប
៥-	លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត	លធ.ខប
៦-	ក្រុមប្រឹក្សាឃុំ សង្កាត់	កបឃ.ស
៧-	គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត	គឃ.សប
៨-	គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត	គ.ក.ប/គ.ក.រ
៩-	ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត	ច.គ.ជ.ប
១០-	ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ	ច.គ.ឃ.ស
១១-	ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ	ច.ប.ឃ.ស
១២-	ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ	ច.ប.ត.រ
១៣-	ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត	ច.វ.ច.ប
១៤-	បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់	ប.ន.ឃ.ស
១៥-	អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសុពលភាព	អ.ខ
១៦-	ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត	ឯ.អ
១៧-	ទម្រង់បែបបទលេខ	ទ.

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ១.១.-

អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ តទៅហៅថា (ច.គ.ជ.ប) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ និងបានធ្វើវិសោធនកម្មបន្តបន្ទាប់រហូតដល់វិសោធនកម្មចុងក្រោយ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ តទៅហៅថា (ច.ប.ឃ.ស) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៩២៦/០១៥ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៦ តទៅហៅថា (ច.គ.ឃ.ស) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ និងបានធ្វើវិសោធនកម្មបន្តបន្ទាប់រហូតដល់វិសោធនកម្មចុងក្រោយ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ តទៅហៅថា (ច.ប.ត.រ) និងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ តទៅហៅថា (ច.វ.ច.ប) គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានសិទ្ធិអំណាច និងការកិច្ចរៀបចំបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ប.ន.ឃ.ស) ដែលកំណត់អំពីការរៀបចំ ការចាត់ចែង ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស)។

ប្រការ១.២.-

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនតាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ស្របតាមនីតិវិធីដូចមានចែងក្នុង ច.ប.ឃ.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ឃ.ស នេះ។

ប្រការ១.៣.-

ការបោះឆ្នោតជ្រើសរើស កបឃ.ស ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងរៀងរាល់ ៥ (ប្រាំ) ឆ្នាំម្តង។



១.៣.១ ការបោះឆ្នោតជ្រើសរើស កបឃ.ស ទាំងអស់ ត្រូវធ្វើនៅថ្ងៃអាទិត្យ តែមួយថ្ងៃ។

១.៣.២ កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើស កបឃ.ស ត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី ក្នុងរយៈពេល ៩ (ប្រាំបួន) ខែយ៉ាងតិចមុនថ្ងៃបោះឆ្នោត តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

១.៣.៣ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទនៃការបោះឆ្នោតខាងលើនេះ នៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស។

ប្រការ១.៤.-

កបឃ.ស មានអាណត្តិ ៥ (ប្រាំ) ឆ្នាំ ហើយត្រូវកាន់កាប់មុខតំណែងរបស់ខ្លួនរហូតទាល់តែមាន កបឃ.ស ថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស។

ប្រការ១.៥.-

ក្នុងពេលដំណើរការរៀបចំការបោះឆ្នោត ប្រសិនបើមានករណីប្រធានសក្តិកើតឡើងក្នុងឃុំ សង្កាត់ណាមួយ គ.ជ.ប ត្រូវរាយការណ៍ភ្លាមជូននាយករដ្ឋមន្ត្រីពីឃុំ សង្កាត់ ដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតជ្រើសរើស កបឃ.ស បាននោះ។

១.៥.១ ករណីប្រធានសក្តិត្រូវបានកំណត់ក្នុងចំណោមករណីណាមួយដូចមានចែងក្នុងចំណុច ១២.១.១ នៃ ប.ន.ឃ.ស នេះ។

១.៥.២ ការបោះឆ្នោតជ្រើសរើស កបឃ.ស នៅឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតបានដោយករណីប្រធានសក្តិដូចមានចែងក្នុងប្រការ១.៥ ខាងលើនេះ ត្រូវដំណើរការនៅពេលស្ថានការណ៍នៅឃុំ សង្កាត់នោះមានប្រក្រតីភាពឡើងវិញ តាមកាលបរិច្ឆេទកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ប្រការ១.៦.-

កបឃ.ស ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ដោយយកឃុំ សង្កាត់ជាមណ្ឌលបោះឆ្នោត និងដោយបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត។

១.៦.១ កបឃ.ស ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រដោយអ្នកបោះឆ្នោតដែល៖

១.៦.១.១ បានចុះឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់នោះ និងមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសុពលភាព (អ.ខ) លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់តាតិ្រមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)។

១.៦.១.២ មានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជាសម្ងាត់។

១.៦.១.៣ មានសិទ្ធិបោះឆ្នោតជ្រើសរើស កបឃ.ស តែមួយប៉ុណ្ណោះ។

ប្រការ១.៧.-

អនុលោមតាម ច.គ.ឃ.ស និង ច.ប.ឃ.ស ចំនួនសមាជិក កបឃ.ស នីមួយៗត្រូវបានកំណត់ដោយអនុក្រឹត្យក្នុងរយៈពេលយ៉ាងតិច ៩ (ប្រាំបួន) ខែមុនថ្ងៃបោះឆ្នោត។

១.៧.១ កបឃ.ស មានសមាជិកចំនួនពី ៥ (ប្រាំ) រូប ទៅ ១១ (ដប់មួយ) រូប ផ្អែកតាមប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់ខ្លួន។

១.៧.២ ចំនួនសមាជិកក្រុមប្រឹក្សាជាក់ស្តែងក្នុងឃុំ សង្កាត់នីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិច ៩ (ប្រាំបួន) ខែមុនថ្ងៃបោះឆ្នោតជ្រើសរើស កបឃ.ស។

ប្រការ១.៨.-

ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើស កបឃ.ស ប្រសិនបើប្រទេសជាតិជួបគ្រោះអាសន្ន ឬស្ថានភាពនៃការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ វិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការចាំបាច់នានាត្រូវអនុវត្តដោយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដោយស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ជំពូកទី២
ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត

ប្រការ២.១.-

ការរៀបចំ ការចាត់ចែង ការគ្រប់គ្រងបញ្ជីបោះឆ្នោត និងការគ្រប់គ្រងការបោះឆ្នោតជ្រើសរើស កបឃ.ស គឺជាសមត្ថកិច្ចរបស់ គ.ជ.ប។

គ.ជ.ប ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួនដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ សមាសភាព គ.ជ.ប និងសមាសភាពនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវមានជំហរអព្យាក្រឹត ឥតលម្អៀងក្នុងការអនុវត្តការងារបោះឆ្នោត។

ប្រការ២.២.-

គ.ជ.ប ត្រូវដាក់ចេញនូវបទបញ្ជា និងនីតិវិធីសម្រាប់រៀបចំ និងចាត់ចែងការបោះឆ្នោតជ្រើសរើស កបឃ.ស ផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុង ច.គ.ជ.ប ច.គ.ឃ.ស ច.ប.ឃ.ស ច.ប.ត.រ ច.វ.ច.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

អំណាច មុខងារ និងភារកិច្ចរបស់ គ.ជ.ប

ប្រការ២.៣.-

គ.ជ.ប មានអំណាច មុខងារ និងភារកិច្ចដូចខាងក្រោម៖

- ២.៣.១ រៀបចំ និងផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត។
- ២.៣.២ ពិនិត្យរៀបចំបញ្ជីបោះឆ្នោតជារៀងរាល់ឆ្នាំ។
- ២.៣.៣ ការពារសុវត្ថិភាព និងរក្សាបញ្ជីបោះឆ្នោត។
- ២.៣.៤ សម្រេចលើការចុះបញ្ជីបេក្ខជន។
- ២.៣.៥ ពិនិត្យតាមដានយុទ្ធនាការឃោសនាបោះឆ្នោត។
- ២.៣.៦ គ្រប់គ្រងនីតិវិធីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត។
- ២.៣.៧ គ្រប់គ្រងនីតិវិធីរាប់សន្លឹកឆ្នោត និងចាត់ចែងការរាប់សន្លឹកឆ្នោត។
- ២.៣.៨ ប្រកាសលទ្ធផលនៃការបោះឆ្នោត។
- ២.៣.៩ ការពារសុវត្ថិភាពក្នុងដំណើរការបោះឆ្នោត ដំណើរការរាប់សន្លឹកឆ្នោត និងការពារសុវត្ថិភាពសម្ភារ ឧបករណ៍ គ្រឿងសង្ហារិមសម្រាប់ដំណើរការបោះឆ្នោតទាំងមូល។

២.៣.១០ បណ្តុះបណ្តាលមន្ត្រីបោះឆ្នោត និងណែនាំដល់បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអំពីនីតិវិធីផ្សេងៗសម្រាប់ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងបទប្បញ្ញត្តិទាំងឡាយនៃ ច.ប.ឃ.ស។

២.៣.១១ ធានាឱ្យសាធារណជនទូទៅមានការយល់ដឹងអំពីគោលបំណងនៃការបោះឆ្នោត។

២.៣.១២ ធានាឱ្យជនគ្រប់រូបមានសិទ្ធិចូលរួមប្រកបដោយសុវត្ថិភាព និងគ្មានការភ័យខ្លាច ឬការបំភិតបំភ័យក្នុងដំណើរការបោះឆ្នោត។

២.៣.១៣ រៀបចំនីតិវិធីនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតប្រកបដោយតម្លាភាព និងដោយមានការចូលរួមពីអ្នកសង្កេតការណ៍បោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយ។

២.៣.១៤ ធានាឱ្យមានទំនាក់ទំនងទៀងទាត់រវាង គ.ជ.ប ជាមួយបេក្ខជន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត។

២.៣.១៥ អនុវត្តតាមការកំណត់ និងនីតិវិធីផ្សេងៗដែលទាក់ទងដល់ការត្រួតពិនិត្យ ការគ្រប់គ្រងហិរញ្ញវត្ថុ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២.៣.១៦ សម្រេចលើពាក្យបណ្តឹងតវ៉ាទាក់ទងការបោះឆ្នោតជ្រើសរើស កបឃ.ស លើកលែងតែពាក្យបណ្តឹងតវ៉ាទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

២.៣.១៧ ធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា និងព្រឹទ្ធសភា ស្តីពីការគ្រប់គ្រង ការប្រព្រឹត្តទៅ និងលទ្ធផលនៃការបោះឆ្នោតក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

២.៣.១៨ រៀបចំគណៈកម្មការដើម្បីបំផ្លាញសន្លឹកឆ្នោតដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើស កបឃ.ស តាមអាណត្តិនីមួយៗ បន្ទាប់ពីបានរក្សាទុកប្រកបដោយសុវត្ថិភាពនូវសន្លឹកឆ្នោតទាំងនោះរយៈពេល ៣ (បី) ឆ្នាំចាប់ពីថ្ងៃបោះឆ្នោត។ ដំណើរការនៃការបំផ្លាញសន្លឹកឆ្នោតខាងលើនេះ ត្រូវធ្វើឡើងប្រកបដោយលក្ខណៈបើកចំហ និងមានការចូលរួមពីគណបក្សនយោបាយដែលពាក់ព័ន្ធ។

២.៣.១៩ អនុវត្តការងារដទៃទៀតតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបការងាររបស់ គ.ជ.ប

ប្រការ២.៤.-

សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបការងាររបស់ គ.ជ.ប ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុង ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត

ប្រការ២.៥.-

អនុលោមតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គ.ជ.ប អាចចេញសេចក្តីសម្រេចប្រគល់សិទ្ធិរបស់ខ្លួនដល់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ) និងមន្ត្រី ឬភ្នាក់ងារបម្រើការងារបោះឆ្នោត ដើម្បីអនុវត្តការងារបោះឆ្នោត។

សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបការងាររបស់ គធ.ខប

ប្រការ២.៦.-

គធ.ខប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្ត ដែលត្រូវតែងតាំងឡើងដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ ការរៀបចំ ការចាត់ចែង និងការត្រួតពិនិត្យដំណើរការបោះឆ្នោត។ សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបការងាររបស់ គធ.ខប ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុង ច.គ.ជ.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និង ប.ន.ឃ.ស នេះ។

បែបបទ នីតិវិធី និងលក្ខណៈនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ.ខប

ប្រការ២.៧.-

បែបបទ នីតិវិធី និងលក្ខណៈនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ.ខប ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុង ច.គ.ជ.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប.ន.ឃ.ស នេះ និងសេចក្តីសម្រេចរបស់ គ.ជ.ប។

២.៧.១ សមាសភាព គធ.ខប ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងរាជធានី ខេត្តដែលមានសិទ្ធិបោះឆ្នោត លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ។

២.៧.២ សមាសភាព គធ.ខប ត្រូវបានជ្រើសរើសដោយអនុលោមតាមបែបបទ និងនីតិវិធីនៃការជ្រើសរើស និងគណៈកម្មការជ្រើសរើសដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។



២.៧.៣ សមាសភាព គធ.ខប ត្រូវយល់ព្រមលើលក្ខខណ្ឌការងារ និងប្រាក់កម្រៃដែលកំណត់ដោយ គ.ជ.ប។

សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបការងាររបស់ គឃ.សប

ប្រការ២.៨.-

សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបការងាររបស់ គឃ.សប ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុង ច.គ.ជ.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និង ប.ន.ឃ.ស នេះ។

បែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គឃ.សប

ប្រការ២.៩.-

បែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គឃ.សប ត្រូវអនុវត្តតាមច.គ.ជ.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប.ន.ឃ.ស នេះ និងសេចក្តីសម្រេចរបស់ គ.ជ.ប។

២.៩.១ សមាសភាព គឃ.សប ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មានន័តិសម្បទាឡើងវិញ។

២.៩.២ សមាសភាព គឃ.សប ត្រូវជ្រើសរើសដោយអនុលោមតាមបែបបទ និងនីតិវិធីនៃការជ្រើសរើស និងគណៈកម្មការជ្រើសរើសដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

២.៩.៣ សមាសភាព គឃ.សប ត្រូវយល់ព្រមលើលក្ខខណ្ឌការងារ និងប្រាក់កម្រៃដែលកំណត់ដោយ គ.ជ.ប។

សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ

ប្រការ២.១០.-

សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ ត្រូវអនុវត្តតាម ច.គ.ជ.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និង ប.ន.ឃ.ស នេះ។

២.១០.១ គ.ក.ប/គ.ក.រ ត្រូវមានសមាសភាព ៦ (ប្រាំមួយ) រូប ដែលរួមមានប្រធាន ១ (មួយ) រូប អនុប្រធាន ១ (មួយ) រូប លេខាធិការ ១ (មួយ) រូប និងសមាជិកចំនួន ៣ (បី) រូប។ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់សមាសភាព គ.ក.ប/គ.ក.រ ត្រូវបានកំណត់ដូចខាងក្រោម៖

២.១០.១.១ ប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចទទួលខុសត្រូវរួមក្នុងការគ្រប់គ្រង និងការចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

២.១០.១.២ អនុប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចជាជំនួយការរបស់ប្រធាន គ.ក.ប/គ.ក.រ ទទួលខុសត្រូវក្នុងការផ្តល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោត នៅពេលបោះឆ្នោត និងក្នុងការកត់ត្រាសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត។

២.១០.១.៣ លេខាធិការមានភារកិច្ចទទួលខុសត្រូវក្នុងការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត និងការបំពេញកំណត់ហេតុ និងរាល់ទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

២.១០.១.៤ សមាជិកទី១ មានភារកិច្ចទទួលខុសត្រូវពិនិត្យការស៊កសន្លឹកឆ្នោតទៅក្នុងហិបឆ្នោត និងជ្រលក់ម្រាមដៃអ្នកបោះឆ្នោតចូលក្នុងទឹកខ្មៅលុបមិនជ្រះ និងទទួលគូសសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត។

២.១០.១.៥ សមាជិកទី២ មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

- ជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត
- ចាត់ចែងសណ្តាប់ធ្នាប់ជូនអ្នកបោះឆ្នោត
- ចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើដើម្បីធ្វើមោឃភាព
- បិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)
- បញ្ជូនស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២)និងស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ទៅ គឃ.សប បន្ទាប់ពីបញ្ចប់ការធ្វើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

២.១០.១.៦ សមាជិកទី៣ មានភារកិច្ចទទួលខុសត្រូវការងារសណ្តាប់ធ្នាប់ របៀបរៀបរយ និងថែរក្សាសម្ភារ ឯកសារបោះឆ្នោតនៅពេលបោះឆ្នោត និងនៅពេលរាប់សន្លឹកឆ្នោត។

២.១០.២ គ.ក.ប/គ.ក.រ ត្រូវអនុវត្តភារកិច្ច និងការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងការចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតពាក់ព័ន្ធដូចមានចែងក្នុងប្រការ៩.៣រហូតដល់ប្រការ៩.៥នៃ ប.ន.ឃ.សនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

២.១០.៣ គ.ក.ប/គ.ក.រ ត្រូវទទួលខុសត្រូវចំពោះមុខ គឃ.សប។

២.១០.៤ គ.ក.ប/គ.ក.រ ទទួលសេចក្តីណែនាំពី គ.ជ.ប តាមរយៈ គធ.ខប និង គឃ.សប។

បែបបទ នីតិវិធី និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស និងការស្នើសុំតែងតាំងសមាសភាព គ.ក.ប/គ.ក.រ

ប្រការ២.១១.

បែបបទ នីតិវិធី និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គ.ក.ប/គ.ក.រ ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុង ច.គ.ជ.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប.ន.ឃ.ស នេះ និងសេចក្តីសម្រេចរបស់ គ.ជ.ប។

២.១១.១ សមាសភាព គ.ក.ប/គ.ក.រ ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និង មន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ។

២.១១.២ អ្នកដែលត្រូវបានជ្រើសរើសជាសមាសភាព គ.ក.ប/គ.ក.រ គឺជាបេក្ខជនដាក់ពាក្យសុំចូលបម្រើការងារណាដែលបានទទួលជោគជ័យក្នុងការជ្រើសរើស បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង និងបានចុះហត្ថលេខាលើកិច្ចសន្យាបម្រើការងារក្នុងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១០០២) នៅក្រោយពេលវគ្គបណ្តុះបណ្តាលត្រូវបានបញ្ចប់។ ក្នុងការជ្រើសរើសនេះត្រូវផ្តល់អាទិភាពចំពោះបេក្ខជនដែលធ្លាប់មានបទពិសោធក្នុងការងារបោះឆ្នោតពីមុនមក ឬបទពិសោធការងារពាក់ព័ន្ធនឹងមុខតំណែង។

២.១១.២.១ បេក្ខជនណាដែលត្រូវបានជ្រើសរើសហើយ ប៉ុន្តែមិនបានចូលរួមវគ្គបណ្តុះបណ្តាលត្រូវដាក់ជំនួសជាបន្ទាន់ដោយបេក្ខជនបម្រុង។

២.១១.២.២ ប្រសិនបើគ្មានបេក្ខជនបម្រុងសម្រាប់ជំនួស គឃ.សប ត្រូវចាត់ចែងស្នើសុំ គ.ជ.ប តាមរយៈ គធ.ខប ជ្រើសរើសអ្នកជំនួសជាបន្ទាន់។

២.១១.៣ ដើម្បីទទួលបានការជ្រើសរើស និងបានបម្រើការងារក្នុងលក្ខណៈជាប់កិច្ចសន្យាជាសមាសភាព គ.ក.ប/គ.ក.រ បេក្ខជនដាក់ពាក្យសុំចូលបម្រើការងារត្រូវ៖

២.១១.៣.១ ឆ្លងកាត់ដោយជោគជ័យនូវការជ្រើសរើសដែលគ្រប់គ្រង និងពិនិត្យដោយអនុគណៈកម្មការសម្ភាសន៍ជ្រើសរើស។

២.១១.៣.២ គោរពរដ្ឋធម្មនុញ្ញ និងអនុវត្តតាម ច.គ.ជ.ប ច.ប.ឃ.ស ច.ប.ត.រ ច.វ.ច.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និង ប.ន.ឃ.ស នេះ។

២.១១.៣.៣ ប្រកាន់ជំហរអព្យាក្រឹត និងមិនលម្អៀង។

២.១១.៣.៤ យល់ព្រមលើលក្ខខណ្ឌការងារ និងប្រាក់កម្រៃ។

២.១១.៣.៥ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង។

២.១១.៣.៦ ចុះហត្ថលេខាយល់ព្រមលើកិច្ចសន្យាបម្រើការងារក្នុងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១០០២)។

២.១១.៤ កិច្ចសន្យាបម្រើការងារក្នុងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១០០២) ត្រូវបញ្ជាក់ព័ត៌មានអ្នកដែលត្រូវតែងតាំងដូចខាងក្រោម៖

២.១១.៤.១ លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត។

២.១១.៤.២ ឈ្មោះ អាសយដ្ឋាន និងកស្តុតាងបញ្ជាក់ពីភាពមានសិទ្ធិបោះឆ្នោត។

២.១១.៤.៣ មុខតំណែងក្នុង គ.ក.ប/គ.ក.រ។

២.១១.៤.៤ លក្ខខណ្ឌការងារ ភារកិច្ច និងការទទួលខុសត្រូវ។

២.១១.៤.៥ ការសន្យាយល់ព្រមទទួលយកភារកិច្ច លក្ខខណ្ឌការងារ និងប្រាក់កម្រៃ។

២.១១.៤.៦ ការសន្យាថានឹងអនុវត្តភារកិច្ចរបស់ខ្លួនដោយអព្យាក្រឹត និងមិនលម្អៀង។

២.១១.៤.៧ ការសន្យាថានឹងអនុវត្តតាម ច.គ.ជ.ប ច.ប.ឃ.ស ច.វ.ច.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និង ប.ន.ឃ.ស ព្រមទាំងរាល់សេចក្តីណែនាំរបស់ គ.ជ.ប។

២.១១.៤.៨ ការសន្យាថានឹងគោរពតាមគោលការណ៍នៃការបោះឆ្នោត។

២.១១.៤.៩ ហត្ថលេខារបស់សាមីខ្លួន និងហត្ថលេខារបស់ប្រធាន គឃ.សប។

២.១១.៥ សមាសភាព គ.ក.ប/គ.ក.រ ត្រូវតែជ្រើសរើសដោយផ្អែកតាមបែបបទ និងនីតិវិធីនៃការជ្រើសរើស និងអនុគណៈកម្មការសម្ភាសន៍ជ្រើសរើសដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

២.១១.៦ គធ.ខប ត្រូវប្រគល់បញ្ជីឈ្មោះអ្នកដែលត្រូវតែងតាំងជាសមាសភាព គ.ក.ប/គ.ក.រ ទាំងអស់តាមឃុំ សង្កាត់ចំណុះរាជធានី ខេត្តរបស់ខ្លួន ដោយភ្ជាប់ជាមួយនូវកិច្ចសន្យាបម្រើការងារក្នុងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១០០២) ដែលបានបំពេញ និងចុះហត្ថលេខារួចក្នុងម្នាក់ ១ (មួយ) ច្បាប់ដើម្បីស្នើសុំសេចក្តីសម្រេចតែងតាំងពី គ.ជ.ប។

២.១១.៧ នៅពេលទទួលបានសំណើសុំតែងតាំងដូចមានចែងក្នុងចំណុច ២.១១.៦ ខាងលើនេះ គ.ជ.ប ត្រូវពិនិត្យ និងចេញសេចក្តីសម្រេចតែងតាំង គ.ក.ប/គ.ក.រ ហើយត្រូវរក្សាទុកឯកសារនៃបញ្ជីឈ្មោះសមាសភាព គ.ក.ប/គ.ក.រ ទាំងនោះជាផ្លូវការ។

២.១១.៨ បន្ទាប់ពីបានទទួលសេចក្តីសម្រេចរបស់ គ.ជ.ប គធ.ខប ត្រូវបញ្ជូនបន្ត និងណែនាំ គឃ.សប ឱ្យបំពេញបណ្ណសម្គាល់ខ្លួន និងផ្តល់ជូនសមាសភាព គ.ក.ប/គ.ក.រ សម្រាប់ពាក់នៅពេលបំពេញភារកិច្ចក្នុងអាណត្តិការងាររបស់ខ្លួន។

២.១១.៩ សមាសភាព គ.ក.ប/គ.ក.រ ត្រូវស្ថិតនៅក្នុងមុខតំណែងរហូតដល់ថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅក្នុងការិយាល័យរបស់ខ្លួន និងក្រោយពីបានប្រគល់ស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតចប់សព្វគ្រប់ជូន គឃ.សប។ ផ្អែកតាមមុខតំណែងរបស់ខ្លួន សមាជិក គ.ក.ប/គ.ក.រ ម្នាក់ៗទទួលបានប្រាក់កម្រៃជាប្រាក់រៀលសម្រាប់ការងាររបស់ខ្លួន ដោយគិតបញ្ចូលទាំងថ្លៃម្ហូបអាហារ ទាំងថ្លៃធ្វើដំណើរ។

២.១១.៩.១ ចំនួនទឹកប្រាក់ដែលត្រូវបានផ្តល់ជាកម្រៃសម្រាប់ការបំពេញការងារនៃសមាសភាព គ.ក.ប/គ.ក.រ ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប។

២.១១.៩.២ ក្នុងករណីសមាសភាព គ.ក.ប/គ.ក.រ ណាដែលតម្រូវឱ្យស្ថិតក្នុងមុខតំណែងយូរជាងការកំណត់ដូចមានចែងក្នុងចំណុច ២.១១.៩.១ ខាងលើនេះ មន្ត្រីនោះត្រូវទទួលបានប្រាក់កម្រៃបន្ថែមតាមសេចក្តីសម្រេចរបស់ គ.ជ.ប។

២.១១.១០ គឃ.សប ត្រូវអនុវត្តការវាយតម្លៃសមាសភាព គ.ក.ប/គ.ក.រ ទាំងអស់ចំណុះឃុំ សង្កាត់ ក្នុងរយៈពេល ២ (ពីរ) សប្តាហ៍យ៉ាងយូរបន្ទាប់ពីថ្ងៃបោះឆ្នោត។

២.១១.១០.១ នៅមុនបញ្ចប់ភារកិច្ចរបស់ខ្លួន គឃ.សប ត្រូវផ្តល់កំណត់ហេតុវាយតម្លៃសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១១៣) ដែលបានបំពេញរួចហើយទៅ គធ.ខប។

២.១១.១០.២ គធ.ខប ត្រូវផ្ញើកំណត់ហេតុវាយតម្លៃសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១១៣) ទាំងអស់ចំណុះរាជធានី ខេត្ត ក្នុងម្នាក់ ១ (មួយ) ច្បាប់ជូន គ.ជ.ប។

២.១១.១០.៣ គ.ជ.ប ត្រូវកត់ត្រាបន្ថែមទិន្នន័យនៃកំណត់ហេតុវាយតម្លៃសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១១៣) ទាំងអស់ទៅក្នុងបញ្ជីឈ្មោះនៃសមាសភាព គ.ក.ប/គ.ក.រ ដែលត្រូវរក្សាទុក។

បែបបទ និងនីតិវិធីនៃការជ្រើសរើសសមាសភាព គធ.ខប គឃ.សប និង គ.ក.ប/គ.ក.រ

ប្រការ២.១២.-

បែបបទ និងនីតិវិធីនៃការជ្រើសរើសសមាសភាព គធ.ខប គឃ.សប និង គ.ក.ប/គ.ក.រ ត្រូវឈរលើគោលការណ៍ស្មើភាព ដោយត្រឹមត្រូវ តម្លាភាព អព្យាក្រឹត សមត្ថភាព មិនប្រកាន់និន្នាការនយោបាយ និងការងារពាក់ព័ន្ធដែលមានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។ គ.ជ.ប លើកទឹកចិត្ត និងផ្តល់អាទិភាពដល់បេក្ខនារី ឬបេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងការងារពាក់ព័ន្ធ។

ប្រាក់កម្រៃរបស់មន្ត្រីបោះឆ្នោត

ប្រការ២.១៣.-

ប្រាក់កម្រៃរបស់សមាជិក និងមន្ត្រី បុគ្គលិកនៃ គ.ជ.ប និងសមាជិក និងមន្ត្រី បុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវបានកំណត់ដោយសេចក្តីសម្រេចរបស់គ.ជ.ប។

២.១៣.១ ប្រាក់កម្រៃត្រូវបើកជារៀងរាល់ខែចំពោះអ្នករាជការ គ.ជ.ប និងមន្ត្រី បុគ្គលិកជាប់កិច្ចសន្យា ហើយត្រូវបើកផ្តាច់ចំពោះមន្ត្រី បុគ្គលិកម៉ៅការក្រោយការបញ្ចប់ការងារ។

២.១៣.២ ប្រាក់កម្រៃត្រូវបើកជូនជាប្រាក់រៀល បន្ទាប់ពី គ.ជ.ប ទទួលបានប្រាក់ពីអគ្គនាយកដ្ឋានរតនាគារជាតិ។

អាណត្តិរបស់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់

ប្រការ២.១៤.-

អាណត្តិរបស់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់រួមមាន៖

២.១៤.១ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់មានសមាសភាព គ.ជ.ប ថ្មីចូលកាន់តំណែង។

២.១៤.២ គធ.ខប ត្រូវបំពេញការកិច្ចរបស់ខ្លួនរហូតដល់ថ្ងៃប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើស កបឃ.ស ទាំងអស់ក្នុងរាជធានី ខេត្តរបស់ខ្លួន។ អាណត្តិរបស់ គធ.ខប ដូចមានចែងក្នុងចំណុចនេះអាចកំណត់ផ្សេងពីនេះដោយសេចក្តីសម្រេចរបស់ គ.ជ.ប តាមតម្រូវការជាក់ស្តែង។

២.១៤.៣ គឃ.សប ត្រូវបំពេញការកិច្ចរបស់ខ្លួនរហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន។ អាណត្តិរបស់ គឃ.សប ដូចមានចែងក្នុងចំណុចនេះអាចកំណត់ផ្សេងពីនេះដោយសេចក្តីសម្រេចរបស់ គ.ជ.ប តាមតម្រូវការជាក់ស្តែង។

២.១៤.៤ គ.ក.ប/គ.ក.រ ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់ថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតរបស់ខ្លួន និងក្រោយពីបានប្រគល់ស្បោង "ខ" និងសម្ភារ ឯកសារបោះឆ្នោតចប់សព្វគ្រប់ជូន គយ.សប។

ការតែងតាំងក្នុងរយៈពេលមានកំណត់

ប្រការ២.១៥.-

គ.ជ.ប មានសិទ្ធិតែងតាំង គធ.ខប គយ.សប ឬ គ.ក.ប/គ.ក.រ ក្នុងរយៈពេលមានកំណត់នៅពេលណាមួយ បន្ទាប់ពីការបោះឆ្នោតក្នុងគោលបំណងគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតសាជាថ្មី ឬការបោះឆ្នោតឡើងវិញ (ប្រសិនបើមាន)។

២.១៥.១ ក្នុងការតែងតាំងក្នុងរយៈពេលមានកំណត់នេះ បែបបទ និងនីតិវិធីនៃការជ្រើសរើស រចនាសម្ព័ន្ធ សមាសភាព លក្ខណៈនិច្ឆ័យ សិទ្ធិអំណាច ការទទួលខុសត្រូវ និងប្រាក់កម្រៃ ត្រូវអនុលោមតាម ច.គ.ជ.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប.ន.ឃ.ស នេះ និងតាមការសម្រេចរបស់ គ.ជ.ប។

២.១៥.២ អាណត្តិរបស់ គធ.ខប គយ.សប និង គ.ក.ប/គ.ក.រ ដែលត្រូវបានតែងតាំងក្នុងរយៈពេលមានកំណត់នេះ ត្រូវបញ្ចប់នៅពេលចប់ការកិច្ចតាមការកំណត់របស់ គ.ជ.ប។

គោលការណ៍នៃការប្រើប្រាស់សម្ភារ និងបរិក្ខាររបស់ គ.ជ.ប

ប្រការ២.១៦.-

សម្ភារ និងបរិក្ខាររបស់ គ.ជ.ប ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការងាររៀបចំការបោះឆ្នោត លើកលែងតែមានការសម្រេចផ្សេងពីនេះរបស់ គ.ជ.ប។

២.១៦.១ គ្មានសមាជិក ឬមន្ត្រី បុគ្គលិកនៃ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយអាចប្រើប្រាស់សម្ភារ និងបរិក្ខាររបស់ គ.ជ.ប ក្រៅពីការរៀបចំការបោះឆ្នោតឡើយ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយ គ.ជ.ប។ ត្រូវបានកំណត់ជាសម្ភារ និងបរិក្ខារ មានជាអាទិ៍រថយន្ត ម៉ូតូ សម្ភារការិយាល័យ សម្ភារបោះឆ្នោត និងសម្ភាររាប់សន្លឹកឆ្នោត ឬសម្ភារផ្គត់ផ្គង់ការបោះឆ្នោត ប្រែងឥន្ធនៈ។

២.១៦.២ ប្រសិនបើសមាជិក ឬមន្ត្រី បុគ្គលិកនៃ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយល្មើសនឹងចំណុច ២.១៦.១ ខាងលើនេះ ជននោះនឹងត្រូវដាក់វិន័យ។ វិធានការដាក់វិន័យគឺ គិតចាប់ពីការព្រមាន រហូតដល់ការបណ្តេញចេញពីការងារ។

២.១៦.៣ សមាជិក ឬមន្ត្រី បុគ្គលិកនៃ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយដែលល្មើសក្នុងការប្រើប្រាស់សម្ភារ និងបរិក្ខារទាំងនេះត្រូវទូទាត់សងតម្លៃទៅតាមការកំណត់របស់ គ.ជ.ប។

២.១៦.៤ ប្រសិនបើសមាជិក ឬមន្ត្រី បុគ្គលិកណាម្នាក់នៃ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយធ្វើឱ្យសម្ភារ និងបរិក្ខារបាត់បង់ ឬខូចខាតក្នុងពេលប្រើប្រាស់ខុសច្បាប់ បុគ្គលនោះត្រូវទូទាត់សងតម្លៃនៃសម្ភារ និងបរិក្ខារដែលបានបាត់បង់ ឬខូចខាតនោះ។

២.១៦.៥ គ.ជ.ប ត្រូវចេញផ្សាយបទបញ្ជាជាមូលដ្ឋានសម្រាប់ការប្រើប្រាស់សម្ភារ និងបរិក្ខារទាំងនោះ។

ប្រតិទិនសម្រាប់ការបោះឆ្នោត

ប្រការ២.១៧._

គ.ជ.ប ត្រូវចាត់ចែងរៀបចំ និងផ្សព្វផ្សាយប្រតិទិនសម្រាប់ការបោះឆ្នោតជ្រើសរើស កបយ.ស។

២.១៧.១ បន្ទាប់ពីរាជរដ្ឋាភិបាលប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើស កបយ.ស គ.ជ.ប ត្រូវចាត់ចែងរៀបចំប្រតិទិនសម្រាប់ការបោះឆ្នោត និងផ្សព្វផ្សាយជាបន្ទាន់។

២.១៧.២ ការផ្សព្វផ្សាយប្រតិទិនសម្រាប់ការបោះឆ្នោត ត្រូវធ្វើឡើងឱ្យបានមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសម្រាប់ឆ្នាំដែលមានការរៀបចំការបោះឆ្នោតជ្រើសរើស កបយ.ស។

២.១៧.៣ ប្រតិទិនសម្រាប់ការបោះឆ្នោតត្រូវកំណត់ជាអាទិ៍ដូចខាងក្រោម៖

- ថ្ងៃចាប់ផ្តើមចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន និងថ្ងៃបញ្ចប់
- ថ្ងៃចាប់ផ្តើមចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងថ្ងៃបញ្ចប់ការទទួលពាក្យ
- ថ្ងៃចាប់ផ្តើមចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសម្រាប់សង្កេតមើលតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងថ្ងៃបញ្ចប់
- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត
- ថ្ងៃបោះឆ្នោត និងថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ន និងលទ្ធផលផ្លូវការនៃការបោះឆ្នោត
- ថ្ងៃចាប់ផ្តើមទទួល និងដោះស្រាយពាក្យបណ្តឹងតាមដំណាក់កាលនីមួយៗ។

ការថែរក្សាសន្តិសុខបោះឆ្នោត

ប្រការ២.១៨._

គ.ជ.ប មានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវក្នុងការលើកវិធានការ និងចាត់ចែងការងារដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងដំណើរការបោះឆ្នោត ក្នុងនោះត្រូវណែនាំ គធ.ខប គយ.សប និង គ.ក.ប/គ.ក.រ ឱ្យសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចលើកវិធានការការពារ បង្ការ និងដោះស្រាយជាក់ស្តែង តាមពេលវេលា ទីកន្លែងក្នុងភូមិសាស្ត្រ និងចាត់ចែងឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងធ្វើការផ្សព្វផ្សាយក្នុងករណីចាំបាច់។

ប្រការ២.១៩.-


ក្រសួង ឬស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត តាមសំណើរបស់ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

២.១៩.១ នៅថ្នាក់ជាតិមានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សរសេរជាអក្សរកាត់ថា "គ.ស.អ" ដែលមានលេខាធិការដ្ឋានមួយជាសេនាធិការ និងមានតួនាទី ភារកិច្ច បញ្ជាដឹកនាំកិច្ចការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិគ្រប់នីតិកាល និងអាណត្តិ និងត្រួតពិនិត្យការអនុវត្តរបស់យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់៖

- នៅថ្នាក់ក្រោមជាតិ ឬរាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត និងជាគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដែលមានស្រាប់ត្រូវបានកំណត់ជាស្វ័យប្រវត្តិជាយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ឬថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីគ្រប់គ្រង ដឹកនាំបញ្ជា និងត្រួតពិនិត្យលើការអនុវត្តរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងដែនសមត្ថកិច្ចនៃរាជធានី ខេត្តរៀងៗខ្លួន
- កម្លាំងនគរបាល ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទ ឬ/និងប្រជាការពារដែលមានមូលដ្ឋានឈរជើងក្នុងភូមិសាស្ត្ររាជធានី ខេត្តនីមួយៗ ត្រូវបានស្នើសុំរៀបចំឱ្យបំពេញការកិច្ចជា "ភ្នាក់ងារសន្តិសុខបោះឆ្នោត" សម្រាប់យុទ្ធនាការការពារការបោះឆ្នោតជ្រើសរើស កបឃ.ស ផ្អែកតាមចំនួនក្នុងផែនការដែលបានកំណត់
- ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ពិសេសយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ត្រូវសហការអនុវត្តសកម្មភាពរបស់ខ្លួនផ្អែកតាមគោលការណ៍ច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ឬ/និងសេចក្តីណែនាំរួមរវាង គ.ស.អ និង គ.ជ.ប ព្រមទាំងអនុវត្តតាមផែនការ និងសេចក្តីណែនាំដោយឡែកស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ការបោះឆ្នោត។

២.១៩.២ លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប ដែលត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេចរបស់ គ.ជ.ប ជាជំនួយការផ្នែកការងារសន្តិសុខបោះឆ្នោតឱ្យ គ.ជ.ប មានភារកិច្ចសម្របសម្រួល និងសហការជាមួយលេខាធិការដ្ឋានរបស់ គ.ស.អ ឬ/និង ក្រសួង ស្ថាប័ន និងអង្គភាពជំនាញពាក់ព័ន្ធក្នុងការរៀបចំខ្លឹមសារនៃផែនការ ឬសេចក្តីណែនាំផ្សេងៗស្តីពីការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើស កបយ.ស។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសជាសេនាធិការឱ្យលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប ត្រូវទទួលជួយការងារបច្ចេកទេស និងរដ្ឋបាល។

២.១៩.៣ យន្តការ និងរចនាសម្ព័ន្ធផ្នែកសន្តិសុខបោះឆ្នោតរបស់ គ.ជ.ប និង គ.ស.អ។



២.១៩.៤ គ.ជ.ប ដែលរួមមានលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប គធ.ខប គឃ.សប និង គ.ក.ប/គ.ក.រ ត្រូវសហការតាមឋានានុក្រមនៃយន្តការ និងរចនាសម្ព័ន្ធផ្នែកសន្តិសុខបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលរួមមានលេខាធិការដ្ឋាននៃ គ.ស.អ និងគណៈអភិបាលរាជធានី ខេត្ត និងជាគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុខសុវត្ថិភាពក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើស កបយ.ស តាមគំនូសបង្ហាញដូចមានចែងក្នុងចំណុច ២.១៩.៣ ខាងលើនេះ។

២.១៩.៥ ភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ត្រូវស្ថិតក្នុងឯកសណ្ឋានតាមប្រភេទនៃកងកម្លាំងនីមួយៗឱ្យបានត្រឹមត្រូវ និងត្រូវគោរពអនុវត្តតាមគោលការណ៍នៃ ច.ប.ឃ.ស ច.ប.ត.រ ច.វ.ច.ប ប.ន.ឃ.ស នេះ ផែនការការពារ ក្រមសីលធម៌ ព្រមទាំងសេចក្តីណែនាំផ្សេងៗ។ យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតត្រូវចាត់ចែងភ្នាក់ងារសន្តិសុខបោះឆ្នោតផ្អែកតាមចំនួនដែលបានកំណត់ក្នុងផែនការការពារ ឬ/និងតាមសំណូមពររបស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីការពារមុខសញ្ញា ឬគោលដៅសំខាន់ៗដែលត្រូវការពារជារួម ឬការពារដោយប្រយោល ដោយយោងទៅលើលទ្ធភាពនៃការប្រើប្រាស់កម្លាំង មធ្យោបាយ សម្ភារនៅក្នុងការការពារមុខសញ្ញា និងគោលដៅដែលបានកំណត់។ មុខសញ្ញា និងគោលដៅសំខាន់ៗរួមមាន៖

ក- មុខសញ្ញាការពារជាអធិភាព

- សមាជិក សមាជិកា គ.ជ.ប និងមន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងអ្នកគាំទ្រ
- ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត
- ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោតនៃសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ
- តំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬប្រទេសនានា និងតំណាងអង្គការអន្តរជាតិដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនឹងអនុញ្ញាតដោយ គ.ជ.ប ឱ្យចូលរួមជាអ្នកសង្កេតការណ៍បោះឆ្នោត។

ខ- គោលដៅការពារជាអធិភាព

- ទីស្តីការ គ.ជ.ប លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លគធ.ខប) និងទីស្នាក់ការ គយ.សប
- ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ទីតាំងបិទផ្សាយបញ្ជីបោះឆ្នោត បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដំបូង និងផ្លូវការ
- ទីតាំងរោងពុម្ពផលិតសន្លឹកឆ្នោត
- កន្លែងរក្សាទុក ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងសង្ហារឹមផ្សេងៗបម្រើឱ្យការងារបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគោលដៅមួយទៅគោលដៅមួយទៀតដែលកំណត់ដោយ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- ទីស្នាក់ការ និងកន្លែងជួបប្រជុំ ឬក្បួនព្យុហយាត្រាយោសនារបស់គណបក្សនយោបាយ ឬបេក្ខជន។

២.១៩.៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ដែលជាសេនាធិការឱ្យលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប មានការកិច្ចពិនិត្យ រៀបចំគម្រោងផលិតឯកសារ និងសម្ភារទាក់ទងការងារសន្តិសុខបោះឆ្នោតសំខាន់ៗ រួមមានសៀវភៅក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងដំណើរការបោះឆ្នោត ខិត្តបណ្ណផ្សព្វផ្សាយផ្សេងៗ ទាក់ទងការងារសន្តិសុខបោះឆ្នោត និងប្រឡង់ដៃសន្តិសុខបោះឆ្នោត ដើម្បីសុំការសម្រេចពី គ.ជ.ប។

២.១៩.៧ គធ.ខប ត្រូវចាត់ចែងរៀបចំកិច្ចប្រជុំចម្រុះក្នុងគោលដៅជួបពិភាក្សាការងារ ចាត់វិធានការបង្ការ ទប់ស្កាត់ ឬស្វែងរកដំណោះស្រាយសមស្រប ដើម្បីបង្ការ និងកាត់បន្ថយបញ្ហាទំនាស់ ឬបាតុភាពនានាដែលអាចកើតមាននៅគ្រប់ដំណាក់កាលនៃការរៀបចំការបោះឆ្នោត។ គធ.ខប ត្រូវរៀបចំកិច្ចប្រជុំម្តងក្នុងមួយសប្តាហ៍ និងអាចកោះប្រជុំតាមការចាំបាច់។ សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះរួមមាន៖

- ប្រធាន គធ.ខប ជាសហប្រធាន
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ឬតំណាង ជាសហប្រធាន
- មេបញ្ជាការយោធភូមិភាគពិសេស ឬមេបញ្ជាការយោធភូមិភាគទី១ ដល់ទី៥ ចំពោះរាជធានី ខេត្តដែលពាក់ព័ន្ធ ឬតំណាង ជាសមាជិក
- ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ឬតំណាង ជាសមាជិក
- មេបញ្ជាការនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្ត ឬតំណាង ជាសមាជិក
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត ឬតំណាង ជាសមាជិក
- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬតំណាង ជាសមាជិក
- ប្រធានមន្ទីរព័ត៌មានរាជធានី ខេត្ត ជាសមាជិក
- តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជាសមាជិក
- តំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធប្រចាំរាជធានី ខេត្ត ជាសមាជិក
- អ្នកសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិ (ប្រសិនបើមាន) ជាសមាជិក។

២.១៩.៨ នៅពេលឃោសនាបោះឆ្នោត យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ ឬភ្នាក់ងារសន្តិសុខបោះឆ្នោតដែលកំពុងបំពេញភារកិច្ចមិនត្រូវ៖

២.១៩.៨.១ ឈរក្បែរ ឬដើរកៀកពេកនឹងទីតាំង ឬក្បួនឃោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណនៃអង្គពិធីឃោសនាបោះឆ្នោតនានា ដោយត្រូវធានាចំពោះគ្រប់គណបក្សនយោបាយឈរឈ្មោះ និងបេក្ខជនគ្រប់រូបនូវសិទ្ធិស្មើៗគ្នាក្នុងការធ្វើសកម្មភាព និងក្នុងការទទួលបានសេវាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព ព្រមទាំងរបៀបរៀបរយពីអាជ្ញាធរមានសមត្ថកិច្ច។

២.១៩.៨.២ ចូលរួមគាំទ្រ ឬប្រឆាំងចំពោះសកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះណាមួយ ឬបេក្ខជនណាម្នាក់ដាច់ខាត។

២.១៩.៩ នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោតមានចំនួនមិនលើសពី ៣ (បី) រូប ដែលការពារនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតែមួយដាច់តែឯង ត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងឱ្យបានត្រឹមត្រូវ និងពាក់ប្រឡង់ដៃសន្តិសុខបោះឆ្នោតរបស់ គ.ជ.ប រហូតដល់ចប់ភារកិច្ច។

២.១៩.១០ ក្នុងករណីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតច្រើនប្រមូលផ្តុំនៅក្នុងបរិវេណ ឬអគារតែមួយ ចំនួនភ្នាក់ងារសន្តិសុខបោះឆ្នោតសម្រាប់ការិយាល័យនីមួយៗ ត្រូវមានចំនួនសមស្របទៅនឹងស្ថានភាពភូមិសាស្ត្រ និងសន្តិសុខជាក់ស្តែង។

២.១៩.១១ ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវហាមជនគ្រប់រូបយកអាវុធ ឬមានលាក់អាវុធ គ្រឿងផ្ទុះ ឬគ្រាប់រំសេវគ្រប់ប្រភេទ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីជៀសវាងកុំឱ្យមានការរំខាន ការអុកឡុក ការបំភិតបំភ័យ និងការគំរាមកំហែង ឬហេតុការណ៍អសន្តិសុខផ្សេងៗដែលនឹងអាចកើតមានជាចៃដន្យ។

២.១៩.១២ ភ្នាក់ងារសន្តិសុខបោះឆ្នោត ឬ/និងភ្នាក់ងារសង្គ្រោះ (ក្រុមបុគ្គលិកពេទ្យ ឬ/និងក្រុមពន្លត់អគ្គិភ័យ ជាអាទិ៍) អាចចូលធ្វើអន្តរាគមន៍នៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតបានតែក្នុងករណីមានសំណូមពរចាំបាច់ពីប្រធាន គ.ជ.ប ប្រធាន គធ.ខប ប្រធាន គឃ.សប ឬប្រធាន គ.ក.ប/គ.ក.រ។

ជំពូកទី៣
ការចុះឈ្មោះបោះឆ្នោត បញ្ជីបោះឆ្នោត និងការបោះឆ្នោត

ប្រការ៣.១.-

ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើស កបឃ.ស ត្រូវអនុវត្តដោយអនុលោមទៅតាមបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំរបស់ គ.ជ.ប។

ប្រការ៣.២.-

គ.ជ.ប ត្រូវផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតជ្រើសរើស កបឃ.ស ផ្លូវការ ៩០ (កៅសិប) ថ្ងៃយ៉ាងតិចមុនថ្ងៃបោះឆ្នោត។ បញ្ជីបោះឆ្នោតផ្លូវការត្រូវមានព័ត៌មានដូចខាងក្រោម៖

- ៣.២.១ ឈ្មោះ និងលេខកូដរាជធានី ខេត្ត។
- ៣.២.២ ឈ្មោះ និងលេខកូដឃុំ សង្កាត់ និងឈ្មោះភូមិ។
- ៣.២.៣ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត។
- ៣.២.៤ កូនប្រអប់ និងលេខរៀងនៃឈ្មោះក្នុងបញ្ជីបោះឆ្នោត។
- ៣.២.៥ អត្តលេខអ្នកបោះឆ្នោត។
- ៣.២.៦ រូបថតអ្នកបោះឆ្នោត។
- ៣.២.៧ ប្រភេទឯកសារចុះឈ្មោះបោះឆ្នោត។
- ៣.២.៨ នាមត្រកូល និងនាមខ្លួនដែលរៀបចំតាមលំដាប់អក្ខរក្រមខ្មែរ។
- ៣.២.៩ ភេទ។
- ៣.២.១០ ថ្ងៃខែឆ្នាំកំណើត។
- ៣.២.១១ លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់នៃអ្នកបោះឆ្នោត។

ប្រការ៣.៣.-

គ.ជ.ប ត្រូវបោះពុម្ពបញ្ជីបោះឆ្នោតផ្លូវការ និងបញ្ជូនសម្រាប់ប្រើប្រាស់ដូចខាងក្រោម៖

- ៣.៣.១ កបឃ.ស ចំនួន ១ (មួយ) ច្បាប់ សម្រាប់រក្សាទុកជាឯកសារផ្លូវការ និងប្រើប្រាស់សម្រាប់បញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតជូនប្រជាពលរដ្ឋដើម្បីបំពេញលក្ខខណ្ឌឈរឈ្មោះជាបេក្ខជន ឬជាភ្នាក់ងារគណបក្សនយោបាយសម្រាប់ការបោះឆ្នោតជ្រើសរើស កបឃ.ស និងសម្រាប់ពិនិត្យ និងសម្រេចផ្តល់សុពលភាពលើទម្រង់ ឯ.អ។

៣.៣.២ គយ.សប ចំនួន ១ (មួយ) ច្បាប់ សម្រាប់បិទផ្សាយជាសាធារណៈនៅទីស្នាក់ការ គយ.សប ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត និងថែរក្សាទុករហូតដល់ថ្ងៃបោះឆ្នោត។

៣.៣.៣ គ.ក.ប ចំនួន ២ (ពីរ) ច្បាប់ ក្នុងនោះ ១ (មួយ) ច្បាប់ សម្រាប់បិទផ្សាយនៅមុខការិយាល័យបោះឆ្នោតនៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត និង ១ (មួយ) ច្បាប់ទៀតសម្រាប់ប្រើប្រាស់ក្នុងការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

៣.៣.៤ គ.ជ.ប ត្រូវបង្ហោះបញ្ជីបោះឆ្នោតផ្លូវការនៅលើអាសយដ្ឋានវេប voterlist.nec.gov.kh និងកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH ដោយត្រូវធានាការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់បុគ្គល និងបង្ហាញតែឈ្មោះ និងលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ ឈ្មោះភូមិ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត លេខរៀងក្នុងបញ្ជីបោះឆ្នោត អត្តលេខអ្នកបោះឆ្នោត លេខ អ.ខ ឬលេខ ឯ.អ ដោយបង្ហាញតែលេខ ៣ (បី) ខ្ទង់ចុងក្រោយ នាមត្រកូល និងនាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើតរបស់អ្នកបោះឆ្នោតប៉ុណ្ណោះ។ ទិន្នន័យបញ្ជីបោះឆ្នោតផ្លូវការត្រូវបានរក្សាទុកដោយសុវត្ថិភាព (Backup Database) និងអាចត្រួតពិនិត្យបាន។

ប្រការ៣.៤.

ដើម្បីជួយដល់អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានយល់ដឹងច្បាស់អំពីលេខរៀង ឈ្មោះ ទិន្នន័យពាក់ព័ន្ធនឹងសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត ព្រមទាំងប្រភេទឯកសារដែលត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសរើស កបឃ.ស គ.ជ.ប ត្រូវអនុវត្តការផ្តល់បណ្ណព័ត៌មានអ្នកបោះឆ្នោត។ ដំណើរការផលិត និងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

ការបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការសម្រាប់ប្រើនៅពេលបោះឆ្នោត

ប្រការ៣.៥.

ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវ៖

៣.៥.១ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការដែលបានផ្តល់សុពលភាពដោយ គ.ជ.ប សម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើស កបឃ.ស នៃឆ្នាំនីមួយៗ។

៣.៥.២ មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ប្រើនៅពេលបោះឆ្នោត។ ឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការរួមមាន៖

- អ.ខ
- លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល
- លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ
- ឯ.អ។

ប្រការ៣.៦.

នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ ទោះបីមានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយដូចមានចែងក្នុងចំណុច ៣.៥.២ ខាងលើនេះ ក៏មិនត្រូវអនុញ្ញាតឱ្យបោះឆ្នោតដែរ។

ប្រការ៣.៧.

នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ ប៉ុន្តែគ្មានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយដូចមានចែងក្នុងចំណុច ៣.៥.២ ខាងលើនេះ ក៏មិនត្រូវអនុញ្ញាតឱ្យបោះឆ្នោតដែរ។

ប្រការ៣.៨.

នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ទោះបីមានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយដូចមានចែងក្នុងចំណុច ៣.៥.២ ខាងលើនេះ ប៉ុន្តែត្រូវបានបាត់សិទ្ធិបោះឆ្នោតស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ក៏មិនត្រូវអនុញ្ញាតឱ្យបោះឆ្នោតដែរ។

នីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)

ប្រការ៣.៩.

អនុលោមតាមមាត្រា១៦៩ នៃ ច.ប.ត.រ ករណីប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ប៉ុន្តែពុំមាន អ.ខ ដើម្បីបោះឆ្នោត ប្រជាពលរដ្ឋនោះអាចប្រើប្រាស់ ឯ.អ ដើម្បីបោះឆ្នោត។ អាជ្ញាធរឃុំ សង្កាត់ និង គយ.សប ត្រូវបានអនុញ្ញាតឱ្យចេញ ឯ.អ តាមការស្នើសុំជូនប្រជាពលរដ្ឋ ស្របតាមសេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និង គ.ជ.ប លេខ០៣៤ ស.ណ.ន ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត។

ការផ្គត់ផ្គង់សម្ភារ បរិក្ខារ កុំព្យូទ័រ

៣.៩.១ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ បរិក្ខារ កុំព្យូទ័រ និងសម្ភារចាំបាច់នានាផ្សេងទៀតដល់ គយ.សប សម្រាប់ប្រើប្រាស់ក្នុងការចេញ ឯ.អ ជូនអ្នកបោះឆ្នោត។

នីតិវិធីនៃការស្នើសុំ ឯ.អ

៣.៩.២ ដើម្បីស្នើសុំ ឯ.អ អ្នកបោះឆ្នោតត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវស្នើសុំក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត និងត្រូវបញ្ឈប់ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត វេលាម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទីជាកំហិត
- ត្រូវបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខ គយ.សប នៃឃុំ សង្កាត់ដែលសាមីខ្លួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ និងត្រូវបោះឆ្នោត
- ត្រូវបំពេញពាក្យស្នើសុំ និងត្រូវផ្តិតស្នាមម្រាមដៃនៅចំពោះមុខប្រធាន គយ.សប

- ត្រូវផ្តល់ស្នាមម្រាមដៃតាមការណែនាំរបស់សមាជិក គឃ.សប ទទួលបន្ទុកលើការងាររដ្ឋបាល និងឋតរូបសម្រាប់ការផ្ទៀងផ្ទាត់ និងទាញទិន្នន័យពីបញ្ជីបោះឆ្នោតផ្លូវការក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត។

បែបបទ និងនីតិវិធីនៃការចេញ ឯ.អ

៣.៩.៣ ប្រធាន គឃ.សប មានសមត្ថកិច្ចក្នុងការពិនិត្យ និងសម្រេចចេញ ឯ.អ ជូនអ្នកបោះឆ្នោតតាមការស្នើសុំ ដោយមិនតម្រូវឱ្យបង់ថ្លៃឡើយ។ បែបបទ និងនីតិវិធីនៃការចេញទម្រង់ ឯ.អ មានដូចខាងក្រោម៖

- យកស្នាមម្រាមដៃសាមីខ្លួន ឬស្វែងរកឈ្មោះតាមរយៈលេខ អ.ខ តាមនាមត្រកូល ឬនាមខ្លួនសម្រាប់ជនមានពិការភាព ឬអ្នកបោះឆ្នោតដែលខូចខ្វៅដៃ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវបន្ថែមទៀតរវាងពាក្យស្នើសុំជាមួយទិន្នន័យក្នុងបញ្ជីបោះឆ្នោតផ្លូវការ ដោយត្រូវយកចិត្តទុកដាក់ជាសំខាន់ទៅលើនាមត្រកូល និងនាមខ្លួន ភេទ ថ្ងៃខែឆ្នាំកំណើត ប្រភេទ អ.ខ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតដែលបានប្រើក្នុងការចុះឈ្មោះបោះឆ្នោត ព្រមទាំងរូបថតរបស់សាមីខ្លួនដោយប្រៀបធៀបរវាងរូបថត និងរូបពិត
- ត្រូវបោះពុម្ពទម្រង់ ឯ.អ ចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ប្រសិនបើអ្នកបោះឆ្នោតបានបំពេញលក្ខខណ្ឌត្រឹមត្រូវ
- ចុះហត្ថលេខា និងបោះត្រា គឃ.សប លើហត្ថលេខារបស់ខ្លួន និងបោះត្រាបន្ថែមនៅចំពាក់កណ្តាលរវាងផ្នែកទាំង ២ (ពីរ) នៃទម្រង់ ឯ.អ
- ចាត់ឱ្យសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលស្តែនពាក្យស្នើសុំ ព្រមទាំងទម្រង់ ឯ.អ (ទាំង ២ (ពីរ) ផ្នត់) បញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីរក្សាទុកជាឯកសារនៅ គឃ.សប
- ជម្រាបអ្នកស្នើសុំឱ្យយកទម្រង់ ឯ.អ ទៅជួបមេឃុំ ចៅសង្កាត់ ដើម្បីចុះហត្ថលេខា និងបោះត្រាឃុំ សង្កាត់ ផ្តល់សុពលភាពប្រើប្រាស់ជាផ្លូវការ។

៣.៩.៤ ក្នុងករណីអ្នកស្នើសុំពុំបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ៣.៩.២ ខាងលើនេះទេ ប្រធាន គឃ.សប ត្រូវណែនាំអ្នកស្នើសុំឱ្យបំពេញឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌ ដើម្បីស្នើសុំ ឯ.អ សាជាថ្មី។

៣.៩.៥ ក្នុងករណីប្រធាន គឃ.សប បោះពុម្ពទម្រង់ ឯ.អ ខុស ឬចុះហត្ថលេខា ឬបោះត្រាលើទម្រង់ ឯ.អ មិនបានត្រឹមត្រូវតាមការណែនាំខាងលើទេ ប្រធាន គឃ.សប ត្រូវគូសខ្វែងលើទម្រង់ ឯ.អ នោះ។ គឃ.សប ត្រូវរក្សាទុកទម្រង់ ឯ.អ ដែលគូសខ្វែងនោះឱ្យបានល្អ និងមានសុវត្ថិភាពនៅទីស្នាក់ការ គឃ.សប។

៣.៩.៦ អាជ្ញាធរឃុំ សង្កាត់មានសមត្ថកិច្ចក្នុងការពិនិត្យ និងសម្រេចផ្តល់សុពលភាពលើទម្រង់ ឯ.អ សម្រាប់ប្រើប្រាស់ជាផ្លូវការ។ បន្ទាប់ពីមេឃុំ ចៅសង្កាត់ចុះហត្ថលេខារួចហើយ ត្រូវចាត់ស្មៀនឃុំ សង្កាត់ឱ្យបោះត្រាឃុំ សង្កាត់លើហត្ថលេខារបស់មេឃុំ ចៅសង្កាត់ រួចហែកផ្តាច់ទម្រង់ ឯ.អ ជា ២ (ពីរ) សន្លឹករួចប្រគល់ ១ (មួយ) សន្លឹក ជូនអ្នកស្នើសុំ និងរក្សាទុកជាឯកសារនៅសាលាឃុំ សង្កាត់ ១ (មួយ) សន្លឹក។

៣.៩.៧ ក្នុងករណីបាត់ ឬខូច ឯ.អ ការស្នើសុំជាថ្មីត្រូវអនុវត្តនីតិវិធីនៃការស្នើសុំដូចមានចែងក្នុងចំណុច ៣.៩.២ ខាងលើនេះ ព្រមទាំងបែបបទ និងនីតិវិធីដូចមានចែងក្នុងចំណុច ៣.៩.៣ រហូតដល់ចំណុច ៣.៩.៦ ខាងលើនេះ ដោយប្រធាន គយ.សប ត្រូវសរសេរបញ្ជាក់ពាក្យថា "ចេញជាលើកទី២" នៅខាងចុងចំណងជើងនៃទម្រង់ ឯ.អ ទាំងពីរផ្នែក។

៣.៩.៨ ក្នុងករណីចាំបាច់ គ.ជ.ប អាចអនុញ្ញាតឱ្យ គធ.ខប គយ.សប ពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងអាជ្ញាធរឃុំ សង្កាត់ ដើម្បីចល័តទៅតាមភូមិមួយចំនួនដែលមានភូមិសាស្ត្រលំបាកស្មុគស្មាញក្នុងគោលដៅបង្កលក្ខណៈងាយស្រួលដល់ការស្នើសុំ ឯ.អ និងការចេញ ឯ.អ ជូនអ្នកបោះឆ្នោត។

៣.៩.៩ បន្ទាប់ពីបញ្ចប់ការចេញ ឯ.អ នៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត ប្រធាន គយ.សប ត្រូវធ្វើរបាយការណ៍ចំនួន ៤ (បួន) ច្បាប់ ដោយត្រូវចុះហត្ថលេខា កាលបរិច្ឆេទ បោះត្រា គយ.សប ដើម្បី៖

- បិទផ្សាយជាសាធារណៈភ្លាមៗនៅទីស្នាក់ការ គយ.សប ១ (មួយ) ច្បាប់
- ផ្ញើជូនរដ្ឋបាលឃុំ សង្កាត់ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់
- ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់
- ស្តែនរបាយការណ៍នេះ រួចបញ្ជូនទៅ គ.ជ.ប តាមអ៊ីនធឺណិត។

៣.៩.១០ ចំពោះរបាយការណ៍ដែលត្រូវផ្ញើជូន គធ.ខប គយ.សប ត្រូវផ្ញើជូនស្របពេលនឹងការបញ្ជូនសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត ដោយត្រូវបោះពុម្ពទម្រង់ ឯ.អ ដែលបានស្តែនបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រភ្ជាប់មកជាមួយផង។ បន្ទាប់ពីទទួលបានរបាយការណ៍ពី គយ.សប ហើយ គធ.ខប ត្រូវធ្វើការបូកសរុបរបាយការណ៍ក្នុងរាជធានី ខេត្តរបស់ខ្លួន ចំនួន ៥ (ប្រាំ) ច្បាប់រួចបិទផ្សាយជាសាធារណៈនៅ លគធ.ខប ១ (មួយ) ច្បាប់ ផ្ញើជូនគណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារនៅ គធ.ខប ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងផ្ញើជូនក្រសួងមហាផ្ទៃ ១ (មួយ) ច្បាប់ ស្របពេលនឹងការបញ្ជូនសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត ដោយត្រូវភ្ជាប់របាយការណ៍របស់ គយ.សប និងទម្រង់ ឯ.អ ដែល គយ.សប បានបោះពុម្ពចេញពីប្រព័ន្ធកុំព្យូទ័រមកជាមួយផង។

ជំពូកទី៤
ប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសនៈ

ប្រព័ន្ធបោះឆ្នោត

ប្រការ៤.១.-

ការបោះឆ្នោតជ្រើសរើស កបយ.ស ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ដោយយកឃុំ សង្កាត់ជាមណ្ឌលបោះឆ្នោត និងបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត។

ប្រការ៤.២.-

ចំនួនអាសនៈនៃ កបយ.ស ត្រូវស្មើគ្នានឹងចំនួនសមាជិក កបយ.ស ដែលកំណត់ដោយអនុក្រឹត្យអនុលោមតាម ច.គ.ឃ.ស។

ប្រការ៤.៣.-

សមាជិក កបយ.ស ត្រូវជ្រើសរើសចេញពីក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានជាប់ឆ្នោតនៅក្នុងឃុំ សង្កាត់។

ការបែងចែកអាសនៈ

ប្រការ៤.៤.-

គជ.ខប ត្រូវធ្វើការបែងចែកអាសនៈ កបយ.ស។

ប្រការ៤.៥.-

អាសនៈនៅក្នុង កបយ.ស ត្រូវបែងចែកដោយផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ។

ប្រការ៤.៦.-

ដើម្បីបែងចែកអាសនៈ កបយ.ស នីមួយៗ ត្រូវអនុវត្តតាមករណីដូចតទៅ៖

៤.៦.១ ឃុំ សង្កាត់ណាដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតែមួយគត់ ឃុំ សង្កាត់នោះក៏ត្រូវធ្វើការបោះឆ្នោតដែរ។

៤.៦.២ ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបយ.ស ក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយឈរឈ្មោះ និងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយជាប់ឆ្នោត ត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយនោះដូចគ្នាតាមលំដាប់លេខរៀងពីលើមកក្រោម រហូតដល់គ្រប់អាសនៈនៅក្នុង កបយ.ស នោះ។

៤.៦.៣ ក្នុងករណីការបោះឆ្នោតក្នុងឃុំ សង្កាត់មានបញ្ជីបេក្ខជននៃគណបក្សនយោបាយលើសពីមួយជាប់ឆ្នោត អាសនៈនៅក្នុង កបយ.ស នោះ ត្រូវបែងចែកដោយផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោតតាមជំហានទាំងឡាយដូចខាងក្រោម៖

ជំហានទី១ : **ការកំណត់កូតា** (Quota)

៤.៦.៣.១ កូតា គឺជាចំនួនសន្លឹកឆ្នោតបានការសរុបនៅក្នុងមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗដែលកំណត់ឡើងសម្រាប់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នោះទទួលបាន ១ (មួយ) អាសនៈ។

៤.៦.៣.២ ដើម្បីកំណត់កូតា ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់មណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗចែកនឹងចំនួនអាសនៈសរុបដែលបានកំណត់សម្រាប់ កបយ.ស នីមួយៗនោះតាមរូបមន្តដូចខាងក្រោម៖

$$\text{ក}_{\text{ត}} = \frac{\text{ស}_{\text{ស}}}{\text{អ}_{\text{ស}}}$$

ក្នុងនោះ៖

- $\text{ក}_{\text{ត}}$: តាងឱ្យកូតាដែលជាផលចែកមិនគិតសំណល់ចែក
- $\text{ស}_{\text{ស}}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប
- $\text{អ}_{\text{ស}}$: តាងឱ្យចំនួនអាសនៈសរុប។

ឧទាហរណ៍ : នៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A មាន៖

- សន្លឹកឆ្នោតបានការសរុប ($\text{ស}_{\text{ស}}$) = ៨ ៣៥២ សន្លឹក
- អាសនៈសរុប ($\text{អ}_{\text{ស}}$) = ១១ អាសនៈ

អនុវត្តតាមរូបមន្តខាងលើយើងបាន៖

$$\text{ក}_{\text{ត}} = \frac{\text{ស}_{\text{ស}}}{\text{អ}_{\text{ស}}} = \frac{\text{៨ ៣៥២}}{\text{១១}} = \text{៧៥៩}$$

កូតាស្មើនឹង ៧៥៩ ($\text{ក}_{\text{ត}} = \text{៧៥៩}$)

ជំហានទី២ : ការកំណត់ចំនួនអាសនៈបឋម ឬការបែងចែកអាសនៈលើកទី១

៤.៦.៣.៣ ដើម្បីកំណត់ចំនួនអាសនៈបឋមសម្រាប់ផ្តល់ឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ មកចែកនឹងកូតា តាមរូបមន្តដូចខាងក្រោម៖

$$\text{អ}_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក}_{\text{ត}}}$$

ក្នុងនោះ៖

- $\text{អ}_{\text{ទ}}$: តាងឱ្យចំនួនអាសនៈជាផលចែកមិនគិតសំណល់ចែក ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវទទួលបានក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២
- $\text{ស}_{\text{ប}}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ
- $\text{ក}_{\text{ត}}$: តាងឱ្យកូតា។

ឧទាហរណ៍ : ការកំណត់ចំនួនអាសនៈបឋមនៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A ដដែល ដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន ៦ ឈរឈ្មោះបោះឆ្នោត។

បញ្ជីបេក្ខជននៃគណបក្ស	**ក**	មានសន្លឹកឆ្នោតបានការ	$\text{ស}_{\text{ប}}\text{ក}$	=	១ ១៧៩	សន្លឹក
បញ្ជីបេក្ខជននៃគណបក្ស	**ខ**	មានសន្លឹកឆ្នោតបានការ	$\text{ស}_{\text{ប}}\text{ខ}$	=	២ ២៧៥	សន្លឹក
បញ្ជីបេក្ខជននៃគណបក្ស	**គ**	មានសន្លឹកឆ្នោតបានការ	$\text{ស}_{\text{ប}}\text{គ}$	=	៣ ១៣១	សន្លឹក
បញ្ជីបេក្ខជននៃគណបក្ស	**ឃ**	មានសន្លឹកឆ្នោតបានការ	$\text{ស}_{\text{ប}}\text{ឃ}$	=	៣៨២	សន្លឹក
បញ្ជីបេក្ខជននៃគណបក្ស	**ង**	មានសន្លឹកឆ្នោតបានការ	$\text{ស}_{\text{ប}}\text{ង}$	=	១ ០៩១	សន្លឹក
បញ្ជីបេក្ខជននៃគណបក្ស	**ច**	មានសន្លឹកឆ្នោតបានការ	$\text{ស}_{\text{ប}}\text{ច}$	=	២៩៨	សន្លឹក

បន្ទាប់ពីអនុវត្តតាមរូបមន្តជំហានទី២ ក្នុងចំណុច ៤.៦.៣.៣ ខាងលើនេះ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ក** $អ_{ទ}ក = \frac{១\ ១៧៩}{៧៥៩} = ១,៥៥$ ត្រូវជា ១ អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ខ** $អ_{ទ}ខ = \frac{២\ ២៧៥}{៧៥៩} = ២,៩៩$ ត្រូវជា ២ អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **គ** $អ_{ទ}គ = \frac{៣\ ១៣១}{៧៥៩} = ៤,១២$ ត្រូវជា ៤ អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ឃ** $អ_{ទ}ឃ = \frac{៣៨២}{៧៥៩} = ០,៥០$ ត្រូវជា ០ អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ង** $អ_{ទ}ង = \frac{១\ ០៩១}{៧៥៩} = ១,៤៣$ ត្រូវជា ១ អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ច** $អ_{ទ}ច = \frac{២៩៤}{៧៥៩} = ០,៣៨$ ត្រូវជា ០ អាសនៈ

៤.៦.៣.៤ បន្ទាប់ពីគណនាតាមរូបមន្តជំហានទី២ គ្រប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់រួចមក ហើយប្រសិនបើគ្មានអាសនៈនៅសល់នោះចំនួនអាសនៈត្រូវកំណត់យកតែម្តង។

ជំហានទី៣ : ការកំណត់មធ្យមភាគខ្ពស់បំផុត និងការបែងចែកអាសនៈលើកទី២

៤.៦.៣.៥ ក្នុងករណីមានអាសនៈនៅសល់បន្ទាប់ពីការបែងចែកអាសនៈលើកទី១ គធ.ខប ត្រូវបន្តបែងចែកអាសនៈដែលនៅសល់នោះឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមការគណនាដូចខាងក្រោម៖

៤.៦.៣.៥.១ មធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវបានកំណត់ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ចែកនឹងចំនួនអាសនៈដែលបញ្ជីបេក្ខជននៃ

គណបក្សនយោបាយនីមួយៗបានទទួលក្នុងការបែងចែកលើកទី១ បូកនឹងលេខនិមិត្តចំនួន ១ (មួយ) តាមរូបមន្តដូចខាងក្រោម៖

$$\text{ម}_{\text{ធ}} = \frac{\text{ស}_{\text{ប}}}{\text{អ}_{\text{ទ}}+\text{១}}$$

ក្នុងនោះ៖

- $\text{ម}_{\text{ធ}}$: តាងឱ្យមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ
- $\text{ស}_{\text{ប}}$: តាងឱ្យសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ
- $\text{អ}_{\text{ទ}}$: តាងឱ្យចំនួនអាសនៈបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបាន
- ១ : ជាលេខនិមិត្ត។

៤.៦.៣.៥.២ ក្នុងការរកមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវគណនាដល់ចំនួនទសភាគ ២ (ពីរ) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់ជាងគេ។

៤.៦.៣.៥.៣ បន្ទាប់ពីកំណត់បានមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ រួចហើយត្រូវធ្វើការប្រៀបធៀបគ្នា។ បញ្ជីបេក្ខជននៃគណបក្សនយោបាយណាមានមធ្យមភាគធំជាងគេដែលជាមធ្យមភាគខ្ពស់បំផុត (គិតទាំងចំនួនទសភាគពីរខ្ទង់ក្រោយក្បៀស) ត្រូវទទួលបានអាសនៈ ១ (មួយ)។

ឧទាហរណ៍ : ការបែងចែកអាសនៈលើកទី២ នៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A ដដែល តាមការបែងចែកអាសនៈលើកទី១ តាមរូបមន្តជំហានទី២ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ក** បានទទួលអាសនៈ ១
បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ ២
បញ្ជីបេក្ខជននៃគណបក្ស **គ** បានទទួលអាសនៈ ៤
បញ្ជីបេក្ខជននៃគណបក្ស **ឃ** បានទទួលអាសនៈ ០
បញ្ជីបេក្ខជននៃគណបក្ស **ង** បានទទួលអាសនៈ ១
បញ្ជីបេក្ខជននៃគណបក្ស **ច** បានទទួលអាសនៈ ០

អាសនៈដែលបានបែងចែកលើកទី១ សរុបមាន ៨ អាសនៈ។

អាសនៈសរុបក្នុង ក.ប.ស មាន ១១ អាសនៈ។

អាសនៈនៅសល់ត្រូវបន្តធ្វើការបែងចែកមាន ៣ អាសនៈ។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ក** $\text{មធ}_{\text{ក}} = \frac{\text{១ ១៧៩}}{\text{១+១}} =$ ៥៨៩,៥០

បញ្ជីបេក្ខជននៃគណបក្ស **ខ** $\text{មធ}_{\text{ខ}} = \frac{\text{២ ២៧៥}}{\text{២+១}} =$ **៧៥៨,៣៣**

បញ្ជីបេក្ខជននៃគណបក្ស **គ** $\text{មធ}_{\text{គ}} = \frac{\text{៣ ១៣១}}{\text{៤+១}} =$ ៦២៦,២០

បញ្ជីបេក្ខជននៃគណបក្ស **ឃ** $\text{មធ}_{\text{ឃ}} = \frac{\text{៣៨២}}{\text{០+១}} =$ ៣៨២,០០

បញ្ជីបេក្ខជននៃគណបក្ស **ង** $\text{មធ}_{\text{ង}} = \frac{\text{១ ០៩១}}{\text{១+១}} =$ ៥៤៥,៥០

បញ្ជីបេក្ខជននៃគណបក្ស **ច** $\text{មធ}_{\text{ច}} = \frac{\text{២៩៤}}{\text{០+១}} =$ ២៩៤,០០

តាមការប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង៦ ខាងលើនេះ បញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគធំជាងគេគឺ **៧៥៨,៣៣** ដែលជាមធ្យមភាគខ្ពស់បំផុត។ ដូចនេះ បញ្ជីបេក្ខជននៃគណបក្ស **ខ** ត្រូវទទួលបានអាសនៈ ១ (មួយ) ក្នុងការបែងចែកអាសនៈលើកទី២ នេះ។

៤.៦.៣.៦ ក្នុងករណីនៅមានសល់អាសនៈបន្ទាប់ពីការបែងចែកលើកទី២ គធ.ខប ត្រូវបន្តបែងចែកអាសនៈដែលនៅសល់នោះតាមរូបមន្ត ជំហានទី៣ ដដែល។

ឧទាហរណ៍ : ការបែងចែកអាសនៈលើកទី៣ នៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A ដដែល តាមការបែងចែកអាសនៈលើកទី១ និងលើកទី២ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស	**ក**	បានទទួលអាសនៈ	១	
បញ្ជីបេក្ខជននៃគណបក្ស	**ខ**	បានទទួលអាសនៈ	៣	ទើបទទួលបាន ១ អាសនៈបន្ថែម
បញ្ជីបេក្ខជននៃគណបក្ស	**គ**	បានទទួលអាសនៈ	៤	
បញ្ជីបេក្ខជននៃគណបក្ស	**ឃ**	បានទទួលអាសនៈ	០	
បញ្ជីបេក្ខជននៃគណបក្ស	**ង**	បានទទួលអាសនៈ	១	
បញ្ជីបេក្ខជននៃគណបក្ស	**ច**	បានទទួលអាសនៈ	០	

អាសនៈដែលបានបែងចែកលើកទី១ និងលើកទី២ សរុបមាន ៩ អាសនៈ។

អាសនៈសរុបក្នុង ក.ប.ស មាន ១១ អាសនៈ។

អាសនៈដែលនៅសល់ត្រូវបន្តធ្វើការបែងចែកមាន ២ អាសនៈ។

ក្នុងការបែងចែកលើកទី៣ តាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ក** $\text{ម}_{\text{ធ}}\text{ក} = \frac{\text{១ ១៧៩}}{\text{១+១}} = \text{៥៨៩,៥០}$

បញ្ជីបេក្ខជននៃគណបក្ស **ខ** $\text{ម}_{\text{ធ}}\text{ខ} = \frac{\text{២ ២៧៥}}{\text{៣+១}} = \text{៥៦៨,៧៥}$

បញ្ជីបេក្ខជននៃគណបក្ស **គ** $\text{ម}_{\text{ធ}}\text{គ} = \frac{\text{៣ ១៣១}}{\text{៤+១}} = \mathbf{\text{៦២៦,២០}}$

បញ្ជីបេក្ខជននៃគណបក្ស **ឃ** $\text{ម}_{\text{ធ}}\text{ឃ} = \frac{\text{៣៨២}}{\text{០+១}} = \text{៣៨២,០០}$

បញ្ជីបេក្ខជននៃគណបក្ស **ង** $\text{ម}_{\text{ធ}}\text{ង} = \frac{\text{១ ០៩១}}{\text{១+១}} = \text{៥៤៥,៥០}$

បញ្ជីបេក្ខជននៃគណបក្ស **ច** $\text{ម}_{\text{ធ}}\text{ច} = \frac{\text{២៩៤}}{\text{០+១}} = \text{២៩៤,០០}$

តាមការប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង៦ ខាងលើនេះ បញ្ជីបេក្ខជននៃគណបក្ស **គ** មានមធ្យមភាគធំជាងគេគឺ **៦២៦,២០** ដែលជាមធ្យមភាគខ្ពស់បំផុត។ ដូចនេះ បញ្ជីបេក្ខជននៃគណបក្ស **គ** ត្រូវទទួលបានអាសនៈ ១ (មួយ) ក្នុងការបែងចែកលើកទី៣ នេះដែលនាំឱ្យ៖

បញ្ជីបេក្ខជននៃគណបក្ស	**ក**	បានទទួលអាសនៈ	១	
បញ្ជីបេក្ខជននៃគណបក្ស	**ខ**	បានទទួលអាសនៈ	៣	
បញ្ជីបេក្ខជននៃគណបក្ស	**គ**	បានទទួលអាសនៈ	៥	ទើបទទួលបាន ១ អាសនៈបន្ថែម
បញ្ជីបេក្ខជននៃគណបក្ស	**ឃ**	បានទទួលអាសនៈ	០	
បញ្ជីបេក្ខជននៃគណបក្ស	**ង**	បានទទួលអាសនៈ	១	
បញ្ជីបេក្ខជននៃគណបក្ស	**ច**	បានទទួលអាសនៈ	០	

៤.៦.៣.៧ ក្នុងករណីនៅសល់អាសនៈត្រូវបែងចែកបន្តទៀត ការគណនាត្រូវអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ និងបន្តបែងចែកតាមរបៀបនេះម្តងមួយអាសនៈៗរហូតដល់អស់អាសនៈ។

ឧទាហរណ៍ : ការបែងចែកអាសនៈបន្តនៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A ដដែល។

បន្ទាប់ពីការបែងចែកអាសនៈលើកទី៣ នៅមានសល់អាសនៈចំនួន ១ (មួយ) ទៀត ដែលត្រូវបន្តបែងចែក។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស	**ក**	$\text{ម}_{\text{ធ}}\text{ក}$	=	$\frac{\text{១ ១៧៩}}{\text{១+១}}$	=	**៥៨៩,៥០**
បញ្ជីបេក្ខជននៃគណបក្ស	**ខ**	$\text{ម}_{\text{ធ}}\text{ខ}$	=	$\frac{\text{២ ២៧៥}}{\text{៣+១}}$	=	៥៦៨,៧៥
បញ្ជីបេក្ខជននៃគណបក្ស	**គ**	$\text{ម}_{\text{ធ}}\text{គ}$	=	$\frac{\text{៣ ១៣១}}{\text{៥+១}}$	=	៥២១,៨៣
បញ្ជីបេក្ខជននៃគណបក្ស	**ឃ**	$\text{ម}_{\text{ធ}}\text{ឃ}$	=	$\frac{\text{៣៨២}}{\text{០+១}}$	=	៣៨២,០០
បញ្ជីបេក្ខជននៃគណបក្ស	**ង**	$\text{ម}_{\text{ធ}}\text{ង}$	=	$\frac{\text{១ ០៩១}}{\text{១+១}}$	=	៥៤៥,៥០
បញ្ជីបេក្ខជននៃគណបក្ស	**ច**	$\text{ម}_{\text{ធ}}\text{ច}$	=	$\frac{\text{២៩៤}}{\text{០+១}}$	=	២៩៤,០០

តាមការប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង៦ ខាងលើនេះ បញ្ជីបេក្ខជននៃគណបក្ស **ក** មានមធ្យមភាគធំជាងគេគឺ **៥៨៩,៥០** ដែលជាមធ្យមភាគខ្ពស់បំផុត។ ដូចនេះ បញ្ជីបេក្ខជននៃគណបក្ស **ក** ត្រូវបានទទួល ១ (មួយ) អាសនៈដែលនៅសល់ចុងក្រោយនេះ។ ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈនៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ក** បានទទួលអាសនៈ ២ ទើបទទួលបាន ១ អាសនៈបន្ថែម

បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ ៣

បញ្ជីបេក្ខជននៃគណបក្ស **គ** បានទទួលអាសនៈ ៥

បញ្ជីបេក្ខជននៃគណបក្ស **ឃ** បានទទួលអាសនៈ ០

បញ្ជីបេក្ខជននៃគណបក្ស **ង** បានទទួលអាសនៈ ១

បញ្ជីបេក្ខជននៃគណបក្ស **ច** បានទទួលអាសនៈ ០

៤.៦.៣.៨ ក្នុងករណីការបែងចែកអាសនៈលើកទី១ តាមរូបមន្តដំហានទី២ ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈទេនោះ គធ.ខប ត្រូវបន្តបែងចែកដោយអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងដំហានទី៣ ម្តងមួយអាសនៈៗរហូតដល់អស់អាសនៈ។

ឧទាហរណ៍ : នៅមណ្ឌលបោះឆ្នោតនៃឃុំ B មាន៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយ = ៧
- សន្លឹកឆ្នោតបានការសរុប ($ស_{ស}$) = ៤ ១០៨
- អាសនៈសរុប ($អ_{ស}$) = ៥ អាសនៈ
- កូតា ($ក_{ត}$) = ៨២១

បញ្ជីបេក្ខជននៃគណបក្ស	សប	អ១	ម១	អ២	ម២	អ៣	ម៣	អ៤	ម៤	អ៥	ម៥	អ៦
ក	៥៨២	០	៥៨២ ០+១	០	៥៨២ ០+១	០	៥៨២ ០+១	០	៥៨២ ០+១	**១**	៥៨២ ១+១	០
ខ	៧៥៤	០	៧៥៤ ០+១	**១**	៧៥៤ ១+១	០	៧៥៤ ១+១	០	៧៥៤ ១+១	០	៧៥៤ ១+១	០
គ	៣៨៣	០	៣៨៣ ០+១	០	៣៨៣ ០+១	០	៣៨៣ ០+១	០	៣៨៣ ០+១	០	៣៨៣ ០+១	០
ឃ	៦៣៧	០	៦៣៧ ០+១	០	៦៣៧ ០+១	០	៦៣៧ ០+១	**១**	៦៣៧ ១+១	០	៦៣៧ ១+១	០
ង	៥៦៤	០	៥៦៤ ០+១	០	៥៦៤ ០+១	០	៥៦៤ ០+១	០	៥៦៤ ០+១	០	៥៦៤ ០+១	**១**
ច	៤៦៧	០	៤៦៧ ០+១	០	៤៦៧ ០+១	០	៤៦៧ ០+១	០	៤៦៧ ០+១	០	៤៦៧ ០+១	០
ឆ	៧២១	០	៧២១ ០+១	០	៧២១ ០+១	**១**	៧២១ ១+១	០	៧២១ ១+១	០	៧២១ ១+១	០

ករណីនេះអាចកើតមាននៅមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ណាដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានចំនួនសន្លឹកឆ្នោតបានការប្រហាក់ប្រហែលគ្នា។ តាមតារាងឧទាហរណ៍ខាងលើ យើងបាន៖

- សប តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ
- អ១ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២ ដែលក្នុងនោះពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈឡើយ និងត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣
- ម១ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគធំជាងគេគឺ **៧៥៤**,**០០** ដែលជាមធ្យមភាគខ្ពស់បំផុត

- អ₍₂₎ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី២ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **ខ**
- ម₍₂₎ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី២ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ឆ** មានមធ្យមភាគធំជាងគេគឺ **៧២១,០០** ដែលជាមធ្យមភាគខ្ពស់បំផុត
- អ₍₃₎ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី៣ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **ឆ**
- ម₍₃₎ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **យ** មានមធ្យមភាគធំជាងគេគឺ **៦៣៧,០០** ដែលជាមធ្យមភាគខ្ពស់បំផុត
- អ₍₄₎ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី៤ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **យ**
- ម₍₄₎ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី៤ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ក** មានមធ្យមភាគធំជាងគេគឺ **៥៨២,០០** ដែលជាមធ្យមភាគខ្ពស់បំផុត
- អ₍₅₎ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី៥ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **ក**
- ម₍₅₎ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី៥ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ង** មានមធ្យមភាគធំជាងគេគឺ **៥៦៤,០០** ដែលជាមធ្យមភាគខ្ពស់បំផុត
- អ₍₆₎ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី៦ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **ង**។

ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈនៅមណ្ឌលបោះឆ្នោតនៃឃុំ B យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ក** ទទួលបាន ១ (មួយ) អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ខ** ទទួលបាន ១ (មួយ) អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ឃ** ទទួលបាន ១ (មួយ) អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ង** ទទួលបាន ១ (មួយ) អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ឆ** ទទួលបាន ១ (មួយ) អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **គ** និងបញ្ជីបេក្ខជននៃគណបក្ស **ច** ពុំទទួលបានអាសនៈទេ។

សរុប = ៥ (ប្រាំ) អាសនៈ។

ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយនៅពេលដែល គធ.ខប បែងចែកអាសនៈរួច

ប្រការ៤.៧.

នៅពេល គធ.ខប បែងចែកអាសនៈរួច ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ បញ្ជីបេក្ខជនទាំងអស់នៃគណបក្សនយោបាយនោះលែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ។

៤.៧.១ គធ.ខប ត្រូវបែងចែកអាសនៈដែលនៅទំនេរទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀតដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងឃុំ សង្កាត់ពាក់ព័ន្ធក្នុងអំឡុងពេលយ៉ាងយូរ ១៤ (ដប់បួន) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលលិខិតបោះបង់ចោលជាផ្លូវការពីគណបក្សនយោបាយ ឬប្រកាសស្តីពីការលុបឈ្មោះគណបក្សនយោបាយចេញពីបញ្ជីគណបក្សនយោបាយ ឬប្រកាសរំលាយគណបក្សនយោបាយ។

៤.៧.២ គណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោតអាចប្រកាសមិនទទួលយកអាសនៈរបស់គណបក្សនយោបាយណាមួយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ នៅឃុំ សង្កាត់ណាមួយ ឬមួយចំនួន ដោយត្រូវធ្វើលិខិតជូនដំណឹងទៅ គធ.ខប ក្នុងអំឡុងពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃតាមការកំណត់របស់ គធ.ខប។

៤.៧.៣ នៅមុនការបែងចែកអាសនៈដែលនៅទំនេរតាមករណីដូចខាងលើនេះ គជ.ខប ត្រូវធ្វើលិខិតជាផ្លូវការទៅគណបក្សនយោបាយផ្សេងទៀតដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដើម្បីសម្របសម្រួល និងកំណត់បញ្ហាមួយចំនួនដូចខាងក្រោម៖

ទី១- ការប្រកាសយល់ព្រមទទួលយក ឬមិនទទួលយកអាសនៈរបស់គណបក្សនយោបាយណាមួយដែលបោះបង់អាសនៈចោល ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ នៅឃុំ សង្កាត់ណាមួយ ឬមួយចំនួន ដោយត្រូវធ្វើលិខិតជូនដំណឹងទៅ គជ.ខប ក្នុងអំឡុងពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ។

ទី២- ការធ្វើបច្ចុប្បន្នភាពបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយរបស់ខ្លួន ដោយត្រូវលុបចេញនូវឈ្មោះបេក្ខជនដែល៖

- បាត់សញ្ជាតិខ្មែរ
- ទទួលមរណភាព
- បាត់បង់សម្បទាវិជ្ជាជីវៈ
- លាលែងជាលាយលក្ខណ៍អក្សរ
- ត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ឬ
- បាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

ទី៣- ករណីគណបក្សនយោបាយណាមួយពុំបានឆ្លើយតបតាមលិខិតផ្លូវការរបស់ គជ.ខប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃតាមកាលបរិច្ឆេទកំណត់ដោយ គជ.ខប នោះចាត់ទុកថាគណបក្សនយោបាយនោះបានយល់ព្រមទទួលយកតាមការបែងចែកអាសនៈដែលនៅទំនេរ និងរក្សាទុកជាបានការនូវបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយរបស់ខ្លួនដដែល។

៤.៧.៤ ការបែងចែកអាសនៈដែលនៅទំនេរដូចមានចែងក្នុងចំណុច ៤.៧.១ ខាងលើនេះ ត្រូវអនុវត្តតាមជំហានទាំងឡាយដូចខាងក្រោម៖

ជំហានទី១ : កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ

៤.៧.៤.១ ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបាន ១ (មួយ) អាសនៈ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសកបឃ.ស ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ

ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់នេះ មកចែកនឹងចំនួនអាសនៈដែលនៅទំនេរនោះតាមរូបមន្ត ដូចខាងក្រោម៖

$$\text{ក}'_{\text{ត}} = \frac{\text{ស}'_{\text{ស}}}{\text{អ}'_{\text{ប}}}$$

ក្នុងនោះ៖

- ក'ត : តាងឱ្យកូតាដែលជាផលចែកមិនគិតសំណល់ចែក
- ស'ស : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើស កបយ.ស ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- អ'ប : តាងឱ្យចំនួនអាសនៈរបស់គណបក្សដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ។

ឧទាហរណ៍ : នៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A ដែលមានអាសនៈចំនួន ១១ មានគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតចំនួន ៦ និងមានលទ្ធផលនៃការបោះឆ្នោតដូចខាងក្រោម៖

បញ្ជីបេក្ខជននៃគណបក្ស	**ក**	មាន	សប្ញក	=	១ ១៧៩	ទទួលបាន ២ អាសនៈ
បញ្ជីបេក្ខជននៃគណបក្ស	**ខ**	មាន	សប្ញខ	=	២ ២៧៥	ទទួលបាន ៣ អាសនៈ
បញ្ជីបេក្ខជននៃគណបក្ស	**គ**	មាន	សប្ញគ	=	៣ ១៣១	ទទួលបាន ៥ អាសនៈ
បញ្ជីបេក្ខជននៃគណបក្ស	**ឃ**	មាន	សប្ញឃ	=	៣៨២	ទទួលបាន ០ អាសនៈ
បញ្ជីបេក្ខជននៃគណបក្ស	**ង**	មាន	សប្ញង	=	១ ០៩១	ទទួលបាន ១ អាសនៈ
បញ្ជីបេក្ខជននៃគណបក្ស	**ច**	មាន	សប្ញច	=	២៩៤	ទទួលបាន ០ អាសនៈ

ករណីគណបក្ស **ក** បានបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន ឬដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវបានរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ដែលនាំឱ្យបញ្ជីបេក្ខជន និងសមាជិក ក.ប.ស ទាំងអស់នៃគណបក្ស **ក** លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ នោះអាសនៈចំនួន២ ដែលគណបក្ស **ក** ទទួលបានត្រូវនៅទំនេរ និងត្រូវបែងចែកទៅឱ្យគណបក្សនយោបាយផ្សេងទៀតដែលបានចូលរួមក្នុងការបោះឆ្នោតនៅសង្កាត់ A គឺ គណបក្ស **ខ** គណបក្ស **គ** គណបក្ស **ឃ** គណបក្ស **ង** និងគណបក្ស **ច**។

ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបាន ១ (មួយ) អាសនៈ ដោយអនុវត្តតាមរូបមន្តក្នុងចំណុច ៤.៧.៤.១ ខាងលើនេះ យើងបាន៖

$$\text{ស'}_{\text{ស}} = (\text{១ ១៧៩}+\text{២ ២៧៥}+\text{៣ ១៣១}+\text{៣៨២}+\text{១ ០៩១}+\text{២៩៤})-\text{១ ១៧៩} = \text{៧ ១៧៣}$$

$$\text{អ'}_{\text{ប}} = \text{២}$$

$$\text{ក'}_{\text{ត}} = \frac{\text{ស'}_{\text{ស}}}{\text{អ'}_{\text{ប}}} = \frac{\text{៧ ១៧៣}}{\text{២}} = \text{៣ ៥៨៦}$$

កូតាស្មើនឹង ៣ ៥៨៦ ($\text{ក}_{\text{ត}} = \text{៣ ៥៨៦}$)។

ជំហានទី២ : ការកំណត់ចំនួនអាសនៈជាបឋម (លើកទី១)

៤.៧.៤.២ ការកំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗដែលបានទទួល មកចែកនឹងកូតានៃអាសនៈដែលនៅទំនេរតាមរូបមន្តដូចខាងក្រោម៖

$$\text{អ'}_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក'}_{\text{ត}}}$$

ក្នុងនោះ៖

- $\text{អ'}_{\text{ទ}}$: តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយបានទទួល មុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី៣
- $\text{ស}_{\text{ប}}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ
- $\text{ក'}_{\text{ត}}$: តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី១។

ឧទាហរណ៍ : ការបែងចែកអាសនៈដែលនៅទំនេរលើកទី១ នៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A ដដែល។

អនុវត្តតាមការបែងចែកអាសនៈដែលនៅទំនេរលើកទី១ តាមរូបមន្តក្នុងជំហានទី២ ខាងលើ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ខ** $\text{អ}'_{\text{ខ}} = \frac{\text{២ ២៧៥}}{\text{៣ ៥៨៦}} = \text{0,៦៣}$

បញ្ជីបេក្ខជននៃគណបក្ស **គ** $\text{អ}'_{\text{គ}} = \frac{\text{៣ ១៣១}}{\text{៣ ៥៨៦}} = \text{0,៨៧}$

បញ្ជីបេក្ខជននៃគណបក្ស **ឃ** $\text{អ}'_{\text{ឃ}} = \frac{\text{៣៨២}}{\text{៣ ៥៨៦}} = \text{0,១0}$

បញ្ជីបេក្ខជននៃគណបក្ស **ង** $\text{អ}'_{\text{ង}} = \frac{\text{១ 0៩១}}{\text{៣ ៥៨៦}} = \text{0,៣0}$

បញ្ជីបេក្ខជននៃគណបក្ស **ច** $\text{អ}'_{\text{ច}} = \frac{\text{២៩៤}}{\text{៣ ៥៨៦}} = \text{0,0៨}$

តាមលទ្ធផលនៃការគណនាខាងលើ ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈដែលនៅទំនេរនេះទេ។

ក្នុងករណីបន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរលើកទី១ តាមរូបមន្តជំហានទី២ ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈ ឬនៅមានសល់អាសនៈ អាសនៈទាំងនោះត្រូវយកមកបែងចែកបន្តទៀត ដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្តដូចខាងក្រោម៖

ជំហានទី៣ : ការកំណត់មធ្យមភាគខ្ពស់បំផុត និងការបែងចែកអាសនៈដែលនៅទំនេរ (លើកទី២)

៤.៧.៤.៣ ដើម្បីកំណត់មធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវធ្វើការគណនាដោយយកចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ចែកនឹងចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះបានទទួលបន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរលើកទី១ បូកនឹងលេខនិមិត្តចំនួន ១ តាមរូបមន្តខាងក្រោម៖

$$\text{ម}'_{\text{ធ}} = \frac{\text{សប}}{\text{អ}'_{\text{ខ}}+\text{១}}$$

ក្នុងនោះ៖

- $\text{ម}'_{\text{ធ}}$: តាងឱ្យមធ្យមភាគខ្ពស់បំផុត
- $\text{ស}_{\text{ប}}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ
- $\text{អ}'_{\text{ទ}}$: តាងឱ្យចំនួនអាសនៈដែលបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានក្នុងការបែងចែកអាសនៈដែលនៅទំនេរលើកទី១
- ១ : ជាលេខនិមិត្ត។

៤.៧.៤.៤ ក្នុងការរកមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវគណនាឱ្យដល់ចំនួនទសភាគ ២ (ពីរ) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់ជាងគេ។

៤.៧.៤.៥ បន្ទាប់ពីកំណត់បានមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗរួចមក ត្រូវធ្វើការប្រៀបធៀបគ្នា។ បញ្ជីបេក្ខជននៃគណបក្សនយោបាយណាមានមធ្យមភាគធំជាងគេដែលជាមធ្យមភាគខ្ពស់បំផុត(គិតដល់ចំនួនទសភាគ២(ពីរ)ខ្ទង់ក្រោយក្បៀស) នឹងត្រូវទទួលបានអាសនៈ ១ (មួយ)។

ឧទាហរណ៍ : ការបែងចែកអាសនៈដែលនៅទំនេរ (លើកទី២) តាមរូបមន្តមធ្យមភាគខ្ពស់បំផុតនៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A ដដែល។

បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរ (លើកទី១) តាមរូបមន្តជំហានទី២ រួចមក ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈទេ។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ខ** $\text{ម}'_{\text{ធ}}\text{ខ} = \frac{\text{២ ២៧៥}}{\text{0+១}} =$ ២ ២៧៥,00

បញ្ជីបេក្ខជននៃគណបក្ស **គ** $\text{ម}'_{\text{ធ}}\text{គ} = \frac{\text{៣ ១៣១}}{\text{0+១}} =$ **៣ ១៣១,00**

បញ្ជីបេក្ខជននៃគណបក្ស **ឃ** $\text{ម}'_{\text{ធ}}\text{ឃ} = \frac{\text{៣៨២}}{\text{0+១}} =$ ៣៨២,00

បញ្ជីបេក្ខជននៃគណបក្ស **ង** $\text{ម}'_{\text{ធ}}\text{ង} = \frac{\text{១ 0៩១}}{\text{0+១}} =$ ១ 0៩១,00

បញ្ជីបេក្ខជននៃគណបក្ស **ច** $\text{ម}'_{\text{ធ}}\text{ច} = \frac{\text{២៩៤}}{\text{0+១}} =$ ២៩៤,00

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង៥ ខាងលើនេះ បញ្ជីបេក្ខជននៃគណបក្ស **គ** មានមធ្យមភាគធំជាងគេគឺ **៣ ១៣១,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះ បញ្ជីបេក្ខជននៃគណបក្ស **គ** ត្រូវទទួលបានអាសនៈដែលនៅទំនេរចំនួន ១ (មួយ) ក្នុងការបែងចែកលើកនេះ។

៤.៧.៤.៦ ប្រសិនបើមាននៅសល់អាសនៈទៀត អាសនៈដែលនៅសល់នោះត្រូវបន្តបែងចែកម្តងមួយអាសនៈៗ រហូតដល់អស់អាសនៈតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងដំហានទី៣ ដដែល។

ឧទាហរណ៍ : ការបែងចែកអាសនៈដែលនៅទំនេរលើកទី៣ នៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A ដដែល។ បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរលើកទី២ តាមរូបមន្តដំហានទី៣ រួចមក នៅមានសល់អាសនៈចំនួន ១ (មួយ) ទៀត ត្រូវបែងចែកបន្ត។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងដំហានទី៣ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ខ** $\text{ម}'_{\text{ធ}}\text{ខ} = \frac{\text{២ ២៧៥}}{\text{០+១}} = \mathbf{\text{២ ២៧៥,០០}}$

បញ្ជីបេក្ខជននៃគណបក្ស **គ** $\text{ម}'_{\text{ធ}}\text{គ} = \frac{\text{៣ ១៣១}}{\text{១+១}} = \text{១ ៥៦៥,៥០}$

បញ្ជីបេក្ខជននៃគណបក្ស **ឃ** $\text{ម}'_{\text{ធ}}\text{ឃ} = \frac{\text{៣៨២}}{\text{០+១}} = \text{៣៨២,០០}$

បញ្ជីបេក្ខជននៃគណបក្ស **ង** $\text{ម}'_{\text{ធ}}\text{ង} = \frac{\text{១ ០៩១}}{\text{០+១}} = \text{១ ០៩១,០០}$

បញ្ជីបេក្ខជននៃគណបក្ស **ច** $\text{ម}'_{\text{ធ}}\text{ច} = \frac{\text{២៩៤}}{\text{០+១}} = \text{២៩៤,០០}$

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង៥ ខាងលើនេះ បញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគធំជាងគេគឺ **២ ២៧៥,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស **ខ** ត្រូវទទួលបានអាសនៈដែលនៅទំនេរចំនួន ១ (មួយ) ចុងក្រោយនេះ។

ជាលទ្ធផលសម្រេចនៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A៖

បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ ១ បន្ថែមទៀត សរុប ៤

បញ្ជីបេក្ខជននៃគណបក្ស **គ** បានទទួលអាសនៈ ១ បន្ថែមទៀត សរុប ៦

បញ្ជីបេក្ខជននៃគណបក្ស **ង** បានទទួលអាសនៈ ១

សរុប = ១១ (ដប់មួយ) អាសនៈ។

៤.៧.៥ ការបែងចែកអាសនៈដែលនៅទំនេរដូចមានចែងក្នុងចំណុច ៤.៧.២ ខាងលើនេះ ត្រូវអនុវត្តតាមជំហានទាំងឡាយដូចខាងក្រោម៖

ជំហានទី១ : កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ

៤.៧.៥.១ ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើស កបយ.ស ដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និងដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ មកចែកនឹងចំនួនអាសនៈដែលនៅទំនេរនោះ តាមរូបមន្តដូចខាងក្រោម៖

$$\text{ក}'_{\text{ត}} = \frac{\text{ស}'_{\text{ស}}}{\text{អ}'_{\text{ប}}}$$

ក្នុងនោះ៖

- ក'ត : តាងឱ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក
- ស'ស : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើស កបយ.ស

ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និងដកចេញចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ

- អ'ប : តាងឱ្យចំនួនអាសនៈរបស់គណបក្សដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ។

ឧទាហរណ៍ : នៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A ដដែល៖

បញ្ជីបេក្ខជននៃគណបក្ស	**ក**	មាន	$ស_{ប}ក$	=	១ ១៧៩	ទទួលបាន	២ អាសនៈ
បញ្ជីបេក្ខជននៃគណបក្ស	**ខ**	មាន	$ស_{ប}ខ$	=	២ ២៧៥	ទទួលបាន	៣ អាសនៈ
បញ្ជីបេក្ខជននៃគណបក្ស	**គ**	មាន	$ស_{ប}គ$	=	៣ ១៣១	ទទួលបាន	៥ អាសនៈ
បញ្ជីបេក្ខជននៃគណបក្ស	**ឃ**	មាន	$ស_{ប}ឃ$	=	៣៨២	ទទួលបាន	០ អាសនៈ
បញ្ជីបេក្ខជននៃគណបក្ស	**ង**	មាន	$ស_{ប}ង$	=	១ ០៩១	ទទួលបាន	១ អាសនៈ
បញ្ជីបេក្ខជននៃគណបក្ស	**ច**	មាន	$ស_{ប}ច$	=	២៩៤	ទទួលបាន	០ អាសនៈ

ករណីគណបក្ស **ក** បានបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន ឬដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវបានរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ដែលនាំឱ្យបញ្ជីបេក្ខជន និងសមាជិក ក.ប.ស ទាំងអស់នៃគណបក្ស **ក** លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀត និងករណីគណបក្ស **គ** ប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ នោះអាសនៈចំនួន២ ដែលគណបក្ស **ក** ទទួលបានត្រូវនៅទំនេរ និងត្រូវបែងចែកទៅឱ្យគណបក្សនយោបាយផ្សេងទៀតដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងសង្កាត់លើកលែងតែគណបក្ស **គ** ដែលបានប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ។ ដូចនេះ អាសនៈដែលនៅទំនេរនឹងត្រូវបែងចែកឱ្យគណបក្ស **ខ** គណបក្ស **ឃ** គណបក្ស **ង** និងគណបក្ស **ច**។

ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបាន ១ (មួយ) អាសនៈ ដោយអនុវត្តតាមរូបមន្តក្នុងចំណុច ៤.៧.៥.១ ខាងលើនេះ យើងបាន៖

ស'ស = (១ ១៧៩+២ ២៧៥+៣ ១៣១+៣៨២+១ ០៩១+២៩៤)-(១ ១៧៩+៣ ១៣១) = ៤ ០៤២

អ'ប = ២

$$\text{ក'}_{\text{ត}} = \frac{\text{ស'}_{\text{ស}}}{\text{អ'}_{\text{ប}}} = \frac{៤\ ០៤២}{២} = ២\ ០២១$$

កូតាស្មើនឹង ២ ០២១ ($\text{ក}_{\text{ត}}$ = ២ ០២១)។

ជំហានទី២ : ការកំណត់ចំនួនអាសនៈជាបឋម (លើកទី១)

៤.៧.៥.២ ការកំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួលដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗដែលបានទទួលមកចែកនឹងកូតានៃអាសនៈដែលនៅទំនេរ តាមរូបមន្តដូចខាងក្រោម៖

$$\text{អ'}_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក'}_{\text{ត}}}$$

ក្នុងនោះ៖

- $\text{អ'}_{\text{ទ}}$: តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយបានទទួល មុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី៣
- $\text{ស}_{\text{ប}}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ
- $\text{ក'}_{\text{ត}}$: តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី១។

ឧទាហរណ៍ : ការបែងចែកអាសនៈដែលនៅទំនេរលើកទី១ នៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A ដដែល។ អនុវត្តតាមការបែងចែកអាសនៈដែលនៅទំនេរលើកទី១ តាមរូបមន្តក្នុងជំហានទី២ ចំណុច ៤.៧.៥.២ ខាងលើនេះ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស	**ខ**	អ'ខ	=	២ ២៧៥ / ២ ០២១	=	**១,១២**
បញ្ជីបេក្ខជននៃគណបក្ស	**ឃ**	អ'ឃ	=	៣៨២ / ២ ០២១	=	០,១៨
បញ្ជីបេក្ខជននៃគណបក្ស	**ង**	អ'ង	=	១ ០៩១ / ២ ០២១	=	០,៥៣
បញ្ជីបេក្ខជននៃគណបក្ស	**ច**	អ'ច	=	២៩៤ / ២ ០២១	=	០,១៤

តាមលទ្ធផលនៃការគណនាខាងលើ បញ្ជីបេក្ខជននៃគណបក្ស **ខ** ទទួលបានអាសនៈ ១ (មួយ) ក្នុងចំណោមអាសនៈចំនួន ២ (ពីរ) ដែលនៅទំនេរ។ បន្ទាប់ពីការបែងចែកអាសនៈលើកទី១ តាមរូបមន្តជំហានទី២ មាននៅសល់អាសនៈ ១ (មួយ) ត្រូវយកមកបែងចែកបន្តទៀត ដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្តដូចខាងក្រោម៖

ជំហានទី៣ : ការកំណត់មធ្យមភាគខ្ពស់បំផុត និងការបែងចែកអាសនៈដែលនៅទំនេរ (លើកទី២)

៤.៧.៥.៣ ដើម្បីកំណត់មធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវធ្វើការគណនាដោយយកចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ចែកនឹងចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះបានទទួល បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរលើកទី១ បូកនឹងលេខនិមិត្តចំនួន១ តាមរូបមន្តខាងក្រោម៖

$$\text{ម'}_{\text{ធ}} = \frac{\text{ស}_{\text{ប}}}{\text{អ'}_{\text{ទ}}+1}$$

ក្នុងនោះ៖

- $\text{ម}'_{\text{ធ}}$: តាងឱ្យមធ្យមភាគខ្ពស់បំផុត
- $\text{ស}_{\text{ប}}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ
- $\text{អ}'_{\text{ទ}}$: តាងឱ្យចំនួនអាសនៈដែលបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានក្នុងការបែងចែកអាសនៈដែលនៅទំនេរលើកទី១
- ១ : ជាលេខនិមិត្ត។

៤.៧.៥.៤ ក្នុងការរកមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវគណនាឱ្យដល់ចំនួនទសភាគ ២ (ពីរ) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់ជាងគេ។

៤.៧.៥.៥ បន្ទាប់ពីកំណត់បានមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗរួចមក ត្រូវធ្វើការប្រៀបធៀបគ្នា។ បញ្ជីបេក្ខជននៃគណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត(គិតដល់ចំនួនទសភាគ២(ពីរ)ខ្ទង់ក្រោយក្បៀស) នឹងត្រូវទទួលបានអាសនៈ ១ (មួយ)។

ឧទាហរណ៍ : ការបែងចែកអាសនៈដែលនៅទំនេរ (លើកទី២) តាមរូបមន្តមធ្យមភាគខ្ពស់បំផុតនៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A ដដែល។

បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរ (លើកទី១) តាមរូបមន្តជំហានទី២ រួចមក មាននៅសល់អាសនៈមួយដែលត្រូវយកមកបែងចែកបន្តទៀត។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស	**ខ**	$\text{ម}'_{\text{ធ}}\text{ខ}$	=	$\frac{\text{២ ២៧៥}}{\text{១+១}}$	=	**១ ១៣៧,៥០**
បញ្ជីបេក្ខជននៃគណបក្ស	**ឃ**	$\text{ម}'_{\text{ធ}}\text{ឃ}$	=	$\frac{\text{៣៨២}}{\text{០+១}}$	=	៣៨២,០០
បញ្ជីបេក្ខជននៃគណបក្ស	**ង**	$\text{ម}'_{\text{ធ}}\text{ង}$	=	$\frac{\text{១ ០៩១}}{\text{០+១}}$	=	១ ០៩១,០០
បញ្ជីបេក្ខជននៃគណបក្ស	**ច**	$\text{ម}'_{\text{ធ}}\text{ច}$	=	$\frac{\text{២៩៤}}{\text{០+១}}$	=	២៩៤,០០

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង៤ ខាងលើនេះ បញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគធំជាងគេគឺ **១ ១៣៧,៥០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះ បញ្ជីបេក្ខជននៃគណបក្ស **ខ** ត្រូវទទួលបានអាសនៈដែលនៅសល់ចំនួន ១ (មួយ) ក្នុងការបែងចែកលើកនេះ។

ជាលទ្ធផលសម្រេចនៅមណ្ឌលបោះឆ្នោតនៃសង្កាត់ A៖

បញ្ជីបេក្ខជននៃគណបក្ស	**ខ**	បានទទួលអាសនៈ ២ បន្ថែមទៀត សរុប	៥
បញ្ជីបេក្ខជននៃគណបក្ស	**គ**	បានទទួលអាសនៈ	៥
បញ្ជីបេក្ខជននៃគណបក្ស	**ង**	បានទទួលអាសនៈ	១

សរុប = ១១ (ដប់មួយ) អាសនៈ។

៤.៧.៦ ក្នុងករណីពុំមានគណបក្សនយោបាយទទួលយកអាសនៈដែលនៅទំនេររបស់គណបក្សនយោបាយដែលប្រកាសបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ គធ.ខប ត្រូវចាត់នីតិវិធីឡើងវិញ ដើម្បីសម្របសម្រួលជាមួយគណបក្សនយោបាយទាំងនោះ។

ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួនមានមធ្យមភាគខ្ពស់បំផុតស្មើគ្នា នៅពេល គធ.ខប បែងចែកអាសនៈរួច

ប្រការ៤.៨.

ក្នុងករណីដែលការគណនាតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដូចមានចែងក្នុងចំណុច ៤.៦.៣.៥ ចំណុច ៤.៧.៤.៣ និងចំណុច ៤.៧.៥.៣ ខាងលើនេះ មានលទ្ធផលស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន នោះការបែងចែកអាសនៈត្រូវកំណត់ដូចខាងក្រោម៖

៤.៨.១ ក្នុងករណីអាសនៈនៅសល់បន្ទាប់ពីការបែងចែកលើកទី១ តាមរូបមន្តដំហានទី២ មានចំនួនស្មើ ឬលើសពីចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា គធ.ខប ត្រូវផ្តល់ឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងនោះ ដោយមួយគណបក្សទទួលបាន ១ (មួយ) អាសនៈដូចគ្នា។

ឧទាហរណ៍ : នៅមណ្ឌលបោះឆ្នោតនៃសង្កាត់ C មាន៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយ = ៧
- សន្លឹកឆ្នោតបានការសរុប ($ស_{ស}$) = ៥ ៧៣២
- អាសនៈសរុប ($អ_{ស}$) = ៩ អាសនៈ
- កូតា ($ក_{ត}$) = ៦៣៦



បញ្ជីបេក្ខជននៃគណបក្ស	សប	អ១	ម១	អ២	ម២	អ៣
ក	៨៩២	**១**	$\frac{\text{៨៩២}}{\text{១+១}}$ = ៤៤៦,០០	០	$\frac{\text{៨៩២}}{\text{១+១}}$ = ៤៤៦,០០	០
ខ	៤៨៩	០	$\frac{\text{៤៨៩}}{\text{០+១}}$ = **៤៨៩,០០**	**១**	$\frac{\text{៤៨៩}}{\text{១+១}}$ = ២៤៤,៥០	០
គ	៣៥៧	០	$\frac{\text{៣៥៧}}{\text{០+១}}$ = ៣៥៧,០០	០	$\frac{\text{៣៥៧}}{\text{០+១}}$ = ៣៥៧,០០	០
ឃ	៣៩៥	០	$\frac{\text{៣៩៥}}{\text{០+១}}$ = ៣៩៥,០០	០	$\frac{\text{៣៩៥}}{\text{០+១}}$ = ៣៩៥,០០	០
ង	១ ៣៥២	**២**	$\frac{\text{១ ៣៥២}}{\text{២+១}}$ = ៤៥០,៦៦	០	$\frac{\text{១ ៣៥២}}{\text{២+១}}$ = **៤៥០,៦៦**	**១**
ច	១ ៩៥៦	**៣**	$\frac{\text{១ ៩៥៦}}{\text{៣+១}}$ = **៤៨៩,០០**	**១**	$\frac{\text{១ ៩៥៦}}{\text{៤+១}}$ = ៣៩១,២០	០
ឆ	២៩១	០	$\frac{\text{២៩១}}{\text{០+១}}$ = ២៩១,០០	០	$\frac{\text{២៩១}}{\text{០+១}}$ = ២៩១,០០	០

- សប តាងសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ
- អ១ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២ នៃចំណុច ៤.៦.៣.៣ ខាងលើនេះ ក្នុងនោះ៖
  - បញ្ជីបេក្ខជននៃគណបក្ស **ក** ទទួលបាន ១ (មួយ) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្ស **ង** ទទួលបាន ២ (ពីរ) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្ស **ច** ទទួលបាន ៣ (បី) អាសនៈ។
- ម១ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ តាមរូបមន្តជំហានទី៣ នៃចំណុច ៤.៦.៣.៥ ខាងលើនេះ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះ បញ្ជីបេក្ខជននៃគណបក្ស **ខ** និងគណបក្ស **ច** មានមធ្យមភាគធំជាងគេស្មើគ្នាគឺ **៤៨៩,០០** ដែលជាមធ្យមភាគខ្ពស់បំផុត
- អ២ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី២។ អនុវត្តតាមចំណុច ៤.៨.១ ខាងលើនេះ គជ.ខប ត្រូវផ្តល់អាសនៈឱ្យទៅបញ្ជីបេក្ខជននៃគណបក្ស **ខ** និងគណបក្ស **ច** ដោយមួយគណបក្សទទួលបាន ១ (មួយ) អាសនៈស្មើគ្នា

- $ม_{ជ}$២ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី២ តាមរូបមន្តដំហានទី៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ង** មានមធ្យមភាគធំជាងគេគឺ **៤៥០,៦៦** ដែលជាមធ្យមភាគខ្ពស់បំផុត
- $អ_{ទ}$៣ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី៣ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ង** ត្រូវទទួលបានអាសនៈដែលនៅសល់ ១ (មួយ) ចុងក្រោយនេះ។

ជាលទ្ធផលសម្រេចនៅមណ្ឌលបោះឆ្នោតនៃ សង្កាត់ C គឺ៖

បញ្ជីបេក្ខជននៃគណបក្ស **ក** ទទួលបាន ១ (មួយ) អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ខ** ទទួលបាន ១ (មួយ) អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ង** ទទួលបាន ៣ (បី) អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **ច** ទទួលបាន ៤ (បួន) អាសនៈ

បញ្ជីបេក្ខជននៃគណបក្ស **គ** គណបក្ស **ឃ** និងគណបក្ស **ឆ** ពុំបានទទួលអាសនៈ។

សរុប = ៩ (ប្រាំបួន) អាសនៈ។


៤.៨.២ ក្នុងករណីអាសនៈនៅសល់មានចំនួនតិចជាងចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា គធ.ខប ត្រូវអនុវត្តវិធីចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈនោះ។

ឧទាហរណ៍ : នៅមណ្ឌលបោះឆ្នោតនៃឃុំ D មាន៖

- ចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយ = ៥
- ចំនួនសន្លឹកឆ្នោតបានការសរុប ($ស_{ស}$) = ៧ ៩៦៣
- ចំនួនអាសនៈសរុប ($អ_{ស}$) = ១១ អាសនៈ
- កូតា ($ក_{ត}$) = ៧២៣

បញ្ជីបេក្ខជននៃគណបក្ស	$ស_{ប}$	$អ_{ទ១}$	$ម_{ធ១}$	$អ_{ទ២}$	$ម_{ធ២}$	$អ_{ទ៣}$
ក	១ ០២៥	**១**	$\frac{\text{១ ០២៥}}{\text{១+១}} = \text{៥១២,៥០}$	០	$\frac{\text{១ ០២៥}}{\text{១+១}} = \text{៥១២,៥០}$	
ខ	៧៧៤	**១**	$\frac{\text{៧៧៤}}{\text{១+១}} = \text{៣៨៧,០០}$	០	$\frac{\text{៧៧៤}}{\text{១+១}} = \text{៣៨៧,០០}$	
គ	១ ៨១៧	**២**	$\frac{\text{១ ៨១៧}}{\text{២+១}} = \text{៦០៥,៦៦}$	០	$\frac{\text{១ ៨១៧}}{\text{២+១}} = \mathbf{\text{៦០៥,៦៦}}$	**?**
ឃ	៧១៣	០	$\frac{\text{៧១៣}}{\text{០+១}} = \text{៧១៣,០០}$	**១**	$\frac{\text{៧១៣}}{\text{១+១}} = \text{៣៥៦,៥០}$	
ង	៣ ៦៣៤	**៥**	$\frac{\text{៣ ៦៣៤}}{\text{៥+១}} = \text{៦០៥,៦៦}$	០	$\frac{\text{៣ ៦៣៤}}{\text{៥+១}} = \mathbf{\text{៦០៥,៦៦}}$	**?**

- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ
- $អ_{ទ១}$ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ តាមរូបមន្តដំហានទី២ ក្នុងនោះ៖
  - បញ្ជីបេក្ខជននៃគណបក្ស **ក** ទទួលបាន ១ (មួយ) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្ស **ខ** ទទួលបាន ១ (មួយ) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្ស **គ** ទទួលបាន ២ (ពីរ) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្ស **ង** ទទួលបាន ៥ (ប្រាំ) អាសនៈ។
- $ម_{ធ១}$ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ តាមរូបមន្តដំហានទី៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ឃ** មានមធ្យមភាគធំជាងគេគឺ **៧១៣,០០** ដែលជាមធ្យមភាគខ្ពស់បំផុត
- $អ_{ទ២}$ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី២ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ឃ** ត្រូវទទួលបាន ១ (មួយ) អាសនៈ



- $м_{ជ}$២ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី២ តាមរូបមន្តដំហានទី៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ត** និងគណបក្ស **ង** មានមធ្យមភាគធំជាងគេស្មើគ្នាគឺ **៦០៥,៦៦** ដែលជាមធ្យមភាគខ្ពស់បំផុត
- $អ_{ទ}$៣ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី៣ ដែលក្នុងនោះចំនួនអាសនៈនៅសល់មានតែ ១ (មួយ) តិចជាងចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា។ អនុវត្តតាមចំណុច ៤.៨.២ នេះ គជ.ខប ត្រូវរៀបចំការចាប់ឆ្នោតជាសាធារណៈដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលត្រូវទទួលបានអាសនៈនៅសល់ ១ (មួយ) ចុងក្រោយនេះ។

ការចាប់ឆ្នោតជាសាធារណៈដើម្បីទទួលបានអាសនៈ

ប្រការ៤.៩.

ក្នុងករណីដូចមានចែងក្នុងចំណុច ៤.៨.២ ខាងលើនេះ គជ.ខប ត្រូវអនុវត្តនូវនីតិវិធីចាប់ឆ្នោតជាសាធារណៈដើម្បីកំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលត្រូវទទួលបានអាសនៈនៅសល់នេះ។

៤.៩.១ ក្នុងករណីបែបនេះ គជ.ខប ត្រូវប្រគល់ភារកិច្ចឱ្យមន្ត្រីនៅផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេសចាត់ចែងរៀបចំការចាប់ឆ្នោតជាសាធារណៈ។

៤.៩.២ ពិធីចាប់ឆ្នោតជាសាធារណៈត្រូវធ្វើនៅ លគជ.ខប ក្រោយពេលបញ្ចប់ការបែងចែកអាសនៈនៅតាមមណ្ឌលបោះឆ្នោតនៃឃុំ សង្កាត់ផ្សេងទៀតក្នុងរាជធានី ខេត្តពាក់ព័ន្ធ។

៤.៩.២.១ គជ.ខប ត្រូវកំណត់ទីកន្លែង ពេលវេលា និងកម្មវិធីនៃការចាប់ឆ្នោត ហើយត្រូវអញ្ជើញអ្នកពាក់ព័ន្ធដើម្បីចូលរួមក្នុងពិធីចាប់ឆ្នោតរួមមាន៖

- តំណាងផ្លូវការនៃគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា
- តំណាងផ្លូវការនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ
- អ្នកសង្កេតការណ៍បោះឆ្នោត។

៤.៩.២.២ ពិធីចាប់ឆ្នោតត្រូវអនុវត្តតាមដំហានដូចខាងក្រោម៖

- មន្ត្រីនៅផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេសត្រូវសរសេរឬបោះពុម្ពនៅលើក្រដាសដែលមានប្រភេទ ទំហំ និងពណ៌ដូចគ្នានូវឈ្មោះនៃគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាស្មើគ្នា

- ក្រដាសសន្លឹកឆ្នោតមួយសន្លឹកត្រូវសរសេរ ឬបោះពុម្ពឈ្មោះតែមួយគណបក្សនយោបាយប៉ុណ្ណោះ។ តួអក្សរជាឈ្មោះរបស់គណបក្សនយោបាយត្រូវមានប្រភេទ ទំហំ និងពណ៌ដូចគ្នា។ ក្រដាសសន្លឹកឆ្នោតដែលសរសេរ ឬបោះពុម្ពឈ្មោះរបស់គណបក្សនយោបាយរួចហើយ ត្រូវបត់ជាផ្នត់ដូចគ្នាជាក់ក្នុងស្រោមសំបុត្រដែលមានប្រភេទ ពណ៌ និងទំហំដូចគ្នា រួចបិទភ្ជិតដោយមូរ និងចងកៅស៊ូកងពណ៌ដូចគ្នា
- មន្ត្រីនៅផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេសត្រូវបង្ហាញកេសឆ្នោតទទេជាសាធារណៈ មុននឹងដាក់សំបុត្រសន្លឹកឆ្នោតចូលទៅក្នុងកេសនោះ និងបិទគម្រប
- មន្ត្រីនៅផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេសត្រូវក្រឡុកកេសឆ្នោត រួចលើកកេសឆ្នោតនោះទៅដាក់លើតុខ្ពស់
- តំណាង គធ.ខប ដែលត្រូវបានចាត់តាំងត្រូវចាប់យកសំបុត្រសន្លឹកឆ្នោត ១ (មួយ) ពីក្នុងកេសនោះ រួចជូនទៅប្រធាន គធ.ខប ឬតំណាង
- ប្រធាន គធ.ខប ឬតំណាងត្រូវបើកស្រោមសំបុត្រនោះជាសាធារណៈ រួចអានប្រកាសឈ្មោះគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈ និងលើកបង្ហាញឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតទាំងអស់ដែលចូលរួមបានឃើញ និងប្រាកដថាឈ្មោះគណបក្សដែលបានប្រកាសដូចគ្នានឹងឈ្មោះរបស់គណបក្សដែលបានសរសេរ ឬបោះពុម្ពនៅលើសន្លឹកឆ្នោតនោះមែន។

៤.៩.២.៣ មន្ត្រីនៅផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេសត្រូវធ្វើកំណត់ហេតុនៃការចាប់ឆ្នោត ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងតំណាងចូលរួម (គធ.ខប តំណាងគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា អ្នកសង្កេតការណ៍បោះឆ្នោត ជាអាទិ៍) ដំណើរការចាប់ឆ្នោតនិងលទ្ធផលនៃការចាប់ឆ្នោត។

៤.៩.២.៤ កំណត់ហេតុត្រូវចុះហត្ថលេខាដោយ៖

- អ្នកធ្វើកំណត់ហេតុ
- ប្រធាន គធ.ខប ឬតំណាងដែលត្រូវបានចាត់តាំង
- តំណាងគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា។

៤.៩.២.៥ កំណត់ហេតុត្រូវធ្វើតាមតម្រូវការដូចខាងក្រោម៖

- ធ្វើជូន គ.ជ.ប ១ (មួយ) ច្បាប់
- ធ្វើជូនទៅគ្រប់គណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ការចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈក្នុង កបយ.ស នៅពេលដែល គធ.ខប ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត

ប្រការ៤.១០.

នៅពេល គធ.ខប ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបយ.ស ស្របតាមប្រការ៤.១១ ខាងក្រោមនេះ ប្រសិនបើគណបក្សនយោបាយណាដែលត្រូវទទួលបានអាសនៈក្នុង កបយ.ស ហើយបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយនោះមានបេក្ខជនបាត់សញ្ជាតិខ្មែរ ទទួលមរណភាព បាត់បង់សម្បទាវិជ្ជាជីវៈ លាលែងជាលាយលក្ខណ៍អក្សរ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ឬបាត់បង់សមាជិកភាពពីគណបក្សនយោបាយ គណបក្សនយោបាយសាមីត្រូវធ្វើលិខិតជូនដំណឹងជាបន្ទាន់ទៅ គធ.ខប ពាក់ព័ន្ធឱ្យបានមុនថ្ងៃ គធ.ខប ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបយ.ស ដើម្បី គធ.ខប ចាត់ចែងអនុវត្តនីតិវិធី។ គធ.ខប ត្រូវចត់ចម្លងលិខិតជូនដំណឹងនេះ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ជាបន្ទាន់។

៤.១០.១ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីគណបក្សនយោបាយសាមី គធ.ខប ត្រូវធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់អំពីចំនួនបេក្ខជននៅសល់ក្នុងបញ្ជី ដើម្បីបញ្ជាក់ឱ្យបានប្រាកដថាបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះមានបេក្ខជនគ្រប់ចំនួនអាសនៈដែលគណបក្សត្រូវទទួលបានដែរទេ។ ក្នុងករណី គធ.ខប ពិនិត្យឃើញ៖

៤.១០.១.១ បញ្ជីបេក្ខជននៃគណបក្សនយោបាយមានបេក្ខជននៅសល់គ្រប់ចំនួនអាសនៈ គធ.ខប ត្រូវឆូតលុបឈ្មោះបេក្ខជនដែលបាត់សញ្ជាតិខ្មែរ ទទួលមរណភាព បាត់បង់សម្បទាវិជ្ជាជីវៈ លាលែងជាលាយលក្ខណ៍អក្សរ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ឬបាត់បង់សមាជិកភាពពីគណបក្សនយោបាយនៅលើបញ្ជីរាយនាមបេក្ខជនដែលរក្សាទុកនៅ គធ.ខប និងបោះត្រា គធ.ខប រួចចត់ចម្លងផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់។ ករណីនេះ គធ.ខប ត្រូវអនុវត្តតាមប្រការ៤.១១ ខាងក្រោមនេះ។

៤.១០.១.២ បញ្ជីបេក្ខជននៃគណបក្សនយោបាយនោះមានបេក្ខជនមិនគ្រប់តាមចំនួនអាសនៈ ដែលគណបក្សនយោបាយត្រូវទទួលបាននៅក្នុងឃុំ សង្កាត់នោះ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងជាបន្ទាន់ទៅ គ.ជ.ប ដើម្បី គ.ជ.ប ជូនដំណឹងទៅគណបក្សនយោបាយសាមីឱ្យមកដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយនៅ គ.ជ.ប

ក្នុងរយៈពេល ១០ (ដប់) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង។ ក្នុងករណីគណបក្សនយោបាយមិនបានអនុវត្តតាមពេលវេលាកំណត់នេះ ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកថាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ ហើយ គ.ជ.ប នឹងចាត់ចែងអនុវត្តតាមមាត្រា២០ថ្មី នៃ ច.ប.ឃ.ស និងបញ្ញត្តិដូចមានចែងក្នុងប្រការ៤.៧ នៃ ប.ន.ឃ.ស នេះ។

៤.១០.២ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គ.ជ.ប (ទ.១០០៨ប) ចំនួន ២ (ពីរ) ច្បាប់។ ពាក្យសុំនេះត្រូវបានផ្តល់ដោយឥតគិតថ្លៃជូនគណបក្សនយោបាយដែលមានបំណងចុះបញ្ជីបេក្ខជនបម្រុងបន្ថែម។

៤.១០.៣ ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គ.ជ.ប (ទ.១០០៨ប) ត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ។ ការផ្ទេរសិទ្ធិនេះមិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។

៤.១០.៤ ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គ.ជ.ប (ទ.១០០៨ប) ត្រូវភ្ជាប់មកជាមួយនូវ៖

៤.១០.៤.១ បញ្ជីរាយនាមបេក្ខជនបម្រុងបន្ថែមចំនួន ៥ (ប្រាំ) ច្បាប់។ គណបក្សនយោបាយសាមីមិនត្រូវស្រង់ឈ្មោះបេក្ខជនដែលនៅសល់ក្នុងបញ្ជីបេក្ខជនផ្លូវការដាក់បញ្ចូលក្នុងបញ្ជីរាយនាមបេក្ខជនបម្រុងបន្ថែមនេះទេ។

៤.១០.៤.២ លិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់ថាពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោតដោយបញ្ជាក់ឱ្យបានច្បាស់អំពីនាមត្រកូល នាមខ្លួន និងអាសយដ្ឋាន។

៤.១០.៤.៣ ជីវប្រវត្តិសង្ខេប និងសេចក្តីប្រកាសយល់ព្រមឈរឈ្មោះរបស់បេក្ខជនដែលត្រូវបំពេញដោយផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ មានបិទរូបថត និងរូបថតបេក្ខជនម្នាក់ៗចំនួន ៣ (បី) សន្លឹកទៀត ដែលមានទំហំ ៤ x ៦ ថតចំពីមុខតាមគំរូរូបថតធ្វើ អ.ខ។

៤.១០.៥ ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

៤.១០.៥.១ មានសញ្ជាតិខ្មែរពីកំណើត។

៤.១០.៥.២ ចេះអាន និងសរសេរអក្សរខ្មែរ។

៤.១០.៥.៣ បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត។

៤.១០.៥.៤ មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំគិតមកទល់ថ្ងៃបោះឆ្នោត។

៤.១០.៥.៥ បានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលលើកចុងក្រោយដែលរៀបចំឡើងដោយ គ.ជ.ប លើកលែងតែករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះមានមូលហេតុសមស្របដូចមានចែងក្នុងប្រការ៦.២ នៃ ប.ន.ឃ.ស នេះ។

៤.១០.៥.៦ មិនត្រូវមានឈ្មោះនៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេង។

៤.១០.៦ ហាមឈរឈ្មោះជាបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ៖

៤.១០.៦.១ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិករាជរដ្ឋាភិបាល និងចៅក្រម។

៤.១០.៦.២ អភិបាល ឬអភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៤.១០.៦.៣ សមាជិក គ.ជ.ប គធ.ខប គឃ.សប គ.ក.ប/គ.ក.រ បុគ្គលិកបម្រើការងារក្នុង គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

៤.១០.៦.៤ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង។

៤.១០.៦.៥ ព្រះសង្ឃ ឬបព្វជិតសាសនានៃសាសនាណាមួយ។

៤.១០.៦.៦ ស្មៀនឃុំ សង្កាត់ណាមួយ។

៤.១០.៧ ចំពោះបេក្ខជនជាមន្ត្រីរាជការស៊ីវិលមន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ នៅពេលជាប់ឆ្នោតជាសមាជិក កបឃ.ស ត្រូវរៀបចំបែបបទដូចមានចែងក្នុងចំណុច ៦.៤.១ នៃ ប.ន.ឃ.ស នេះ។

៤.១០.៨ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គ.ជ.ប (ទ.១០០៨ប)។

៤.១០.៨.១ ក្នុងករណីគណបក្សនយោបាយបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ៤.១០.២ ចំណុច ៤.១០.៣ ចំណុច ៤.១០.៤ ចំណុច ៤.១០.៥ និងចំណុច ៤.១០.៦ ខាងលើនេះ គ.ជ.ប ត្រូវសម្រេចយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនោះ ដោយត្រូវបំពេញលើពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គ.ជ.ប (ទ.១០០៨ប) ទាំង ២ (ពីរ) ច្បាប់ ដោយចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប រួចផ្ញើជូនគណបក្សនយោបាយសាមី ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៤.១០.៨.២ ក្នុងករណីគណបក្សនយោបាយបំពេញមិនបានត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ៤.១០.២ ចំណុច ៤.១០.៣ ចំណុច ៤.១០.៤ ចំណុច ៤.១០.៥ និងចំណុច ៤.១០.៦ ខាងលើនេះ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹង និងណែនាំដល់គណបក្សនយោបាយនោះឱ្យធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង។

៤.១០.៨.២.១ ក្នុងករណីគណបក្សនយោបាយបានកែតម្រូវចំណុចខ្វះខាតបានត្រឹមត្រូវ និងទាន់ពេលវេលា គ.ជ.ប ត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនោះ ក្នុងរយៈពេល ១ (មួយ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំដែលបានកែតម្រូវរួចហើយ។

៤.១០.៨.២.២ ក្នុងករណីគណបក្សនយោបាយមិនបានកែតម្រូវចំណុចខ្វះខាតតាមលក្ខខណ្ឌ និងពេលវេលាដូចមានចែងក្នុងចំណុច ៤.១០.៨.២ ខាងលើនេះទេ គ.ជ.ប ត្រូវបដិសេធបេក្ខភាពដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់នោះតែប៉ុណ្ណោះ។ សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ។

៤.១០.៩ បន្ទាប់ពីការពិនិត្យ និងសម្រេចលើពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ រួចហើយ គ.ជ.ប ត្រូវចាត់ឱ្យ គធ.ខប បិទផ្សាយបញ្ជីបេក្ខជនបម្រុងបន្ថែមដំបូងនៅសាលាឃុំ សង្កាត់ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចយល់ព្រម។

៤.១០.១០ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនបម្រុងបន្ថែមដំបូង ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ។

៤.១០.១១ គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។ សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ។

៤.១០.១២ ប្រសិនបើគ្មានពាក្យបណ្តឹងជំទាស់លើបញ្ជីបេក្ខជនបម្រុងបន្ថែមដំបូង ឬការប្តឹងជំទាស់ត្រូវបានដោះស្រាយចប់ បញ្ជីបេក្ខជនបម្រុងបន្ថែមដំបូងនឹងក្លាយជាបញ្ជីបេក្ខជនបម្រុងបន្ថែមផ្លូវការ។ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជនបម្រុងបន្ថែមនៅក្នុងបញ្ជីនេះមិនអាចកែប្រែបានឡើយ។

៤.១០.១៣ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងទៅក្រសួងមហាផ្ទៃ ដោយភ្ជាប់ជាមួយនូវបញ្ជីបេក្ខជនបម្រុងបន្ថែមផ្លូវការខាងលើនេះ។

៤.១០.១៤ គធ.ខប ឬ/និង គ.ជ.ប ត្រូវចាត់ចែងអនុវត្តការស្រង់ឈ្មោះបេក្ខជនដែលត្រូវដាប់ឆ្នោតជាសមាជិក កបយ.ស តាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ៤.១១ ខាងក្រោមនេះ។

ការស្រង់ឈ្មោះបេក្ខជនដាប់ឆ្នោតជាសមាជិក កបយ.ស

ប្រការ៤.១១.-

បន្ទាប់ពីបានធ្វើការគណនាកំណត់ចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួលហើយ គធ.ខប ត្រូវស្រង់ឈ្មោះបេក្ខជនដាប់ឆ្នោតជាសមាជិក កបយ.ស តាមលក្ខខណ្ឌដូចខាងក្រោម៖

៤.១១.១ ឈ្មោះបេក្ខជនដាប់ឆ្នោតទាំងអស់ត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលដាប់ឆ្នោត។ ចំនួនឈ្មោះបេក្ខជនដាប់ឆ្នោតដែលត្រូវស្រង់ត្រូវស្មើគ្នានឹងចំនួនអាសនៈដែលបានកំណត់ដោយអនុក្រឹត្យ។

៤.១១.២ ឈ្មោះបេក្ខជនដាប់ឆ្នោតត្រូវស្រង់តាមលំដាប់លេខរៀងពីលើមកក្រោម តាមបញ្ជីបេក្ខជននៃគណបក្សនយោបាយដាប់ឆ្នោតនីមួយៗ។

៤.១១.៣ ក្នុងករណីនៅឃុំ សង្កាត់មួយមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតែមួយគត់ដែលត្រូវបានយល់ព្រមឱ្យចុះបញ្ជីដូចមានចែងក្នុងចំណុច ៤.៦.១ នៃ ប.ន.ឃ.ស នេះ ឬមានបញ្ជីបេក្ខជនតែមួយគត់ជាប់ឆ្នោត ឈ្មោះបេក្ខជនត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយនោះតាមលំដាប់លេខរៀងពីលើមកក្រោម រហូតដល់គ្រប់អាសនៈក្នុងក្រុមប្រឹក្សា។

៤.១១.៤ ឈ្មោះបេក្ខជនណាដែលបានស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតក្នុងឃុំ សង្កាត់ និងត្រូវបានតែងតាំងជាសមាជិក កបយ.ស រួចហើយ បេក្ខជននោះត្រូវលុបឈ្មោះចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ។

ការកំណត់ឈ្មោះសមាជិក កបយ.ស ជាប្រធាន កបយ.ស ជាមេឃុំ ឬចៅសង្កាត់ ដំទប់ទី១ ឬចៅសង្កាត់រងទី១ និងដំទប់ទី២ ឬចៅសង្កាត់រងទី២

ប្រការ៤.១២.

បន្ទាប់ពីបានកំណត់ចំនួនអាសនៈតាមប្រការ៤.៦ ប្រការ៤.៧ ប្រការ៤.៨ និងប្រការ៤.៩ នៃ ប.ន.ឃ.ស នេះ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតតាមប្រការ៤.១១ ខាងលើនេះហើយ គធ.ខប ត្រូវកំណត់ឈ្មោះសមាជិក កបយ.ស ដែលទទួលតំណែងជាប្រធាន កបយ.ស ជាមេឃុំ ឬចៅសង្កាត់ ដំទប់ទី១ ឬចៅសង្កាត់រងទី១ និងដំទប់ទី២ ឬចៅសង្កាត់រងទី២ តាមលក្ខខណ្ឌដូចមានចែងក្នុង ច.គ.ឃ.ស ដូចខាងក្រោម៖

៤.១២.១ ប្រធាន កបយ.ស ដែលជាមេឃុំ ឬចៅសង្កាត់ ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសំឡេងឆ្នោតច្រើនជាងគេបង្អស់។

៤.១២.២ ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិក កបយ.ស ណាបានផ្តល់សំឡេងគាំទ្រដល់បញ្ជីបេក្ខជនណាមួយបានសំឡេងឆ្នោតភាគច្រើនពីរភាគបីនៃសំឡេងឆ្នោតសរុប ត្រូវជ្រើសរើសសមាជិក កបយ.ស ពីក្នុងបញ្ជីបេក្ខជននោះ ឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ដំទប់ទី១ ឬចៅសង្កាត់រងទី១ និងដំទប់ទី២ ឬចៅសង្កាត់រងទី២ តាមលំដាប់លេខរៀងបន្តបន្ទាប់។

៤.១២.៣ ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិក កបយ.ស ណាមិនមានបញ្ជីបេក្ខជនណាមួយទទួលបានសំឡេងឆ្នោតភាគច្រើនពីរភាគបីនៃសំឡេងឆ្នោតសរុបទេ ការជ្រើសរើសមេឃុំ ឬចៅសង្កាត់ ដំទប់ទី១ ឬចៅសង្កាត់រងទី១ និងដំទប់ទី២ ឬចៅសង្កាត់រងទី២ ត្រូវអនុវត្តដូចខាងក្រោម៖

៤.១២.៣.១ ត្រូវជ្រើសរើសសមាជិក កបយ.ស ដែលមានឈ្មោះលេខរៀងលើគេបង្អស់ និងលេខរៀងបន្ទាប់ពីបញ្ជីបេក្ខជនដែលទទួលបានសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃសំឡេងឆ្នោតសរុប ឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ និងដំទប់ទី១ ឬចៅសង្កាត់រងទី១។

៤.១២.៣.២ ត្រូវជ្រើសរើសសមាជិក កបយ.ស ដែលមានឈ្មោះលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលទទួលបានសំឡេងឆ្នោតលំដាប់ទី២ ឱ្យទទួលតំណែងជាជំទប់ទី២ ឬចៅសង្កាត់រងទី២។

៤.១២.៤ ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិក កបយ.ស ណាមិនមានបញ្ជីបេក្ខជនណាមួយទទួលបានសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃសំឡេងឆ្នោតសរុបទេ ការជ្រើសរើសមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ត្រូវអនុវត្តដូចខាងក្រោម៖

៤.១២.៤.១ ត្រូវជ្រើសរើសសមាជិក កបយ.ស ដែលមានឈ្មោះលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេបង្អស់ ឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់។

៤.១២.៤.២ ត្រូវជ្រើសរើសសមាជិក កបយ.ស ដែលមានឈ្មោះលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសំឡេងឆ្នោតលំដាប់ទី២ ឱ្យទទួលតំណែងជាជំទប់ទី១ ឬចៅសង្កាត់រងទី១។

៤.១២.៤.៣ ត្រូវជ្រើសរើសសមាជិក កបយ.ស ដែលមានឈ្មោះលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសំឡេងឆ្នោតលំដាប់ទី៣ ឱ្យទទួលតំណែងជាជំទប់ទី២ ឬចៅសង្កាត់រងទី២។ ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិក កបយ.ស បានផ្តល់សំឡេងគាំទ្រដល់បញ្ជីបេក្ខជនតែ២(ពីរ)ដែលមានលក្ខណសម្បត្តិទទួលបានអាសនៈក្នុង កបយ.ស ត្រូវជ្រើសរើសសមាជិក កបយ.ស ជាបេក្ខជនដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីបេក្ខជនដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេបង្អស់ ឱ្យទទួលតំណែងជាជំទប់ទី២ ឬចៅសង្កាត់រងទី២។

៤.១២.៥ ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិក កបយ.ស ណាមានបញ្ជីបេក្ខជន ២ (ពីរ) ឬច្រើនបានទទួលសំឡេងឆ្នោតស្មើគ្នា ការជ្រើសរើសមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ត្រូវអនុវត្តដូចខាងក្រោម៖

៤.១២.៥.១ ពិនិត្យមើលចំនួនអាសនៈរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានអាសនៈច្រើនជាងជាអ្នកឈ្នះ។

៤.១២.៥.២ ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងនោះមានសំឡេងឆ្នោតនិងចំនួនអាសនៈស្មើគ្នា គជ.ខប ត្រូវរៀបចំការចាប់ឆ្នោតជាសាធារណៈចំនួន ១ (មួយ) លើក ឬលើសពីមួយលើកតាមលំនាំដូចមានចែងក្នុងប្រការ៤.៩ នៃ ប.ន.ឃ.ស នេះ ដោយផ្អែកលើករណីជាក់ស្តែងនីមួយៗ។

៤.១២.៥.៣ បន្ទាប់ពីបានអនុវត្តចំណុច ៤.១២.៥.១ ឬចំណុច ៤.១២.៥.២ ខាងលើនេះ គជ.ខប ត្រូវកំណត់ឈ្មោះសមាជិក កបឃ.ស ឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ តាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ៤.១២.៣ និងចំណុច ៤.១២.៤ ខាងលើនេះ។

៤.១២.៦ ការរកចំនួនសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតភាគច្រើនពីរភាគបី ឬសំឡេងឆ្នោតភាគច្រើនជាច់ខាតនៃសំឡេងឆ្នោតសរុប ត្រូវអនុវត្តដូចខាងក្រោម៖

៤.១២.៦.១ ប្រសិនបើសំឡេងឆ្នោតរបស់បញ្ជីបេក្ខជនណាមួយមានចំនួនស្មើ ឬច្រើនជាងលទ្ធផលដែលបានមកពីការយកសំឡេងឆ្នោតសរុបគុណនឹង ២ ចែកនឹង ៣ បញ្ជីបេក្ខជននោះត្រូវបានកំណត់ថាទទួលបានសំឡេងឆ្នោតភាគច្រើនពីរភាគបី។

ឧទាហរណ៍ទី១ : នៅមណ្ឌលបោះឆ្នោតនៃឃុំ A មាន៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន ៣ ក្នុងនោះ បញ្ជីបេក្ខជននៃគណបក្ស **ក** មានសំឡេងឆ្នោត ១ ៣៥១
- សំឡេងឆ្នោតសរុប = ២ ០២៦
- ការគណនារកសំឡេងឆ្នោតភាគច្រើនពីរភាគបី

$$\frac{\text{២ ០២៦ x ២}}{\text{៣}} = \text{ ១ ៣៥០,៦៦}$$

- បញ្ជីបេក្ខជននៃគណបក្ស **ក** មានសំឡេងឆ្នោត ១ ៣៥១ ដែលច្រើនជាង ១ ៣៥០,៦៦ នាំឱ្យបញ្ជីបេក្ខជននៃគណបក្សនេះទទួលបានសំឡេងឆ្នោតភាគច្រើនពីរភាគបី។

ឧទាហរណ៍ទី២ : នៅមណ្ឌលបោះឆ្នោតនៃឃុំ B មាន៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន ៣ ក្នុងនោះ បញ្ជីបេក្ខជននៃគណបក្ស **ខ** មានសំឡេងឆ្នោត ១ ៥០០
- សំឡេងឆ្នោតសរុប = ២ ២៥០
- ការគណនារកសំឡេងឆ្នោតភាគច្រើនពីរភាគបី

$$\frac{\text{២ ២៥០ x ២}}{\text{៣}} = \text{ ១ ៥០០}$$

- បញ្ជីបេក្ខជននៃគណបក្ស **ខ** មានសំឡេងឆ្នោត ១ ៥០០ ដែលស្មើនឹង ១ ៥០០ នាំឱ្យបញ្ជីបេក្ខជននៃគណបក្សនេះទទួលបានសំឡេងឆ្នោតភាគច្រើនពីរភាគបី។

ឧទាហរណ៍ទី៣ : នៅមណ្ឌលបោះឆ្នោតនៃឃុំ C មាន៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន ៣ ក្នុងនោះ បញ្ជីបេក្ខជននៃគណបក្ស **គ** មានសំឡេងឆ្នោត ១ ៥៦៣
- សំឡេងឆ្នោតសរុប = ២ ៣៤៥
- ការគណនារកសំឡេងឆ្នោតភាគច្រើនពីរភាគបី

$$\frac{\text{២ ៣៤៥ x ២}}{\text{៣}} = \text{ ១ ៥៦៣,៣៣}$$

- បញ្ជីបេក្ខជននៃគណបក្ស **គ** មានសំឡេងឆ្នោត ១ ៥៦៣ ដែលតិចជាង ១ ៥៦៣,៣៣ នាំឱ្យបញ្ជីបេក្ខជននៃគណបក្សនេះមិនទទួលបានសំឡេងឆ្នោតភាគច្រើនពីរភាគបីទេ។

៤.១២.៦.២ ប្រសិនបើសំឡេងឆ្នោតរបស់បញ្ជីបេក្ខជនណាមួយមានចំនួនច្រើនជាងលទ្ធផលដែលបានមកពីការយកសំឡេងឆ្នោតសរុប ចែកនឹង ២ បញ្ជីបេក្ខជននោះត្រូវបានកំណត់ថាទទួលបានសំឡេងឆ្នោតភាគច្រើនដាច់ខាត។

ឧទាហរណ៍ទី១ : នៅមណ្ឌលបោះឆ្នោតនៃឃុំ D មាន៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន ៣ ក្នុងនោះ បញ្ជីបេក្ខជននៃគណបក្ស **ឃ** មានសំឡេងឆ្នោត ១ ១១៩
- សំឡេងឆ្នោតសរុប = ២ ២៣៧
- ការគណនារកសំឡេងឆ្នោតភាគច្រើនដាច់ខាត

$$\frac{\text{២ ២៣៧}}{\text{២}} = \text{ ១ ១១៨,៥០}$$

- បញ្ជីបេក្ខជននៃគណបក្ស **ឃ** មានសំឡេងឆ្នោត ១ ១១៩ ដែលច្រើនជាង ១ ១១៨,៥០ នាំឱ្យបញ្ជីបេក្ខជននៃគណបក្សនេះទទួលបានសំឡេងឆ្នោតភាគច្រើនដាច់ខាត។

ឧទាហរណ៍ទី២ : នៅមណ្ឌលបោះឆ្នោតនៃឃុំ E មាន៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន ៣ ក្នុងនោះ បញ្ជីបេក្ខជននៃគណបក្ស **ង** មានសំឡេងឆ្នោត ១ ២២៩
- សំឡេងឆ្នោតសរុប = ២ ៤៥៨
- ការគណនារកសំឡេងឆ្នោតភាគច្រើនដាច់ខាត

$$\frac{\text{២ ៤៥៨}}{\text{២}} = \text{ ១ ២២៩}$$

- បញ្ជីបេក្ខជននៃគណបក្ស **ង** មានសំឡេងឆ្នោត ១ ២២៩ ដែលស្មើនឹង ១ ២២៩ នាំឱ្យបញ្ជីបេក្ខជននៃគណបក្សនេះមិនទទួលបានសំឡេងឆ្នោតភាគច្រើនដាច់ខាតទេ។

៤.១២.៧ ក្នុងករណីដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតនៅក្នុងឃុំ សង្កាត់ណាមួយមានចំនួនអាសនៈស្មើគ្នាទាំងអស់ដូចមានក្នុងឧទាហរណ៍ក្នុងចំណុច ៤.៦.៣.៨ នៃ ប.ន.ឃ.ស នេះ នោះការកំណត់សមាជិក កបឃ.ស ទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ដំទប់ទី១ ឬចៅសង្កាត់រងទី១ និងដំទប់ទី២ ឬចៅសង្កាត់រងទី២ ត្រូវអនុលោមទៅតាមលក្ខខណ្ឌ និងតាមករណីនីមួយៗដូចមានចែងក្នុងចំណុច ៤.១២.៤ និងចំណុច ៤.១២.៥ ខាងលើនេះ។

ប្រការ៤.១៣.

បន្ទាប់ពីបានកំណត់ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតឈ្មោះសមាជិក កបឃ.ស ជាប់ឆ្នោត និងឈ្មោះសមាជិក កបឃ.ស ដែលទទួលតំណែងជាប្រធាន កបឃ.ស ជាមេឃុំ ឬចៅសង្កាត់ ដំទប់ទី១ ឬចៅសង្កាត់រងទី១ និងដំទប់ទី២ ឬចៅសង្កាត់រងទី២ រួចហើយ គធ.ខប ត្រូវរាយការណ៍ជូនទៅ គ.ជ.ប តាមតារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១)។

ប្រការ៤.១៤._

អនុលោមតាម ច.គ.ឃ.ស ប្រសិនបើសមាជិក កបយ.ស ណាម្នាក់ត្រូវបាត់បង់សមាជិកភាពដូចករណីមានចែងក្នុងប្រការ៤.១៥ ខាងក្រោមនេះ បេក្ខជនជំនួសត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយពាក់ព័ន្ធ ដោយមិនចាំបាច់បោះឆ្នោតឡើងវិញឡើយ។ លើកលែងតែបេក្ខជនដែលត្រូវជំនួសនោះបាត់បង់គុណសម្បត្តិជាបេក្ខជនស្របតាមលក្ខខណ្ឌដែលមានចែងក្នុងប្រការ៦.១ នៃ ប.ន.ឃ.ស នេះ។

ការបាត់បង់សមាជិកភាព កបយ.ស

ប្រការ៤.១៥._

ការបាត់បង់សមាជិកភាព កបយ.ស អាចកើតមានឡើងដោយករណីណាមួយក្នុងចំណោមករណីខាងក្រោម៖

៤.១៥.១ សាមីខ្លួនបាត់សញ្ជាតិខ្មែរ។

៤.១៥.២ សាមីខ្លួនទទួលមរណភាព។

៤.១៥.៣ សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច។

៤.១៥.៤ សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិក កបយ.ស។

៤.១៥.៥ សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ។

៤.១៥.៦ សាមីខ្លួនត្រូវបានបណ្តេញចេញ ដោយសារបានប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃ កបយ.ស។

៤.១៥.៧ កបយ.ស ទាំងមូលត្រូវរំសាយ។

៤.១៥.៨ សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយនៅក្នុងអាណត្តិនៃ កបយ.ស

ប្រការ៤.១៦._

នៅក្នុងអាណត្តិនៃ កបយ.ស ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយស្របតាមច្បាប់ស្តីពី

គណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ បញ្ជីបេក្ខជន និងសមាជិក កបយ.ស ទាំងអស់នៃគណបក្សនយោបាយនោះលែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ។

៤.១៦.១ គ.ជ.ប ត្រូវបែងចែកអាសនៈដែលនៅទំនេរនោះទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀតដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ក្នុងអំឡុងពេលយ៉ាងយូរ ១៤ (ដប់បួន) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលលិខិតបោះបង់ចោលជាផ្លូវការពីគណបក្សនយោបាយ ឬប្រកាសស្តីពីការលុបឈ្មោះគណបក្សនយោបាយចេញពីបញ្ជីគណបក្សនយោបាយ ឬប្រកាសរំលាយគណបក្សនយោបាយ។

៤.១៦.២ គណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោតអាចប្រកាសមិនទទួលយកអាសនៈរបស់គណបក្សនយោបាយណាមួយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ នៅឃុំ សង្កាត់ណាមួយ ឬមួយចំនួន ដោយត្រូវធ្វើលិខិតជូនដំណឹងទៅ គ.ជ.ប ក្នុងអំឡុងពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃតាមការកំណត់របស់ គ.ជ.ប។

៤.១៦.៣ គ.ជ.ប ត្រូវបង្កើតក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យសំឡេងឆ្នោតបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបយ.ស និងកំណត់ឈ្មោះសមាជិក កបយ.ស ឱ្យទទួលតំណែងជាប្រធាន កបយ.ស ជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

៤.១៦.៤ នៅមុនការបែងចែកអាសនៈដែលនៅទំនេរតាមករណីដូចខាងលើនេះ គ.ជ.ប ត្រូវធ្វើលិខិតជាផ្លូវការទៅគណបក្សនយោបាយផ្សេងទៀតដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដើម្បីសម្របសម្រួល និងកំណត់បញ្ហាមួយចំនួនដូចខាងក្រោម៖

ទី១- ការប្រកាសយល់ព្រមទទួលយក ឬមិនទទួលយកអាសនៈរបស់គណបក្សនយោបាយណាមួយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ នៅឃុំ សង្កាត់ណាមួយ ឬមួយចំនួន ដោយត្រូវធ្វើលិខិតជូនដំណឹងទៅ គ.ជ.ប ក្នុងអំឡុងពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ។

ទី២- ការធ្វើបច្ចុប្បន្នភាពបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់ខ្លួនក្នុងអាណត្តិពាក់ព័ន្ធ ដោយត្រូវលុបចេញនូវឈ្មោះបេក្ខជនដែល៖

- បាត់សញ្ជាតិខ្មែរ
- ទទួលមរណភាព
- បាត់បង់សម្បទាវិជ្ជាជីវៈ
- លាលែងជាលាយលក្ខណ៍អក្សរ
- ត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ឬ
- បាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

ទី៣- ករណីគណបក្សនយោបាយណាមួយពុំបានឆ្លើយតបតាមលិខិតផ្លូវការរបស់ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃតាមកាលបរិច្ឆេទកំណត់ដោយ គ.ជ.ប នោះចាត់ទុកថាគណបក្សនយោបាយនោះបានយល់ព្រមទទួលយកតាមការបែងចែកអាសនៈដែលនៅទំនេរ និងរក្សាទុកជាបាននូវបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយរបស់ខ្លួនក្នុងអាណត្តិពាក់ព័ន្ធ។

៤.១៦.៥ ការបែងចែកអាសនៈដែលនៅទំនេរដូចមានចែងក្នុងចំណុច ៤.១៦.១ ខាងលើនេះ ត្រូវអនុវត្តតាមជំហានទាំងឡាយដូចមានចែងក្នុងចំណុច ៤.៧.៤ នៃ ប.ន.ឃ.ស នេះ។

៤.១៦.៦ ការបែងចែកអាសនៈដែលនៅទំនេរដូចមានចែងក្នុងចំណុច ៤.១៦.២ ខាងលើនេះ ត្រូវអនុវត្តតាមជំហានទាំងឡាយដូចមានចែងក្នុងចំណុច ៤.៧.៥ នៃ ប.ន.ឃ.ស នេះ។

ករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួនមានមធ្យមភាគខ្ពស់បំផុតស្មើគ្នាក្នុងពេលបែងចែកអាសនៈទំនេរនៅក្នុងអាណត្តិនៃ កបយ.ស

ប្រការ៤.១៧.

ក្នុងករណីគណនាតាមរូបមន្តដូចមានចែងក្នុងប្រការ៤.១៦ ខាងលើនេះ មានលទ្ធផលស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន ដែលមិនអាចកំណត់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបានទទួលអាសនៈដែលត្រូវបែងចែក គ.ជ.ប ត្រូវអនុវត្តវិធីចាប់ឆ្នោតដើម្បីកំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយឈ្នះឆ្នោត។

គ.ជ.ប ត្រូវប្រគល់ភារកិច្ចជូនអគ្គលេខាធិការដ្ឋាន គ.ជ.ប ចាត់ចែងរៀបចំការចាប់ឆ្នោត។

វិធីចាប់ឆ្នោតត្រូវដំណើរការតាមនីតិវិធីដែលកំណត់ដូចមានចែងក្នុងប្រការ៤.៩ នៃ ប.ន.ឃ.ស នេះ។

ប្រការ៤.១៨.–

បន្ទាប់ពីបានធ្វើការគណនាកំណត់ចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវទទួលបានរួចហើយ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតតាមលំដាប់លេខរៀងជាសមាជិក កបយ.ស និងកំណត់ឈ្មោះជាប្រធាន កបយ.ស ជាមេឃុំ ចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ពីបញ្ជីបេក្ខជនដែលនៅជាធរមាន ឬពីបញ្ជីបេក្ខជនដែលបានធ្វើបច្ចុប្បន្នភាព ឬពីបេក្ខជនបម្រុងបន្ថែមរបស់គណបក្សនយោបាយដែលជាប់ឆ្នោត រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

ការចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយនៅក្នុងអាណត្តិនៃ កបយ.ស

ប្រការ៤.១៩.–

គណបក្សនយោបាយដែលទទួលបានអាសនៈក្នុង កបយ.ស ហើយបេក្ខជនផ្លូវការរបស់ខ្លួនត្រូវបានរំកិលលេខរៀងអស់ ឬនៅសល់បេក្ខជន ២ (ពីរ) ឬ ៣ (បី) រូប ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រសួងមហាផ្ទៃជាបន្ទាន់ ដើម្បីក្រសួងមហាផ្ទៃស្នើមក គ.ជ.ប ដើម្បីចាត់ចែងចុះបញ្ជីបេក្ខជនបម្រុងបន្ថែមសម្រាប់សមាជិក កបយ.ស។

៤.១៩.១ នៅពេលដែលបានទទួលសំណើពីក្រសួងមហាផ្ទៃ គ.ជ.ប ត្រូវជូនដំណឹងដល់គណបក្សនយោបាយសាមីឱ្យមកដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ។

៤.១៩.២ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គ.ជ.ប (ទ.១០០៨ប) ចំនួន ២ (ពីរ) ច្បាប់។ ពាក្យសុំនេះត្រូវបានផ្តល់ដោយឥតគិតថ្លៃជូនគណបក្សនយោបាយដែលមានបំណងចុះបញ្ជីបេក្ខជនបម្រុងបន្ថែម។

៤.១៩.៣ ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គ.ជ.ប (ទ.១០០៨ប) ត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ។ ការផ្ទេរសិទ្ធិនេះមិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះ មានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។

៤.១៩.៤ ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គ.ជ.ប (ទ.១០០៨ប) ត្រូវភ្ជាប់មកជាមួយនូវ៖

៤.១៩.៤.១ បញ្ជីរាយនាមបេក្ខជនបម្រុងបន្ថែមចំនួន ៦ (ប្រាំមួយ) ច្បាប់ ដែលមានចំនួនបេក្ខជនបម្រុងបន្ថែមយ៉ាងតិចស្មើនឹងចំនួនអាសនៈនៃ កបយ.ស ក្នុងឃុំ សង្កាត់ពាក់ព័ន្ធ។

៤.១៩.៤.២ លិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់ថាពិតជាបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត ដោយបញ្ជាក់ឱ្យបានច្បាស់អំពីនាមត្រកូល នាមខ្លួន និងអាសយដ្ឋាន។

៤.១៩.៤.៣ ជីវប្រវត្តិសង្ខេប និងសេចក្តីប្រកាសយល់ព្រមឈរឈ្មោះរបស់បេក្ខជន ដែលត្រូវបំពេញដោយផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ មានបិទរូបថត និងរូបថតបេក្ខជនម្នាក់ៗចំនួន ៣ (បី) សន្លឹកទៀត ដែលមានទំហំ ៤ x ៦ ថតចំពីមុខតាមគំរូរូបថតធ្វើ អ.ខ។

៤.១៩.៥ ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

៤.១៩.៥.១ មានសញ្ជាតិខ្មែរពីកំណើត។

៤.១៩.៥.២ ចេះអាន និងសរសេរអក្សរខ្មែរ។

៤.១៩.៥.៣ បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត។

៤.១៩.៥.៤ មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតមកទល់ថ្ងៃដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម។

៤.១៩.៥.៥ បានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលលើកចុងក្រោយដែលរៀបចំឡើងដោយ គ.ជ.ប លើកលែងតែករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះមានមូលហេតុសមស្របដូចមានចែងក្នុងប្រការ៦.២ នៃ ប.ន.ឃ.ស នេះ។

៤.១៩.៥.៦ មានឈ្មោះនៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ។

៤.១៩.៦ ហាមឈរឈ្មោះជាបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយចំពោះ៖

៤.១៩.៦.១ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិករាជរដ្ឋាភិបាល និងចៅក្រម។

៤.១៩.៦.២ អភិបាល ឬអភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៤.១៩.៦.៣ សមាជិក គ.ជ.ប គធ.ខប គឃ.សប គ.ក.ប/គ.ក.រ បុគ្គលិកបម្រើការងារនៅ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

៤.១៩.៦.៤ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬ នគរបាលជាតិក្នុងមុខតំណែង។

៤.១៩.៦.៥ ព្រះសង្ឃ ឬបព្វជិតសាសនានៃសាសនាណាមួយ។

៤.១៩.៦.៦ ស្មៀនឃុំ សង្កាត់ណាមួយ។។

៤.១៩.៧ ចំពោះបេក្ខជនជាមន្ត្រីរាជការស៊ីវិលមន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ នៅពេលជាប់ឆ្នោតជាសមាជិក កបឃ.ស ត្រូវរៀបចំបែបបទដូចមានចែងក្នុងចំណុច ៦.៤.១ នៃ ប.ន.ឃ.ស នេះ។

៤.១៩.៨ គ.ជ.ប ត្រូវរក្សាបញ្ជីរាយនាមបេក្ខជនបម្រុងបន្ថែម ៦ (ប្រាំមួយ) ច្បាប់ ខាងលើនេះ ដើម្បីបិទផ្សាយនៅសាលាឃុំ សង្កាត់ ១ (មួយ) ច្បាប់ ជាបញ្ជីបេក្ខជនបម្រុងបន្ថែម ដំបូង បិទផ្សាយនៅសាលាឃុំ សង្កាត់ ១ (មួយ) ច្បាប់ ជាបញ្ជីបេក្ខជនបម្រុងបន្ថែម ផ្លូវការ រក្សាទុកជាឯកសារនៅ កបឃ.ស ១ (មួយ) ច្បាប់ ផ្ញើជូន លធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រសួងមហាផ្ទៃ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារនៅ គ.ជ.ប ១ (មួយ) ច្បាប់។

៤.១៩.៩ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្ស នយោបាយជាបន្ទាន់សមស្រប បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនបម្រុង បន្ថែម។

៤.១៩.៩.១ ក្នុងករណីគណបក្សនយោបាយបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌ ដូចបានកំណត់ខាងលើនេះ គ.ជ.ប ត្រូវសម្រេចយល់ព្រមលើពាក្យសុំ ចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនោះ ដោយត្រូវបំពេញលើពាក្យសុំចុះ បញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយនិងសេចក្តីសម្រេច របស់ គ.ជ.ប (ទ.១០០៨ប) ទាំង ២ (ពីរ) ច្បាប់ ដោយចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប រួចផ្ញើជូនគណបក្ស នយោបាយសាមី ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៤.១៩.៩.២ ក្នុងករណីគណបក្សនយោបាយបំពេញមិនបានត្រឹមត្រូវតាមលក្ខខណ្ឌ ដូចបានកំណត់ខាងលើ គ.ជ.ប ត្រូវបដិសេធបេក្ខភាពដែលពុំមាន លក្ខណសម្បត្តិគ្រប់គ្រាន់នោះតែប៉ុណ្ណោះ។ សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ។

៤.១៩.១០ បន្ទាប់ពីការពិនិត្យ និងសម្រេចលើពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ រួចហើយ គ.ជ.ប ត្រូវចាត់ឱ្យ លធ.ខប បិទផ្សាយបញ្ជីបេក្ខជនបម្រុងបន្ថែមដំបូងនៅសាលាឃុំ សង្កាត់ពាក់ព័ន្ធចំនួន ១ (មួយ) ច្បាប់ ជាបន្ទាន់បន្ទាប់ពីថ្ងៃសម្រេចយល់ព្រម។

៤.១៩.១១ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះមានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនបម្រុងបន្ថែមដំបូង ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ។

៤.១៩.១២ គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។ សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ។

៤.១៩.១៣ ប្រសិនបើគ្មានពាក្យបណ្តឹងជំទាស់លើបញ្ជីបេក្ខជនបម្រុងបន្ថែមដំបូង ឬការប្តឹងជំទាស់ត្រូវបានដោះស្រាយចប់ បញ្ជីបេក្ខជនបម្រុងបន្ថែមដំបូងនឹងក្លាយជាបញ្ជីបេក្ខជនបម្រុងបន្ថែមផ្លូវការ។ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជនបម្រុងបន្ថែមនៅក្នុងបញ្ជីនេះមិនអាចកែប្រែបានឡើយ។

៤.១៩.១៤ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងទៅក្រសួងមហាផ្ទៃ ដោយភ្ជាប់ជាមួយនូវបញ្ជីបេក្ខជនបម្រុងបន្ថែមផ្លូវការខាងលើនេះ។

ជំពូកទី៥
ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

ការកំណត់ទីតាំងការិយាល័យបោះឆ្នោត

ប្រការ៥.១.-

គ.ជ.ប ត្រូវកំណត់ក្នុងដំហានដំបូងនូវចំនួន និងទីតាំងការិយាល័យបោះឆ្នោតចំនួនមួយ ឬច្រើនក្នុងឃុំ សង្កាត់នីមួយៗ នៅក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ថ្ងៃមុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ ចំនួន និងទីតាំងការិយាល័យបោះឆ្នោតអាចនឹងកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គ.ជ.ប បន្ទាប់ពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតបានបញ្ចប់ និងត្រូវធ្វើឱ្យហើយរួចរាល់មុនថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ។

៥.១.១ ការកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ត្រូវផ្អែកលើមូលដ្ឋានស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មានសម្រាប់ការចុះឈ្មោះបោះឆ្នោតនៅតាមភូមិក្នុងឃុំ សង្កាត់នីមួយៗ។ ទន្ទឹមនឹងនេះ គ.ជ.ប ត្រូវកែសម្រួលការិយាល័យបោះឆ្នោត ឬ/និងបង្កើតការិយាល័យបោះឆ្នោតថ្មីបន្ថែមឱ្យសមស្របតាមសភាពជាក់ស្តែង និងការចាំបាច់ដោយត្រូវប្រើប្រាស់លក្ខណៈនិច្ឆ័យលើកត្តាប្រជាសាស្ត្រ ចម្ងាយផ្លូវ ភូមិសាស្ត្រ សង្គម និងរដ្ឋបាល។

៥.១.២ គ.ជ.ប អាចធ្វើការកែសម្រួលការិយាល័យបោះឆ្នោត និងតំបន់ស្ថិតក្នុងដែនសមត្ថកិច្ចដែលការិយាល័យនោះទទួលខុសត្រូវបានតែក្នុងករណីមានការប្រែប្រួលខាងប្រជាសាស្ត្រ សង្គម ឬ/និងមានការប្រែប្រួលខាងភូមិសាស្ត្រ និងរដ្ឋបាល។

៥.១.៣ ការកំណត់ និងការកែសម្រួលការិយាល័យបោះឆ្នោត ឬ/និងការបង្កើតការិយាល័យបោះឆ្នោតថ្មីក្នុងឃុំ សង្កាត់ ត្រូវគោរពតាមលក្ខខណ្ឌនៃ ច.គ.ឃ.ស ច.ប.ឃ.ស និង ច.ប.ត.រ។

៥.១.៤ ការបង្កើតការិយាល័យបោះឆ្នោតជាដំបូងគឺសម្រាប់បម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ ការិយាល័យបោះឆ្នោតដែលបញ្ជីបោះឆ្នោតនៃការិយាល័យទាំងនោះត្រូវបានផ្តល់សុពលភាពជាផ្លូវការចុងក្រោយដោយ គ.ជ.ប នឹងត្រូវប្រើជាការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើស កបយ.ស។ ការិយាល័យបោះឆ្នោតនឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោតនៅពេលរាប់សន្លឹកឆ្នោត។

៥.១.៥ ការិយាល័យបោះឆ្នោតនីមួយៗត្រូវបម្រើឱ្យតំបន់បោះឆ្នោតមួយដែលបានកំណត់។ ការិយាល័យបោះឆ្នោត និងតំបន់ស្ថិតក្នុងដែនសមត្ថកិច្ចដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវតែស្ថិតនៅក្នុងព្រំប្រទល់ឃុំ សង្កាត់។

៥.១.៦ គ.ជ.ប ត្រូវធានាថាទីតាំងការិយាល័យបោះឆ្នោតនីមួយៗមិនត្រូវស្ថិតនៅឆ្ងាយជាង ៥ (ប្រាំ) គីឡូម៉ែត្រពីទីកន្លែងរស់នៅរបស់អ្នកបោះឆ្នោតឡើយ។

៥.១.៧ ទីតាំងការិយាល័យបោះឆ្នោតត្រូវតែជាទីកន្លែងដែលអ្នកបោះឆ្នោតអាចធ្វើដំណើរទៅមកបានដោយគ្មានឧបសគ្គ និងគ្មានការរំខាន ព្រមទាំងមានសុវត្ថិភាពសម្រាប់អ្នកបោះឆ្នោត។

៥.១.៨ នៅទីណាមានស្ទឹង ទន្លេ ឬភូមិសាស្ត្រដែលនាំឱ្យប្រជាពលរដ្ឋពិបាកធ្វើដំណើរឆ្លងកាត់ គ.ជ.ប ត្រូវតែបង្កើតការិយាល័យបោះឆ្នោតនៅទាំងសងខាងស្ទឹង ទន្លេ ឬ/និងនៅទីតាំងជាក់លាក់ណាមួយ ដែលមានលក្ខណៈប្រសើរជាង។

៥.១.៩ នៅតំបន់ដាច់ស្រយាលដែលមានប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតតិចជាង ១០០ (មួយរយ) នាក់ គ.ជ.ប ក៏ត្រូវតែបង្កើតការិយាល័យបោះឆ្នោតមួយដែរ។

៥.១.១០ ការិយាល័យបោះឆ្នោតនីមួយៗត្រូវប្រមូលផ្តុំដោយភូមិទាំងមូល និងត្រូវបង្កលក្ខណៈឱ្យសមាជិកគ្រួសារទាំងអស់ក្នុងភូមិនោះបានទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។

៥.១.១១ គ.ជ.ប ត្រូវធានាថាការិយាល័យបោះឆ្នោតមួយត្រូវទទួលចុះឈ្មោះអ្នកបោះឆ្នោតយ៉ាងច្រើនបំផុតត្រឹមចំនួន ៧៥០ (ប្រាំពីររយហាសិប) នាក់។ ក្នុងករណីការិយាល័យបោះឆ្នោតណាមួយមានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០ (ប្រាំពីររយហាសិប) នាក់ គ.ជ.ប ត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះទៅក្នុងការិយាល័យបោះឆ្នោតណាមួយក្នុងភូមិជាមួយ ឬការិយាល័យបោះឆ្នោតណាដែលជិតបំផុតនៅក្នុងឃុំ សង្កាត់ជាមួយ ឬអាចបង្កើតការិយាល័យបោះឆ្នោតថ្មីក្នុងភូមិជាមួយតាមការចាំបាច់។

ប្រការ៥.២.

ការិយាល័យបោះឆ្នោតជាការិយាល័យនៅមួយកន្លែង ដែលបង្កើតឡើងនៅទីតាំងជាក់លាក់មួយសម្រាប់តំបន់បោះឆ្នោតមួយដែលបានកំណត់ ហើយដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

ប្រការ៥.៣.

ទីតាំងដែលអ្នកបោះឆ្នោតងាយរកឃើញ និងអាចធ្វើដំណើរទៅមកបានគឺជាលក្ខណៈវិនិច្ឆ័យសំខាន់ក្នុងការបង្កើតការិយាល័យបោះឆ្នោត។

៥.៣.១ ការិយាល័យបោះឆ្នោតត្រូវមានទីតាំងនៅកន្លែងណាដែលអ្នកបោះឆ្នោតអាចធ្វើដំណើរទៅមកបានដោយគ្មានឧបសគ្គ និងគ្មានការរំខាន មានសុវត្ថិភាព និងបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព ហើយជាការប្រសើរត្រូវស្ថិតនៅជាន់ផ្ទាល់ដី។

៥.៣.២ ក្នុងករណីចាំបាច់ ការិយាល័យបោះឆ្នោតចំនួនពីរ ឬច្រើនអាចតាំងនៅក្នុងបរិវេណសំណង់ ឬអគារតែមួយ ប៉ុន្តែមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ប្រក្រតីភាពនៃការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតទេ។ ការិយាល័យបោះឆ្នោតចំនួនពីរ ឬច្រើនដែលតាំងនៅក្នុងបរិវេណសំណង់ ឬអគារតែមួយនោះ ត្រូវតែរៀបចំខណ្ឌដាច់ពីគ្នា និងគ្រប់គ្រងដោយឡែកពីគ្នា។

៥.៣.៣ ការិយាល័យបោះឆ្នោតមិនត្រូវបានបង្កើតនៅក្នុងបរិវេណទីធ្លា និងអគាររបស់រាជរដ្ឋាភិបាលដូចជាសាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ សាលាឃុំ សង្កាត់ ជាដើម ឬនៅបន្ទាយ ឬអគារនៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ ឬ/និងអគាររបស់គណបក្សនយោបាយនៅគ្រប់លំដាប់ថ្នាក់។

ការផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត

ប្រការ៥.៤._

គ.ជ.ប ត្រូវបោះពុម្ព និងផ្សព្វផ្សាយ និងបញ្ជូនបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅតាមដំណាក់កាលនីមួយៗទៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ដើម្បីចាត់ចែងបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតទាំងនោះនៅតាមទីកន្លែង និងតាមកាលបរិច្ឆេទដែល គ.ជ.ប បានកំណត់។

៥.៤.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតតាមអាសយដ្ឋានវេប www.nec.gov.kh និងកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH។

៥.៤.២ គជ.ខប ត្រូវបន្តចាត់ឱ្យ គយ.សប បិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ និងនៅទីស្នាក់ការ គយ.សប លើកទី១ នៅ ២ (ពីរ) ថ្ងៃមុនថ្ងៃចាប់ផ្តើមចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើស កបយ.ស។

៥.៤.៣ គជ.ខប ត្រូវបន្តចាត់ឱ្យ គយ.សប បិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ និងនៅទីស្នាក់ការ គយ.សប លើកទី២ នៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត។

ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

ប្រការ៥.៥._

ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗគឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលត្រូវមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ។

៥.៥.១ បរិវេណខាងក្នុងជាតំបន់ព័ទ្ធជុំវិញសំណង់ ឬអគារដែលការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាំងនៅ ហើយដែលខណ្ឌដោយរបាំងឬរបាំងណាមួយមានកាំប្រវែងយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ែត្រ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចូលមួយ និងច្រកចេញមួយ។

៥.៥.២ បរិវេណខាងក្រៅជាតំបន់ព័ទ្ធជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដែលខណ្ឌដោយវណ្ឌមណ្ឌលមានកាំប្រវែង ១០០ (មួយរយ) ម៉ែត្រ ឬតូចជាងអាស្រ័យដោយស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជាបរិវេណរបងនៃសាលារៀន វត្តអារាម សាលមហោស្រព ទីសាធារណៈ ជាដើម។

៥.៥.៣ នៅតំបន់ទីប្រជុំជន បរិវេណខាងក្រៅត្រូវបានកំណត់ដោយ គយ.សប ដោយយោងលើការវាយតម្លៃអំពីស្ថានភាពសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងតំបន់នោះ។

៥.៥.៤ នៅតំបន់ទីប្រជុំជន ក្នុងករណីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតមួយតាំងនៅប្រមាណ ១០០ (មួយរយ) ម៉ែត្រពីការិយាល័យពាក់ព័ន្ធមួយផ្សេងទៀតមួយផ្នែកនៃផ្លូវនេះត្រូវតែបិទចរាចរណ៍។

វិធានការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់

ប្រការ៥.៦.-

ដើម្បីការពារអ្នកនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខាន ការអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងដើម្បីរក្សាការពារឧបករណ៍ សម្ភារ ឯកសារបោះឆ្នោតទាំងអស់ក្នុងការិយាល័យទាំងនោះ គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ជាពិសេស គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានាដូចខាងក្រោម៖

៥.៦.១ ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងតែក្នុងករណីមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដែលប្រធាន គ.ជ.ប ឬ/និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មានការកិច្ចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១០ និងមាត្រា៨២ នៃ ច.ប.ឃ.ស។

៥.៦.១.១ ប្រធាន គ.ជ.ប និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវប្រគល់សិទ្ធិអំណាចពេញលេញឱ្យដល់ប្រធាន គ.ក.ប/គ.ក.រ ក្នុងការស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីដូចមានចែងក្នុងចំណុច ៥.៦.១ ខាងលើនេះ។

៥.៦.១.២ ក្នុងករណីមានសំណូមពរពីប្រធាន គ.ក.ប/គ.ក.រ ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោតណាមួយនោះ ភ្នាក់ងារសន្តិសុខបោះឆ្នោតមានបំពាក់អាវុធដែលត្រូវបានតែងតាំងអាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធ។

៥.៦.២ ហាមយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិណាម្នាក់ក្នុងឯកសណ្ឋាន ជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬឈរជើតបរិវេណការពារសន្តិសុខ លើកលែងតែក្នុងករណីអ្នកទាំងនោះត្រូវបានប្រគល់ភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ឬភ្នាក់ងារសង្គ្រោះ និងត្រូវបានប្រធាន គ.ក.ប/គ.ក.រ ស្នើសុំឱ្យធ្វើអន្តរាគមន៍ដូចមានចែងក្នុងប្រការ៥.៦ និងលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងចំណុច ៥.៦.១ ខាងលើនេះ ឬកាលៈទេសៈចាំបាច់តម្រូវ។

៥.៦.៣ ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោត មុនពេលចាប់ផ្តើមការបោះឆ្នោត ឬក្រោយពេលបិទការបោះឆ្នោតដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម៖

- ៥.៦.៣.១ មន្ត្រីបោះឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប។
- ៥.៦.៣.២ ភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ ដែលបានអនុញ្ញាត ហើយមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គយ.សប។
- ៥.៦.៣.៣ អ្នកសង្កេតការណ៍បោះឆ្នោតដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ឬដោយ គធ.ឧប។
- ៥.៦.៣.៤ អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប។ ក្នុងករណីគ្មានបណ្ណសម្គាល់អនុញ្ញាត អ្នកសារព័ត៌មានអាចចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីគោលបំណងបោះឆ្នោតតែប៉ុណ្ណោះ ប្រសិនបើគាត់មានឈ្មោះបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។
- ៥.៦.៣.៥ អ្នកដែលមានសិទ្ធិបោះឆ្នោត ហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។
- ៥.៦.៣.៦ ជនដែលអមដំណើរអ្នកបោះឆ្នោតជាជនមានពិការភាពតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១១៦ នៃ ច.ប.ឃ.ស។
- ៥.៦.៣.៧ ភ្នាក់ងារសន្តិសុខបោះឆ្នោត និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.ប ធ្វើសំណូមពរក្នុងករណីចាំបាច់។

៥.៦.៤ ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត មុនពេលចាប់ផ្តើមការរាប់សន្លឹកឆ្នោត ឬក្រោយការរាប់សន្លឹកឆ្នោតដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម៖

- ៥.៦.៤.១ មន្ត្រីរាប់សន្លឹកឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប។

៥.៦.៤.២ ភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ និងដែលបានអនុញ្ញាត ហើយមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គយ.សប។

៥.៦.៤.៣ អ្នកសង្កេតការណ៍បោះឆ្នោតដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ឬដោយ គធ.ខប។

៥.៦.៤.៤ អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប។

៥.៦.៤.៥ ភ្នាក់ងារសន្តិសុខបោះឆ្នោត និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.រ ធ្វើសំណូមពរក្នុងករណីចាំបាច់។

៥.៦.៥ សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ៖

៥.៦.៥.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ។

៥.៦.៥.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យអ្នកបោះឆ្នោតបោះឆ្នោតឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ។

៥.៦.៥.៣ ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ។

៥.៦.៥.៤ ការរារាំង ឬការញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។

៥.៦.៥.៥ ការណែនាំ ឬការញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

៥.៦.៥.៦ ការធ្វើសកម្មភាពនានាដែលនាំឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

៥.៦.៥.៧ ការបង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។

៥.៦.៥.៨ ការធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

៥.៦.៥.៩ ការប្រើប្រាស់ឧបករណ៍ដែលអាចថតរូប ឬវីដេអូបាននៅក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតផ្សេងពីនេះដោយ គ.ជ.ប។

៥.៦.៥.១០ ការធ្វើសកម្មភាពទាំងឡាយណាដែល ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ ហាមឃាត់។

៥.៦.៦ សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ៖

៥.៦.៦.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ។

៥.៦.៦.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីរាប់សន្លឹកឆ្នោតរាប់គំនូសនៅលើសន្លឹកឆ្នោត ដើម្បីបំពេញចិត្ត ឬប្រឆាំងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ។

៥.៦.៦.៣ ការបង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។

៥.៦.៦.៤ ការធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលរាប់សន្លឹកឆ្នោត។

៥.៦.៦.៥ ការធ្វើសកម្មភាពទាំងឡាយណាដែល ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ ហាមឃាត់។

៥.៦.៧ ក្នុងករណីចាំបាច់ ប្រធាន គ.ក.ប/គ.ក.រ មានការកិច្ចអនុវត្តនូវលក្ខខណ្ឌដូចមានចែងក្នុងចំណុច ៥.៥.៣ ចំណុច ៥.៦.៣ និងចំណុច ៥.៦.៤ ខាងលើនេះ ចំពោះបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែក ដើម្បីធានាឱ្យការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព។

៥.៦.៨ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងណែនាំរបស់ គ.ជ.ប ស្របតាមលក្ខខណ្ឌនៃ ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ។

៥.៦.៩ គ.ជ.ប គធ.ខប និង គឃ.សប អាចពិគ្រោះយោបល់ជាមួយស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីផ្លាស់ប្តូរដោយបណ្តោះអាសន្ននូវទីតាំងការិយាល័យបោះឆ្នោតមួយចំនួនដែលរងផលប៉ះពាល់ដោយសារស្ថានភាពអសន្តិសុខ និងមិនមានសុវត្ថិភាពសម្រាប់អ្នកបោះឆ្នោតអាចចូលរួមបោះឆ្នោត។

វិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ

ប្រការ៥.៧.

គ.ជ.ប ត្រូវចាត់វិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការចាំបាច់ផ្សេងទៀត ដើម្បីបង្ការ ការពារ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ នៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៥.៧.១ ជនគ្រប់រូបដែលនៅបរិវេណខាងក្នុង បរិវេណខាងក្រៅ និងក្នុងការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោតត្រូវគោរពតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងទៀត និងសេចក្តីណែនាំផ្សេងៗស្តីពីវិធានការការពារ និងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ ក្នុងករណីតម្រូវឱ្យអនុវត្ត។

ប្រការ៥.៨.

ចំពោះការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបានក្នុងករណីប្រជានសក្តិ ឬអសន្តិសុខ គ.ជ.ប ត្រូវសម្រេចឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះនៅកន្លែងផ្សេងទៀត។ គ.ជ.ប ត្រូវផ្សព្វផ្សាយជាបន្ទាន់ និងជាសាធារណៈអំពីសេចក្តីសម្រេចនេះ។

ប្រការ៥.៩.

សាលារៀន ទីវត្តអារាម រាល់សំណង់ អគារ សាល ឬទីសាធារណៈ ត្រូវបានផ្តល់ដោយឥតគិតថ្លៃទៅ គ.ជ.ប សម្រាប់គោលបំណងនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

ជំពូកទី៦
ការចុះបញ្ជីបេក្ខជនតែគណបក្សនយោបាយសម្រាប់ឈរឈ្មោះ ឬបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន

ប្រការ៦.១.

ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើស កបឃ.ស ប្រជាពលរដ្ឋទាំងពីរភេទ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

៦.១.១ មានសញ្ជាតិខ្មែរពីកំណើត។

៦.១.២ ចេះអាន និងសរសេរអក្សរខ្មែរ។

៦.១.៣ បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត។

៦.១.៤ មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើស កបឃ.ស។

៦.១.៥ បានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលលើកចុងក្រោយដែលរៀបចំឡើងដោយ គ.ជ.ប លើកលែងតែករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះមានមូលហេតុសមស្រប។

មូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធិបោះឆ្នោត

ប្រការ៦.២.

មូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតពាក់ព័ន្ធនឹងលក្ខខណ្ឌដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើស កបឃ.ស ដូចមានចែងក្នុងចំណុច ៦.១.៥ ខាងលើនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

៦.២.១ ស្ថិតនៅក្រៅប្រទេសនៅថ្ងៃបោះឆ្នោត ដោយសារជាប់បំពេញបេសកកម្មផ្លូវការ ឬបំពេញការសិក្សា ឬបំពេញការងារដែលមានកិច្ចសន្យាការងារស្របច្បាប់។

៦.២.២ មានជំងឺដែលមិនអាចទៅបោះឆ្នោតបាននៅថ្ងៃបោះឆ្នោត។

៦.២.៣ ស្ត្រីសម្រាលកូននៅថ្ងៃបោះឆ្នោត។

៦.២.៤ ត្រូវបានព្យួរសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្នស្របតាមច្បាប់ជាធរមាន។

៦.២.៥ ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នដែលអ្នកបោះឆ្នោតមិនអាចបោះឆ្នោតបានស្របតាមបទប្បញ្ញត្តិនៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

អ្នកបោះឆ្នោតដែលមិនបានអនុវត្តសិទ្ធិបោះឆ្នោតដោយមូលហេតុសមស្របដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការ៦.២ ខាងលើនេះ ហើយមានបំណងឈរឈ្មោះបោះឆ្នោតត្រូវបញ្ជាក់អំពីមូលហេតុ និងត្រូវមានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ដល់ គ.ជ.ប។

តារាងគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន

ប្រការ៦.៣.-

ហាមឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស កបយ.ស ចំពោះ៖

៦.៣.១ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិករាជរដ្ឋាភិបាល និងចៅក្រម។

៦.៣.២ អភិបាល ឬអភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៦.៣.៣ សមាជិក គ.ជ.ប គធ.ខប គយ.សប គ.ក.ប/គ.ក.រ និងបុគ្គលិកបម្រើការងារក្នុង គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

៦.៣.៤ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង។

៦.៣.៥ ព្រះសង្ឃ ឬបព្វជិតសាសនានៃសាសនាណាមួយ។

៦.៣.៦ ស្មៀនឃុំ សង្កាត់ណាមួយ។

ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស

ប្រការ៦.៤.-

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើស កបយ.ស ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ។

៦.៤.១ ប្រសិនបើសាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅក្រសួង ស្ថាប័ន ឬអង្គភាពសាមីទៅបម្រើការក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលអាណត្តិរបស់ខ្លួន។ ក្នុងឋានៈនេះ សាមីខ្លួនត្រូវមានសិទ្ធិឡើងថ្នាក់ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍។

៦.៤.២ នៅពេលចប់អាណត្តិជាសមាជិក កបយ.ស សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ស្ថាប័ន ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយក្រសួង ស្ថាប័ន ឬអង្គភាពសាមីជាអ្នកសម្រេច។

៦.៤.៣ លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ស្ថាប័ន ឬអង្គភាពសាមីអាចភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គយ.សប (ទ.១០០៨)។ ក្នុងករណីមិនអាចធ្វើទាន់ គណបក្សនយោបាយត្រូវភ្ជាប់ច្បាប់ថតចម្លងលិខិតស្នើសុំអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ស្ថាប័ន ឬអង្គភាពសាមី ដោយមានហត្ថលេខារបស់ថ្នាក់លើមួយថ្នាក់យ៉ាងតិចដែលខ្លួននៅក្រោមឱវាទជូន គយ.សប។ បេក្ខជនឈរឈ្មោះត្រូវធ្វើកិច្ចសន្យាតាមទម្រង់ដែលផ្តល់ជូនដោយ គ.ជ.ប ដើម្បីធានាថានឹងប្រគល់លិខិតអនុញ្ញាតច្បាប់ឈប់ពិសេសដែលប្រធានក្រសួង ស្ថាប័ន ឬអង្គភាពសាមីសម្រេចជាផ្លូវការមក គយ.សប ឱ្យបានយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃចាប់ផ្តើមបើកយុទ្ធនាការឃោសនាបោះឆ្នោត។

ប្រការ៦.៥.

បន្ទាប់ពីនាយករដ្ឋមន្ត្រីកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើស កបយ.ស តាមលក្ខខណ្ឌដូចមានចែងក្នុង ច.ប.ឃ.ស គ.ជ.ប ត្រូវផ្សព្វផ្សាយនៅក្នុងឃុំ សង្កាត់នីមួយៗនូវកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើស កបយ.ស កាលបរិច្ឆេទនៃការចុះបញ្ជីបេក្ខជន និងទីកន្លែង។

ប្រការ៦.៦.

ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស កបយ.ស ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ។

៦.៦.១ បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវរៀបចំដោយគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ។

៦.៦.២ បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង។

៦.៦.៣ បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ។ បេក្ខជនម្នាក់ៗមិនត្រូវបានអនុញ្ញាតឱ្យលាឈប់ពីបេក្ខភាពមុនបញ្ជីបេក្ខជនផ្លូវការត្រូវបានសម្រេចឡើយ។

ប្រការ៦.៧.

ដើម្បីឈរឈ្មោះបោះឆ្នោតជ្រើសរើស កបយ.ស គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយតាមការកំណត់របស់ គ.ជ.ប ទៅ គយ.សប យ៉ាងតិច ៩០ (កៅសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត។

៦.៧.១ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គយ.សប (ទ.១០០៨) ចំនួន ២ (ពីរ) ច្បាប់។ ពាក្យសុំនេះត្រូវបានផ្តល់ដោយឥតគិតថ្លៃជូនគណបក្សនយោបាយដែលមានបំណងចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

៦.៧.២ ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គយ.សប (ទ.១០០៨) ត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ។ ការផ្ទេរសិទ្ធិនេះមិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។

៦.៧.៣ ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គយ.សប (ទ.១០០៨) ត្រូវភ្ជាប់មកជាមួយនូវ៖

៦.៧.៣.១ សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ជាសេចក្តីចម្លងប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្មដោយអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ឬការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន ១ (មួយ) ច្បាប់។ គណបក្សនយោបាយត្រូវធ្វើសេចក្តីចម្លងប្រកាសនេះ ១ (មួយ) ច្បាប់ មក គ.ជ.ប ដើម្បីតម្កល់ទុក ហើយនៅពេលដាក់ពាក្យសុំចុះបញ្ជីនៅ គយ.សប គណបក្សនយោបាយគ្រាន់តែថតចម្លងសេចក្តីចម្លងប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃដែលមានបញ្ជាក់នីត្យានុកូលកម្មនេះ ភ្ជាប់ជាមួយពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គយ.សប (ទ.១០០៨)។

៦.៧.៣.២ អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ អាសយដ្ឋានទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងឈ្មោះតំណាងប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ ដែលបានដាក់ស្នើបញ្ជីបេក្ខជន។

៦.៧.៣.៣ បញ្ជីរាយនាមបេក្ខជនចំនួន ៧ (ប្រាំពីរ) ច្បាប់ ដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹង ២ (ពីរ) ដងនៃចំនួនសមាជិកកបយ.ស។ គយ.សប ត្រូវរក្សាបញ្ជីរាយនាមបេក្ខជនទាំង ៧ (ប្រាំពីរ) ច្បាប់ ដើម្បីបិទផ្សាយនៅទីស្នាក់ការ គយ.សប ១ (មួយ) ច្បាប់ បន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជន បិទផ្សាយនៅទីស្នាក់ការ គយ.សប ១ (មួយ) ច្បាប់ ជាបញ្ជីបេក្ខជនដំបូងបិទផ្សាយនៅទីស្នាក់ការ គយ.សប ១ (មួយ) ច្បាប់ ជាបញ្ជីបេក្ខជនផ្លូវការ រក្សាទុកជាឯកសារនៅ គយ.សប ១ (មួយ) ច្បាប់ ជូនគណបក្សនយោបាយសាមី ១ (មួយ) ច្បាប់ ផ្ញើជូន គជ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់។

ខ.៧.៣.៤ លិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់ថាពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត ដោយបញ្ជាក់ឱ្យបានច្បាស់អំពីនាមត្រកូល នាមខ្លួន និងអាសយដ្ឋាន។ មេឃុំ ចៅសង្កាត់ត្រូវចេញលិខិតបញ្ជាក់នេះជូនតាមការស្នើសុំក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលលិខិតស្នើសុំ ដោយផ្អែកលើបញ្ជីបោះឆ្នោតផ្លូវការ។

ខ.៧.៣.៥ ជីវប្រវត្តិសង្ខេប និងសេចក្តីប្រកាសយល់ព្រមឈរឈ្មោះរបស់បេក្ខជនដែលត្រូវបំពេញដោយផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ មានបិទរូបថត និងរូបថតបេក្ខជនម្នាក់ចំនួន ៣ (បី) សន្លឹកទៀតដែលមានទំហំ ៤x៦ ថតចំពីមុខតាមគំរូរូបថតធ្វើ អ.ខ។ គយ.សប ត្រូវរក្សារូបថតរបស់បេក្ខជននៃគណបក្សនយោបាយនីមួយៗ ដើម្បីបិទផ្សាយជាមួយបញ្ជីបេក្ខជនបន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនរួច នៅទីស្នាក់ការ គយ.សប ១ (មួយ) សន្លឹក បិទផ្សាយជាមួយបញ្ជីបេក្ខជនដំបូងនៅទីស្នាក់ការ គយ.សប ១ (មួយ) សន្លឹក និងបិទផ្សាយជាមួយបញ្ជីបេក្ខជនផ្លូវការនៅទីស្នាក់ការ គយ.សប ១ (មួយ) សន្លឹក។ គយ.សប ត្រូវបិទរូបថតតាមលេខរៀងឈ្មោះបេក្ខជននៃគណបក្សនយោបាយនីមួយៗលើក្រដាសដែលមានទំហំសមស្របទៅតាមចំនួនបេក្ខជន។

ខ.៧.៣.៦ លិខិតសន្យារបស់បេក្ខជនឈរឈ្មោះបោះឆ្នោតដែលជាមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ថានឹងផ្តល់លិខិតអនុញ្ញាតច្បាប់សុំឈប់ពិសេសជូន គយ.សប។

ខ.៧.៣.៧ ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ។

ការដាក់ឱ្យប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ប្រការ ខ.៨.

គ.ជ.ប អាចដាក់ឱ្យប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដើម្បីជាជំនួយដល់គណបក្សនយោបាយដែលមានបំណងរៀបចំបញ្ជីបេក្ខជនឈរឈ្មោះតាមកម្មវិធី និងសម្រួលដល់ការត្រួតពិនិត្យ និងធ្វើឱ្យផ្ទាត់ភាពត្រឹមត្រូវនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗដោយ គយ.សប។

បែបបទ និងនីតិវិធីនៃការប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ គ.ជ.ប។

ការទទួលពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយដោយ គយ.សប

ប្រការ៦.៩.-

គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឃុំ សង្កាត់នីមួយៗ។

៦.៩.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយនៅគ្រប់ទីស្នាក់ការ គយ.សប។

៦.៩.២ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារបរិក្ខារ កុំព្យូទ័រ និងសម្ភារចាំបាច់នានាផ្សេងទៀតដល់ គយ.សប សម្រាប់បម្រើឱ្យការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ចូលទិន្នន័យពាក់ព័ន្ធនឹងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ។

៦.៩.៣ ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនមានរយៈពេល ៣ (បី) ថ្ងៃ គឺរៀងរាល់ថ្ងៃ ព្រឹកចាប់ពីម៉ោង ៧:០០ (ប្រាំពីរ) រហូតដល់ម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០ (ដប់បួន) រហូតដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី។

៦.៩.៤ គយ.សប ត្រូវចេញបង្កាន់ដៃទទួលពាក្យជូនគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងរក្សាគល់បញ្ជី ១ (មួយ) ច្បាប់ ទុកជាឯកសារ។

៦.៩.៥ បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួន និងប្រភេទឯកសារដែលបានទទួលចុះកាលបរិច្ឆេទប្រគល់ ទទួល និងហត្ថលេខា ឬស្នាមមេដៃនៃអ្នកប្រគល់ ទទួល។ បន្ទាប់មក គយ.សប ត្រូវបញ្ចូលព័ត៌មានរបស់គណបក្សនយោបាយ និងស្ថានបង្កាន់ដៃទទួលពាក្យនោះបញ្ចូលទៅក្នុងកម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ។

៦.៩.៦ នៅពេលបញ្ចប់ការទទួលពាក្យ គយ.សប ត្រូវធ្វើកំណត់ហេតុស្តីពីលទ្ធផលនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឃុំ សង្កាត់របស់ខ្លួនចំនួន ៤ (បួន) ច្បាប់ ដោយមានចុះកាលបរិច្ឆេទ ហត្ថលេខា ឈ្មោះ និងបោះត្រា គយ.សប រួចបិទផ្សាយនៅទីស្នាក់ការ គយ.សប ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាលើកំណត់ហេតុនេះបាន។

ប្រការ៦.១០.-

បន្ទាប់ពីថ្ងៃបញ្ចប់ការទទួលពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ គយ.សប ត្រូវធ្វើការពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនទាំងនោះក្នុងរយៈពេល ១ (មួយ) ថ្ងៃ។ គយ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជន។

ប្រការ៦.១១.-

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់មានសិទ្ធិផ្តល់មតិចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបិទផ្សាយខាងលើនេះមក គយ.សប ដើម្បីជាព័ត៌មានសម្រាប់ជាមូលដ្ឋានពិចារណាមុនពេលសម្រេចយល់ព្រម ឬបដិសេធការសុំចុះបញ្ជីបេក្ខជន ហើយ គយ.សប ត្រូវធ្វើកំណត់ហេតុផ្តល់មតិពីប្រជាពលរដ្ឋដែលមកផ្តល់មតិនោះ។

ការពិនិត្យ និងសម្រេចរបស់ គយ.សប លើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ

ប្រការ៦.១២.-

គយ.សប ត្រូវពិនិត្យ និងសម្រេចយល់ព្រម ឬបដិសេធលើពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយតាមលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងប្រការ៦.១ ប្រការ៦.២ ប្រការ៦.៣ ចំណុច ៦.៤.៣ ប្រការ៦.៦ និងប្រការ៦.៧ នៃ ប.ន.ឃ.ស នេះ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យសុំចុះបញ្ជីបេក្ខជន។

៦.១២.១ គយ.សប ត្រូវបញ្ចូលទិន្នន័យបេក្ខជននៃគណបក្សនយោបាយផ្អែកតាមបញ្ជីរាយនាមបេក្ខជនដែលបានភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គយ.សប (ទ.១០០៨) ដោយត្រូវទាញទិន្នន័យពីបញ្ជីបោះឆ្នោតផ្លូវការក្នុងកម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដើម្បីពិនិត្យនិងផ្ទៀងផ្ទាត់លក្ខខណ្ឌរបស់បេក្ខជននៃគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន។

៦.១២.២ ក្នុងករណីគណបក្សនយោបាយណាមួយបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើនេះ គយ.សប ត្រូវសម្រេចយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននោះ ដោយត្រូវបំពេញលើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គយ.សប (ទ.១០០៨) ទាំង ២ (ពីរ) ច្បាប់ ចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គយ.សប រួចផ្ញើជូនគណបក្សនយោបាយសាមី ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៦.១២.២.១ ករណីឃុំ សង្កាត់ណាមួយត្រូវបាន គយ.សប សម្រេចយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយដែលបានដាក់ពាក្យសុំទាំងអស់ក្នុងឃុំ សង្កាត់នោះ គយ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃសម្រេចយល់ព្រម។

៦.១២.២.២ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះមានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២)

ទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ។ នីតិវិធីនៃការប្តឹងជំទាស់នឹងបេក្ខជន ឬបញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្នុងប្រការ៦.១៧ នៃ ប.ន.ឃ.ស នេះ។

៦.១២.២.៣ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៦.១២.២.២ ខាងលើនេះ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេនោះ ចាត់ទុកថាគ្មានការប្តឹងជំទាស់។ បញ្ជីបេក្ខជនដំបូងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ។ គយ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ។

៦.១២.២.៤ គយ.សប ត្រូវធ្វើការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ.ខប ពាក់ព័ន្ធ។ ការចាប់ឆ្នោតកំណត់លំដាប់លេខរៀងនេះ គយ.សប ត្រូវអនុវត្តដូចមានចែងក្នុងប្រការ៦.២២ នៃ ប.ន.ឃ.ស នេះ។

៦.១២.៣ ក្នុងករណីគណបក្សនយោបាយណាមួយបំពេញមិនបានត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើនេះ គយ.សប ត្រូវធ្វើលិខិតជូនដំណឹង និងណែនាំដល់គណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជននោះឱ្យធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវ ហើយផ្តល់ឱកាសឱ្យគណបក្សនយោបាយនោះធ្វើការកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង។

៦.១២.៤ ក្នុងករណីគណបក្សនយោបាយដែលបានទទួលលិខិតជូនដំណឹងពី គយ.សប ឱ្យធ្វើការកែតម្រូវនូវចំណុចខ្វះខាតបានកែតម្រូវត្រឹមត្រូវ និងទាន់ពេលវេលាហើយនោះ គយ.សប ត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនដូចមានចែងក្នុងចំណុច ៦.១២.២ ខាងលើនេះ ក្នុងរយៈពេល ១ (មួយ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំដែលបានកែតម្រូវរួចហើយ។

៦.១២.៤.១ ក្នុងករណីគណបក្សនយោបាយទាំងអស់ដែល គយ.សប ឱ្យធ្វើការកែតម្រូវនូវចំណុចខ្វះខាតបានកែតម្រូវត្រឹមត្រូវហើយត្រូវបាន គយ.សប សម្រេចដូចមានចែងក្នុងចំណុច ៦.១២.៤ ខាងលើនេះ គយ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃសម្រេចយល់ព្រម។

ខ.១២.៤.២ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះមានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ។ នីតិវិធីនៃការប្តឹងជំទាស់នឹងបេក្ខជន ឬបញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្នុងប្រការ ខ.១៧ នៃ ប.ន.ឃ.ស នេះ។

ខ.១២.៤.៣ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ខ.១២.៤.២ ខាងលើនេះ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេនោះ ចាត់ទុកថាគ្មានការប្តឹងជំទាស់។ បញ្ជីបេក្ខជនដំបូងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ។ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ។

ខ.១២.៤.៤ គឃ.សប ត្រូវធ្វើការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ.ខប ពាក់ព័ន្ធ។ ការចាប់ឆ្នោតកំណត់លំដាប់លេខរៀងនេះ គឃ.សប ត្រូវអនុវត្តដូចមានចែងក្នុងប្រការ ខ.២២ នៃ ប.ន.ឃ.ស នេះ។

ខ.១២.៥ ក្នុងករណីគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជនមិនបានកែតម្រូវចំណុចខ្វះខាតតាមលក្ខខណ្ឌ និងពេលវេលាដូចមានចែងក្នុងប្រការ ខ.១២ និងចំណុច ខ.១២.៣ ខាងលើនេះ គឃ.សប ត្រូវបដិសេធពាក្យសុំចុះបញ្ជីបេក្ខជននោះ។

ខ.១២.៦ ក្នុងការសម្រេចបដិសេធ គឃ.សប ត្រូវ៖

ខ.១២.៦.១ បំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ ចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទរួចផ្ញើជូនគណបក្សនយោបាយសាមី ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ខ.១២.៦.២ ប្រគល់ពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ជូនគណបក្សនយោបាយសាមី ឬតំណាងដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាទៅ គធ.ខប (ប្រសិនបើមានការស្នើសុំ)។

ប្រការ៦.១៣.–

គណបក្សនយោបាយណាដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន ហើយត្រូវបាន គយ.សប បដិសេធ គណបក្សនយោបាយសាមី ឬតំណាងមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ទៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៦.១៣.១ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) ប៉ុន្តែគណបក្សនយោបាយសាមី ឬតំណាងពុំបានដាក់ពាក្យបណ្តឹងតវ៉ាទៅ គធ.ខប តាមពេលវេលាដូចមានចែងក្នុងប្រការ៦.១៣ ខាងលើទេនោះ ត្រូវចាត់ទុកថាមិនបានប្តឹងតវ៉ា។

៦.១៣.២ ក្នុងករណីមានពាក្យបណ្តឹងតវ៉ា គធ.ខប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងតវ៉ាពីគណបក្សនយោបាយសាមី ឬតំណាង។ គធ.ខប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលត្រូវបើកសវនាការ។

៦.១៣.៣ ក្នុងករណីសម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា គធ.ខប ត្រូវបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៤ (បួន) ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹងតវ៉ា ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៦.១៣.៤ ក្នុងករណីបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) ដូចមានចែងក្នុងចំណុច ៦.១៣.៣ ខាងលើនេះ គយ.សប ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះ និងត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយសាមី ឬតំណាង ដោយត្រូវបំពេញលើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គយ.សប (ទ.១០០៨) ទាំង ២ (ពីរ) ច្បាប់ ចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គយ.សប រួចផ្ញើជូនគណបក្សនយោបាយសាមី ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៦.១៣.៤.១ ករណីពាក្យបណ្តឹងតវ៉ាទាំងអស់ក្នុងឃុំ សង្កាត់នោះត្រូវបានយល់ព្រមដោយ គធ.ខប គយ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) ពី គធ.ខប។

៦.១៣.៤.២ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះមានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២)

ទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ។ នីតិវិធីនៃការប្តឹងជំទាស់នឹងបេក្ខជន ឬបញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្នុងប្រការ៦.១៧ នៃ ប.ន.ឃ.ស នេះ។

៦.១៣.៤.៣ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៦.១៣.៤.២ ខាងលើនេះ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេនោះ ចាត់ទុកថាគ្មានការប្តឹងជំទាស់។ បញ្ជីបេក្ខជនដំបូងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ។ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ។

៦.១៣.៤.៤ គឃ.សប ត្រូវធ្វើការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ.ខប ពាក់ព័ន្ធ។ ការចាប់ឆ្នោតកំណត់លំដាប់លេខរៀងនេះ គឃ.សប ត្រូវអនុវត្តដូចមានចែងក្នុងប្រការ៦.២២ នៃ ប.ន.ឃ.ស នេះ។

ប្រការ៦.១៤.-

ក្នុងករណីសម្រេចបដិសេធលើពាក្យបណ្តឹងតវ៉ា គធ.ខប ត្រូវបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៤ (បួន) ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ ចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនគណបក្សនយោបាយសាមី ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

គធ.ខប ត្រូវប្រគល់ពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ជូនគណបក្សនយោបាយសម្រាប់បំពេញពាក្យបណ្តឹងតវ៉ាទៅ គ.ជ.ប (ប្រសិនបើមានការស្នើសុំ)។

ប្រការ៦.១៥.-

គណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន ហើយបញ្ជីបេក្ខជននោះត្រូវបានបដិសេធដោយ គធ.ខប គណបក្សនយោបាយសាមី ឬតំណាងមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។



៦.១៥.១ គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។

៦.១៥.២ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនៅទីស្តីការរបស់ខ្លួននូវកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង ដែលត្រូវបើកសវនាការ។

៦.១៥.៣ ក្នុងករណីយល់ព្រមតាមពាក្យបណ្តឹងតវ៉ា គ.ជ.ប ត្រូវ៖

៦.១៥.៣.១ បំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៤ (បួន) ច្បាប់ ចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹងតវ៉ា ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៦.១៥.៣.២ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) ដូចមានចែងក្នុងចំណុច ៦.១៥.៣.១ ខាងលើនេះ រួចហើយ គឃ.សប ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជន និងត្រូវចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយ ហើយចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយសាមី ដោយត្រូវបំពេញលើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងសេចក្តីសម្រេចរបស់ គឃ.សប (ទ.១០០៨) ទាំង ២ (ពីរ) ច្បាប់ ចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គឃ.សប រួចផ្ញើជូនគណបក្សនយោបាយសាមី ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៦.១៥.៣.៣ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) ពី គ.ជ.ប។

៦.១៥.៣.៤ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះមានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ។ នីតិវិធីនៃការប្តឹងជំទាស់នឹងបេក្ខជន ឬបញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្នុងប្រការ៦.១៧ ខាងក្រោមនេះ។

៦.១៥.៣.៥ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៦.១៥.៣.៤ ខាងលើនេះ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេនោះចាត់ទុកថាគ្មានការប្តឹងជំទាស់។ បញ្ជី

បេក្ខជនដំបូងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ។ គយ.សប ត្រូវបិទ
ផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ
និងឈ្មោះបេក្ខជននីមួយៗក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ។

៦.១៥.៣.៦ គយ.សប ត្រូវធ្វើការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជី
បេក្ខជនដែលត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជា
បន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ
គធ.ខប ពាក់ព័ន្ធ។ ការចាប់ឆ្នោតកំណត់លំដាប់លេខរៀងនេះ
គយ.សប ត្រូវអនុវត្តដូចមានចែងក្នុងប្រការ៦.២២ នៃ ប.ន.ឃ.ស នេះ។

៦.១៥.៤ ក្នុងករណីបដិសេធពាក្យបណ្តឹងតវ៉ា គ.ជ.ប ត្រូវ៖

៦.១៥.៤.១ បំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៤ (បួន) ច្បាប់
ចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូន
អ្នកប្តឹងតវ៉ា ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១
(មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សា
ទុកជាឯកសារ ១ (មួយ) ច្បាប់។

៦.១៥.៤.២ ផ្តល់ដំណឹងដល់គណបក្សនយោបាយដែលដាក់ពាក្យបណ្តឹងតវ៉ា ឬ
តំណាងថាសេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ។

ប្រការ៦.១៦.

បន្ទាប់ពីបញ្ចប់រយៈពេលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ហើយឃុំ សង្កាត់ណាដែលការប្តឹងតវ៉ា
ទាំងអស់ត្រូវបានដោះស្រាយរួចរាល់ គ.ជ.ប ត្រូវចាត់ឱ្យ គយ.សប បិទផ្សាយជាសាធារណៈនៅទីស្នាក់ការ
របស់ខ្លួននូវបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច
(ទ.១២០៣) ពី គ.ជ.ប។

ប្រការ៦.១៧.

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះមានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរ
តាមពាក្យបណ្តឹង (ទ.១២០២) ទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ៣ (បី)
ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ។

៦.១៧.១ ពាក្យបណ្តឹងជំទាស់ត្រូវចោទប្រកាន់ទៅលើបេក្ខជន ឬបញ្ជីបេក្ខជននៃគណបក្ស
នយោបាយណាមួយដែលមានភាពមិនប្រក្រតី ឬ/និងដែលបំពេញមិនបានគ្រប់គ្រាន់
តាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ៦.១ ប្រការ៦.២ ប្រការ៦.៣ ប្រការ៦.៤ ប្រការ៦.៦
និងប្រការ៦.៧ នៃ ប.ន.ឃ.ស នេះ។

៦.១៧.២ ពាក្យបណ្តឹងជំទាស់ទាំងនោះត្រូវបង្ហាញអំពីបេក្ខជន ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយជាក់លាក់ណាមួយ ដោយបញ្ជាក់ពីភាពមិនប្រក្រតី ចំណុចខ្វះខាតជាក់ស្តែងរបស់បេក្ខជន ឬបញ្ជីបេក្ខជននោះ និងហេតុផលដែលស្នើសុំឱ្យច្រានចោលបេក្ខជន ឬបញ្ជីបេក្ខជននោះផង។

៦.១៧.២.១ អ្នកប្តឹងជំទាស់អំពីបេក្ខជនណាម្នាក់ ឬច្រើននាក់នៃបញ្ជីបេក្ខជនណាមួយ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីមូលហេតុ ឬ/និងចំណុចខ្វះខាតរបស់បេក្ខជននោះ ឬទាំងនោះដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ស្របទៅនឹងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់។

៦.១៧.២.២ អ្នកប្តឹងជំទាស់អំពីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីភាពមិនប្រក្រតី កំហុស ឬ/និងចំណុចខ្វះខាតខាងផ្លូវច្បាប់របស់គណបក្សនយោបាយក្នុងការរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដើម្បីឱ្យបានស្របទៅនឹងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់។

ប្រការ៦.១៨.

គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈដើម្បីសម្រេចលើពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយដោយផ្អែកលើអង្គច្បាប់ និងអង្គហេតុដែលរួមមានភាពមិនប្រក្រតី ចំណុចខ្វះខាតរបស់បេក្ខជន ឬបញ្ជីបេក្ខជន និងហេតុផលដែលស្នើសុំឱ្យច្រានចោលបេក្ខជន ឬបញ្ជីបេក្ខជនដូចមានចែងក្នុងចំណុច ៦.១៧.១ និងចំណុច ៦.១៧.២ ខាងលើនេះ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។ គ.ជ.ប ត្រូវផ្តល់ព័ត៌មានដល់គណបក្សនយោបាយដែលពាក្យសុំចុះបញ្ជីបេក្ខជនរបស់ខ្លួនមានការប្តឹងជំទាស់ ផ្តល់ព័ត៌មានដល់អ្នកប្តឹងជំទាស់ ឬតំណាង និងផ្សព្វផ្សាយជាសាធារណៈអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលត្រូវបើកសវនាការនោះ។

ប្រការ៦.១៩.

ក្នុងករណីយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងជំទាស់ណាមួយ គ.ជ.ប ត្រូវ៖

៦.១៩.១ បំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៥ (ប្រាំ) ច្បាប់ ចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទរួចផ្ញើជូនអ្នកប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនគណបក្សនយោបាយត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គជ.ឧប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៦.១៩.២ ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ ឬតំណាង និងគណបក្សនយោបាយនៃបញ្ជីបេក្ខជននោះថាសេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ។

ប្រការ៦.២០.-

ក្នុងករណីពាក្យបណ្តឹងជំទាស់ត្រូវបានយល់ព្រមដោយ គ.ជ.ប តាមសម្រង់សេចក្តីសម្រេច (ទ.១២០៣) ដូចមានចែងក្នុងចំណុច ៦.១៩.១ ខាងលើនេះ គយ.សប ត្រូវបដិសេធបេក្ខភាព ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានការប្តឹងជំទាស់នោះ រួចហើយលុបបេក្ខភាព ឬបញ្ជីបេក្ខជននោះចេញ ព្រមទាំងដកហូតនិងបដិសេធលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជននោះ។

៦.២០.១ ក្នុងករណី គ.ជ.ប សម្រេចយល់ព្រមតាមពាក្យបណ្តឹងជំទាស់ដោយលុបបេក្ខភាពបេក្ខជននៃគណបក្សនយោបាយដែលមានការប្តឹងជំទាស់ គយ.សប ត្រូវបដិសេធបេក្ខភាពដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់នោះតែប៉ុណ្ណោះ ដោយរក្សាបញ្ជីបេក្ខជននោះមានសុពលភាពដដែល។

៦.២០.២ ក្នុងករណី គ.ជ.ប សម្រេចយល់ព្រមតាមពាក្យបណ្តឹងជំទាស់ដោយលុបបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានការប្តឹងជំទាស់ គយ.សប ត្រូវលុបបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះចេញ ព្រមទាំងដកហូត និងបដិសេធលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជននោះ។

ប្រការ៦.២១.-

បញ្ជីបេក្ខជនដំបូងនឹងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ប្រសិនបើគ្មានពាក្យបណ្តឹងជំទាស់មកលើបញ្ជីនេះក្នុងរយៈពេលដូចមានចែងក្នុងប្រការ៦.១៧ នៃ ប.ន.ឃ.ស នេះ ឬការប្តឹងជំទាស់ត្រូវបានដោះស្រាយស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ៦.១៨ ប្រការ៦.១៩ និងប្រការ៦.២០ នៃ ប.ន.ឃ.ស នេះ។

ការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

ប្រការ៦.២២.-

គយ.សប ត្រូវធ្វើការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ.ខប។

៦.២២.១ ផ្អែកលើបញ្ជីបេក្ខជនផ្លូវការ គយ.សប ត្រូវធ្វើការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលត្រូវដាក់លើសន្លឹកឆ្នោត។

៦.២២.២ ការចាប់ឆ្នោតត្រូវធ្វើឡើងជាសាធារណៈ។ គយ.សប ត្រូវបិទផ្សាយជាសាធារណៈអំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលាយ៉ាងហោចណាស់ ២៤ (ម្ភៃបួន) ម៉ោងមុននឹងចាប់ផ្តើមធ្វើពិធីចាប់ឆ្នោត។

៦.២២.៣ លិខិតអញ្ជើញត្រូវប្រគល់ជូនទៅគណបក្សនយោបាយនីមួយៗដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់របស់ខ្លួន និងដែលមានចុះហត្ថលេខារបស់អ្នកទទួលសម្រាប់ទុកជាឯកសារយ៉ាងហោចណាស់ ២៤ (ម្ភៃបួន) ម៉ោងមុនពិធីចាប់ឆ្នោត។

៦.២២.៤ របៀបវារៈនៃពិធីចាប់ឆ្នោតមានដូចខាងក្រោមនេះ៖

៦.២២.៤.១ សុន្ទរកថាបើកពិធីថ្លែងដោយប្រធាន គយ.សប។

៦.២២.៤.២ ការបង្ហាញសន្លឹកឆ្នោតសម្រាប់ចាប់ឆ្នោត និងស្រោមសំបុត្រ។

៦.២២.៤.៣ ការចាប់ឆ្នោតត្រូវធ្វើដោយព្រះសង្ឃ ឬឥស្សរជនចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យដែលមានជំហរអព្យាក្រឹត និងដែលអាចទទួលយកបានពីគ្រប់គណបក្សនយោបាយ។

៦.២២.៤.៤ ការប្រកាសលទ្ធផលនៃការចាប់ឆ្នោត។

៦.២២.៤.៥ ការបិទពិធីចាប់ឆ្នោត។

៦.២២.៥ គយ.សប ត្រូវរៀបចំក្រដាសសមួយសន្លឹកសម្រាប់គណបក្សនយោបាយនីមួយៗ។

៦.២២.៥.១ ក្រដាសនេះមានប្រភេទដូចគ្នា និងទំហំប៉ុនគ្នា។

៦.២២.៥.២ ត្រូវសរសេរ ឬបោះពុម្ពឈ្មោះគណបក្សនយោបាយជាអក្សរដែលមានពណ៌ និងប្រភេទតួអក្សរដូចគ្នា និងមានទំហំប៉ុនគ្នានៅលើក្រដាសសនេះ។

៦.២២.៥.៣ ក្រដាសដែលបានសរសេរ ឬបោះពុម្ពឈ្មោះគណបក្សនយោបាយនីមួយៗរួចហើយ ត្រូវក្លាយទៅជាសន្លឹកឆ្នោតរបស់គណបក្សដែលនឹងត្រូវបត់ជាក់ចូលក្នុងស្រោមសំបុត្រដែលមានទំហំប៉ុនគ្នា ពណ៌ដូចគ្នា រួចមូរ និងចងកៅស៊ូកងពណ៌ដូចគ្នា។

៦.២២.៦ មុនចាប់ផ្តើមការចាប់ឆ្នោត គយ.សប ត្រូវបង្ហាញសន្លឹកឆ្នោតរបស់គណបក្សនីមួយៗនៅចំពោះមុខអង្គពិធីមុននឹងបត់ជាក់ចូល និងបិទភ្ជិតស្រោមសំបុត្រ។

៦.២២.៦.១ សន្លឹកឆ្នោតនីមួយៗត្រូវបត់ជា ២ (ពីរ) ផ្នត់ ហើយស៊កបញ្ចូលក្នុងស្រោមសំបុត្ររួចបិទភ្ជិត រួចមូរ និងចងកៅស៊ូកងពណ៌ដូចគ្នា។

៦.២២.៦.២ ស្រោមសំបុត្រឆ្នោតទាំងអស់ត្រូវដាក់ច្របល់បញ្ចូលគ្នាក្នុងកេសតែមួយ ហើយត្រូវក្រឡុកកេសឆ្នោតនោះ។

៦.២២.៦.៣ បន្ទាប់មកត្រូវនិមន្តព្រះសង្ឃ ឬអញ្ជើញឥស្សរជនចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យដែលត្រូវបានជ្រើសរើសហើយតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ៦.២២.៤.៣ ខាងលើនេះចាប់យកស្រោមសំបុត្រឆ្នោតម្តងមួយៗពីកេសឆ្នោត។

៦.២២.៦.៤ ស្រោមសំបុត្រឆ្នោតដែលចាប់បានត្រូវប្រគល់ទៅសមាជិក គយ.សប ១ (មួយ) រូប ក្នុងចំណោម ២ (ពីរ) រូប ដែលជាសមាជិក គយ.សប។

៦.២២.៦.៥ សមាជិក គឃ.សប ១ (មួយ) រូប ត្រូវបើកស្រោមសំបុត្របង្ហាញ សន្លឹកឆ្នោតរបស់គណបក្សនៅចំពោះមុខអង្គពិធី ហើយដូនសន្លឹកឆ្នោត នោះទៅឱ្យសមាជិក គឃ.សប ១ (មួយ) រូបទៀត។

៦.២២.៦.៦ សមាជិក គឃ.សប ១ (មួយ) រូបទៀត ត្រូវអានឈ្មោះគណបក្ស នយោបាយដែលសរសេរនៅលើសន្លឹកឆ្នោតឱ្យបានឮ និងសរសេរ លេខរៀង "លេខ១" នៅលើសន្លឹកឆ្នោតនោះ ហើយត្រូវបន្តធ្វើការ ចាប់ឆ្នោត និងចុះលេខរៀងតាមលំដាប់រហូតដល់សន្លឹកឆ្នោត ចុងក្រោយបង្អស់។

៦.២២.៧ សមាជិក គឃ.សប ទទួលបន្ទុកលើការងាររដ្ឋបាលត្រូវបញ្ចូលទិន្នន័យលទ្ធផលលំដាប់លេខរៀងទៅក្នុងកម្មវិធីកុំព្យូទ័រ ហើយបោះពុម្ពកំណត់ហេតុនៃការចាប់ឆ្នោតកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត (ទ.១១២១) ដោយត្រូវដាក់ភ្ជាប់ជាមួយនូវសន្លឹកឆ្នោតរបស់គណបក្សដែលបានចុះលេខរៀងហើយដូចមានចែងក្នុងចំណុច ៦.២២.៦.៦ ខាងលើនេះ រួចចុះហត្ថលេខា និងដាក់ជូនប្រធាន គឃ.សប ចុះហត្ថលេខា។ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខានៅលើកំណត់ហេតុនេះបាន។

៦.២២.៨ បន្ទាប់មកសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលត្រូវស្តែនកំណត់ហេតុនៃការចាប់ឆ្នោតកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត (ទ.១១២១) ដែលបានចុះហត្ថលេខាចូលក្នុងកម្មវិធីកុំព្យូទ័រទុកសម្រាប់បម្រើឱ្យការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់។

៦.២២.៩ គឃ.សប ត្រូវធ្វើបញ្ជីកំណត់លេខរៀងបញ្ជីបេក្ខជនដែលត្រូវដាក់លើសន្លឹកឆ្នោតតាមលទ្ធផលនៃការចាប់ឆ្នោតចំនួន ៤ (បួន) ច្បាប់ ផ្ញើជូន គ.ជ.ប (នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម) ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្នាក់ការ គឃ.សប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។ គឃ.សប ត្រូវធ្វើរបាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះ ដោយភ្ជាប់ជាមួយនូវកំណត់ហេតុដូចមានចែងក្នុងចំណុច ៦.២២.៧ ខាងលើនេះ ដើម្បីផ្ញើជូន គ.ជ.ប (នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម) តាមរយៈ គធ.ខប ពាក់ព័ន្ធ។ បន្ទាប់ពីទទួលបានរបាយការណ៍ពី គឃ.សប នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យ ផ្ទៀងផ្ទាត់ រួចបញ្ជូនបញ្ជីខាងលើនេះទៅនាយកដ្ឋានប្រតិបត្តិការដើម្បីរៀបចំគំរូសន្លឹកឆ្នោត។

៦.២២.១០ គ.ជ.ប ត្រូវធ្វើគំរូ និងបោះពុម្ពសន្លឹកឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ។

៦.២២.១០.១ ការបោះពុម្ពសន្លឹកឆ្នោតត្រូវផ្អែកតាមចំនួនគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនផ្លូវការនៅក្នុងឃុំ សង្កាត់នោះ។ សន្លឹកឆ្នោតសម្រាប់ឃុំ សង្កាត់ណាប្រើប្រាស់បានតែនៅមណ្ឌលឃុំ សង្កាត់នោះតែប៉ុណ្ណោះ។

៦.២២.១០.២ ឈ្មោះ សញ្ញាសម្គាល់គណបក្សនយោបាយនៅលើសន្លឹកឆ្នោតត្រូវបោះពុម្ពតាមរបៀបតែមួយគត់ ហើយលេខសម្គាល់របស់គណបក្សនយោបាយត្រូវដាក់ជាលេខរៀងតាមលទ្ធផលនៃការចាប់ឆ្នោត។

ប្រការ៦.២៣.

គយ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជនក្នុងបញ្ជីនីមួយៗ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីបញ្ជីបេក្ខជនដំបូងក្លាយជាបញ្ជីបេក្ខជនផ្លូវការ។ បញ្ជីបេក្ខជនផ្លូវការ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជននៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ។

ប្រការ៦.២៤.

គ.ជ.ប ត្រូវរៀបចំបញ្ជីបេក្ខជនផ្លូវការតាមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់នីមួយៗ ដោយផ្អែកតាមទិន្នន័យបញ្ជីបេក្ខជនដែលបានបញ្ចូលក្នុងកម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ។

៦.២៤.១ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវគ្រប់គ្រងទិន្នន័យបញ្ជីបេក្ខជនផ្លូវការ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធដើម្បីប្រគល់ទិន្នន័យនេះ សម្រាប់បម្រើឱ្យការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៦.២៤.២ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវរៀបចំរបាយការណ៍អំពីលទ្ធផលនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើស កបយ.ស និងសុំ គ.ជ.ប ពិនិត្យ សម្រេចមុននឹងធ្វើការផ្សព្វផ្សាយជាសាធារណៈ។

ប្រការ៦.២៥.

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវរៀបចំសៀវភៅណែនាំអំពីការប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ។

ប្រការ៦.២៦.

គណបក្សនយោបាយ និងបេក្ខជននៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗដែលបានចុះបញ្ជីជាផ្លូវការត្រូវគោរព ច.ប.ឃ.ស ច.វ.ច.ប ប.ន.ឃ.ស នេះ និងក្រមសីលធម៌ដែលកំណត់ដោយ គ.ជ.ប។

ជំពូកទី៧
ការឃោសនាបោះឆ្នោត

បទប្បញ្ញត្តិទូទៅនៃការឃោសនាបោះឆ្នោត

ប្រការ៧.១.

អនុលោមតាម ច.ប.ឃ.ស ការឃោសនាបោះឆ្នោតមានបំណងឱ្យគណបក្សនយោបាយដែលបានអនុញ្ញាតឱ្យចុះបញ្ជីបេក្ខជន និងបេក្ខជនធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ដល់អ្នកបោះឆ្នោត។ ការឃោសនាបោះឆ្នោតគឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជនណាម្នាក់ ឬគណបក្សនយោបាយណាមួយ។ សកម្មភាពមួយចំនួនដើម្បីគាំទ្របេក្ខជនណាម្នាក់ ឬគណបក្សនយោបាយណាមួយមានដូចជា៖

- ៧.១.១ ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន។
- ៧.១.២ ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅឃុំ សង្កាត់យ៉ាងច្រើន ២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។
- ៧.១.៣ ការជួបជុំ ឬការឃោសនាតាមផ្ទះ។
- ៧.១.៤ ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន។
- ៧.១.៥ ការផ្សព្វផ្សាយតាមរលកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាស្សែតវីដេអូ ឬវីស៊ីឌី ឬឌីវីឌីក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ។
- ៧.១.៦ សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនានានា។
- ៧.១.៧ សកម្មភាពចែកចាយខិត្តបណ្ណគណបក្សនយោបាយដើម្បីឱ្យអ្នកបោះឆ្នោតបោះឆ្នោតឱ្យខ្លួន ឬគណបក្សនយោបាយរបស់ខ្លួន។
- ៧.១.៨ សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬ/និងបេក្ខជនជូនអ្នកបោះឆ្នោត។
- ៧.១.៩ សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទប្រកាសផ្សាយពីគោលនយោបាយរបស់គណបក្សនយោបាយ ឬបេក្ខជន។
- ៧.១.១០ ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត ដើម្បីផ្សព្វផ្សាយគាំទ្របេក្ខជនណាម្នាក់ ឬគណបក្សនយោបាយណាមួយ។
- ៧.១.១១ ការរៀបចំកម្មវិធីប្រកួតកីឡាដើម្បីគាំទ្របេក្ខជនណាម្នាក់ ឬគណបក្សនយោបាយណាមួយ។

ប្រការ៧.២.

ការឃោសនាបោះឆ្នោតត្រូវបើករយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃមុនថ្ងៃបោះឆ្នោត។ ការឃោសនាបោះឆ្នោតមានរយៈពេល ១៤ (ដប់បួន) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់ ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោត។

៧.២.១ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើមពីម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក រហូតដល់ម៉ោង ២២:០០ (ម្ភៃពីរ)។

៧.២.២ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវឈប់សម្រាកនៅចន្លោះពីម៉ោង ២២:០០ (ម្ភៃពីរ) រហូតដល់ម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក។

៧.២.៣ សកម្មភាពឃោសនាបោះឆ្នោតដោយឧបករណ៍បំពងសំឡេងត្រូវបានកំណត់ដូចខាងក្រោម៖

- ត្រូវហាមឃាត់ចាប់ពីម៉ោង ១២:០០ (ដប់ពីរ) ថ្ងៃត្រង់ រហូតដល់ម៉ោង ១៤:០០ (ដប់បួន)
- ត្រូវហាមឃាត់នៅក្បែរមន្ទីរពេទ្យ
- ត្រូវហាមឃាត់នៅក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានាក្នុងពេលម៉ោងសិក្សា លើកលែងតែនៅក្រៅពេលម៉ោងសិក្សា។

៧.២.៤ គ្រប់សកម្មភាពឃោសនាបោះឆ្នោតដូចមានចែងក្នុងជំពូកទី៧ នេះ ត្រូវបញ្ឈប់ទាំងអស់ក្នុងអំឡុងពេល ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។ ជនណា ឬគណបក្សនយោបាយណាប្រព្រឹត្តល្មើសនឹងបម្រាមនេះ ត្រូវទទួលការពិន័យតាម ច.ប.ឃ.ស និង ច.វ.ច.ប។

៧.២.៥ រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិពាក់ព័ន្ធនឹងកិច្ចការបោះឆ្នោត ត្រូវបញ្ឈប់ ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃបោះឆ្នោត។ ការស្ទង់មតិពាក់ព័ន្ធនឹងកិច្ចការបោះឆ្នោត គឺជាការប្រើសំណាកដែលបានជ្រើសរើស ឬ/និងបញ្ជីសំណួរដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីដំណើរការបោះឆ្នោត។ រាល់ការរៀបចំការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោតត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ដំណើរការប្រកបដោយតម្លាភាព និងភាពមិនលម្អៀង
- រៀបចំឡើងដោយអង្គការ ឬស្ថាប័នដែលមានវិជ្ជាជីវៈ
- ការគោរពសិទ្ធិ សេរីភាពបុគ្គល
- រក្សាការសម្ងាត់នៃការបោះឆ្នោតរបស់អ្នកបោះឆ្នោត
- ការមិនបង្កឱ្យមានអសន្តិសុខ ភាពចលាចល ឬការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬការធ្វើឱ្យភាន់ច្រឡំក្នុងដំណើរការបោះឆ្នោត

- លទ្ធផលដែលបានមកពីការស្នង់មតិត្រូវបញ្ជាក់អំពីប្រភពផ្តល់ព័ត៌មាន ពេលវេលា ចំនួនប្រជាពលរដ្ឋដែលត្រូវបានជ្រើសរើសមកស្នង់មតិ កម្រិតលម្អៀងនៃលទ្ធផល ព្រមទាំងត្រូវផ្តល់ជូនគណបក្សនយោបាយ និងផ្សព្វផ្សាយជូនសាធារណជនដោយស្មើភាព។

ប្រការ៧.៣.-

គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិលើកស្លាកសញ្ញាគណបក្សរបស់ខ្លួន ឬបិទផ្សាយឯកសារយោសនាបោះឆ្នោតបម្រើឱ្យគោលដៅយោសនាបោះឆ្នោតបាននៅទីសាធារណៈ ឬនៅទីស្នាក់ការរបស់ខ្លួន ឬទីកន្លែងឯកជនដោយមានការអនុញ្ញាតពីម្ចាស់ទីតាំង ក្នុងអំឡុងពេលយោសនាបោះឆ្នោត។

៧.៣.១ ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភណភាពសាធារណៈ។

៧.៣.២ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារយោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយមិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទនៅបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ។

៧.៣.៣ ស្លាកសញ្ញាគណបក្សនយោបាយនីមួយៗត្រូវដាក់ឈ្មោះ និងសញ្ញាសម្គាល់រៀងៗខ្លួន ទោះបីជាគណបក្សនយោបាយនោះមានសម្ព័ន្ធភាពជាមួយគ្នាក៏ដោយ។

៧.៣.៤ ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាយោសនាបោះឆ្នោត រូបសញ្ញាយោសនាបោះឆ្នោត ពាក្យស្លោក ខិត្តបណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនបើមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទស្លាកសញ្ញា បដាយោសនាបោះឆ្នោត រូបសញ្ញាយោសនាបោះឆ្នោត ពាក្យស្លោក ខិត្តបណ្ណរបស់គណបក្សនយោបាយណាមួយបាន។

៧.៣.៥ ស្លាកសញ្ញា ឬសម្ភារយោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោតត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការយោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ។

៧.៣.៦ គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវបណ្ណប្រកាស ឬបណ្ណបិទផ្សាយ បដា ឯកសារយោសនាបោះឆ្នោតទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

ប្រការ៧.៤.

ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្តល់ជូននូវយានជំនិះមិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនោះមានលក្ខណៈឯកជន មិនមានទ្រង់ទ្រាយធំ និងមិនមានភ្ជាប់នូវការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១ ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូនជាទ្រព្យសម្បត្តិរបស់រដ្ឋដែលមានផ្លាកលេខ ឬដោះផ្លាកលេខចេញ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូនជាទ្រព្យសម្បត្តិរបស់រដ្ឋដែលមានផ្លាកលេខ ឬដោះផ្លាកលេខចេញ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។

៧.៤.២ មធ្យោបាយដឹកជញ្ជូនដែលជាទ្រព្យសម្បត្តិរបស់រដ្ឋត្រូវបានកំណត់ រួមមានរថយន្តត្រីចក្រយានយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទដែលប្រើប្រាស់ផ្លាកលេខសម្គាល់យានជំនិះដែលមានអក្សររដ្ឋ នគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល។

៧.៤.៣ ការដឹកជញ្ជូនមានលក្ខណៈប្រមូលផ្តុំ ឬរៀបចំទុកជាមុនត្រូវហាមឃាត់ លើកលែងតែករណីចាំបាច់មានការសម្រេចផ្សេងពីនេះដោយ គ.ជ.ប។

ប្រការ៧.៥.

ការស្លៀកពាក់ (សម្លៀកបំពាក់ មួក) ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា សារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់មិនរាប់បញ្ចូលទៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ លើកលែងតែការស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត។

ប្រការ៧.៦.

គណបក្សនយោបាយអាចហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទក្នុងអំឡុងពេលឃោសនាបោះឆ្នោតយ៉ាងច្រើន ២ (ពីរ) ដងនៅក្នុងឃុំ សង្កាត់ ដែលគណបក្សមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

៧.៦.១ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទត្រូវបានកំណត់ដូចខាងក្រោម៖

៧.៦.១.១ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ដែលគណបក្សនយោបាយសាមីបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

៧.៦.១.២ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទមិនត្រូវបានអនុញ្ញាតឱ្យធ្វើឆ្លងឃុំ សង្កាត់។

៧.៦.១.៣ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទក្នុងឃុំ សង្កាត់ ឬពីឃុំ សង្កាត់មួយទៅឃុំ សង្កាត់មួយផ្សេងទៀត ត្រូវបានចាត់ទុកថាជាការហែក្បួនចំនួន ១ (មួយ) ដងក្នុងក្របខ័ណ្ឌមណ្ឌលបោះឆ្នោតឃុំ សង្កាត់ទាំងនោះ។

៧.៦.១.៤ គណបក្សនយោបាយដែលហែក្បួនឃោសនាបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ហើយតម្រាយផ្លូវនៃក្បួនឃោសនាបោះឆ្នោតនោះត្រូវឆ្លងកាត់ឃុំ សង្កាត់ដទៃ ដោយសារស្ថានភាពទីតាំងភូមិសាស្ត្រជាក់ស្តែងនៃឃុំ សង្កាត់នោះមានព្រំប្រទល់ជាប់គ្នាដែលមិនអាចវាងបាន គណបក្សនយោបាយសាមីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គយ.សប ពាក់ព័ន្ធយ៉ាងតិចឱ្យបាន ៣ (បី) ថ្ងៃមុនថ្ងៃហែក្បួនឃោសនាបោះឆ្នោត ទោះបីជាឃុំ សង្កាត់ដែលត្រូវឆ្លងកាត់នោះខ្លួនមានឬគ្មានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក៏ដោយ។ ក្នុងដំណើរឆ្លងកាត់នេះ គណបក្សនយោបាយសាមីត្រូវបិទឧបករណ៍បំពងសំឡេង និងផ្អាករាល់សកម្មភាពឃោសនាបោះឆ្នោតរបស់ខ្លួន។ គយ.សប ពាក់ព័ន្ធត្រូវស្នើសុំកិច្ចសហការ និងការសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចាត់វិធានការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងពេលឃោសនាបោះឆ្នោត។

៧.៦.១.៥ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ទម្រង់ និងទំហំដូចខាងក្រោម៖

- មានការរៀបចំជាក្បួន មានបិទបដា ឬ/និងពាក្យស្លោក ឬ/និងសារនយោបាយផ្សេងៗភ្ជាប់នឹងរថយន្ត ឬ/និងទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ឬជលយានគ្រប់ប្រភេទ និងមានការចាក់ផ្សាយដោយឧបករណ៍បំពងសំឡេង

- មានអ្នកចូលរួមចាប់ពី ២០ (ម្ភៃ) នាក់ឡើងទៅ ដោយក្រុមថ្មើរជើង ឬ/និងប្រើប្រាស់យានជំនិះតាមប្រភេទណាមួយ ឬទាំងអស់ក្នុងការឃោសនាបោះឆ្នោតមានដូចខាងក្រោម៖
  - រថយន្តចាប់ពី ២ (ពីរ) គ្រឿងឡើងទៅ អមដោយទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ១០ (ដប់) គ្រឿងឡើងទៅ
  - ទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ២០ (ម្ភៃ) គ្រឿងឡើងទៅ
  - ជលយានគ្រប់ប្រភេទចាប់ពី ៥ (ប្រាំ) គ្រឿងឡើងទៅ។

៧.៦.២ គណបក្សនយោបាយដែលមានបំណងហែក្បួនឃោសនាបោះឆ្នោត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គយ.សប យ៉ាងហោចឱ្យបាន ៣ (បី) ថ្ងៃមុនថ្ងៃហែក្បួនឃោសនាបោះឆ្នោត។ ការជូនដំណឹងនេះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី៖

៧.៦.២.១ នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ។

៧.៦.២.២ កាលបរិច្ឆេទ និងពេលវេលានៃការហែក្បួន។

៧.៦.២.៣ ទីតាំងប្រមូលផ្តុំ និងគម្រោយផ្លូវដែលត្រូវហែក្បួន និងទីតាំងរំសាយ។

៧.៦.២.៤ ចំនួនអ្នកចូលរួម។

៧.៦.២.៥ ចំនួនយានជំនិះតាមប្រភេទនីមួយៗ។

៧.៦.៣ ក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗត្រូវរក្សានូវសណ្តាប់ធ្នាប់ល្អតាមដងផ្លូវ ទីប្រជុំជន ទីសាធារណៈ និងត្រូវយកចិត្តទុកដាក់គោរពតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

៧.៦.៤ ការបង្ហោះអាកាសយានគ្មានមនុស្សបើក (ដ្រូន) សម្រាប់ថតសកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ប្រការ៧.៧.

មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការមិនត្រូវធ្វើសកម្មភាពដូចខាងក្រោម៖

៧.៧.១ ប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ។

៧.៧.២ ប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោតស្វែងរកសំឡេងឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៧.៣ ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ឡើយ។ ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការដែលកំពុងបំពេញការកិច្ច ត្រូវបានកំណត់ដូចតទៅ៖

៧.៧.៣.១ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៧.៧.៣.២ ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

៧.៧.៣.៣ ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៧.៣.៤ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៧.៣.៥ ការធ្វើសកម្មភាពចែកចាយសម្ភារឃោសនាបោះឆ្នោតដល់អ្នកបោះឆ្នោតក្នុងគោលបំណងគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

៧.៧.៣.៦ ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

៧.៧.៣.៧ ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

ប្រការ៧.៨.

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថកាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការអាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ។

ប្រការ៧.៩.

ក្នុងដំណើរការបោះឆ្នោត មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវអនុវត្តតួនាទី និងកាតព្វកិច្ចរបស់ខ្លួនស្របតាមគោលការណ៍ណែនាំដូចមានណែនាំក្នុងសៀវភៅណែនាំរបស់ គ.ជ.ប ស្តីពីការកិច្ច និងកាតព្វកិច្ចរបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិក្នុងដំណើរការរៀបចំការបោះឆ្នោត។ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មានសិទ្ធិបញ្ចេញមតិយោបល់ផ្ទាល់ខ្លួន និងមានសិទ្ធិចូលរួមក្នុងជីវភាពនយោបាយដើម្បីគាំទ្រគណបក្សនយោបាយដែលខ្លួនជ្រើសរើស ប៉ុន្តែសកម្មភាពទាំងនោះត្រូវធ្វើក្នុងឋានៈជាបុគ្គលឯកជន មិនមែនក្នុងតួនាទីជាមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិឡើយ។ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវព្យាយាមធ្វើឱ្យបាននូវសកម្មភាពដូចខាងក្រោម៖

៧.៩.១ ផ្តល់សេវា និងព័ត៌មានដូចៗគ្នាជូនដល់អ្នកភូមិទាំងអស់ ដោយមិនប្រកាន់និន្នាការនយោបាយ ដើម្បីបង្កើតបរិយាកាសជឿទុកចិត្តគ្នា។

៧.៩.២ ធានាថាការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត និងព័ត៌មានផ្សេងៗដទៃទៀត ត្រូវបានអនុវត្តដោយយុត្តិធម៌ ដោយស្មើភាព និងអស់ពីកម្លាំងចិត្តដល់អ្នកភូមិគ្រប់ៗរូប និងដោយឥតគិតថ្លៃ។

៧.៩.៣ ត្រូវប្រកាន់ខ្ជាប់ឥរិយាបថអព្យាក្រឹត ឥតលម្អៀងនៅក្នុងការបំពេញការងារទាក់ទងនឹងដំណើរការរៀបចំការបោះឆ្នោត។

៧.៩.៤ ត្រូវរាប់អាន ទទួលស្គាល់ និងអនុវត្តការងារចំពោះអ្នកភូមិគ្រប់ៗរូបឱ្យបានស្មើគ្នា។

៧.៩.៥ ផ្តល់កិច្ចសហការជាមួយនឹង គឃ.សប គធ.ឧប និង គ.ជ.ប ទាក់ទងនឹងការអនុវត្តការងារបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ ដូចជាការផ្តល់ព័ត៌មានអំពីការបោះឆ្នោត ការចែកខិត្តបណ្ណ សៀវភៅព័ត៌មាន បណ្ណប្រកាសផ្សេងៗ ជាដើម ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

ប្រការ៧.១០.

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិត្រូវជៀសវាងការគំរាមកំហែង ឬបង្ហាញឥរិយាបថលម្អៀងក្នុងការអនុវត្តការងាររបស់ខ្លួនទាក់ទងនឹងការបោះឆ្នោត។ ក្នុងពេលអនុវត្តការងារ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិមិនត្រូវអនុវត្តដូចខាងក្រោម៖

៧.១០.១ បង្ហាញការគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយជាសាធារណៈ។

៧.១០.២ ប្រើប្រាស់ឥទ្ធិពល ឬតួនាទីរបស់ខ្លួនរំលោភលើសិទ្ធិសម្រេចរបស់ប្រជាពលរដ្ឋចូលរួមក្នុងដំណើរការបោះឆ្នោត។ ការរំលោភលើសិទ្ធិរួមមាន៖

៧.១០.២.១ បំភិតបំភ័យ ឬគំរាមកំហែងអ្នកបោះឆ្នោតក្នុងគោលបំណងឱ្យអ្នកបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១០.២.២ សួរនាំអ្នកបោះឆ្នោត ឬចង់ដឹងអំពីការបោះឆ្នោតជាសម្ងាត់របស់អ្នកបោះឆ្នោត។

៧.១០.២.៣ ដកហូត អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ ពីប្រជាពលរដ្ឋ។

៧.១០.២.៤ ជ្រៀតជ្រែកលើសិទ្ធិអ្នកបោះឆ្នោតក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយសេរី ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១០.២.៥ បញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យគាំទ្រ ឬប្រឆាំងចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១០.២.៦ រារាំងអ្នកភូមិគ្រប់រូបដែលមានបំណងចូលរួមក្នុងកិច្ចប្រជុំរបស់គណបក្សនយោបាយណាមួយ ឬរារាំងការទទួលព័ត៌មានពីគណបក្សនយោបាយណាមួយ។

៧.១០.៣ ធ្វើសកម្មភាពណាមួយ ទោះដោយប្រយោលក្តី ឬផ្ទាល់ក្តី ដើម្បីបំភិតបំភ័យ គំរាមកំហែងអ្នកបោះឆ្នោត ដែលនាំឱ្យបាត់សេរីភាពនៃការជ្រើសរើសរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោត។

៧.១០.៤ ធ្វើជាអ្នកផ្សព្វផ្សាយឱ្យគណបក្សនយោបាយណាមួយ ដែលនាំឱ្យដុះតិទ្ធិពលដល់អ្នកភូមិ និងបាត់បង់ភាពយុត្តិធម៌សម្រាប់គណបក្សនយោបាយផ្សេងទៀត។

៧.១០.៥ ផ្ទឹបទុកព័ត៌មាន ឬផ្សព្វផ្សាយព័ត៌មានដោយមានការរើសអើងចំពោះអ្នកគាំទ្រគណបក្សនយោបាយណាមួយ។

ប្រការ៧.១១.

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើសកបយ.ស។ អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជាមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដូចខាងក្រោម៖

៧.១១.១ ផ្តួចផ្តើម ឬចូលរួមនៅក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការផ្តួចផ្តើម ឬការចូលរួមឃោសនាបោះឆ្នោតរួមមាន៖

៧.១១.១.១ ការបញ្ចុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនាបោះឆ្នោតដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.១.២ ការចូលរួមក្នុងក្បួនដង្ហែ ការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.១.៣ ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.១.៤ ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៧.១១.២ ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ និងការបង្ហាញភាពលម្អៀងរួមមាន៖

៧.១១.២.១ ការស្នងមតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.២.២ ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.២.៣ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យប្រមាថ មាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.២.៤ ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួនដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.៣ ផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស រួមមាន៖

៧.១១.៣.១ ការផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.៣.២ ការផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋសម្រាប់ចូលរួមឃោសនាបោះឆ្នោត ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.៣.៣ ការផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ក្បួនដង្ហែឃោសនាបោះឆ្នោត ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនាបោះឆ្នោត ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.១១.៤ ហាមជនបរទេសដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងការឃោសនាបោះឆ្នោតដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ប្រការ៧.១២.-

មុននឹងបើកការឃោសនាបោះឆ្នោត គធ.ខប និង គយ.សប ត្រូវផ្សព្វផ្សាយដល់មន្ត្រីដែលបានកំណត់ក្នុងប្រការ៧.៧ រហូតដល់ប្រការ៧.១១ នៃ ប.ន.ឃ.ស នេះ តាមរយៈអាជ្ញាធរដែនដី កងយោធពលខេមរភូមិន្ទ នគរបាលជាតិថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ឬ/និងកិច្ចប្រជុំនានាអំពីភារកិច្ច និងអព្យាក្រឹតភាពក្នុងពេលធ្វើការទាក់ទិនដល់ការឃោសនាបោះឆ្នោត។

ប្រការ៧.១៣.-

គធ.ខប និង គយ.សប ត្រូវចាត់ចែងកម្មវិធីប្រជុំប្រចាំសប្តាហ៍ និងប្រជុំបន្ថែមតាមការចាំបាច់ជាមួយតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងភាគីពាក់ព័ន្ធនានា ដើម្បី៖

៧.១៣.១ ជម្រាបឱ្យដឹងពីការវិវត្តនៃដំណើរការបោះឆ្នោត។

៧.១៣.២ ជម្រាបជូនជាសង្ខេបពី ប.ន.ឃ.ស នេះ។

៧.១៣.៣ ស្តាប់មតិយោបល់ សំណូមពរ និងការកត់សម្គាល់ផ្សេងៗ។

៧.១៣.៤ ពិភាក្សាលើបញ្ហាផ្សេងៗទៀតដែលពាក់ព័ន្ធដល់ដំណើរការបោះឆ្នោត។

ប្រការ៧.១៤.-

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ត្រូវតែគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុង ច.ប.ឃ.ស ច.វ.ច.ប ប.ន.ឃ.ស នេះ ក្រមសីលធម៌ គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

៧.១៤.១ គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ។

៧.១៤.២ គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវបង្គាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួនទៅហែក ឬបំផ្លាញចោលសម្ភារ ឯកសារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងបេក្ខជនដទៃឡើយ។

៧.១៤.៣ គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់ត្រូវជៀសវាងប្រព្រឹត្តអំពើគំរាមកំហែង បំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៧.១៤.៤ គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភ គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ។

៧.១៤.៥ គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន អ្នកគាំទ្រ ឬបុគ្គលណាម្នាក់ឡើយ។

៧.១៤.៦ គ្រប់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រទាំងអស់មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយឡើយ។

៧.១៤.៧ គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជាវង្វាន់លើកទឹកចិត្ត វិភាគទាន ជូនសគុណ ឬវង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត។

៧.១៤.៨ គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ក្នុងពេលឃោសនាបោះឆ្នោត។

៧.១៤.៩ គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវព្យាយាមដោយទុច្ចរិតតាមគ្រប់មធ្យោបាយដើម្បីរារាំង ឬញុះញង់អ្នកបោះឆ្នោតមិនឱ្យចូលរួមក្នុងដំណើរការបោះឆ្នោតឬណែនាំ ញុះញង់អ្នកបោះឆ្នោតឱ្យបំផ្លាញឬធ្វើឱ្យខូចសន្លឹកឆ្នោតឬដំណើរការបោះឆ្នោត។

៧.១៤.១០ គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយ ដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលទាំងនោះឱ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀតឡើយ។ ការគំរាមកំហែង ការបំភិតបំភ័យ និងការបំបាក់ទឹកចិត្តរួមមាន៖

៧.១៤.១០.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ។

៧.១៤.១០.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរដោលាយលក្ខណ៍អក្សរក្នុងន័យថានឹងធ្វើទារុណកម្ម។

៧.១៤.១០.៣ ការវាយតប់បន្តិចបន្តួច ឬធ្ងន់ធ្ងរលើបុគ្គលណាម្នាក់។

៧.១៤.១០.៤ ការគំរាមដោយពាក្យសម្តីថានឹងធ្វើទារុណកម្មដល់រាងកាយ។

៧.១៤.១០.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ។

៧.១៤.១០.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាល ដូចជាឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់។

៧.១៤.១០.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ លើដំបូលផ្ទះ លើយានដំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ។

៧.១៤.១០.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់សុវត្ថិភាព និងអាយុជីវិតរបស់ខ្លួន ឬបងប្អូនក្រុមគ្រួសាររបស់ខ្លួន។

៧.១៤.១០.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន។

៧.១៤.១០.១០ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ឬអចលនទ្រព្យដទៃទៀត ឬធ្វើឱ្យខូចផលប្រយោជន៍មុខរបរ ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត។

៧.១៤.១០.១១ ការប្រមូល ការដកហូត ឬការបំផ្លាញឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតរបស់អ្នកបោះឆ្នោត។

៧.១៤.១០.១២ ការកំហិតសិទ្ធិណាមួយចំពោះអ្នកបោះឆ្នោតក្នុងការស្វែងរក ឬស្តាប់នូវព័ត៌មានអំពីគណបក្សនយោបាយនានា។

ប្រការ៧.១៥.

គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់ដែលប្រព្រឹត្តផ្ទុយនឹងប្រការ៧.១៤ ខាងលើនេះ នឹងត្រូវទទួលទោសតាមបញ្ញត្តិនៃ ច.ប.ឃ.ស និង ច.វ.ច.ប។

សម្ភារអប់រំអ្នកបោះឆ្នោត

ប្រការ៧.១៦.-

អគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ដែលមាននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈជាសេនាធិការ ទទួលខុសត្រូវក្នុងការផលិត និងការផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត និងសាធារណជនដើម្បីលើកកម្ពស់ការយល់ដឹងអំពីដំណើរការបោះឆ្នោត។

៧.១៦.១ គ.ជ.ប អំពាវនាវ និងលើកទឹកចិត្តដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលកំពុងបំពេញការកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យចូលរួមយ៉ាងសកម្ម ដើម្បីឱ្យការអប់រំសាធារណជនដែលទាក់ទងដល់ដំណើរការបោះឆ្នោតមានប្រសិទ្ធភាពខ្ពស់។

៧.១៦.២ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលកំពុងបំពេញការកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងសហការជាមួយ គ.ជ.ប នៅក្នុងផ្នែកណាមួយនៃការអប់រំសាធារណជនអំពីការបោះឆ្នោតអាចទាក់ទងព័ត៌មានជាមួយនឹងនាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈនៃអគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ។

៧.១៦.៣ សម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិត្រូវតែអព្យាក្រឹត និងមិនលម្អៀង។ សម្ភារនោះមិនត្រូវគាំទ្រ ឬបន្ទុះបង្អាប់គណបក្សនយោបាយ ហើយត្រូវគោរពទៅតាម ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ។

៧.១៦.៤ សម្ភារព័ត៌មានសាធារណៈ និងសម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយ គ.ជ.ប និងសម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិដែលបានទទួលលិខិតយល់ព្រមពី គ.ជ.ប ត្រូវបានរក្សាសិទ្ធិ ហើយមិនត្រូវបន្ថែម ឬបន្ថយខ្លឹមសារដោយគ្មានការយល់ព្រមពី គ.ជ.ប ឡើយ។

៧.១៦.៥ ដើម្បីធានាថាខ្លឹមសារនៃសម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិត្រឹមត្រូវតាមបច្ចេកទេស និងតាម ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ គ.ជ.ប នឹងជួយផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ និងយល់ព្រម និងណែនាំដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលអំពីលក្ខណៈបច្ចេកទេស និងបញ្ហាក់ពីភាពស្របច្បាប់នៃសម្ភារអប់រំនេះ។



៧.១៦.៦ ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោតពុំត្រូវឱ្យមានសេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ និងយល់ព្រមចាំបាច់ពី គ.ជ.ប ឡើយ។

៧.១៦.៧ ទោះបីជាសម្ភារអប់រំអ្នកបោះឆ្នោតត្រូវបានទទួល ឬមិនបានទទួលលិខិតយល់ព្រមក៏ដោយ អ្នកទទួលបោះពុម្ពផ្សាយ និងអ្នកទទួលផ្សព្វផ្សាយត្រូវស្គាល់អត្តសញ្ញាណអតិថិជនរបស់ខ្លួន ហើយមិនទទួលខុសត្រូវចំពោះមុខច្បាប់បោះឆ្នោតចំពោះខ្លឹមសារបច្ចេកទេសនៃសម្ភារអប់រំនោះឡើយ លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ។ ម្ចាស់សម្ភារអប់រំអ្នកបោះឆ្នោតត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

៧.១៦.៨ ក្នុងករណីដែលមានការស្នើសុំការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ គណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងគោលនយោបាយរបស់គណបក្សនយោបាយដូចមានចែងក្នុងប្រការ៧.១៨ ខាងក្រោមនេះមានការកិច្ចក្នុងការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ និងយល់ព្រមក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោងបន្ទាប់ពីបានទទួលសំណើពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានាសុំឱ្យជួយពិនិត្យ ផ្ទៀងផ្ទាត់សម្ភារអប់រំនោះ។ ក្នុងករណីពិនិត្យឃើញថាសម្ភារ ឬខ្លឹមសារអប់រំមិនសមស្របតាម ច.ប.ឃ.ស ឬ/និង ច.វ.ច.ប ឬ/និង ប.ន.ឃ.ស នេះទេ គណៈកម្មការសម្របសម្រួលត្រូវបង្ហាញអំពីការខុសឆ្គង ហើយស្នើសុំឱ្យមានការកែតម្រូវ និងប្រគល់ឱ្យគណៈកម្មការសម្របសម្រួលពិនិត្យឡើងវិញ។ ក្នុងករណីគណៈកម្មការសម្របសម្រួលធ្វើការពិនិត្យ ផ្ទៀងផ្ទាត់សម្ភារអប់រំរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលហួសរយៈពេល ៧២ (ចិតសិបពីរ) ម៉ោង ដោយពុំទាន់ផ្តល់លិខិតយល់ព្រមទេ ចាត់ទុកថាគណៈកម្មការសម្របសម្រួលបានឯកភាពលើខ្លឹមសារ និងអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយឯកសារនោះជាសាធារណៈបាន។

៧.១៦.៩ សម្ភារអប់រំអ្នកបោះឆ្នោតដែលត្រូវបានពិនិត្យ ផ្ទៀងផ្ទាត់ និងទទួលបានលិខិតយល់ព្រមពី គ.ជ.ប ដូចជា៖

- ៧.១៦.៩.១ ស៊្បតវីដេអូ ឬរឿងវីដេអូអប់រំខ្លីៗ។
- ៧.១៦.៩.២ ស៊្បតអូឌីយោ។
- ៧.១៦.៩.៣ ខិត្តបណ្ណផ្សេងៗ និងបដា។
- ៧.១៦.៩.៤ សៀវភៅអប់រំទាក់ទងដល់ការបោះឆ្នោត។
- ៧.១៦.៩.៥ អត្ថបទ និងរូបភាពចុះលើទំព័រសារព័ត៌មាន។
- ៧.១៦.៩.៦ រូបភាព ឬពាក្យស្លោកបោះពុម្ពលើសម្លៀកបំពាក់ ឬមួក។

៧.១៦.១០ សម្ភារដែលបានពិនិត្យ ផ្ទៀងផ្ទាត់ ហើយបានទទួលលិខិតយល់ព្រមពី គ.ជ.ប ត្រូវតម្កល់ទុកជាឯកសារនៅ គ.ជ.ប មួយមុខ ១ (មួយ) ច្បាប់។

៧.១៦.១១ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលមិនប្រើប្រាស់ប្រព័ន្ធពិនិត្យ ផ្ទៀងផ្ទាត់ និងយល់ព្រមដែលផ្តល់ដោយ គ.ជ.ប ត្រូវទទួលខុសត្រូវតាមបញ្ញត្តិនៃ ច.ប.ឃ.ស និង ច.វ.ច.ប។ ប្រសិនបើព័ត៌មានដែលមានក្នុងសម្ភារអប់រំអ្នកបោះឆ្នោតដែលខ្លួនបានផលិតនោះត្រូវបានរកឃើញថាមានភាពលម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយដែលផ្ទុយពី ច.ប.ឃ.ស ឬ/និង ច.វ.ច.ប និង ប.ន.ឃ.ស នេះ ឬធ្វើឱ្យសាធារណជនយល់ខុសពី ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ គ.ជ.ប ត្រូវឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមីធ្វើការកែតម្រូវ ឬបញ្ឈប់ដកហូតសម្ភារនោះទាំងស្រុងតែម្តង។ សម្ភារដែលរកឃើញថាលម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយ ត្រូវបានកំណត់ដូចមានចែងក្នុងចំណុច ៧.១៧.៥ ខាងក្រោមនេះ។

៧.១៦.១២ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិត្រូវបានអនុញ្ញាតឱ្យផលិតតាមគោលការណ៍ស្មើភាពនូវសៀវភៅអប់រំអ្នកបោះឆ្នោត ដែលមានកម្មវិធីនយោបាយរបស់គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើស កបយ.ស។ សៀវភៅអប់រំអ្នកបោះឆ្នោតនេះអាចបោះពុម្ព និងធ្វើការដឹកជញ្ជូនទៅដល់មូលដ្ឋានមុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ប៉ុន្តែអាចចែកចាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈបានតែក្នុងអំឡុងពេលឃោសនាបោះឆ្នោតតែប៉ុណ្ណោះ។

៧.១៦.១៣ គ.ជ.ប មានសិទ្ធិធ្វើការកែតម្រូវ ឬដកហូតនូវផ្នែកណាមួយ ឬសម្ភារអប់រំទាំងអស់ដែលមិនគោរពតាមចំណុច ៧.១៦.៣ និងចំណុច ៧.១៦.១២ ខាងលើនេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសាមីត្រូវធ្វើការកែតម្រូវតាមសំណើរបស់ គ.ជ.ប ជាចាំបាច់។ ក្នុងករណីកំហុសធ្ងន់ធ្ងរ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសាមីត្រូវទទួលទោសតាម ច.ប.ឃ.ស និង ច.វ.ច.ប។

រូបភាព និងសម្ភារឃោសនាបោះឆ្នោត

ប្រការ៧.១៧._

អនុលោមតាមប្រការ៧.២ នៃ ប.ន.ឃ.ស នេះ គណបក្សនយោបាយ បេក្ខជននានា និងអ្នកគាំទ្រទាំងឡាយអាចប្រើប្រាស់រូបភាព ឬសម្ភារឃោសនាបោះឆ្នោតសម្រាប់ផ្សព្វផ្សាយបានដូចជា៖

៧.១៧.១ ខិត្តបណ្ណឃោសនាបោះឆ្នោត។

៧.១៧.២ ការឃោសនាតាមរលកអាកាស ឬតាមឧបករណ៍បំពងសំឡេង ឬតាមឧបករណ៍បញ្ចាំងរូបភាព។

៧.១៧.២.១ អត្ថបទឃោសនា។

៧.១៧.២.២ បទភ្លេង និងចម្រៀងជាពាក្យស្លោកខ្លីៗ។

៧.១៧.២.៣ ការសូត្រកំណាព្យ។

៧.១៧.២.៤ ការប្រគំតន្ត្រីនៅនឹងកន្លែង។

៧.១៧.២.៥ សម្ភាសន៍ដោយបន្តផ្ទាល់ ឬដោយមិនបន្តផ្ទាល់។

៧.១៧.២.៦ ការសម្តែងសិល្បៈ។

៧.១៧.២.៧ ការចាក់ផ្សាយការស្សែតវីដេអូ ឬវីស៊ីឌី ឬឌីវីឌីក្នុងរោងវីដេអូជាសាធារណៈ ឬទីធ្លាសាធារណៈ។

៧.១៧.២.៨ ការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គមផ្លូវការរបស់ខ្លួន។

៧.១៧.៣ ក្រៅពីរូបភាព និងសម្ភារយោសនាបោះឆ្នោតដូចមានចែងខាងលើនេះ មធ្យោបាយផ្សេងៗទៀតត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ការយោសនាបោះឆ្នោត រួមមានដូចខាងក្រោម៖

៧.១៧.៣.១ រឿងល្ខោនខ្លីៗ និងការសម្តែងសិល្បៈការបញ្ចាំងខ្សែភាពយន្តវីដេអូ។

៧.១៧.៣.២ ប៉ោងប៉ោង ឬ/និងបង្ហោះខ្លែង។

៧.១៧.៣.៣ សម្ភារបោះពុម្ព មានដូចជាអាទិ៍រូបភាពបិទផ្សាយ សម្លៀកបំពាក់ អាវយឺតមួក ស្លាកសញ្ញា ពាក្យស្លោករូបភាពបិទតាមយានយន្ត លោហៈខ្ទាស់បដា។

៧.១៧.៣.៤ ការស្រែកយោសនាតាមទីសាធារណៈ។

៧.១៧.៤ គ្រប់សម្ភារ ឯកសារយោសនាបោះឆ្នោតទាំងអស់ដែលបានបោះពុម្ព ចែកផ្សាយ ឬផ្សព្វផ្សាយដោយបេក្ខជនណាម្នាក់ ឬ/និងគណបក្សនយោបាយណាមួយត្រូវតែមានដាក់សញ្ញាសម្គាល់របស់គណបក្សនយោបាយសាមី (ឈ្មោះ ឬ/និងអាសយដ្ឋាន)។

៧.១៧.៥ សម្ភារយោសនាបោះឆ្នោតដែលត្រូវបានផ្សព្វផ្សាយជាទម្រង់អត្ថបទបោះពុម្ព ឬតាមឧបករណ៍បំពងសំឡេង ឬការចាក់ផ្សាយ ឬបង្ហោះផ្សព្វផ្សាយខ្លឹមសារតាមអនឡាញមិនត្រូវរួមបញ្ចូល ឬប្រើប្រាស់នូវរូបភាពណាមួយដូចខាងក្រោម៖

៧.១៧.៥.១ ប្រើប្រាស់រូបភាព ឬភាសាដែលញុះញង់អ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើហិង្សា បំភិតបំភ័យ គំរាមកំហែងប្រឆាំងអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត ឬធ្វើឱ្យបាត់បង់ជំនឿជឿជាក់លើភាពសម្ងាត់នៃការបោះឆ្នោត។

៧.១៧.៥.២ ប្រើប្រាស់រូបភាព ឬភាសាដែលមាក់ងាយ បំភិតបំភ័យ ប្រមាថ សម្តែងការមាក់ងាយ ឬអសីលធម៌ ឬការរើសអើងប្រកាន់ពូជសាសន៍។

៧.១៧.៥.៣ ប្រើប្រាស់រូបភាព ឬភាសាដែលសាបព្រោះភាពភ័យខ្លាចធ្វើឱ្យភាន់ច្រឡំ ប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ និងខូចរបៀបរបបសង្គម។

៧.១៧.៥.៤ ប្រើប្រាស់រូបភាព ឬភាសាដែលមានព័ត៌មានមិនត្រឹមត្រូវចំពោះដំណើរការបោះឆ្នោត។

៧.១៧.៥.៥ ប្រើប្រាស់សារជាសំឡេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់ទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន។

៧.១៧.៥.៦ ប្រើប្រាស់សារជាសំឡេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់បុគ្គលដែលកំពុងស្ថិតក្នុងស្ថានភាពត្រូវបានហាមឃាត់ការធ្វើសកម្មភាពនយោបាយដោយស្តាប័នមានសមត្ថកិច្ច។

៧.១៧.៦ ការផ្សព្វផ្សាយ ការចុះផ្សាយ ឬការបោះពុម្ពផ្សាយសម្ភារឃោសនាបោះឆ្នោតដែលត្រូវបានរកឃើញថារំលោភលើចំណុច ៧.១៧.៥ ខាងលើនេះ គ.ជ.ប អាចបញ្ជាឱ្យដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយ និងការប្រើប្រាស់សម្ភារខុសច្បាប់ទាំងនោះ។

៧.១៧.៧ គណបក្សនយោបាយត្រូវទទួលខុសត្រូវចំពោះសម្ភារឃោសនាបោះឆ្នោតដែលខ្លួនផ្សព្វផ្សាយ និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើសម្ភារទាំងនោះរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី៧ នៃ ប.ន.ឃ.ស នេះ។

៧.១៧.៨ ហាមធ្វើសកម្មភាពឃោសនាបោះឆ្នោតដោយយកព្រះឆាយាលក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រី ព្រះវររាជមាតា និងរូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ដើម្បីរកសំឡេងឆ្នោត។

៧.១៧.៩ ហាមលើកបដាឃោសនាបោះឆ្នោត ស្លាកសញ្ញាគណបក្សនយោបាយ និងរូបសញ្ញាណាមួយដែលបង្ហាញពីការគាំទ្រគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ឆ្លងកាត់ទទឹងផ្លូវសាធារណៈ។

ប្រការ៧.១៨.-

គ.ជ.ប ត្រូវបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ ហៅថា "គណៈកម្មការសម្របសម្រួល" តាមសេចក្តីសម្រេចរបស់គ.ជ.ប ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់សម្ភារអប់រំអ្នកបោះឆ្នោតរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឬ/និងសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយព្រមទាំងរៀបចំគោលការណ៍កម្មវិធីស្មើភាព ឬ/និងសមធម៌។

៧.១៨.១ តួនាទី និងភារកិច្ចរបស់គណៈកម្មការសម្របសម្រួលត្រូវបានកំណត់ដូចខាងក្រោម៖

៧.១៨.១.១ ពិនិត្យ ផ្ទៀងផ្ទាត់ និងយល់ព្រម ឬ/និងកែសម្រួលលើខ្លឹមសារសម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងករណីមានការស្នើសុំពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសាមី។

៧.១៨.១.២ ត្រួតពិនិត្យសម្ភារយោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ក្នុងករណីមានការតវ៉ា ឬមានពាក្យបណ្តឹងពីគណបក្សនយោបាយ បេក្ខជនដទៃទៀត ឬតំណាង ដោយយោងតាម ច.ប.ឃ.ស ច.វ.ច.ប និងយោងតាមចំណុច ៧.១៤.១០ ចំណុច ៧.១៧.៥ និងចំណុច ៧.១៧.៨ នៃ ប.ន.ឃ.ស នេះ។

៧.១៨.១.៣ សម្របសម្រួលកម្មវិធីស្មើភាព ឬ/និងសមធម៌ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត។

៧.១៨.១.៤ សម្របសម្រួលជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជនក្នុងពេលយោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ដើម្បីមានឱកាសទិញ ឬជួលម៉ោងផ្សាយផ្អែកតាមគោលការណ៍ស្មើភាព ឬ/និងសមធម៌ និងតាមលំដាប់មុនក្រោយ។

៧.១៨.១.៥ សម្របសម្រួលជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងរៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត។

៧.១៨.២ គណៈកម្មការសម្របសម្រួលត្រូវរៀបចំចាត់ចែងឱ្យមានគោលការណ៍រៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌ជូនគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើស កបឃ.ស ជាផ្លូវការ មានឱកាសផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយនីមួយៗក្នុងការអភិវឌ្ឍឃុំ សង្កាត់ដល់អ្នកបោះឆ្នោត តាមវិទ្យុ និងទូរទស្សន៍របស់រដ្ឋ ផ្អែកតាមគោលការណ៍របស់ គ.ជ.ប និងតាមលំដាប់ពេលមុនក្រោយ។

៧.១៨.២.១ គណៈកម្មការសម្របសម្រួលត្រូវរៀបចំចាត់ចែងឱ្យមានកិច្ចប្រជុំជាមួយគណបក្សនយោបាយឈរឈ្មោះ ដើម្បីពិភាក្សាកំណត់អំពីការរៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌ ហើយត្រូវមានបទបញ្ជាមួយសម្រាប់ថតកម្មវិធី ដែលអនុម័តដោយ គ.ជ.ប។

៧.១៨.២.២ គណៈកម្មការសម្របសម្រួលត្រូវអនុវត្តតាមគោលការណ៍ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីស្មើភាព ឬ/និងសមធម៌របស់ គ.ជ.ប ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ។

៧.១៨.៣ កម្មវិធីស្មើភាព ឬ/និងសមធម៌ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវបានកំណត់ដូចខាងក្រោម៖

៧.១៨.៣.១ កម្មវិធីចាក់ផ្សាយកិច្ចពិភាក្សាតាមប្រធានបទរវាងបេក្ខជនឈរឈ្មោះបោះឆ្នោត ឬតំណាងគណបក្សនយោបាយអំពីកម្មវិធីនយោបាយរបស់ខ្លួនតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ។

៧.១៨.៣.២ កម្មវិធីចាក់ផ្សាយស្ប៊ុតរបស់គណបក្សនយោបាយតាមវិទ្យុ និងទូរទស្សន៍រដ្ឋ។

៧.១៨.៣.៣ ការបោះពុម្ពផ្សាយអត្ថបទឃោសនាអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬប្រសាសន៍ដើមទាំងស្រុងរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតលើព្រឹត្តិបត្រគោលនយោបាយគណបក្សដែលបោះពុម្ពផ្សាយដោយ គ.ជ.ប។

៧.១៨.៤ គណៈកម្មការសម្របសម្រួលត្រូវជួបពិភាក្សាជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ និងឯកជន និងភាគីពាក់ព័ន្ធ ដើម្បីពន្យល់ណែនាំអំពីបទបញ្ជា និងនីតិវិធី ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត និងគោលការណ៍ណែនាំផ្សេងៗរបស់ គ.ជ.ប។

៧.១៨.៥ ការផ្សព្វផ្សាយគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សឈរឈ្មោះបោះឆ្នោតដូចមានចែងក្នុងចំណុច ៧.១៨.៣ ខាងលើនេះ គណបក្សនយោបាយសាមីត្រូវគោរពតាម ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ ព្រមទាំងការឯកភាពគ្នាជាមួយគណៈកម្មការសម្របសម្រួល។ ករណីរកឃើញថាសម្ភារឃោសនាបោះឆ្នោតទាំងនោះផ្ទុយពី ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ ព្រមទាំងការឯកភាពគ្នានេះ គ.ជ.ប មានសិទ្ធិបញ្ជាឱ្យដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយសម្ភារទាំងនេះ។

ប្រការ៧.១៩.-

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីសាធារណៈ ឬសាលសាធារណៈ ត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជនណាម្នាក់ ឬគណបក្សនយោបាយណាមួយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលសុំជួលប្រើប្រាស់សម្រាប់ធ្វើការឃោសនាបោះឆ្នោត ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់លំដោយ តាមកាលបរិច្ឆេទនៃការស្នើសុំ។ គណបក្សនយោបាយ ឬបេក្ខជនដែលមានបំណងជួលរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីសាធារណៈ ឬសាលសាធារណៈ ត្រូវដាក់ពាក្យសុំទៅអ្នកគ្រប់គ្រងយ៉ាងហោច ៣ (បី) ថ្ងៃមុនថ្ងៃប្រជុំឃោសនាបោះឆ្នោត ហើយត្រូវផ្ញើសេចក្តីចម្លងនៃពាក្យសុំនេះ ១ (មួយ) ច្បាប់ជូន គយ.សប។ អ្នកគ្រប់គ្រងត្រូវឆ្លើយតបទៅនឹងពាក្យស្នើសុំមិនឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោងបន្ទាប់ពីបានទទួលពាក្យស្នើសុំ។

៧.១៩.១ គធ.ខប និង គឃ.សប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីកំណត់ទីសាធារណៈសម្រាប់ការឃោសនាបោះឆ្នោត ហើយត្រូវផ្សព្វផ្សាយជាសាធារណៈនៅក្នុងឃុំ សង្កាត់ យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត។

៧.១៩.២ បន្ទាប់ពីបានទទួលនូវសេចក្តីជូនដំណឹងដូចមានចែងក្នុងប្រការ៧.១៩ ខាងលើនេះ គឃ.សប ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីសម្របសម្រួលអំពីការងារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ឱ្យគណបក្សនយោបាយ ឬបេក្ខជនធ្វើការឃោសនា។

៧.១៩.៣ គឃ.សប ត្រូវមានសៀវភៅចុះលិខិតចម្លងនៃពាក្យស្នើសុំធ្វើការឃោសនារបស់គណបក្សនយោបាយ ឬបញ្ជីបេក្ខជនដែលបានចម្លងជូន ដើម្បីឱ្យបានដឹងថាគណបក្សនយោបាយណាបានស្នើសុំធ្វើការឃោសនាបោះឆ្នោតមុន និងគណបក្សនយោបាយណាបានស្នើសុំធ្វើការឃោសនាបោះឆ្នោតបន្តបន្ទាប់។

៧.១៩.៤ គឃ.សប ត្រូវធ្វើកាលវិភាគប្រចាំសប្តាហ៍ស្តីពីកាលកំណត់តាមលំដាប់លំដោយនៃការស្នើសុំប្រើប្រាស់ទីធ្លាសាធារណៈ និងទីកន្លែងឯកជន រួចបិទផ្សាយជាសាធារណៈនៅទីស្នាក់ការ គឃ.សប ១ (មួយ) ច្បាប់ និងនៅទីកន្លែងដែលត្រូវធ្វើការឃោសនាបោះឆ្នោត ១ (មួយ) ច្បាប់។

៧.១៩.៥ គធ.ខប គឃ.សប ជាអ្នកសម្របសម្រួល និងរៀបចំតាមលំដាប់នៃការជូនដំណឹងស្តីពីការធ្វើការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ដោយណែនាំឱ្យគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត និងចាត់វិធានការទប់ស្កាត់ និងដោះស្រាយចំពោះការឃោសនាបោះឆ្នោតទាំងឡាយណាដែលផ្ទុយនឹង ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ។

៧.១៩.៦ គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងដែលមានបំណងធ្វើសកម្មភាពចែកខិត្តបណ្ណនៅក្នុងផ្សារ គណបក្សនយោបាយសាមីទាំងនោះត្រូវស្នើសុំទៅអ្នកគ្រប់គ្រងផ្សារ និងជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គឃ.សប ពាក់ព័ន្ធយ៉ាងហោចឱ្យបាន ៣ (បី) ថ្ងៃមុនថ្ងៃធ្វើសកម្មភាព។

៧.១៩.៦.១ ការជូនដំណឹងនេះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពី៖

- នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ
- កាលបរិច្ឆេទ ពេលវេលា និងឈ្មោះផ្សារដែលត្រូវធ្វើសកម្មភាព
- ចំនួនអ្នកចូលរួម។

៧.១៩.៦.២ ការធ្វើសកម្មភាពក្នុងផ្សារត្រូវកម្រិតយ៉ាងច្រើនត្រឹម ១០ (ដប់) នាក់ ប៉ុណ្ណោះ ហើយត្រូវយកចិត្តទុកដាក់គោរព និងរក្សាឱ្យបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងមិនត្រូវយកតាមខ្លួននូវឧបករណ៍បំពងសំឡេងឡើយ។

៧.១៩.៦.៣ ការផ្សព្វផ្សាយតាមឧបករណ៍បំពងសំឡេងអំពីគោលនយោបាយ ឬ/និងកម្មវិធីនយោបាយ ឬ/និងសារនយោបាយរបស់គណបក្ស អាចធ្វើបាននៅក្រៅបរិវេណផ្សារ។

៧.១៩.៦.៤ គយ.សប ត្រូវសហការ សម្របសម្រួលជាមួយអាជ្ញាធរដែនដី និងអ្នកគ្រប់គ្រងផ្សារ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការធ្វើសកម្មភាពនេះ។

ប្រការ៧.២០.-

គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយត្រូវរក្សានូវសណ្តាប់ធ្នាប់ រៀបរៀបរយ ឱ្យបានល្អ និងត្រឹមត្រូវតាមពេលវេលា ទីកន្លែងកំណត់ តាមដងផ្លូវ ទីប្រជុំជន និងទីសាធារណៈ។

ប្រការ៧.២១.-

គណបក្សនយោបាយ ឬ/និងបេក្ខជនអាចធ្វើសកម្មភាពឃោសនាបោះឆ្នោតនៅតាមកន្លែងឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គយ.សប យ៉ាងតិច ៣ (បី) ថ្ងៃមុនថ្ងៃប្រជុំឃោសនាបោះឆ្នោត។ អ្នកគ្រប់គ្រងទីកន្លែងត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់គ្រប់បេក្ខជន ឬគ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលមានបំណងសុំជួលប្រើប្រាស់សម្រាប់បម្រើការឃោសនាបោះឆ្នោត ដោយផ្អែកលើតម្លៃស្មើៗគ្នា និងតាមលំដាប់លំដោយតាមកាលបរិច្ឆេទនៃការសុំជួល។

ប្រការ៧.២២.-

គណបក្សនយោបាយ ឬ/និងបេក្ខជន ឬអ្នកគាំទ្រទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរំខាន ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងបេក្ខជន ឬអ្នកគាំទ្រផ្សេងទៀតឡើយ។ សកម្មភាពដែលជ្រៀតជ្រែក និងធ្វើឱ្យរំខាន រាំងស្ទះនោះ រួមមាន៖

៧.២២.១ ការនិយាយដៀមដាម ប្រមាថ មាក់ងាយ។

៧.២២.២ ការធ្វើទារុណកម្មដល់រាងកាយ។

៧.២២.៣ ការវាយតប់លើរាងកាយនៃបុគ្គលណាម្នាក់។

៧.២២.៤ ការបាញ់កាំភ្លើងនៅនឹងកន្លែងដែលគណបក្សកំពុងធ្វើការឃោសនាបោះឆ្នោត ឬកន្លែងប្រជុំ ឬបង្ហើរលើក្បាលអ្នកណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ។

៧.២២.៥ ការរារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមកាលកំណត់។

៧.២២.៦ ការរារាំងដោយមធ្យោបាយផ្សេងៗ ដើម្បីបន្ទប់បង្អាក់មិនឱ្យក្បួនដង្ហែឃោសនាបោះឆ្នោតទៅមុខបាន ឬបញ្ឈប់សកម្មភាពឃោសនាផ្សេងៗទៀត។

៧.២២.៧ ការហាមឃាត់ ឬរាំងប្រជាពលរដ្ឋមិនឱ្យចូលរួមក្នុងកិច្ចប្រជុំ ឬក្បួនដង្ហែរបស់គណបក្សនយោបាយណាមួយ។

៧.២២.៨ ការប្រើគ្រឿងផ្ទុះដើម្បីរំខានដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.២២.៩ ការប្រើឧបករណ៍បំពងសំឡេងដើម្បីរំខានដល់ទីកន្លែងដែលគណបក្សនយោបាយ ឬបេក្ខជនកំពុងធ្វើការឃោសនាបោះឆ្នោត ឬការជួបប្រជុំ។

៧.២២.១០ ការទម្លាក់ស្លាក ឬបំផ្លាញបដាគណបក្សនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ។

៧.២២.១១ ការបង្កើត ការធ្វើ ការបញ្ចូនដំណឹងក្លែងក្លាយ ព័ត៌មានក្លែងបន្លំ ព័ត៌មានបំភ្លៃ ឬព័ត៌មានភាន់ច្រឡំ ដោយមធ្យោបាយណាក៏ដោយ ដើម្បីបង្ខូច ឬបង្អាប់គណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត។

ប្រការ៧.២៣.

បេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត។

៧.២៣.១ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិមានភារកិច្ច និងការទទួលខុសត្រូវក្នុងការរក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ការឃោសនាបោះឆ្នោត។

៧.២៣.២ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិមានភារកិច្ច និងការទទួលខុសត្រូវដោយជានាំចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត។

៧.២៣.៣ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិដែលមានភារកិច្ចការពារមិនត្រូវឈរក្បែរ ឬដើរកៀកពេកទៅនឹងទីតាំង ឬក្បួនឃោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណនៃអង្គពិធីឃោសនាបោះឆ្នោតនានា លើកលែងតែមានការស្នើសុំដោយបេក្ខជន ឬ/និងគណបក្សនយោបាយណាមួយ។

៧.២៣.៤ ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត គឃ.សប ត្រូវតាមដានជារៀងរាល់ថ្ងៃអំពីកម្រិតសន្តិសុខ និងសុវត្ថិភាពក្នុងឃុំ សង្កាត់ និងត្រូវជូនព័ត៌មានទៅ គធ.ខប ជារៀងរាល់ថ្ងៃ។ គធ.ខប ត្រូវសរុបសភាពការណ៍សន្តិសុខ សុវត្ថិភាព និងរាយការណ៍ជូន គ.ជ.ប ជារៀងរាល់ថ្ងៃ។

កិច្ចសហការ និងតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាមួយ គ.ជ.ប

ប្រការ៧.២៤._

គ្រប់អង្គភាពប្រព័ន្ធផ្សព្វផ្សាយរដ្ឋ ដែលមានកាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវចូលរួមផ្សព្វផ្សាយព័ត៌មានដែលស្នើឡើងដោយ គ.ជ.ប ដោយឥតគិតថ្លៃ ទាក់ទងនឹងដំណើរការបោះឆ្នោតទាំងមុន ទាំងក្រោយការបោះឆ្នោត។ គ.ជ.ប ត្រូវស្នើសុំកិច្ចសហការពីក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោតជូនសាធារណជន និងចាត់វិធានការ ក្នុងករណីប្រព័ន្ធផ្សព្វផ្សាយ ឬអង្គភាពសារព័ត៌មានមិនគោរព ច.ប.ឃ.ស ច.វ.ច.ប ប.ន.ឃ.ស នេះ និងក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងដំណើរការបោះឆ្នោតពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត។

ប្រការ៧.២៥._

ប្រព័ន្ធផ្សព្វផ្សាយឯកជនដែលមានបំណងផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត ត្រូវអនុវត្តតាមក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ដើម្បីឱ្យការបោះឆ្នោតមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌។

ប្រការ៧.២៦._

គ្រប់ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ និងឯកជនត្រូវគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត។ ប្រព័ន្ធផ្សព្វផ្សាយដែលមិនគោរពតាម ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

ប្រការ៧.២៧._

រាល់ពាក្យបណ្តឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោតត្រូវអនុវត្តតាមជំពូកទី១៤ នៃ ប.ន.ឃ.ស នេះ។

ជំពូកទី៨
ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន

ផ្នែកទី១
ភ្នាក់ងារគណបក្សនយោបាយ

ភ្នាក់ងារគណបក្សនយោបាយ

ប្រការ៨.១.-

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវចាត់ចែងអនុវត្តការងារទាក់ទងទៅនឹងភ្នាក់ងារគណបក្សនយោបាយ។

៨.១.១ ភ្នាក់ងារគណបក្សនយោបាយគឺជាតំណាងដែលចាត់តាំងដោយគណបក្សនយោបាយ និងត្រូវបានអនុញ្ញាតដោយ គយ.សប ដើម្បីសង្កេតមើលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។ ភ្នាក់ងារគណបក្សនយោបាយគឺជាអ្នកសង្កេតការណ៍ដែលមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់។

៨.១.២ ការផ្តល់បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយគឺសម្រាប់សង្កេតមើលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.១.៣ គណបក្សនយោបាយត្រូវបណ្តុះបណ្តាលដល់ភ្នាក់ងាររបស់ខ្លួនអំពី ច.ប.ឃ.ស ច.វ.ច.ប និងច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ព្រមទាំង ប.ន.ឃ.ស នេះ និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត។

៨.១.៤ គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើស កបឃ.ស មានសិទ្ធិចាត់តាំងភ្នាក់ងារពេញសិទ្ធិរបស់ខ្លួន ១ (មួយ) រូប និងភ្នាក់ងារបម្រុង ១ (មួយ) រូប ដើម្បីសង្កេតមើលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ដែលខ្លួនឈរឈ្មោះបោះឆ្នោត។

៨.១.៥ បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើស កបឃ.ស អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កបឃ.ស មេភូមិ អនុប្រធានភូមិ សមាជិកភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយសង្កេតមើលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ។

៨.១.៦ ភ្នាក់ងារពេញសិទ្ធិនៃគណបក្សនយោបាយនីមួយៗ ត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត តាមចំនួនសមស្របដោយមានការសម្របសម្រួលពីប្រធាន គ.ក.ប/គ.ក.រ។ ភ្នាក់ងារបម្រុងនៃគណបក្សនយោបាយត្រូវអនុញ្ញាតឱ្យចាំនៅក្រៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិក្នុងករណីអវត្តមាន។

៨.១.៧ គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើស កបយ.ស ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយរបស់ខ្លួនទៅ គយ.សប ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជនផ្លូវការ។

៨.១.៨ គណបក្សនយោបាយដែលបានទទួលស្គាល់ឱ្យចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ដើម្បីសង្កេតមើលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត មានសិទ្ធិផ្លាស់ប្តូរភ្នាក់ងាររបស់ខ្លួន រហូតដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី ថ្ងៃសុក្រ មុនថ្ងៃបោះឆ្នោតពីរថ្ងៃ។

៨.១.៩ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវផ្តល់គំរូពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ដល់គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើស កបយ.ស ដោយឥតគិតថ្លៃ។ គណបក្សនយោបាយអាចថតចម្លងគំរូពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ដើម្បីប្រើប្រាស់ក្នុងការដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីអាសយដ្ឋានវេប www.nec.gov.kh។

៨.១.១០ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ត្រូវធ្វើចំនួន ៣ (បី) ច្បាប់តាមគំរូទម្រង់ដែលកំណត់ដោយ គ.ជ.ប។ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ត្រូវភ្ជាប់មកជាមួយនូវ៖

៨.១.១០.១ បញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងសេចក្តីប្រកាសគោរព ច.ប.ឃ.ស ច.វ.ច.ប ប.ន.ឃ.ស ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត និងច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ចំនួន ៣ (បី) ច្បាប់។ បញ្ជីឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងត្រូវបញ្ជាក់នាមត្រកូល នាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋាន និងការិយាល័យបោះឆ្នោតដែលភ្នាក់ងារនោះ ត្រូវបំពេញការងារ។

៨.១.១០.២ លិខិតបញ្ជាក់របស់មេឃុំ ចៅសង្កាត់នៃឃុំ សង្កាត់ពាក់ព័ន្ធជាបុគ្គលឬជាបញ្ជីដែលបញ្ជាក់ថាភ្នាក់ងារនោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ១ (មួយ) ច្បាប់។ ទម្រង់លិខិតបញ្ជាក់នេះ គណបក្សនយោបាយអាចទាញយកពីកម្មវិធីដែលកំណត់ដោយ គ.ជ.ប។

៨.១.១១ ភ្នាក់ងារគណបក្សនយោបាយត្រូវជាអ្នក៖

៨.១.១១.១ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនបំពេញការងារ។

៨.១.១១.២ មានសមត្ថភាពអាចបំពេញការងារបានតាមការជានារបស់គណបក្សនយោបាយ។

៨.១.១១.៣ បានទទួលការបណ្តុះបណ្តាលជាភ្នាក់ងារគណបក្សនយោបាយតាមការជានារបស់គណបក្សនយោបាយសាមី។

៨.១.១២ ភ្នាក់ងារគណបក្សនយោបាយត្រូវចុះហត្ថលេខាក្នុងខ្នង់ហត្ថលេខាត្រង់បន្ទាត់ឈ្មោះរបស់ខ្លួនក្នុងបញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយ ដើម្បីជាភស្តុតាងនៃការប្រកាសសន្យាថា៖

៨.១.១២.១ ស្ម័គ្រចិត្តយល់ព្រមតាមការតែងតាំងរបស់គណបក្សឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយសម្រាប់សង្កេតមើលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.១.១២.២ គោរព ច.ប.ឃ.ស ច.វ.ច.ប ប.ន.ឃ.ស និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត។

៨.១.១២.៣ ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងករណីសាមីខ្លួនរំលោភបំពានលើសេចក្តីប្រកាសសន្យានៅចំណុច ៨.១.១២.២ ខាងលើនេះ។

៨.១.១៣ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ត្រូវចុះហត្ថលេខាដោយប្រធាន ឬតំណាងគណបក្សនយោបាយដែលទទួលបានការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ។ ការផ្ទេរសិទ្ធិនេះមិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។

៨.១.១៤ គយ.សប ត្រូវពិនិត្យពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងចេញសេចក្តីសម្រេចអនុញ្ញាត ឬបដិសេធលើឈ្មោះភ្នាក់ងារគណបក្សនយោបាយដែលមានក្នុងបញ្ជីឈ្មោះស្នើសុំក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

បន្ទាប់ពី គឃ.សប ពិនិត្យ និងសម្រេចលើបញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ គឃ.សប ត្រូវចុះហត្ថលេខា និងបោះត្រា គឃ.សប លើគ្រប់ទំព័រទាំង ៣ (បី) ច្បាប់ ជូនគណបក្សនយោបាយសាមី ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.១.១៥ ប្រសិនបើ គឃ.សប ពិនិត្យលើពាក្យសុំឃើញថាភ្នាក់ងារគណបក្សនយោបាយណាម្នាក់ពុំមានលក្ខណសម្បត្តិត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងខាងលើនេះ គឃ.សប ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅតំណាងគណបក្សនយោបាយសាមីដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។ គណបក្សនយោបាយមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងរបស់ខ្លួនជាថ្មីមួយលើកទៀតជំនួសឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងដែលបានបដិសេធមក គឃ.សប ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីការបដិសេធនេះ។ ក្នុងរយៈពេលនេះ ប្រសិនបើតំណាងគណបក្សនយោបាយនៅតែពុំព្រមកែតម្រូវតាមលក្ខខណ្ឌដូចបានកំណត់ទេនោះ គឃ.សប ត្រូវសម្រេចទទួលស្គាល់តែឈ្មោះភ្នាក់ងារគណបក្សនយោបាយណាដែលបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌតែប៉ុណ្ណោះ។ បន្ទាប់ពី គឃ.សប សម្រេចអនុញ្ញាតលើពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ គឃ.សប ត្រូវចុះហត្ថលេខា ឈ្មោះ និងចុះកាលបរិច្ឆេទលើបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងបោះត្រា គឃ.សប នៅលើជ្រុងខាងស្តាំនៃរូបថត និងផ្តល់ជូនភ្នាក់ងារនោះ ដើម្បីពាក់ក្នុងពេលបំពេញការងារ។

៨.១.១៦ បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយមានសុពលភាពប្រើប្រាស់សម្រាប់តែការសង្កេតមើលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.១.១៧ គ.ក.ប/គ.ក.រ គឃ.សប និង គធ.ខប ត្រូវរាយការណ៍ទៅថ្នាក់លើមួយថ្នាក់របស់ខ្លួនអំពីវត្តមាន និងសកម្មភាពនានារបស់ភ្នាក់ងារគណបក្សនយោបាយក្នុងអំឡុងពេលនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

សិទ្ធិ និងតារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ

៨.១.១៨ ក្នុងការសង្កេតមើលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

៨.១.១៨.១ មានវត្តមាននៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដែលខ្លួនបានទទួលការអនុញ្ញាត តាមទីកន្លែងដែលបានកំណត់ដោយ គ.ក.ប/គ.ក.រ ឬ គ.ជ.ប និងត្រូវចុះបញ្ជីវត្តមាន។

៨.១.១៨.២ ចូលទៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត បានតែម្នាក់ប៉ុណ្ណោះ។ ភ្នាក់ងារបម្រុងត្រូវរង់ចាំនៅក្រៅការិយាល័យ ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិក្នុងករណីមានការផ្លាស់ប្តូរ។

៨.១.១៨.៣ ជំទាស់ ឬតវ៉ារាល់ការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធីដែលខ្លួនបានឃើញផ្ទាល់។ ការជំទាស់ ឬការតវ៉ាត្រូវធ្វើឡើងទៅប្រធាន គ.ក.ប/គ.ក.រ។ នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ការជំទាស់ ឬការតវ៉ាអាចលើកឡើងដោយផ្ទាល់មាត់ ឬ/និងទៅតាមទម្រង់បែបបទរបស់ គ.ជ.ប។

៨.១.១៨.៤ ចុះហត្ថលេខាលើរបាយការណ៍ ឬកំណត់ហេតុផ្សេងៗដែលកំណត់ដោយ គ.ជ.ប។

៨.១.១៨.៥ ចុះហត្ថលេខា ឬផ្តិតមេដៃនៅលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

៨.១.១៨.៦ ទទួលបានកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) សម្រាប់ភ្នាក់ងារដែលមានវត្តមាន។

៨.១.១៨.៧ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប អាជ្ញាធរដែនដី អ្នកសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

៨.១.១៨.៨ ប្តឹងជំទាស់ ឬប្តឹងតវ៉ាទៅតាម ប.ន.ឃ.ស នេះ ប្រសិនបើពិនិត្យឃើញថាមានភស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹង ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ ក្នុងដំណើរការបោះឆ្នោត។

៨.១.១៨.៩ ទទួលបានដោយស្មើភាពគ្នាក្នុងការការពារសន្តិសុខ សុវត្ថិភាពក្នុងអំឡុងពេលធ្វើសកម្មភាពនានាក្នុងដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

បម្រាមចំពោះគណបក្សនយោបាយ និងភ្នាក់ងារគណបក្សនយោបាយ

៨.១.១៩ ក្នុងដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត គណបក្សនយោបាយ និងភ្នាក់ងារគណបក្សនយោបាយមិនត្រូវ៖

៨.១.១៩.១ ប្រព្រឹត្តអំពើគំរាមកំហែង ឬអំពើបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ឬគណបក្សនយោបាយដទៃ។

៨.១.១៩.២ ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃ។

ជ.១.១៩.៣ និយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរដោលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន អ្នកគាំទ្រ ឬលើបុគ្គលណាម្នាក់។

ជ.១.១៩.៤ រិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ។

ជ.១.១៩.៥ ធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ។

ជ.១.១៩.៦ ផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ក្នុងរយៈពេលឃោសនាបោះឆ្នោត ថ្ងៃស និងថ្ងៃបោះឆ្នោត។

ជ.១.១៩.៧ ធ្វើសកម្មភាពឃោសនាបោះឆ្នោតនៅចន្លោះពីម៉ោង ២២:០០ (ម្ភៃពីរ) រហូតដល់ម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក។

ជ.១.១៩.៨ ធ្វើសកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ចាប់ពីម៉ោង ១២:០០ (ដប់ពីរ) ថ្ងៃត្រង់ រហូតដល់ម៉ោង ១៤:០០ (ដប់បួន)។

ជ.១.១៩.៩ ជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពគណបក្សនយោបាយ ឬបេក្ខជនដទៃ។

ជ.១.១៩.១០ ប្រើកម្លាំង ឬអំពើហិង្សាណាមួយ ដើម្បីរារាំងអ្នកមានសិទ្ធិបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន។

ជ.១.១៩.១១ រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់របស់ គ.ជ.ប។

ជ.១.១៩.១២ ប្រើកម្លាំងអំពើហិង្សា អំពើរំលោភបំភិតបំភ័យ ឬប្រើពាក្យសម្តីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាច ការគាន់ច្រឡំធ្វើឱ្យច្របូកច្របល់ បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

ជ.១.១៩.១៣ បង្កការរំខានផ្សេងៗដែលធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបាន។

ជ.១.១៩.១៤ បង្កការរំខានដល់ការងាររាប់សន្លឹកឆ្នោត។

ជ.១.១៩.១៥ ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

ជ.១.១៩.១៦ ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ជ.១.១៩.១៧ បង្គាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត។

ជ.១.១៩.១៨ ធ្វើឱ្យរបើកហិបឆ្នោត ដាច់ រហែក ឬរបូតសោឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់សុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

ជ.១.១៩.១៩ ទាមទារ ឬចូលទៅក្នុងការិយាល័យបោះឆ្នោត ឬ/ការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតបន្ថែមលើភ្នាក់ងារគណបក្សនយោបាយដែលបានអនុញ្ញាតជាផ្លូវការរួចហើយ។

ជ.១.១៩.២០ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត។

ជ.១.១៩.២១ ជ្រៀតជ្រែកដល់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀត ដែលទាក់ទងនឹងការងារបោះឆ្នោត។

ជ.១.១៩.២២ ញុះញង់ឱ្យមានការរើសអើងប្រកាន់បក្សពួក ភេទ ឋានៈក្នុងសង្គមសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ និងតាមគ្រប់រូបភាពទាំងអស់។

ជ.១.១៩.២៣ រារាំង ឬញុះញង់អ្នកបោះឆ្នោតមិនឱ្យចូលរួមក្នុងដំណើរការបោះឆ្នោត ឬណែនាំញុះញង់អ្នកបោះឆ្នោតឱ្យបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត ឬដំណើរការបោះឆ្នោត។

ជ.១.១៩.២៤ រារាំង រំខាន ឬបង្កើតពាក្យចចាមអារ៉ាមនាំឱ្យមានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាពលរដ្ឋមិនឱ្យចូលរួមការប្រជុំ ការហែក្បួនយោសនាបោះឆ្នោតណាមួយរបស់គណបក្ស ឬបេក្ខជនដទៃ។

ជ.១.១៩.២៥ ប្រើប្រាស់ភាសា ពាក្យសម្តីដែលស្តែងចេញពីការសេពសុរា ឬគ្រឿងញៀនជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំ បំភិតបំភ័យណាមួយ។

ជ.១.១៩.២៦ ដាក់តាំង ឬបង្ហាញ ឬចែកចាយខិត្តបណ្ណ ដែលពិពណ៌នាអំពីការវាយប្រហារដោយពាក្យសម្តី ឬដោយអាវុធ។

ជ.១.១៩.២៧ ប្រើភាសា ឬរូបភាពរំលោភបំពាន ខ្វះសីលធម៌ ដែលមានលក្ខណៈអុជអាល បង្កជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬជាងនេះទៀត បង្កឱ្យកើតមានអំពើហិង្សាតាមរយៈសេចក្តីថ្លែងការណ៍ សេចក្តីប្រកាសខិត្តបណ្ណ រូបភាពបិទផ្សាយ និងសម្ភារយោសនាបោះឆ្នោតផ្សេងទៀត។

៨.១.១៩.២៨ ចាក់ផ្សាយព័ត៌មាន ឬការប្រើប្រាស់ឧបករណ៍បំពងសំឡេងតាមផ្លូវសាធារណៈណាមួយ ដែលមានសំឡេងខ្លាំងៗលុបលើសំឡេងឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៨.១.១៩.២៩ ធ្វើសកម្មភាពឃោសនាបោះឆ្នោតដោយឧបករណ៍បំពងសំឡេងនៅក្បែរមន្ទីរពេទ្យ ឬក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានា ក្នុងពេលម៉ោងសិស្សកំពុងសិក្សា។

៨.១.១៩.៣០ យកព្រះនាយាលក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រី ព្រះវររាជមាតារូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ដើម្បីរកសំឡេងឆ្នោត។

៨.១.១៩.៣១ ចម្លងយកសញ្ញាសម្គាល់របស់គណបក្សនយោបាយដទៃទៀតមកប្រើប្រាស់បម្រើឱ្យផលប្រយោជន៍គណបក្សនយោបាយរបស់ខ្លួន។

៨.១.១៩.៣២ បិទបណ្ណ ខិត្តបណ្ណ រូបភាពឃោសនាបោះឆ្នោត សេចក្តីថ្លែងការណ៍នយោបាយ ឬឯកសារឃោសនាបោះឆ្នោតដទៃទៀតពីលើឯកសារផ្សេងៗរបស់អ្នកដទៃ ឬគណបក្សនយោបាយដទៃ។

៨.១.១៩.៣៣ បក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោលនូវបណ្ណបិទផ្សាយ ខិត្តបណ្ណ សេចក្តីប្រកាសនយោបាយ ឬឯកសារឃោសនាបោះឆ្នោត ឬសេចក្តីណែនាំផ្សេងៗរបស់គណបក្សនយោបាយដទៃ ក្រសួងស្ថាប័ននានា ឬអាជ្ញាធរដែនដី។

៨.១.១៩.៣៤ បិទបណ្ណផ្សព្វផ្សាយរូបភាពឃោសនាបោះឆ្នោត សេចក្តីប្រកាសនយោបាយ ចងបដា ឬឯកសារឃោសនាបោះឆ្នោតដទៃទៀតក្បែរការិយាល័យបោះឆ្នោតក្នុងចម្ងាយតិចជាង ១០០ (មួយរយ) ម៉ែត្រ លើកលែងតែទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ។

៨.១.១៩.៣៥ ចងបដា ឬរូបសញ្ញាឃោសនាបោះឆ្នោតណាមួយឆ្លងកាត់ផ្លូវសាធារណៈ។

៨.១.១៩.៣៦ លើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ នៅក្នុងបរិវេណ ឬលើអគារឬការិយាល័យរបស់រដ្ឋ។

៨.១.១៩.៣៧ ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដូចជារថយន្តត្រីចក្រយានយន្ត ទោចក្រយានយន្ត និងដឡយានគ្រប់ប្រភេទ ដែលប្រើប្រាស់ផ្លាកលេខសម្គាល់យានជំនិះដែលមានអក្សររដ្ឋនគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។

ជ.១.១៩.៣៨ ផ្តល់វិភាគទាន ជូនសគុណ ឬផ្តល់រង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ដើម្បីទទួលបានសំឡេងឆ្នោត ទោះបីតាមមធ្យោបាយណាក៏ដោយក្នុងអំឡុងពេលឃោសនាបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត។

ជ.១.១៩.៣៩ ប្រើប្រាស់តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិ ឥទ្ធិពល ឬសិទ្ធិអំណាចខាងមេបា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទម្លាប់ ដើម្បីបង្ខំ ឬគំរាមកំហែងក្នុងគោលបំណងទទួលបានការគាំទ្រ។

ជ.១.១៩.៤០ ក្លែងបន្លំ បំផ្លាញ ឬគូសសញ្ញាសម្គាល់ណាមួយលើសន្លឹកឆ្នោត។

ជ.១.១៩.៤១ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗនៅក្នុងការិយាល័យបោះឆ្នោត។

ជ.១.១៩.៤២ នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

ជ.១.១៩.៤៣ ជក់បារី និងគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

ជ.១.១៩.៤៤ ធ្វើសកម្មភាពផ្សេងទៀតដែលត្រូវបានហាមឃាត់ដូចបានកំណត់ក្នុង ប.ន.ឃ.ស នេះ និងគោលការណ៍ណែនាំរបស់ គ.ជ.ប។

ផ្នែកទី២
អ្នកសង្កេតការណ៍បោះឆ្នោត

អ្នកសង្កេតការណ៍បោះឆ្នោត
ប្រការ៨.២.-

អ្នកសង្កេតការណ៍បោះឆ្នោតរួមមានអ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ៖

ជ.២.១ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ គឺជាជនជាតិខ្មែរ ឬជនបរទេសជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ និងអនុញ្ញាតដោយ គ.ជ.ប។

ជ.២.២ បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើស កបយ.ស អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កបយ.ស មេភូមិ អនុប្រធានភូមិ សមាជិកភូមិ និងកម្លាំងប្រដាប់អាវុធមិនត្រូវបានអនុញ្ញាតឱ្យធ្វើជាអ្នកសង្កេតការណ៍បោះឆ្នោត ដើម្បីសង្កេតមើលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ។

៨.២.៣ អ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តសំដៅដល់ថ្នាក់ដឹកនាំ ឬមន្ត្រីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិដែលអង្គភាពសាមីស្នើសុំ និងដែលត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការបោះឆ្នោតទូទាំងប្រទេស។

៨.២.៤ អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ សំដៅដល់អ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានាដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនឹងអនុញ្ញាតដោយ គ.ជ.ប។

៨.២.៥ រាល់ការចំណាយទាំងឡាយរបស់អ្នកសង្កេតការណ៍បោះឆ្នោតជាបន្ទុករបស់ស្ថាប័ន សមាគម អង្គការមិនមែនរដ្ឋាភិបាលសាមី ឬសាមីខ្លួន។

អ្នកសង្កេតការណ៍បោះឆ្នោតជាតិ

ប្រការ៨.៣.-

គ.ជ.ប ត្រូវធ្វើសេចក្តីជូនដំណឹងជាមុនអំពីប្រតិទិនសម្រាប់ការបោះឆ្នោតជ្រើសរើស កបយ.ស។ ការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិត្រូវធ្វើនៅ គ.ជ.ប។ ការទទួលពាក្យចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិនសម្រាប់ការបោះឆ្នោតរហូតដល់ ១០ (ដប់) ថ្ងៃមុនថ្ងៃបោះឆ្នោត ឬតាមការសម្រេចផ្សេងទៀតដោយ គ.ជ.ប។

៨.៣.១ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសរើស កបយ.ស ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- ៨.៣.១.១ មានលិខិតបញ្ជាក់ការចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា។
- ៨.៣.១.២ មានលក្ខន្តិកៈឬឯកសារប្រហាក់ប្រហែលគ្នាដែលបញ្ជាក់ពីគោលបំណង ឬទិសដៅក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ប្រជាធិបតេយ្យ ការបោះឆ្នោត សិទ្ធិមនុស្ស ច្បាប់ ឬយុត្តិធម៌សង្គម។
- ៨.៣.១.៣ មានកម្មវិធីបណ្តុះបណ្តាលអប់រំស្តីពីការបោះឆ្នោតជូនសមាជិកសង្កេតការណ៍បោះឆ្នោតរបស់ខ្លួន។
- ៨.៣.១.៤ មានផែនការការងារ និងស្ថានភាពថវិការបស់ខ្លួន។

៨.៣.២ ដើម្បីចូលរួមសង្កេតការណ៍បោះឆ្នោត និងរាប់សន្លឹកឆ្នោត សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានលក្ខណសម្បត្តិដូចខាងលើ ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតរបស់ខ្លួនទៅ គ.ជ.ប តាមប្រតិទិនសម្រាប់ការបោះឆ្នោតដែលកំណត់ដោយ គ.ជ.ប។

៨.៣.៣ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវផ្តល់គំរូនៃពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិដោយឥតគិតថ្លៃ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីអាសយដ្ឋានវេប www.nec.gov.kh។ ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិត្រូវធ្វើចំនួន ១ (មួយ) ច្បាប់ ដោយភ្ជាប់មកជាមួយ៖

៨.៣.៣.១ លក្ខខណ្ឌដូចមានចែងក្នុងចំណុច ៨.៣.១ ខាងលើនេះ។

៨.៣.៣.២ បញ្ជីឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតតាមរាជធានី ខេត្តដែលត្រូវធ្វើការសង្កេតការណ៍។

៨.៣.៣.៣ សេចក្តីប្រកាសគោរព ច.ប.ឃ.ស ច.ប.ត.រ ច.វ.ច.ប ប.ន.ឃ.ស នេះ និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត។

៨.៣.៤ អ្នកសង្កេតការណ៍បោះឆ្នោតជាតិត្រូវជាអ្នក៖

៨.៣.៤.១ មានសិទ្ធិបោះឆ្នោត លើកលែងតែជនបរទេសដូចមានចែងក្នុងចំណុច ៨.២.១ ខាងលើនេះ។

៨.៣.៤.២ បានទទួលការបណ្តុះបណ្តាលអំពី ច.ប.ឃ.ស ច.ប.ត.រ ច.វ.ច.ប ប.ន.ឃ.ស នេះ និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត។

៨.៣.៥ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

៨.៣.៦ ក្នុងករណីពិនិត្យបញ្ជីឈ្មោះដែលដាក់ស្នើសុំមកឃើញថា អ្នកសង្កេតការណ៍បោះឆ្នោតណាម្នាក់ពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ គ.ជ.ប ត្រូវបដិសេធឈ្មោះរបស់ជននោះដោយត្រូវ៖

៨.៣.៦.១ រក្សាទុកឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់។

៨.៣.៦.២ គូសបន្ទាត់លុបលើឈ្មោះដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់ និងចារ "បដិសេធ" នៅខាងចុងឈ្មោះត្រង់ខ្នង់ផ្សេងៗ ដោយបញ្ជាក់អំពីមូលហេតុនៃការបដិសេធ។

៨.៣.៧ គ.ជ.ប ត្រូវចេញសេចក្តីសម្រេចអនុញ្ញាតជាលាយលក្ខណ៍អក្សរចំពោះតែអ្នកសង្កេតការណ៍បោះឆ្នោតណាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងបដិសេធឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់នោះចោល។

៨.៣.៨ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតរបស់ខ្លួនជាថ្មីតាមប្រតិទិនដែលកំណត់ដោយ គ.ជ.ប។

៨.៣.៩ សេចក្តីសម្រេចអនុញ្ញាតលើឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិត្រូវធ្វើចំនួន ៤ (បួន) ច្បាប់ ជូនសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមី ២ (ពីរ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.៣.១០ បញ្ជីឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិដែលត្រូវបានសម្រេចរួច ត្រូវចុះហត្ថលេខា និងបោះត្រាលើគ្រប់ទំព័រ រួចផ្ញើបញ្ជីឈ្មោះនោះទៅ គធ.ខប ពាក់ព័ន្ធ។

៨.៣.១១ គធ.ខប ត្រូវផ្តល់បណ្ណសម្គាល់សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតជាតិសម្រាប់បំពេញការងារសង្កេតការណ៍នៅរាជធានី ខេត្តរបស់ខ្លួន។ គធ.ខប ត្រូវធ្វើឆាងផ្ទាត់បញ្ជីឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិដែលតំណាងរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមីបង្ហាញជូនជាមួយនឹងបញ្ជីឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិដែលផ្ញើជូនជាផ្លូវការដោយ គ.ជ.ប។

៨.៣.១២ ក្រោយពីបានពិនិត្យឃើញថាត្រឹមត្រូវហើយ គធ.ខប ត្រូវ៖

- ៨.៣.១២.១ ប្រគល់បណ្ណគ្រប់ចំនួនតាមឈ្មោះនៃអ្នកសង្កេតការណ៍បោះឆ្នោតដែលមាននៅក្នុងបញ្ជីឈ្មោះដើម្បីឱ្យតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបំពេញ និងបិទរូបថត។
- ៨.៣.១២.២ ប្រាប់ទៅតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានទទួលបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិគ្រប់ចំនួនហើយនោះថាឱ្យបំពេញឱ្យបានត្រឹមត្រូវ។
- ៨.៣.១២.៣ ចុះហត្ថលេខា និងបោះត្រា គធ.ខប លើបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមីបានបំពេញត្រឹមត្រូវ និងបិទរូបថតរួច ដោយសាមីខ្លួនអាចចុះហត្ថលេខាជាក្រោយ។

៨.៣.១៣ បណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិដែលអាចយកជាផ្លូវការបានក្នុងដំណើរការសង្កេតការណ៍បោះឆ្នោត លុះត្រាតែ៖

- ៨.៣.១៣.១ បណ្ណសម្គាល់ចេញដោយ គ.ជ.ប តាមរយៈ គធ.ខប។
- ៨.៣.១៣.២ បណ្ណមានបិទរូបថត និងបំពេញត្រឹមត្រូវតាមខ្លឹមសារក្នុងបណ្ណសម្គាល់។
- ៨.៣.១៣.៣ ត្រូវបាន គធ.ខប បោះត្រានៅលើជ្រុងខាងស្តាំ ផ្នែកខាងក្រោមនៃរូបថត។

៨.៣.១៤ ប្រធាន ឬតំណាងរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមីត្រូវចុះហត្ថលេខាលើការធានា និងការទទួលខុសត្រូវលើបញ្ជីឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិរបស់ខ្លួន ជាពិសេសគឺការទទួលខុសត្រូវចំពោះមុខច្បាប់អំពីអត្តសញ្ញាណរបស់អ្នកសង្កេតការណ៍បោះឆ្នោតម្នាក់ៗដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។

៨.៣.១៥ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលអាចស្នើសុំដាក់អ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តទូទាំងប្រទេសរបស់ខ្លួនបានយ៉ាងច្រើន ១០ (ដប់) នាក់ ក្នុងករណីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមីនោះមានអ្នកសង្កេតការណ៍បោះឆ្នោតរបស់ខ្លួនចាប់ពី ៥ (ប្រាំ) រាជធានី ខេត្តឡើងទៅ។ បណ្ណអ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តទូទាំងប្រទេសមានគំរូ និងពណ៌ផ្សេងគ្នាពីបណ្ណអ្នកសង្កេតការណ៍បោះឆ្នោតជាតិ។ ការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តទូទាំងប្រទេសមាននីតិវិធីដូចគ្នានឹងការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិដែរ។ អ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តទូទាំងប្រទេសមានសិទ្ធិ និងភារកិច្ចដូចមានចែងក្នុង ប.ន.ឃ.ស នេះ ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត និងគោលការណ៍ណែនាំនានារបស់ គ.ជ.ប។

៨.៣.១៦ អង្គការដែលបង្កើតដោយរាជរដ្ឋាភិបាលមិនអនុញ្ញាតឱ្យធ្វើជាអ្នកសង្កេតការណ៍ឡើយ។

៨.៣.១៧ គជ.ខប ត្រូវធ្វើរបាយការណ៍បូកសរុបចំនួនអ្នកសង្កេតការណ៍បោះឆ្នោតជាតិតាមដំណាក់កាលនីមួយៗ រួចផ្ញើមក គ.ជ.ប។

អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ

ប្រការ៨.៤.-

នៅពេលអញ្ជើញចូលមកដល់ព្រះរាជាណាចក្រកម្ពុជា អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិត្រូវទៅបង្ហាញខ្លួននៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីទទួលព័ត៌មានផ្សេងៗ។

៨.៤.១ អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិដែលមានបំណងចូលរួមសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិនៅ គ.ជ.ប ឬតាមរយៈអ៊ីមែល info@nec.gov.kh ចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិនសម្រាប់ការបោះឆ្នោតរហូតដល់ ៣ (បី) ថ្ងៃមុនថ្ងៃបោះឆ្នោត ឬតាមការសម្រេចផ្សេងទៀតដោយ គ.ជ.ប។

៨.៤.២ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវផ្តល់ជូននូវគំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ និងបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ ដោយឥតគិតថ្លៃ ដើម្បីបំពេញ និងបិទរូបថត។ ទម្រង់បែបបទស្នើសុំអាចទាញយកពីអាសយដ្ឋានវែប www.nec.gov.kh ។

៨.៤.៣ គ.ជ.ប ត្រូវពិនិត្យពាក្យសុំ និងបណ្ណសម្គាល់ដែលបានបំពេញហើយ និងចេញសេចក្តីសម្រេចអនុញ្ញាតយល់ព្រមឱ្យអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

៨.៤.៤ ក្រោយពីពិនិត្យឃើញថាពាក្យសុំរៀបចំពុំទាន់បានត្រឹមត្រូវ គ.ជ.ប ត្រូវណែនាំអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិនោះឱ្យបំពេញ ឬកែតម្រូវឡើងវិញភ្លាមៗ ដើម្បី គ.ជ.ប ចេញសេចក្តីសម្រេចអនុញ្ញាត។

៨.៤.៥ ក្នុងករណីពិនិត្យឃើញថាពាក្យសុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ហើយ គ.ជ.ប ត្រូវជូនបណ្ណអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិឱ្យសាមីខ្លួន ឬតំណាង ដើម្បីសរសេរបំពេញបិទរូបថត និងចុះហត្ថលេខាសាមីខ្លួន រួចហើយត្រូវជូនបណ្ណនោះមក គ.ជ.ប វិញ។

៨.៤.៦ បន្ទាប់ពីទទួលបណ្ណដែលបានបំពេញត្រឹមត្រូវហើយ គ.ជ.ប ត្រូវចេញសេចក្តីសម្រេចអនុញ្ញាត ចុះហត្ថលេខា និងបោះត្រានៅលើជ្រុងខាងស្តាំផ្នែកខាងក្រោមនៃរូបថតភ្ជាប់ទៅនឹងបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ រួចប្រគល់ជូនទៅអ្នកសង្កេតការណ៍បោះឆ្នោតនោះវិញ ដើម្បីពាក់បំពេញការងារ។

៨.៤.៧ អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប មានសិទ្ធិសង្កេតមើលដំណើរការបោះឆ្នោតទាំងមូល ឬតាមដំណាក់កាល និងគ្រប់ទីកន្លែងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

៨.៤.៨ អ្នកបកប្រែភាសារបស់អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ ត្រូវដាក់ឈ្មោះភ្ជាប់មកជាមួយនឹងពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ ដោយបញ្ជាក់ពីមុខងាររបស់ខ្លួនផង។ អ្នកបកប្រែភាសាពុំមានសិទ្ធិដូចអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិឡើយ ប៉ុន្តែអាចចូលរួមដំណើរជាមួយអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិទៅគ្រប់កន្លែងធ្វើការសង្កេតការណ៍។

សិទ្ធិរបស់អ្នកសង្កេតការណ៍បោះឆ្នោត

៨.៤.៩ នៅពេលត្រូវបានទទួលស្គាល់ជាផ្លូវការ និងទទួលបានបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតរួចហើយ អ្នកសង្កេតការណ៍បោះឆ្នោតទាំងឡាយមានសិទ្ធិដូចខាងក្រោម៖

៨.៤.៩.១ អ្នកសង្កេតការណ៍បោះឆ្នោតជាតិអាចធ្វើដំណើរសង្កេតការណ៍ក្នុងរាជធានី ខេត្តដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួនបានស្នើសុំប៉ុណ្ណោះ លើកលែងតែអ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តទូទាំងប្រទេសដែលត្រូវបានអនុញ្ញាត និងផ្តល់បណ្ណសម្គាល់ខ្លួនដោយ គ.ជ.ប។

៨.៤.៩.២ អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិអាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ។

៨.៤.៩.៣ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ អ្នកសង្កេតការណ៍បោះឆ្នោតត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោត និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីជួយដោះស្រាយទាន់ពេលវេលា។

៨.៤.៩.៤ អមដំណើរជាមួយ គ.ក.ប/គ.ក.រ គឃ.សប គធ.ខប និង គ.ជ.ប នៅរាល់ពេលដឹកជញ្ជូនសម្ភារ បរិក្ខារ។

៨.៤.៩.៥ សង្កេតការណ៍នូវរាល់សកម្មភាពរបស់ គ.ក.ប/គ.ក.រ ឬ គឃ.សប ឬ គធ.ខប និង គ.ជ.ប នៅមុនពេល ក្នុងពេល និងក្រោយបោះឆ្នោត តាមប្រតិទិនកំណត់ដោយ គ.ជ.ប។

៨.៤.៩.៦ ចូលចេញក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយមិនត្រូវបង្កការរំខាន។

៨.៤.៩.៧ ជួប ឬនិយាយ ឬលើកសំណួរជាមួយបេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោតនៅក្រៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ហើយកម្មវត្ថុនៃការជជែកនោះមិនទាក់ទងនឹងការគាំទ្រ ឬការប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

តារកិច្ចរបស់អ្នកសង្កេតការណ៍បោះឆ្នោត

៨.៤.១០ អ្នកសង្កេតការណ៍បោះឆ្នោតទាំងឡាយមានភារកិច្ចដូចខាងក្រោម៖

៨.៤.១០.១ ត្រូវគោរពច្បាប់ដែលមានជាធរមាននៅព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលស្គាល់ និងគោរពអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។

៨.៤.១០.២ ត្រូវយល់ដឹងពីច្បាប់បោះឆ្នោត និង ប.ន.ឃ.ស នេះ។ ក្នុងករណីមានការរំលោភច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី ត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវ ព្រមទាំងកស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន។

៨.៤.១០.៣ ត្រូវមានដំហរអព្យាក្រឹត និងមិនត្រូវប្រកាន់បក្ខពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេឃើញតាមរយៈឯកសណ្ឋាន ពណ៌ ឬវត្ថុដទៃទៀតដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

៨.៤.១០.៤ រក្សាការសម្ងាត់នៃការបោះឆ្នោត។

៨.៤.១០.៥ ត្រូវបង្ហាញកស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចដែលបានសាកសួរខ្លួន ហើយត្រូវពាក់បណ្ណសម្គាល់ខ្លួនដែលត្រូវបានសម្រេចទទួលស្គាល់ និងចេញឱ្យដោយ គធ.ខប ឬ គ.ជ.ប។

៨.៤.១០.៦ ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និងនីតិវិធីដែលបានកំណត់ដោយ គ.ជ.ប និងការណែនាំរបស់មន្ត្រីបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោម ហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការបោះឆ្នោត ក្នុងអំឡុងពេលចុះសង្កេតការណ៍នៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ។

៨.៤.១០.៧ ធ្វើរបាយការណ៍ស្តីពីការរកឃើញ ការកត់សម្គាល់ និងសេចក្តីសន្និដ្ឋានរបស់ខ្លួនឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួន។

៨.៤.១០.៨ ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធីដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងធ្វើរបាយការណ៍អំពីបញ្ហាធ្ងន់ធ្ងរនានាជាបន្ទាន់ជូនគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងត្រូវជូនរបាយការណ៍នេះ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ផងដែរ។

៨.៤.១០.៩ ត្រូវគោរពតាមការកំណត់របស់ប្រធាន គ.ក.ប/គ.ក.រ ដែលតម្រូវឱ្យផ្លាស់ប្តូរគ្នាចូលសង្កេតការណ៍ម្តង ៤ (បួន) នាក់ ក្នុងករណីមានអ្នកសង្កេតការណ៍បោះឆ្នោតច្រើនលើសពី ៤ (បួន) នាក់ សម្រាប់ការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោតមួយ។

បម្រាមចំពោះអ្នកសង្កេតការណ៍បោះឆ្នោត

៨.៤.១១ ក្នុងការសង្កេតមើលការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានានៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោត អ្នកសង្កេតការណ៍បោះឆ្នោតមិនត្រូវ៖

៨.៤.១១.១ ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា។

៨.៤.១១.២ ជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយជាមួយនឹងអ្នកបោះឆ្នោត។

៨.៤.១១.៣ យកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួន។

៨.៤.១១.៤ បញ្ចុះបញ្ចូល ឬប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនាបោះឆ្នោតដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.៤.១១.៥ ចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.៤.១១.៦ ចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.៤.១១.៧ ចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៨.៤.១១.៨ ស្នងមតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.៤.១១.៩ សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.៤.១១.១០ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.៤.១១.១១ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.៤.១១.១២ ដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.៤.១១.១៣ ផ្តល់យានយន្តគ្រប់ប្រភេទដើម្បីជាមធ្យោបាយសម្រាប់ការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.៤.១១.១៤ ផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋសម្រាប់ចូលរួមក្នុងសកម្មភាពឃោសនាបោះឆ្នោត ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.៤.១១.១៥ ផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ដង្ហែក្បួនឃោសនាបោះឆ្នោត ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនាបោះឆ្នោត ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.៤.១១.១៦ រំខាន ឬជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយ នៅពេលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតកំពុងប្រព្រឹត្តទៅ។

៨.៤.១១.១៧ ប៉ះពាល់សម្ភារឯកសារបោះឆ្នោត ក្នុងនោះរួមទាំងសន្លឹកឆ្នោតផង។

៨.៤.១១.១៨ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗនៅក្នុងការិយាល័យបោះឆ្នោត។

៨.៤.១១.១៩ នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៨.៤.១១.២០ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត និងបង្អាក់ដំណើរការនៃការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោត។

៨.៤.១១.២១ រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់បោះឆ្នោត ឬបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

៨.៤.១១.២២ ចូលរួមជជែកវែកញែកក្នុងដំណើរការដោះស្រាយពាក្យបណ្តឹងណាមួយក្នុងអំឡុងពេលបោះឆ្នោត ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយពាក្យបណ្តឹងនេះបាន។

៨.៤.១១.២៣ ធ្វើសកម្មភាពផ្សេងទៀតដែលត្រូវបានហាមឃាត់ដូចបានកំណត់ក្នុង ប.ន.ឃ.ស នេះ និងគោលការណ៍ណែនាំរបស់ គ.ជ.ប។

ផ្នែកទី៣
អ្នកសារព័ត៌មាន

អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ

ប្រការ៨.៥.

សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាព ដែលមានបំណងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោតជ្រើសរើស កបយ.ស មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះដោយផ្ទាល់នៅ គ.ជ.ប។

៨.៥.១ នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈនៃអគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ត្រូវអនុវត្តការងារទាក់ទងនឹងអង្គភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន សមាគមអ្នកសារព័ត៌មាន អង្គភាពសារព័ត៌មាន អ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាពដែលចូលរួមក្នុងដំណើរការបោះឆ្នោតជ្រើសរើស កបយ.ស។

៨.៥.២ គ.ជ.ប ត្រូវផ្តល់ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានដល់សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាព តាមការស្នើសុំដោយឥតគិតថ្លៃ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីអាសយដ្ឋានវេប www.nec.gov.kh។

៨.៥.២.១ រយៈពេលនៃការទទួលពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិគឺចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិនសម្រាប់ការបោះឆ្នោត រហូតដល់ ១០ (ដប់) ថ្ងៃមុនថ្ងៃបោះឆ្នោត ឬតាមការសម្រេចផ្សេងទៀតដោយ គ.ជ.ប។

៨.៥.២.២ រយៈពេលនៃការទទួលពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិគឺចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិនសម្រាប់ការបោះឆ្នោត រហូតដល់ ៣ (បី) ថ្ងៃមុនថ្ងៃបោះឆ្នោត ឬតាមការសម្រេចផ្សេងទៀតដោយ គ.ជ.ប។

៨.៥.៣ ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាពត្រូវភ្ជាប់ជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម៖

៨.៥.៣.១ សម្រាប់អ្នកសារព័ត៌មានជាតិត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតចេញដោយក្រសួងព័ត៌មាន
- ច្បាប់ចម្លងបណ្ណសារព័ត៌មានដែលមានសុពលភាព និងចេញដោយក្រសួងព័ត៌មាន
- ប្រវត្តិរូបសង្ខេប។

៨.៥.៣.២ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិដែលមានការិយាល័យអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជាត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតចេញដោយក្រសួងព័ត៌មាន
- ច្បាប់ចម្លងបណ្ណសារព័ត៌មានដែលមានសុពលភាព និងចេញដោយក្រសួងព័ត៌មាន
- ប្រវត្តិរូបសង្ខេប
- ច្បាប់ចម្លងលិខិតឆ្លងដែន (សម្រាប់ជនបរទេស)។

៨.៥.៣.៣ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិដែលពុំមានការិយាល័យអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវភ្ជាប់ជាមួយនូវ៖

- ច្បាប់ចម្លងលិខិតឆ្លងដែន
- បណ្ណសម្គាល់ខ្លួនអ្នកសារព័ត៌មានរបស់អង្គភាពសាមី ឬអាជ្ញាធរមានសមត្ថកិច្ច
- លិខិតបញ្ជាបេសកកម្មរបស់អង្គភាពសាមី
- ប្រវត្តិរូបសង្ខេប។

៨.៥.៣.៤ សម្រាប់អ្នកសារព័ត៌មានគ្មានអង្គភាពត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងបណ្ណសារព័ត៌មានដែលមានសុពលភាព និងចេញដោយក្រសួងព័ត៌មាន
- ប្រវត្តិរូបសង្ខេប
- អត្ថបទចុងក្រោយដែលខ្លួនបានសរសេរចុះផ្សាយក្នុងសារព័ត៌មានស្របច្បាប់ក្នុងអំឡុងឆ្នាំចុងក្រោយចំនួន ៣ (បី) អត្ថបទ។

៨.៥.៤ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ អង្គភាពសាមី ឬសាមីអ្នកសារព័ត៌មានអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំឡើងវិញក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតបដិសេធ។

៨.៥.៥ គ.ជ.ប ត្រូវពិនិត្យ សម្រេចលើពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ អង្គភាពសាមី ឬសាមីអ្នកសារព័ត៌មានអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំឡើងវិញក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតបដិសេធ។

៨.៥.៦ គ.ជ.ប ត្រូវបោះពុម្ពបណ្ណអ្នកសារព័ត៌មានជាតិ និងបណ្ណអ្នកសារព័ត៌មានអន្តរជាតិ ដើម្បីផ្តល់ជូនដោយឥតគិតថ្លៃដល់អ្នកសារព័ត៌មានដែលត្រូវបានអនុញ្ញាតឱ្យយកព័ត៌មានដោយ គ.ជ.ប ដើម្បីពាក់ក្នុងពេលបំពេញការងារ។

៨.៥.៧ អ្នកសារព័ត៌មានត្រូវគោរពច្បាប់ស្តីពីរបបសារព័ត៌មាន ច.ប.ឃ.ស ប.ន.ឃ.ស នេះ ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន និងធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។

៨.៥.៨ អ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាពដែលបានទទួលការអនុញ្ញាតដោយ គ.ជ.ប អាចយកព័ត៌មានក្នុងដំណើរការបោះឆ្នោតទាំងមូលដោយត្រូវគោរព ច.ប.ឃ.ស ប.ន.ឃ.ស នេះ និងក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត។

៨.៥.៩ អ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាពមានសិទ្ធិថត និងយកព័ត៌មាន។

៨.៥.១០ ការយកព័ត៌មានដោយរូបភាពក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវជម្រាបជូនដំណឹងទៅប្រធាន គ.ក.ប/គ.ក.រ ជាមុន។

៨.៥.១១ អ្នកសារព័ត៌មានជាតិ អន្តរជាតិ អ្នកសារព័ត៌មានគ្មានអង្គភាពមិនត្រូវ៖

- ជ្រៀតជ្រែក ឬរំខានដល់ការងារបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ធ្វើសម្ភាសន៍នៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៨.៥.១២ អ្នកបកប្រែភាសារបស់អ្នកសារព័ត៌មានអន្តរជាតិត្រូវដាក់ឈ្មោះភ្ជាប់មកជាមួយនឹងពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិ ដោយត្រូវបញ្ជាក់ពីមុខងាររបស់ខ្លួន និងត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ថតចម្លង អ.ខ
- លេខទូរសព្ទទំនាក់ទំនង
- ប្រវត្តិរូបសង្ខេប។

អ្នកបកប្រែភាសាពុំមានសិទ្ធិដូចអ្នកសារព័ត៌មានអន្តរជាតិឡើយ។ ប៉ុន្តែអាចចូលរួមដំណើរជាមួយអ្នកសារព័ត៌មានអន្តរជាតិទៅគ្រប់កន្លែង។

៨.៥.១៣ អ្នកសារព័ត៌មាន គ្រប់អង្គភាពប្រព័ន្ធផ្សព្វផ្សាយរដ្ឋ និងឯកជនមិនត្រូវប្រើប្រាស់តួនាទីរបស់ខ្លួន ដើម្បីគាបសង្កត់លើសមាជិក គឃ.សប សមាជិក គ.ក.ប/គ.ក.រ អ្នកសង្កេតការណ៍បោះឆ្នោត បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោតឡើយ។

ជំពូកទី៩
ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត

ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត

ប្រការ៩.១.

អនុលោមតាម ច.ប.ឃ.ស គ.ជ.ប ត្រូវបោះពុម្ព និងចាត់ចែងឱ្យបិទផ្សាយនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅការិយាល័យបោះឆ្នោត និងនៅទីស្នាក់ការ គឃ.សប យ៉ាងយូរ ២ (ពីរ) ថ្ងៃមុនការចាប់ផ្តើមចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត រហូតដល់ពេលបិទការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត។

៩.១.១ គ.ជ.ប ត្រូវណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យចាត់ចែងបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតខាងលើនេះបានទាន់ពេលវេលា។ គ.ជ.ប ត្រូវធានាថា៖

៩.១.១.១ បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ត្រូវបានថតចម្លងឱ្យគ្រប់ចំនួនសម្រាប់ការបិទផ្សាយ ២ (ពីរ) លើកនៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ ១ (មួយ) ច្បាប់ និងនៅទីស្នាក់ការ គឃ.សប ១ (មួយ) ច្បាប់ (លើកទី១ នៅ ២ (ពីរ) ថ្ងៃមុនថ្ងៃចាប់ផ្តើមចុះបញ្ជីបេក្ខជន និងលើកទី២ នៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត) ព្រមទាំងរក្សាទុកឯកសារនៅ គឃ.សប ១ (មួយ) ច្បាប់។

៩.១.១.២ បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ចំណុះរាជធានី ខេត្តនីមួយៗ ត្រូវបានថតចម្លងលើក្រដាស ឬក្នុងទម្រង់ភីឌីអេហ្វ (PDF) ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ដើម្បីរក្សាទុកជាឯកសារ និងបម្រើសាធារណជន។

៩.១.២ នាយកដ្ឋានប្រតិបត្តិការត្រូវសហការជាមួយនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ដើម្បីរៀបចំបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត។ នាយកដ្ឋានប្រតិបត្តិការត្រូវផ្តល់បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតជូននាយកដ្ឋានរដ្ឋបាលនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ១ (មួយ) ច្បាប់ ដើម្បីសហការគ្នាធ្វើជាសេនាធិការជូន គ.ជ.ប ក្នុងការកំណត់ចំនួនមន្ត្រីការិយាល័យបោះឆ្នោត ដើម្បីជ្រើសរើសសមាសភាព គ.ក.ប/គ.ក.រ។

៩.១.៣ គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតអាចសុំថតចម្លងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ដោយបង់ថ្លៃ។ តម្លៃគិតត្រឹមតែតម្លៃផលិតតែប៉ុណ្ណោះ។ ការផ្តត់ផ្តង់ចំពោះការស្នើសុំនេះ ត្រូវផ្អែកលើលទ្ធភាពផលិត និងតាមលំដាប់មុនក្រោយនៃការស្នើសុំ។ រាល់ការស្នើសុំតម្រូវឱ្យបង់ប្រាក់មុនស្មើនឹង ១០០ (មួយរយ) ភាគរយនៃតម្លៃផលិត។

ការផ្តត់ផ្តង់សន្លឹកឆ្នោត និងសម្ភារ ឧបករណ៍ចាំបាច់សម្រាប់ការបោះឆ្នោត ប្រការ៩.២.

គ.ជ.ប ត្រូវផ្តត់ផ្តង់សន្លឹកឆ្នោត និងឧបករណ៍សម្រាប់បម្រើឱ្យការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

៩.២.១ គ.ជ.ប ជានាបោះពុម្ពសន្លឹកឆ្នោតគ្រប់ចំនួនសម្រាប់ឃុំ សង្កាត់នីមួយៗនៅលើក្រដាសពណ៌ស។

៩.២.២ សន្លឹកឆ្នោតនីមួយៗត្រូវមានគល់បញ្ជីសន្លឹកឆ្នោត។ លេខរៀងតាមលំដាប់តគ្នានៃសន្លឹកឆ្នោតត្រូវបោះនៅលើគល់បញ្ជីសន្លឹកឆ្នោត។

៩.២.៣ សន្លឹកឆ្នោតនីមួយៗត្រូវមានសញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់។ សញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់ដែលត្រូវដាក់នៅលើសន្លឹកឆ្នោតត្រូវដាក់តាមលំដាប់លំដោយផ្អែកតាមលទ្ធផលនៃការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលត្រូវដាក់លើសន្លឹកឆ្នោតដូចមានចែងក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ។

៩.២.៤ ឃុំ សង្កាត់នីមួយៗត្រូវមានសន្លឹកឆ្នោតដោយឡែករបស់ខ្លួនដែល គ.ជ.ប ផ្តល់ជូន។

៩.២.៥ គ.ជ.ប ត្រូវធានាផ្តល់ហិបឆ្នោតឱ្យបានគ្រប់ចំនួនសម្រាប់ឃុំ សង្កាត់នីមួយៗ។ គ្រប់ហិបឆ្នោតទាំងអស់ត្រូវ៖

- មានគម្របជាប់មកជាមួយដែលអាចចាក់បិទបានដោយប្រើប្រាស់សោឃ្លុំមានលេខ
- ធានានូវស្ថេរភាពដែលមិនអាចហូតយកសន្លឹកឆ្នោតចេញពីក្នុងហិបឆ្នោតបានប្រសិនបើមិនបើកគម្រប
- មានសោ ឬឧបករណ៍ផ្សេងទៀតសម្រាប់កិបពេលបិទហិបឆ្នោត
- មានស្លាកលេខ ឬសញ្ញាសម្គាល់នៅផ្នែកខាងក្រៅយ៉ាងច្បាស់ដែលមិនអាចដូរ ឬលុបបានដោយងាយ ហើយស្លាកលេខ ឬសញ្ញាសម្គាល់នេះត្រូវមានតែមួយគត់សម្រាប់ហិបឆ្នោតនោះ និងសម្គាល់បានថាហិបឆ្នោតនោះទាក់ទងទៅនឹងឃុំ សង្កាត់ និងការិយាល័យបោះឆ្នោតណាមួយ។

៩.២.៦ គ.ជ.ប ត្រូវធានាឱ្យមានត្រាសម្ងាត់ជាផ្លូវការគ្រប់ចំនួន និងខុសៗគ្នាសម្រាប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ។ គ.ជ.ប ត្រូវតាក់តែងបទបញ្ជា និងនីតិវិធីសម្រាប់ការប្រគល់ ការទទួល និងការប្រគល់ត្រឡប់មកវិញ និងធានាឱ្យបាននូវភាពសម្ងាត់នៃត្រានេះ។

៩.២.៧ គ.ជ.ប ត្រូវធានាឱ្យការិយាល័យបោះឆ្នោតនីមួយៗមានសម្ភារ ឧបករណ៍ដូចខាងក្រោម៖

១- បញ្ជីបោះឆ្នោត។
២- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់។
៣- ហិបឆ្នោតដែលអាចចាក់ជាមួយសោឃ្លុំមានលេខ។
៤- បន្ទប់សម្ងាត់។
៥- ត្រា គ.ក.ប។
៦- ត្រាសម្ងាត់សម្រាប់បោះលើសន្លឹកឆ្នោត។
៧- ទឹកខ្មៅលុបមិនជ្រះសម្រាប់ជ្រលក់សម្គាល់ថាបានបោះឆ្នោតហើយ។
៨- សោ និងប្រដាប់ឃ្លុំ។
៩- ទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល។
១០- ប៊ិកសរសេរដែលមានគុណភាពល្អ។
១១- ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ។
១២- ថង់ប្លាស្ទិក។
១៣- សម្ភារ និងបរិក្ខារចាំបាច់ផ្សេងៗទៀត។

ការទទួលខុសត្រូវ និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ

ប្រការ៩.៣._

គ.ក.ប/គ.ក.រ នីមួយៗមានភារកិច្ចចាត់ចែង គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដែល គ.ក.ប/គ.ក.រ នោះទទួលខុសត្រូវ។

៩.៣.១ ប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចចាត់ចែង និងគ្រប់គ្រងនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដែលខ្លួនទទួលខុសត្រូវ និងត្រូវ៖

៩.៣.១.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៩.៣.១.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតស្របតាម ច.ប.ឃ.ស ច.វ.ច.ប ប.ន.ឃ.ស នេះ ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត និងការណែនាំរបស់ គ.ជ.ប។

៩.៣.១.៣ ទទួលពិនិត្យ ផ្ទៀងផ្ទាត់ និងការពារឱ្យបានហ្មត់ចត់នូវរាល់សម្ភារ ឯកសារបោះឆ្នោតសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ជាពិសេសពិនិត្យលេខកូដនៃកញ្ចប់សន្លឹកឆ្នោត ដើម្បីឱ្យប្រាកដថាជាសន្លឹកឆ្នោតនៃឃុំ សង្កាត់សម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

៩.៣.១.៤ រៀបចំទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ទៅតាមគំរូប្លង់ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងបំពាក់គ្រឿងសង្ហារិម។

៩.៣.១.៥ តាមដាន និងត្រួតពិនិត្យការបំពេញការងាររបស់សមាសភាព គ.ក.ប/គ.ក.រ នៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងអាណត្តិរបស់ខ្លួន។

៩.៣.១.៦ ដាក់ជំនួសតំណែងសមាជិក គ.ក.ប/គ.ក.រ ណាដែលមិនបានមកបំពេញការងារបោះឆ្នោតតាមកិច្ចសន្យា ដោយយោងទៅតាមចំណុច ៩.៤.១០ ខាងក្រោមនេះ។

៩.៣.១.៧ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត។ ក្នុងពេលកំពុងដំណើរការបោះឆ្នោតយ៉ាងយូរ ១ (មួយ) ម៉ោងម្តង ត្រូវចូលក្នុងបន្ទប់សម្ងាត់ ដើម្បីធ្វើអនាម័យសម្លាប់មេរោគ និងត្រួតពិនិត្យសុវត្ថិភាពសម្ភារដែលបំពាក់នៅទីនោះ និងសណ្តាប់ធ្នាប់ក្នុងករណីគ្មានអ្នកបោះឆ្នោតនៅក្នុងបន្ទប់សម្ងាត់។

៩.៣.១.៨ ជានាឱ្យប្រាកដថាគ្រប់កំណត់ហេតុ និងទម្រង់បែបបទទាំងអស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតត្រូវបានបំពេញ និងចុះហត្ថលេខាត្រឹមត្រូវ និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយឱ្យចូលរួមចុះហត្ថលេខាជាសាក្សី។

៩.៣.១.៩ ត្រួតពិនិត្យបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ និងបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតដែលត្រូវចូលរួមសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៩.៣.១.១០ អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតផ្លាស់ប្តូរទីកន្លែងពិនិត្យមើលដំណើរការបោះឆ្នោត ដោយត្រូវរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងជានាឱ្យបាននូវការសម្ងាត់នៃការបោះឆ្នោត។

៩.៣.១.១១ ត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតដល់អ្នកដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត។

៩.៣.១.១២	ប្រកាសបើក និងបិទការបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត។
៩.៣.១.១៣	ចាត់វិធានការនានាដើម្បីធានាឱ្យបាននូវសណ្តាប់ធ្នាប់ របៀបរៀបរយ និងការប្រព្រឹត្តទៅជាប្រក្រតីនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត នៅក្នុងការិយាល័យបោះឆ្នោតឬការិយាល័យរាប់សន្លឹកឆ្នោត ព្រមទាំងបរិវេណខាងក្នុង និងបរិវេណខាងក្រៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។
៩.៣.១.១៤	ចាក់ ឬកាត់ផ្តាច់សោឃ្លុំការពារហិបឆ្នោត។
៩.៣.១.១៥	ធានាឱ្យប្រាកដថាអ្នកបោះឆ្នោតម្នាក់ៗត្រូវបានបង្រៀនឱ្យចេះពីរបៀបបោះឆ្នោត និងតាមដានពិនិត្យមើល ដើម្បីឱ្យប្រាកដថានៅពេលចេញពីបន្ទប់សម្ងាត់ អ្នកបោះឆ្នោតបានបត់សន្លឹកឆ្នោតតាមផ្នត់ដើមដូចការណែនាំ។
៩.៣.១.១៦	ធានាឱ្យប្រាកដថាការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះ ត្រូវតែបានអនុវត្តតាមការណែនាំ។
៩.៣.១.១៧	ធានាឱ្យប្រាកដថាការលើកយោបល់ជំទាស់ ឬតវ៉ាក្នុងការិយាល័យបោះឆ្នោតដោយភ្នាក់ងារគណបក្សនយោបាយស្របតាម ច.ប.ឃ.ស ត្រូវបានដោះស្រាយភ្លាមដោយអនុវត្តស្របតាម ប.ន.ឃ.ស នេះ និងការណែនាំរបស់ គ.ជ.ប។
៩.៣.១.១៨	ជួយអ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបានតាមការស្នើសុំរបស់សាមីខ្លួន។
៩.៣.១.១៩	ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការធ្វើងផ្នាត់ និងការរាប់សន្លឹកឆ្នោត។
៩.៣.១.២០	ត្រួតពិនិត្យសុពលភាពសន្លឹកឆ្នោត និងប្រកាសឈ្មោះគណបក្សនយោបាយដែលបានទទួលសំឡេងឆ្នោត។
៩.៣.១.២១	ប្រគល់ជូន គឃ.សប នូវស្បោង “ខ” ដាក់សម្ភារ ឯកសារបោះឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត។
៩.៣.១.២២	ប្រគល់ជូន គឃ.សប នូវកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសេសសល់ផ្សេងទៀត ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតបាន។
៩.៣.១.២៣	បំពេញការកិច្ចរបស់ខ្លួនក្នុងជំហរអព្យាក្រឹត និងមិនលម្អៀង។
៩.៣.១.២៤	បំពេញការកិច្ចផ្សេងៗទៀតដែល គឃ.សប ប្រគល់ជូន។

៩.៣.២ អនុប្រធាន គ.ក.ប/គ.ក.រ ត្រូវជួយប្រធាន គ.ក.ប/គ.ក.រ និងមានភារកិច្ចដោយឡែក ដូចខាងក្រោម៖

៩.៣.២.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៩.៣.២.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ឃ.ស ប.ន.ឃ.ស នេះ និងការណែនាំរបស់ គ.ជ.ប។

៩.៣.២.៣ ជំនួសតំណែងប្រធាន គ.ក.ប ក្នុងករណីប្រធាន គ.ក.ប មិនអាចមកបំពេញការងារបាន។

៩.៣.២.៤ រាប់ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែងសម្រាប់ប្រើក្នុងការិយាល័យបោះឆ្នោតមុននឹងបើកការបោះឆ្នោត។

៩.៣.២.៥ ហែកសន្លឹកឆ្នោតផ្តាច់ចេញពីគល់បញ្ជីសៀវភៅសន្លឹកឆ្នោត បោះត្រាសម្ងាត់លើផ្នែកខាងខ្នង និងបត់ជា ៤ (បួន) ផ្នត់តាមការណែនាំរបស់ គ.ជ.ប រួចប្រគល់ជូនអ្នកបោះឆ្នោត។

៩.៣.២.៦ ផ្តល់ការណែនាំស្តីពីនីតិវិធីនៃការបោះឆ្នោតដល់អ្នកបោះឆ្នោត។

៩.៣.២.៧ អនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់នៅពេលដែលបន្ទប់សម្ងាត់នោះទំនេរ គ្មានអ្នកបោះឆ្នោតផ្សេងទៀត។

៩.៣.២.៨ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតនៅពេលបញ្ចប់ការបោះឆ្នោត។

៩.៣.២.៩ ត្រួតពិនិត្យ និងបែងចែកតាមពំនូកសន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់នៅខាងខ្នង មុននឹងប្រគល់ជូនប្រធាន គ.ក.រ។

៩.៣.២.១០ កត់ត្រាសំឡេងឆ្នោតដែលគណបក្សនយោបាយនីមួយៗបានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨)។

៩.៣.២.១១ អមដំណើរប្រធាន គ.ក.រ ក្នុងការបញ្ជូន និងការប្រគល់ស្បោង “ខ” ព្រមទាំងសម្ភារៈឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតជូន គយ.សប។

៩.៣.២.១២ បំពេញភារកិច្ចផ្សេងៗទៀតដែល គយ.សប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ជូន។

៩.៣.៣ លេខាធិការត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន គ.ក.ប/គ.ក.រ និងជាអ្នកទទួលបន្ទុកការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត ព្រមទាំងការបំពេញទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងត្រូវ៖

៩.៣.៣.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៩.៣.៣.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ឃ.ស ប.ន.ឃ.ស នេះ និងការណែនាំរបស់ គ.ជ.ប។

៩.៣.៣.៣ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការគ្រប់គ្រងសម្ភារៈឯកសារបោះឆ្នោត។

៩.៣.៣.៤ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប។

៩.៣.៣.៥ ត្រួតពិនិត្យរកមើលស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថាគាត់បានបោះឆ្នោតរួចហើយ ឬនៅមិនទាន់បានបោះឆ្នោត នៅមុនពេលពិនិត្យឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោត។

៩.៣.៣.៦ សួរបញ្ជាក់ឈ្មោះ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ភាពដូចគ្នារវាងរូបពិត ឈ្មោះ និងទិន្នន័យក្នុង អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ របស់សាមីអ្នកបោះឆ្នោតនិងរូបថត ឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតរួចគូសសញ្ញាធិកថាបានមកបោះឆ្នោតក្នុងកូនប្រអប់បួនជ្រុងទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះលើបញ្ជីបោះឆ្នោត។

៩.៣.៣.៧ រាប់គំនូសសញ្ញាធិកលើបញ្ជីបោះឆ្នោត និងរាយការណ៍ជូនប្រធាន គ.ក.ប អំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងមិនបានបោះឆ្នោត។

៩.៣.៣.៨ កត់ត្រាចំនួនអ្នកដែលបានមកបោះឆ្នោតសរុបនៅទំព័រចុងក្រោយផ្នែកខាងក្រោមនៃបញ្ជីបោះឆ្នោតដែលបានប្រើក្នុងការិយាល័យបោះឆ្នោត ព្រមទាំងបោះត្រា គ.ក.ប នៅគ្រប់ទំព័រនៃបញ្ជីបោះឆ្នោត រួចដាក់បញ្ជីបោះឆ្នោតទៅក្នុងស្រោមសំបុត្រដែលមានកាខ្នងស្រាប់ថា “ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត” រួចបិទភ្ជិតដោយការ។

៩.៣.៣.៩ បំពេញកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងដាក់ជូនប្រធាន គ.ក.ប ចុះហត្ថលេខា រួចដាក់បង្ហាញឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតពិនិត្យមើល។

៩.៣.៣.១០ កត់ត្រាក្នុងកំណត់ហេតុនូវរាល់ការលើកយោបល់តវ៉ា ឬជំទាស់ទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៩.៣.៣.១១ កត់ត្រាសំឡេងឆ្នោតដែលគណបក្សនយោបាយនីមួយៗបានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨)។

៩.៣.៣.១២ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងដាក់ជូនប្រធាន គ.ក.រ ចុះហត្ថលេខា។

៩.៣.៣.១៣ បំពេញភារកិច្ចផ្សេងៗទៀតដែល គឃ.សប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ជូន។

៩.៣.៤ សមាជិកទី១ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន គ.ក.ប/គ.ក.រ និងត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

៩.៣.៤.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៩.៣.៤.២ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត។

៩.៣.៤.៣ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប។

៩.៣.៤.៤ ត្រួតពិនិត្យហិបឆ្នោត និងការស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោតក្នុងពេលកំពុងដំណើរការបោះឆ្នោត។

៩.៣.៤.៥ រាយការណ៍ជូនប្រធាន គ.ក.ប ក្នុងករណីពិនិត្យឃើញថាអ្នកបោះឆ្នោតណាម្នាក់បាន និងកំពុងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀតចូលក្នុងហិបឆ្នោត។

៩.៣.៤.៦ ជ្រលក់ម្រាមដៃរបស់អ្នកបោះឆ្នោតដែលបានបោះឆ្នោតរួចទៅក្នុងទឹកខ្មៅលុបមិនជ្រះឱ្យដល់គល់ក្រចក និងណែនាំគាត់ឱ្យរង់ចាំលុបទឹកខ្មៅស្ងួត មុននឹងចេញពីការិយាល័យបោះឆ្នោត។

៩.៣.៤.៧ រាប់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត ដើម្បីផ្ទៀងផ្ទាត់ទៅនឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងដកយកវត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ដាក់ទៅក្នុងស្រោមសំបុត្រដោយឡែក។

៩.៣.៤.៨ លាសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត ដើម្បីត្រួតពិនិត្យស្នាមគ្រាសម្ងាត់នៅផ្នែកខាងខ្នង និងបែងចែកតាមពំនូកសន្លឹកឆ្នោតមានគ្រាសម្ងាត់ ឬគ្មានគ្រាសម្ងាត់។

៩.៣.៤.៩ កត់ត្រាសំឡេងឆ្នោតដែលគណបក្សនយោបាយនីមួយៗបានទទួលនៅផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត។

៩.៣.៤.១០ បំពេញការកិច្ចផ្សេងៗទៀតដែល គយ.សប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ជូន។

៩.៣.៥ សមាជិកទី២ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន គ.ក.ប/គ.ក.រ និងត្រូវបំពេញការកិច្ចដូចខាងក្រោម៖

៩.៣.៥.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៩.៣.៥.២ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប។

៩.៣.៥.៣ ជួយរកឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតដែលបិទនៅខាងក្រៅការិយាល័យបោះឆ្នោត និងប្រាប់លេខរៀងឈ្មោះរបស់គាត់។

៩.៣.៥.៤ ចាត់ចែង និងថែរក្សារបៀបរៀបរយជូនអ្នកបោះឆ្នោត (ក្នុងករណីចាំបាច់ អាចផ្តល់បណ្ណលេខរៀងតាមលំដាប់អ្នកមកមុនមកក្រោយ) ព្រមទាំងរាយការណ៍ជូនប្រធាន គ.ក.ប អំពីការរំខាន ការអុកឡុក ការរារាំង ឬការជ្រៀតជ្រែកនានាក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត (ប្រសិនបើមាន)។

៩.៣.៥.៥ រាយការណ៍ជូនប្រធាន គ.ក.ប ក្នុងករណីពិនិត្យឃើញថាមានអ្នកបោះឆ្នោតណាម្នាក់បានយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត។

៩.៣.៥.៦ ប្រមូល អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ ពីអ្នកបោះឆ្នោតដែលស្ថិតក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅពេលដល់ម៉ោងបញ្ចប់ការបោះឆ្នោតម៉ោង ១៥:០០ (ដប់ប្រាំ) (ប្រសិនបើមាន)។

៩.៣.៥.៧ ចោះ ឬកាត់សន្លឹកឆ្នោតដែលនៅសល់មិនបានប្រើប្រាស់បន្ទាប់ពីបញ្ចប់ការផ្ទៀងផ្ទាត់សន្លឹកឆ្នោត។

៩.៣.៥.៨ សហការជាមួយសមាជិកទី៣ ក្នុងការការពារមាត់ទ្វារការិយាល័យបោះឆ្នោត ការថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់ក្នុងការិយាល័យបោះឆ្នោត និងការដែយាល័យរាប់សន្លឹកឆ្នោត។

៩.៣.៥.៩ បិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅមុខការិយាល័យរាប់សន្លឹកឆ្នោត។

៩.៣.៥.១០ បញ្ជូនស្រោមសំបុត្រដែលមានដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ទៅ គយ.សប។

៩.៣.៥.១១ បំពេញភារកិច្ចផ្សេងៗទៀតដែល គយ.សប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ជូន។

៩.៣.៦ សមាជិកទី៣ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន គ.ក.ប/គ.ក.រ និងត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

៩.៣.៦.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៩.៣.៦.២ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត។

៩.៣.៦.៣ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប។

៩.៣.៦.៤ ត្រួតពិនិត្យច្រកទ្វារចូលនៃការិយាល័យបោះឆ្នោត ណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តគ្នាជាជួរតាមលំដាប់មុនក្រោយ និងត្រូវរក្សាគម្លាតសុវត្ថិភាពបុគ្គល ប្រសិនបើគាត់ត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះ និងត្រួតពិនិត្យ អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ របស់គាត់។

៩.៣.៦.៥ អនុញ្ញាតឱ្យអ្នកបោះឆ្នោតមានវត្តមានក្នុងការិយាល័យបោះឆ្នោតចំនួន ៤ (បួន) នាក់ ក្នុងពេលតែមួយ។

៩.៣.៦.៦ ផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោតចំពោះអ្នកបោះឆ្នោតជាព្រះសង្ឃ មនុស្សចាស់ជរាស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូចអ្នកមានជំងឺជនមានពិការភាព និងអ្នកបោះឆ្នោតដែលមានកាតព្វកិច្ចការពារទឹកដីនៅសមរភូមិមុខ (ករណីកាលៈទេសៈតម្រូវ) បន្ទាប់មកគឺអ្នកឈរខាងមុខគេក្នុងជួរ។

៩.៣.៦.៧ ត្រួតពិនិត្យស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថាគាត់បានបោះឆ្នោតហើយ ឬមិនទាន់បានបោះឆ្នោត។

៩.៣.៦.៨ ជួយចាត់ចែង និងថែរក្សារបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងរាយការណ៍អំពីការរំខាន ការអុកឡុក ការរាំងស្ទះ ឬការជ្រៀតជ្រែកជូនប្រធាន គ.ក.ប។

៩.៣.៦.៩ សហការជាមួយសមាជិកទី២ ក្នុងការការពារសន្តិសុខនៅច្រកផ្លូវចូលការិយាល័យបោះឆ្នោត ថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់នៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៩.៣.៦.១០ បំពេញការកិច្ចផ្សេងៗទៀតដែល គយ.សប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ជូន។

ការត្រៀមសម្ភារ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត ប្រការ៩.៤.

គ.ជ.ប ត្រូវធានាថារាល់សម្ភារ ឯកសារបោះឆ្នោតត្រូវតែបានបញ្ជូន និងប្រគល់ជូន គ.ក.ប មិនឱ្យលើសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោងមុនថ្ងៃបោះឆ្នោត។ នៅពេលព្រឹកថ្ងៃសៅរ៍មុនថ្ងៃបោះឆ្នោតមួយថ្ងៃ ប្រធាន គ.ក.ប ត្រូវកោះប្រជុំសមាសភាពទាំងអស់នៃ គ.ក.ប ឱ្យមកបង្ហាញខ្លួននៅទីតាំងការិយាល័យបោះឆ្នោត ដើម្បីធ្វើការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរៀបចំប្លង់ការិយាល័យបោះឆ្នោត។

៩.៤.១ គ.ជ.ប ត្រូវផ្តត់ផ្តង់សម្ភារ ឯកសារបោះឆ្នោតគ្រប់គ្រាន់សម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតជូន គជ.ឧប គយ.សប និង គ.ក.ប ទាំងអស់។

៩.៤.២ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវទទួលខុសត្រូវក្នុងការផលិតបញ្ជីបោះឆ្នោតផ្លូវការចំនួន ៣ (បី) ច្បាប់ ក្នុងការិយាល័យបោះឆ្នោតនីមួយៗសម្រាប់បែងចែកជូន គយ.សប និង គ.ក.ប ដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើស កបយ.ស។

៩.៤.៣ នាយកដ្ឋានប្រតិបត្តិការនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវរៀបចំផែនការបែងចែក និងត្រៀមសម្ភារ ឯកសារបោះឆ្នោតសម្រាប់ដឹកជញ្ជូនទៅកាន់គោលដៅនានាដើម្បីបម្រើការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឱ្យបានគ្រប់គ្រាន់ជាមុន។ សម្ភារ ឯកសារសម្រាប់បម្រើការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតត្រូវបានរៀបចំដាក់ក្នុងហិបដែលរួមមាន ៤ (បួន) ប្រភេទគឺ៖

៩.៤.៣.១ ហិបបរិក្ខារសម្រាប់បណ្តុះបណ្តាលដែលត្រូវបញ្ជូន និងប្រគល់ជូននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតនៃអគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ និង គធ.ខប។

៩.៤.៣.២ ហិបបរិក្ខារ គធ.ខប ដែលអាចមានមួយ ឬច្រើន ហើយត្រូវបញ្ជូន និងប្រគល់ជូន គធ.ខប។

៩.៤.៣.៣ ហិបបរិក្ខារ គឃ.សប ដែលអាចមានមួយ ឬច្រើន ហើយត្រូវបញ្ជូន និងប្រគល់ជូន គឃ.សប។

៩.៤.៣.៤ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលត្រូវបញ្ជូន និងប្រគល់ជូន គ.ក.ប។

៩.៤.៤ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវផ្តត់ផ្គង់សម្ភារ បរិក្ខារ កុំព្យូទ័រ និងសម្ភារចាំបាច់នានាផ្សេងទៀតដល់ គធ.ខប និង គឃ.សប សម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។

៩.៤.៥ នៅរាល់ពេលនៃការបញ្ជូន និងការប្រគល់ ទទួលហិបបរិក្ខារ និងសម្ភារផ្សេងៗដូចមានចែងក្នុងចំណុច ៩.៤.៣ និងចំណុច ៩.៤.៤ ខាងលើនេះ មន្ត្រីដែលទទួលបន្ទុកការបញ្ជូននៅតាមថ្នាក់នីមួយៗ ត្រូវបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) និងត្រូវឱ្យមន្ត្រីដែលទទួលបន្ទុកការទទួលនៅតាមថ្នាក់នីមួយៗចុះហត្ថលេខាបញ្ជាក់ថាបានទទួលគ្រប់ចំនួនហើយ។

៩.៤.៦ ហិបបរិក្ខារ គធ.ខប ដែលត្រូវបញ្ជូន និងប្រគល់ជូន គធ.ខប សម្រាប់ប្រើប្រាស់ក្នុងដំណើរការបោះឆ្នោតដូចមានក្នុងឧបសម្ព័ន្ធទី៦ (សម្ភារ ឯកសារបោះឆ្នោតដែលត្រូវប្រគល់ជូន គធ.ខប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល)។

៩.៤.៧ ហិបបរិក្ខារ គឃ.សប ដែលត្រូវបញ្ជូន និងប្រគល់ជូន គឃ.សប សម្រាប់ប្រើប្រាស់ក្នុងដំណើរការបោះឆ្នោតដូចមានក្នុងឧបសម្ព័ន្ធទី៧ (សម្ភារ ឯកសារបោះឆ្នោតដែលត្រូវប្រគល់ជូន គឃ.សប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល)។

៩.៤.៨ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារ ឧបករណ៍ និងឯកសារផ្សេងទៀតដូចមានក្នុងឧបសម្ព័ន្ធទី៨ (សម្ភារ ឯកសារបោះឆ្នោតដែលត្រូវប្រគល់ជូន គ.ក.ប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល) ដែល គឃ.សប ត្រូវបញ្ជូន និងប្រគល់ជូន គ.ក.ប នីមួយៗ មិនឱ្យលើសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោងមុនថ្ងៃបោះឆ្នោត។

៩.៤.៩ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវធានាក្នុងការបញ្ជូន និងការប្រគល់ឱ្យបានគ្រប់គ្រាន់ជូន គ.ក.ប/គ.ក.រ មិនឱ្យហួសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោង មុនថ្ងៃបោះឆ្នោតនូវសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ៩.៤.៨ ខាងលើនេះ។ គយ.សប ត្រូវជូនដំណឹងដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ដើម្បីចូលរួមសង្កេតមើល គ.ក.ប/គ.ក.រ នៅពេលធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ៩.៤.១១ ខាងក្រោមនេះ។

៩.៤.១០ សមាសភាពទាំងអស់នៃ គ.ក.ប/គ.ក.រ ត្រូវតែមកបង្ហាញខ្លួនតាមការកោះអញ្ជើញរបស់ប្រធាន គ.ក.ប/គ.ក.រ និងត្រូវធានាថានឹងមានវត្តមានក្នុងការបំពេញការងារនៅថ្ងៃបោះឆ្នោត។

៩.៤.១០.១ មុនថ្ងៃបោះឆ្នោត ២៤ (ម្ភៃបួន) ម៉ោង ប្រធាន គ.ក.ប ត្រូវប្រជុំមន្ត្រីទាំងអស់ ដើម្បីពិនិត្យវត្តមាន និងពិនិត្យទីតាំងការិយាល័យបោះឆ្នោត និងពិនិត្យសម្ភារ បរិក្ខារបម្រើឱ្យការបោះឆ្នោត។ ក្នុងករណីបើមានមន្ត្រីណាម្នាក់អវត្តមាន មន្ត្រីនោះត្រូវជំនួសដោយមន្ត្រីថ្មីដែលជ្រើសតាំងឡើងតាមការសម្រេចរបស់ គយ.សប ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុង ប.ន.ឃ.ស នេះ។

៩.៤.១០.២ ប្រសិនបើសមាសភាពណាម្នាក់នៃ គ.ក.ប/គ.ក.រ មិនអាចបំពេញការងារក្នុងថ្ងៃបោះឆ្នោត ប្រធាន គ.ក.ប ត្រូវតែជូនដំណឹងដល់ គយ.សប ជាបន្ទាន់ ដើម្បីដាក់អ្នកជំនួស។

៩.៤.១០.៣ ប្រសិនបើប្រធាន គ.ក.ប មិនអាចមកបំពេញការងារបានដោយសារមូលហេតុសំខាន់ណាមួយនោះ អនុប្រធាន គ.ក.ប ត្រូវចូលកាន់តំណែងប្រធាន គ.ក.ប ហើយសមាជិកទី ១ ចូលកាន់តំណែងអនុប្រធាន គ.ក.ប ចំណែកអ្នកដែលត្រូវជ្រើសរើសថ្មីចេញពីក្នុងចំណោមប្រជាពលរដ្ឋដែលបានដាក់ពាក្យប្រឡងត្រូវចូលកាន់តំណែងជំនួសសមាជិកទី ១។

៩.៤.១០.៤ ប្រសិនបើអនុប្រធាន គ.ក.ប មិនអាចមកធ្វើការបាននោះត្រូវតែងតាំងសមាជិកទី ១ ជាអនុប្រធាន គ.ក.ប ហើយអ្នកដែលត្រូវជ្រើសរើសថ្មីនឹងកាន់តំណែងជាសមាជិកទី ១។

៩.៤.១០.៥ ប្រសិនបើលេខាធិការមិនអាចមកធ្វើការបាន ត្រូវតែងតាំងសមាជិកទី ១ ជាលេខាធិការ ហើយអ្នកដែលត្រូវជ្រើសរើសថ្មីនឹងកាន់តំណែងជាសមាជិកទី ១។

៩.៤.១០.៦ សមាសភាពទាំងអស់នៃ គ.ក.ប/គ.ក.រ រួមទាំងអ្នកដែលទើបតែជ្រើសរើសថ្មីត្រូវរួមគ្នាសិក្សាឡើងវិញនូវនីតិវិធីនៃការបោះឆ្នោត និងសៀវភៅណែនាំ គ.ក.ប/គ.ក.រ។

៩.៤.១០.៧ អ្នកតែងតាំងថ្មីទាំងអស់ត្រូវតែបានទទួលការបណ្តុះបណ្តាល និងអនុវត្តដូចមានចែងក្នុងចំណុច ៩.៤.១០.៦ ខាងលើនេះ។

៩.៤.១០.៨ ប្រធាន គ.ក.ប/គ.ក.រ ត្រូវតែជូនដំណឹងជាបន្ទាន់ដល់ គយ.សប អំពីអ្វីដែលបានអនុវត្តពាក់ព័ន្ធនឹងការដាក់ជំនួសតំណែងណាមួយ នៃ គ.ក.ប/គ.ក.រ។

៩.៤.១១ បន្ទាប់ពីអនុវត្តចំណុច ៩.៤.១០ ខាងលើនេះរួច គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវ សម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែល គ.ក.ប បានទទួល ហើយដែលមានរាយមុខក្នុងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)។

៩.៤.១១.១ គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារ ឯកសារបោះឆ្នោត ដោយប្រើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតនៅមុនថ្ងៃបោះឆ្នោត (ទ.១១១២)។

៩.៤.១១.២ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតដែលបានទទួលមានចំនួនគ្រប់គ្រាន់ហើយ សមាសភាពទាំងអស់នៃ គ.ក.ប ត្រូវចុះហត្ថលេខាលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតនៅមុនថ្ងៃបោះឆ្នោត (ទ.១១១២)។

៩.៤.១១.៣ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតណាមួយ ឬច្រើនដែលបានទទួលនោះមិនមានចំនួនគ្រប់គ្រាន់ លេខាធិការត្រូវបំពេញត្រង់ផ្នែកសម្ភារ ឯកសារបោះឆ្នោតដែលបាត់បង់នៅលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតនៅមុនថ្ងៃបោះឆ្នោត (ទ.១១១២) ហើយត្រូវផ្ញើតារាងត្រួតពិនិត្យនេះ ១ (មួយ) ច្បាប់ ជាបន្ទាន់ទៅ គយ.សប។

៩.៤.១១.៤ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតដែលបាត់បង់ទៅនោះជាសម្ភារ ឯកសារបោះឆ្នោតចាំបាច់សម្រាប់ការបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិក ២ (ពីរ) រូប ឱ្យធ្វើដំណើរទៅទីស្នាក់ការ គយ.សប ដើម្បីទទួលសម្ភារ ឯកសារបោះឆ្នោតថ្មីជំនួសសម្ភារ ឯកសារបោះឆ្នោតដែលខ្វះ ឬបានបាត់បង់ លើកលែងតែមានវិទ្យទាក់ទង ឬទូរស័ព្ទដែលអាចបញ្ជូនព័ត៌មានស្នើសុំ គយ.សប ដោះស្រាយបញ្ហានេះបាន។

៩.៤.១១.៥ ក្នុងការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតខាងលើនេះ គ.ក.ប ត្រូវយកចិត្តទុកដាក់ចំពោះមុខសម្ភារ ឯកសារបោះឆ្នោតដូចខាងក្រោម៖

- ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យប្រាកដថាជាកញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នោះ ហើយគ្រាន់តែពិនិត្យ ផ្ទៀងផ្ទាត់ចំនួន និងលេខរៀងដែលបានកត់ត្រានៅលើកញ្ចប់សន្លឹកឆ្នោតប៉ុណ្ណោះ ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតជាដាច់ខាត
- ពិនិត្យស្រោមសំបុត្រដាក់ត្រាសម្ងាត់ឱ្យប្រាកដថាពិតជាមានត្រាសម្ងាត់នៅខាងក្នុងប៉ុន្តែមិនត្រូវបើកស្រោមសំបុត្រជាដាច់ខាត។

៩.៤.១២ សម្ភារ ឯកសារបោះឆ្នោតចាំបាច់ដែល គ.ក.ប មិនបានទទួល ហើយដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត រួមមាន៖

៩.៤.១២.១ សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់។

៩.៤.១២.២ ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត។

៩.៤.១២.៣ បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។

៩.៤.១២.៤ ហិបឆ្នោត និងសោឃ្លុំមានលេខ។

៩.៤.១២.៥ ទឹកខ្មៅលុបមិនជ្រះ។

៩.៤.១៣ សម្ភារ ឯកសារបោះឆ្នោតដទៃទៀត ប្រសិនបើមិនបានផ្តល់ដោយ គយ.សប នោះ គ.ក.ប ត្រូវច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង៖

៩.៤.១៣.១ កន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាចប្រើបិទបាំងជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៩.៤.១៣.២ ក្រដាសសម្រាប់សរសេរកំណត់ហេតុដោយដៃ ដែលអាចជំនួសទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុជាគំរូ។

៩.៤.១៣.៣ បិកសរសេរ បន្ទាត់ កន្ត្រៃ ខ្សែចង ជាអាទិ៍។

៩.៤.១៤ នៅពេលដែលសម្ភារ ឯកសារបោះឆ្នោតមានគ្រប់ចំនួនហើយ ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី២ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ១ (មួយ) ច្បាប់ នៅមុខការិយាល័យបោះឆ្នោត លើកស្លាកការិយាល័យបោះឆ្នោត និងបិទលេខកូដការិយាល័យបោះឆ្នោតនៅនឹងមាត់ច្រកចូលការិយាល័យបោះឆ្នោត។

៩.៤.១៥ បន្ទាប់ពីបានអនុវត្តចំណុច ៩.៤.១៤ ខាងលើនេះរួច គ.ក.ប ត្រូវរៀបចំការិយាល័យបោះឆ្នោតតាមគំរូប្លង់ការិយាល័យបោះឆ្នោត ដើម្បីឱ្យប្រាកដថាទីតាំងការិយាល័យបោះឆ្នោតនោះអាចដំណើរការបោះឆ្នោតបាន ហើយដែលអាចរៀបចំឱ្យរួចស្រេចនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹកនៃថ្ងៃបោះឆ្នោត។

៩.៤.១៥.១ គ.ក.ប ត្រូវរៀបចំការិយាល័យបោះឆ្នោតតាមគំរូប្លង់ឯកភាពគ្នាមួយ ដោយត្រូវគោរពតាមគោលការណ៍ដូចមានណែនាំក្នុងសៀវភៅណែនាំ គ.ក.ប/គ.ក.រ។

៩.៤.១៥.២ ប្រសិនបើគ្មានគ្រឿងសង្ហារិមនៅក្នុងការិយាល័យបោះឆ្នោតទេ ប្រធាន គ.ក.ប ត្រូវធ្វើសំណើសុំខ្ចីពីអាជ្ញាធរមូលដ្ឋានជាបន្ទាន់នូវគ្រឿងសង្ហារិមចាំបាច់មួយចំនួនសម្រាប់បម្រើការបោះឆ្នោត ដូចជាតុ កៅអី និងសម្ភារដទៃទៀតដែលអាចសម្រួលដល់ការងារបោះឆ្នោត។

៩.៤.១៥.៣ ប្រធាន គ.ក.ប ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខយាមកាមដើម្បីរក្សាសន្តិសុខទីតាំងការិយាល័យបោះឆ្នោត។ ប្រសិនបើអាចធ្វើបាន ប្រធាន គ.ក.ប ត្រូវបិទទ្វារចាក់សោទីតាំងការិយាល័យបោះឆ្នោតនោះផង។

៩.៤.១៦ ប្រធាន គ.ក.ប រួមជាមួយសមាជិក គ.ក.ប ត្រូវរក្សាការពារសម្ភារ ឯកសារបោះឆ្នោតទាំងនោះឱ្យបានហ្មត់ចត់នៅមុនពេលបោះឆ្នោត។

៩.៤.១៦.១ សម្ភារ ឯកសារបោះឆ្នោតអាចនឹងរក្សាទុកនៅផ្ទះរបស់ប្រធាន គ.ក.ប ឬសមាជិកណាម្នាក់ ឬនៅទីតាំងណាមួយដែល គ.ក.ប ឯកភាពគ្នាថាមានសុវត្ថិភាព។

៩.៤.១៦.២ យ៉ាងហោចណាស់ត្រូវមានសមាជិក គ.ក.ប ៣ (បី) នាក់ គិតទាំងប្រធាន គ.ក.ប ផង សម្រាកនៅផ្ទះ ឬទីតាំងដែលទទួលរក្សាសម្ភារ ឯកសារបោះឆ្នោត ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាព។

៩.៤.១៦.៣ ប្រធាន គ.ក.ប ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខ ដើម្បីរួមសហការការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលទទួលរក្សាទុកសម្ភារ ឯកសារបោះឆ្នោត។

៩.៤.១៧ ប្រធាន គ.ក.ប ត្រូវណាត់ជាមួយសមាជិកដទៃទៀតនៃ គ.ក.ប ឱ្យមកកាន់ផ្ទះ ឬទីតាំងសុវត្ថិភាពដែលទទួលរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅម៉ោង ៥:៣០ (ប្រាំ សាមសិប) នាទីព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដើម្បីដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោតទៅកាន់ទីតាំងការិយាល័យបោះឆ្នោត។

៩.៤.១៨ សមាជិកទាំងអស់នៃ គ.ក.ប ត្រូវត្រៀមអាហារសម្រាប់រយៈពេល ១ (មួយ) ថ្ងៃ សម្រាប់ហូបនៅពេលទំនេរដែលពុំមានអ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប។

ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

ប្រការ៩.៥.-

ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតគឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅដូចមានចែងក្នុងប្រការ៥.៥ នៃ ប.ន.ឃ.ស នេះ។ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតត្រូវតែជាកន្លែងដែលមានការត្រួតពិនិត្យ និងយាមកាមយ៉ាងតឹងរ៉ឹងបំផុត ក្នុងគោលបំណងនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៩.៥.១ ប្រធាន គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីការពារអ្នកនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងការិយាល័យទាំងនោះឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខាន ការអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងរក្សាការពារសម្ភារ ឯកសារបោះឆ្នោតទាំងអស់នៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតទាំងនោះ។

៩.៥.២ ក្របខ័ណ្ឌនៃការិយាល័យបោះឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងប្រការ៥.៦ និងចំណុច ៥.៦.១ ចំណុច ៥.៦.២ ចំណុច ៥.៦.៣ ចំណុច ៥.៦.៥ ចំណុច ៥.៦.៧ ចំណុច ៥.៦.៨ និងប្រការ៥.៧ នៃ ប.ន.ឃ.ស នេះ ត្រូវតែបានអនុវត្ត។

៩.៥.៣ ក្របខ័ណ្ឌនៃការិយាល័យរាប់សន្លឹកឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងប្រការ៥.៦ និងចំណុច ៥.៦.១ ចំណុច ៥.៦.២ ចំណុច ៥.៦.៤ ចំណុច ៥.៦.៦ ចំណុច ៥.៦.៧ ចំណុច ៥.៦.៨ និងប្រការ៥.៧ នៃ ប.ន.ឃ.ស នេះ ត្រូវតែបានអនុវត្ត។

ការប្រព្រឹត្តទៅនៃការបោះឆ្នោត

ប្រការ៩.៦.-

គ.ក.ប ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោតដោយនាំមកជាមួយនូវសម្ភារ ឯកសារបោះឆ្នោតឱ្យបានទាន់ពេលនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹកនាថ្ងៃបោះឆ្នោតជាកំហិត ដើម្បីគ្រប់គ្រង និងចាត់ចែងការបោះឆ្នោត។

៩.៦.១ បន្ទាប់ពី គ.ក.ប បានចូលដល់ក្នុងការិយាល័យបោះឆ្នោតភ្លាម ប្រធាន គ.ក.ប ត្រូវប្រកាសឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិចូលក្នុងការិយាល័យបោះឆ្នោត ដោយធ្វើការត្រួតពិនិត្យបណ្តាសម្ភាល់ផ្លូវការម្នាក់ម្តងៗ រួចប្រាប់ទីកន្លែងដែលបម្រុងទុកសម្រាប់ពួកគាត់ដូចមានចែងក្នុងចំណុច ៩.៦.២.៥ ខាងក្រោមនេះ។

៩.៦.២ ទន្ទឹមពេលអនុវត្តចំណុច ៩.៦.១ ខាងលើនេះ ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី២ ឱ្យទៅបំពេញការកិច្ចរបស់ខ្លួននៅបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ព្រមទាំង

ត្រូវចាត់ចែងសមាជិកដទៃទៀតនៃ គ.ក.ប ឱ្យរៀបចំគ្រឿងសង្ហារឹម និងដាក់សម្ភារ ឯកសារ សម្រាប់ការបោះឆ្នោតដូចបានកំណត់ឯកភាពគ្នាលើគំរូប្លង់ការិយាល័យបោះឆ្នោតដែលបានរៀបចំមុនមួយថ្ងៃ និងដូចមានណែនាំនៅក្នុងសៀវភៅណែនាំ គ.ក.ប/គ.ក.រ។

៩.៦.២.១ តុមួយដាក់នៅប៉ែកខាងឆ្វេងដៃ បន្ទាប់ពីផ្លូវចូលសម្រាប់ប្រធាន គ.ក.ប ដែលនៅលើនោះមានសម្ភារ ឯកសារបោះឆ្នោត រួមទាំងបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតចុះហត្ថលេខា និងពាក្យបណ្តឹង (ទ.១២០២) សម្រាប់ផ្តល់ជូនភ្នាក់ងារគណបក្សនយោបាយ។

៩.៦.២.២ តុវែងមួយ ឬតុតូចពីរដាក់នៅប៉ែកខាងស្តាំដៃបន្ទាប់ពីផ្លូវចូលសម្រាប់លេខាធិការ និងអនុប្រធាន គ.ក.ប អង្គុយជាប់គ្នា ដែលនៅចំកន្លែងលេខាធិការមានដាក់បញ្ជីបោះឆ្នោត ត្រា គ.ក.ប កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងទម្រង់បែបបទផ្សេងទៀត ហើយនៅចំកន្លែងអនុប្រធាន គ.ក.ប មានដាក់កញ្ចប់សន្លឹកឆ្នោត តាំប៉ុងពណ៌ក្រហម និងស្រោមសំបុត្រដាក់ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត។

៩.៦.២.៣ បន្ទប់សម្ងាត់សម្រាប់បិទបាំងការគូសសន្លឹកឆ្នោតចំនួន ២ (ពីរ) ដែលមានបិកចងខ្សែភ្ជាប់ស្រាប់ដាក់នៅលើតុពីរក្បែរជញ្ជាំងប្រមាណ ១,៥០ (មួយក្បៀសហាសិប) ម៉ែត្រពីជញ្ជាំង និងមានចម្ងាយពីគ្នាយ៉ាងតិច ១,៥០ (មួយក្បៀសហាសិប) ម៉ែត្រ។ ផ្ទាំងក្រដាសសម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ១ (មួយ) សន្លឹកត្រូវបិទភ្ជាប់ទៅនឹងផ្ទៃតុនៃបន្ទប់សម្ងាត់នីមួយៗ។ បន្ទប់សម្ងាត់ត្រូវមានពន្លឺគ្រប់គ្រាន់។

៩.៦.២.៤ ហិបឆ្នោត ទឹកខ្មៅលុបមិនជ្រះ និងកំណាត់សម្រាប់ជូតដាក់នៅលើតុវែងមួយដែលស្ថិតនៅត្រង់កណ្តាលបន្ទប់ទល់មុខតុរបស់ប្រធាន គ.ក.ប សម្រាប់សមាជិកទី១។

៩.៦.២.៥ តុ និងកៅអីសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ (ប្រសិនបើមាន) ដាក់នៅអែបជញ្ជាំងប៉ែកខាងឆ្វេងដៃនៃតុរបស់ប្រធាន គ.ក.ប និងនៅក្រោយតុអនុប្រធាន គ.ក.ប និងលេខាធិការ។

៩.៦.២.៦ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលមានសម្ភារ ឯកសារបោះឆ្នោតមិនទាន់ត្រូវប្រើប្រាស់ រក្សាទុកនៅក្បែរតុប្រធាន គ.ក.ប។

៩.៦.៣ នៅពេលអនុវត្តចំណុច ៩.៦.១ និងចំណុច ៩.៦.២ ខាងលើនេះរួចរាល់ ប្រធាន គ.ក.ប ត្រូវពន្យល់ណែនាំជារួមដល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាននានា ដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗដែលត្រូវអនុវត្ត ដូចខាងក្រោម៖

៩.៦.៣.១ ត្រូវគោរព ច.ប.ឃ.ស ច.វ.ច.ប ប.ន.ឃ.ស ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត និងក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ដែលកំណត់ដោយ គ.ជ.ប។

៩.៦.៣.២ ត្រូវតាមដានជាប្រចាំកិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោត បង្ការក្រែងមានករណីមិនប្រក្រតីក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៩.៦.៣.៣ ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតក្លែងក្លាយចូលក្នុងការិយាល័យបោះឆ្នោត និងការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត។

៩.៦.៣.៤ មិនត្រូវថតឯកសារ ឬណែនាំ ឬស្តីបន្ទោសអ្វីដល់សមាសភាព គ.ក.ប/គ.ក.រ។

៩.៦.៣.៥ មិនត្រូវណែនាំ ឬសាកសួរអ្វីចំពោះអ្នកបោះឆ្នោត។

៩.៦.៣.៦ មិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ។

៩.៦.៣.៧ ត្រូវលើកសំណួរ សំណូមពរផ្សេងៗ ឬ/និងយោបល់ជំទាស់ដោយផ្ទាល់ទៅប្រធាន គ.ក.ប/គ.ក.រ ចំពោះភ្នាក់ងារគណបក្សនយោបាយ។

៩.៦.៣.៨ ត្រូវបំពេញបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) ដោយត្រូវបញ្ជាក់ឈ្មោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសាមី ម៉ោងចូល ម៉ោងចេញ និងចុះហត្ថលេខា។

៩.៦.៣.៩ ត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតចូលតាមទីកន្លែងដូចបានកំណត់ក្នុងចំណុច ៩.៦.២.៥ ខាងលើនេះ។

៩.៦.៤ នៅចន្លោះពីម៉ោង ៦:០០ (ប្រាំមួយ) ដល់ម៉ោង ៦:៣០ (ប្រាំមួយ សាមសិប) នាទីព្រឹកនៃថ្ងៃបោះឆ្នោត គ.ក.ប ត្រូវត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតជូនអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតតាមនីតិវិធីដូចខាងក្រោម៖

៩.៦.៤.១ ប្រធាន គ.ក.ប ត្រូវពិនិត្យឡើងវិញនូវហិបឆ្នោត ដើម្បីឱ្យប្រាកដថាត្រូវបានដំឡើងត្រឹមត្រូវតាមការណែនាំ។

៩.៦.៤.២ ប្រធាន គ.ក.ប ត្រូវបើកគម្របក្រៅ និងគម្របក្នុងនៃហិបឆ្នោតរួចបង្ហាញហិបឆ្នោតទទេចំពោះមុខអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកត្រូវបិទគម្របក្នុងនៃហិបឆ្នោតទៅវិញ មួលភ្ជិតគម្របសន្ទះ បិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ហើយខ្ចាស់គន្លឹះគម្របក្នុង រួចចាក់សោឃ្លុំ និងប្រាប់លេខាធិការឱ្យកត់ត្រាលេខសោឃ្លុំក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៩.៦.៤.៣ ប្រធាន គ.ក.ប ត្រូវយកក្រដាសលេខកូដការិយាល័យបោះឆ្នោតចំនួន ២ (ពីរ) សន្លឹក និងបោះត្រា គ.ក.ប រួចបិទភ្ជាប់ទៅនឹងជញ្ជាំងខាងមុខ និងខាងក្រោយនៃហិបឆ្នោត ហើយបន្ទាប់មកអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតពិនិត្យមើល និងកត់ចំណាំហិបឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។

៩.៦.៤.៤ លេខាធិការត្រូវកត់ត្រាពេលម៉ោងនៃការពិនិត្យហិបឆ្នោតនៅលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៩.៦.៥ ហិបឆ្នោតដែលបានចាក់សោឃ្លុំ និងបិទសម្គាល់លេខកូដការិយាល័យបោះឆ្នោតរួចហើយដូចមានចែងក្នុងចំណុច ៩.៦.៤.២ និងចំណុច ៩.៦.៤.៣ ខាងលើនេះ គ.ក.ប ត្រូវធានាដូចខាងក្រោម៖

៩.៦.៥.១ មិនអនុញ្ញាតឱ្យបើកចំហដាច់ខាត លើកលែងតែក្នុងគោលបំណងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់ពីការបោះឆ្នោតបានបញ្ចប់។

៩.៦.៥.២ មិនអនុញ្ញាតឱ្យយកចេញពីការិយាល័យបោះឆ្នោត លើកលែងតែ គ.ជ.ប សម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ក្នុងករណីប្រធានសក្តិឬអសន្តិសុខ។

៩.៦.៦ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតត្រូវបានប្រគល់ទទួលនៅក្រោយម៉ោង ៦:៣០ (ប្រាំមួយ សាមសិប) នាទីព្រឹក ប៉ុន្តែមិនហួសពីម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក ប្រធាន គ.ក.ប ត្រូវព្យួរការអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច

៩.៦.៧ ខាងក្រោមនេះ នៅការិយាល័យបោះឆ្នោតនោះជាបណ្តោះអាសន្នសិន រហូតទាល់តែនីតិវិធីដូចមានចែងក្នុងចំណុច ៩.៦.៤ ខាងលើនេះ ត្រូវបានបំពេញចប់សព្វគ្រប់។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាអំពីពេលម៉ោងនៃការអនុវត្តនីតិវិធីបោះឆ្នោតនីមួយៗទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ឱ្យបានច្បាស់លាស់។

៩.៦.៧ នៅចន្លោះពីម៉ោង ៦:៣០ (ប្រាំមួយ សាមសិប) នាទីព្រឹក ដល់ម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកនៃថ្ងៃបោះឆ្នោត គ.ក.ប ត្រូវត្រួតពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតដែលទទួលជាក់ស្តែង ព្រមទាំងត្រួតពិនិត្យ និងបង្ហាញគ្រាសម្ងាត់ផ្លូវការសម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមាន។

៩.៦.៧.១ អនុប្រធាន គ.ក.ប ត្រូវត្រួតពិនិត្យមើលកញ្ចប់សន្លឹកឆ្នោត ដើម្បីឱ្យប្រាកដថាសន្លឹកឆ្នោតនេះជាសន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើស កបយ.ស នោះប្រាកដមែន។ ក្នុងករណីពិនិត្យឃើញថា សន្លឹកឆ្នោតនេះមិនមែនជាសន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនោះ គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈ គយ.សប និង គធ.ខប ជូន គ.ជ.ប ដើម្បីមានវិធានការដោះស្រាយ។

៩.៦.៧.២ បន្ទាប់មកអនុប្រធាន គ.ក.ប ត្រូវបើកកញ្ចប់សន្លឹកឆ្នោត រួចរាប់សន្លឹកឆ្នោត ដែលជាធម្មតាមានចំនួនលើសចំនួនអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ក្នុងចន្លោះពី ២៥ (ម្ភៃប្រាំ) សន្លឹក ដល់ ៧៤ (ចិតសិបបួន) សន្លឹក។

៩.៦.៧.៣ លេខាធិការត្រូវកត់ត្រាចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញជាក់ស្តែង ព្រមទាំងលេខរៀងសន្លឹកឆ្នោតដំបូងនៃក្បាលទី១ និងលេខរៀងសន្លឹកឆ្នោតចុងក្រោយនៃក្បាលចុងក្រោយទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។ ទោះបីសន្លឹកឆ្នោតរាប់ឃើញជាក់ស្តែងមានចំនួនលើស ឬខ្វះធៀបនឹងចំនួនសន្លឹកឆ្នោតដែលត្រូវប្រគល់ឱ្យក្តី ក៏លេខាធិការត្រូវកត់ត្រាចំនួនលើសឬខ្វះនោះទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដែរ។

៩.៦.៧.៤ លេខាធិការត្រូវពិនិត្យចំនួនអ្នកបោះឆ្នោតដែលមាននៅក្នុងបញ្ជីបោះឆ្នោត និងកត់ត្រាចំនួននេះទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៩.៦.៧.៥ ប្រធាន គ.ក.ប ត្រូវបើកស្រោមសំបុត្រដែលមានគ្រាសម្ងាត់សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត រួចដកយកគ្រានោះមកបោះសាកល្បងនៅលើក្រដាសធម្មតាពណ៌ស និងលើកបង្ហាញអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់ឱ្យបានឃើញច្បាស់ និងចំណាំបាននូវរូបសញ្ញានៃគ្រានោះ។

៩.៦.៨ ប្រធាន គ.ក.ប ត្រូវប្រកាសបើកការបោះឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួននៅម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកនៃថ្ងៃបោះឆ្នោត និងអញ្ជើញសមាសភាព គ.ក.ប ឱ្យបោះឆ្នោតមុនគេបង្អស់ រួចបន្ទាប់មកភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន ប្រសិនបើអ្នកទាំងនេះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។ ផ្អែកតាមករណីដូចមានចែងក្នុងចំណុច ៩.៦.៦ ខាងលើនេះ ប្រសិនបើប្រធាន គ.ក.ប មិនអាចប្រកាសបើកការបោះឆ្នោតនៅម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកបាន គាត់អាចប្រកាសបើកការបោះឆ្នោតនៅក្រោយម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោង ៨:០០ (ប្រាំបី) ព្រឹកឡើយ។

៩.៦.៩ បន្ទាប់ពីបានបោះឆ្នោតរួចហើយ សមាជិកទី២ ត្រូវបន្តចាត់ចែងសណ្តាប់ធ្នាប់អ្នកបោះឆ្នោតនៅបរិវេណខាងក្នុង ដោយជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតប្រាប់លេខរៀងឈ្មោះរបស់គាត់ ចេញក្រដាសលេខរៀងតាមលំដាប់មុនក្រោយ និងណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តគ្នាជាជួរ។

៩.៦.១០ បន្ទាប់ពីប្រធាន គ.ក.ប ប្រកាសបើកការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ សមាជិកទី៣ ដែលប្រចាំការនៅត្រង់មាត់ទ្វារត្រូវជម្រាបអ្នកបោះឆ្នោតដែលកំពុងឈរជាជួរបន្តគ្នាតម្រង់ទៅកាន់មាត់ទ្វារចូលការិយាល័យបោះឆ្នោតអំពីអាទិភាពក្នុងការចូលបោះឆ្នោតតាមលំដាប់លំដោយគឺ ព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច ជនមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជំនួយអមដំណើរជនមានពិការភាពនោះ អ្នកមានជំងឺ ឬអ្នកបោះឆ្នោតដែលមានកាតព្វកិច្ចការពារទឹកដីនៅសមរភូមិមុខ (ករណីកាលៈទេសៈតម្រូវ) ព្រមទាំងអ្នកឈរក្នុងជួរខាងមុខគេ។ សមាជិកទី៣ អាចសួរព្រឹកអ្នកបោះឆ្នោតថាបានស្នើឱ្យសមាជិកទី២ ជួយរកឈ្មោះ និងឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនេះហើយឬនៅ។ សមាជិកទី៣ ត្រូវអនុញ្ញាតឱ្យអ្នកបោះឆ្នោតមានវត្តមានក្នុងការិយាល័យបោះឆ្នោតតែចំនួន ៤ (បួន) នាក់ ក្នុងពេលតែមួយ ដោយត្រូវយកចិត្តទុកដាក់ដូចខាងក្រោម៖

៩.៦.១០.១ ត្រូវពិនិត្យមើលអ្នកបោះឆ្នោតមាន អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ សម្រាប់បោះឆ្នោតឬទេ?

៩.៦.១០.២ ត្រូវពិនិត្យមើលម្រាមដៃអ្នកបោះឆ្នោតដែលពិតជាពុំមានស្នាមទឹកខ្មៅលុបមិនជ្រះមែន។ ករណីឃើញមានស្នាមប្រឡាក់ទឹកខ្មៅលុបមិនជ្រះ ត្រូវនាំគាត់ទៅជួបប្រធាន គ.ក.ប។

៩.៦.១០.៣ ត្រូវជម្រាបអ្នកបោះឆ្នោតដែលចូលក្នុងការិយាល័យបោះឆ្នោតឱ្យដើរតម្រង់ទៅតុលេខាធិការ និងអនុប្រធាន គ.ក.ប និងឱ្យបង្ហាញ អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ ទៅលេខាធិការ។

៩.៦.១១ នៅពេលអ្នកបោះឆ្នោតចូលមកដល់ លេខាធិការត្រូវសុំឱ្យអ្នកបោះឆ្នោតបង្ហាញ អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ របស់ខ្លួន។ ពេលនោះលេខាធិការត្រូវ៖

៩.៦.១១.១ ត្រួតពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថាគ្មានស្នាមទឹកខ្មៅលុបមិនជ្រះជាប់នៅលើម្រាមដៃគាត់ទេ។

៩.៦.១១.២ ពិនិត្យមើលលេខរៀងនៅលើបណ្ណព័ត៌មានអ្នកបោះឆ្នោត (ប្រសិនបើមាន) ដើម្បីរកឈ្មោះអ្នកបោះឆ្នោត រួចប្រគល់បណ្ណព័ត៌មានអ្នកបោះឆ្នោតជូនអ្នកបោះឆ្នោតវិញ។ បន្ទាប់មកសួរបញ្ជាក់ឈ្មោះ ពិនិត្យ ផ្ទៀងផ្ទាត់ អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ របស់គាត់ជាមួយនឹងរូបពិត រួចពិនិត្យ ផ្ទៀងផ្ទាត់ជាមួយនឹងរូបថត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត។

៩.៦.១១.៣ ដាក់បន្ទាត់តម្រង់តាមបណ្តោយជួរឈ្មោះរបស់គាត់ និងគូសសញ្ញាធិកបញ្ជាក់ការបានមកបោះឆ្នោតរបស់អ្នកបោះឆ្នោតក្នុងកូនប្រអប់ទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះ រួចហុច អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ របស់គាត់បន្តទៅឱ្យអនុប្រធាន គ.ក.ប ប្រសិនបើឈ្មោះ និងទិន្នន័យក្នុង អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ របស់អ្នកបោះឆ្នោតដូចគ្នានឹងឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត។

៩.៦.១១.៤ ប្រាប់អ្នកបោះឆ្នោតឱ្យទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន គ.ក.ប។

៩.៦.១២ ប្រសិនបើក្នុងពេលអនុវត្តក្នុងចំណុច ៩.៦.១១ ខាងលើនេះ លេខាធិការបានរកឃើញថាអ្នកបោះឆ្នោតមានប្រឡាក់ស្នាមទឹកខ្មៅលុបមិនជ្រះជាប់នៅនឹងម្រាមដៃ ឬរបេះតមិន

ដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន គ.ក.ប ដើម្បីរាយការណ៍អំពីករណីនេះ។

៩.៦.១២.១ ប្រធាន គ.ក.ប ត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតឱ្យមកធ្វើការកត់សម្គាល់អំពីបញ្ហានេះ ហើយត្រូវឱ្យអ្នកបោះឆ្នោតរូបនេះពន្យល់អំពីស្នាមទឹកខ្មៅលុបមិនជ្រះដៃលមានជាប់នឹងម្រាមដៃរបស់គាត់ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា។

៩.៦.១២.២ ប្រសិនបើអ្នកបោះឆ្នោតនោះមិនអាចផ្តល់ការពន្យល់របស់ខ្លួនបានសមហេតុផលអំពីបញ្ហាទឹកខ្មៅ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នានេះទេ នោះគាត់នឹងត្រូវបានសន្និដ្ឋានថាមានបំណងបោះឆ្នោតលើសពីមួយដង ឬមានចេតនាទុច្ចរិតក្នុងការបោះឆ្នោតដែលត្រូវមានទោសតាមច្បាប់។

៩.៦.១២.៣ ប្រធាន គ.ក.ប ត្រូវដកហូត អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ របស់គាត់ជាបណ្តោះអាសន្ន ហើយបញ្ជូនទៅ គឃ.សប ដើម្បីចាត់វិធានការបន្ត។

៩.៦.១២.៤ លេខាធិការត្រូវកត់ត្រាទុកអំពីហេតុការណ៍នេះនៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងត្រូវស្រង់ឈ្មោះ និងទិន្នន័យពី អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ របស់ជននោះសម្រាប់ជាការតាមដានបន្ថែមទៀត។

៩.៦.១២.៥ ប្រសិនបើអ្នកបោះឆ្នោតនោះមិនយល់ព្រមតាមការអនុវត្តនីតិវិធីខាងលើ ប្រធាន គ.ក.ប ឬ គឃ.សប ត្រូវស្នើសុំអាជ្ញាធរមានសមត្ថកិច្ចឱ្យឃាត់ខ្លួនជននោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់។

៩.៦.១៣ ប្រសិនបើក្នុងពេលអនុវត្តចំណុច ៩.៦.១១.២ ខាងលើនេះ លេខាធិការរកមិនឃើញឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតទេ ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន គ.ក.ប ដើម្បីរាយការណ៍អំពីករណីនេះ។

៩.៦.១៣.១ ប្រធាន គ.ក.ប ត្រូវប្រាប់អ្នកបោះឆ្នោតនោះថាគាត់មិនអាចបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះបានទេ ពីព្រោះគាត់គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ទោះបីជាគាត់មាន អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ ក៏ដោយ។

៩.៦.១៣.២ ប្រសិនបើជាករណីច្រឡំការិយាល័យបោះឆ្នោត ប្រធាន គ.ក.ប អាចសួរកបណ្ណព័ត៌មានអ្នកបោះឆ្នោតរបស់គាត់ដើម្បីផ្ទៀងផ្ទាត់

និងត្រូវណែនាំគាត់អំពីទីតាំងការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ដែលឈ្មោះរបស់គាត់មានក្នុងបញ្ជីបោះឆ្នោត។

៩.៦.១៣.៣ ប្រធាន គ.ក.ប ត្រូវប្រាប់គាត់ឱ្យចេញពីការិយាល័យបោះឆ្នោត។

៩.៦.១៤ បន្ទាប់ពីអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ៩.៦.១១ ខាងលើនេះរួច អនុប្រធាន គ.ក.ប ត្រូវហែកសន្លឹកឆ្នោត ១ (មួយ) សន្លឹកចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង និងបត់ជា ៤ (បួន) ផ្នត់ តាមការកំណត់របស់ គ.ជ.ប ហើយប្រគល់ជូនអ្នកបោះឆ្នោត រួមជាមួយ អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ របស់គាត់ផង។ អនុប្រធាន គ.ក.ប មិនត្រូវប្រគល់សន្លឹកឆ្នោត និងមិនត្រូវអនុញ្ញាតឱ្យអ្នកបោះឆ្នោតបន្ទាប់ចូលក្នុងបន្ទប់សម្ងាត់ទេ ប្រសិនបើអ្នកបោះឆ្នោតមុនមិនទាន់ចេញផុតពីបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតនៅឡើយ។ នៅពេលប្រគល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតរួចហើយ អនុប្រធាន គ.ក.ប ត្រូវណែនាំជាសង្ខេបចំពោះអ្នកបោះឆ្នោតដូចខាងក្រោម៖

៩.៦.១៤.១ នេះគឺជាសន្លឹកឆ្នោត។

៩.៦.១៤.២ អ្នកត្រូវដើរទៅកាន់បន្ទប់សម្ងាត់ ប្រើបិកដែលមាននៅទីនោះស្រាប់ ឬបិកផ្ទាល់ខ្លួន (លើកលែងតែខ្មៅដៃ) អ្នកត្រូវគូសសញ្ញាគាំទ្រនៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយដែលអ្នកពេញចិត្ត។ អ្នកត្រូវគិតពិចារណាឱ្យបានហ្មត់ចត់មុននឹងគូសសញ្ញាគាំទ្រ ដើម្បីបង្ការការខូចសន្លឹកឆ្នោត ដោយសារការផ្លាស់ប្តូរចិត្តបន្ទាប់ពីបានគូសសញ្ញាគាំទ្ររួច។

៩.៦.១៤.៣ មុននឹងចេញពីបន្ទប់សម្ងាត់ អ្នកត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើមដើម្បីឱ្យសញ្ញាដែលអ្នកបានគូសស្ថិតនៅក្នុងផ្នត់មិនអាចមើលឃើញ និងឱ្យរូបសញ្ញានៃត្រាសម្ងាត់ស្ថិតនៅខាងក្រៅ។

៩.៦.១៥ បន្ទាប់ពីបានទទួលសន្លឹកឆ្នោត អ្នកបោះឆ្នោតមិនត្រូវសួរអ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត ឬ/និងមិនត្រូវធ្វើសកម្មភាពណាមួយដែលរំលោភទៅលើការសម្ងាត់នៃការបោះឆ្នោតឡើយ។

៩.៦.១៥.១ អ្នកបោះឆ្នោតមិនត្រូវសួរនាំ ឬប្រាប់អ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោតឱ្យដឹងអំពីគណបក្សនយោបាយជាក់លាក់ណាមួយដែលគាត់ពេញចិត្ត ឬមិនពេញចិត្តឡើយ។

៩.៦.១៥.២ អ្នកបោះឆ្នោត ទោះបីមិនចេះអក្សរក៏ដោយ ក៏មិនអាចស្នើសុំជំនួយពីជនណាម្នាក់ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោតឱ្យជួយគាត់ក្នុងការបោះឆ្នោតឡើយ លើកលែងតែអ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯងដូចមានចែងក្នុងចំណុច ៩.៦.១៨ ខាងក្រោមនេះ។

៩.៦.១៥.៣ ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍បោះឆ្នោតដែលនៅក្នុងការិយាល័យបោះឆ្នោត មិនត្រូវបានអនុញ្ញាតឱ្យជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតទេ ទោះបីអ្នកបោះឆ្នោតនោះស្នើសុំឱ្យជួយក៏ដោយ។

៩.៦.១៥.៤ ហាមអ្នកបោះឆ្នោត និងអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប្រើទូរសព្ទដៃ ឬ/និងម៉ាស៊ីនថត ឬ/និងឧបករណ៍ផ្សេងទៀតដែលអាចថតរូប ឬ/និងថតសំឡេងបាន ឬ/និងហាមធ្វើសកម្មភាពរំលោភលើការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត។ អ្នកសារព័ត៌មានដែលទទួលស្គាល់ដោយ គ.ជ.ប និងបានការអនុញ្ញាតពីប្រធាន គ.ក.ប អាចថតយកសកម្មភាពនៅការិយាល័យបោះឆ្នោតប៉ុន្តែមិនត្រូវរំលោភលើការសម្ងាត់នៃការបោះឆ្នោត។ ការហាមឃាត់នេះសម្រាប់តែក្នុងដំណើរការបោះឆ្នោតប៉ុណ្ណោះ។

៩.៦.១៦ បន្ទាប់ពីបានទទួលសន្លឹកឆ្នោត និងអនុវត្តតាមការណែនាំរបស់អនុប្រធាន គ.ក.ប ដូចមានចែងក្នុងចំណុច ៩.៦.១៤.២ និងចំណុច ៩.៦.១៤.៣ ខាងលើនេះរួច អ្នកបោះឆ្នោតត្រូវចេញពីបន្ទប់សម្ងាត់ ហើយដើរតម្រង់ទៅតុដាក់ហិបឆ្នោត។

៩.៦.១៦.១ អ្នកបោះឆ្នោតត្រូវបង្ហាញសន្លឹកឆ្នោតរបស់ខ្លួនដែលបានបត់រួចនោះដោយដាក់បែរផ្នែកខាងខ្នងដែលមានបោះត្រាសម្ងាត់ទៅកសមាជិកទី១ ហើយស៊កវាដោយខ្លួនឯងតាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត លើកលែងតែអ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចស៊កដោយខ្លួនឯងបាន។

៩.៦.១៦.២ ស្របពេលដែលអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោតដែលបត់រួចបម្រុងនឹងស៊កទៅក្នុងហិបឆ្នោត សមាជិកទី១ ត្រូវពិនិត្យឱ្យប្រាកដថាពិតជាសន្លឹកឆ្នោតផ្លូវការតែមួយសន្លឹកដែលមានបោះត្រាសម្ងាត់ជាផ្លូវការសម្រាប់ការិយាល័យបោះឆ្នោតនោះ។

៩.៦.១៦.៣ បន្ទាប់មកអ្នកបោះឆ្នោតត្រូវយល់ព្រមឱ្យសមាជិកទី១ ជ្រលក់ឱ្យលិចដល់គល់ក្រចកនៃម្រាមចង្អុលដៃស្តាំ ឬម្រាមផ្សេងទៀត ប្រសិនបើម្រាមចង្អុលដៃស្តាំពិការចូលទៅក្នុងដបទឹកខ្មៅលុបមិនជ្រះដូចមានចែងក្នុងចំណុច ៩.៦.១៧ ខាងក្រោមនេះ។

៩.៦.១៦.៤ ប្រសិនបើសមាជិកទី១ ពិនិត្យឃើញថាអ្នកបោះឆ្នោតណាម្នាក់បានស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀតចូលទៅក្នុងហិបឆ្នោត

ត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធាន គ.ក.ប។ ក្នុងករណីនេះ ប្រធាន គ.ក.ប ត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត មុននឹងចាត់វិធានការឆែកឆេរកសន្លឹកឆ្នោតផ្លូវការ។

៩.៦.១៦.៥ ប្រសិនបើមានអ្នកបោះឆ្នោតណាម្នាក់ដែលត្រូវបានសមាជិកទី១ ចាប់កស្តុតាងបានថាមានបំណងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពី ១ (មួយ) សន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតនោះត្រូវតែមានទោសដោយផ្អែកតាម ច.ប.ឃ.ស និង ច.វ.ច.ប។

៩.៦.១៦.៦ ប្រធាន គ.ក.ប ត្រូវឃាត់អ្នកបោះឆ្នោតដូចបញ្ជាក់ក្នុងចំណុច ៩.៦.១៦.៥ ខាងលើនេះ មិនឱ្យបោះឆ្នោត រួចដកហូតសន្លឹកឆ្នោតមិនត្រឹមត្រូវទាំងនោះនិងឆែកឆេរកសន្លឹកឆ្នោតផ្លូវការ(ប្រសិនបើមាន) ដាក់ទៅក្នុងស្រោមសំបុត្រមានកាខ្នងថា “សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត” បន្ទាប់មកត្រូវដកហូត អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ របស់ជននោះជាបណ្តោះអាសន្ន ព្រមទាំងចាត់ចែងឱ្យធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្តឹងចោទប្រកាន់ជនប្រព្រឹត្តអំពើល្មើសទៅ គឃ.សប។

៩.៦.១៦.៧ ប្រសិនបើជនដែលបានប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយបើមានភស្តុតាងគ្រប់គ្រាន់នោះ គឃ.សប ត្រូវបន្តប្តឹងទៅ គធ.ខប និង គ.ជ.ប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

៩.៦.១៧ ទឹកខ្មៅលុបមិនជ្រះដែលអាចមើលឃើញច្បាស់ត្រូវបានដាក់បញ្ញត្តិឱ្យប្រើក្នុងការបោះឆ្នោតជ្រើសរើស កបឃ.ស សម្រាប់បង្ការការបោះឆ្នោតលើសពី ១ (មួយ) ដង។

៩.៦.១៧.១ ក្នុងការិយាល័យបោះឆ្នោតនីមួយៗត្រូវបានផ្គត់ផ្គង់ទឹកខ្មៅលុបមិនជ្រះចំនួន ២ (ពីរ) ដប។

៩.៦.១៧.២ ដបទឹកខ្មៅលុបមិនជ្រះ ១ (មួយ) ដប ត្រូវបានបើកគម្របប្រើនៅពេលបើកការបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងបម្រុងទុក ១ (មួយ) ដប សម្រាប់ប្រើនៅពេលអស់ទឹកខ្មៅលុបមិនជ្រះដបទីមួយ។

៩.៦.១៧.៣ បន្ទាប់ពីអ្នកបោះឆ្នោតបានស៊កសន្លឹកឆ្នោតរបស់ខ្លួនទៅក្នុងហិបឆ្នោត និងនៅមុនពេលគាត់ដើរចេញពីការិយាល័យបោះឆ្នោត គាត់ត្រូវ

យល់ព្រមឱ្យសមាជិកទី១ ជ្រលក់ម្រាមចង្អុលដៃស្តាំរបស់គាត់ឱ្យលិចគល់ក្រចកទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ និងរង់ចាំល្មមទឹកខ្មៅស្ងួត ទើបអនុញ្ញាតឱ្យគាត់ចេញពីការិយាល័យបោះឆ្នោត។

៩.៦.១៧.៤ ក្នុងករណីម្រាមចង្អុលដៃស្តាំពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយតាមលំដាប់លំដោយដូចតទៅ ម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ឬមេដៃឆ្វេង ឬចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង។ ប្រសិនបើគាត់មិនអាចធ្វើបានតាមការកំណត់ខាងលើរាល់ការជ្រលក់ ឬលាបត្រង់ផ្នែកណាមួយនៃអវយវៈរបស់គាត់ត្រូវទទួលយកជាបានការ។

៩.៦.១៧.៥ រៀងរាល់ ៣០ (សាមសិប) នាទីម្តង ដបទឹកខ្មៅលុបមិនជ្រះត្រូវតែបានបិទគម្របយ៉ាងជិតហើយក្រឡុក។

៩.៦.១៧.៦ ប្រសិនបើគ្មានអ្នកបោះឆ្នោតមួយរយៈពេលយូរគួរសម សមាជិកទី១ ត្រូវបិទគម្របដបទឹកខ្មៅ ដើម្បីការពារកុំឱ្យវាហួត។

៩.៦.១៨ គ្មានជនណាម្នាក់ចូលទៅជ្រៀតជ្រែកនៅក្នុងការិយាល័យបោះឆ្នោត ឬជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបានឡើយ លើកលែងតែអ្នកបោះឆ្នោតនោះជាជនមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ហើយបានស្នើសុំអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬស្នើសុំជំនួយពីប្រធាន គ.ក.ប ដូចមានចែងក្នុង ច.ប.ឃ.ស ដោយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

៩.៦.១៨.១ បន្ទាប់ពីបានអនុញ្ញាតឱ្យចូលការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន និងអ្នកជំនួយជានីតិជនម្នាក់ ដែលអមដំណើរជាមួយដើម្បីជួយគាត់ក្នុងការបោះឆ្នោតត្រូវអនុវត្តជាបន្តបន្ទាប់តាមចំណុច ៩.៦.១១ ចំណុច ៩.៦.១៤ និងចំណុច ៩.៦.១៦ ខាងលើនេះ។

៩.៦.១៨.២ បន្ទាប់ពីបានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ដែលមានបំណងស្នើសុំជំនួយពីប្រធាន គ.ក.ប ត្រូវទៅជួបប្រធាន គ.ក.ប ដោយផ្ទាល់។ បន្ទាប់មកប្រធាន គ.ក.ប ត្រូវអមដំណើរអ្នកបោះឆ្នោតជាជនមានពិការភាពនោះអនុវត្តជាបន្តបន្ទាប់តាមចំណុច ៩.៦.១១ ចំណុច ៩.៦.១៤ និងចំណុច ៩.៦.១៦ ខាងលើនេះ។ ក្នុងករណីនេះ ប្រធាន គ.ក.ប អាចចាត់សមាជិក គ.ក.ប ណាម្នាក់ឱ្យជួយក៏បាន ប៉ុន្តែត្រូវមានការយល់ព្រមពីអ្នកបោះឆ្នោតជាជនមានពិការភាពនោះ។

៩.៦.១៨.៣ អ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯងត្រូវសួរនាំ ឬប្រាប់អំពីគណបក្សនយោបាយដែលខ្លួនពេញចិត្តទៅប្រធាន គ.ក.ប សមាជិក គ.ក.ប ឬអ្នកជំនួយដែលខ្លួនជ្រើសរើសតែនៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតប៉ុណ្ណោះ។

៩.៦.១៨.៤ នៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ប្រធាន គ.ក.ប សមាជិក គ.ក.ប ឬអ្នកជំនួយដែលជួយអ្នកបោះឆ្នោតជាជនមានពិការភាពក្នុងការបោះឆ្នោត ត្រូវសួរអ្នកបោះឆ្នោតជាជនមានពិការភាពនោះថាតើគាត់បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ដោយសួរតិចៗ ធ្វើយ៉ាងណាកុំឱ្យមនុស្សដែលនៅក្នុងការិយាល័យបោះឆ្នោតឮឱ្យសោះ។ បន្ទាប់មកប្រធាន គ.ក.ប សមាជិក គ.ក.ប ឬអ្នកជំនួយត្រូវគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយនៅលើសន្លឹកឆ្នោតដែលឆ្លើយតបនឹងការជ្រើសរើសរបស់អ្នកបោះឆ្នោតជាជនមានពិការភាព ហើយបត់សន្លឹកឆ្នោតនោះតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅក្នុងផ្នត់ រួចត្រូវនាំអ្នកបោះឆ្នោតជាជនមានពិការភាពទៅកាន់ហិបឆ្នោត និងជួយសិកសន្លឹកឆ្នោតរបស់គាត់តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត។

៩.៦.១៨.៥ ប្រធាន គ.ក.ប សមាជិក គ.ក.ប ឬអ្នកជំនួយដែលបានជួយអ្នកបោះឆ្នោតដែលជាជនមានពិការភាពដូចលក្ខខណ្ឌមានចែងក្នុងចំណុច ៩.៦.១៨ ខាងលើនេះ ត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់។

៩.៦.១៩ ចំពោះអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាង ហើយមានបំណងចង់បោះឆ្នោតដោយខ្លួនឯង ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតនោះឱ្យប្រើក្របក្រដាសពិសេសដែលជាសម្ភារជំនួយដល់ការបោះឆ្នោត។

៩.៦.១៩.១ ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាងនោះទៅជួបលេខាធិការ ដើម្បីអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ៩.៦.១១ ខាងលើនេះ។ នៅពេលអនុវត្តចំណុច ៩.៦.១១ ខាងលើនេះរួចរាល់ លេខាធិការត្រូវហុចឯកសារពាក់ព័ន្ធជូនអនុប្រធាន គ.ក.ប។

៩.៦.១៩.២ អនុប្រធាន គ.ក.ប ត្រូវហែកសន្លឹកឆ្នោត ១ (មួយ) សន្លឹកចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នងបត់ជា ៤ (បួន) ផ្នត់តាមការកំណត់ និងត្រូវណែនាំអ្នកបោះឆ្នោតដែលជាជនពិការភ្នែក

ទាំងសងខាងឱ្យស្អាបសន្លឹកឆ្នោត និងស្នាមបត់ រួចលាសន្លឹកឆ្នោតឱ្យស្មើឡើងវិញ និងដាក់នៅក្នុងក្របក្រដាសពិសេស ដោយឱ្យផ្នែកខាងមុខនៃសន្លឹកឆ្នោតលេចចេញប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សតាមប្រហោងសម្រាប់គូស និងប្រើឃ្នាបគាបសន្លឹកឆ្នោតនោះភ្ជាប់នឹងក្របក្រដាសពិសេស ដើម្បីបង្ការកុំឱ្យប្រអប់លេខរៀងសម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយងាក ឬល្អៀងចេញពីប្រហោងនៃក្របក្រដាសពិសេស។

៩.៦.១៩.៣ អនុប្រធាន គ.ក.ប ត្រូវប្រគល់ក្របក្រដាសពិសេសដែលមានដាក់សន្លឹកឆ្នោតខាងក្នុងជូនទៅអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាង និងកាន់ម្រាមដៃណាមួយរបស់គាត់ឱ្យមកប៉ះ និងស្អាបប្រហោងរាងបួនជ្រុងទ្រវែងដែលចោះលើក្របក្រដាសពិសេសពីលើចុះក្រោម និងជម្រាបគាត់ថា៖

- អ្នកអាចស្អាប និងរាប់ប្រហោងរាងបួនជ្រុងទ្រវែងដែលកំណត់លេខរៀង និងចំនួនគណបក្សនយោបាយទាំងអស់នៅលើសន្លឹកឆ្នោត។ ប្រហោងរាងបួនជ្រុងទ្រវែងគឺជាប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នេះ
- អ្នកត្រូវចងចាំអំពីលេខរៀងរបស់គណបក្សនយោបាយដែលអ្នកពេញចិត្ត
- អ្នកត្រូវប្រើបិកគូសសញ្ញាគាំទ្រក្នុងប្រហោងរាងបួនជ្រុងទ្រវែងបន្ទាប់ពីអ្នកបានស្អាប និងដឹងច្បាស់អំពីប្រអប់លេខរៀងគណបក្សដែលអ្នកពេញចិត្ត
- អ្នកត្រូវដោះឃ្នាប និងដកសន្លឹកឆ្នោតចេញពីក្របក្រដាសពិសេស រួចបត់តាមផ្នត់ដើម ហើយស្នើសុំប្រធាន គ.ក.ប ឱ្យជួយជូនទៅស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោត។

៩.៦.១៩.៤ ប្រធាន គ.ក.ប ត្រូវអនុវត្តភារកិច្ចដូចខាងក្រោម បន្ទាប់ពីអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាងបានទទួលក្របក្រដាសពិសេសដែលមានសន្លឹកឆ្នោតផ្លូវការនៅខាងក្នុងរួចហើយ។

- ជួយជូនអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាងនោះទៅកាន់បន្ទប់សម្ងាត់ និងជួយរកបិកសម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយ

- ជួយរៀបចំក្របក្រដាសពិសេសឱ្យមានភាពត្រឹមត្រូវ ប្រសិនបើពិនិត្យឃើញថាក្របក្រដាសពិសេសនោះមានសភាពមិនប្រក្រតី ឬដាក់មិនទំនង
- ចេញពីបន្ទប់សម្ងាត់ និងរង់ចាំជួយបន្ថែមទៀត ប្រសិនបើមានសំណូមពរពីអ្នកបោះឆ្នោតនោះ។

៩.៦.១៩.៥ រាល់ការអនុវត្តនីតិវិធីខាងលើនេះ ត្រូវធ្វើឡើងចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត។

៩.៦.១៩.៦ គ.ជ.ប ត្រូវរៀបចំឱ្យមានក្របក្រដាសពិសេសមានទម្រង់ជា ២ (ពីរ) សន្លឹកជាប់គ្នា ដែលមានក្របមុខ និងក្របខាងខ្នង មានទំហំប៉ុនគ្នានឹងសន្លឹកឆ្នោតផ្លូវការនៃឃុំ សង្កាត់នីមួយៗ ហើយក្របក្រដាសពិសេសនេះ ត្រូវចោះប្រហោងរាងបួនជ្រុងទ្រវែងមានទំហំប៉ុនគ្នានៅចំប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយដែលមាននៅលើសន្លឹកឆ្នោតផ្លូវការ។

៩.៦.២០ ប្រសិនបើក្នុងការិយាល័យបោះឆ្នោតគ្មានអ្នកបោះឆ្នោតនោះទេ សមាជិកទី១ ត្រូវបិទភ្ជិតសន្ទះបិទប្រឡោះសម្រាប់សឹកសន្លឹកឆ្នោតជាបណ្តោះអាសន្ន ហើយត្រូវបើកឡើងវិញនៅពេលមានវត្តមានអ្នកបោះឆ្នោត។

៩.៦.២១ គ្មានជនណាម្នាក់ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោតអាចពិនិត្យមើលការគូសសញ្ញាលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតឡើយ លើកលែងតែអ្នកដែលជួយអ្នកបោះឆ្នោតដែលជាជនមានពិការភាពដូចមានចែងក្នុងចំណុច ៩.៦.១៨ ខាងលើនេះ។

៩.៦.២១.១ ជនណាក៏ដោយដូចមានចែងក្នុងចំណុច ៩.៦.២១ ខាងលើនេះ ដែលប៉ុនប៉ងចង់ឃើញការគូសសញ្ញានៅលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោត ជននោះនឹងត្រូវទទួលការព្រមានពីប្រធាន គ.ក.ប។ ការប៉ុនប៉ងជាលើកទីពីរ ដើម្បីធ្វើឱ្យបែកខ្ញែកខ្ចាយនូវគោលការណ៍សម្ងាត់នៃការបោះឆ្នោតនឹងត្រូវចាត់ទុកថាជាការរំលោភទៅលើច្បាប់ ហើយជនដែលមានការពាក់ព័ន្ធត្រូវតែបានបណ្តេញចេញពីការិយាល័យបោះឆ្នោត និងត្រូវទទួលទោសតាម ច.ប.ប.ស និង ច.វ.ច.ប។

៩.៦.២១.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត។

៩.៦.២១.៣ ប្រសិនបើជនប្រព្រឹត្តអំពើល្មើសលើគោលការណ៍សម្ងាត់នៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ៩.៦.២១.១ ខាងលើនេះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត ប្រធាន គ.ក.ប ត្រូវបញ្ជូនកំណត់ហេតុស្តីពីហេតុការណ៍នោះទៅ គយ.សប។

៩.៦.២១.៤ ពេលបានទទួលកំណត់ហេតុដូចមានចែងក្នុងចំណុច ៩.៦.២១.៣ ខាងលើនេះភ្លាម គយ.សប ត្រូវធ្វើការស៊ើបអង្កេតអំពើរំលោភនោះជាបន្ទាន់ ហើយប្រសិនបើមានភស្តុតាងបញ្ជាក់ថាពិតប្រាកដមែន ត្រូវតែប្តឹងជនប្រព្រឹត្តអំពើល្មើសទៅ គធ.ខប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

៩.៦.២២ អ្នកបោះឆ្នោតណាម្នាក់ដែលបានធ្វើឱ្យខូចសន្លឹកឆ្នោតដោយអចេតនា ដោយធ្វើឱ្យរហែក ឬធ្វើឱ្យប្រឡាក់ ឬដែលបានគូសសញ្ញានៅលើសន្លឹកឆ្នោតរួចហើយ តែបានប្តូរចិត្តវិញ គាត់អាចសុំសន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀតពីប្រធាន គ.ក.ប។

៩.៦.២២.១ អ្នកបោះឆ្នោតដែលស្នើសុំសន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀត ត្រូវបត់សន្លឹកឆ្នោតខូចតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅខាងក្នុងផ្នត់ រួចប្រគល់ជូនប្រធាន គ.ក.ប។

៩.៦.២២.២ ប្រធាន គ.ក.ប ត្រូវសិកសន្លឹកឆ្នោតដែលខូចនោះទៅក្នុងស្រោមសំបុត្រមួយដែលមានកាខ្នងស្រាប់ថា “សន្លឹកឆ្នោតខូច”។

៩.៦.២២.៣ លេខាធិការដែលបានគូសសញ្ញាសម្គាល់ម្តងហើយក្នុងប្រអប់នៅប៉ែកខាងដើមទន្ទឹមនឹងឈ្មោះគាត់ក្នុងបញ្ជីបោះឆ្នោតដូចមានចែងក្នុងចំណុច ៩.៦.១១.៣ ខាងលើនេះ មិនចាំបាច់គូសសញ្ញាសម្គាល់ជាលើកទីពីរឡើយ ប៉ុន្តែត្រូវកត់ចំណាំទុកសម្រាប់សរសេរចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៩.៦.២២.៤ ប្រធាន គ.ក.ប ត្រូវអនុញ្ញាតឱ្យអនុប្រធាន គ.ក.ប ផ្តល់សន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀតចំពោះអ្នកបោះឆ្នោតដែលមានចែងក្នុងចំណុច ៩.៦.២២ ខាងលើនេះ តែមួយលើកគត់ និងត្រូវធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់សម្រាប់ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងត្រូវរំឭកអនុប្រធាន គ.ក.ប ឱ្យណែនាំអ្នកបោះឆ្នោតបន្ទាប់តាមខ្លឹមសារនៃចំណុច ៩.៦.១៤.២ ខាងលើនេះ ដោយឆ្លៃលើចំនួនជាក់ស្តែងនៃសន្លឹកឆ្នោតនៅការិយាល័យនោះ។

៩.៦.២២.៥ ក្នុងករណីមានអ្នកបោះឆ្នោតមួយចំនួនជាបន្តបន្ទាប់គ្នាសុំសន្លឹកឆ្នោត ១ (មួយ) សន្លឹកឆ្នោតផ្សេងទៀតដូចមានចែងក្នុងចំណុច ៩.៦.២២

ខាងលើនេះ ដែលអាចចាត់ទុកថាជាភាពមិនប្រក្រតីមួយនោះ ប្រធាន គ.ក.ប អាចសម្រេចមិនព្រមផ្តល់សន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀតតាមការស្នើសុំទេ ហើយឱ្យលេខាធិការកត់ត្រាបញ្ហាទាំងនេះចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៩.៦.២៣ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយណាម្នាក់ជំទាស់ ឬតវ៉ានឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬការសម្រេចណាមួយរបស់ គ.ក.ប គាត់ត្រូវលើកការជំទាស់ ឬការតវ៉ានោះដោយផ្ទាល់ទៅប្រធាន គ.ក.ប ដោយបង្ហាញអំពីមូលហេតុ ឬ/និងភស្តុតាងដែលនាំឱ្យគាត់ជឿថាមានភាពមិនប្រក្រតី ឬការរំលោភច្បាប់ ឬ/និងការរំលោភ ប.ន.ឃ.ស ក្នុងការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។

៩.៦.២៣.១ ប្រសិនបើយល់ឃើញថាសមហេតុផល ប្រធាន គ.ក.ប ត្រូវបញ្ឈប់ជាបណ្តោះអាសន្ននូវកិច្ចប្រតិបត្តិការបោះឆ្នោត ដើម្បីស្តាប់ការជំទាស់ ឬការតវ៉ារបស់ភ្នាក់ងារគណបក្សនយោបាយនោះ ហើយបន្ទាប់មកពិភាក្សាបញ្ហានេះជាមួយនឹងសមាជិក គ.ក.ប ដទៃទៀត។

៩.៦.២៣.២ បន្ទាប់ពីបានពិនិត្យឡើងវិញអំពីករណីដែលបានលើកជំទាស់ ឬតវ៉ា ប្រសិនបើប្រធាន គ.ក.ប យល់ព្រមតាមការជំទាស់ ឬការតវ៉ា ប្រធាន គ.ក.ប ត្រូវណែនាំ និងរំឭកសមាជិក គ.ក.ប និងអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោតអំពីខ្លឹមសារពាក់ព័ន្ធដែលមានចែងក្នុង ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ ហើយត្រូវចាត់វិធានការដោះស្រាយភាពមិនប្រក្រតីនោះជាបន្ទាន់។

៩.៦.២៣.៣ ប្រសិនបើប្រធាន គ.ក.ប បដិសេធការជំទាស់ ឬការតវ៉ា គាត់ត្រូវផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធនោះជូនភ្នាក់ងារគណបក្សនយោបាយ។

៩.៦.២៣.៤ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនៅតែជំទាស់ ឬតវ៉ា ប្រធាន គ.ក.ប ត្រូវកត់ត្រាការជំទាស់ ឬការតវ៉ានេះក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដោយឱ្យអ្នកជំទាស់ ឬតវ៉ានោះចុះហត្ថលេខាលើកំណត់ហេតុនេះ។

៩.៦.២៣.៥ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនោះមិនយល់ព្រមចុះហត្ថលេខា ករណីនៃការជំទាស់ ឬការតវ៉ានោះមិនត្រូវបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ទេ។

៩.៦.២៣.៦ ការសម្រេចរបស់ប្រធាន គ.ក.ប ជាការសម្រេចបានការក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធាន គ.ក.ប ត្រូវប្រកាសបន្តដំណើរការបោះឆ្នោតទៅទៀត។

៩.៦.២៣.៧ ចំណុច ៩.៦.២៣.៦ ខាងលើនេះ មិនបានច្រានចោលជាមុននូវដំណើរហេតុដែលភ្នាក់ងារគណបក្សនយោបាយណាម្នាក់ចង់បន្តប្តឹងជំទាស់ ឬប្តឹងតវ៉ាទៅ គឃ.សប អំពីករណីដែលគាត់បានលើកជំទាស់ ឬតវ៉ាក្នុងការិយាល័យបោះឆ្នោតនោះទេ ប៉ុន្តែក្នុងស្ថានភាពនេះ គាត់ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គ.ក.ប និងមិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោតឡើយ។

៩.៦.២៣.៨ ប្រធាន គ.ក.ប ត្រូវផ្តល់ពាក្យបណ្តឹង (ទ.១២០២) ប្រសិនបើភ្នាក់ងារគណបក្សនយោបាយស្នើសុំសម្រាប់ប្តឹងបន្តទៅ គឃ.សប។

៩.៦.២៤ ប្រសិនបើមានអ្នកបោះឆ្នោតណាម្នាក់រំខានដល់កិច្ចប្រតិបត្តិការបោះឆ្នោត ទោះបីគាត់ស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬកំពុងឈរតម្រង់ជួរនៅខាងក្រៅការិយាល័យក្តី ប្រធាន គ.ក.ប ត្រូវណែនាំឱ្យគាត់រក្សារបៀបរៀបរយ។ ក្នុងករណីអ្នកបោះឆ្នោតនោះបដិសេធមិនព្រមគោរពតាមបញ្ជារបស់ខ្លួន ប្រធាន គ.ក.ប ត្រូវស្នើកម្លាំងសន្តិសុខបោះឆ្នោតឱ្យបណ្តេញបុគ្គលនោះចេញ ឬឃាត់ខ្លួនបុគ្គលនោះរហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់។

៩.៦.២៥ ប្រធាន គ.ក.ប អាចស្នើសុំកម្លាំងសន្តិសុខបោះឆ្នោតឱ្យរៀបចំសារឡើងវិញនូវរបៀបរៀបរយនៅក្នុងការិយាល័យបោះឆ្នោត និងក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោត ប្រសិនបើកិច្ចប្រតិបត្តិការបោះឆ្នោតត្រូវបានរំខានដល់កម្រិតដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោតបន្តទៀតបាន ឬធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរី។ ការរំខានដល់អ្នកបោះឆ្នោត ឬដល់ការប្រព្រឹត្តទៅនៃការបោះឆ្នោត គឺជាសកម្មភាពទាំងឡាយណាដែលកើតមានឡើងនៅក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត មានជាអាទិ៍ដូចខាងក្រោម៖

៩.៦.២៥.១ ការបញ្ចេញសម្រែកខ្លាំងៗ ការបញ្ចេញសម្តីគំរាមកំហែង ឬការជេរប្រមាថ មាក់ងាយ។

៩.៦.២៥.២ ការធ្វើសកម្មភាពរាំង ឬញុះញង់អ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។

៩.៦.២៥.៣ ការណែនាំ ឬការញុះញង់អ្នកបោះឆ្នោតឱ្យបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

៩.៦.២៥.៤ ការរុញច្រានដោយប្រើកម្លាំងធ្ងន់។

៩.៦.២៥.៥ ការគប់វត្ថុផ្សេងៗសំដៅអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត។

៩.៦.២៥.៦ ការអុកឡុកនៃបុគ្គលណាម្នាក់ ឬច្រើននាក់ ដែលធ្វើឱ្យរំខានដល់អ្នកបោះឆ្នោត។

៩.៦.២៥.៧ ការបញ្ចេញអាកប្បកិរិយា និងភាសាមិនសមរម្យ។

៩.៦.២៥.៨ ការបញ្ចេញឱ្យឃើញនូវអាវុធ គ្រឿងផ្ទុះ ឬសារធាតុផ្សេងៗប្រកបដោយគ្រោះថ្នាក់។

៩.៦.២៦ ប្រសិនបើការបោះឆ្នោតឈានដល់ម៉ោង ១៥:០០ (ដប់ប្រាំ) នៃថ្ងៃបោះឆ្នោតដែលជាពេលវេលាកំណត់សម្រាប់ការបញ្ចប់ដំណើរការបោះឆ្នោត ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោតទៀត អ្នកបោះឆ្នោតទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត។

៩.៦.២៦.១ ក្នុងករណីនេះ សមាជិកទី២ ត្រូវប្រកាសអញ្ជើញអ្នកបោះឆ្នោតដែលមានវត្តមាននៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងត្រូវប្រមូលយក អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ ពីអ្នកបោះឆ្នោតដែលនៅក្នុងជួរ ដោយចាប់ផ្តើមពីអ្នកបោះឆ្នោតដែលឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ទៅឱ្យសមាជិកទី៣ នៅត្រង់មាត់ទ្វារ។

៩.៦.២៦.២ សមាជិកទី៣ ត្រូវហៅឈ្មោះអ្នកបោះឆ្នោតម្នាក់ម្តងៗ រហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោតដើម្បីបោះឆ្នោតតាមលំដាប់លំដោយរហូតដល់អស់អ្នកបោះឆ្នោត។

៩.៦.២៦.៣ អ្នកបោះឆ្នោតដែលគ្មានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតនៅនាទីចុងក្រោយនាម៉ោង ១៥:០០ (ដប់ប្រាំ) នៃថ្ងៃបោះឆ្នោតទេនោះ អ្នកបោះឆ្នោតទាំងនោះពុំត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ។

៩.៦.២៧ ប្រសិនបើអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនទាន់បានមកបោះឆ្នោតគ្រប់គ្នាទេ ទោះបីគ្មានអ្នកបោះឆ្នោតឈរចាំបោះឆ្នោតក្តី ប្រធាន គ.ក.ប មិនអាចបិទការបោះឆ្នោតនៅការិយាល័យរបស់ខ្លួននៅមុនម៉ោង ១៥:០០ (ដប់ប្រាំ) នៃថ្ងៃបោះឆ្នោតបានឡើយ។

៩.៦.២៨ ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានបោះឆ្នោតគ្រប់គ្នាហើយ ប្រធាន គ.ក.ប អាចប្រកាសបញ្ចប់ការបោះឆ្នោតនៅការិយាល័យរបស់ខ្លួននៅមុនម៉ោង ១៥:០០ (ដប់ប្រាំ)។

ជំពូកទី១០
ការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត
និងការប្រមូល ប្រគល់ ទទួលសម្ភារបោះឆ្នោត

ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត

ប្រការ១០.១.

នៅពេលដែលអ្នកបោះឆ្នោតចុងក្រោយបង្អស់បានបោះឆ្នោតរួច និងបានចេញផុតពីការិយាល័យបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី៣ ឱ្យចាត់វិធានការចាំបាច់ដើម្បីការពារច្រកចូលការិយាល័យបោះឆ្នោតកុំឱ្យអ្នកគ្មានភារកិច្ចចូលចេញ។ ប្រធាន គ.ក.ប ត្រូវប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់មកត្រូវចាត់ចែងការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត និងចំនួនសន្លឹកឆ្នោត និងការបំពេញកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

១០.១.១ បន្ទាប់ពីបានប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ប្រធាន គ.ក.ប ត្រូវចាត់ចែងតាមនីតិវិធីដើម្បីធានាសុវត្ថិភាពហិបឆ្នោត ដែលក្នុងនោះ៖

- ១០.១.១.១ ប្រធាន គ.ក.ប ត្រូវបិទភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនៃហិបឆ្នោត ព្រមទាំងបិទក្រដាសស្តើងមួយសន្លឹកដែលមានហត្ថលេខារបស់ប្រធាន គ.ក.ប និងភ្នាក់ងារគណបក្សនយោបាយពាសពីលើសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនោះផង។
- ១០.១.១.២ ប្រធាន គ.ក.ប ត្រូវបិទគម្របខាងក្រៅនៃហិបឆ្នោត និងចាក់សោឃ្លុំមានលេខនៅត្រង់ក្រវិលសម្រាប់ចាក់សោទាំងពីរនៃហិបឆ្នោត រួចអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតពិនិត្យមើលហិបឆ្នោត និងសោឃ្លុំមានលេខទាំងពីរនោះ។
- ១០.១.១.៣ លេខាធិការត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) នូវពេលវេលានៃការបិទការបោះឆ្នោតព្រមទាំងលក្ខណៈសម្គាល់ និងលេខនៃសោឃ្លុំទាំងពីរ។
- ១០.១.១.៤ ប្រធាន គ.ក.ប ត្រូវចាត់វិធានការការពារហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុងយ៉ាងហ្មត់ចត់ សម្រាប់ការរាប់សន្លឹកឆ្នោតនៅនឹងកន្លែងការិយាល័យបោះឆ្នោត ឬសម្រាប់ការបញ្ជូនទៅរាប់នៅកន្លែងផ្សេង ប្រសិនបើមានការសម្រេចឱ្យធ្វើដូច្នេះដោយ គ.ជ.ប។
- ១០.១.១.៥ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអាចថតយកសកម្មភាពនៅការិយាល័យបោះឆ្នោត ក្រោយពីការប្រកាសបិទការបោះឆ្នោតដោយសុំការអនុញ្ញាតពីប្រធាន គ.ក.ប។

១០.១.២ បន្ទាប់មកស្ថិតនៅចំពោះមុខវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតនានា ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិក គ.ក.ប ឱ្យធ្វើការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ សន្លឹកឆ្នោតមិនបានប្រើ និងសន្លឹកឆ្នោតខូច (ប្រសិនបើមាន) ដែលក្នុងនោះ៖

១០.១.២.១ លេខាធិការត្រូវរាប់ចំនួនគំនូសសញ្ញាធិកក្នុងកូនប្រអប់ផ្នែកខាងដើមនៅក្នុងបញ្ជីបោះឆ្នោតដូចមានចែងក្នុងចំណុច ៩.៦.១១.៣ នៃ ប.ន.ឃ.ស នេះ និងរាយការណ៍ជូនប្រធាន គ.ក.ប អំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត រួចកត់ត្រាចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតសរុបនៅទំព័រចុងក្រោយផ្នែកខាងក្រោមនៃបញ្ជីបោះឆ្នោត ព្រមទាំងបោះត្រា គ.ក.ប នៅគ្រប់ទំព័រនៃបញ្ជីបោះឆ្នោត និងដាក់ជូនប្រធាន គ.ក.ប ចុះហត្ថលេខានៅទំព័រចុងក្រោយ។

១០.១.២.២ អនុប្រធាន គ.ក.ប ត្រូវកត់សម្គាល់រវាងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ និងគល់បញ្ជីនៃសន្លឹកឆ្នោតដែលមិនទាន់បានប្រើ រួចរាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងសន្លឹកឆ្នោតខូចដោយឡែកពីគ្នា។ ប្រសិនបើចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែងដូចមានចែងក្នុងចំណុច ៩.៦.៧.៣ នៃ ប.ន.ឃ.ស នេះ ដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតដូចមានចែងក្នុងចំណុច ១០.១.២.១ ខាងលើនេះ លេខាធិការត្រូវកត់ត្រាតួលេខចំនួនទាំងនេះក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

១០.១.២.៣ ប្រសិនបើក្នុងការផ្ទៀងផ្ទាត់នេះបង្ហាញថានៅមានភាពខុសគ្នារវាងចំនួនសន្លឹកឆ្នោតដែលបានប្រើ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតលេខាធិការត្រូវផ្ទៀងផ្ទាត់ជាលើកទីពីរនូវចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតនៅលើបញ្ជីបោះឆ្នោត ហើយអនុប្រធាន គ.ក.ប ក៏ត្រូវផ្ទៀងផ្ទាត់ឡើងវិញផងដែរនូវចំនួនសន្លឹកឆ្នោតដែលបានប្រើ (រាប់ចំនួនសន្លឹកគល់បញ្ជីនៃសន្លឹកឆ្នោតដែលបានប្រើ) ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច។ ប្រសិនបើភាពខុសគ្នានៅតែមាន លេខាធិការត្រូវកត់ត្រានូវតួលេខនៃចំនួនដែលខុសគ្នានោះក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ហើយប្រធាន គ.ក.ប ត្រូវបន្តចាត់ចែងអនុវត្តតាមនីតិវិធីជាបន្ត។

១០.១.២.៤ សមាជិកទី២ ត្រូវចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើទាំងអស់ ជាមួយនឹងប្រដាប់ចោះ ឬកន្ត្រៃ ដើម្បីធ្វើមោឃភាពសន្លឹកឆ្នោត ដែលនៅសល់មិនបានប្រើ។

១០.១.២.៥ អនុប្រធាន គ.ក.ប ត្រូវដាក់សន្លឹកឆ្នោតមោឃភាព និងគល់បញ្ជី សន្លឹកឆ្នោតដែលបានប្រើទៅក្នុងស្បោងប្លាស្ទិកតែមួយរួចបិទឱ្យជិត។

១០.១.៣ ប្រធាន គ.ក.ប ត្រូវធានាថាលេខាធិការបានកត់ត្រាជាមុននូវលេខសោឃ្លុំដែលនឹងត្រូវប្រើចាក់ឃ្លុំមាត់ស្បោង "ខ" ដូចមានចែងក្នុងចំណុច ១០.៤.៧ នៃ ប.ន.ឃ.ស នេះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងបោះត្រាសម្ងាត់នៅជ្រុងខាងស្តាំប៉ែកខាងលើនៃកំណត់ហេតុនេះ។ កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ចំនួន ២ (ពីរ) ច្បាប់ ដែលលេខាធិការបានបំពេញរួច ត្រូវចុះហត្ថលេខាដោយលេខាធិការ និងប្រធាន គ.ក.ប ហើយបោះត្រា គ.ក.ប។

១០.១.៣.១ ប្រធាន គ.ក.ប ត្រូវដាក់បង្ហាញកំណត់ហេតុដូចមានចែងក្នុងចំណុច ១០.១.៣ ខាងលើនេះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ដើម្បីពិនិត្យ។

១០.១.៣.២ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុខាងលើនេះ។

១០.១.៣.៣ ការមិនព្រមចុះហត្ថលេខាលើកំណត់ហេតុខាងលើនេះពីភ្នាក់ងារគណបក្សនយោបាយណាម្នាក់មិនអាចចាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ។

១០.១.៤ ប្រធាន គ.ក.ប ត្រូវរៀបចំទុកដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដែលបានចុះហត្ថលេខារួចដូចមានចែងក្នុងចំណុច ១០.១.៣ ខាងលើនេះដូចខាងក្រោម៖

១០.១.៤.១ ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្នងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គ.ជ.ប"។

១០.១.៤.២ ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្នងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គឃ.សប"។

១០.១.៥ ប្រធាន គ.ក.ប ត្រូវរៀបចំបញ្ជីបោះឆ្នោតដែលលេខាធិការបានផ្ទៀងផ្ទាត់ និងកត់ត្រាចំនួនអ្នកដែលបានបោះឆ្នោតសរុបរួចហើយដូចមានចែងក្នុងចំណុច ១០.១.២.១ ខាងលើនេះ ចូលទៅក្នុងស្រោមសំបុត្រដែលមានកាខ្នងស្រាប់ថា "ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត" រួចបិទភ្ជិតដោយការ៉ ហើយបោះត្រា គ.ក.ប នៅត្រង់ផ្នែកមាត់ស្រោមសំបុត្រ និងបិទភ្ជិតបន្ថែមដោយស្កុត ព័ទ្ធជុំវិញនៅត្រង់ផ្នែកមាត់ស្រោមសំបុត្រដែលបានបោះត្រា គ.ក.ប រួច។ ប្រធាន គ.ក.ប ត្រូវរក្សាទុកស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតនេះឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ត្រៀមសម្រាប់រៀបចំដាក់ចូលក្នុងស្បោង "ខ"។

១០.១.៦ បន្ទាប់មកប្រធាន គ.ក.ប ត្រូវរៀបចំដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រដោយឡែកពីគ្នា រួចដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព "ក" ដែលមានបោះពុម្ពសម្គាល់ថា "ការិយាល័យបោះឆ្នោតលេខ..." នូវ៖

- ១០.១.៦.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដូចមានចែងក្នុងចំណុច ១០.១.៤.១ ខាងលើនេះ។
- ១០.១.៦.២ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតខូច (ប្រសិនបើមាន)។
- ១០.១.៦.៣ ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ។
- ១០.១.៦.៤ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់។
- ១០.១.៦.៥ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន)។
- ១០.១.៦.៦ ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (ប្រសិនបើមាន)។

១០.១.៧ ប្រធាន គ.ក.ប ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ថារាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ១០.១.៦ ខាងលើនេះត្រូវបានដាក់ក្នុងកញ្ចប់សុវត្ថិភាព "ក"។ ប្រធាន គ.ក.ប ត្រូវធានាថាកញ្ចប់សុវត្ថិភាព "ក" នៅពេលនេះមិនទាន់ត្រូវបិទភ្ជិតឡើយ ហើយត្រូវបិទភ្ជិតដោយការ៉សុវត្ថិភាពបម្រុងស្រាប់លុះណាតែ គ.ក.រ បានបញ្ចប់ការរាប់សន្លឹកឆ្នោត និងបានដាក់តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតទៅក្នុងកញ្ចប់សុវត្ថិភាព "ក" ពាក់ព័ន្ធរួចរាល់សិន។

១០.១.៨ ប្រធាន គ.ក.ប ត្រូវធានាថាកញ្ចប់សុវត្ថិភាព “ក” ដូចមានចែងក្នុងចំណុច ១០.១.៧ ខាងលើនេះ និងស្រោមសំបុត្រដូចមានចែងក្នុងចំណុច ១០.១.៤.១ ចំណុច ១០.១.៤.២ និងចំណុច ១០.១.៥ ខាងលើនេះ ត្រូវបានបំពេញលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធយ៉ាងត្រឹមត្រូវដោយប្រើបិកហ្វឺតលុបមិនជ្រះ ព្រមទាំងត្រូវរក្សាទុកឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាពក្នុងពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតកំពុងដំណើរការ។

១០.១.៩ ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិក គ.ក.ប ឱ្យរៀបចំទុកដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទៅក្នុងកេសស័ង្កសី និងវេចខ្ចប់ដបទឹកខ្មៅលុបមិនជ្រះដោយឡែក។ ទន្ទឹមនឹងនេះ ត្រូវរុះរើបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតទាំង ២ (ពីរ) រួចច្រកទៅក្នុងការុងនីឡុង ឬកេសក្រដាសដែលបានប្រើសម្រាប់ដាក់បន្ទប់សម្ងាត់ដូចនៅពេលប្រគល់ជូន គ.ក.ប នាពេលដំបូង។

ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត

ប្រការ១០.២.

អនុលោមតាម ច.ប.ឃ.ស ការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ បន្ទាប់ពីបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) រួច លើកលែងតែការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបានដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ហើយដែល គ.ជ.ប បានសម្រេចឱ្យ គឃ.សប ចាត់ចែងរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះនៅទីស្នាក់ការ គឃ.សប ឬនៅកន្លែងណាមួយដែលមានសុវត្ថិភាព។

១០.២.១ ក្នុងករណីដែលការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោត ការិយាល័យបោះឆ្នោតក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត ហើយ គ.ក.ប ក្លាយជា គ.ក.រ។ ក្នុងករណីនេះ ប្រធាន គ.ក.ប ដែលក្លាយជាប្រធាន គ.ក.រ ត្រូវចាត់វិធានការដោយអនុវត្តតាមប្រការ៩.៥ ចំណុច ៩.៥.១ និងចំណុច ៩.៥.៣ នៃ ប.ន.ឃ.ស នេះ ហើយទន្ទឹមនឹងនេះត្រូវចាត់ចែងឱ្យប្រមូលទុកដាក់សម្ភារ ឯកសារបោះឆ្នោតដែលបានប្រើនៅពេលបោះឆ្នោតឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព។ បន្ទាប់មកប្រធាន គ.ក.រ ត្រូវចាត់ចែងឱ្យរៀបចំឡើងវិញនូវគំរូប្លង់បន្ទប់សម្រាប់ការរាប់សន្លឹកឆ្នោត ដែលក្នុងនោះត្រូវ៖

១០.២.១.១ រៀបចំតុធំមួយឬតុតូចច្រើនផ្ទុំគ្នា និងកៅអី ៤ (បួន) សម្រាប់សមាជិក គ.ក.រ ដោយដាក់នៅចំកណ្តាលបន្ទប់ ដើម្បីអាចឱ្យភ្នាក់ងារតំណាងបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតនានាដើរចេះឡើងជុំវិញតុក្នុងការសង្កេតតាមដានកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត។

១០.២.១.២ លើកហិបឆ្នោតដាក់នៅចំកណ្តាលតុ ព្រមទាំងយកកញ្ចប់សុវត្ថិភាព "ក" ដូចមានចែងក្នុងចំណុច ១០.១.៦ ខាងលើនេះ និងរាល់សម្ភារ ឯកសាររបោះឆ្នោត និងទម្រង់បែបបទចាំបាច់ត្រៀមសម្រាប់ប្រើក្នុង កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតដាក់នៅលើតុត្រង់កន្លែងប្រធាន គ.ក.រ អង្គុយ។

១០.២.១.៣ ចាត់សមាជិកទី២ និងសមាជិកទី៣ ឱ្យសហការគ្នាការពារមាត់ទ្វារ និងបង្អួចដែលបើកចំហ កុំឱ្យមានអ្នកចូលចេញ មើលថែរក្សាសុវត្ថិភាព សម្ភារ ឯកសាររបោះឆ្នោតដែលមិនត្រូវប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត និងមើលថែរក្សាសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត។

១០.២.២ កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅតែមួយកន្លែងសម្រាប់ការិយាល័យរាប់សន្លឹកឆ្នោតមួយ ប្រសិនបើចាប់ផ្តើមហើយត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយពុំត្រូវឈប់សម្រាកឡើយ។ ប្រធាន គ.ក.រ ត្រូវចាត់ចែងត្រៀមឱ្យមានភ្លើងបំភ្លឺនៅការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីបង្ការក្នុងករណីការរាប់សន្លឹកឆ្នោតត្រូវអូសបន្លាយដល់ពេលយប់។

១០.២.២.១ ក្នុងដំណើរការនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មមដែលអាចសង្កេតមើលឃើញសកម្មភាពទាំងឡាយនៃការរាប់សន្លឹកឆ្នោត។

១០.២.២.២ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលដំណើរការនៃការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ និងត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) នៅមុនពេលចាប់ផ្តើមរាប់សន្លឹកឆ្នោត។

១០.២.២.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអាចផ្លាស់ប្តូរភ្នាក់ងារបម្រុងរបស់ខ្លួន (ប្រសិនបើមាន) ឱ្យបំពេញការកិច្ចជំនួស និងត្រូវចូលរួមឱ្យបានចប់ចុងចប់ដើម។

១០.២.២.៤ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអាចថតយករូបភាពនៅការិយាល័យរាប់សន្លឹកឆ្នោតបាន ប៉ុន្តែមិនត្រូវរំខាន ជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ។

១០.២.៣ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ប្រធាន គ.ក.រ ត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខគាត់ ហើយឱ្យអនុប្រធាន គ.ក.រ និងសមាជិកទី១ អង្គុយនៅអមសងខាងតុទល់មុខគ្នា។ ស្ថិតនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមានក្នុងការិយាល័យរាប់សន្លឹកឆ្នោត ប្រធាន គ.ក.រ ត្រូវប្រកាសចាប់ផ្តើមកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ហើយត្រូវ៖

១០.២.៣.១ បម្រុងទុកនៅក្បែរខ្លួនគាត់នូវ៖

- កញ្ចប់សុវត្ថិភាព "ក" ដែលមានស្បោងប្លាស្ទិក និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត
- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត
- ស្បោងប្លាស្ទិកថ្លាសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ
- ពាក្យបណ្តឹង (ទ.១២០២) សម្រាប់ផ្តល់ជូនភ្នាក់ងារគណបក្សនយោបាយបំពេញពាក្យបណ្តឹង ប្រសិនបើគាត់ស្នើសុំ
- កៅស៊ូកង។

១០.២.៣.២ ប្រគល់ជូនអនុប្រធាន គ.ក.រ នូវតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួន ១ (មួយ) ច្បាប់។

១០.២.៣.៣ ប្រគល់ជូនលេខាធិការនូវកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ចំនួន ៣ (បី) ច្បាប់ និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួន ១ (មួយ) ច្បាប់ និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលត្រូវដកយកពីកញ្ចប់សុវត្ថិភាព "ក"។

១០.២.៣.៤ ប្រគល់ជូនសមាជិកទី១ នូវបិកហ្វឺតធំចំនួន ១ (មួយ) ដើម និងផ្ទាំងក្រដាសធំសម្រាប់កត់ត្រាសំឡេងឆ្នោតចំនួន ១ (មួយ) ផ្ទាំង ឬតាមចំនួនដែលផ្តល់ជូនដោយ គ.ជ.ប។

១០.២.៣.៥ ចាត់លេខាធិការឱ្យចាប់ផ្តើមបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយចម្លងនូវតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង សន្លឹកឆ្នោតខូចពេលបោះឆ្នោត សន្លឹកឆ្នោតដែល

មិនបានប្រើ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដែលតួលេខទាំងនេះត្រូវបានពិនិត្យ ផ្ទៀងផ្ទាត់រួចហើយដូចមានចែងក្នុងចំណុច ១០.១.២ ខាងលើនេះ និងដែលមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ព្រមទាំងចាត់ឱ្យអនុប្រធាន គ.ក.រ ចម្លងតួលេខចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតចូលទៅក្នុងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងសមាជិកទី១ ធ្វើកិច្ចការដូចគ្នានេះនៅលើផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត។

១០.២.៤ ស្ថិតនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតទាំងអស់ ប្រធាន គ.ក.រ ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឱ្យច្បាស់ថាសោឃ្លុំមានលេខទាំងពីរដែលចាក់ជាប់នឹងគម្របខាងក្រៅនៃហិបឆ្នោតស្ថិតក្នុងស្ថានភាពដើម រួចកាត់ផ្តាច់សោឃ្លុំទាំងនេះដោយកន្ត្រៃ ឬកូនកាំបិតដែលអាចរកបានដោយខ្លួនឯង និងបើកគម្របខាងក្រៅចេញ។ បន្ទាប់មកប្រធាន គ.ក.រ ត្រូវបន្តត្រួតពិនិត្យ ផ្ទៀងផ្ទាត់លេខសោឃ្លុំដែលចាក់ជាប់នឹងគន្លឹះខ្ចាស់បិទគម្របខាងក្នុងនៃហិបឆ្នោត និងក្រដាសស្តើងដែលបិទពាសពីលើសន្ទះបិទភ្ជិតប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ដើម្បីបញ្ជាក់ថាគ្មានការរុះរើរួចកាត់ផ្តាច់សោឃ្លុំ និងហែកក្រដាសនេះចោល។ ចុងក្រោយប្រធាន គ.ក.រ ត្រូវបើកគម្របខាងក្នុងនៃហិបឆ្នោត និងចាក់សន្លឹកឆ្នោតឱ្យអស់ពីហិបឆ្នោតដាក់នៅលើតុត្រង់ចន្លោះអនុប្រធាន គ.ក.រ និងសមាជិកទី១ ហើយដាក់ហិបឆ្នោតទទេនៅក្បែរគាត់។

- ១០.២.៤.១ សមាជិកទី១ ត្រូវរើសយកវត្ថុមិនមែនជាសន្លឹកឆ្នោតដែលមិនស្ថិតនៅជាប់ជាមួយសន្លឹកឆ្នោត (ប្រសិនបើមាន) ចេញពីគំនរសន្លឹកឆ្នោត រួចដាក់ទៅក្នុងស្រោមសំបុត្រមួយបម្រុងស្រាប់។
- ១០.២.៤.២ លេខាធិការត្រូវកត់ត្រាអំពីករណីដូចមានចែងក្នុងចំណុច ១០.២.៤.១ ខាងលើនេះ (ប្រសិនបើមាន) ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

១០.២.៥ ប្រធាន គ.ក.រ ត្រូវបង្គាប់ឱ្យអនុប្រធាន គ.ក.រ និងសមាជិកទី១ លា និងតម្រៀបសន្លឹកឆ្នោតដែលទើបបានចាក់ចេញពីហិបឆ្នោត ដោយដាក់ផ្តាប់ចុះក្រោម និងដាក់សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នងក្នុង ១ (មួយ) បាច់មាន ២៥ (ម្ភៃប្រាំ) សន្លឹកនៅពំនូកទី១ ហើយដាក់សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង (ប្រសិនបើមាន) នៅពំនូកទី២។ បន្ទាប់មកអនុប្រធាន គ.ក.រ និងសមាជិកទី១ ត្រូវរាប់សន្លឹកឆ្នោតទាំង ២ (ពីរ) ពំនូក រួចរាយការណ៍ជូនប្រធាន គ.ក.រ អំពីចំនួនសន្លឹកឆ្នោតសរុបដែល

បានរាប់ឃើញ។ ប្រធាន គ.ក.រ ត្រូវធានាថានីតិវិធីមួយចំនួនដូចខាងក្រោម ត្រូវតែបានអនុវត្ត៖

១០.២.៥.១ ក្នុងករណីចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើមានចំនួនសរុបស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬស្មើនឹងចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួននេះក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

១០.២.៥.២ ប្រសិនបើចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើមានចំនួនតិចជាង ឬច្រើនជាងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬម៉្យាងបើមានចំនួនតិចជាង ឬច្រើនជាងផលសងរវាងចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតមិនបានប្រើនោះ ប្រធាន គ.ក.រ ត្រូវរាប់សន្លឹកឆ្នោតដូចមានចែងក្នុងចំណុច ១០.២.៥ ខាងលើនេះឡើងវិញជាលើកទីពីរ។

១០.២.៥.៣ ប្រសិនបើបន្ទាប់ពីប្រធាន គ.ក.រ បានរាប់ឡើងវិញហើយ តួលេខនៃចំនួនសន្លឹកឆ្នោតនៅតែមានភាពខុសគ្នាដដែលដូចមានចែងក្នុងចំណុច ១០.២.៥.២ ខាងលើនេះ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នានោះក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

១០.២.៥.៤ ប្រធាន គ.ក.រ ត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអំពីលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតដូចមានចែងក្នុងចំណុច ១០.២.៥.១ ឬចំណុច ១០.២.៥.២ ឬ/និង ចំណុច ១០.២.៥.៣ ខាងលើនេះ ដើម្បីឱ្យអ្នកទាំងនោះអាចពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនោះបាន។

១០.២.៥.៥ អនុប្រធាន គ.ក.រ ត្រូវហុចសន្លឹកឆ្នោតពំនូកទី២ ដែលគ្មានបោះត្រាសម្ងាត់ផ្លូវការនៅខាងខ្នង (ប្រសិនបើមាន) ជូនប្រធាន គ.ក.រ ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងស្តាំដៃគាត់។

១០.២.៥.៦ អនុប្រធាន គ.ក.រ ត្រូវហុចសន្លឹកឆ្នោតពំនូកទី១ ដែលខ្ចាស់ជាបាច់ក្នុងមួយបាច់ ២៥ (ម្ភៃប្រាំ) សន្លឹក ជូនប្រធាន គ.ក.រ ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងឆ្វេងដៃគាត់។

១០.២.៦ បន្ទាប់ពីការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតបានបញ្ចប់ ប្រធាន គ.ក.រ ត្រូវចាប់ផ្តើមរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ដែលជាដំបូងត្រូវពិនិត្យ ផ្ទៀងផ្ទាត់សុពលភាពនៃសន្លឹកឆ្នោត រួចកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ ហើយបន្ទាប់មកត្រូវប្រកាសសន្លឹកឆ្នោតដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ។ ប្រធាន គ.ក.រ ត្រូវធានាថាកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតត្រូវបានអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម៖

១០.២.៦.១ ដោយផ្អែកតាមការកំណត់ដូចមានចែងក្នុងប្រការ១០.៣ ខាងក្រោមនេះ ប្រធាន គ.ក.រ ត្រូវយកសន្លឹកឆ្នោតម្តង ១ (មួយ) សន្លឹកពីពំនូកទី១ មកពិនិត្យ ផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ ព្រមទាំងត្រូវលើកបង្ហាញសន្លឹកឆ្នោតដែលបានកំណត់ហើយនោះ ដើម្បីឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអាចមើលឃើញច្បាស់។

១០.២.៦.២ ប្រសិនបើប្រធាន គ.ក.រ កំណត់សន្លឹកឆ្នោតនោះជាសន្លឹកឆ្នោតមិនបានការ គាត់ត្រូវប្រកាសថា “សន្លឹកឆ្នោតមិនបានការ” រួចដាក់សន្លឹកឆ្នោតនោះនៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការដែលស្ថិតនៅខាងស្តាំដៃគាត់។

១០.២.៦.៣ ប្រសិនបើប្រធាន គ.ក.រ កំណត់សន្លឹកឆ្នោតនោះជាសន្លឹកឆ្នោតបានការ គាត់ត្រូវប្រកាសឱ្យឮៗនូវឈ្មោះគណបក្សនយោបាយដែលសន្លឹកឆ្នោតនោះត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ ហើយត្រូវដាក់សន្លឹកឆ្នោតនោះទៅតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយពាក់ព័ន្ធនីមួយៗ។

១០.២.៦.៤ ផ្អែកតាមការប្រកាសរបស់ប្រធាន គ.ក.រ អនុប្រធាន គ.ក.រ និងលេខាធិការត្រូវគូសពិន្ទុ ១ (មួយ) សម្រាប់សន្លឹកឆ្នោត ១ (មួយ) សន្លឹក ដែលគណបក្សនយោបាយណាមួយត្រូវបានទទួលតាមការណែនាំរបស់ គ.ជ.ប នៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨)។ ទន្ទឹមនឹងនេះ សមាជិកទី១ ត្រូវប្រើបិកហ្វឺតគូសពិន្ទុ ១ (មួយ) នៅលើផ្នាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតដែលបិទភ្ជាប់នឹងជញ្ជាំង ឬលើក្តារខៀន។

១០.២.៦.៥ ក្នុងករណីមានការជំទាស់ចំពោះសន្លឹកឆ្នោតដែលបានផ្ទៀងផ្ទាត់រាប់តាមចំណុច ១០.២.៦.៣ ខាងលើនេះ ប្រធាន គ.ក.រ ត្រូវដាក់សន្លឹកឆ្នោតដែលមានការជំទាស់នោះទៅក្នុងពំនូកសន្លឹកឆ្នោត

មិនបានការដូចមានចែងក្នុងចំណុច ១០.២.៦.២ ខាងលើនេះ។ សន្លឹកឆ្នោតទាំងនោះនឹងត្រូវពិនិត្យ ផ្ទៀងផ្ទាត់សុពលភាព និងកំណត់ម្តងទៀតជាចុងក្រោយដោយអនុវត្តតាមចំណុច ១០.២.៦.៦ ខាងក្រោមនេះ។

១០.២.៦.៦ នៅពេលផ្ទៀងផ្ទាត់សុពលភាព និងរាប់អស់សន្លឹកឆ្នោតពីពំនូកទី១ ប្រធាន គ.ក.រ ត្រូវបន្តយកសន្លឹកឆ្នោតម្តង ១ (មួយ) សន្លឹកៗពីពំនូកសន្លឹកឆ្នោតមិនបានការមកពិនិត្យ ផ្ទៀងផ្ទាត់សុពលភាព និងកំណត់ម្តងទៀតជាចុងក្រោយ ដើម្បីឱ្យប្រាកដថាជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ។

១០.២.៦.៧ ប្រសិនបើប្រធាន គ.ក.រ សម្រេចថាជាសន្លឹកឆ្នោតបានការវិញត្រូវអនុវត្តចំណុច ១០.២.៦.៣ និងចំណុច ១០.២.៦.៤ ខាងលើនេះ។

១០.២.៦.៨ ប្រសិនបើប្រធាន គ.ក.រ សម្រេចថាជាសន្លឹកឆ្នោតមិនបានការ ប្រធាន គ.ក.រ ត្រូវដាក់សន្លឹកឆ្នោតនោះទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការដដែល។

១០.២.៧ ក្នុងអំឡុងពេលនៃការពិនិត្យ ផ្ទៀងផ្ទាត់សុពលភាព និងកំណត់សន្លឹកឆ្នោតដូចមានចែងក្នុងចំណុច ១០.២.៦.១ និងចំណុច ១០.២.៦.៦ ខាងលើនេះ ប្រសិនបើប្រធាន គ.ក.រ កត់សម្គាល់ឃើញថាសន្លឹកឆ្នោតណាមួយជាសន្លឹកឆ្នោតមិនច្បាស់លាស់ ដោយយោងទៅតាមបញ្ញត្តិនៃប្រការ១០.៣ ខាងក្រោមនេះ ប្រធាន គ.ក.រ ត្រូវពិភាក្សាជាមួយសមាជិកទាំងអស់នៃ គ.ក.រ អំពីសុពលភាព និងការកំណត់ប្រភេទនៃសន្លឹកឆ្នោតនោះម្តងទៀត ដើម្បីកំណត់ចុងក្រោយថាពិតជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ។

១០.២.៧.១ ទោះបីប្រធាន គ.ក.រ កំណត់ថាជាសន្លឹកឆ្នោតបានការក្តី ឬជាសន្លឹកឆ្នោតមិនបានការក្តី ប្រធាន គ.ក.រ ត្រូវប្រកាសឱ្យឮៗអំពីហេតុផលសម្រាប់សន្លឹកឆ្នោតនោះ និងត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតធ្វើការត្រួតពិនិត្យសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការនោះ និងឱ្យចោទជាសំណួរចំពោះហេតុផលនៃការកំណត់របស់ប្រធាន គ.ក.រ ចំពោះសន្លឹកឆ្នោតនោះ។ ក្នុងករណីនេះ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតមិនត្រូវបានអនុញ្ញាតឱ្យកាន់សន្លឹកឆ្នោតនោះឡើយ។

១០.២.៧.២ ក្នុងករណីប្រធាន គ.ក.រ កំណត់ថាជាសន្លឹកឆ្នោតបានការ ត្រូវអនុវត្តតាមចំណុច ១០.២.៦.៣ និងចំណុច ១០.២.៦.៤ ខាងលើនេះ។

១០.២.៧.៣ ក្នុងករណីប្រធាន គ.ក.រ កំណត់ថាជាសន្លឹកឆ្នោតមិនបានការ ប្រធាន គ.ក.រ ត្រូវដាក់សន្លឹកឆ្នោតនោះនៅពំនូកសន្លឹកឆ្នោតមិនបានការ។

១០.២.៧.៤ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយណាម្នាក់មិនឯកភាពចំពោះការសម្រេចរបស់ប្រធាន គ.ក.រ ក្នុងការកំណត់សន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការខាងលើ ភ្នាក់ងារនោះមានសិទ្ធិលើកការជំទាស់ និងស្នើសុំឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនៃការជំទាស់នោះក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។ ខ្លឹមសារ និងហេតុផលនៃការជំទាស់នោះមិនត្រូវបានកត់ត្រាឡើយ ក្នុងករណីភ្នាក់ងារនោះមិនយល់ព្រមចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

១០.២.៧.៥ ការសម្រេចរបស់ប្រធាន គ.ក.រ ត្រូវតែមានប្រសិទ្ធភាពក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធាន គ.ក.រ ត្រូវប្រកាសបន្តដំណើរការរាប់សន្លឹកឆ្នោតតទៅទៀត។

១០.២.៧.៦ ការកំណត់ដូចមានចែងក្នុងចំណុច ១០.២.៧.៥ ខាងលើនេះ មិនបានច្រានចោលជាមុននូវដំណើរហេតុដែលភ្នាក់ងារគណបក្សនយោបាយណាម្នាក់ចង់បន្តប្តឹងជំទាស់ទៅ គយ.សប អំពីករណីដែលគាត់បានលើកជំទាស់ដូចមានចែងក្នុងចំណុច ១០.២.៧.៤ ខាងលើនោះទេ ប៉ុន្តែគាត់ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គ.ក.រ និងមិនត្រូវជ្រៀតជ្រែកកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតឡើយ។

១០.២.៧.៧ ប្រធាន គ.ក.រ ត្រូវផ្តល់ពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ជូនភ្នាក់ងារគណបក្សនយោបាយ ប្រសិនបើគាត់ស្នើសុំសម្រាប់បំពេញពាក្យបណ្តឹងទៅ គយ.សប។

១០.២.៨ ដើម្បីរក្សាការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យរាប់សន្លឹកឆ្នោតក្នុងពេលកំពុងរាប់សន្លឹកឆ្នោត ហាមជនគ្រប់រូបព្យាយាមធ្វើសកម្មភាពដោយទុច្ចរិត ក្នុងគោលបំណងកត់សម្គាល់ដើម្បីឱ្យដឹងថាតើអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់បានបោះឆ្នោតឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ។

១០.២.៨.១ ជនណាក៏ដោយដែលបានធ្វើសកម្មភាពដូចមានចែងក្នុងចំណុច ១០.២.៨ ខាងលើនេះ នឹងត្រូវទទួលការព្រមានពីប្រធាន គ.ក.រ។ ការធ្វើសកម្មភាពដដែលឡើងវិញជាលើកទីពីរនឹងត្រូវចាត់ទុកថាជាការរំលោភលើគោលការណ៍សម្ងាត់នៃការបោះឆ្នោត ហើយជនដែលមានការពាក់ព័ន្ធត្រូវតែបានបណ្តេញចេញពីការិយាល័យរាប់សន្លឹកឆ្នោត និងត្រូវទទួលទោសតាម ច.ប.ឃ.ស និង ច.វ.ច.ប។

១០.២.៨.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត និងរាយការណ៍ជូន គឃ.សប។

១០.២.៨.៣ ពេលទទួលបានកំណត់ហេតុដូចមានចែងក្នុងចំណុច ១០.២.៨.២ ខាងលើនេះភ្លាម គឃ.សប ត្រូវធ្វើការស៊ើបអង្កេតអំពើរំលោភនេះជាបន្ទាន់ ហើយប្រសិនបើមានភស្តុតាងបញ្ជាក់ថាពិតប្រាកដមែន ប្រធាន គឃ.សប ត្រូវប្តឹងទៅ គធ.ខប ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់។

១០.២.៩ នៅពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់រួចហើយ ប្រធាន គ.ក.រ ត្រូវចាត់អនុប្រធាន គ.ក.រ និងលេខាធិការឱ្យបូកសរុប និងកត់ត្រាចំនួនសន្លឹកឆ្នោតមិនបានការសរុប ចំនួនសន្លឹកឆ្នោតបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់នៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ព្រមទាំងបង្គាប់សមាជិកទី១ ឱ្យធ្វើកិច្ចការដូចគ្នានេះនៅលើផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត។ ទន្ទឹមនេះដោយមានការពិនិត្យសង្កេតមើលរបស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតនានា ប្រធាន គ.ក.រ ត្រូវរាប់ចំនួនសន្លឹកឆ្នោតបានការតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយនីមួយៗ និងតាមពំនូកសន្លឹកឆ្នោតមិនបានការ ហើយត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញជាមួយនឹងតួលេខចំនួនសន្លឹកឆ្នោតដែលអនុប្រធាន គ.ក.រ លេខាធិការ និងសមាជិកទី១ បានបូកសរុបឃើញខាងលើ។ ប្រធាន គ.ក.រ ត្រូវធានាថាតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ទាំង ២ (ពីរ) ច្បាប់ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងខ្លួនគាត់ផ្ទាល់។ ភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមានអាចចូលរួមចុះហត្ថលេខាលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតបាន។ ការមិនចុះហត្ថលេខារបស់ភ្នាក់ងារគណបក្សនយោបាយមិនអាចចាត់ទុកតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងផ្ទាំងក្រដាសធំទាំងនេះជាមោឃៈបានទេ។

១០.២.១០ ប្រធាន គ.ក.រ ត្រូវប្រកាសជាចំហនូវលទ្ធផលនៃការបូកសរុប និងការរាប់ចំនួនសន្លឹកឆ្នោតដែលបានអនុវត្តតាមចំណុច ១០.២.៩ ខាងលើនេះ និងត្រូវធ្វើការផ្ទៀងផ្ទាត់ ដោយធ្វើប្រមាណវិធីបូកបញ្ចូលគ្នានូវចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់ និងចំនួនសន្លឹកឆ្នោតមិនបានការទាំងអស់។

១០.២.១០.១ ប្រសិនបើផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះស្មើគ្នាទៅនឹងចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចមានចែងក្នុងចំណុច ១០.២.៥ ខាងលើនេះ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ សន្លឹកឆ្នោតបានការសរុប និងចំនួនសន្លឹកឆ្នោតមិនបានការសរុបពីតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ទៅក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

១០.២.១០.២ ប្រសិនបើផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះមានចំនួនតិចជាងឬច្រើនជាងចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចមានចែងក្នុងចំណុច ១០.២.៥ ខាងលើនេះ ប្រធាន គ.ក.រ ត្រូវរាប់សន្លឹកឆ្នោតតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការឡើងវិញម្តងទៀត។

១០.២.១០.៣ ប្រសិនបើបន្ទាប់ពីប្រធាន គ.ក.រ បានរាប់ឡើងវិញ និងធ្វើប្រមាណវិធីបូក ឃើញផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះនៅតែមានភាពខុសគ្នាដដែល ម៉្យាងប្រសិនបើគ្មានព្រឹត្តិការណ៍ណាមួយខាងដល់ការរាប់សន្លឹកឆ្នោតទេ ឬ/និងគ្មានសន្លឹកឆ្នោតណាមួយ ឬច្រើនត្រូវបានគេរកឃើញនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ដោយសារការធ្លាក់ជ្រុះទេនោះត្រូវសន្មតថាភាពខុសគ្នានេះបានកើតឡើងមុនជាយថាហេតុ។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នាទាំងនោះក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

១០.២.១១ ប្រធាន គ.ក.រ ត្រូវជានាថាសន្លឹកឆ្នោតបានការដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ត្រូវបានចងនឹងកៅស៊ូកងឱ្យជាប់ និងដាក់ដោយឡែកពីគ្នា។

១០.២.១២ ប្រធាន គ.ក.រ ត្រូវជានាថាសន្លឹកឆ្នោតមិនបានការទាំងអស់ត្រូវបានចងនឹងកៅស៊ូកង និងដាក់បញ្ចូលទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានការខ្ជង់ថា "សន្លឹកឆ្នោតមិនបានការ"។

១០.២.១៣ ប្រធាន គ.ក.រ ត្រូវជានាថាសន្លឹកឆ្នោតបានការដែលបានចងនឹងកៅស៊ូកងដូចមានចែងក្នុងចំណុច ១០.២.១១ ខាងលើនេះ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការដូចមានចែងក្នុងចំណុច ១០.២.១២ ខាងលើនេះ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតដូចមានចែងក្នុងចំណុច ១០.២.៩ ខាងលើនេះ និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ដូចមានចែងក្នុងចំណុច ១០.២.៤.១ ខាងលើនេះ ត្រូវបានដាក់រួមគ្នាក្នុងស្បោងប្លាស្ទិកតែមួយដែលមានបោះពុម្ពសម្គាល់ពីខាងក្រៅថា "សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការនៃការិយាល័យបោះឆ្នោតលេខ..." បន្ទាប់មកត្រូវបិទភ្ជិតមាត់ស្បោងប្លាស្ទិកនេះ និងត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធដោយប្រើប៊ិកហ្វឺតធំលុបមិនជ្រះនៅលើផ្នែកខាងក្រៅនៃស្បោងប្លាស្ទិក ដើម្បីត្រៀមបញ្ជូននិងប្រគល់ជូន គយ.សប។

១០.២.១៤ បន្ទាប់ពីបានអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ១០.២.៣ រហូតដល់ចំណុច ១០.២.១៣ ខាងលើនេះ ប្រធាន គ.ក.រ ត្រូវចាត់លេខាធិការឱ្យបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) គ្រប់ចំនួន ៣ (បី) ច្បាប់ និងត្រូវចុះហត្ថលេខាដោយលេខាធិការ និងប្រធាន គ.ក.រ។ ភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមានអាចចូលរួមចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) បាន។ ការមិនចុះហត្ថលេខារបស់ភ្នាក់ងារគណបក្សនយោបាយមិនអាចចាត់ទុកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ទាំងនេះជាមោឃៈបានទេ។

១០.២.១៥ បន្ទាប់ពីធ្វើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) រួចហើយ ប្រធាន គ.ក.រ ត្រូវ៖

- ១០.២.១៥.១ ចាត់សមាជិកទី២ ឱ្យបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ ជាសាធារណៈនៅត្រង់ច្រកចូលទីតាំងការិយាល័យរាប់សន្លឹកឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត និងជម្រាបជូនភ្នាក់ងារគណបក្សនយោបាយថាគាត់អាចថតរូបភាព ឬចម្លងតួលេខពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលបិទផ្សាយនេះបាន និងសូមឱ្យគាត់ទៅយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅទីស្នាក់ការ គយ.សប។
- ១០.២.១៥.២ ចាត់លេខាធិការឱ្យដាក់តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ១ (មួយ) ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ ចូលក្នុងស្រោមសំបុត្របោះពុម្ពដែលមានការខ្ជង់ថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត

(ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គយ.សប" និងដាក់បញ្ចីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ចូលទៅក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្នងថា "បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត(ទ.១១១៥)" រួចចាត់សមាជិកទី២ ឱ្យនាំយកស្រោមសំបុត្រទាំងពីរនេះទៅប្រគល់ជូន គយ.សប ដើម្បីបូកសរុប និងបញ្ជូនទៅ គ.ជ.ប ប្រកាសផ្សព្វផ្សាយជាលទ្ធផលបឋមនៃការបោះឆ្នោត រួមនឹងការពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់។

១០.២.១៥.៣ ប្រកាសអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមានអាចចូលរួមអមដំណើរសមាជិកទី២ ក្នុងការបញ្ជូនស្រោមសំបុត្រដូចមានចែងក្នុងចំណុច ១០.២.១៥.២ ខាងលើនេះ និងត្រូវស្នើសុំភ្នាក់ងារសន្តិសុខបោះឆ្នោត ១ (មួយ) រូប ដើម្បីការពារសន្តិសុខ និងសុវត្ថិភាពក្នុងកិច្ចដំណើរការបញ្ជូនស្រោមសំបុត្រទាំងនេះ។

១០.២.១៦ ក្នុងអំឡុងពេលនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេសត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀង ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុង ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ឃ.ស នេះ។

សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ

ប្រការ១០.៣.

ដើម្បីអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គ.ក.រ ជាពិសេសប្រធាន គ.ក.រ និងអនុប្រធាន គ.ក.រ ត្រូវយល់ដឹងយ៉ាងច្បាស់លាស់អំពីលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ។

១០.៣.១ សន្លឹកឆ្នោតបានការ គឺជាសន្លឹកឆ្នោតផ្លូវការដែលបានផ្តល់ជូនដោយ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសរើស កបយ.ស នីមួយៗ និងមានបោះត្រាសម្គាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនៅផ្នែកខាងខ្នង ហើយដែលនៅលើសន្លឹកឆ្នោតនោះអ្នកបោះឆ្នោតបានបញ្ជាក់យ៉ាងច្បាស់ពីឆន្ទៈរបស់ខ្លួន ដោយមានគូសសញ្ញាគាំទ្រក្នុងប្រអប់បន្ទះជ្រើងទ្រវែងនៃគណបក្សនយោបាយណាមួយដែលគាត់ពេញចិត្ត។

១០.៣.២ សន្លឹកឆ្នោតមិនបានការ គឺជាសន្លឹកឆ្នោតដែលត្រូវបានចាត់ទុកជាមោឃៈដែលក្នុងនោះរួមមានសន្លឹកឆ្នោតដែលមិនមែនជាសន្លឹកឆ្នោតផ្លូវការ ឬ/និងសន្លឹកឆ្នោតដែលគ្មានគំនូស ឬមានគំនូស ប៉ុន្តែ គ.ក.រ ពុំអាចសន្និដ្ឋានបានថាបោះគាំទ្រឱ្យគណបក្សនយោបាយណាមួយ ឬ/និងសន្លឹកឆ្នោតដែលមានសញ្ញានាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត ឬ/និងសន្លឹកឆ្នោតដែលមានរហែក ឬប្រឡាក់ខូច ឬ/និងសន្លឹកឆ្នោតដែលគ្មានបោះត្រាសម្ងាត់ជាផ្លូវការ។ សន្លឹកឆ្នោតមិនបានការ រួមមាន ៥ (ប្រាំ) ប្រភេទដូចខាងក្រោមត្រូវបានចាត់ទុកជាមោឃៈ។

១០.៣.២.១ សន្លឹកឆ្នោតមិនផ្លូវការត្រូវបានកំណត់ដូចខាងក្រោម៖

- សន្លឹកឆ្នោតមានខ្នាតតូចជាង ឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប
- សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ជាង ឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប
- សន្លឹកឆ្នោតមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប
- សន្លឹកឆ្នោតដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើនដែលបានឈរឈ្មោះបោះឆ្នោតជ្រើសរើស កបយ.ស ៣ក់ព័ន្ធ
- សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយលើសពីចំនួនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើស កបយ.ស ៣ក់ព័ន្ធ
- សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើស កបយ.ស ៣ក់ព័ន្ធ
- សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ និងដែលមិនបានផ្តល់ឱ្យដោយ គ.ក.ប ៣ក់ព័ន្ធ។

១០.៣.២.២ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូសដែលពុំអាចសន្និដ្ឋានបានថាបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ ត្រូវបានកំណត់ដូចខាងក្រោម៖

- សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ)
- សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់ប្លង់ជ្រុងទ្រវែងនៃគណបក្សនយោបាយលើសពីមួយគណបក្ស

- សន្លឹកឆ្នោតមានគំនូសក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយ ដោយគូសហួសចូលទៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយមួយទៀត
- សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើននៅក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ទោះបីជាសន្លឹកឆ្នោតនោះមាន ឬគ្មានគំនូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយក៏ដោយ។

១០.៣.២.៣ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត ត្រូវបានកំណត់ដូចខាងក្រោម៖

- សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត
- សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះបីនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត
- សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗ ភ្ជាប់នឹងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត
- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ចាស់ជាប់ជាមួយ
- សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត។

១០.៣.២.៤ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូច ត្រូវបានកំណត់ដូចខាងក្រោម៖

- សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ
- សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង
- សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្នែកខាងមុខ ឬ/និងនៅផ្នែកខាងខ្នង ដែលមិនអាចមើលយល់នូវរូបសញ្ញា និងអក្សរដែលត្រូវបានបោះពុម្ពនៅលើសន្លឹកឆ្នោត ឬ/និងគំនូសសញ្ញាដែលគូសគាំទ្រគណបក្សនយោបាយណាមួយ។

១០.៣.២.៥ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

- សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ
- សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

ការរៀបចំ និងការខេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ដាក់កំណត់ហេតុនៃការបោះឆ្នោត តារាងកត់ត្រាសំឡេងឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ

ប្រការ១០.៤.

នៅពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតដូចមានចែងក្នុងប្រការ១០.២ ខាងលើនេះ ត្រូវបានបំពេញរួចរាល់ ប្រធាន គ.ក.រ ត្រូវធានាថាតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួន ២ (ពីរ) ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ចំនួន ៣ (បី) ច្បាប់ ដែលលេខាធិការបានបំពេញត្រឹមត្រូវហើយដូចមានចែងក្នុងចំណុច ១០.២.១៤ ខាងលើនេះ ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងខ្លួនគាត់ផ្ទាល់ ព្រមទាំងបោះត្រា គ.ក.ប។ ប្រធាន គ.ក.រ ត្រូវចាត់ចែងវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅការិយាល័យបោះឆ្នោតរបស់ខ្លួន ព្រមទាំងរាល់សម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ដើម្បីបញ្ជូនទៅ គយ.សប។

១០.៤.១ ប្រធាន គ.ក.រ ត្រូវដាក់បង្ហាញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដូចមានចែងក្នុងប្រការ១០.៤ ខាងលើនេះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ដើម្បីពិនិត្យ ព្រមទាំងអញ្ជើញភ្នាក់ងារគណបក្សនយោបាយឱ្យចូលរួមចុះហត្ថលេខាជាសាក្សី។

១០.៤.១.១ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ខាងលើ។



១០.៤.១.២ ការមិនព្រមចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពីភ្នាក់ងារគណបក្សនយោបាយ មិនអាចបាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ។

១០.៤.២ ប្រធាន គ.ក.រ ត្រូវដាក់តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ១ (មួយ) ច្បាប់ ដូចមានចែងក្នុងចំណុច ១០.២.៩ ខាងលើនេះ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ ដូចមានចែងក្នុងចំណុច ១០.២.១៤ ខាងលើនេះ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្នងថា "ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គ.ជ.ប"។ បន្ទាប់មកប្រធាន គ.ក.រ ត្រូវរៀបចំវេចខ្ចប់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ព្រមទាំងរាល់ស្រោមសំបុត្រ ឬ/និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងកញ្ចប់សុវត្ថិភាព "ក" ហើយត្រូវបិទភ្ជិតដោយការសុវត្ថិភាពដែលបម្រុងស្រាប់ និងបំពេញលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធឱ្យបានត្រឹមត្រូវ។ ប្រធាន គ.ក.រ ត្រូវជានាថានៅក្នុងកញ្ចប់សុវត្ថិភាព "ក" រួមមានសម្ភារ ឯកសារបោះឆ្នោតដូចខាងក្រោម៖

- ១០.៤.២.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គ.ជ.ប។
- ១០.៤.២.២ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតខូច (ប្រសិនបើមាន)។
- ១០.៤.២.៣ ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ។
- ១០.៤.២.៤ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់។
- ១០.៤.២.៥ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន)។
- ១០.៤.២.៦ ស្រោមសំបុត្រដាក់ឯកសារកស្តុតាងដែលបានដកហូត (ប្រសិនបើមាន)។
- ១០.៤.២.៧ ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ដូចមានចែងក្នុងចំណុច ១០.២.១៣ ខាងលើនេះ។

១០.៤.៣ ប្រធាន គ.ក.រ ត្រូវដាក់តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ១ (មួយ) ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្នងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គឃ.សប" ដូចមានចែងក្នុងចំណុច ១០.១.៤.២ នៃ ប.ន.ឃ.ស នេះ។

១០.៤.៤ ប្រធាន គ.ក.រ ត្រូវធានាថាលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញលម្អិតមុខសម្ភារ ឯកសារបោះឆ្នោត ដោយលេខាធិការ និងចុះហត្ថលេខាដោយប្រធាន គ.ក.រ ផ្ទាល់ សម្រាប់ប្រើក្នុងការបញ្ជូន និងការប្រគល់ ការទទួលស្បោង "ខ" នៅ គយ.សប។ ប្រធាន គ.ក.រ ត្រូវ៖

- ១០.៤.៤.១ ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្ររួចដាក់ទៅក្នុងស្បោង "ខ"។
- ១០.៤.៤.២ ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង "ខ"។
- ១០.៤.៤.៣ រក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការចុះហត្ថលេខាប្រគល់ទទួលស្បោង "ខ" នៅ គយ.សប។

១០.៤.៥ ប្រធាន គ.ក.រ ត្រូវធានាក្នុងការវេចខ្ចប់ដាក់ក្នុងស្បោង "ខ" ដើម្បីបញ្ជូនទៅ គយ.សប នូវសម្ភារ ឯកសារបោះឆ្នោតដូចខាងក្រោម៖

- ១០.៤.៥.១ កញ្ចប់សុវត្ថិភាព "ក" ដាក់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធដូចមានចែងក្នុងចំណុច ១០.៤.២ ខាងលើនេះ។
- ១០.៤.៥.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត។
- ១០.៤.៥.៣ ស្រោមសំបុត្រតូចដាក់ត្រា គ.ក.ប (ដាក់ក្រោយពេលបានបោះត្រាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) រួចរាល់ហើយ)។
- ១០.៤.៥.៤ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ១ (មួយ) ច្បាប់ ដូចមានចែងក្នុងចំណុច ១០.៤.៤.១ ខាងលើនេះ។

១០.៤.៦ ប្រធាន គ.ក.រ ត្រូវធានាថាស្បោង "ខ" ដែលផ្ទុកសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ១០.៤.៥ ខាងលើនេះ ត្រូវបានចងភ្ជិត ចាក់សោឃ្លុំមានលេខ សរសេរលេខកូដការិយាល័យបោះឆ្នោតឱ្យបានត្រឹមត្រូវដោយប្រើបិកហ្វឺតលុបមិនជ្រះ និងដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង "ខ"។

១០.៤.៧ ប្រធាន គ.ក.រ ត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិបានសង្កេតមើលក្នុងរាល់ដំណើរការនៃការរៀបចំ និងការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតសម្រាប់ការបញ្ជូនទៅ គយ.សប និងបានកត់ត្រាលេខសោឃ្លុំដែលបានចាក់នៅត្រង់មាត់ស្បោង "ខ" ដូចមានចែងក្នុងចំណុច ១០.៤.៦ ខាងលើនេះ។

១០.៤.៨ ប្រធាន គ.ក.រ ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដែលត្រូវផ្ញើជូន គ.ជ.ប វិញ ដូចជាហិបឆ្នោត បន្ទប់សម្ងាត់ កេសស័ង្កសី ទឹកខ្មៅលុបមិនជ្រះ ស្លាកការិយាល័យបោះឆ្នោត ជាដើម ហើយត្រូវបញ្ជូន និងប្រគល់សម្ភារ ឯកសារបោះឆ្នោតទាំងនោះជូន គឃ.សប អមជាមួយនឹងការបញ្ជូនស្បោង “ខ”។ ប្រធាន គ.ក.រ ត្រូវធានាថាលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ ត្រូវបានបំពេញលម្អិតមុខសម្ភារ ឯកសារបោះឆ្នោតនៅសល់ទាំងអស់សម្រាប់ប្រើក្នុងពេលប្រគល់ ទទួលនៅ គឃ.សប។

កិច្ចប្រតិបត្តិការរបស់ គឃ.សប ក្នុងការស្នែន និងបញ្ជូនរូបភាពកំណត់ហេតុនៃការបោះឆ្នោត តារាងកត់ត្រាសំឡេងឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ទៅ គ.ជ.ប សម្រាប់ផ្សាយជាលទ្ធផលបឋមនៃការបោះឆ្នោត

ប្រការ១០.៥.

នៅរសៀលនៃថ្ងៃបោះឆ្នោត គឃ.សប ត្រូវរង់ចាំទទួលស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ដែលសមាជិកទី២ នៃ គ.ក.រ ប្រគល់ជូន។ បន្ទាប់មក គឃ.សប ត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ជាលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយត្រូវចាត់ចែងបញ្ជូនលទ្ធផលនេះ តាមបែបបទ និងនីតិវិធីដូចខាងក្រោម៖

១០.៥.១ ប្រធាន គឃ.សប ត្រូវពិនិត្យ ផ្ទៀងផ្ទាត់អំពីភាពពេញលេញនៃការបំពេញទិន្នន័យនានាក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) រួចចារបញ្ជាក់ពីការបានទទួលនៅលើផ្នែកខាងលើនៃទម្រង់បែបបទទាំងនេះ ចុះកាលបរិច្ឆេទ និងពេលវេលានៃការទទួល រួចចុះហត្ថលេខា ឈ្មោះ និងបោះត្រា គឃ.សប។ ករណីរកឃើញថាតួលេខសំខាន់ៗនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោតណាមួយមានកំហុស ត្រូវធ្វើការកត់ត្រាទុកបន្ថែមសម្រាប់ជាមូលដ្ឋានកែតម្រូវនៅពេលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់។



១០.៥.២ ចាត់សមាជិកទទួលបន្ទុកលើការងាររដ្ឋបាលស្នែនកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) បញ្ចូលទៅក្នុងកម្មវិធីកុំព្យូទ័រ។

១០.៥.៣ បញ្ចូលទិន្នន័យ និងតួលេខលទ្ធផលពីកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដូចមានចែងក្នុងចំណុច ១០.៥.២ ខាងលើនេះ បញ្ចូលទៅក្នុងកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត រួចបញ្ជូនមក គ.ជ.ប តាមអ៊ីនធឺណិត ដើម្បីផ្សាយជាព័ត៌មានអំពីលទ្ធផលបឋមនៃការបោះឆ្នោត។

១០.៥.៤ ចាត់សមាជិកទទួលបន្ទុកលើការងាររដ្ឋបាលឱ្យបោះពុម្ពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដូចមានចែងក្នុងចំណុច ១០.៥.២ ខាងលើនេះ តាមចំនួនគ្រប់គ្រាន់ និងត្រូវបោះត្រា គយ.សប សម្រាប់ចែកជូនភ្នាក់ងារគណបក្សនយោបាយតាមការស្នើសុំ។

១០.៥.៥ រក្សាទុកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) សម្រាប់ដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដូចមានចែងក្នុងប្រការ១០.១១ នៃ ប.ន.ឃ.ស នេះ។

១០.៥.៦ បែបបទ និងនីតិវិធីអនុវត្តលម្អិតក្នុងប្រការ១០.៥ ខាងលើនេះ ត្រូវកំណត់ដោយសៀវភៅណែនាំរបស់ គ.ជ.ប។

ការបញ្ជូនស្បោង "ខ" និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតទៅទីស្នាក់ការ គយ.សប

ប្រការ១០.៦.-

បន្ទាប់ពីបានធ្វើការវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត រួចសព្វគ្រប់ហើយ ប្រធាន គ.ក.រ ត្រូវចាត់វិធានការចាំបាច់ទាំងឡាយក្នុងការបញ្ជូនជាបន្ទាន់នូវស្បោង "ខ" ដូចមានចែងក្នុងចំណុច ១០.៤.៦ ខាងលើនេះ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដូចមានចែងក្នុងចំណុច ១០.៤.៨ ខាងលើនេះ ឱ្យបានទៅដល់ទីស្នាក់ការ គយ.សប ក្នុងវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត។

១០.៦.១ ផ្អែកលើស្ថានភាពនៃចម្ងាយផ្លូវ មធ្យោបាយដឹកជញ្ជូន ពេលវេលា និងសភាពការណ៍សន្តិសុខ ប្រធាន គ.ក.រ យល់ថាអាចនឹងបញ្ជូនស្បោង "ខ" និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដូចមានចែងក្នុងប្រការ១០.៤ ខាងលើនេះ ទៅ គយ.សប បានតាមពេលវេលាកំណត់ និងធានាបាននូវសុវត្ថិភាពនោះ ប្រធាន គ.ក.រ ត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតនានាឱ្យចូលរួមក្នុងការបញ្ជូនខាងលើ និងត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរ ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ និងការទទួលស្បោង "ខ" និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទាំងនោះនៅទីស្នាក់ការ គយ.សប។

១០.៦.២ ប្រធាន គ.ក.រ ដែលអមដំណើរដោយអនុប្រធាន គ.ក.រ ត្រូវទទួលខុសត្រូវដឹកជញ្ជូនដោយផ្ទាល់នូវស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងប្រការ១០.៦ ខាងលើនេះទៅទីស្នាក់ការ គយ.សប។ ប្រធាន គ.ក.រ ត្រូវចាត់សមាជិក គ.ក.រ តាមការចាំបាច់ ដើម្បីជួយដឹកជញ្ជូនឱ្យអស់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត។

១០.៦.៣ ប្រសិនបើត្រូវការចាំបាច់ប្រធាន គ.ក.រ ត្រូវស្នើសុំកម្លាំងសន្តិសុខបោះឆ្នោត ២ (ពីរ) រូប ដើម្បីអមដំណើរការដឹកជញ្ជូនស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទៅ គយ.សប។

១០.៦.៤ នៅពេលទទួលស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដូចមានចែងក្នុងប្រការ១០.៦ ខាងលើនេះ គយ.សប ត្រូវធានាថាបានត្រួតពិនិត្យរាល់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ និងចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) បញ្ជាក់ថាបានទទួលគ្រប់ចំនួនហើយ។ ដោយឡែកក្នុងការប្រគល់ និងការទទួលស្បោង “ខ” គយ.សប ត្រូវ៖

១០.៦.៤.១ បើកស្បោង “ខ” ត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតខាងក្នុងដោយផ្អែកលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតទាំង ៣ (បី) ច្បាប់ ប៉ុន្តែមិនត្រូវរុះរើកញ្ចប់សុវត្ថិភាព “ក” ឡើយ។

១០.៦.៤.២ ត្រួតពិនិត្យស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត ដោយត្រូវពិនិត្យលេខកូដរាជធានី ខេត្ត លេខកូដឃុំ សង្កាត់ និងលេខកូដការិយាល័យបោះឆ្នោត ព្រមទាំងភិនភាគស្លាកស្នាម ឬស្ថានភាពបិទភ្ជិតនៃស្រោមសំបុត្រនេះ។ គយ.សប ត្រូវត្រួតពិនិត្យស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោតតាមស្ថានភាពនីមួយៗដូចខាងក្រោម៖

- ក្នុងករណី គយ.សប ពិនិត្យឃើញថាស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតត្រូវបានរុះរើ របើក ឬមានស្នាមរហែក គយ.សប ត្រូវស្នើឱ្យ គ.ក.រ ធ្វើការឆ្លើយបំភ្លឺ ដោយត្រូវធ្វើកំណត់ហេតុ ឬរបាយការណ៍ឱ្យបានច្បាស់លាស់
- ក្នុងករណីស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតត្រូវបាន គ.ក.រ ដាក់ចូលទៅក្នុងកញ្ចប់សុវត្ថិភាព “ក” គយ.សប ត្រូវធ្វើរបាយការណ៍ឱ្យបានច្បាស់លាស់ជូន គ.ជ.ប តាមរយៈ គជ.ខប ពាក់ព័ន្ធ ហើយមិនត្រូវបើកកញ្ចប់សុវត្ថិភាព “ក” ឡើយ

- ក្នុងករណី គយ.សប ពិនិត្យឃើញថាស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតមានស្ថានភាពបិទភ្ជិតត្រឹមត្រូវ ច្បាស់លាស់ ដូចមានចែងក្នុងចំណុច ១០.១.៥ នៃ ប.ន.ឃ.ស នេះ គយ.សប ត្រូវចារបញ្ជាក់លើស្រោមសំបុត្រនេះថា "ត្រឹមត្រូវ" ប្រធាន គយ.សប ត្រូវចុះហត្ថលេខា ឈ្មោះ រួចបោះត្រា គយ.សប ហើយដាក់ស្រោមសំបុត្រនេះចូលទៅក្នុងស្បោង "ខ" វិញ និងនាំយកទៅរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព។

១០.៦.៤.៣ ចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ៣ (បី) ច្បាប់ បន្ទាប់ពីបានត្រួតពិនិត្យត្រឹមត្រូវហើយ។

១០.៦.៤.៤ ប្រគល់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដែលចុះហត្ថលេខារួច ជូនប្រធាន គ.ក.រ ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ដាក់ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង "ខ" ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១០.៦.៥ រាល់ស្បោង "ខ" ដែល គយ.សប បានទទួលខាងលើនេះ ត្រូវតែបានកត់ចំណាំ និងរក្សាទុកនៅកន្លែងមានសុវត្ថិភាពដោយដាក់តាមលំដាប់លេខកូដការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់។

១០.៦.៦ គយ.សប ត្រូវចាត់វិធានការយ៉ាងហ្មត់ចត់ក្នុងការការពារសន្តិសុខ និងសុវត្ថិភាពនៃស្បោង "ខ" ដែលមានកញ្ចប់សុវត្ថិភាព "ក" ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត និងស្រោមសំបុត្រតូចដាក់ត្រា គ.ក.ប ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត។ ក្នុងនោះ គយ.សប ត្រូវ៖

១០.៦.៦.១ ទាក់ទងស្នើសុំកម្លាំងសន្តិសុខបោះឆ្នោត ដើម្បីយាមការពារបរិវេណទីស្នាក់ការ គយ.សប ឬអគារដែលត្រូវរក្សាទុកស្បោង "ខ" និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត។

១០.៦.៦.២ ចាត់ចែងឱ្យមានភ្លើងបំភ្លឺនៅទីស្នាក់ការ គយ.សប ឬអគារដែលត្រូវរក្សាទុកស្បោង "ខ" និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត។

ប្រការ១០.៧.

ផ្អែកលើស្ថានភាពនៃចម្ងាយផ្លូវ មធ្យោបាយដឹកជញ្ជូន ពេលវេលា និងសភាពការណ៍សន្តិសុខ ប្រសិនបើប្រធាន គ.ក.រ យល់ថាមិនអាចបញ្ជូនស្បោង "ខ" ដែលមានកញ្ចប់សុវត្ថិភាព "ក" ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត និងស្រោមសំបុត្រតូចដាក់ត្រា គ.ក.ប នៃការិយាល័យបោះឆ្នោតរបស់ខ្លួន

ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទៅ គយ.សប នៅពេលល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត បានទេនោះ ប្រធាន គ.ក.រ ត្រូវចាត់វិធានការដើម្បីថែរក្សាការពារស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោត នៅសល់ផ្សេងទៀតទាំងនោះនៅពេលយប់នៅទីតាំងសុវត្ថិភាពណាមួយ ដោយត្រូវផ្តល់ព័ត៌មានអំពីបញ្ហានេះ ជូន គយ.សប ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតនានា។

១០.៧.១ ប្រធាន គ.ក.រ ត្រូវថែរក្សាការពារស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតខាងលើនៅផ្ទះរបស់គាត់ ផ្ទះរបស់សមាជិកណាម្នាក់នៃ គ.ក.រ ឬនៅទីតាំងសុវត្ថិភាពណាមួយដែលបានកំណត់។

១០.៧.២ ប្រធាន គ.ក.រ ត្រូវជម្រាបជូន គយ.សប ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតឱ្យបានដឹងអំពីផ្ទះ ឬទីតាំងសុវត្ថិភាពដែលនឹងត្រូវរក្សាទុកស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតនៅពេលយប់ ហើយត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតឱ្យចូលរួមថែរក្សាការពារ។ ទន្ទឹមនឹងនេះត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរនៅព្រឹកស្អែក និងពេលវេលានៃការប្រគល់ និងការទទួលស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទាំងនោះនៅទីស្នាក់ការ គយ.សប។

១០.៧.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតនានាអាចស្នាក់នៅពេលយប់នៅផ្ទះ ឬទីតាំងសុវត្ថិភាពដែលទទួលរក្សាការពារស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត។

១០.៧.៤ ប្រធាន គ.ក.រ ត្រូវចាត់សមាជិក គ.ក.រ យ៉ាងហោចណាស់ចំនួន ៣ (បី) នាក់ គិតទាំងរូបគាត់ផងឱ្យចូលរួមក្នុងការរក្សាការពារស្បោង «ខ» និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទាំងនោះ។

១០.៧.៥ ប្រធាន គ.ក.រ មិនត្រូវទុកស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតចោលដោយគ្មានការយាមកាមទេ។

១០.៧.៦ ប្រសិនបើចាំបាច់ ប្រធាន គ.ក.រ ត្រូវស្នើសុំកម្លាំងសន្តិសុខបោះឆ្នោត ២ (ពីរ) រូបដើម្បីយាមការពារបរិវេណផ្ទះ ឬទីតាំងដែលរក្សាទុកស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតនៅពេលយប់។

១០.៧.៧ នៅព្រឹកថ្ងៃបន្ទាប់ អនុវត្តតាមពេលវេលាដែលបានកំណត់ ប្រធាន គ.ក.រ ត្រូវទទួលបន្ទុកក្នុងការបញ្ជូនស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទៅប្រគល់ជូន គយ.សប។ ក្នុងករណីនេះ បញ្ញត្តិដូចមានចែងក្នុងចំណុច ១០.៦.២ រហូតដល់ចំណុច ១០.៦.៥ ខាងលើនេះ ត្រូវតែបានអនុវត្ត។

ការរាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គឃ.សប ឬនៅទីតាំងសុវត្ថិភាពណាមួយក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ

ប្រការ១០.៨.-

អនុលោមតាម ច.ប.ឃ.ស ចំពោះការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ឬច្រើនដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបាន ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខកើតឡើងនៅពេលបន្ទាប់ពីបានបិទការបោះឆ្នោត ព្រមទាំងធ្វើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) រួចរាល់ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចនៅខាងក្នុង និងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅរក្សាបានល្អ គ.ជ.ប ត្រូវណែនាំដល់ គឃ.សប ពាក់ព័ន្ធឱ្យចាត់ចែងការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះនៅទីស្នាក់ការ គឃ.សប ឬទីតាំងសុវត្ថិភាពណាមួយ។

១០.៨.១ ករណីប្រធានសក្តិ ឬអសន្តិសុខត្រូវបានកំណត់ក្នុងចំណោមករណីណាមួយដូចមានចែងក្នុងចំណុច ១២.១.១ នៃ ប.ន.ឃ.ស នេះ។

១០.៨.២ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខដែលកើតឡើងនៅក្រោយពេល គ.ក.ប បានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីដូចមានចែងក្នុងប្រការ១០.១ នៃ ប.ន.ឃ.ស នេះ ហើយប្រសិនបើប្រធានសក្តិ ឬអសន្តិសុខនោះបានបណ្តាលឱ្យខូចខាតដល់ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងរាល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ប្រធាន គ.ក.ប ត្រូវចាត់ចែងជាបន្ទាន់ដូចខាងក្រោម៖

- ១០.៨.២.១ ធ្វើរបាយការណ៍ស្តីពីស្ថានភាពនៃករណីប្រធានសក្តិ ឬអសន្តិសុខនោះ ព្រមទាំងការខូចខាតជាក់ស្តែងជូន គឃ.សប។
- ១០.៨.២.២ ប្រមូលនិងវេចខ្ចប់រាល់សម្ភារឯកសារបោះឆ្នោតនៅសេសសល់ទាំងអស់ដែលអមដោយរបាយការណ៍ខាងលើ រួចបញ្ជូន និងប្រគល់ជូន គឃ.សប។ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអាចចូលរួមអមដំណើរក្នុងការបញ្ជូននេះ។
- ១០.៨.២.៣ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើនៅពេលប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គឃ.សប។
- ១០.៨.២.៤ នៅពេលប្រគល់របាយការណ៍ និងសម្ភារ ឯកសារបោះឆ្នោតនៅសេសសល់ខាងលើ ប្រធាន គឃ.សប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ២ (ពីរ) ច្បាប់ រួចប្រគល់ជូនប្រធាន គ.ក.ប ១ (មួយ) ច្បាប់។

១០.៨.២.៥ នៅពេលបានទទួលរបាយការណ៍ដូចមានចែងក្នុងចំណុច ១០.៨.២.៤ ខាងលើនេះ គយ.សប ត្រូវបន្តលើកយោបល់ស្នើជាបន្ទាន់ទៅ គធ.ខប និង គ.ជ.ប សុំឱ្យមានការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

១០.៨.៣ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខដែលកើតឡើងនៅក្រោយពេល គ.ក.ប បានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីដូចមានចែងក្នុងប្រការ១០.១ នៃ ប.ន.ឃ.ស នេះ ហើយប្រសិនបើប្រធានសក្តិ ឬអសន្តិសុខនោះមិនបានបណ្តាលឱ្យខូចខាតដល់ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងរាល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ទេ ប្រធាន គ.ក.ប ត្រូវចាត់ចែងជាបន្ទាន់ដូចខាងក្រោម៖

១០.៨.៣.១ ថែរក្សាហិបឆ្នោតដែលបានបិទភ្ជិត និងចាក់សោឃ្លុំរួចដូចមានចែងក្នុងចំណុច ១០.១.១.២ នៃ ប.ន.ឃ.ស នេះ ឱ្យបានហ្មត់ចត់ត្រៀមសម្រាប់ការបញ្ជូនទៅ គយ.សប។

១០.៨.៣.២ រៀបចំស្រោមសំបុត្រសម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដូចមានចែងក្នុងចំណុច ១០.១.៤ នៃ ប.ន.ឃ.ស នេះ និងវេចខ្ចប់រាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ១០.១.៦ នៃ ប.ន.ឃ.ស នេះ ទៅក្នុងកញ្ចប់សុវត្ថិភាព “ក” ប៉ុន្តែមិនចាំបាច់បិទភ្ជិតដោយការសុវត្ថិភាពនៅពេលនេះទេ បន្ទាប់មកត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

១០.៨.៣.៣ វេចខ្ចប់កញ្ចប់សុវត្ថិភាព “ក” ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត និងស្រោមសំបុត្រតូចដាក់ត្រា គ.ក.ប (បន្ទាប់ពីបោះត្រាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) រួច) ទៅក្នុងស្បោង “ខ” ហើយចងភ្ជិត និងចាក់សោឃ្លុំ។

១០.៨.៣.៤ ប្រមូល និងវេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតនៅសេសសល់ទាំងអស់ដោយឡែក។

១០.៨.៣.៥ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើនៅពេលប្រគល់ទទួលនៅ គយ.សប។


១០.៨.៣.៦ បញ្ជូន និងប្រគល់ហិបឆ្នោត ស្បោង “ខ” និងរាល់សម្ភារ ឯកសារ បោះឆ្នោតនៅសេសសល់ខាងលើជូន គឃ.សប។ ប្រធាន គ.ក.ប ដែលអមដំណើរដោយអនុប្រធាន គ.ក.ប និងសមាជិក គ.ក.ប មួយចំនួនទៀតត្រូវទទួលបន្ទុកក្នុងការបញ្ជូន ការប្រគល់ និងការទទួលនេះដោយផ្ទាល់ ព្រមទាំងត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតចូលរួម និងត្រូវស្នើសុំកម្លាំងសន្តិសុខបោះឆ្នោត ២ (ពីរ) រូប ឱ្យជួយការពារ និងជូនដំណើរនេះ។

១០.៨.៤ នៅពេលទទួលហិបឆ្នោតមានសន្លឹកឆ្នោតនៅខាងក្នុង ស្បោង “ខ” និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសេសសល់ខាងលើ ប្រធាន គឃ.សប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ២ (ពីរ) ច្បាប់ រួចប្រគល់ជូនប្រធាន គ.ក.ប ១ (មួយ) ច្បាប់។

១០.៨.៥ បន្ទាប់ពីបានទទួលហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង “ខ” ដែលមានកញ្ចប់សុវត្ថិភាព “ក” ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត និងស្រោមសំបុត្រតូចដាក់ត្រា គ.ក.ប នៅការិយាល័យបោះឆ្នោតដែលមានករណីប្រធានសក្តិ ឬអសន្តិសុខភ្លាម គឃ.សប ត្រូវធ្វើការកត់ចំណាំ និងរក្សាទុកដោយឡែកនៅកន្លែងមានសុវត្ថិភាព និងត្រូវជូនដំណឹងដល់សមាសភាព គ.ក.ប ព្រមទាំងភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍បោះឆ្នោតឱ្យមកកាន់ទីស្នាក់ការ គឃ.សប នៅវេលាម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកនៃថ្ងៃបន្ទាប់ ដើម្បីរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតរបស់ខ្លួន។

១០.៨.៥.១ គឃ.សប អាចចាត់ចែងសមាសភាព គ.ក.ប ផ្សេង ឬសមាជិក គឃ.សប ឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ប្រសិនបើសមាសភាព គ.ក.ប ពាក់ព័ន្ធអវត្តមាន។

១០.៨.៥.២ សមាសភាព គ.ក.ប ដែលត្រូវបំពេញការកិច្ចរាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គឃ.សប ឬនៅទីតាំងណាមួយដែលមានសុវត្ថិភាព ត្រូវទទួលប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរ និងម្ហូបអាហារក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនោះ។



១០.៨.៦ តាមពេលវេលាដូចមានចែងក្នុងចំណុច ១០.៨.៥ ខាងលើនេះ គឃ.សប ត្រូវចាត់ចែងឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតដែលជួបករណីប្រធានសក្តិ ឬអសន្តិសុខដូចមានចែងក្នុងប្រការ១០.៨ ខាងលើនេះ នៅទីស្នាក់ការរបស់ខ្លួន ឬនៅទីតាំងណាមួយដែលមានសុវត្ថិភាព។

១០.៨.៧ នៅពេលសមាសភាព គ.ក.រ ឬមន្ត្រីបោះឆ្នោតដែលទទួលភារកិច្ចរាប់សន្លឹកឆ្នោតមានវត្តមាននៅក្នុងបន្ទប់រាប់សន្លឹកឆ្នោតហើយ ប្រធាន គឃ.សប ត្រូវប្រគល់ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង “ខ” ដែលមានកញ្ចប់សុវត្ថិភាព “ក” ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត និងស្រោមសំបុត្រគូចដាក់ត្រា គ.ក.ប ព្រមទាំងទម្រង់បែបបទចាំបាច់ផ្សេងទៀតឱ្យទៅប្រធាន គ.ក.រ ដើម្បីអនុវត្តការរាប់សន្លឹកឆ្នោត។ ប្រធាន គ.ក.រ ត្រូវ៖

១០.៨.៧.១ ពិនិត្យឱ្យប្រាកដថាហិបឆ្នោតមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង “ខ” ដែលបានទទួលពុំត្រូវបានគេរុះរើឡើយ។

១០.៨.៧.២ កាត់ផ្តាច់សោឃ្លុំស្បោង “ខ” និងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតខាងក្នុង ដោយធ្វើឆ្លងផ្ទាត់ទៅនឹងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)។

១០.៨.៨ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតខាងលើ រាល់បញ្ញត្តិដូចមានចែងក្នុងប្រការ១០.២ ប្រការ១០.៣ ប្រការ១០.៤ និងប្រការ១០.៦ នៃ ប.ន.ឃ.ស នេះ ត្រូវតែបានអនុវត្ត។ ដោយសារការរាប់សន្លឹកឆ្នោតនេះត្រូវបានធ្វើនៅទីស្នាក់ការ គឃ.សប ឬទីតាំងណាមួយដែលមានសុវត្ថិភាព នីតិវិធីពាក់ព័ន្ធមួយចំនួនត្រូវបានកំណត់ឱ្យអនុវត្តដោយឡែកដែលក្នុងនោះប្រធាន គ.ក.រ ត្រូវ៖

១០.៨.៨.១ ទទួលខុសត្រូវនាំយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ ទៅបិទផ្សាយនៅខាងមុខទីតាំងការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

១០.៨.៨.២ ធានាថាបន្ទាប់ពីការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ រាល់សម្ភារ ឯកសារបោះឆ្នោតត្រូវបានវេចខ្ចប់ក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រ និងដាក់ក្នុងកញ្ចប់សុវត្ថិភាព “ក” រួចបិទភ្ជិតដោយការសុវត្ថិភាពបម្រុងស្រាប់។ បន្ទាប់មកស្បោង “ខ” ត្រូវបានវេចខ្ចប់ជាថ្មីដោយដាក់សម្ភារ ឯកសារបោះឆ្នោតតាមលំនាំដូចមានចែងក្នុងចំណុច ១០.៤.៦ នៃ ប.ន.ឃ.ស នេះ រួចចងមាត់ស្បោងឡើងវិញ ហើយត្រូវប្រគល់ជូន គឃ.សប ដោយផ្ទាល់នៅបន្ទប់រាប់សន្លឹកឆ្នោតនោះនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត។

១០.៨.៨.៣ ប្រគល់ហិបឆ្នោតទទេ ជូន គឃ.សប។

១០.៨.៨.៤ ធានាថាលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ត្រូវបានបំពេញ និងប្រើប្រាស់ក្នុងការប្រគល់ និងការទទួល ស្របតាមការកំណត់របស់ គ.ជ.ប។

ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតទៅ គយ.សប

ប្រការ១០.៩.

ភ្នាក់ងារគណបក្សនយោបាយដែលមិនសុខចិត្តនឹងការសម្រេចរបស់ គ.ក.ប/គ.ក.រ ពាក់ព័ន្ធនឹងការជំទាស់ ឬការតវ៉ា ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយនៅក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតដូចមានចែងក្នុងចំណុច ៩.៦.២៣ នៃ ប.ន.ឃ.ស នេះ ឬ/និងក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតដូចមានចែងក្នុងចំណុច ១០.២.៧ នៃ ប.ន.ឃ.ស នេះ អាចបំពេញបែបបទសម្រាប់ប្តឹងទៅ គយ.សប។

ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ត្រូវធ្វើឡើងជាបន្ទាន់ស្របពេលនឹងការបញ្ជូនស្បោង “ខ” ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទៅ គយ.សប នៅពេលល្ងាចនៃថ្ងៃបោះឆ្នោត ឬយ៉ាងយូរបំផុតត្រឹមម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទី ព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។ ប្រសិនបើនៅក្នុងរយៈពេលកំណត់ខាងលើនេះ គយ.សប មិនបានទទួលពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានការប្តឹងតវ៉ា ឬការប្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ។

- ១០.៩.១ ភ្នាក់ងារគណបក្សនយោបាយដែលមានបំណងប្តឹងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតមេដៃលើពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖
  - ១០.៩.១.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង។
  - ១០.៩.១.២ លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត។
  - ១០.៩.១.៣ កម្មវត្ថុនៃបណ្តឹង។
  - ១០.៩.១.៤ មូលហេតុនៃការប្តឹង។
  - ១០.៩.១.៥ ពេលវេលានៃការកើតឡើងនូវភាពមិនប្រក្រតី។
  - ១០.៩.១.៦ ប្រសិនបើអាចបានត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ឃ.ស ច.វ.ច.ប ឬប្រការនៃ ប.ន.ឃ.ស ដែលត្រូវបានរំលោភ។
  - ១០.៩.១.៧ មនុស្សដែលពាក់ព័ន្ធក្នុងភាពមិនប្រក្រតីនេះ។
  - ១០.៩.១.៨ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)។
  - ១០.៩.១.៩ សេចក្តីអះអាងគាំទ្រ ឬកស្តុតាងផ្សេងៗទៀត (ប្រសិនបើមាន)។
  - ១០.៩.១.១០ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង (ប្រសិនបើមាន)។

១០.៩.២ នៅពេលបានទទួលពាក្យបណ្តឹង សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន មានជាអាទិ៍ដូចខាងក្រោម៖

- ទី១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- ទី២- កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់យ៉ាងយូរម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទីព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

១០.៩.៣ បន្ទាប់មកសមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុសាកសួរនោះ។

១០.៩.៤ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

១០.៩.៤.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ដូចមានចែងក្នុងប្រការ ១០.៩ ខាងលើនេះ ប្រធាន គយ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុថា "ពាក្យបណ្តឹងបានដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងប្រការ១០.៩ នៃ ប.ន.ឃ.ស ដែលជាហេតុថ្លោះសិទ្ធិក្នុងការប្តឹងមក គយ.សប។ ដូចនេះ គយ.សប មិនអាចទទួលយកពាក្យបណ្តឹងនេះ មកពិនិត្យ និងដោះស្រាយបានឡើយ។" ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងប្រាប់អ្នកប្តឹង ឬតំណាងថាពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ គយ.សប មិនអាចទទួលយកមកដោះស្រាយបានទេ។



១០.៩.៤.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ១០.៩.១ ខាងលើនេះ សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវណែនាំ

អ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយត្រូវកត់ត្រាក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គយ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១០.៩.៤.៣ ពាក្យបណ្តឹងគោរពរយៈពេលកំណត់ដូចមានចែងក្នុងប្រការ១០.៩ ខាងលើនេះ និងមានព័ត៌មានចាំបាច់ សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវចុះកាលបរិច្ឆេទពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ និងបោះត្រា គយ.សប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅទីស្នាក់ការ គយ.សប ១ (មួយ) ច្បាប់ និងរក្សាទុកប្រើក្នុងពេលប្រជុំសម្រេច ១ (មួយ) ច្បាប់។ សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវជម្រាបអ្នកប្តឹង ឬតំណាងថា គយ.សប នឹងធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ ព្រមទាំងប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធនៅក្នុងអំឡុងពេលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនានាក្នុងឃុំ សង្កាត់។

១០.៩.៥ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងដំទាស់មានភស្តុតាងបញ្ជាក់អាចនាំឱ្យជឿថាមានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ឬ/និងភាពមិនប្រក្រតីណាមួយដែលអាចប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ប្រធាន គយ.សប ត្រូវ៖

១០.៩.៥.១ ចាត់ចែងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់ការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹង។

១០.៩.៥.២ បើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតដូចមានចែងក្នុងប្រការ១០.១៣ នៃ ប.ន.ឃ.ស នេះ។ ក្នុងការបើកកញ្ចប់សុវត្ថិភាព “ក” នេះ គឃ.សប ពុំមានសិទ្ធិធ្វើការរាប់ និងផ្តល់សុពលភាពសន្លឹកឆ្នោតឡើងវិញ បាននោះទេ។

១០.៩.៥.៣ អនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នោះ និងអ្នកសង្កេតការណ៍បោះឆ្នោតចូលរួមសង្កេតមើលក្នុងការអនុវត្តនីតិវិធីចំណុច ១០.៩.៥.១ និងចំណុច ១០.៩.៥.២ ខាងលើនេះ។

១០.៩.៦ ប្រសិនបើក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឡើងវិញដូចមានចែងក្នុងចំណុច ១០.៩.៥.១ និងចំណុច ១០.៩.៥.២ ខាងលើនេះ គឃ.សប មិនឃើញមានកស្តុតាងបញ្ជាក់ថាមានកំហុសណាមួយក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ឬ/និងភាពមិនប្រក្រតីណាមួយដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធទេនោះ គឃ.សប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងនោះ។ គឃ.សប ត្រូវបដិសេធលើពាក្យបណ្តឹង ដោយប្រធាន គឃ.សប ត្រូវ៖

១០.៩.៦.១ ចាត់សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ចំនួន ៣ (បី) ច្បាប់ ចុះហត្ថលេខា ឈ្មោះ និងចុះកាលបរិច្ឆេទ។

១០.៩.៦.២ ចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប លើសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១០.៩.៦.៣ ជម្រាបអ្នកប្តឹង ឬតំណាងថាគាត់អាចប្តឹងតវ៉ាទៅនឹងការសម្រេចរបស់ គឃ.សប ទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃ គឃ.សប បិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់។



១០.៩.៦.៤ ប្រគល់ជូនអ្នកប្តឹង ឬតំណាងនូវពាក្យបណ្តឹង (ទ.១២០២) សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាចំនួន ៣ (បី) ច្បាប់ (ប្រសិនបើគាត់ស្នើសុំ)។

១០.៩.៧ ប្រសិនបើក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឡើងវិញដូចមានចែងក្នុងចំណុច ១០.៩.៥.១ និងចំណុច ១០.៩.៥.២ ខាងលើនេះ គយ.សប បានរកឃើញថា គ.ក.ប/គ.ក.រ មានកំហុសក្នុងការគណនាតួលេខនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ គយ.សប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងនោះ។ គយ.សប ត្រូវយល់ព្រមលើពាក្យបណ្តឹង ដោយប្រធាន គយ.សប ត្រូវ៖

- ១០.៩.៧.១ ចាត់សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ចំនួន ៣ (បី) ច្បាប់ ចុះហត្ថលេខា ឈ្មោះ និងចុះកាលបរិច្ឆេទ។
- ១០.៩.៧.២ ចុះហត្ថលេខា ឈ្មោះ បោះត្រា គយ.សប លើសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។
- ១០.៩.៧.៣ ជម្រាបអ្នកប្តឹង ឬតំណាងថា គយ.សប យល់ព្រមកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោត។

១០.៩.៨ ប្រសិនបើក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឡើងវិញដូចមានចែងក្នុងចំណុច ១០.៩.៥.១ និងចំណុច ១០.៩.៥.២ ខាងលើនេះ គយ.សប បានរកឃើញភស្តុតាងបញ្ជាក់ថាមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោតដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ គយ.សប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងនោះ។ គយ.សប ត្រូវយល់ព្រមតាមពាក្យបណ្តឹង ដោយប្រធាន គយ.សប ត្រូវ៖

- ១០.៩.៨.១ ចាត់សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ចំនួន ៣ (បី) ច្បាប់ ចុះហត្ថលេខា ឈ្មោះ និងចុះកាលបរិច្ឆេទ។
- ១០.៩.៨.២ ចុះហត្ថលេខា ឈ្មោះ និងបោះត្រា គយ.សប លើសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១០.៩.៨.៣ ជម្រាបអ្នកប្តឹង ឬតំណាងថា គឃ.សប នឹងធ្វើរបាយការណ៍ និងលើកយោបល់ស្តីពីករណីនេះ ផ្ញើអមជាមួយកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ជូន គជ.ខប ដើម្បីពិនិត្យ សម្រេច។

ការជាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងភាពមិនប្រក្រតីនៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោតទៅ គឃ.សប ប្រការ១០.១០.-

នីតិវិធីដូចមានចែងក្នុងប្រការ១០.៩ ខាងលើនេះ ក៏មានសុពលភាពផងដែរសម្រាប់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយដែលបានកើតមានឡើងនៅក្នុងតំបន់បោះឆ្នោតណាមួយនៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត។

១០.១០.១ អំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយដូចបញ្ជាក់ក្នុងប្រការ១០.៩ ខាងលើនេះ ត្រូវបានកំណត់ជាក់ស្តែងតាមរយៈកិច្ចសង្កេតការណ៍ ការរាយការណ៍ ឬការចោទប្រកាន់ដោយមានភស្តុតាងគ្រប់គ្រាន់ ដែលរួមមានប្រភេទបទរំលោភណាមួយដូចខាងក្រោម៖

- ១០.១០.១.១ ការប្រើកម្លាំងដកហូតឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតពីអ្នកបោះឆ្នោត។
- ១០.១០.១.២ ការប្រើកម្លាំង អំពើហិង្សា ឬការគំរាមកំហែងដើម្បីរារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ១០.១០.១.៣ ការគាបសង្កត់ ការគំរាមកំហែង ឬការបង្ខំអ្នកបោះឆ្នោតឱ្យស្បថថានឹងបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ។
- ១០.១០.១.៤ ការធ្វើឱ្យខូចរបៀបរៀបរយ ឬការអុកឡុករំខានកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតមិនឱ្យដំណើរការបាន។
- ១០.១០.១.៥ ការញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង ឬអំពើហិង្សាទៅលើបេក្ខជននៃគណបក្សនយោបាយណាមួយ។
- ១០.១០.១.៦ ការប្រើកម្លាំងអំពើហិង្សា ឬការបំភិតបំភ័យដែលបង្កឱ្យមានការភ័យខ្លាច ការគាន់ច្រឡំ ភាពច្របូកច្របល់ និងការបាត់ទំនុកចិត្តលើការបោះឆ្នោត ឬលើការសម្ងាត់នៃការបោះឆ្នោត។
- ១០.១០.១.៧ ការបោកបញ្ឆោត ឬការលួងលោមទិញសន្លឹកឆ្នោតដោយសម្ភារៈ ឬប្រាក់កាស។

១០.១០.២ ការបំភិតបំភ័យ ការគាបសង្កត់ ការគំរាមកំហែង ការប្រើកម្លាំង ឬអំពើហិង្សា ការរំលោភបំពាន ឬការគំរាមកំហែងដោយហិង្សា ត្រូវបានកំណត់តាមរយៈការស្តែងឡើងតាមគ្រប់មធ្យោបាយដោយពាក្យសម្តី ជាលាយលក្ខណ៍អក្សរ ដោយរូបភាព ដោយវីដេអូ ឬដោយកាយវិការដូចខាងក្រោម៖

- ១០.១០.២.១ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬដោយការសរសេរជាលាយលក្ខណ៍អក្សរ រូបភាព ឬវីដេអូដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ។
- ១០.១០.២.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យថានឹងធ្វើទារុណកម្ម។
- ១០.១០.២.៣ ការវាយតប់បន្តិចបន្តួច ឬធ្ងន់ធ្ងរលើបុគ្គលណាម្នាក់។
- ១០.១០.២.៤ ការរំលោភដោយពាក្យសម្តីថានឹងធ្វើទុក្ខទោសដល់រាងកាយ។
- ១០.១០.២.៥ ការបង្ហាញ ឬការប្រើប្រាស់នូវគ្រឿងសព្វាវុធ ឬវត្ថុដែលមានគ្រោះថ្នាក់ផ្សេងៗ ដើម្បីបំភិតបំភ័យ។
- ១០.១០.២.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដែលយោងទៅលើព្រឹត្តការណ៍ពីអតីតកាល ដូចជាឃាតកម្ម ការវាយដំ ការរំលោភ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ជាដើម។
- ១០.១០.២.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ លើដំបូលផ្ទះ លើយានដំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ។
- ១០.១០.២.៨ ការយកសាកសពសត្វជាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់សុវត្ថិភាព និងអាយុជីវិតរបស់ខ្លួន ឬបងប្អូនគ្រួសាររបស់ខ្លួន។
- ១០.១០.២.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន។
- ១០.១០.២.១០ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត ជាដើម។

១០.១០.៣ ការប្តឹងតវ៉ា ឬ/និងការជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយដូចមានចែងក្នុងប្រការ១០.១០ ខាងលើនេះ មិនច្រានចោលការប្តឹងចំពោះគ្រប់អំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប ឡើយ។ ការប្តឹងចំពោះគ្រប់អំពើបំពាននេះត្រូវអនុវត្តតាម ច.ប.ឃ.ស និងជំពូកទី១៤ នៃ ប.ន.ឃ.ស នេះ។

កិច្ចប្រតិបត្តិការរបស់ គយ.សប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត

ប្រការ១០.១១.-

បន្ទាប់ពីបានទទួលស្បោង “ខ” ដែលមានកញ្ចប់សុវត្ថិភាព “ក” ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត និងស្រោមសំបុត្រតូចដាក់ត្រា គ.ក.ប ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតពីគ្រប់ការិយាល័យបោះឆ្នោតចំណុះឃុំ សង្កាត់ដូចមានចែងក្នុងចំណុច ១០.៦.៤ ចំណុច ១០.៧.៧ ចំណុច ១០.៨.៥ និងចំណុច ១០.៨.៨.២ នៃ ប.ន.ឃ.ស នេះ គយ.សប ត្រូវចាត់វិធានការចាំបាច់នានាដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនានាក្នុងឃុំ សង្កាត់បញ្ចូលគ្នាឱ្យរួចរាល់ឆាប់រហ័សតាមដែលអាចធ្វើបាន និងមិនត្រូវឱ្យហួសរយៈពេល ៣ (បី) ថ្ងៃឡើយ។

- ១០.១១.១ អគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវទទួលបន្ទុកណែនាំដល់ គយ.សប តាមរយៈ គធ.ខប អំពីរបៀបប្រើប្រាស់ និងដំណើរការកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតដើម្បីជាជំនួយដល់ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។
- ១០.១១.២ គធ.ខប ត្រូវផ្តល់ការគាំទ្រដល់ គយ.សប ក្នុងដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។
- ១០.១១.៣ គយ.សប ត្រូវអនុវត្តការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតដោយរួមបញ្ចូលនីតិវិធីដោយដៃ និងតាមកម្មវិធីកុំព្យូទ័រ។
- ១០.១១.៤ តំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ គយ.សប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតចំណុះឃុំ សង្កាត់។
  - ១០.១១.៤.១ គណបក្សនយោបាយនីមួយៗប្រចាំការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ឬសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោត ត្រូវចាត់តាំងឱ្យមានតំណាងរបស់ខ្លួនម្នាក់ និងតំណាងបម្រុងម្នាក់សម្រាប់ចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ គយ.សប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់។

១០.១១.៤.២ តំណាងគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល សង្កេតការណ៍បោះឆ្នោតដែលត្រូវចូលរួមសង្កេតមើលដំណើរការនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ខាងលើ អាចផ្លាស់ប្តូរតំណាងបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួនបាន។

១០.១១.៤.៣ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មមដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់។

១០.១១.៤.៤ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអាចថតយករូបភាពនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់បាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ។

១០.១១.៥ កិច្ចប្រតិបត្តិការរបស់ គយ.សប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតចំពោះការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រសិនបើចាប់ដំណើរការហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយមិនត្រូវឈប់សម្រាកឡើយ។ គយ.សប ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយរួមបញ្ចូលទាំងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់ការិយាល័យបោះឆ្នោតដែលត្រូវបានរាប់នៅទីស្នាក់ការ គយ.សប ឬទីតាំងសុវត្ថិភាពណាមួយក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ រួមនឹងការិយាល័យបោះឆ្នោតដែលត្រូវបាន គយ.សប សម្រេចបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយផ្អែកលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងដំទាស់ទៅនឹងភាពមិនប្រក្រតីដែលកើតមានឡើង (ប្រសិនបើមាន)។

១០.១១.៦ គយ.សប ត្រូវបើកកិច្ចប្រតិបត្តិការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនៅក្នុងឃុំ សង្កាត់នៅទីស្នាក់ការរបស់ខ្លួន ឬនៅអគារណាមួយដែលតម្រូវឱ្យមានបរិវេណសន្តិសុខធានាបានសុវត្ថិភាពល្អ ហើយត្រូវរៀបចំបន្ទប់តាមលំនាំគំរូប្លង់ការិយាល័យរាប់សន្លឹកឆ្នោតដូចមានចែងក្នុងចំណុច ១០.២.១.១ នៃ ប.ន.ឃ.ស នេះ។ ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតខាងលើនេះ ប្រធាន គយ.សប ត្រូវ

អង្គុយនៅចុងតុម្ខាង និងឱ្យសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលអង្គុយនៅចុងតុម្ខាងទៀតទល់មុខគាត់ ហើយឱ្យអនុប្រធាន គយ.សប និងសមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតអង្គុយនៅអមសងខាងតុទល់មុខគ្នា។ ចំណែកសមាជិកដទៃទៀតត្រូវទទួលបន្ទុករួមគ្នាការពារមាត់ទ្វារ និងរក្សាសណ្តាប់ធ្នាប់ក្នុងបន្ទប់ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។ ប្រធាន គយ.សប ត្រូវ៖

១០.១១.៦.១ ត្រៀមនៅលើតុខាងមុខគាត់នូវ៖

- ពាក្យបណ្តឹង (ទ.១២០២) ដែលត្រូវប្រគល់ជូនតំណាងគណបក្សនយោបាយ ឬតំណាងតាមការស្នើសុំ
- ម៉ាស៊ីនគិតលេខ ១ (មួយ) គ្រឿង
- សម្ភារ ឯកសារបោះឆ្នោតចាំបាច់ផ្សេងទៀត។

១០.១១.៦.២ ចាត់ចែងឱ្យសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលរៀបចំដំឡើងកុំព្យូទ័រ និងភ្ជាប់អ៊ីនធឺណិត ដើម្បីទាញយកទិន្នន័យ និងរូបភាពកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពីសេរ៉ូបករណ៍ (Server) គ.ជ.ប ដែលខ្លួនបានបញ្ចូល និងបញ្ជូនទៅ គ.ជ.ប សម្រាប់ផ្សព្វផ្សាយលទ្ធផលបឋមនៃការបោះឆ្នោត។

ប្រការ១០.១២.

ក្នុងករណីឃុំ សង្កាត់ណាគ្មានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ ឬមានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ដែលបានដាក់ក្រោយពេលវេលាកំណត់ ឬមានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ដែលគ្មានកស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីនាំឱ្យប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយទេនោះ គយ.សប មិនអាចបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតទេ។ ក្នុងករណីនេះ គយ.សប ត្រូវចាត់ចែងត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតទាំងអស់ចំណុះឃុំ សង្កាត់បញ្ចូលគ្នាជាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់។

១០.១២.១ ក្នុងដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ចំពោះករណីដូចមានចែងក្នុងប្រការ១០.១២ ខាងលើនេះ គយ.សប គ្រាន់តែពិនិត្យ ផ្ទៀងផ្ទាត់ និងគណនាដោយផ្អែកលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ធៀបនឹងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)

តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលបានបញ្ចូលក្នុងកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតប៉ុណ្ណោះ។ ប្រធាន គយ.សប ត្រូវ៖

១០.១២.១.១ បង្គាប់សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតឱ្យនាំយកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតម្តងមួយៗពីកន្លែងរក្សាទុកមកដាក់នៅលើតុចំមុខប្រធាន គយ.សប។

១០.១២.១.២ បង្គាប់ឱ្យសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលបញ្ចាប់ចូល (Login) ក្នុងកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ដើម្បីទាញយកទិន្នន័យពីសេវ៉ូបករណ៍ (Server) គ.ជ.ប សម្រាប់បង្ហាញលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗលើឧបទស្សន៍កុំព្យូទ័រ (Monitor) ជូនភាគីពាក់ព័ន្ធដែលមានវត្តមានបានមើលឃើញទាំងអស់គ្នា។

១០.១២.១.៣ បង្គាប់ឱ្យសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលបោះពុម្ពកំណត់ហេតុរាប់សន្លឹកឆ្នោត (ទ.១១០២) ពីកម្មវិធីកុំព្យូទ័រ ១ (មួយ) ច្បាប់ រួចបោះត្រា គយ.សប និងប្រគល់ឱ្យសមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតយកទៅបិទផ្សាយនៅខាងមុខទីស្នាក់ការ គយ.សប។

១០.១២.១.៤ ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបតួលេខដែលមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) នៃការិយាល័យបោះឆ្នោតនីមួយៗ រួចធ្វើការប្រៀបធៀបលទ្ធផលជាមួយនឹងតួលេខពាក់ព័ន្ធដែលមានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដើម្បីឱ្យដឹងប្រាកដថាលទ្ធផលដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពិតជាត្រឹមត្រូវមែន ឬមានកំហុសក្នុងការគណនាលេខណាមួយ។

១០.១២.១.៥ សម្រេចកែតម្រូវតួលេខលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះនៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមាន

ប្រសិនបើបានរកឃើញថា គ.ក.ប/គ.ក.រ មានកំហុសក្នុងការគណនាលេខ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធាន គឃ.សប ត្រូវឆូតលុបតួលេខដែលខុសរួចសរសេរតួលេខថ្មីក្បែរនោះដោយមានចុះហត្ថលេខារបស់ប្រធាន គឃ.សប ផង។ ករណីនេះ ត្រូវឱ្យសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលកត់ត្រាអំពីបញ្ហានេះនៅក្នុងកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) នៅក្នុងកម្មវិធីកុំព្យូទ័រផង។ ប្រធាន គឃ.សប ត្រូវប្រកាសជាចំហដល់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមានអំពីការកែតម្រូវនេះ។ ប្រធាន គឃ.សប ត្រូវធ្វើកំណត់ហេតុអំពីការកែតម្រូវនេះដោយបញ្ជាក់អំពីមូលហេតុ ព្រមទាំងចុះហត្ថលេខា ឈ្មោះ និងបោះត្រា គឃ.សប និងចែកជូនតំណាងគណបក្សនយោបាយដែលមានវត្តមាន។

១០.១២.១.៦ ចាត់ឱ្យសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលស្តែនទម្រង់បែបបទទាំងឡាយណាដែលមានការកែតម្រូវបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រ។

១០.១២.១.៧ ណែនាំសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលឱ្យកែតម្រូវទិន្នន័យក្នុងកម្មវិធីកុំព្យូទ័រដែលបានទាញយកពីសេរ៉ូបករណ៍ (Server) គ.ជ.ប ក្នុងករណីមានការកែតម្រូវទិន្នន័យនៃទម្រង់បែបបទណាមួយដូចមានចែងក្នុងចំណុច ១០.១២.១.៥ ខាងលើនេះ។

១០.១២.១.៨ ណែនាំសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលឱ្យបោះពុម្ពតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ដែលប្រព័ន្ធបានគណនាដោយស្វ័យប្រវត្តិផ្អែកតាមទិន្នន័យក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ បន្ទាប់ពីបានពិនិត្យ ផ្ទៀងផ្ទាត់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់រួចរាល់អស់ហើយ។



១០.១២.១.៩ ធានាថារាល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៃការិយាល័យបោះឆ្នោតដែលបានប្រើប្រាស់ក្នុង

ដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ន ខាងលើនេះរួច ត្រូវតែបានដាក់ទៅក្នុងស្រោមសំបុត្រដែលមានកាខ្ជង "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គជ.ខប" ដើម្បីត្រៀមផ្ញើជូន គជ.ខប និងបោះពុម្ពក្នុង ១ (មួយ) មុខ ១ (មួយ) ច្បាប់ រក្សាទុកជាឯកសាររបស់ គឃ.សប។

១០.១២.២ ប្រធាន គឃ.សប ត្រូវធានាថាតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ដែលសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលបានរៀបចំរួចរាល់ក្នុងកម្មវិធីកុំព្យូទ័រដូចមានចែងក្នុងចំណុច ១០.១២.១.៨ ខាងលើនេះ ត្រូវបានបោះពុម្ពចំនួន ២ (ពីរ) ច្បាប់ បន្ទាប់មកប្រគល់ជូនអនុប្រធាន គឃ.សប ១ (មួយ) ច្បាប់ និងសមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត ១ (មួយ) ច្បាប់ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់បន្ថែមដោយប្រើប្រមាណវិធីដោយដៃ និងដោយម៉ាស៊ីនគិតលេខ។ តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ទាំង ២ (ពីរ) ច្បាប់នោះ ត្រូវតែពិនិត្យ ផ្ទៀងផ្ទាត់ឡើងវិញ ឱ្យបានត្រឹមត្រូវ និងចុះហត្ថលេខាដោយសមាជិកទទួលបន្ទុកលើការងាររដ្ឋបាល និងប្រធាន គឃ.សប ហើយត្រូវផ្ញើជូន គជ.ខប ៣ក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារនៅ គឃ.សប ១ (មួយ) ច្បាប់។

១០.១២.៣ ប្រធាន គឃ.សប ត្រូវធានាថាសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលបានផ្ទេរទិន្នន័យលទ្ធផលពីតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ទៅក្នុងកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) តាមកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត រួចបោះពុម្ពកំណត់ហេតុនេះតាមចំនួនចាំបាច់។ កំណត់ហេតុនេះត្រូវតែបានចុះហត្ថលេខាដោយសមាជិកទទួលបន្ទុកលើការងាររដ្ឋបាល និងប្រធាន គឃ.សប។

១០.១២.៤ ប្រធាន គឃ.សប ត្រូវធានាថាតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) និងកំណត់ហេតុនៃការបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ដែលបានចុះហត្ថលេខា និងបោះត្រា គឃ.សប រួច ត្រូវបានស្កែនបញ្ចូលទៅក្នុងកម្មវិធីកុំព្យូទ័រ។



១០.១២.៥ ប្រធាន គឃ.សប ត្រូវធានាថានីតិវិធីទាំងឡាយដូចមានចែងក្នុងចំណុច ១០.១២.១ ខាងលើនេះ ត្រូវតែបានអនុវត្តដូចគ្នាសម្រាប់ស្រោមសំបុត្រដាក់កំណត់ហេតុនៃ

ការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) របស់ការិយាល័យបោះឆ្នោតម្តងមួយៗ រហូតដល់អស់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៃការិយាល័យទាំងអស់ក្នុងឃុំ សង្កាត់។

១០.១២.៦ កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ត្រូវដាក់បង្ហាញតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដើម្បីពិនិត្យ។

- ១០.១២.៦.១ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣)។
- ១០.១២.៦.២ ការមិនព្រមចុះហត្ថលេខាពីតំណាងគណបក្សនយោបាយមិនអាចចាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ។

១០.១២.៧ ប្រធាន គយ.សប ត្រូវរៀបចំបែងចែក និងប្រើប្រាស់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ដូចមានចែងក្នុងចំណុច ១០.១២.៤ ខាងលើនេះ ដូចខាងក្រោម៖

- ១០.១២.៧.១ បិទផ្សាយនៅខាងមុខទីស្នាក់ការ គយ.សប ១ (មួយ) ច្បាប់ និងត្រូវធ្វើកំណត់ហេតុស្តីពីការបិទផ្សាយកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ដោយបញ្ជាក់ច្បាស់ពីពេលវេលា និងកាលបរិច្ឆេទនៃការបិទផ្សាយនេះផង។ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាលើកំណត់ហេតុស្តីពីការបិទផ្សាយនេះ ប៉ុន្តែការមិនព្រមចុះហត្ថលេខារបស់ភ្នាក់ងារគណបក្សនយោបាយមិនអាចចាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ។
- ១០.១២.៧.២ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ដែលត្រូវដាក់រួមជាមួយតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ១ (មួយ) ច្បាប់ និងកំណត់ហេតុស្តីពីការបិទផ្សាយដូចមានចែងក្នុងចំណុច ១០.១២.៧.១ ខាងលើនេះទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្នងថា “កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ផ្ញើជូន គធ.ខប”។

១០.១២.៧.៣ បោះពុម្ពកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) បន្ថែម ហើយចែកជូនតំណាងគណបក្សនយោបាយដែលមានវត្តមាន។

១០.១២.៧.៤ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១០.១២.៨ ប្រធាន គយ.សប ត្រូវធានាថារូបភាព និងទិន្នន័យនៃកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) រួមនឹងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) និងកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ដែលមានក្នុងកម្មវិធីកុំព្យូទ័របញ្ជូនទៅសេរ៉ូបករណ៍ (Server) គ.ជ.ប តាមអ៊ីនធឺណិត និងរក្សាទុកក្នុងយូអេសប៊ីផ្លាសជ្រាយ (USB Flash Drive) មួយដែលមានចងលេខកូដសម្ងាត់សម្រាប់បញ្ជូនទៅ គធ.ខប។

១០.១២.៩ ប្រធាន គយ.សប ត្រូវត្រៀមកញ្ចប់ "គ ពិសេស" មួយ ដែលត្រូវដាក់រាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតសម្រាប់ផ្ញើជូន គធ.ខប និងផ្ញើជូន គ.ជ.ប តាមរយៈ គធ.ខប។ ប្រធាន គយ.សប ត្រូវប្រមូល និងចងជាបាច់ទៅតាមមុខឯកសារ និងគោលដៅដែលត្រូវទទួល ហើយរៀបចំដាក់ទៅក្នុងកញ្ចប់ "គ ពិសេស" នូវ៖

១០.១២.៩.១ រាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គធ.ខប ដូចមានចែងក្នុងចំណុច ១០.១២.១.៩ ខាងលើនេះ។

១០.១២.៩.២ រាល់ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) និងកំណត់ហេតុស្តីពីការបិទផ្សាយកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដូចមានចែងក្នុងចំណុច ១០.១២.៧.២ ខាងលើនេះ។

១០.១២.៩.៣ ស្រោមសំបុត្រដាក់យូអេសប៊ីផ្លាសជ្រាយ (USB Flash Drive) រក្សាទុករូបភាពទិន្នន័យ និងទិន្នន័យនៃកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) និងកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣)។

១០.១២.៩.៤ ស្រោមសំបុត្រតែមួយដាក់រាល់ឯកសារពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលត្រូវផ្ញើជូន គធ.ខប។

១០.១២.៩.៥ ក្នុងករណីឃុំ សង្កាត់ណាមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលតម្រូវឱ្យមានការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ប្រធាន គយ.សប ត្រូវធានាថាស្រោមសំបុត្រដាក់របាយការណ៍ផ្ញើជូន គធ.ខប ដូចមានចែងក្នុងចំណុច ១០.១៣.៣.២ ខាងក្រោមនេះ ត្រូវតែបានកិបភ្ជាប់ទៅនឹងស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ដូចមានចែងក្នុងចំណុច ១០.១២.៧.២ ខាងលើនេះ។

១០.១២.១០ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវគត់ចម្លងឱ្យបានត្រឹមត្រូវនូវតួលេខលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធពីកំណត់ហេតុដែលបានបិទផ្សាយដូចមានចែងក្នុងចំណុច ១០.១២.៧.១ ខាងលើនេះ។

ប្រការ១០.១៣.-

ក្នុងករណីឃុំ សង្កាត់ណាមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលត្រូវបានដាក់ក្នុងអំឡុងពេលកំណត់ដូចមានចែងក្នុងប្រការ១០.៩ និងប្រការ១០.១០ ខាងលើនេះ គយ.សប ក៏ត្រូវធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់ការិយាល័យបោះឆ្នោតទាំងអស់ចំណុះឃុំ សង្កាត់បញ្ចូលគ្នាជាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផងដែរ ដោយត្រូវអនុវត្តតាមនីតិវិធីក្នុងដំពូកនេះចាប់ពីចំណុច ១០.១២.១ រហូតដល់ចំណុច ១០.១២.១០ ខាងលើនេះ។

ប្រសិនបើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់គ្មានភស្តុតាងបញ្ជាក់ពីកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬភាពមិនប្រក្រតីណាមួយដែលនាំឱ្យប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើនក្នុងឃុំ សង្កាត់ទេនោះ គយ.សប ត្រូវចាត់ចែងត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យពាក់ព័ន្ធតាមនីតិវិធីជាធម្មតា ដោយមិនចាំបាច់បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតទេ។

១០.១៣.១ ប្រសិនបើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់មានភស្តុតាងបញ្ជាក់ថាមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន គយ.សប អាចបើកកញ្ចប់សុវត្ថិភាព "ក" នៃការិយាល័យពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ប៉ុន្តែ គយ.សប ពុំមានសិទ្ធិរាប់ និងផ្តល់សុពលភាពសន្លឹកឆ្នោតឡើងវិញទេ។

ករណីនេះនៅពេលកំពុងអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ១០.១២.១ ខាងលើនេះ ប្រធាន គឃ.សប ត្រូវ៖

១០.១៣.១.១ ដកយកកញ្ចប់សុវត្ថិភាព “ក” និងស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោតពីក្នុងស្បោង “ខ” មកដាក់នៅលើតុ។

១០.១៣.១.២ ប្រើកន្ត្រៃកាត់បើកកញ្ចប់សុវត្ថិភាព “ក” រួចដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ ដែលមាននៅខាងក្នុងមកដាក់ដោយឡែកពីគ្នានៅលើតុមុខគាត់។

១០.១៣.១.៣ ប្រគល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ឱ្យទៅសមាជិកទទួលបន្ទុកលើការងាររដ្ឋបាលសម្រាប់តាមដានពិនិត្យ ដោយប្រៀបធៀបទៅនឹងលទ្ធផលនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។

១០.១៣.១.៤ បើកស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត និងបើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតម្តងមួយៗ ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់តាមនីតិវិធីដូចមានចែងក្នុងចំណុច ១០.១៣.២ ខាងក្រោមនេះ។

១០.១៣.២ នៅពេលមានកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់ហើយ ប្រធាន គឃ.សប ត្រូវចាត់ចែងឱ្យត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅការិយាល័យនោះ ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ និងបញ្ហាជារួមដូចខាងក្រោម៖

១០.១៣.២.១ ពិនិត្យផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

១០.១៣.២.២ ពិនិត្យ ផ្ទៀងផ្ទាត់ត្រាសម្ងាត់ដែលប្រើសម្រាប់បោះលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។

១០.១៣.២.៣ ពិនិត្យ និងរាប់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតដែលបានមកបោះឆ្នោត។

១០.១៣.២.៤ ពិនិត្យ ផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោតនោះ ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលទទួលពីការិយាល័យបោះឆ្នោតនោះវិញ។

១០.១៣.២.៥ រាប់ចំនួនសន្លឹកឆ្នោតខូច (ប្រសិនបើមាន)។

១០.១៣.២.៦ រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ។

១០.១៣.២.៧ ពិនិត្យ ផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការ។

១០.១៣.២.៨ ពិនិត្យ ផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ។

១០.១៣.២.៩ ពិនិត្យមើលថាតើនៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) មានកត់ត្រាអំពីភាពមិនប្រក្រតីដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតដែរឬទេ។

១០.១៣.២.១០ ពិនិត្យមើលថាតើនៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ភ្នាក់ងារគណបក្សនយោបាយបានចុះហត្ថលេខាជាសាក្សីដែរឬទេ។

១០.១៣.៣ បន្ទាប់ពីអនុវត្តការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ដូចមានចែងក្នុងចំណុច ១០.១៣.២ ខាងលើនេះរួចរាល់ហើយ ប្រធាន គយ.សប ត្រូវ៖

១០.១៣.៣.១ ធ្វើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតចំនួន ២ (ពីរ) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃ គយ.សប។ របាយការណ៍នេះត្រូវតែមានការលើកយោបល់ស្នើសុំ គធ.ខប ពិនិត្យសម្រេច៖

- យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ
- ព្យួរដោយបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

១០.១៣.៣.២ ដាក់រាល់របាយការណ៍ដូចមានចែងក្នុងចំណុច ១០.១៣.៣.១ ខាងលើនេះ ១ (មួយ) ច្បាប់ ទៅក្នុងស្រោមសំបុត្រ រួចកាន់ដងថា “របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ផ្ញើជូន គធ.ខប” ដែលត្រូវកិបភ្ជាប់ទៅនឹងស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ដូចមានចែងក្នុងចំណុច ១០.១២.៧.២ ខាងលើនេះ ហើយដែលត្រូវដាក់ទៅក្នុងកញ្ចប់ “គ ពិសេស” ដូចមានចែងក្នុងចំណុច ១០.១៤.១ ខាងក្រោមនេះ។

១០.១៣.៣.៣ រក្សាទុកជាឯកសារនូវរបាយការណ៍ដូចមានចែងក្នុងចំណុច ១០.១៣.៣.១ ខាងលើនេះ ១ (មួយ) ច្បាប់។

១០.១៣.៣.៤ ដាក់សម្គារ ឯកសារបោះឆ្នោតដែលបានពិនិត្យ ផ្ទៀងផ្ទាត់ទៅក្នុងស្រោមសំបុត្រ និងស្បោងប្លាស្ទិកនានា រួចវេចខ្ចប់ក្នុងកញ្ចប់សុវត្ថិភាព "ក" ឡើងវិញតាមលំនាំដើមដូចមានចែងក្នុងចំណុច ១០.៤.២ នៃ ប.ន.ឃ.ស នេះ។

១០.១៣.៣.៥ វេចខ្ចប់ដាក់ក្នុងស្បោង "ខ" ឡើងវិញនូវ៖

- កញ្ចប់សុវត្ថិភាព "ក"
- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត ដោយត្រូវបិទភ្ជិតឡើងវិញ និងមានការបញ្ជាក់អំពីការបើកស្រោមសំបុត្រនេះ
- ស្រោមសំបុត្រតូចដាក់ត្រា គ.ក.ប
- នាំយកស្បោង "ខ" ទៅរក្សាទុកនៅកន្លែងដើមត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គធ.ខប។

១០.១៣.៤ នៅពេលបញ្ចប់ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលណ្តោះអាសន្ននៃការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់រួចរាល់ហើយ ប្រធាន គឃ.សប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹង ដោយត្រូវអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ១០.៩.៦ ចំណុច ១០.៩.៧ និងចំណុច ១០.៩.៨ នៃ ប.ន.ឃ.ស នេះ។

ប្រការ១០.១៤.

បន្ទាប់ពីបានអនុវត្តនីតិវិធីដូចមានចែងក្នុងប្រការ១០.១២ និងប្រការ១០.១៣ ខាងលើនេះចប់សព្វគ្រប់ហើយ ប្រធាន គឃ.សប ត្រូវធានាថាកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងរាល់សម្គារ ឯកសារបោះឆ្នោតពីការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ត្រូវតែបានវេចខ្ចប់ក្នុងកញ្ចប់ "គ ពិសេស" ស្បោង "គ" និងដាក់ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលប្រើក្នុងការបោះឆ្នោតគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ទៅក្នុងស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ រួចប្រគល់ជូន គធ.ខប បានយ៉ាងត្រឹមត្រូវក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលស្បោង "ខ" ព្រមទាំងសម្គារ ឯកសារបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់។

ក្នុងករណីឃុំ សង្កាត់ណាមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលតម្រូវឱ្យមានការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្គារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ប្រធាន គឃ.សប ត្រូវធានាថារាល់ស្បោង "ខ" ដាក់កញ្ចប់សុវត្ថិភាព "ក" ដែលបានបើកត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្គារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនោះ ត្រូវតែបានវេចខ្ចប់ក្នុងស្បោង "គ" ដោយឡែក។

១០.១៤.១ ប្រធាន គឃ.សប ត្រូវធានាដាក់ទៅក្នុងកញ្ចប់ "គ ពិសេស" ឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ នៅមុនពេលបិទក្តិតនូវរាល់ស្រោមសំបុត្រផ្ទុកកំណត់ហេតុ របាយការណ៍ និងឯកសារបោះឆ្នោតដែលត្រូវផ្ញើជូន គជ.ខប ដូចខាងក្រោម៖

- ១០.១៤.១.១ ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ១ (មួយ) ច្បាប់ តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ១ (មួយ) ច្បាប់ និងកំណត់ហេតុស្តីពីការបិទផ្សាយកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ផ្ញើជូន គជ.ខប ពាក់ព័ន្ធ។
- ១០.១៤.១.២ ស្រោមសំបុត្រដាក់របាយការណ៍របស់ គឃ.សប ស្តីពីការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតដូចមានចែងក្នុងចំណុច ១០.១៣.៣.២ ខាងលើនេះ (ប្រសិនបើមាន) ហើយត្រូវតែបានកិបស្រោមសំបុត្រនេះភ្ជាប់ទៅនឹងស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ដូចមានចែងក្នុងចំណុច ១០.១៤.១.១ ខាងលើនេះ។
- ១០.១៤.១.៣ រាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) តាមការិយាល័យបោះឆ្នោតនីមួយៗ ១ (មួយ) ច្បាប់ ផ្ញើជូន គជ.ខប។
- ១០.១៤.១.៤ ស្រោមសំបុត្រដាក់យូអេសប៊ីផ្លាសដ្រាយ (USB Flash Drive) រក្សាទុករូបភាពទិន្នន័យ និងទិន្នន័យនៃកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) និងកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣)។
- ១០.១៤.១.៥ រាល់ឯកសារពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ (ប្រសិនបើមាន) ដែលត្រូវប្រមូលដាក់ក្នុងស្រោមសំបុត្រតែមួយ និងកាខ្នងថាផ្ញើជូន គជ.ខប។
- ១០.១៤.១.៦ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់។

១០.១៤.២ ប្រធាន គឃ.សប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារ បោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ដោយមានសរសេររាយមុខសម្ភារ ឯកសារ ដែលបានដាក់ក្នុងកញ្ចប់ "គ ពិសេស" ខាងលើ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុង កញ្ចប់ "គ ពិសេស" ដាក់ ១ (មួយ) ច្បាប់ទៀត ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ "គ ពិសេស" និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ និងការទទួល សម្ភារ ឯកសារបោះឆ្នោតនៅ លគធ.ខប។

១០.១៤.៣ ប្រធាន គឃ.សប ត្រូវបិទភ្ជិតកញ្ចប់ "គ ពិសេស" រួចហើយត្រូវសរសេរសម្គាល់លេខ កូដឃុំ សង្កាត់របស់ខ្លួននៅលើផ្នែកខាងក្រៅនៃកញ្ចប់ "គ ពិសេស" ដោយប្រើបិកហ្វឺត លុបមិនជ្រះ រួចត្រៀមទុកសម្រាប់បញ្ជូនទៅ លគធ.ខប។

១០.១៤.៤ ប្រធាន គឃ.សប ត្រូវចាត់ចែងដកយកស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតពីគ្រប់ ស្បោង "ខ" នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ដាក់ទៅក្នុងស្បោង ដែលមានបោះពុម្ពកាខ្នងថា "ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់" តាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតទាំងនោះ។ នៅក្នុងការរៀចខ្ចប់ស្បោង ដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់នេះ គឃ.សប ត្រូវ៖

- ១០.១៤.៤.១ ដាក់ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត តាមលំដាប់លេខកូដការិយាល័យបោះឆ្នោតនីមួយៗទៅក្នុងស្បោង ដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ។
- ១០.១៤.៤.២ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដោយឡែកចំនួន ៣ (បី) ច្បាប់ ដោយបញ្ជាក់ឱ្យបាន ច្បាស់អំពីចំនួនស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោត និងលេខកូដ ការិយាល័យបោះឆ្នោតពាក់ព័ន្ធពីលេខប៉ុន្មានរហូតដល់លេខប៉ុន្មាន ព្រមទាំងសរសេរសម្គាល់បន្ថែមនូវលេខសោឃ្លុំដែលចាក់មាត់ស្បោងនេះ រួចហើយដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់ ទៅក្នុងស្បោង ដាក់ ១ (មួយ) ច្បាប់ទៀត ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលនៅ លគធ.ខប។
- ១០.១៤.៤.៣ ចងភ្ជិតមាត់ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ និង ចាក់សោឃ្លុំមានលេខ។ សរសេរសម្គាល់ពីក្រៅ "ស្បោងដាក់បញ្ជី បោះឆ្នោតនៃឃុំ សង្កាត់" នីមួយៗ ដោយប្រើបិកហ្វឺតលុបមិនជ្រះ នូវលេខកូដការិយាល័យពាក់ព័ន្ធពីលេខប៉ុន្មានដល់លេខប៉ុន្មាន។

១០.១៤.៤.៤ ក្នុងករណីមានស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ដូចមានចែងក្នុងចំណុច ១០.១៤.៤ ខាងលើនេះ សរុបលើសពីមួយប្រធាន គឃ.សប ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ទាំងនោះនូវលេខរៀងនៃស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ។ ឧទាហរណ៍ : ប្រសិនបើមានស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ សរុបចំនួន ៣ ត្រូវសរសេរសម្គាល់លេខរៀង ១/៣ ២/៣ និង ៣/៣។

១០.១៤.៥ បន្ទាប់មកប្រធាន គឃ.សប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់ស្បោង “ខ” នៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ និងដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ប៉ុន្តែគ្មានការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតដូចមានចែងក្នុងប្រការ១០.១៣ ខាងលើនេះ ដោយដាក់ទៅក្នុងស្បោង “គ” តាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់ស្បោង “ខ” ទាំងនោះ។ ក្នុងការវេចខ្ចប់នេះ គឃ.សប ត្រូវ៖

- ១០.១៤.៥.១ ដាក់ស្បោង “ខ” តាមលំដាប់លេខរៀងនៃលេខកូដការិយាល័យបោះឆ្នោត និងទៅក្នុងស្បោង “គ” នីមួយៗ។
- ១០.១៤.៥.២ ធានាថាលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញ ដោយមានរាយមុខសម្ភារ ឯកសារដែលបានដាក់ក្នុងស្បោង “គ” នីមួយៗ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុងស្បោង“គ” ដាក់ ១ (មួយ) ច្បាប់ទៀតទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង “គ” និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ និងការទទួលសម្ភារ ឯកសារបោះឆ្នោតនៅ លគធ.ខប។
- ១០.១៤.៥.៣ ចងក្ងិតស្បោង “គ” នីមួយៗ និងចាក់សោឃ្លុំមានលេខ។ សរសេរសម្គាល់ពីក្រៅស្បោង “គ” នីមួយៗ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះនូវលេខកូដការិយាល័យពាក់ព័ន្ធពីលេខប៉ុន្មានដល់លេខប៉ុន្មាន និងពាក្យថា “ពិនិត្យរួច”។

១០.១៤.៦ បន្ទាប់មកប្រធាន គឃ.សប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់ស្បោង “ខ” នៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ និងដែលមានការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតដូចមានចែងក្នុងប្រការ១០.១៣ ខាងលើនេះ ដោយដាក់ទៅក្នុងស្បោង “គ” ដោយឡែកតាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់ស្បោង “ខ” ទាំងនោះ។ ក្នុងការវេចខ្ចប់នេះ គឃ.សប ត្រូវ៖

១០.១៤.៦.១ ដាក់ស្បោង “ខ” នៃការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹង ឬ/និងមានការបើកកញ្ចប់សុវត្ថិភាព “ក” ទៅក្នុងស្បោង “គ”។

១០.១៤.៦.២ ធានាថាលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញដោយមានរាយមុខសម្ភារ ឯកសារដែលបានដាក់ក្នុងស្បោង “គ” ពាក់ព័ន្ធ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុងស្បោង “គ” ដាក់ ១ (មួយ) ច្បាប់ទៀត ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង “គ” និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ និងការទទួលសម្ភារ ឯកសារបោះឆ្នោត នៅ លគធ.ខប។

១០.១៤.៦.៣ ចងក្ងិតស្បោង “គ” និងចាក់សោឃ្លុំមានលេខ។

១០.១៤.៦.៤ សរសេរសម្គាល់ពីក្រៅស្បោង “គ” ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ នូវលេខកូដការិយាល័យពាក់ព័ន្ធ និងពាក្យថា “មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព “ក”។

១០.១៤.៧ ក្នុងករណីមានស្បោង “គ” ដូចមានចែងក្នុងចំណុច ១០.១៤.៥ ឬ/និងចំណុច ១០.១៤.៦ ខាងលើនេះ សរុបលើសពីមួយ ប្រធាន គឃ.សប ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃស្បោង “គ” ទាំងនោះនូវលេខរៀងនៃស្បោង “គ” នីមួយៗ។ ឧទាហរណ៍ : ប្រសិនបើមានស្បោង “គ” សរុបចំនួន ៣ ត្រូវសរសេរសម្គាល់លេខរៀង ១/៣ ២/៣ និង ៣/៣។

១០.១៤.៨ ប្រធាន គឃ.សប ត្រូវធានាថារាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត មានជាអាទិ៍ហិបឆ្នោត បន្ទប់សម្ងាត់ កេសស័ង្កសី ត្រា គឃ.សប ម៉ាស៊ីនគិតលេខ គ្រឿងបរិក្ខារវិទ្យុទាក់ទង ទឹកខ្មៅលុបមិនជ្រះ ដែលបានទទួលពីការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ឬ/និងមាននៅទីស្នាក់ការ គឃ.សប ត្រូវតែបានវេចខ្ចប់ និងបញ្ជូនទន្ទឹមគ្នានឹងការបញ្ជូនកញ្ចប់ “គ ពិសេស” ស្បោង “គ” និងស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ទៅ លគធ.ខប។ ការបញ្ជូនសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតខាងលើនេះ ប្រធាន គឃ.សប ត្រូវធានាថាលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ត្រូវតែបានបំពេញដោយឡែក និងអនុវត្តយ៉ាងត្រឹមត្រូវតាមគោលការណ៍នៃការប្រគល់ និងការទទួលសម្ភារ ឯកសារបោះឆ្នោត។

១០.១៤.៩ ប្រធាន គឃ.សប ត្រូវចាត់ចែងវេចខ្ចប់ និងប្រគល់ជូន គធ.ខប នូវស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ទាំងអស់ក្នុងឃុំ សង្កាត់ ស្របពេលការបញ្ជូនលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)។

១០.១៤.១០ ប្រធាន គយ.សប ត្រូវប្រកាសអញ្ជើញតំណាងគណបក្សនយោបាយ ព្រមទាំង អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិដែលមានវត្តមានឱ្យចូលរួមជាសាក្សី ក្នុងការបញ្ជូន ការប្រគល់ និងការទទួលកញ្ចប់ “គ ពិសេស” រាល់ស្បោង “គ” ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតខាងលើនេះ ហើយត្រូវជូនដំណឹងអំពីពេលវេលានៃការចេញដំណើរការបញ្ជូន ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ និងការទទួលនៅ លគធ.ខប ផង។

ជំពូកទី១១
លទ្ធផលបណ្តោះអាសន្ន លទ្ធផលផ្លូវការ
និងការជំទាស់ចំពោះលទ្ធផលនៃការបោះឆ្នោត

ការសម្របសម្រួលសកម្មភាពរបស់ និងបញ្ជូនទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត

ប្រការ១១.១.

គធ.ខប មានភារកិច្ចផ្តល់ការគាំទ្រដល់ គយ.សប ក្នុងការត្រួតពិនិត្យ និងការបូកសរុបលទ្ធផលបឋមនៃការបោះឆ្នោតឱ្យបានទាន់ពេលវេលានៅវេលាល្ងាចឬយប់នៃថ្ងៃបោះឆ្នោត ដើម្បីបញ្ជូនទិន្នន័យតាមអ៊ីនធឺណិតមក គ.ជ.ប ធ្វើការផ្សព្វផ្សាយជូនដល់សាធារណជន និងភាគីពាក់ព័ន្ធ។ ក្នុងដំណើរការគាំទ្រនេះ គធ.ខប ត្រូវតាមដានការបញ្ជូនរូបភាព និងទិន្នន័យកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយ គយ.សប។ ប្រសិនបើពិនិត្យឃើញថា គយ.សប មានការយឺតយ៉ាវ ឬមិនទាន់បានបញ្ជូនទិន្នន័យមក គ.ជ.ប ទេ គធ.ខប ត្រូវធ្វើទំនាក់ទំនង និងណែនាំព្រមដល់ គយ.សប ពាក់ព័ន្ធឱ្យចាត់ចែងបញ្ជូនមក គ.ជ.ប ឱ្យបានទាន់ពេលវេលា។

ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ នៃ គធ.ខប

ប្រការ១១.២.

គធ.ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់ត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ កំណត់ចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបាន ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបឃ.ស និងកំណត់ឈ្មោះសមាជិក កបឃ.ស ដែលត្រូវទទួលតំណែងជាប្រធាន កបឃ.ស ជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ តាមប្រមាណវិធីដោយដៃ និងតាមកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតកំណត់ដោយ គ.ជ.ប ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យ សម្រេចជាផ្លូវការ។

១១.២.១ មជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នៃ គធ.ខប អាចមានទីតាំងនៅ លគធ.ខប ឬនៅអគារមួយផ្សេង ឬផ្នែកមួយដែលមានទំហំទូលាយល្មមអាចរៀបចំឱ្យមានកន្លែងបម្រុងដូចខាងក្រោម៖

- ១១.២.១.១ កន្លែងសម្រាប់ទទួលកញ្ចប់ “គ ពិសេស” ស្បោង “គ” ឬ/និងស្បោង “គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក” ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតពីគ្រប់ឃុំ សង្កាត់ចំណុះរាជធានី ខេត្តពាក់ព័ន្ធ ដែលត្រូវស្ថិតនៅក្បែរផ្លូវចូល។

១១.២.១.២ បន្ទប់មួយទូលាយល្មមដែលអាចស្តុកកញ្ចប់ “គ ពិសេស” ស្បោង “គ” ឬ/និងស្បោង “គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក” ស្បោង ដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ដាច់ដោយឡែកពីគ្នាទៅតាមឃុំ សង្កាត់ និងមានសរសេរសម្គាល់លេខកូដឃុំ សង្កាត់នីមួយៗផង។

១១.២.១.៣ បន្ទប់មួយដោយឡែកដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដែល គឃ.សប បានប្រគល់ឱ្យ។

១១.២.១.៤ បន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើន ដែលត្រូវមានតុ និងកៅអីគ្រប់គ្រាន់សម្រាប់ប្រើក្នុងពេលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ហើយដែលអាចទទួលបានទាំងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ទាំងតំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកប្តឹង ឬតំណាង។

១១.២.១.៥ បន្ទប់ស្អាតតូចមួយ (ប្រសិនបើមាន) សម្រាប់ដាក់គ្រឿងបរិក្ខារកុំព្យូទ័រដែលមានភ្ជាប់អ៊ីនធឺណិត មានទិន្នន័យគ្រប់គ្រាន់ពាក់ព័ន្ធនឹងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត និងកម្មវិធីត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតដែលមានមុខងារប្រតិបត្តិការបែងចែកអាសនៈដែលរៀបចំ និងផ្តល់ជូនដោយ គ.ជ.ប។

១១.២.២ គធ.ខប ត្រូវធានាអំពីសន្តិសុខ សុវត្ថិភាពនៃអគារមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នៃ គធ.ខប។ ទ្វារ និងបង្អួចទាំងអស់ត្រូវបិទ និងចាក់សោយ៉ាងត្រឹមត្រូវនៅពេលផុតម៉ោងធ្វើការងារ។ នៅក្នុងដំណើរការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ គធ.ខប ត្រូវចាត់ឱ្យមានមន្ត្រីម្នាក់ទទួលបន្ទុកសណ្តាប់ធ្នាប់ក្នុងមជ្ឈមណ្ឌល និងមានមន្ត្រីម្នាក់ទៀតប្រចាំការនៅមាត់ទ្វារចូលចេញ ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធាន គធ.ខប។

១១.២.៣ គធ.ខប ត្រូវតែរៀបចំឱ្យមានបរិវេណសន្តិសុខមួយនៅអគារមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នៃ គធ.ខប ដោយនៅបរិវេណខាងក្រៅ ត្រូវស្នើសុំកិច្ចសហការពីគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដើម្បីចាត់កម្លាំងការពារ និងទទួលបន្ទុកការពារនៅបរិវេណខាងក្នុងត្រូវចាត់កម្លាំងសន្តិសុខផ្ទាល់របស់ លគធ.ខប ដើម្បីការពារ។

១១.២.៤ គជ.ខប ត្រូវទទួលបន្ទុកគ្រប់គ្រងការចូលចេញមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នៃ គជ.ខប និងមានសិទ្ធិអំណាចចូលចេញមជ្ឈមណ្ឌលនេះ។ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងបរិវេណសន្តិសុខ និងក្នុងមជ្ឈមណ្ឌលនេះត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គជ.ខប។

១១.២.៥ ហាមជនគ្រប់រូបចូលក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នៃ គជ.ខប ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងមជ្ឈមណ្ឌលនេះនូវជនទាំងឡាយដូចខាងក្រោម៖

- ១១.២.៥.១ ថ្នាក់ដឹកនាំ និងមន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ដែលបានទទួលការចាត់តាំង។
- ១១.២.៥.២ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត អ្នកសារព័ត៌មាន និងអ្នកប្តឹង ឬតំណាងដូចមានចែងក្នុងចំណុច ១១.៤.១ ខាងក្រោមនេះ។
- ១១.២.៥.៣ ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធាន គជ.ខប ឬតំណាង គជ.ខប សំណូមពរក្នុងករណីចាំបាច់។
- ១១.២.៥.៤ មន្ត្រីនៃ គ.ជ.ប ដែលកំពុងបំពេញភារកិច្ចស៊ើបអង្កេតអំពើល្មើសដែលគេបានចោទប្រកាន់ចំពោះសមាជិក គជ.ខប ឬមន្ត្រី លគជ.ខប ដែលចាត់ឱ្យបំពេញភារកិច្ចត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់។

១១.២.៦ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់នៅក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នៃ គជ.ខប៖

- ១១.២.៦.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ បញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ។
- ១១.២.៦.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីត្រួតពិនិត្យលទ្ធផលនៃ គជ.ខប បំពេញចិត្ត ឬប្រឆាំងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ។

១១.២.៧ គជ.ខប ត្រូវចាត់តាំងក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ចំនួនមួយ ឬច្រើនក្រុម ដោយយោងតាមចំនួនឃុំ សង្កាត់ក្នុងរាជធានី ខេត្តនីមួយៗ។ ជាធម្មតា គជ.ខប ត្រូវធានាថាក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប នីមួយៗដែលត្រូវបានចាត់តាំងអាចត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ចំនួន ១០ (ដប់)។ ដោយឡែក ចំពោះរាជធានី ខេត្តដែលមានចំនួនឃុំ សង្កាត់តិចពេក រួមមានខេត្តកែប ខេត្តប៉ៃលិន និងខេត្តព្រះសីហនុ ឬច្រើនពេក ដូចជាខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកណ្តាល រាជធានីភ្នំពេញ ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តតាកែវ ជាដើម ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប នីមួយៗដែលត្រូវបានចាត់តាំងអាចត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ចំនួនតិចជាង ១០ (ដប់) ឬច្រើនជាង ១០ (ដប់)។ គជ.ខប អាចបែងចែកឱ្យក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប នីមួយៗទទួលបន្ទុកឃុំ សង្កាត់ក្នុងក្រុង ស្រុក ខណ្ឌមួយ ឬលើសពីមួយ។

- ១១.២.៧.១ សមាសភាពនៃក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប នីមួយៗត្រូវជ្រើសតាំងពីក្នុងចំណោមសមាសភាពអនុគណៈកម្មការបច្ចេកទេស និងមន្ត្រី លគជ.ខប ក្នុងនោះត្រូវយកចិត្តទុកដាក់ចាត់តាំងមន្ត្រីណាដែលពេលនោះមិនសូវមានការងារមមាញឹក ដូចជាគ្រូបង្ហាត់ ជាដើម។ ប្រសិនបើ លគជ.ខប ពុំមានមន្ត្រី បុគ្គលិកគ្រប់គ្រាន់ គជ.ខប អាចលើកសំណើសុំចាត់តាំងសមាសភាពនៃ គយ.សប ដែលស្ថិតនៅជិតលគជ.ខប បញ្ចូលក្នុងក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ទាំងនេះ។
- ១១.២.៧.២ សមាសភាពក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប នីមួយៗត្រូវមាន ៤ (បួន) រូប ដឹកនាំដោយប្រធាន ១ (មួយ) រូប ដែលជាសមាសភាពអនុគណៈកម្មការបច្ចេកទេស ឬមន្ត្រី លគជ.ខប អនុប្រធាន ១ (មួយ) រូប លេខាធិការ ១ (មួយ) រូប និងជំនួយការ ១ (មួយ) រូប ដែលជាមន្ត្រី លគជ.ខប។
- ១១.២.៧.៣ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ដូចមានចែងក្នុងចំណុច ១១.២.៧.១ ខាងលើនេះ មានភារកិច្ចត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់តាមចំនួនឃុំ សង្កាត់ដែលក្រុមទទួលបន្ទុកប៉ុណ្ណោះ។



១១.២.៨ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប នីមួយៗមានភារកិច្ចត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗទៅតាមករណីដោយឡែកពីគ្នា និងតាមការណែនាំរបស់ប្រធាន គជ.ខប ដោយផ្អែកលើ៖

๑๑.๒.๘.๑ កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.๑๑๐๓) ពាក់ព័ន្ធ។

๑๑.๒.๘.๒ តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.๑๑๐๔) ពាក់ព័ន្ធ។

๑๑.๒.๘.๓ ទិន្នន័យលទ្ធផលនៃការបោះឆ្នោតដែល គយ.សប បានបញ្ជូនតាមអ៊ីនធឺណិត ឬយូអេសប៊ីផ្លាសដ្រាយ (USB Flash Drive) រក្សាទុកទិន្នន័យដែល គយ.សប បញ្ជូនមក។

๑๑.๒.๘.๔ កំណត់ហេតុនៃការបោះឆ្នោត (ទ.๑๑๐๑) តារាងកត់ត្រាសំឡេងឆ្នោត (ទ.๑๑๐๘) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.๑๑๐๒) ដែលមានក្នុងស្រោមសំបុត្រដូចមានចែងក្នុងចំណុច ๑๐.๑๒.๙.๑ នៃ ប.ន.ឃ.ស នេះ ក្នុងករណីចាំបាច់។

๑๑.๒.๘.๕ របាយការណ៍របស់ គយ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមានការបើកកញ្ចប់សុវត្ថិភាព "ក")។

๑๑.๒.๘.๖ សម្រង់សេចក្តីសម្រេច (ទ.๑๒๐๓) របស់ គយ.សប យល់ព្រម ឬបដិសេធលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ (ប្រសិនបើមាន)។

๑๑.๒.๘.๗ ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលបានដាក់នៅ គធ.ខប ដូចមានចែងក្នុងចំណុច ๑๑.๔.๗ ខាងក្រោមនេះ (ប្រសិនបើមាន)។

๑๑.๒.๘.๘ របាយការណ៍បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប (ប្រសិនបើ គធ.ខប សម្រេចឱ្យធ្វើដូច្នេះ)។

๑๑.๒.๙ គ.ជ.ប ត្រូវផ្តត់ផ្គង់សម្ភារ បរិក្ខារ កុំព្យូទ័រ និងសម្ភារចាំបាច់នានាផ្សេងទៀតដល់ គធ.ខប សម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ការបែងចែកអាសនៈ ការស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត និងកំណត់ឈ្មោះសមាជិក កបយ.ស ដែលត្រូវទទួលតំណែងជាប្រធាន កបយ.ស ជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២។

๑๑.๒.๙.๑ អគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវផ្តល់ការគាំទ្រដល់ គធ.ខប អំពីការអនុវត្តកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត និងការប្រើអ៊ីនធឺណិត។

๑๑.๒.๙.๒ គធ.ខប ត្រូវប្រើអ៊ីនធឺណិតសម្រាប់តែការបញ្ជូនសារ លិខិតស្នាម ព័ត៌មានបន្ទាន់ និងទិន្នន័យបច្ចេកទេសក្នុងការបោះឆ្នោតប៉ុណ្ណោះ។

๑๑.๒.๙.๓ គ.ជ.ប ត្រូវធានាឱ្យមានទិន្នន័យបញ្ជីបេក្ខជនផ្លូវការនៃគណបក្ស នយោបាយឈរឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ចំណុះរាជធានី ខេត្តពាក់ព័ន្ធនៅក្នុងកម្មវិធីកុំព្យូទ័រ។

๑๑.๒.๑๐ ផ្អែកតាមការណែនាំរបស់ គធ.ខប ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវអនុវត្ត ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ដោយត្រូវបំពេញការងារពាក់ព័ន្ធតាមការចាំបាច់ និងតាមលំដាប់លំដោយនៃ ករណីដាក់ស្នើងនីមួយៗដូចខាងក្រោម៖

๑๑.๒.๑๐.๑ ករណីឃុំ សង្កាត់ណាដែលគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គយ.សប និងនៅ គធ.ខប។

๑๑.๒.๑๐.๒ ករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដាក់នៅ គយ.សប និងមានកញ្ចប់សុវត្ថិភាព “ក” ត្រូវបានបើក ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ហើយ គយ.សប បានយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងនោះ និងករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹង ជំទាស់ត្រូវបានដាក់នៅ គធ.ខប។

๑๑.๒.๑๐.๓ ករណីឃុំ សង្កាត់ណាដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ๐,๕ ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ហើយករណីឃុំ សង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹង ជំទាស់ ត្រូវបានដាក់នៅ គធ.ខប។

๑๑.๒.๑๑ គធ.ខប ត្រូវប្រគល់ការកិច្ចជូនសមាជិក គធ.ខប ដែលជាប្រធានផ្នែកប្រតិបត្តិការ បោះឆ្នោត និងបច្ចេកទេសដឹកនាំផ្ទាល់ក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប ដែលមាន មន្ត្រីផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេស ๑ (មួយ) រូប មន្ត្រីផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ๑ (មួយ) រូប និងមន្ត្រីមួយចំនួនទៀតតាមការចាំបាច់ ជាសមាជិក និងលេខាធិការ ๑ (មួយ) រូប។ ក្នុងចំណោមសមាជិកក្រុមត្រូវតែមាន អ្នកមានចំណេះដឹងផ្នែកកុំព្យូទ័រ និងការប្រើអ៊ីនធឺណិត។ ក្រុមនេះមានការទទួលខុសត្រូវ និងភារកិច្ច ជាអាទិ៍ផ្ទៀងផ្ទាត់បន្ថែមនូវតួលេខលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ក្នុងឃុំ សង្កាត់កំណត់ចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបាន ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបយ.ស និងកំណត់ឈ្មោះសមាជិក កបយ.ស ដែលត្រូវទទួលតំណែងជាប្រធាន កបយ.ស និងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី๑ ឬ ចៅសង្កាត់រងទី๑ និងជំទប់ទី២ ឬចៅសង្កាត់រងទី២។

ការប្រគល់ និងការទទួលកញ្ចប់ "គ ពិសេស" ស្បោង "គ" ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតនៅ លគធ.ខប ប្រការ១១.៣.

នៅពេលមកដល់មជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នៃ គធ.ខប ភ្លាម ប្រធាន គយ.សប ត្រូវប្រគល់ទៅឱ្យក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប នូវរាល់កញ្ចប់ "គ ពិសេស" រាល់ស្បោង "គ" ឬ/និងស្បោង "គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក" រាល់ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ និងរាល់កញ្ចប់ដែលមានវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត។ ប្រធាន គយ.សប ត្រូវប្រគល់ទៅឱ្យក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប នូវលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ពាក់ព័ន្ធ។

១១.៣.១ នៅពេលប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត មន្ត្រីទទួលបន្ទុក ទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ត្រូវជានាថា កញ្ចប់ "គ ពិសេស" ស្បោង "គ" ឬ/និងស្បោង "គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក" ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ទាំងអស់ និងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដូចមានចែងក្នុងប្រការ១០.១៤ នៃ ប.ន.ឃ.ស នេះ ត្រូវបានពិនិត្យ និងផ្ទៀងផ្ទាត់ត្រឹមត្រូវ ដោយផ្អែកលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដែលមាននៅក្នុងកញ្ចប់ "គ ពិសេស" ស្បោង "គ" ឬ/និងស្បោង "គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក" និងស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ និងស្បោងទាំងនោះ និងដែលប្រធាន គយ.សប បានប្រគល់ជូនដូចមានចែងក្នុងប្រការ១១.៣ ខាងលើនេះ។ បន្ទាប់ពីបានត្រួតពិនិត្យឃើញថាត្រឹមត្រូវហើយ ក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំងនេះបញ្ជាក់ថាបានទទួលគ្រប់ចំនួនហើយ។

១១.៣.២ ក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ត្រូវកត់ត្រាមុខសម្ភារ ឯកសារបោះឆ្នោតដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីទទួលសម្ភារ ឯកសារបោះឆ្នោតរបស់ខ្លួន និងត្រូវចារសម្គាល់ថា "ការប្រគល់គ្រប់ចំនួន" បន្ទាប់មកត្រូវចាត់ចែងប្រើប្រាស់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដែលបានចុះហត្ថលេខារួចដូចមានចែងក្នុងចំណុច ១១.៣.១ ខាងលើនេះ ដូចខាងក្រោម៖

- ១១.៣.២.១ ប្រគល់ជូនប្រធាន គយ.សប ១ (មួយ) ច្បាប់។
- ១១.៣.២.២ ដក ១ (មួយ) ច្បាប់ ទុកជាឯកសារ។
- ១១.៣.២.៣ ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅកញ្ចប់ "គ ពិសេស" ស្បោង "គ" ឬ/និងស្បោង "គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក" និងស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ។

១១.៣.៣ បន្ទាប់ពីបានអនុវត្តចំណុច ១១.៣.២ ខាងលើនេះរួច ក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ត្រូវប្រគល់រាល់សម្ភារ ឯកសារបោះឆ្នោតដែលបានទទួលទាំងអស់ឱ្យសហការីរបស់ខ្លួនដែលទទួលបន្ទុករក្សាស្តុកនាំយកកញ្ចប់ "គ ពិសេស" ស្បោង "គ" ឬ/និងស្បោង "គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក" និងស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ទៅរក្សាទុកនៅក្នុងបន្ទប់ដូចមានចែងក្នុងចំណុច ១១.២.១.២ ខាងលើនេះ និងនាំយកសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទៅរក្សាទុកនៅក្នុងបន្ទប់ដូចមានចែងក្នុងចំណុច ១១.២.១.៣ ខាងលើនេះ។ មន្ត្រីទទួលបន្ទុករក្សាស្តុកត្រូវបែងចែក និងរក្សាមុខសម្ភារ ឯកសារបោះឆ្នោតដោយឡែកពីគ្នាទៅតាមឃុំ សង្កាត់ ព្រមទាំងត្រូវសរសេរសម្គាល់លេខកូដឃុំ សង្កាត់នីមួយៗផង។

១១.៣.៤ នៅក្នុងពេលអនុវត្តចំណុច ១១.៣.១ ខាងលើនេះ ក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ដូចខាងក្រោម៖

- ១១.៣.៤.១ កាត់សោឃ្លុំមាត់ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោតម្តងមួយៗ ដោយត្រូវពិនិត្យលេខកូដរាជធានី ខេត្ត លេខកូដឃុំ សង្កាត់ និងលេខកូដការិយាល័យបោះឆ្នោត ព្រមទាំងកិនកាគ ស្លាកស្នាម ឬស្ថានភាពបិទភ្ជិតនៃស្រោមសំបុត្រ ដើម្បីធានាថាគ្មានការរុះរើ រើបក ឬរហែក លើកលែងតែករណីការិយាល័យបោះឆ្នោតដែល គឃ.សប សម្រេចបើកកញ្ចប់សុវត្ថិភាព "ក" (ប្រសិនបើមាន)។
- ១១.៣.៤.២ ករណីក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ពិនិត្យឃើញថា ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោតត្រូវបានរុះរើ រើបក ឬមានស្នាមរហែក ប្រធានក្រុមត្រូវស្នើឱ្យប្រធាន គឃ.សប ធ្វើការឆ្លើយបំភ្លឺ ដោយត្រូវធ្វើកំណត់ហេតុឬរបាយការណ៍ឱ្យបានច្បាស់លាស់។ ប្រសិនបើហេតុផលដែលផ្តល់ជូនដោយ គឃ.សប ពុំមានមូលដ្ឋានដែលអាចជឿបាន គធ.ខប ត្រូវរាយការណ៍ជាបន្ទាន់អំពីករណីនេះជូន គ.ជ.ប។
- ១១.៣.៤.៣ ករណីស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោតមានស្ថានភាពបិទភ្ជិតត្រឹមត្រូវ ច្បាស់លាស់ដូចមានចែងក្នុង ប.ន.ឃ.ស នេះ និងមានចំនួនគ្រប់គ្រាន់ ក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ត្រូវដាក់ស្រោមសំបុត្រនេះចូលទៅក្នុងស្បោងដើមវិញ រួចចងភ្ជិតមាត់ស្បោង និងនាំយកទៅរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព ត្រៀមសម្រាប់រៀបខ្ចប់បញ្ជូនទៅ គ.ជ.ប។

១១.៣.៥ ប្រសិនបើនៅក្នុងការប្រគល់ និងការទទួលសម្ភារ ឯកសារបោះឆ្នោតពី គឃ.សប ណាមួយ ដូចមានចែងក្នុងប្រការ១១.៣ ខាងលើនេះ មានស្បោង "គ" មួយ ឬច្រើន ត្រូវបានសរសេរ សម្គាល់ថា "មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក" នោះ នៅពេលកំពុងអនុវត្ត នីតិវិធីចំណុច ១១.៣.២ ខាងលើនេះ ក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ត្រូវចារបន្ថែមក្នុងបញ្ជីទទួលសម្ភារ ឯកសារបោះឆ្នោតរបស់ខ្លួនថា "មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក"។ ក្នុងករណីនេះ ក្រុមទទួលបន្ទុកការទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ត្រូវ៖

- ១១.៣.៥.១ ស្រង់កត់ត្រាឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ហើយដែលមានកញ្ចប់សុវត្ថិភាព "ក" មួយ ឬច្រើនត្រូវបានបើកដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។
- ១១.៣.៥.២ យកកញ្ចប់ "គ ពិសេស" និងស្បោង "គមានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក" និងស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធទៅរក្សាទុកដោយឡែកនៅក្នុងបន្ទប់ស្តុក ដើម្បីងាយស្រួលរក។

១១.៣.៦ ក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ត្រូវរាយការណ៍អំពីចំនួនកញ្ចប់ "គ ពិសេស" ស្បោង "គ" ឬ/និងស្បោង "គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក" ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ និងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដែលបានទទួលពីគ្រប់ឃុំ សង្កាត់ចំណុះរាជធានី ខេត្តរួចហើយ និងបញ្ជាក់ច្បាស់នូវឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានពាក្យបណ្តឹងដូចមានចែងក្នុងចំណុច ១១.៣.៥.១ ខាងលើនេះ ជូន គធ.ខប ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ឱ្យត្រួតពិនិត្យលទ្ធផលទៅតាមករណីជាក់ស្តែងនីមួយៗ។

១១.៣.៧ ក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ត្រូវយកស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) តាមឃុំ សង្កាត់ ដើម្បីបញ្ជូនឱ្យប្រធាន គធ.ខប ចាត់ចែងបូកសរុបចំនួនអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន រួចបញ្ជូនមក គ.ជ.ប។

ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទៅ គជ.ខប ទាក់ទងនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយឬច្រើនក្នុងឃុំ សង្កាត់

ប្រការ១១.៤.

ជនគ្រប់រូបដែលបានចុះឈ្មោះបោះឆ្នោតនៅលើបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ឬតំណាង ដែលមានកស្តុតាងច្បាស់លាស់បញ្ជាក់អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងដំណើរការបោះឆ្នោតដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅ គជ.ខប អំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ឬការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់ពាក់ព័ន្ធ។

១១.៤.១ រាល់ការប្តឹងតវ៉ា ឬការប្តឹងជំទាស់ដូចមានចែងក្នុងប្រការ១១.៤ ខាងលើនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ទៅ គជ.ខប ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃ គយ.សប បិទផ្សាយកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ហើយ គជ.ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងទាំងនេះក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។

១១.៤.២ ប្រសិនបើនៅក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ១១.៤.១ ខាងលើនេះ គជ.ខប មិនបានទទួលពាក្យបណ្តឹងណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ចំណុះរាជធានី ខេត្តពាក់ព័ន្ធ។

១១.៤.៣ ជនគ្រប់រូបដែលបានចុះឈ្មោះបោះឆ្នោតនៅលើបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់ ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ ឬតំណាងដែលមានបំណងប្តឹងតវ៉ា ឬប្តឹងជំទាស់ដូចមានចែងក្នុងប្រការ១១.៤ ខាងលើនេះ ត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ចុះហត្ថលេខា ឬផ្តិតមេដៃលើពាក្យបណ្តឹងដែលក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

- ១១.៤.៣.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង។
- ១១.៤.៣.២ លក្ខណៈសម្គាល់នៃ គយ.សប ឬ/និងការិយាល័យបោះឆ្នោត។
- ១១.៤.៣.៣ កម្មវត្ថុនៃបណ្តឹង។
- ១១.៤.៣.៤ មូលហេតុនៃការប្តឹង។
- ១១.៤.៣.៥ ពេលវេលានៃការកើតឡើងនូវភាពមិនប្រក្រតី។

១១.៤.៣.៦ ប្រសិនបើអាចធ្វើបានត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ឃ.ស ឬ ច.វ.ច.ប ឬប្រការនៃ ប.ន.ឃ.ស ដែលត្រូវបានរំលោភ។

១១.៤.៣.៧ មនុស្សដែលពាក់ព័ន្ធក្នុងភាពមិនប្រក្រតីនេះ។

១១.៤.៣.៨ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)។

១១.៤.៣.៩ សេចក្តីអះអាងគាំទ្រ ឬកស្តុតាងផ្សេងទៀត (ប្រសិនបើមាន)។

១១.៤.៣.១០ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង (ប្រសិនបើមាន)។

១១.៤.៤ នៅពេលបានទទួលពាក្យបណ្តឹង សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍ដូចខាងក្រោម៖

- ទី១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- ទី២- កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។

១១.៤.៥ បន្ទាប់មកសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនោះ។

១១.៤.៦ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

១១.៤.៦.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ១១.៤.១ ខាងលើនេះ ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ និងបោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងជម្រាបអ្នកប្តឹង ឬតំណាងថាពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយរយៈពេលកំណត់ គធ.ខប មិនអាចទទួលយកមកដោះស្រាយបានទេ។

១១.៤.៦.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ១១.៤.៣ ខាងលើនេះ ឬ/និងមិនមានលិខិតប្រគល់សិទ្ធិ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ គធ.ខប ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសរយៈពេលនៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១១.៤.៦.៣ ពាក្យបណ្តឹងគោរពរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ១១.៤.៣ ខាងលើនេះ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង ចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅ លគធ.ខប ១ (មួយ) ច្បាប់ និងរក្សាទុកសម្រាប់ គធ.ខប ប្រើក្នុងពេលប្រជុំសម្រេច ១ (មួយ) ច្បាប់។ បន្ទាប់មក ជម្រាបអ្នកប្តឹង ឬតំណាងថា គធ.ខប នឹងប្រជុំសម្រេចលើពាក្យបណ្តឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប បានបញ្ចប់ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ។

១១.៤.៧ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវរាយការណ៍អំពីករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ខាងលើនេះជូនប្រធាន គធ.ខប ជាបន្ទាន់ ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ឱ្យត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានពាក្យបណ្តឹងនោះនៅចំពោះមុខតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកប្តឹង ឬតំណាង។ ប្រសិនបើចាំបាច់ គធ.ខប ត្រូវបង្គាប់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ឱ្យបើកកញ្ចប់សុវត្ថិភាព “ក” នៃការិយាល័យបោះឆ្នោតដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរបស់សន្លឹកឆ្នោតឡើងវិញ។

កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្នៃការបោះឆ្នោតនៅឃុំ សង្កាត់

ប្រការ១១.៥._

បន្ទាប់ពីបានទទួលកញ្ចប់ “គ ពិសេស” ស្បោង “គ” ឬ/និងស្បោង “គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក” និងស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់មួយចំនួនហើយ គធ.ខប ត្រូវចាត់វិធានការជាបណ្តើរៗ ឱ្យក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ដែលខ្លួនទទួលបន្ទុកតាមករណីនីមួយៗដោយឡែកពីគ្នា ទាំងឃុំ សង្កាត់គ្មានពាក្យបណ្តឹង ទាំងឃុំ សង្កាត់មានពាក្យបណ្តឹងឱ្យរួចរាល់ឆាប់រហ័សតាមដែលអាចធ្វើបាន និងមិនត្រូវឱ្យហួសរយៈពេល ៥ (ប្រាំ) ថ្ងៃឡើយ ដោយគិតចាប់ពីថ្ងៃបានទទួលកញ្ចប់ “គ ពិសេស” ស្បោង “គ” ឬ/និងស្បោង “គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក” និងស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ។

១១.៥.១ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត អ្នកសារព័ត៌មាន និងអ្នកប្តឹង ឬតំណាងត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលរាល់ដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ចំណុះរាជធានី ខេត្តនៅមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ នៃ គធ.ខប។

១១.៥.១.១ គណបក្សនយោបាយនីមួយៗនៅតាមឃុំ សង្កាត់ទាំងអស់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោតនីមួយៗក្នុងរាជធានី ខេត្ត ត្រូវជ្រើសតាំងឱ្យមានតំណាងពេញសិទ្ធិ និងតំណាងបម្រុងរបស់ខ្លួនតាមចំនួនដែល គធ.ខប បានកំណត់ដែលអាចចូលរួមគ្រប់គ្រាន់ល្មមក្នុងការសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ព្រមទាំងអ្នកសារព័ត៌មានផងដែរ។

១១.៥.១.២ តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍បោះឆ្នោតដែលត្រូវចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប នីមួយៗអាចផ្លាស់ប្តូរតំណាងបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួន។

១១.៥.១.៣ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកប្តឹង ឬតំណាងត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មមដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត។

១១.៥.១.៤ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកប្តឹង ឬតំណាងអាចថតយករូបភាពនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងរាជធានី ខេត្តបាន ប៉ុន្តែមិនត្រូវបង្កការអុកឡុក ការរំខាន ការជ្រៀតជ្រែក ឬការធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ។

១១.៥.២ កិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ប្រសិនបើចាប់ដំណើរការហើយត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ជាពិសេសចំពោះឃុំ សង្កាត់មានពាក្យបណ្តឹងទាក់ទងនឹងភាពមិនប្រក្រតីធ្ងន់ធ្ងរដែលតម្រូវឱ្យក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប បើកកញ្ចប់សុវត្ថិភាព “ក” មួយ ឬច្រើន ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។

១១.៥.៣ គធ.ខប ត្រូវចាត់ចែងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត នៅបន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើននៃមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នៃ គធ.ខប ដែលបានបង្កើតឡើងក្នុងប្រការ១១.២ នៃ ប.ន.ឃ.ស នេះ។ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ពីរ ឬច្រើនក្រុមអាចបំពេញការងារនៅតាមតុរៀងខ្លួនក្នុងបន្ទប់តែមួយ ឬនៅតាមបន្ទប់ដោយឡែកពីគ្នា ដោយយោងតាមលទ្ធភាពជាក់ស្តែងរបស់រាជធានី ខេត្ត។ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប នីមួយៗត្រូវរៀបចំគំរូប្លង់បន្ទប់តាមលំនាំប្លង់ការិយាល័យរាប់សន្លឹកឆ្នោតដូចមានចែងក្នុងចំណុច ១០.២.១ នៃ ប.ន.ឃ.ស នេះ និងត្រូវមានសម្ភារ ឯកសារបោះឆ្នោត និងទម្រង់បែបបទគ្រប់គ្រាន់សម្រាប់បំពេញការងារ។

១១.៥.៣.១ ក្នុងការត្រួតពិនិត្យលទ្ធផលខាងលើនេះ ប្រធានក្រុមត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខប្រធានក្រុម ហើយឱ្យអនុប្រធានក្រុម និងជំនួយការអង្គុយនៅអមសងខាងតុទល់មុខគ្នា។

១១.៥.៣.២ ប្រធានក្រុមត្រូវត្រៀមនៅក្បែរខ្លួនគាត់នូវពាក្យបណ្តឹង (ទ.១២០២) សម្រាប់ប្រគល់ជូនតំណាងគណបក្សនយោបាយ ឬអ្នកប្តឹង ដើម្បីបំពេញពាក្យបណ្តឹង ប្រសិនបើមានការស្នើសុំ និងរាល់ទម្រង់បែបបទចាំបាច់ផ្សេងទៀតសម្រាប់ប្រើក្នុងការត្រួតពិនិត្យលទ្ធផលនេះ។

១១.៥.៣.៣ ប្រធានក្រុមត្រូវជានាឱ្យមានម៉ាស៊ីនគិតលេខ ១ (មួយ) គ្រឿង សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលនេះ។

១១.៥.៤ គជ.ខប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ឱ្យត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ចំណុះរាជធានី ខេត្តដោយឡែកពីគ្នា និងតាមលំដាប់លំដោយនៃករណីជាក់ស្តែងនីមួយៗដូចមានចែងជាបន្តបន្ទាប់គ្នាក្នុងចំណុច ១១.២.១០.១ ចំណុច ១១.២.១០.២ និងចំណុច ១១.២.១០.៣ នៃ ប.ន.ឃ.ស នេះ។ ប្រសិនបើលក្ខខណ្ឌតម្រូវ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប អាចធ្វើការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ពាក់ព័ន្ធដោយគួបផ្សំការអនុវត្តនីតិវិធីសម្រាប់ករណីលើសពីមួយស្របពេលជាមួយគ្នា។

ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គយ.សប និងនៅ គជ.ខប ប្រការ១១.៦.

ក្នុងករណីឃុំ សង្កាត់ណាដែលគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គយ.សប និងនៅ គជ.ខប ដូចមានចែងក្នុងចំណុច ១១.២.១០.១ នៃ ប.ន.ឃ.ស នេះ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប មិនអាចបើកកញ្ចប់សុវត្ថិភាព “ក” ណាមួយ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ។ ក្នុងករណីនេះ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប គ្រាន់តែធ្វើការត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ដោយផ្អែកលើកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ប៉ុណ្ណោះ ព្រមទាំងផ្ទៀងផ្ទាត់បន្ថែមជាមួយទិន្នន័យតួលេខលទ្ធផលដែលមានស្រាប់ក្នុងកម្មវិធីកុំព្យូទ័រ ឬនៅក្នុងយូអេសប៊ីផ្លាសដ្រាយ (USB Flash Drive) រក្សាទុកទិន្នន័យ។

ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ត្រូវត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានរក្សាទុកក្នុងកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ឬនៅក្នុងយូអេសប៊ីផ្លាសដ្រាយ (USB Flash Drive) រក្សាទុកទិន្នន័យ ធៀបជាមួយកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ដែលបានទទួលពី គយ.សប។

១១.៦.១ ក្នុងដំណើរការនៃការត្រួតពិនិត្យលទ្ធផលក្នុងករណីខាងលើ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ត្រូវចាត់ចែងអនុវត្តតាមនីតិវិធីដូចខាងក្រោម ដោយត្រូវ៖

១១.៦.១.១ បង្គាប់ជំនួយការឱ្យនាំយកកញ្ចប់ “គ ពិសេស” នៃឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងម្តងមួយៗពីកន្លែងរក្សាស្តុកមកដាក់នៅលើតុចំពីមុខប្រធានក្រុម។

๑๑.๖.๑.๒ បើកកញ្ចប់ "គ ពិសេស" រួចដកយកស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.๑๑๐๓) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.๑๑๐๙) ស្រោមសំបុត្រដាក់យូអេសប៊ីផ្លាសដ្រាយ (USB Flash Drive) រក្សាទុកទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងរាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.๑๑๐๑) តារាងកត់ត្រាសំឡេងឆ្នោត (ទ.๑๑๐๘) និងកំណត់ហេតុការរាប់សន្លឹកឆ្នោត (ទ.๑๑๐๒) ដែលផ្ញើជូន គធ.ខប មកដាក់នៅលើតុ។

๑๑.๖.๑.๓ បញ្ជាប់ចូល (Login) ក្នុងកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ដើម្បីទាញយកទិន្នន័យពីសេវ៉ូបករណ៍ (Server) គ.ជ.ប ឬពីយូអេសប៊ីផ្លាសដ្រាយ (USB Flash Drive) រក្សាទុកទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដើម្បីបង្ហាញលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់លើឧបទស្សន៍កុំព្យូទ័រ (Monitor) ដើម្បីឱ្យភាគីពាក់ព័ន្ធដែលមានវត្តមានបានមើលឃើញទាំងអស់គ្នា។

๑๑.๖.๑.๔ ចាត់ចែងសមាជិកក្នុងក្រុមឱ្យត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ក្នុងកម្មវិធីកុំព្យូទ័រ ធៀបនឹងកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.๑๑๐๓) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.๑๑๐๙)។ ក្នុងករណីមានភាពមិនច្បាស់លាស់ក្នុងការត្រួតពិនិត្យនេះ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវផ្ទៀងផ្ទាត់បន្ថែមជាមួយនឹងកំណត់ហេតុនៃការបោះឆ្នោត (ទ.๑๑๐๑) តារាងកត់ត្រាសំឡេងឆ្នោត (ទ.๑๑๐๘) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.๑๑๐๒) នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

๑๑.๖.๑.๕ ធានាថាតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.๑๑๑๖តព) ចំនួន ๒ (ពីរ) ច្បាប់ ដែលត្រូវបោះពុម្ពចេញត្រូវបានផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវជាមួយគ្នា និងត្រូវមានបញ្ជាក់ឈ្មោះ និងលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ។

១១.៦.១.៦ ជានាថាតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ខាងលើទាំង ២ (ពីរ) ច្បាប់ មានបញ្ជាក់ច្បាស់នូវខ្លឹមសារដូចខាងក្រោម ប្រសិនបើបានរកឃើញថា៖

- តួលេខនៃលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់មានភាពត្រឹមត្រូវ
- គយ.សប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ហើយកំហុសនោះ ត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប
- បញ្ជីបេក្ខជនពីរ ឬច្រើនទទួលបានសន្លឹកឆ្នោតគាំទ្រស្មើគ្នាក្នុងការបោះឆ្នោតនៅឃុំ សង្កាត់នោះ។

១១.៦.១.៧ ក្នុងករណីក្រុមត្រួតពិនិត្យលទ្ធផលបានរកឃើញកំហុសក្នុងការគណនាបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ប្រធានក្រុមត្រូវបង្ហាញកំហុស និងការកែតម្រូវកំហុសព្រមទាំងហេតុផលនៃការកែតម្រូវនោះចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមាន។ ក្នុងការកែតម្រូវកំហុសនេះ ប្រធានក្រុមត្រូវឆូតលើតួលេខដែលខុសតែមិនត្រូវធ្វើឱ្យបាត់លក្ខណៈសម្គាល់នៃតួលេខដើមនោះទេ រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង។ កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ឬ/និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ឬ/និងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ឬ/និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ឬ/និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធដែលបានកែសម្រួលរួចហើយ ត្រូវតែបានស្នែនបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រ ទន្ទឹមនេះត្រូវកែតម្រូវតួលេខទាំងនេះនៅក្នុងកម្មវិធីកុំព្យូទ័រផងដែរ។ តំណាងគណបក្សនយោបាយមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ក្នុងករណីមិនពេញចិត្តនឹងការកែតម្រូវរបស់ប្រធានក្រុម។

១១.៦.១.៨ ធានាថាតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ខាងលើ ត្រូវបានចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប។

១១.៦.១.៩ ធានាថាតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ខាងលើនេះ ត្រូវបានដាក់ភ្ជាប់ទៅនឹងកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) រួចដាក់ទៅក្នុងស្រោមសំបុត្រដដែលត្រៀមដាក់ជូន គធ.ខប តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ដើម្បីពិនិត្យ សម្រេច។

១១.៦.២ គធ.ខប ត្រូវពិនិត្យ សម្រេចលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដែលបានដាក់ជូនដូចមានចែងក្នុងចំណុច ១១.៦.១.៩ ខាងលើនេះ។ ប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយ ប្រធាន គធ.ខប ត្រូវចារឯកភាព រួចចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងកាលបរិច្ឆេទ និងដាក់បង្ហាញចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍បោះឆ្នោត ហើយត្រូវ៖

១១.៦.២.១ ប្រគល់តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ដែលចារឯកភាពខាងលើនេះ ១ (មួយ) ច្បាប់ និងរាល់សំណុំឯកសារពាក់ព័ន្ធជូនក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដើម្បីដាក់ទៅក្នុងកញ្ចប់ "គ ពិសេស" រក្សាទុកជាឯកសារនៅ គធ.ខប។

១១.៦.២.២ ប្រគល់តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ដែលចារឯកភាពខាងលើនេះ ១ (មួយ) ច្បាប់ ជូនក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប ដែលត្រូវបន្តអនុវត្តតាមនីតិវិធីដូចមានចែងក្នុងប្រការ១១.៩ នៃ ប.ន.ឃ.ស នេះ។

១១.៦.៣ ប្រធាន គធ.ខប ត្រូវធានាថានៅរៀងរាល់ពេលនៃកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗរួចរាល់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប បានដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ចូលទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់

ដែលមានកាខ្នងថា “កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ផ្ញើជូន គ.ជ.ប” ដើម្បីគាត់ប្រមូលផ្តុំដាក់ទៅក្នុងកញ្ចប់ “ឃ ពិសេស” ដែលត្រៀមបម្រុងជាស្រេចដូចមានចែងក្នុងចំណុច ១១.១១.២ នៃ ប.ន.ឃ.ស នេះ។

១១.៦.៤ ប្រធាន គធ.ខប ត្រូវធានាថាតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត (ទ.១១១៦តព) ១ (មួយ) ច្បាប់ និងឯកសារពាក់ព័ន្ធដូចមានចែងក្នុងចំណុច ១១.៦.១.៤ ខាងលើនេះ ដែលបានប្រើក្នុងការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត និងដាក់ជូន គធ.ខប ពិនិត្យ សម្រេចរួចហើយ ត្រូវបានក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដាក់ទៅក្នុងស្រោមសំបុត្រដូចដើម និងវេចខ្ចប់ក្នុងកញ្ចប់ “គ ពិសេស” រួចយកទៅរក្សាទុកនៅកន្លែងស្តុកវិញ ដែលត្រូវរក្សាទុកជាឯកសាររបស់ គធ.ខប។

១១.៦.៥ គធ.ខប ត្រូវធានាថាការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលគ្មានពាក្យបណ្តឹងទាំងអស់ចំណុះរាជធានី ខេត្ត ត្រូវបានអនុវត្តម្តងមួយឃុំ សង្កាត់ ហើយរាល់នីតិវិធីដូចមានចែងចាប់ពីចំណុច ១១.៦.១ រហូតដល់ចំណុច ១១.៦.៤ ខាងលើនេះត្រូវតែបានអនុវត្ត។

ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប មានការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅ គឃ.សប និងដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដាក់នៅ គធ.ខប ប្រការ១១.៧.

ក្នុងករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប មានកញ្ចប់សុវត្ថិភាព “ក” មួយ ឬច្រើនត្រូវបានបើកដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅ គឃ.សប មានសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គឃ.សប យល់ព្រម ឬបដិសេធលើពាក្យបណ្តឹងនោះ និងដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ដូចមានចែងក្នុងចំណុច ១១.២.១០.២ នៃ ប.ន.ឃ.ស នេះ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ក៏ត្រូវធ្វើការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះផងដែរ។ ក្នុងករណីនេះ នីតិវិធីដូចមានចែងក្នុងចំណុច ១១.៦.១ និងចំណុច ១១.៦.៣ ខាងលើនេះ ត្រូវតែបានអនុវត្ត ប៉ុន្តែក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវអនុវត្តបន្ថែមតាមលក្ខខណ្ឌដូចខាងក្រោម៖



១១.៧.១ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវត្រួតពិនិត្យជាមុននូវសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គឃ.សប លើពាក្យបណ្តឹងពាក់ព័ន្ធ របាយការណ៍របស់ គឃ.សប

ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត និងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងឃុំ សង្កាត់ ដែលបានដាក់នៅ គធ.ខប ហើយត្រូវស្នើសុំយោបល់សម្រេចរបស់ គធ.ខប អំពីការអនុញ្ញាតឱ្យបើកឬមិនឱ្យបើកកញ្ចប់សុវត្ថិភាព“ក”នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

១១.៧.១.១ ផ្អែកតាមឯកសារខាងលើនេះ ក្នុងករណីគ្មានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលនាំឱ្យប៉ះពាល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត គធ.ខប មិនចាំបាច់តម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញឡើយ។


១១.៧.១.២ ផ្អែកតាមឯកសារខាងលើនេះ ក្នុងករណីមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលនាំឱ្យប៉ះពាល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ គធ.ខប ត្រូវសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។

១១.៧.២ ប្រសិនបើ គធ.ខប សម្រេចមិនឱ្យបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញដូចមានចែងក្នុងចំណុច ១១.៧.១.១ ខាងលើនេះទេ រាល់នីតិវិធីដូចមានចែងចាប់ពីចំណុច ១១.៦.១ រហូតដល់ចំណុច ១១.៦.៤ ខាងលើនេះត្រូវតែបានអនុវត្ត។

១១.៧.៣ ប្រសិនបើ គធ.ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញដូចមានចែងក្នុងចំណុច ១១.៧.១.២ ខាងលើនេះ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវអនុវត្តនីតិវិធីចំណុច ១១.៦.១ និងចំណុច ១១.៦.៣ ខាងលើនេះ ហើយបន្ទាប់មកប្រធានក្រុមត្រូវ៖

១១.៧.៣.១ បង្គាប់ជំនួយការឱ្យទៅនាំយកស្បោង “គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក” និងស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធពីបន្ទប់រក្សាស្តុកមកដាក់នៅលើតុចំពីមុខប្រធានក្រុម។

១១.៧.៣.២ បើកស្បោង “គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក” នោះ ដកយកស្បោង “ខ” ចេញមកក្រៅ រួចបើក និងដកយកកញ្ចប់សុវត្ថិភាព “ក” មកដាក់នៅលើតុ។



១១.៧.៣.៣ បើកកញ្ចប់សុវត្ថិភាព “ក” រួចដកយកកាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែលមាននៅខាងក្នុងមកដាក់ដោយឡែកពីគ្នានៅលើតុខាងមុខគាត់។

១១.៧.៣.៤ ប្រគល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ឱ្យទៅលេខាធិការសម្រាប់តាមដានពិនិត្យ ដោយប្រៀបធៀបទៅនឹងលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។

១១.៧.៣.៥ បើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតម្តងមួយៗ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់តាមនីតិវិធីដូចមានចែងក្នុងចំណុច ១១.៧.៤ ខាងក្រោមនេះ។

១១.៧.៣.៦ បើកស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ រួចដកយកស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោត ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់តាមនីតិវិធីដូចមានចែងក្នុងចំណុច ១១.៧.៤ ខាងក្រោមនេះ។

១១.៧.៤ នៅពេលមានកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវចាត់ចែងត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យនោះឡើងវិញតាមលំនាំនីតិវិធីដូចមានចែងក្នុងចំណុច ១០.១៣.២ នៃ ប.ន.ឃ.ស នេះ ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាក្នុងកម្មវត្ថុនៃបណ្តឹងពាក់ព័ន្ធ និងត្រូវពិនិត្យ ផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការ ដោយត្រូវអនុវត្តតាមលំនាំនីតិវិធីចាប់ពីចំណុច ១០.២.៦ រហូតដល់ចំណុច ១០.២.១២ នៃ ប.ន.ឃ.ស នេះ។

១១.៧.៥ ក្នុងករណី គធ.ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព "ក" នៃការិយាល័យបោះឆ្នោតលើសពីមួយ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវអនុវត្តតាមលំនាំនីតិវិធីដដែលដូចមានចែងក្នុងចំណុច ១១.៧.៣ និងចំណុច ១១.៧.៤ ខាងលើនេះ សម្រាប់កញ្ចប់សុវត្ថិភាព "ក" នីមួយៗ រហូតទាល់តែអស់កញ្ចប់សុវត្ថិភាព "ក" ដែលត្រូវបើក។

១១.៧.៦ បន្ទាប់ពីអនុវត្តការបើកកញ្ចប់សុវត្ថិភាព "ក" នៃការិយាល័យបោះឆ្នោតណាមួយ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញដូចមានចែងក្នុងចំណុច ១១.៧.៣ ចំណុច ១១.៧.៤ និងចំណុច ១១.៧.៥ ខាងលើនេះរួចរាល់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវចាត់ចែងអនុវត្តដូចខាងក្រោម៖

១១.៧.៦.១ ធ្វើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ចំនួន ២ (ពីរ) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប។ ក្នុងរបាយការណ៍នេះត្រូវតែមានលើកយោបល់ស្នើសុំ គធ.ខប ពិនិត្យ សម្រេច៖

- យល់ព្រមទទួលយកលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ/និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ
- កែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោត ឬ
- ព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដោយត្រូវបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ។

១១.៧.៦.២ ចារលើរបាយការណ៍របស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយបញ្ជាក់ខ្លឹមសារស្របទៅនឹងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដូចមានចែងក្នុងចំណុច ១១.៧.៦.១ ខាងលើនេះ។

១១.៧.៦.៣ ដាក់របាយការណ៍ដូចមានចែងក្នុងចំណុច ១១.៧.៦.១ ខាងលើនេះ សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គឃ.សប លើពាក្យបណ្តឹងពាក់ព័ន្ធ របាយការណ៍របស់ គឃ.សប ដូចមានចែងក្នុងចំណុច ១១.៧.៦.២ ខាងលើនេះ ភ្ជាប់ទៅនឹងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) និងសំណុំឯកសារពាក់ព័ន្ធ ដែលក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវដាក់ជូន គធ.ខប ពិនិត្យ សម្រេចដូចមានចែងក្នុងចំណុច ១១.៦.១.៩ ខាងលើនេះ។

១១.៧.៦.៤ ដាក់សម្ភារ ឯកសារបោះឆ្នោតទៅក្នុងស្បោងប្លាស្ទិក និងស្រោមសំបុត្រពាក់ព័ន្ធនានារួចវេចខ្ចប់ក្នុងកញ្ចប់សុវត្ថិភាព “ក” វិញតាមលំនាំដើម។ ទន្ទឹមនេះ បិទភ្ជិតស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតពាក់ព័ន្ធឡើងវិញ រួចដាក់ទៅក្នុងស្បោងដាក់បញ្ជីបោះឆ្នោតតាមលំនាំដើម។

១១.៧.៦.៥ ដាក់កញ្ចប់សុវត្ថិភាព “ក” ទៅក្នុងស្បោង “ខ” រួចចងភ្ជិត និងដាក់ស្បោង“ខ”ទៅក្នុងស្បោង“គ មានពាក្យបណ្តឹងរបើកកញ្ចប់សុវត្ថិភាពក” នៃឃុំ សង្កាត់ពាក់ព័ន្ធតាមលំនាំដើម ដែលត្រូវនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប។

១១.៧.៧ ផ្អែកលើរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ និងសំណុំឯកសារដូចមានចែងក្នុងចំណុច ១១.៧.៦.៣ ខាងលើនេះ ព្រមទាំងផ្អែកលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែល គធ.ខប បានទទួល គធ.ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធដោយត្រូវអនុវត្តតាមចំណុច ១១.៧.១១ រហូតដល់ចំណុច ១១.៧.១៤ ខាងក្រោមនេះ។

១១.៧.៨ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដូចមានចែងក្នុងចំណុច ១១.៤.៦.៣ នៃ ប.ន.ឃ.ស នេះ ត្រូវបានដាក់នៅ គធ.ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប បានធ្វើការត្រួតពិនិត្យរួចហើយតាមនីតិវិធីដូចមានចែងក្នុងប្រការ១១.៧ នេះនូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ គធ.ខប ត្រូវផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យរួចហើយនោះ ដើម្បីប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធ។

១១.៧.៩ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដូចមានចែងក្នុងចំណុច ១១.៤.៦.៣ នៃ ប.ន.ឃ.ស នេះ ត្រូវបានដាក់នៅ គធ.ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប បានធ្វើការត្រួតពិនិត្យរួចហើយតាមនីតិវិធីដូចមានចែងក្នុងប្រការ១១.៦ ខាងលើនេះ នូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ គធ.ខប ត្រូវធានាថារាល់នីតិវិធីដូចមានចែងក្នុងចំណុច ១១.៧.៣ រហូតដល់ចំណុច ១១.៧.៧ ខាងលើនេះ ត្រូវតែបានអនុវត្តនៅមុនពេល គធ.ខប ប្រជុំសម្រេចលើពាក្យបណ្តឹង។

១១.៧.១០ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដូចមានចែងក្នុងចំណុច ១១.៤.៦.៣ ខាងលើនេះពាក់ព័ន្ធនឹងឃុំ សង្កាត់ដែលមិនទាន់បានត្រួតពិនិត្យ គធ.ខប ត្រូវធានាថារាល់នីតិវិធីដូចមានចែងក្នុងចំណុច ១១.៦.១ ចំណុច ១១.៦.៣ ចំណុច ១១.៧.៣ ចំណុច ១១.៧.៤ ចំណុច ១១.៧.៥ ចំណុច ១១.៧.៦ និងចំណុច ១១.៧.៧ ខាងលើនេះ ត្រូវតែបានអនុវត្តនៅមុនពេល គធ.ខប ប្រជុំសម្រេចលើពាក្យបណ្តឹង។

ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់

១១.៧.១១ ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ គធ.ខប ត្រូវបដិសេធការសម្រេចរបស់ គឃ.សប ដែលបានយល់ព្រមតាមពាក្យបណ្តឹងពាក់ព័ន្ធ និងបដិសេធពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលបានដាក់នៅ គធ.ខប។ ប្រធាន គធ.ខប ត្រូវ៖

- ១១.៧.១១.១ ចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) និងលើរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ឬ/និងលើរបាយការណ៍របស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដែលបានដាក់ភ្ជាប់ជាមួយសំណុំឯកសារពាក់ព័ន្ធជូន គធ.ខប ពិនិត្យ សម្រេចដូចមានចែងក្នុងចំណុច ១១.៧.៦.៣ ខាងលើនេះ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គធ.ខប ព្រមទាំងដាក់បង្ហាញចំពោះមុខអ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមាន។
- ១១.៧.១១.២ ចារបដិសេធលើសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គឃ.សប ដែលបានយល់ព្រមតាមពាក្យបណ្តឹងពាក់ព័ន្ធ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គធ.ខប។
- ១១.៧.១១.៣ ធានាថាសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតបានបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ និងត្រូវបដិសេធពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលដាក់នៅ គធ.ខប ដោយបញ្ជាក់ច្បាស់អំពីមូលហេតុ ហើយត្រូវចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គធ.ខប ដោយសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត និងប្រធាន គធ.ខប។

១១.៧.១១.៤ ប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយឈរឈ្មោះក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១១.៧.១១.៥ ជម្រាបអ្នកប្តឹង ឬតំណាងថាគាត់មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប នៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប។

១១.៧.១១.៦ ប្រគល់ពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ជូនអ្នកប្តឹង ឬតំណាង ប្រសិនបើគាត់ស្នើសុំ។

១១.៧.១១.៧ ប្រគល់រាល់ឯកសារដូចមានចែងក្នុងចំណុច ១១.៧.១១.១ ចំណុច ១១.៧.១១.២ និងចំណុច ១១.៧.១១.៤ ខាងលើនេះ ក្នុងមួយមុខ ១ (មួយ) ច្បាប់ ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដាក់ក្នុងកញ្ចប់ “គ ពិសេស” ដើម្បីរក្សាទុកជាឯកសារនៅ គធ.ខប និងត្រៀមសម្រាប់ផ្ញើជូន គ.ជ.ប។

១១.៧.១១.៨ ប្រគល់រាល់ឯកសារដូចមានចែងក្នុងចំណុច ១១.៧.១១.១ ចំណុច ១១.៧.១១.២ និងចំណុច ១១.៧.១១.៤ ខាងលើនេះ ក្នុងមួយមុខ ១ (មួយ) ច្បាប់ ទៅឱ្យក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប ដែលត្រូវបន្តអនុវត្តតាមនីតិវិធីដូចមានចែងក្នុងប្រការ១១.៩ ខាងក្រោមនេះ។

១១.៧.១២ ប្រសិនបើ គធ.ខប សម្រេចកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោត ក្នុងករណីដែល គ.ក.ប/គ.ក.រ ឬ/និង គឃ.សប មានកំហុសក្នុងការគណនាតួលេខលទ្ធផលនៃការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់ ប្រធាន គធ.ខប ត្រូវ៖

១១.៧.១២.១ ចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) និងលើរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ឬ/និងលើរបាយការណ៍របស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និង

សន្លឹកឆ្នោត ដែលបានដាក់ភ្ជាប់ជាមួយសំណុំឯកសារពាក់ព័ន្ធជូន គជ.ខប ពិនិត្យ សម្រេចដូចមានចែងក្នុងចំណុច ១១.៧.៦.៣ ខាងលើនេះ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គជ.ខប ព្រមទាំងដាក់បង្ហាញចំពោះមុខអ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមាន។

១១.៧.១២.២ ចារបដិសេធលើសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គយ.សប ដែលបានបដិសេធពាក្យបណ្តឹងពាក់ព័ន្ធ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គជ.ខប។

១១.៧.១២.៣ ធានាថាសមាជិក គជ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតបានបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គជ.ខប ហើយដែលត្រូវចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គជ.ខប ដោយសមាជិក គជ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត និងប្រធាន គជ.ខប។

១១.៧.១២.៤ ប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គជ.ខប ខាងលើ ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១១.៧.១២.៥ ជម្រាបអ្នកប្តឹង ឬតំណាងថា គជ.ខប យល់ព្រមកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោត។

១១.៧.១២.៦ ប្រគល់រាល់ឯកសារដូចមានចែងក្នុងចំណុច ១១.៧.១២.១ ចំណុច ១១.៧.១២.២ និងចំណុច ១១.៧.១២.៤ ខាងលើនេះ ក្នុងមួយមុខ ១ (មួយ) ច្បាប់ ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ដាក់ទៅក្នុងកញ្ចប់ “គ ពិសេស” ដើម្បីរក្សាទុកជាឯកសាររបស់ គជ.ខប និងត្រៀមសម្រាប់ផ្ញើជូន គ.ជ.ប។

១១.៧.១២.៧ ប្រគល់រាល់ឯកសារដូចមានចែងក្នុងចំណុច ១១.៧.១២.១ ចំណុច ១១.៧.១២.២ និងចំណុច ១១.៧.១២.៤ ខាងលើនេះ ក្នុងមួយមុខ ១ (មួយ) ច្បាប់ ទៅឱ្យក្រុមកំណត់ចំនួនអាសនៈនៃ គជ.ខប ដែលត្រូវបន្តអនុវត្តតាមនីតិវិធីដូចមានចែងក្នុងប្រការ ១១.៩ ខាងក្រោមនេះ។

១១.៧.១៣ ប្រសិនបើ គជ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់ណាមួយ គជ.ខប ត្រូវយល់ព្រមតាមការសម្រេចរបស់ គយ.សប និងត្រូវបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ហើយយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលបានដាក់នៅ គជ.ខប ប្រធាន គជ.ខប ត្រូវ៖

- ១១.៧.១៣.១ ចារព្យួរលទ្ធផលលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) និងលើរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ដែលបានដាក់ជូន គជ.ខប ពិនិត្យ សម្រេចដូចមានចែងក្នុងចំណុច ១១.៧.៦.៣ ខាងលើនេះ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គជ.ខប ព្រមទាំងដាក់បង្ហាញចំពោះមុខអ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមាន។
- ១១.៧.១៣.២ ចារយល់ព្រមលើសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គយ.សប ដែលបានយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គជ.ខប។
- ១១.៧.១៣.៣ ជានាថាសមាជិក គជ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតបានបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គជ.ខប បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ និងត្រូវយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលបានដាក់នៅ គជ.ខប ដោយបញ្ជាក់ច្បាស់អំពីមូលហេតុផង ហើយដែលត្រូវចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គជ.ខប ដោយសមាជិក គជ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត និងប្រធាន គជ.ខប។
- ១១.៧.១៣.៤ ប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គជ.ខប បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតខាងលើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១១.៧.១៣.៥ ប្រកាសថាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះត្រូវបានបដិសេធដោយ គធ.ខប ហើយសេចក្តីសម្រេចនេះស្ថិតក្រោមការត្រួតពិនិត្យឡើងវិញរបស់ គ.ជ.ប។

១១.៧.១៣.៦ ធានាថាសមាជិក គធ.ខប ដែលជាប្រធានផ្នែកសោកម្មច្បាប់វិវាទកម្ម និងសន្តិសុខបោះឆ្នោតបានដាក់ទៅក្នុងស្រោមសំបុត្រដោយឡែកពីគ្នាសម្រាប់ផ្ញើជូន គ.ជ.ប នូវសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ព្រមទាំងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ១ (មួយ) ច្បាប់ តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ដែលត្រូវបាន គធ.ខប ចារព្យួរជាបណ្តោះអាសន្ន ១ (មួយ) ច្បាប់ និងរបាយការណ៍របស់ គយ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ១ (មួយ) ច្បាប់។

១១.៧.១៣.៧ ប្រគល់រាល់ឯកសារដូចមានចែងក្នុងចំណុច ១១.៧.១៣.១ ចំណុច ១១.៧.១៣.២ និងចំណុច ១១.៧.១៣.៤ ខាងលើនេះ ក្នុងមួយមុខ ១ (មួយ) ច្បាប់ ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដាក់ទៅក្នុងកញ្ចប់ "គ ពិសេស" ដើម្បីរក្សាទុកជាឯកសាររបស់ គធ.ខប និងត្រៀមឯកសារនេះក្នុងមួយមុខ ១ (មួយ) ច្បាប់ សម្រាប់ផ្ញើជូន គ.ជ.ប។

១១.៧.១៤ ក្នុងករណី គធ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់ណាមួយ ប្រធាន គធ.ខប ត្រូវបញ្ជូនសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធជូន គ.ជ.ប មិនឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោងគិតចាប់ពីពេលចេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ព្យួរលទ្ធផល។ ប្រធាន គធ.ខប ត្រូវធានាថាសម្ភារ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធត្រូវបានវេចខ្ចប់ដូចខាងក្រោមសម្រាប់បញ្ជូនទៅ គ.ជ.ប។

១១.៧.១៤.១ ដាក់ទៅក្នុងស្រោមសំបុត្រធំមួយនូវរាល់ស្រោមសំបុត្រដាក់ឯកសារ និងទម្រង់បែបបទនានាដូចមានចែងក្នុងចំណុច ១១.៧.១៣.៧ ខាងលើនេះ និងស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) នៃឃុំ សង្កាត់ពាក់ព័ន្ធដែលត្រូវផ្ញើជូន គ.ជ.ប ហើយត្រូវសរសេរសម្គាល់ពីក្រៅថា "សេចក្តីសម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់លេខ...(បំពេញលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ)"។

១១.៧.១៤.២ ដាក់រាល់ស្បោង "គ" ដែលផ្ទុកស្បោង "ខ" នៃឃុំ សង្កាត់ពាក់ព័ន្ធទៅក្នុងស្បោង "ឃ" ទៅតាមចំនួនដែលអាចដាក់ឱ្យអស់ស្បោង "គ" រួចចងភ្ជិតចាក់សោឃ្លុំ និងត្រូវសរសេរសម្គាល់ពីក្រៅស្បោង "ឃ" ថា "ព្យួរលទ្ធផលឃុំ សង្កាត់លេខ...(បំពេញលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ)"។

១១.៧.១៤.៣ ចាត់ចែងបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ដោយរាយមុខសម្ភារ ឯកសារបោះឆ្នោតដែលមាននៅក្នុងស្រោមសំបុត្រធំ និងក្នុងស្បោង "ឃ"។

១១.៧.១៤.៤ ដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត ១ (មួយ) ច្បាប់ទៅក្នុងស្រោមសំបុត្រធំដូចមានចែងក្នុងចំណុច ១១.៧.១៤.១ ខាងលើនេះ រួចកិបភ្ជាប់ ១ (មួយ) ច្បាប់ ទៅនឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំនេះ និងរក្សាទុក ១ (មួយ) ច្បាប់សម្រាប់ប្រើក្នុងការប្រគល់ និងការទទួលនៅ គ.ជ.ប។

ការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានសំឡេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គជ.ខប ប្រការ១១.៨.

ក្នុងករណីឃុំ សង្កាត់ណាមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយឃុំ សង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គជ.ខប ដូចមានចែងក្នុងចំណុច ១១.៣.៦ នៃ ប.ន.ឃ.ស នេះ គជ.ខប ត្រូវកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ឱ្យត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ដោយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១១.៨.១ ប្រសិនបើឃុំ សង្កាត់ណាមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយរវាងបញ្ជីបេក្ខជនពីរ ឬច្រើន ប៉ុន្តែឃុំ សង្កាត់នោះគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ដូចមានចែងក្នុងចំណុច ១១.៤.១ នៃ ប.ន.ឃ.ស នេះ ឬមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់បានដាក់នៅ គធ.ខប ប៉ុន្តែត្រូវបាន គធ.ខប ចារបដិសេធលើពាក្យបណ្តឹង (ទ.១២០២) ដូចមានចែងក្នុងចំណុច ១១.៤.៦.១ និងចំណុច ១១.៤.៦.២ នៃ ប.ន.ឃ.ស នេះ គធ.ខប ត្រូវកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ឱ្យត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ដោយត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងប្រការ ១១.៦ ខាងលើនេះ។

១១.៨.២ ប្រសិនបើឃុំ សង្កាត់ណាមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដូចមានចែងក្នុងចំណុច ១១.៤.៦.៣ នៃ ប.ន.ឃ.ស នេះ ត្រូវបានដាក់នៅ គធ.ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប បានធ្វើការត្រួតពិនិត្យរួចហើយតាមនីតិវិធីដូចមានចែងក្នុងប្រការ១១.៦ និងប្រការ១១.៧ ខាងលើនេះនូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ គធ.ខប ត្រូវផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យរួចហើយនោះ ដើម្បីប្រជុំសម្រេចលើពាក្យបណ្តឹង។

១១.៨.៣ ប្រសិនបើឃុំ សង្កាត់ណាមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដូចមានចែងក្នុងចំណុច ១១.៤.៦.៣ នៃ ប.ន.ឃ.ស នេះ ត្រូវបានដាក់នៅ គធ.ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប បានធ្វើការត្រួតពិនិត្យរួចហើយតាមនីតិវិធីដូចមានចែងក្នុងប្រការ១១.៦ ខាងលើនេះ នូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ គធ.ខប ត្រូវធានាថារាល់នីតិវិធីដូចមានចែងក្នុងចំណុច ១១.៧.៣ រហូតដល់ចំណុច ១១.៧.៧ ខាងលើនេះ ត្រូវតែបានអនុវត្តនៅមុនពេល គធ.ខប ប្រជុំសម្រេចលើពាក្យបណ្តឹង។

១១.៨.៤ ប្រសិនបើឃុំ សង្កាត់ណាមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ដូចមានចែងក្នុងចំណុច ១១.៤.៦.៣ នៃ ប.ន.ឃ.ស នេះ ពាក់ព័ន្ធនឹងឃុំ សង្កាត់ ដែលក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប មិនទាន់បានត្រួតពិនិត្យលទ្ធផលនៅឡើយ គធ.ខប ត្រូវធានាថារាល់នីតិវិធីដូចមានចែងក្នុងចំណុច ១១.៦.១ ចំណុច ១១.៦.៣ និងចំណុច ១១.៧.៣ រហូតដល់ចំណុច ១១.៧.៧ ខាងលើនេះ ត្រូវតែបានអនុវត្តនៅមុនពេល គធ.ខប ប្រជុំសម្រេចលើពាក្យបណ្តឹង។

១១.៨.៥ ប្រសិនបើផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធឡើងវិញ ដូចមានចែងក្នុងចំណុច ១១.៨.២ ចំណុច ១១.៨.៣ និងចំណុច ១១.៨.៤ ខាងលើនេះ គជ.ឧប មិនឃើញមានភស្តុតាងបញ្ជាក់ថាមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងដំណើរការនៃការបោះឆ្នោតដែលនាំឱ្យផ្លាស់ប្តូរដល់លទ្ធផលនៃការបោះឆ្នោតទេនោះ គជ.ឧប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹង ដោយត្រូវអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ១១.៧.១១ ខាងលើនេះ។

១១.៨.៦ ប្រសិនបើផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធឡើងវិញ ដូចមានចែងក្នុងចំណុច ១១.៨.២ ចំណុច ១១.៨.៣ និងចំណុច ១១.៨.៤ ខាងលើនេះ គជ.ឧប បានរកឃើញភស្តុតាងបញ្ជាក់ថាមានកំហុសក្នុងការគណនាតួលេខ ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងដំណើរការនៃការបោះឆ្នោតដែលនាំឱ្យផ្លាស់ប្តូរដល់លទ្ធផលនៃការបោះឆ្នោតនោះ គជ.ឧប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹង ដោយត្រូវអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ១១.៧.១២ និងចំណុច ១១.៧.១៣ ខាងលើនេះ។

១១.៨.៧ ការរកកម្រិតលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ ត្រូវអនុវត្តតាមរូបមន្តដូចមានចែងក្នុងឧបសម្ព័ន្ធទី៩ (រូបមន្តរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់កម្រិតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរឬច្រើន) នៃ ប.ន.ឃ.ស នេះ។

១១.៨.៨ ក្នុងករណី គជ.ឧប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ប្រធាន គជ.ឧប ត្រូវធានាថានីតិវិធីដូចមានចែងក្នុងចំណុច ១១.៧.១៤ ខាងលើនេះត្រូវតែបានអនុវត្ត។

ការកំណត់ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជនតំណាងក្បួនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងការស្រង់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើស តាម ប.ន.ឃ.ស ប្រការ១១.៩.

បន្ទាប់ពីបានប្រគល់តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) និងរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ (ប្រសិនបើមាន) របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ឧប ដែលត្រូវបានចារឯកភាពទទួលយកលទ្ធផលដោយប្រធាន គជ.ឧប ដូចមានចែងក្នុងចំណុច ១១.៦.២.២ ចំណុច ១១.៧.១១.៨ និងចំណុច ១១.៧.១២.៨ ខាងលើនេះ ប្រធាន គជ.ឧប ត្រូវធានាថា ក្រុមកំណត់ចំនួនអាសនៈនៃ គជ.ឧប បានបន្តអនុវត្តការទទួលខុសត្រូវ និងភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងចំណុច ១១.២.១១ នៃ ប.ន.ឃ.ស នេះ។

១១.៩.១ ប្រធាន គធ.ខប ត្រូវធានាឱ្យមានកុំព្យូទ័រគ្រប់គ្រាន់ ដែលមានស្កែននរ (Scanner) ម៉ាស៊ីនបោះពុម្ព អ៊ីនធឺណិត និងកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតដែលមានមុខងារប្រតិបត្តិការបែងចែកអាសនៈផ្អែកតាមរូបមន្ត និងនីតិវិធីដូចមានចែងក្នុងជំពូកទី៤ នៃ ប.ន.ឃ.ស នេះ។ ប្រធាន គធ.ខប ត្រូវ៖

- ១១.៩.១.១ ធានាថាគ្រឿងបរិក្ខារ កុំព្យូទ័រត្រូវបានដំឡើង និងដំណើរការបានល្អត្រឹមត្រូវដោយមានផ្គុំកទិន្នន័យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត ព្រមទាំងទម្រង់បែបបទចាំបាច់ផ្សេងទៀត។
- ១១.៩.១.២ ធានាឱ្យមានបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត ១ (មួយ) ច្បាប់ សម្រាប់ក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប ប្រើប្រាស់ក្នុងការពិនិត្យ ផ្ទៀងផ្ទាត់។
- ១១.៩.១.៣ ត្រូវរាយការណ៍ និងស្នើសុំជំនួយអន្តរាគមន៍ជាបន្ទាន់ពីអគ្គលេខាធិការដ្ឋាន គ.ជ.ប ក្នុងករណីប្រព័ន្ធគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោតមិនអាចដំណើរការបាន។

១១.៩.២ ប្រធានក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប ត្រូវធានាថារាល់តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) និងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដែលក្រុមបានទទួលដូចមានចែងក្នុងប្រការ១១.៩ ខាងលើនេះ ត្រូវតែបានត្រួតពិនិត្យសុពលភាពឱ្យប្រាកដថា ប្រធាន គធ.ខប បានចារឯកភាពទទួលយកលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធរួចហើយ ព្រមទាំងត្រូវបានរៀបចំដោយឡែក និងតាមលំដាប់លំដោយនៃលេខកូដឃុំ សង្កាត់។

១១.៩.៣ នៅក្នុងការផ្ទៀងផ្ទាត់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ប្រធានក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប ត្រូវ៖

- ១១.៩.៣.១ ចាត់ចែងសមាជិកក្រុមឱ្យផ្ទេរទិន្នន័យពីតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ទៅក្នុងក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) តាមកម្មវិធីកុំព្យូទ័រ។
- ១១.៩.៣.២ ចាត់ចែងសមាជិកក្រុមឱ្យបោះពុម្ពក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយគធ.ខប (ទ.១១០៥ធខ) ចំនួន ៣ (បី) ច្បាប់ ដោយពិនិត្យឱ្យបានត្រឹមត្រូវតាមតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ដែលប្រធាន គធ.ខប បានចារឯកភាព។

ក្នុងរាជធានី ខេត្ត (ទ.១១១០) ចំនួន ២ (ពីរ) ច្បាប់។

ចាត់ចែងលេខាធិការក្រុមឱ្យបោះពុម្ពតារាងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) ចំនួន ២ (ពីរ) ច្បាប់។

ធានាថាក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) ទាំងអស់ដែលបានបោះពុម្ពត្រូវបានផ្ទៀងផ្ទាត់តួលេខលទ្ធផល ដោយការធ្វើប្រមាណវិធីដោយដៃ ឬ/និងម៉ាស៊ីនគិតលេខ ហើយប្រៀបធៀបជាមួយតួលេខលទ្ធផលក្នុងតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ ក្នុងរាជធានី ខេត្ត (ទ.១១១០) ដែលបានបោះពុម្ពពីកុំព្យូទ័រ។

ធានាថានីតិវិធីចាប់ពីចំណុច ១១.៩.៣.១ រហូតដល់ចំណុច ១១.៩.៣.៤ ខាងលើនេះ ត្រូវបានអនុវត្តឡើងវិញឱ្យបានហ្មត់ចត់ និងត្រឹមត្រូវ ប្រសិនបើឃើញមានភាពខុសគ្នាក្នុងការផ្ទៀងផ្ទាត់តួលេខលទ្ធផលខាងលើ។

ធានាថាក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) ទាំង ៣ (បី) ច្បាប់ ដែលផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ ត្រូវបានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈ។

ធានាថាតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) ចំនួន ២ (ពីរ) ច្បាប់ ដែលបានបោះពុម្ព និងផ្ទៀងផ្ទាត់ត្រូវបានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប។

នៅក្នុងការគណនា និងកំណត់ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធណាមួយ ប្រធានក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប ត្រូវៈ

អនុវត្តមុខងារបែងចែកអាសនៈ និងបញ្ជាកម្មវិធីគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ហើយលេខាធិការត្រូវធ្វើការបោះពុម្ពលទ្ធផលទាំងនេះ ១ (មួយ) ច្បាប់។

ចាត់ចែងសមាជិកដទៃទៀតក្នុងក្រុមឱ្យអនុវត្តប្រមាណវិធីដោយដៃ ឬ/និងម៉ាស៊ីនគិតលេខ ដោយផ្អែកតាមរូបមន្តនៃការបែងចែកអាសនៈ

ដូចមានចែងក្នុងជំពូកទី៤ នៃ ប.ន.ឃ.ស នេះ ដើម្បីគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ។

១១.៩.៤.៣ ចាត់ចែងសមាជិកក្នុងក្រុមឱ្យសហការគ្នាធ្វើងផ្ទាត់ និងគណនាឡើងវិញ ដោយផ្អែកតាមរូបមន្តបែងចែកអាសនៈដូចមានចែងក្នុងជំពូកទី៤ នៃ ប.ន.ឃ.ស នេះ ប្រសិនបើលទ្ធផលនៃការគណនាតាមរូបភាពទាំងពីរខាងលើមានភាពខុសគ្នា។


១១.៩.៤.៤ ធានាថាក្រដាសលទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈតាមរូបភាពទាំងពីរដែលបានធ្វើងផ្ទាត់ត្រឹមត្រូវដូចគ្នា ហើយត្រូវបានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈ។

១១.៩.៥ បន្ទាប់ពីបានអនុវត្តរាល់នីតិវិធីដូចមានចែងក្នុងចំណុច ១១.៩.៣ និងចំណុច ១១.៩.៤ ខាងលើនេះ ផ្អែកលើលទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈដូចមានចែងក្នុងចំណុច ១១.៩.៤.៤ ខាងលើនេះ ប្រធានក្រុមកំណត់ចំនួនអាសនៈនៃ គឧ.ខប ត្រូវ៖

១១.៩.៥.១ ចាត់ចែងសមាជិកក្រុមឱ្យបោះពុម្ពតារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ចំនួន ២ (ពីរ) ច្បាប់ ដោយត្រូវបញ្ជាក់នូវ៖

- ឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ចំនួនសំឡេងឆ្នោតគាំទ្រសរុបតាមគណបក្ស និងចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបាន ដោយគិតតាមលំដាប់ពីខ្ពស់មកទាប
- ឈ្មោះបេក្ខជននៃគណបក្សនយោបាយដែលត្រូវជាប់ឆ្នោតជាសមាជិក កបយ.ស ក្នុងនោះត្រូវបញ្ជាក់ចំពោះបេក្ខជនដែលត្រូវជាប់ជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ផង។

១១.៩.៥.២ ធានាថាការស្រង់ឈ្មោះបេក្ខជននៃគណបក្សនយោបាយដែលត្រូវជាប់ឆ្នោតជាសមាជិក កបយ.ស ត្រូវតែផ្អែកលើបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយដែលបានទទួលអាសនៈ ដោយគិតតាមលំដាប់ពីខ្ពស់មកទាប។



១១.៩.៥.៣ ធានាថាតារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ទាំង ២ (ពីរ) ច្បាប់ ត្រូវតែបានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈ។

១១.៩.៦ ប្រសិនបើការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយមានលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើនដែលនឹងត្រូវបានទទួលអាសនៈក្នុង កបយ.ស ប្រធានក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប ត្រូវរាយការណ៍ជូនប្រធាន គធ.ខប ដើម្បីចាត់ចែងអនុវត្តការចាប់ឆ្នោតដោយផ្អែកតាមលក្ខខណ្ឌ និងនីតិវិធីស្តីពីការចាប់ឆ្នោតដូចមានចែងក្នុងប្រការ៤.៩ នៃ ប.ន.ឃ.ស នេះ។ ប្រធាន គធ.ខប ត្រូវធានាថាកំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោតដូចមានចែងក្នុងចំណុចនេះត្រូវបានធ្វើចំនួន ២ (ពីរ) ច្បាប់ ដែល ១ (មួយ) ច្បាប់ ត្រូវដាក់ក្នុងកញ្ចប់ “គ ពិសេស” នៃឃុំ សង្កាត់ពាក់ព័ន្ធរក្សាទុកជាឯកសាររបស់ គធ.ខប និង ១ (មួយ) ច្បាប់ទៀតត្រូវដាក់ក្នុងកញ្ចប់ “ឃ ពិសេស” ផ្ញើជូន គ.ជ.ប។

១១.៩.៧ ប្រសិនបើការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយមានលទ្ធផលសំឡេងឆ្នោត និងចំនួនអាសនៈស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើនដែលមានបេក្ខជនជាប់ឆ្នោតនឹងត្រូវជាប់ជាមេឃុំ ឬចៅសង្កាត់ ដំទប់ទី១ ឬចៅសង្កាត់រងទី១ និងដំទប់ទី២ ឬចៅសង្កាត់រងទី២ ប្រធានក្រុមកំណត់ចំនួនអាសនៈនៃ គធ.ខប ត្រូវរាយការណ៍ជូនប្រធាន គធ.ខប ដើម្បីចាត់ចែងអនុវត្តការចាប់ឆ្នោតដោយផ្អែកតាមនីតិវិធីដូចមានចែងក្នុងប្រការ៤.៩ នៃ ប.ន.ឃ.ស នេះ។ ប្រធាន គធ.ខប ត្រូវធានាថាកំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោតដូចបញ្ជាក់ក្នុងចំណុចនេះត្រូវបានធ្វើចំនួន ២ (ពីរ) ច្បាប់ ដែល ១ (មួយ) ច្បាប់ ត្រូវដាក់ក្នុងកញ្ចប់ “គ ពិសេស” នៃឃុំ សង្កាត់ពាក់ព័ន្ធរក្សាទុកជាឯកសាររបស់ គធ.ខប និង ១ (មួយ) ច្បាប់ទៀត ត្រូវដាក់ក្នុងកញ្ចប់ “ឃ ពិសេស” ផ្ញើជូន គ.ជ.ប។

ការពិនិត្យ និងចុះហត្ថលេខាលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើស កបយ.ស

ប្រការ១១.១០.-

បន្ទាប់ពីបានត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ កំណត់ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ការស្រង់ឈ្មោះបេក្ខជនដែលត្រូវជាប់ឆ្នោតជាសមាជិក កបយ.ស និងកំណត់ឈ្មោះសមាជិក កបយ.ស ដែលត្រូវជាប់ឆ្នោតជាមេឃុំ ឬចៅសង្កាត់ ដំទប់ទី១ ឬចៅសង្កាត់រងទី១ និងដំទប់ទី២ ឬចៅសង្កាត់រងទី២ នៃឃុំ សង្កាត់នីមួយៗចំណុះរាជធានី ខេត្ត រួចរាល់ហើយ ប្រធាន គធ.ខប ត្រូវធានាថាតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) និងតារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ត្រូវតែបានបោះពុម្ព ចុះហត្ថលេខា និងតាលប់រួចទ្រួចបញ្ចូនដោយរវេចខ្ចប់អមជាមួយនូវសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប ដើម្បីពិនិត្យ សម្រេចជាលទ្ធផលបោះឆ្នោតផ្លូវការ។



១១.១០.១ តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) ចំនួន ២ (ពីរ) ច្បាប់ ដែលបានបោះពុម្ព និងពិនិត្យត្រឹមត្រូវរួចហើយ

ដូចមានចែងក្នុងចំណុច ១១.៩.៣.៦ ខាងលើនេះ ត្រូវចុះហត្ថលេខា បោះត្រា គធ.ខប និងកាលបរិច្ឆេទដោយប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប រួចដាក់បង្ហាញចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍បោះឆ្នោត។ ប្រធាន គធ.ខប ត្រូវចាត់ចែង និងប្រើប្រាស់តារាងលទ្ធផលខាងលើនេះដូចខាងក្រោម៖

១១.១០.១.១ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ដែលត្រូវដាក់ក្នុងស្រោមសំបុត្រ បោះពុម្ពស្រាប់ដែលមានកាខ្នងថា "តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត... (បំពេញលេខកូដរាជធានី ខេត្តពាក់ព័ន្ធ) ផ្ញើជូន គ.ជ.ប"។

១១.១០.១.២ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១១.១០.២ ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) ចំនួន ៣ (បី) ច្បាប់ ដែលបានបោះពុម្ពរួចហើយដូចមានចែងក្នុងចំណុច ១១.៩.៣.៧ ខាងលើនេះ ត្រូវចុះហត្ថលេខា បោះត្រា គធ.ខប និងកាលបរិច្ឆេទដោយប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប រួចដាក់បង្ហាញចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍បោះឆ្នោត។ ប្រធាន គធ.ខប ត្រូវចាត់ចែង និងប្រើប្រាស់ក្រដាសលទ្ធផលខាងលើនេះដូចខាងក្រោម៖

១១.១០.២.១ បិទផ្សាយនៅ លគធ.ខប ១ (មួយ) ច្បាប់។

១១.១០.២.២ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ដែលត្រូវដាក់ទៅក្នុងស្រោមសំបុត្រ បោះពុម្ពស្រាប់ដែលមានកាខ្នងថា "ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់លេខ... (បំពេញលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ) ផ្ញើជូន គ.ជ.ប"។

១១.១០.២.៣ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១១.១០.៣ តារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនដាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ចំនួន ២ (ពីរ) ច្បាប់ ដែលបានបំពេញរួចហើយដូចមានចែងក្នុងចំណុច ១១.៩.៥.៣ ខាងលើនេះ ត្រូវចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងកាលបរិច្ឆេទដោយប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប រួចដាក់បង្ហាញចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍បោះឆ្នោត។ ប្រធាន គធ.ខប ត្រូវចាត់ចែង និងប្រើប្រាស់លទ្ធផលខាងលើនេះដូចខាងក្រោម៖

១១.១០.៣.១ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ដែលត្រូវដាក់ទៅក្នុងស្រោមសំបុត្រ បោះពុម្ពស្រាប់ដែលមានកាខ្នងថា "លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លេខ... (បំពេញលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ) ផ្ញើជូន គ.ជ.ប"។

១១.១០.៣.២ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១១.១០.៤ ប្រធាន គធ.ខប ត្រូវធានាថារូបភាព និងទិន្នន័យនៃកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) តារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ដែលមានក្នុងកម្មវិធីកុំព្យូទ័រត្រូវបានរក្សាទុកក្នុងយូអេសប៊ីផ្លាសដ្រាយ (USB Flash Drive) មួយចងដោយលេខកូដសម្ងាត់ និងត្រូវដាក់ក្នុងស្រោមសំបុត្របញ្ជូនមក គ.ជ.ប ហើយទិន្នន័យទាំងអស់នេះ ក៏ត្រូវផ្ញើមក គ.ជ.ប តាមអ៊ីនធឺណិតផងដែរ។

១១.១០.៥ តំណាងគណបក្សនយោបាយពាក់ព័ន្ធអាចស្នើសុំថតចម្លងក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ)។

ការវេចខ្ចប់ និងបញ្ជូនលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើស កបយ.ស និងរាល់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប

ប្រការ១១.១១.-

បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីដូចមានចែងចាប់ពីប្រការ១១.៥ រហូតដល់ប្រការ១១.១០ នៃ ប.ន.ឃ.ស នេះ ប្រធាន គធ.ខប ត្រូវធានាថាតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) តារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) និងរាល់ស្បោង "គ" ដាក់សម្ភារឯកសារបោះឆ្នោតនៃឃុំ សង្កាត់ទាំងអស់ចំណុះរាជធានី ខេត្ត ត្រូវតែបានវេចខ្ចប់ទៅក្នុងកញ្ចប់ "ឃ ពិសេស" និងស្បោង "ឃ" និងស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ត្រូវបានវេចខ្ចប់ទៅក្នុងស្បោងដាក់បញ្ជីបោះឆ្នោតនៃរាជធានី ខេត្ត បញ្ជូន និងប្រគល់ជូន គ.ជ.ប បានយ៉ាងត្រឹមត្រូវក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃក្រោយពេលបានទទួលកំណត់ហេតុបូកសរុបលទ្ធផល

បណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣)។ ក្នុងករណីមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងឃុំ សង្កាត់មួយ ឬច្រើនត្រូវបានដាក់នៅ គធ.ខប ប្រធាន គធ.ខប អាចចាត់ចែងវេចខ្ចប់រាល់ក្រដាសលទ្ធផល និងសម្ភារ ឯកសារបោះឆ្នោតដូចមានចែងខាងលើនេះ ដើម្បីបញ្ជូន និងប្រគល់ជូន គ.ជ.ប នៅក្រោយពេលដែល គធ.ខប ដោះស្រាយពាក្យបណ្តឹងចប់សព្វគ្រប់ស្របតាម ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ។

១១.១១.១ ប្រធាន គធ.ខប ត្រូវធានាថារាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនឹងឃុំ សង្កាត់ដែលត្រូវបានសម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ១១.៧.១៣ និងចំណុច ១១.៨.៨ នៃ ប.ន.ឃ.ស នេះ ត្រូវតែបានវេចខ្ចប់ដោយឡែកតាមឃុំ សង្កាត់ និងបញ្ជូនទៅ គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.៧.១៤ នៃ ប.ន.ឃ.ស នេះ។

១១.១១.២ ចំពោះករណីឃុំ សង្កាត់ទាំងឡាយណាដែលលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះ ត្រូវបាន គធ.ខប សម្រេចយល់ព្រម ប្រធាន គធ.ខប ត្រូវត្រៀមកញ្ចប់ “ឃ ពិសេស” មួយសម្រាប់ដាក់រាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតដែលនឹងត្រូវផ្ញើជូន គ.ជ.ប និងត្រូវធានាថារាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតទាំងនោះ ត្រូវតែបានត្រួតពិនិត្យឡើងវិញ និងរៀបចំចងជាបាច់ដោយឡែកពីគ្នាទៅតាមប្រភេទឯកសារក្នុងស្រោមសំបុត្រ។ នៅរៀងរាល់ពេលនៃកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នីមួយៗ ប្រធាន គធ.ខប ត្រូវប្រមូល និងរៀបចំដាក់ទៅក្នុងកញ្ចប់ “ឃ ពិសេស” នូវ៖

- ១១.១១.២.១ រាល់ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ផ្ញើជូន គ.ជ.ប ដែលប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប បានប្រគល់ជូនដូចមានចែងក្នុងចំណុច ១១.៦.៣ និងចំណុច ១១.៧.១១.៧ នៃ ប.ន.ឃ.ស នេះ។
- ១១.១១.២.២ រាល់ស្រោមសំបុត្រដាក់តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) និងតារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ដូចមានចែងក្នុងចំណុច ១១.១០.១.១ ចំណុច ១១.១០.២.២ និងចំណុច ១១.១០.៣.១ ខាងលើនេះ។

๑๑.๑๑.๒.๓ រាល់តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.๑๑๑๖តព) របាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ (ប្រសិនបើមាន) ឬ/និងរបាយការណ៍របស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារៈឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន) ដូចមានចែងក្នុងចំណុច ๑๑.๖.๒.๒ និងចំណុច ๑๑.๗.๑๑.๑ នៃ ប.ន.ឃ.ស នេះ។

๑๑.๑๑.๒.๔ រាល់សម្រង់សេចក្តីសម្រេច (ទ.๑๒๐๓) របស់ គធ.ខប ពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងដំទាស់ដែលត្រូវប្រមូលដាក់ក្នុងស្រោមសំបុត្រមួយ និងកាខ្នងផ្ញើជូន គ.ជ.ប។

๑๑.๑๑.๒.๕ រាល់កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោតដូចមានចែងក្នុងចំណុច ๑๑.๙.๖ និងចំណុច ๑๑.๙.๗ ខាងលើនេះ (ប្រសិនបើមាន)។

๑๑.๑๑.๒.๖ ស្រោមសំបុត្រដាក់យូអេសប៊ីផ្លាសជ្រាយ (USB Flash Drive) រក្សាទុករូបភាពទិន្នន័យ និងទិន្នន័យនៃកំណត់ហេតុនៃការបោះឆ្នោត (ទ.๑๑๐๑) តារាងកត់ត្រាសំឡេងឆ្នោត (ទ.๑๑๐๘) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.๑๑๐๒) តារាងបូកសរុបលទ្ធផលបណ្តោះអាសន្នក្នុងឃុំ សង្កាត់ (ទ.๑๑๐๙) កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.๑๑๐๓) តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.๑๑๑๖តព) ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.๑๑๐๕ធខ) តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.๑๑๑๐) និងតារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.๑๑๑๑)។

๑๑.๑๑.๒.๗ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈឯកសារបោះឆ្នោត (ទ.๑๑๐๗)។

๑๑.๑๑.๓ ប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈឯកសារបោះឆ្នោត (ទ.๑๑๐๗) ចំនួន ๓ (បី) ច្បាប់ ដោយមានសរសេរអមមុខសម្ភារៈឯកសារ

បោះឆ្នោតដែលបានដាក់ក្នុងកញ្ចប់ “ឃ ពិសេស” ខាងលើ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុងកញ្ចប់ “ឃ ពិសេស” ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ “ឃ ពិសេស” និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ និងការទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប។

១១.១១.៤ ប្រធាន គធ.ខប ត្រូវបិទក្តិតកញ្ចប់ “ឃ ពិសេស” រួចហើយត្រូវសរសេរសម្គាល់លេខកូដរាជធានី ខេត្តរបស់ខ្លួននៅលើផ្នែកខាងក្រៅនៃកញ្ចប់ “ឃ ពិសេស” ដោយប្រើបិកហ្វឺតលុបមិនជ្រះ។

១១.១១.៥ បន្ទាប់មកប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់ស្បោង “គ” នៃឃុំ សង្កាត់ដែលគ្មានឬមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ប៉ុន្តែគ្មានការបើកកញ្ចប់សុវត្ថិភាព “ក” ហើយដែលបានត្រួតពិនិត្យលទ្ធផលឡើងវិញដូចមានចែងក្នុងប្រការ១១.៦ និងចំណុច ១១.៧.២ នៃ ប.ន.ឃ.ស នេះ ដោយដាក់ទៅក្នុងស្បោង “ឃ” តាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់ស្បោង “គ” នៃឃុំ សង្កាត់ពាក់ព័ន្ធ។ ក្នុងការវេចខ្ចប់នេះ គធ.ខប ត្រូវ៖

- ១១.១១.៥.១ ដាក់ស្បោង “គ” តាមលំដាប់លេខរៀងនៃលេខកូដឃុំ សង្កាត់ ប្រសិនបើអាចទៅក្នុងស្បោង “ឃ” នីមួយៗ។
- ១១.១១.៥.២ ធានាថាលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញដោយមានរាយមុខសម្ភារ ឯកសារបោះឆ្នោតដែលបានដាក់ក្នុងស្បោង “ឃ” នីមួយៗ ហើយត្រូវបានដាក់ ១ (មួយ) ច្បាប់ ទៅក្នុងស្បោង “ឃ” ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង “ឃ” និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ និងការទទួលសម្ភារ ឯកសារបោះឆ្នោតនៅទីស្តីការ គ.ជ.ប។
- ១១.១១.៥.៣ ចងក្តិតស្បោង “ឃ” នីមួយៗ និងចាក់សោឃ្លុំមានលេខ រួចសរសេរសម្គាល់ពីក្រៅស្បោង “ឃ” នីមួយៗ ដោយប្រើបិកហ្វឺតលុបមិនជ្រះនូវលេខកូដឃុំ សង្កាត់ពាក់ព័ន្ធពីលេខប៉ុន្មានដល់លេខប៉ុន្មាន និងពាក្យថា “ពិនិត្យរួច”។

១១.១១.៦ ប្រសិនបើក្នុងរាជធានី ខេត្ត មានឃុំ សង្កាត់មួយចំនួនមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលតម្រូវឱ្យមានការបើកកញ្ចប់សុវត្ថិភាព “ក” នៃការិយាល័យបោះឆ្នោតមួយ ឬច្រើន ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ប្រធាន គធ.ខប ត្រូវធានាថារាល់ស្បោង “គ” មានពាក្យបណ្តឹង/បើក

កញ្ចប់សុវត្ថិភាព ក” នៃឃុំ សង្កាត់ពាក់ព័ន្ធទាំងនោះ ត្រូវតែបានវេចខ្ចប់ក្នុងស្បោង “ឃ” ដោយឡែក។ ប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់ស្បោង “គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក” នៃឃុំ សង្កាត់ទាំងនោះ ហើយដែលបានត្រួតពិនិត្យលទ្ធផលឡើងវិញដូចមានចែងក្នុងប្រការ១១.៧ និងប្រការ១១.៨ នៃ ប.ន.ឃ.ស នេះ ដោយដាក់ទៅក្នុងស្បោង “ឃ” ដោយឡែកតាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់ស្បោង “គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក” នៃឃុំ សង្កាត់ទាំងនោះ។ ក្នុងការវេចខ្ចប់នេះ គធ.ខប ត្រូវ៖

១១.១១.៦.១ ដាក់រាល់ស្បោង “គ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក” នៃឃុំ សង្កាត់ពាក់ព័ន្ធ ដែលមានការបើកកញ្ចប់សុវត្ថិភាព “ក” ទៅក្នុងស្បោង “ឃ” ដោយឡែក។

១១.១១.៦.២ ធានាថាលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញដោយមានរាយមុខសម្ភារ ឯកសារដែលបានដាក់ក្នុងស្បោង “ឃ” ពាក់ព័ន្ធ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុងស្បោង “ឃ” ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង “ឃ” និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ និងការទទួលសម្ភារ ឯកសារបោះឆ្នោតនៅទីស្តីការ គ.ជ.ប។

១១.១១.៦.៣ ចងភ្ជិតស្បោង “ឃ” និងចាក់សោឃ្លុំមានលេខ។

១១.១១.៦.៤ សរសេរសម្គាល់ពីក្រៅស្បោង “ឃ” ដោយប្រើបិកហ្វឺតលុបមិនជ្រះនូវលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ និងពាក្យថា “មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក”។

១១.១១.៧ ក្នុងករណីមានស្បោង “ឃ” ដូចមានចែងក្នុងចំណុច ១១.១១.៥ ឬ/និងចំណុច ១១.១១.៦ ខាងលើនេះ សរុបលើសពីមួយ ប្រធាន គធ.ខប ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃស្បោង “ឃ” ទាំងនោះនូវលេខរៀងនៃស្បោង “ឃ” នីមួយៗ។ ឧទាហរណ៍ : ប្រសិនបើមានស្បោង “ឃ” សរុបចំនួន ៣ ត្រូវសរសេរសម្គាល់លេខរៀង ១/៣ ២/៣ និង ៣/៣។

១១.១១.៨ ប្រធាន គធ.ខប ត្រូវណែនាំឱ្យក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ចាត់ចែងវេចខ្ចប់ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ដាក់ក្នុងស្បោងដែលបោះពុម្ពកាខ្នងថា "ស្បោងដាក់បញ្ជីបោះឆ្នោតនៃរាជធានី ខេត្ត" តាមចំនួនចាំបាច់ដើម្បីដាក់ឱ្យអស់ស្បោងនេះ។ នៅក្នុងការវេចខ្ចប់ស្បោងដាក់បញ្ជីបោះឆ្នោតនៃរាជធានី ខេត្ត ក្រុមទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គធ.ខប ត្រូវ៖

- ដាក់ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់តាមលំដាប់លេខរៀងនៃឃុំ សង្កាត់នីមួយៗ
- បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ដោយបញ្ជាក់ឱ្យច្បាស់អំពីចំនួនស្បោងដាក់បញ្ជីបោះឆ្នោតនៃ គឃ.សប និងលេខរៀងនៃលេខកូដឃុំ សង្កាត់ពាក់ព័ន្ធពីលេខប៉ុន្មានដល់លេខប៉ុន្មាន ព្រមទាំងសរសេរសម្គាល់បន្ថែមនូវលេខសោឃ្លុំដែលចាក់មាត់ស្បោងនេះរួចហើយដាក់ទៅក្នុងស្បោងចំនួន ១ (មួយ) ច្បាប់ ដាក់ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង ១ (មួយ) ច្បាប់ និងរក្សាទុក សម្រាប់ប្រើក្នុងការប្រគល់ និងការទទួលនៅទីស្តីការ គ.ជ.ប ១ (មួយ) ច្បាប់
- ចងភ្ជិតមាត់ស្បោង និងចាក់សោឃ្លុំមានលេខ។

១១.១១.៩ ប្រធាន គធ.ខប ត្រូវប្រកាសអញ្ជើញតំណាងគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិ និងអ្នកសារព័ត៌មានដែលមានវត្តមានឱ្យចូលរួមជាសាក្សីក្នុងការបញ្ជូន និងការប្រគល់ទទួលកញ្ចប់ "ឃ ពិសេស" រាល់ស្បោង "ឃ" ខាងលើនេះ និងរាល់ស្បោងដាក់បញ្ជីបោះឆ្នោតនៃរាជធានី ខេត្ត ហើយត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរនៃការបញ្ជូន ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ និងការទទួលនៅទីស្តីការ គ.ជ.ប។

១១.១១.១០ ប្រធាន គធ.ខប ត្រូវធានាថារាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដែលបានទទួលពី គឃ.សប ចំណុះរាជធានី ខេត្ត ឬ/និងមាននៅ លគធ.ខប ត្រូវតែបានវេចខ្ចប់ និងបញ្ជូនដោយឡែកទៅ គ.ជ.ប នៅពេលក្រោយ។ នៅក្នុងការវេចខ្ចប់បញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅសល់ ប្រធាន គធ.ខប ត្រូវធានាថាលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ត្រូវតែបានបំពេញ និងប្រើប្រាស់តាមគោលការណ៍នៃការប្រគល់ និងការទទួលសម្ភារ ឯកសារបោះឆ្នោត។

ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ដែលបដិសេធលើពាក្យបណ្តឹងទៅ គ.ជ.ប

ប្រការ១១.១២.

អ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយដែលមិនសុខចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់ គធ.ខប លើពាក្យបណ្តឹងរបស់ខ្លួនពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ដូចមានចែងក្នុងចំណុច ១១.៧.១១.៤ នៃ ប.ន.ឃ.ស នេះ និងដែលត្រូវបានបដិសេធពាក្យបណ្តឹងក្នុងការអនុវត្តករណីដូចមានចែងក្នុងចំណុច ១១.៨.៥ នៃ ប.ន.ឃ.ស នេះ មានសិទ្ធិប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប។

- ១១.១២.១ រាល់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដូចបញ្ជាក់ក្នុងប្រការ១១.១២ ខាងលើនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) និងដាក់ពាក្យបណ្តឹងនៅទីស្តីការ គ.ជ.ប ហើយ គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្តឹងទាំងនេះក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។
- ១១.១២.២ ប្រសិនបើនៅក្នុងរយៈពេលកំណត់ខាងលើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានការប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចបដិសេធរបស់ គធ.ខបលើពាក្យបណ្តឹងពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ចំណុះរាជធានី ខេត្តពាក់ព័ន្ធ។
- ១១.១២.៣ អ្នកប្តឹង ឬតំណាង ឬតំណាងគណបក្សនយោបាយដែលមានបំណងប្តឹងតវ៉ាដូចមានចែងក្នុងប្រការ១១.១២ ខាងលើនេះ ត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតមេដៃលើពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ដែលក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុងចំណុច ១១.៤.៣ នៃ ប.ន.ឃ.ស នេះ។
- ១១.១២.៤ នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីពិនិត្យ និងទទួលពាក្យបណ្តឹងត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន មានជាអាទិ៍ដូចខាងក្រោម៖
  - ទី១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
  - ទី២- កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប។
- ១១.១២.៥ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនោះ។

១១.១២.៦ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

១១.១២.៦.១ ពាក្យបណ្តឹងតវ៉ាដែលត្រូវបានដាក់ក្រោយពេលវេលាដូចមានចែងក្នុងប្រការ១១.១២ ខាងលើនេះ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវចុះពេលវេលា និងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ រួចដាក់ជូន គ.ជ.ប តាមហានានុក្រម ចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ចុះហត្ថលេខាឈ្មោះ និងបោះត្រា គ.ជ.ប លើពាក្យបណ្តឹងនោះ ហើយប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ និងជម្រាបអ្នកប្តឹង ឬតំណាងថាពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ គ.ជ.ប មិនអាចទទួលដោះស្រាយបានទេ។

១១.១២.៦.២ ពាក្យបណ្តឹងតវ៉ាមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ១១.៤.៣ នៃ ប.ន.ឃ.ស នេះ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ហើយ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាតនោះទេ គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ហើយប្រគល់ជូនអ្នកប្តឹង ឬតំណាងចំនួន ១ (មួយ) ច្បាប់ និងរក្សាទុកឯកសារចំនួន ២ (ពីរ) ច្បាប់។

១១.១២.៦.៣ ពាក្យបណ្តឹងតវ៉ាដែលត្រូវបានដាក់ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងប្រការ១១.១២ ខាងលើនេះ និងមានព័ត៌មានចាំបាច់ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងត្រូវចុះកាលបរិច្ឆេទ ពេលវេលាហើយចុះហត្ថលេខាលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅទីស្តីការ គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកសម្រាប់ គ.ជ.ប ប្រើពេលសវនាការ ១ (មួយ) ច្បាប់។



១១.១២.៦.៤ ជម្រាបអ្នកប្តឹង ឬតំណាងថា គ.ជ.ប នឹងសម្រេចលើពាក្យបណ្តឹងតវ៉ារបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ។

១១.១២.៧ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប អំពីករណីនៃបណ្តឹងដោយក្លាប់ពាក្យបណ្តឹងតវ៉ាដែលបានទទួល និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប បដិសេធលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដូចមានចែងក្នុងចំណុច ១១.៧.១១.៤ និងចំណុច ១១.៨.៥ នៃ ប.ន.ឃ.ស នេះ ដែលត្រូវដកចេញពីកញ្ចប់ "ឃ ពិសេស" និងដើម្បីសុំការណែនាំពី គ.ជ.ប អំពីករណីនៃការត្រួតពិនិត្យលទ្ធផល និងភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។ ផ្អែកតាមការណែនាំខាងលើនេះ អគ្គលេខាធិការ គ.ជ.ប ត្រូវចាត់ចែងក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះនៅចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកប្តឹង ឬតំណាង និងអ្នកសង្កេតការណ៍បោះឆ្នោត។

ការបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណសម្បត្តិបម្រើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស

ប្រការ១១.១៣.

ក្នុងគោលបំណងត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស ទាំងអស់ គ.ជ.ប ត្រូវបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ១ (មួយ) ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញមួយចំនួនតាមការចាំបាច់ និងក្រុមកំណត់បែងចែកអាសនៈ ១ (មួយ) ព្រមទាំងត្រូវត្រៀមលក្ខណសម្បត្តិជាមុនដើម្បីបម្រើឱ្យការងារត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញនេះ។

១១.១៣.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបង្កើតឡើង ដើម្បីធានាការទទួលកញ្ចប់ "ឃ ពិសេស" ស្បោង "ឃ" ឬ/និងស្បោង "ឃ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក" ស្បោងដាក់បញ្ជីបោះឆ្នោតនៃរាជធានី ខេត្ត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធដែល គធ.ខប បានបញ្ជូន និងប្រគល់ជូន គ.ជ.ប ព្រមទាំងធានាការបែងចែក និងការរក្សាទុកសម្ភារ ឯកសារបោះឆ្នោតទាំងនោះនៅបន្ទប់ស្តុកតាមរាជធានី ខេត្តនីមួយៗ។

១១.១៣.១.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវដឹកនាំដោយប្រធាននាយកដ្ឋានរដ្ឋបាល និងមានមន្ត្រីនាយកដ្ឋានប្រតិបត្តិការ មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងមន្ត្រីលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប មួយចំនួនជាសមាជិក។



១១.១៣.១.២ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប។

១១.១៣.២ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប មួយចំនួនត្រូវបង្កើតឡើងតាមការចាំបាច់ ដើម្បីអនុវត្តការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ ចំណុះរាជធានី ខេត្តទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប នីមួយៗ រួមមានសមាសភាពដែលត្រូវបានចាត់តាំងពីក្នុងចំណោមមន្ត្រីនៃនាយកដ្ឋាន និងអង្គភាពនានាចំណុះអគ្គលេខាធិការដ្ឋាន គ.ជ.ប និងត្រូវបានបែងចែកឱ្យទទួលបន្ទុកត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់សម្រាប់រាជធានី ខេត្តមួយ ឬច្រើន។

- ១១.១៣.២.១ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប នីមួយៗ ត្រូវមានសមាសភាព ៤ (បួន) រូប ដែលដឹកនាំដោយប្រធាន ១ (មួយ) រូប អនុប្រធាន ១ (មួយ) រូប លេខាធិការ ១ (មួយ) រូប និងជំនួយការ ១ (មួយ) រូប។
- ១១.១៣.២.២ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប។

១១.១៣.៣ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប នីមួយៗ មានភារកិច្ចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗដោយឡែកពីគ្នា រួចត្រូវបោះពុម្ពតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព)។ ក្នុងករណីឃុំ សង្កាត់មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គ.ជ.ប ឬលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ត្រូវបានព្យួរជាបណ្តោះអាសន្នដោយ គធ.ខប ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ត្រូវអនុវត្តបន្ថែមដោយធ្វើរបាយការណ៍លើកយោបល់យល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់។ ប្រធានក្រុមត្រូវធានាថាតារាងត្រួតពិនិត្យលទ្ធផល ឬ/និងរបាយការណ៍ខាងលើ ត្រូវបានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមពាក់ព័ន្ធ និងត្រូវដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច បន្ទាប់មក គ.ជ.ប ត្រូវប្រគល់សំណុំឯកសារដែលបានសម្រេចរួចនេះតាមរយៈអគ្គលេខាធិការ គ.ជ.ប ឱ្យទៅក្រុមកំណត់បែងចែកអាសនៈ នៃ គ.ជ.ប ដើម្បីមុខការបន្ត។ ការត្រួតពិនិត្យលទ្ធផលនេះ ត្រូវអនុវត្តដោយផ្អែកលើ៖

- ១១.១៣.៣.១ តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) និងតារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១)។
- ១១.១៣.៣.២ កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ដែល គធ.ខប ផ្ញើជូន គ.ជ.ប។

១១.១៣.៣.៣ តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) ព្រមទាំងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ឧប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ (ប្រសិនបើមាន) ឬ/និងរបាយការណ៍របស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន)។

១១.១៣.៣.៤ សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គជ.ឧប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ និងរាល់ឯកសារពាក់ព័ន្ធនឹងពាក្យបណ្តឹង (ប្រសិនបើមាន)។

១១.១៣.៣.៥ កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោតដូចមានចែងក្នុងចំណុច ១១.៩.៦ និងចំណុច ១១.៩.៧ នៃ ប.ន.ឃ.ស នេះ (ប្រសិនបើមាន)។

១១.១៣.៣.៦ ពាក្យបណ្តឹងដែលបានដាក់នៅ គ.ជ.ប ដូចមានចែងក្នុងប្រការ ១១.១២ ខាងលើនេះ (ប្រសិនបើមាន)។

១១.១៣.៣.៧ លទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនៅ គ.ជ.ប (ប្រសិនបើ គ.ជ.ប សម្រេចឱ្យធ្វើដូច្នេះ)។

១១.១៣.៤ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប មួយក្រុមត្រូវបានបង្កើតឡើងដើម្បីទាញទិន្នន័យដែលជាលទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបយ.ស ទាំងអស់ចំណុះរាជធានី ខេត្ត នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងអនុវត្តការផ្ទៀងផ្ទាត់ការបែងចែកអាសនៈតាមឃុំ សង្កាត់ រួចធ្វើការផ្ទៀងផ្ទាត់លទ្ធផលជាមួយតារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១)។ ក្នុងករណីគ្មានពាក្យបណ្តឹង ឬរាល់ពាក្យបណ្តឹងត្រូវបានដោះស្រាយចប់ស្ថាពរ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវរៀបចំបោះពុម្ពសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផលនៃការបោះឆ្នោត តារាងលទ្ធផលនៃការផ្ទៀងផ្ទាត់ការបែងចែកអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនជាប់ឆ្នោតជាសមាជិក កបយ.ស និងជាមេឃុំ ចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

១១.១៣.៤.១ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវមានសមាសភាពមួយចំនួនតាមការចាំបាច់ ដែលត្រូវបានចាត់តាំងពីក្នុងចំណោមថ្នាក់ដឹកនាំ

អគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ប្រធាននាយកដ្ឋានប្រតិបត្តិការ ប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម និងប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត។

១១.១៣.៤.២ ក្រុមនេះត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប ដែលជាអគ្គនាយកនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស អនុប្រធានមួយចំនួនដែលជាអគ្គនាយករងនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ប្រធាននាយកដ្ឋានប្រតិបត្តិការ ប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម និងប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ព្រមទាំងមានក្រុមជំនួយការមួយចំនួនតាមការចាំបាច់។

១១.១៣.៤.៣ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប។

១១.១៣.៥ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួននៅបន្ទប់នាយកដ្ឋានប្រតិបត្តិការនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស និងត្រូវមានការទទួលខុសត្រូវ និងការកិច្ចដូចខាងក្រោម៖

១១.១៣.៥.១ បោះពុម្ពតារាងលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ដោយផ្អែកតាមតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) ដែល គជ.ខប បានបញ្ជូនមកសេរ៉ូបកណ៍ (Server) គ.ជ.ប បន្ទាប់មកកែតម្រូវ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ទៅនឹងក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គជ.ខប (ទ.១១០៥ជខ) និងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) របស់ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ដែល គ.ជ.ប បានពិនិត្យសម្រេចរួចហើយ។

១១.១៣.៥.២ ដាក់សេចក្តីព្រាងតារាងលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេចជាផ្លូវការ និងផ្សព្វផ្សាយជាសាធារណៈ។

១១.១៣.៥.៣ កែតម្រូវតួលេខលទ្ធផលយោងតាមសេចក្តីសម្រេចរបស់ គ.ជ.ប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ (ប្រសិនបើមាន) និង

រៀបចំបោះពុម្ពសេចក្តីព្រាងតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតតាមឃុំ សង្កាត់ទូទាំងប្រទេស និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេចជាផ្លូវការ និងផ្សព្វផ្សាយសាធារណៈ។

១១.១៣.៥.៤ កំណត់បែងចែកអាសនៈតាមរូបមន្តដែលកំណត់ដោយច្បាប់ និងដូចមានចែងក្នុងជំពូកទី៤ នៃ ប.ន.ឃ.ស នេះ ដោយគណនាតាមការធ្វើប្រមាណវិធីដោយដៃ និងដោយប្រើមុខងារប្រតិបត្តិការបែងចែកអាសនៈក្នុងកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត យោងតាមតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតតាមឃុំ សង្កាត់ទូទាំងប្រទេស។

១១.១៣.៥.៥ បោះពុម្ពតារាងផ្ទៀងផ្ទាត់បែងចែកអាសនៈតាមឃុំ សង្កាត់ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវទទួលបាន រួចផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធផលនៃការបែងចែកអាសនៈដែលគណនាដោយដៃ បន្ទាប់មកទាញឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបឃ.ស តាមចំនួនអាសនៈ និងលំដាប់លេខរៀងពីក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលត្រូវទទួលបានអាសនៈ ទៅក្នុងសេចក្តីព្រាងលទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស និងដោយមានបញ្ជាក់សមាជិក កបឃ.ស ជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ផង។

១១.១៣.៥.៦ ផ្ទៀងផ្ទាត់បន្ថែមនូវតួលេខ និងទិន្នន័យក្នុងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយនឹងតារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១)។

១១.១៣.៥.៧ រៀបចំតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈ ដែលបានគណនាឃើញតាមរូបភាពទាំងពីរ មួយមុខ ១ (មួយ) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយលេខាធិការ អនុប្រធានក្រុម និងប្រធានក្រុម និងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) ចំនួន ៥ (ប្រាំ) ច្បាប់ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេចជាផ្លូវការ។



១១.១៣.៦ អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំ និងចាត់ចែងក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប នៅក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ និងកិច្ចប្រតិបត្តិការផ្ទៀងផ្ទាត់ឡើងវិញនូវ

លទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបយ.ស។ អគ្គលេខាធិការ គ.ជ.ប ត្រូវពិនិត្យ រាល់សំណុំឯកសាររបស់ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប និងក្រុមកំណត់ បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។

១១.១៣.៧ អគ្គលេខាធិការ គ.ជ.ប ត្រូវត្រៀមបន្ទប់មួយចំនួននៅទីស្តីការ គ.ជ.ប សម្រាប់ធ្វើជា ឃ្លាំងស្តុកកញ្ចប់ "ឃ ពិសេស" ដាក់ឯកសារដែលជាលទ្ធផលបណ្តោះអាសន្ននៃការ បោះឆ្នោតជ្រើសរើស កបយ.ស និងស្បោង "ឃ" ដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ ក្នុងនោះត្រូវ៖

- ១១.១៣.៧.១ ត្រៀមបន្ទប់មួយដោយឡែកសម្រាប់រក្សាទុករាល់ស្រោមសំបុត្រធំ ដាក់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ព្យួរលទ្ធផល បណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ និងរាល់ស្បោង "ឃ ព្យួរលទ្ធផល" ដាក់ស្បោង "គ" នៃឃុំ សង្កាត់ពាក់ព័ន្ធដែល លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅ ការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះត្រូវបានបដិសេធ និងស្បោងដាក់បញ្ជីបោះឆ្នោតនៃរាជធានី ខេត្ត។
- ១១.១៣.៧.២ ត្រៀមបន្ទប់មួយដោយឡែកសម្រាប់ដាក់រាល់កញ្ចប់ "ឃ ពិសេស" នៃ គធ.ខប ទាំងអស់។
- ១១.១៣.៧.៣ ត្រៀមបន្ទប់មួយចំនួនសម្រាប់ស្តុកស្បោង "ឃ" ដែលមានដាក់ ស្បោង "គ" ហើយដែលត្រូវដាក់ដោយឡែកពីគ្នាទៅតាមរាជធានី ខេត្តនីមួយៗ។

១១.១៣.៨ អគ្គលេខាធិការ គ.ជ.ប ត្រូវត្រៀមបន្ទប់ធំទូលាយមួយចំនួន ឬបន្ទប់តូចៗច្រើនដែល អាចឱ្យក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប នីមួយៗ បំពេញការងាររបស់ខ្លួន បានល្អ។

- ១១.១៣.៨.១ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ពីរ ឬច្រើនក្រុមអាច បំពេញការងាររបស់ខ្លួនក្នុងបន្ទប់តែមួយ ឬនៅបន្ទប់ដោយឡែកពីគ្នា ដោយផ្អែកតាមលទ្ធភាពជាក់ស្តែង។
- ១១.១៣.៨.២ សេចក្តីជូនដំណឹងស្តីពីពេលវេលា កាលបរិច្ឆេទ ទីកន្លែង ឈ្មោះ និង លេខកូដឃុំ សង្កាត់ និងរាជធានី ខេត្ត ដែលត្រូវធ្វើការត្រួតពិនិត្យ លទ្ធផលឡើងវិញ ព្រមទាំងលេខក្រុម និងឈ្មោះប្រធានក្រុមត្រួត ពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ដែលទទួលបន្ទុក ត្រូវតែបាន បិទផ្សាយជាសាធារណៈនៅមុខទីស្តីការ គ.ជ.ប ដើម្បីជាដំណឹងដល់

គណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍បោះឆ្នោត និង
អ្នកប្តឹងឬតំណាងព្រមទាំងអ្នកសារព័ត៌មានដែលទទួលបានការអនុញ្ញាត
ឱ្យចូលរួមសង្កេតមើលក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនោះ។

១១.១៣.៩ ក្នុងអំឡុងពេលនៃដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញនៅ គ.ជ.ប
លក្ខខណ្ឌសន្តិសុខនៅជុំវិញបរិវេណ និងក្នុងទីស្តីការ គ.ជ.ប ព្រមទាំងសណ្តាប់ធ្នាប់
និងរបៀបរៀបរយត្រូវតែបានពង្រឹងតាមវិធានការរដ្ឋបាលដែលគ្រប់គ្រង និងចាត់ចែង
ដោយអគ្គលេខាធិការ គ.ជ.ប។

១១.១៣.៩.១ តំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍បោះឆ្នោត
និងអ្នកប្តឹង ឬតំណាង ព្រមទាំងអ្នកសារព័ត៌មានដែលទទួលបាន
ការអនុញ្ញាតឱ្យចូលរួមសង្កេតមើលការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់
លទ្ធផលឡើងវិញនៅទីស្តីការ គ.ជ.ប ត្រូវស្ថិតនៅក្រោមអំណាច
គ្រប់គ្រង និងការណែនាំរបស់អគ្គលេខាធិការ គ.ជ.ប ឬមន្ត្រីដែល
ត្រូវបានប្រគល់សិទ្ធិ។

១១.១៣.៩.២ តំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍បោះឆ្នោត
និងអ្នកប្តឹង ឬតំណាង ព្រមទាំងអ្នកសារព័ត៌មានដែលទទួលបាន
ការអនុញ្ញាតឱ្យចូលរួមសង្កេតមើលការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់
លទ្ធផលឡើងវិញនៅទីស្តីការ គ.ជ.ប ត្រូវគោរពក្រមសីលធម៌
សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្ស
នយោបាយក្នុងដំណើរការបោះឆ្នោត ក្រមសីលធម៌សម្រាប់
អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត ក្រមសីលធម៌
សម្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងដំណើរការបោះឆ្នោត និង ប.ន.ឃ.ស នេះ
ហើយមិនត្រូវធ្វើសកម្មភាព ឬអំពើអ្វីមួយដែលរំខាន អុកឡុក ឬរាំង
ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល
ឡើងវិញ ឬបំពានលើសិទ្ធិអំណាច និងឯករាជ្យភាពរបស់ គ.ជ.ប
ឡើយ។

១១.១៣.១០ ហាមជនគ្រប់រូបចូលក្នុងបន្ទប់ដែលក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប និង
ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប កំពុងត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវ
លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍

អក្សរពី គ.ជ.ប។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងបន្ទប់ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលខាងលើនេះនូវដែនទាំងឡាយដូចខាងក្រោម៖

១១.១៣.១០.១ មន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដែលបានទទួលការចាត់តាំងពី គ.ជ.ប។

១១.១៣.១០.២ តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ពាក់ព័ន្ធដែលបានអនុញ្ញាត អ្នកប្តឹងពាក់ព័ន្ធ ឬតំណាង ព្រមទាំងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ឬ គធ.ខប និងអ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប។

១១.១៣.១០.៣ ប្រធាន អនុប្រធាន សមាជិក គ.ជ.ប និងអគ្គលេខាធិការ គ.ជ.ប ឬមន្ត្រីដែលបានប្រគល់សិទ្ធិ ដែលមានបំណងត្រួតពិនិត្យតាមដាន និងណែនាំក្នុងដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលរបស់ក្រុមនីមួយៗ។

ការប្រគល់ និងការទទួលស្បោង "ឃ" ស្បោងជាក់បញ្ជីបោះឆ្នោត និងកញ្ចប់ "ឃ ពិសេស" ជាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើស កបឃ.ស និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅទីស្តីការ គ.ជ.ប

ប្រការ១១.១៤.

សមាសភាពក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ដែលបានចាត់តាំងដូចមានចែងចំណុច ១១.១៣.១ ខាងលើនេះ ត្រូវមានវត្តមានជាប្រចាំនៅទីស្តីការ គ.ជ.ប ចាប់ពីពេលដែល គធ.ខប ចាប់ផ្តើមធ្វើការត្រួតពិនិត្យលទ្ធផលដើម្បីរង់ចាំទទួលសម្ភារ ឯកសារបោះឆ្នោតដែល គធ.ខប ត្រូវបញ្ជូន និងប្រគល់ជូន គ.ជ.ប។

១១.១៤.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដើម្បីទទួលសម្ភារ ឯកសារបោះឆ្នោត ដោយផ្អែកតាមករណីដោយឡែកនៃរាជធានី ខេត្តនីមួយៗដែល គធ.ខប ពាក់ព័ន្ធ អាចវេចខ្ចប់ និងបញ្ជូនសម្ភារ ឯកសារបោះឆ្នោតជូន គ.ជ.ប ជា ៣ (បី) ផ្នែកដូចខាងក្រោម៖

១១.១៤.១.១ រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនឹងឃុំ សង្កាត់ដែលត្រូវបាន គធ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ១១.១១.១ នៃ ប.ន.ឃ.ស នេះ។

១១.១៤.១.២ រាល់ស្បោង “ឃ” និងកញ្ចប់ “ឃ ពិសេស” ដាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើស កបឃ.ស ក្នុងរាជធានី ខេត្ត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះត្រូវបាន គធ.ខប សម្រេចយល់ព្រមដូចមានចែងក្នុងចំណុច ១១.១១.២ ចំណុច ១១.១១.៥ ចំណុច ១១.១១.៦ និងចំណុច ១១.១១.៨ នៃ ប.ន.ឃ.ស នេះ។

១១.១៤.១.៣ រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដែលត្រូវបានវេចខ្ចប់ និងបញ្ជូនដោយឡែកមក គ.ជ.ប នៅពេលក្រោយដូចមានចែងក្នុងចំណុច ១១.១១.១០ ខាងលើនេះ។

១១.១៤.២ ក្នុងករណីមន្ត្រី លគធ.ខប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ១១.១៤.១.១ ខាងលើនេះ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើក និងត្រួតពិនិត្យមើលរាល់សម្ភារ ឯកសារបោះឆ្នោតដែលមាននៅក្នុងស្រោមសំបុត្រធំ និងរាល់ស្បោង “ឃ ព្យួរលទ្ធផល” ដាក់ស្បោង “គ” នៃឃុំ សង្កាត់ពាក់ព័ន្ធដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះត្រូវបាន គធ.ខប សម្រេចព្យួរ។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវផ្ទៀងផ្ទាត់ជាមួយលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ៣ (បី) ច្បាប់ ដែល ១ (មួយ) ច្បាប់ នៅក្នុងស្រោមសំបុត្រធំ ១ (មួយ) ច្បាប់ កិបជាប់នឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំ និង ១ (មួយ) ច្បាប់ នៅនឹងមន្ត្រី លគធ.ខប ដែលបញ្ជូនសម្ភារ ឯកសារបោះឆ្នោតមក។

១១.១៤.២.១ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវកត់ត្រាមុខសម្ភារ ឯកសារបោះឆ្នោតដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីរបស់ខ្លួន ប្រសិនបើគ្រប់គ្រាន់ហើយ ត្រូវចារសម្គាល់ថា “គ្រប់ចំនួន”។


១១.១៤.២.២ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដូចមានចែងក្នុងចំណុច ១១.១៤.២ ខាងលើនេះ រួចប្រគល់ ១ (មួយ) ច្បាប់ ជូនមន្ត្រី លគធ.ខប ទទួលបន្ទុកការបញ្ជូនវិញ រក្សា ១ (មួយ) ច្បាប់ ភ្ជាប់ទៅនឹងស្រោមសំបុត្រធំ និងដក ១ (មួយ) ច្បាប់ ចងក្រងទុកជាឯកសារ។

១១.១៤.២.៣ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវនាំយកស្រោមសំបុត្រធំ និងស្បោង “ឃ ព្យួរលទ្ធផល” ដាក់រាល់ស្បោង “គ” នៃឃុំ សង្កាត់ ដែលត្រូវបានព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនោះទៅរក្សាទុកនៅក្នុងបន្ទប់ដែលបានត្រៀមបម្រុងទុកដូចមានចែងក្នុងចំណុច ១១.១៣.៧.១ ខាងលើនេះ និងត្រូវសរសេរសម្គាល់លេខកូដឃុំ សង្កាត់ និងរាជធានី ខេត្តពាក់ព័ន្ធផង។

១១.១៤.២.៤ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប នូវឈ្មោះ និងលេខកូដឃុំ សង្កាត់ ដែលត្រូវបាន គធ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនោះ ដោយដាក់អមទៅជាមួយនូវស្រោមសំបុត្រធំពាក់ព័ន្ធផង។

១១.១៤.៣ ក្នុងករណីមន្ត្រី លគធ.ខប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ១១.១៤.១.២ ខាងលើនេះ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើក និងត្រួតពិនិត្យមើលរាល់សម្ភារ ឯកសារបោះឆ្នោតដែលមាននៅក្នុងកញ្ចប់ “ឃ ពិសេស” ស្បោង “ឃ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក” និងរាល់ស្បោង “ឃ ពិនិត្យរួច” ដាក់ស្បោង “គ” នៃឃុំ សង្កាត់ពាក់ព័ន្ធទាំងអស់ដែលលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះត្រូវបាន គធ.ខប សម្រេចយល់ព្រម។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវផ្ទៀងផ្ទាត់ជាមួយលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ៣ (បី) ច្បាប់ ដោយឡែកពីគ្នា ដែល ១ (មួយ) ច្បាប់ នៅក្នុងស្បោង “ឃ” ឬ កញ្ចប់ “ឃ ពិសេស” ១ (មួយ) ច្បាប់ នៅក្នុងហោប៉ៅខាងក្រៅនៃស្បោង “ឃ” ឬ កញ្ចប់ “ឃ ពិសេស” និង ១ (មួយ) ច្បាប់ នៅនឹងមន្ត្រី លគធ.ខប ដែលបញ្ជូនសម្ភារ ឯកសារបោះឆ្នោតមក។

១១.១៤.៣.១ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវកត់ត្រាមុខសម្ភារ ឯកសារបោះឆ្នោតដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីរបស់ខ្លួន ដែលប្រសិនបើគ្រប់គ្រាន់ហើយ ត្រូវចារសម្គាល់ថា “គ្រប់ចំនួន”។



១១.១៤.៣.២ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដូចមានចែងក្នុងចំណុច ១១.១៤.៣ ខាងលើនេះ

រួចប្រគល់ ១ (មួយ) ច្បាប់ ជូនមន្ត្រី លគធ.ខប ទទួលបន្ទុកការបញ្ជូនវិញ ដាក់ ១ (មួយ) ច្បាប់ ក្នុងហោប៉ៅខាងក្រៅស្បោង "ឃ" ឬកញ្ចប់ "ឃ ពិសេស" វិញ និងដក ១ (មួយ) ច្បាប់ ចងក្រងទុកជាឯកសារ។

១១.១៤.៣.៣ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសាររបោះឆ្នោតនៃ គ.ជ.ប ត្រូវនាំយកកញ្ចប់ "ឃ ពិសេស" នៃរាជធានី ខេត្តពាក់ព័ន្ធ ទៅរក្សាទុកនៅក្នុងបន្ទប់ដែលបានត្រៀមបម្រុងទុកដូចមានចែងក្នុងចំណុច ១១.១៣.៧.២ ខាងលើនេះ ដោយត្រូវដាក់តាមលំដាប់លេខរៀងនៃលេខកូដរាជធានីខេត្តនីមួយៗ។

១១.១៤.៣.៤ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសាររបោះឆ្នោតនៃ គ.ជ.ប ត្រូវនាំយករាល់ស្បោង "ឃ" ដាក់ស្បោង "គ" នៃឃុំ សង្កាត់ពាក់ព័ន្ធដែលលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះត្រូវបាន គធ.ខប សម្រេចយល់ព្រមទៅរក្សាទុកនៅក្នុងបន្ទប់ដែលបានត្រៀមបម្រុងទុកដូចមានចែងក្នុងចំណុច ១១.១៣.៧.៣ ខាងលើនេះ និងត្រូវសរសេរសម្គាល់លេខកូដរាជធានី ខេត្តពាក់ព័ន្ធផង។ ប្រសិនបើក្នុងចំណោមស្បោង "ឃ" នៃរាជធានី ខេត្តពាក់ព័ន្ធមានស្បោង "ឃ" មួយចំនួនដែលមានសរសេរសម្គាល់ "មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព" មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសាររបោះឆ្នោតនៃ គ.ជ.ប ត្រូវដាក់បំបែករាល់ស្បោង "ឃ" ទាំងនោះដោយឡែក។

១១.១៤.៣.៥ ប្រធានក្រុមទទួលសម្ភារ ឯកសាររបោះឆ្នោតនៃ គ.ជ.ប ត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប នូវរាជធានីខេត្តដែលបានប្រគល់កញ្ចប់ "ឃ ពិសេស" និងរាល់ស្បោង "ឃ" ដាក់ស្បោង "គ" នៃឃុំ សង្កាត់ពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះត្រូវបាន គធ.ខប សម្រេចយល់ព្រម។ ប្រសិនបើក្នុងរាជធានី ខេត្តពាក់ព័ន្ធមានឃុំ សង្កាត់ណាដែលមានពាក្យបណ្តឹងត្រូវបានដាក់នៅ គឃ.សប ឬ/និង គធ.ខប និងដែលមានកញ្ចប់សុវត្ថិភាព "ក" មួយ ឬច្រើនត្រូវបានបើក ប្រធានក្រុមត្រូវបញ្ជាក់បន្ថែមក្នុងរបាយការណ៍ខាងលើផងដែរនូវឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានបណ្តឹងទាំងនោះ និងត្រូវដកយករាល់ស្រោមសំបុត្រដាក់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ពាក់ព័ន្ធរបស់ គធ.ខប ពីក្នុងកញ្ចប់ "ឃ ពិសេស" ដាក់អមទៅជាមួយផង។

១១.១៤.៤ នៅពេលអនុវត្តនីតិវិធីប្រគល់ ទទួល និងត្រួតពិនិត្យកញ្ចប់ “ឃ ពិសេស” និងស្បោង “ឃ” ឬ/និងស្បោង “ឃ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក” ជាមួយមន្ត្រី លគធ.ខប ទទួលបន្ទុកបញ្ជូនសម្ភារ ឯកសារបោះឆ្នោត ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវអនុវត្តភារកិច្ចបន្ថែមដោយត្រូវត្រួតពិនិត្យអំពីភាពត្រឹមត្រូវនៃការវេចខ្ចប់ស្បោងដាក់បញ្ជីបោះឆ្នោតនៃរាជធានី ខេត្ត និងត្រូវថែរក្សាទុកឱ្យមានសុវត្ថិភាពរួចត្រៀមសម្រាប់ប្រគល់ជូននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ដើម្បីរៀបចំស្រង់ទិន្នន័យអ្នកដែលបានបោះឆ្នោតបន្ទាប់ពីលទ្ធផលផ្លូវការនៃការបោះឆ្នោតត្រូវបានប្រកាសផ្សាយរួចរាល់ជាស្ថាពរ។

១១.១៤.៥ ក្នុងករណីមន្ត្រី លគធ.ខប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដូចមានចែងក្នុងចំណុច ១១.១៤.១.៣ ខាងលើនេះ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើកកញ្ចប់ និងត្រួតពិនិត្យមើលរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ដែលបានប្រគល់ជូន គ.ជ.ប។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវផ្ទៀងផ្ទាត់ជាមួយលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដែលប្រសិនបើត្រឹមត្រូវគ្រប់ចំនួនហើយ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) នោះរួចប្រគល់ជូនមន្ត្រី លគធ.ខប ទទួលបន្ទុកការបញ្ជូនវិញ ១ (មួយ) ច្បាប់។ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវផ្ទេររាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដែលបានទទួលខាងលើដោយភ្ជាប់ជាមួយលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់ ទៅឱ្យនាយកដ្ឋានប្រតិបត្តិការនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេទេសទទួលគ្រប់គ្រង និងរក្សាទុកនៅឃ្លាំង គ.ជ.ប ឬបន្ទប់ស្តុកដែលបានកំណត់។

កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ក្នុងការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបយ.ស

ប្រការ១១.១៥.-

ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប មានភារកិច្ចត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបយ.ស ទាំងអស់ចំណុះរាជធានី

ខេត្តទូទាំងប្រទេស ក្នុងគោលបំណងបញ្ជាក់ជាចុងក្រោយអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នីមួយៗ ការកំណត់ចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ទទួលបាន ការស្រង់ឈ្មោះបេក្ខជនដែលជាប់ឆ្នោតជាសមាជិក កបឃ.ស និងការបញ្ជាក់ឈ្មោះសមាជិក កបឃ.ស ដែលត្រូវទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ដំទប់ទី១ ឬចៅសង្កាត់រងទី១ និងដំទប់ទី២ ឬចៅសង្កាត់រងទី២ ដែល គជ.ខប បានធ្វើការត្រួតពិនិត្យម្តងរួចហើយ។ ប្រសិនបើក្នុងការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់ឡើងវិញនេះ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប យល់ព្រមតាមលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើស កបឃ.ស ណាមួយនោះ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ត្រូវបោះពុម្ពតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបោះពុម្ពតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈ និងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើស កបឃ.ស (ទ.១១១៨) រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច និងប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស នោះជាផ្លូវការ និងជាសាធារណៈ។

១១.១៥.១ នៅពេលដែល គ.ជ.ប បានទទួលតាមរយៈអគ្គលេខាធិការ គ.ជ.ប នូវរបាយការណ៍ពីក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.១៤.២.៤ និងចំណុច ១១.១៤.៣.៥ ខាងលើនេះ និងពីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសដូចមានចែងក្នុងចំណុច ១១.១២.៧ នៃ ប.ន.ឃ.ស នេះ គ.ជ.ប ត្រូវសម្រេចកំណត់ករណីនៃឃុំ សង្កាត់នីមួយៗក្នុងរាជធានី ខេត្ត ដែលនឹងត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល និងត្រូវសម្រេចអំពីភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។

១១.១៥.២ ផ្អែកតាមការកំណត់ និងសម្រេចរបស់ គ.ជ.ប អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ឱ្យអនុវត្តការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស ចំណុះរាជធានី ខេត្ត ដែលក្រុមនីមួយៗទទួលបន្ទុក ដោយត្រូវបំពេញការងារពាក់ព័ន្ធតាមការចាំបាច់ និងតាមករណីជាក់ស្តែងនីមួយៗដូចខាងក្រោម៖

១១.១៥.២.១ ក្នុងករណីឃុំ សង្កាត់ណាដែលលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះត្រូវបាន គជ.ខប សម្រេចព្យួរជាបណ្តោះអាសន្ន ហើយដែលក្នុងនោះ គជ.ខប បានសម្រេចបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ។

១១.១៥.២.២ ក្នុងករណីឃុំ សង្កាត់ណាដែលគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គយ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប។

១១.១៥.២.៣ ក្នុងករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់នឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ត្រូវបានដាក់នៅ គយ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ដូចមានចែងក្នុងប្រការ ១១.១២ នៃ ប.ន.ឃ.ស នេះ ហើយដែលក្នុងនោះមានកញ្ចប់សុវត្ថិភាព “ក” មួយ ឬច្រើន ត្រូវបានបើកនៅ គយ.សប ឬ គធ.ខប ប៉ុន្តែ គធ.ខប បានសម្រេចយល់ព្រមចំពោះលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើស កបឃ.ស នោះ។

១១.១៥.២.៤ ក្នុងករណីឃុំ សង្កាត់ណាដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយក្នុងករណីឃុំ សង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ឬ/និងនៅ គ.ជ.ប។

១១.១៥.៣ តំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍បោះឆ្នោត អ្នកប្តឹង ឬតំណាងនិងអ្នកសារព័ត៌មានដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប មានសិទ្ធិចូលរួមសង្កេតមើលរាល់ដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស នីមួយៗនៅទីស្តីការ គ.ជ.ប។ ប្រសិនបើបន្ទប់ចង្អៀតការចូលរួមសង្កេតមើលរបស់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោតដូចមានចែងក្នុងចំណុចនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ប្រធានក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ឬប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប តាមរបៀបផ្លាស់ប្តូរវេនគ្នា។

១១.១៥.៤ កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ក្នុងការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ប្រសិនបើចាប់ដំណើរការហើយត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ។

១១.១៥.៥ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ត្រូវបើកកិច្ចប្រតិបត្តិការដើម្បីត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ដែលខ្លួនទទួលបន្ទុកម្តងមួយឃុំ សង្កាត់ៗ នៅបន្ទប់ធំទូលាយណាមួយ ឬបន្ទប់តូចៗដោយឡែកពីគ្នាដែលបានត្រៀមបម្រុងដូចមានចែងក្នុងចំណុច ១១.១៣.៨ ខាងលើនេះ។ ក្នុងការត្រួតពិនិត្យលទ្ធផលខាងលើនេះ

ប្រធានក្រុមត្រូវធានាឱ្យមានម៉ាស៊ីនគិតលេខ ១ (មួយ) គ្រឿង ទម្រង់បែបបទសម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ក្នុងកម្មវិធីកុំព្យូទ័រ ព្រមទាំងរាល់សំណុំឯកសារយោងដូចមានចែងចាប់ពីចំណុច ១១.១៣.៣.១ រហូតដល់ចំណុច ១១.១៣.៣.៧ ខាងលើនេះ។

១១.១៥.៦ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបើកកិច្ចប្រតិបត្តិការដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស ម្តងមួយឃុំ សង្កាត់ៗ បន្ទាប់ពីបានទទួលតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) ដែល គ.ជ.ប បានពិនិត្យ សម្រេចរួច។

ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែល គធ.ខប បានសម្រេចព្យួរលទ្ធផលបណ្តោះអាសន្ន

ប្រការ១១.១៦.-

អនុលោមតាមការកំណត់របស់ គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.១៥.១ ខាងលើនេះ ប្រសិនបើឃុំ សង្កាត់ដែលនឹងត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញស្ថិតក្នុងករណីដែលលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះត្រូវបាន គធ.ខប សម្រេចព្យួរបណ្តោះអាសន្ន ហើយដែល គធ.ខប បានសម្រេចបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ដែលទទួលបន្ទុក និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ឱ្យធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមនីតិវិធីដូចខាងក្រោម៖

១១.១៦.១ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវធានាថាការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលត្រូវបាន គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្នត្រូវបានអនុវត្តយ៉ាងរួសរាន់ និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេចក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ។

១១.១៦.២ ក្នុងករណី គ.ជ.ប សម្រេចមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យដោយគ្រាន់តែផ្អែកលើរាល់សំណុំឯកសារដែលមានក្នុងស្រោមសំបុត្រធំដាក់រាល់ឯកសារ និងទម្រង់បែបបទនានាដូចមានចែងក្នុងចំណុច ១១.៧.១៣.១ ខាងលើនេះប៉ុណ្ណោះ។

១១.១៦.៣ ក្នុងករណី គ.ជ.ប សម្រេចតម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនោះ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យដោយផ្អែកលើរាល់សំណុំឯកសារដែលមានក្នុងស្រោមសំបុត្រធំដាក់រាល់ឯកសារ និងទម្រង់បែបបទនានាដូចមានចែងក្នុងចំណុច ១១.៧.១៣.១ ខាងលើនេះផង និងត្រូវអនុវត្តបន្ថែមការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញតាមលំនាំនីតិវិធីទាំងឡាយដែល គជ.ខប អនុវត្តដូចមានចែងចាប់ពីចំណុច ១១.៧.៣.១ រហូតដល់ចំណុច ១១.៧.៣.៦ និងចំណុច ១១.៧.៤ នៃ ប.ន.ឃ.ស នេះ។

១១.១៦.៤ ក្នុងករណី គ.ជ.ប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព “ក” នៃការិយាល័យបោះឆ្នោតលើសពីមួយក្នុងឃុំ សង្កាត់ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ត្រូវអនុវត្តតាមលំនាំនីតិវិធីដដែលដូចមានចែងក្នុងចំណុច ១១.១៦.៣ ខាងលើនេះ សម្រាប់កញ្ចប់សុវត្ថិភាព “ក” នីមួយៗ រហូតដល់អស់កញ្ចប់សុវត្ថិភាព “ក” នៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធដែលត្រូវសម្រេចឱ្យបើក។

១១.១៦.៥ បន្ទាប់ពីបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលឡើងវិញតាមនីតិវិធីដូចមានចែងក្នុងចំណុច ១១.១៦.២ ឬចំណុច ១១.១៦.៣ និងចំណុច ១១.១៦.៤ ខាងលើនេះ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ត្រូវធានាថារបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ១ (មួយ) ច្បាប់ តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ (ទ.១១១៧តព) នោះ ចំនួន ១ (មួយ) ច្បាប់ និងរបាយការណ៍លើកយោបល់យល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតចំនួន ១ (មួយ) ច្បាប់ត្រូវតែបានធ្វើ និងចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

១១.១៦.៦ អគ្គលេខាធិការ គ.ជ.ប ត្រូវចារយោបល់លើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) និងរបាយការណ៍ដែលបានដាក់ជូនពិនិត្យដូចមានចែងក្នុងចំណុច ១១.១៦.៥ ខាងលើនេះ រួចចុះហត្ថលេខា និងដាក់ជូន គ.ជ.ប ដើម្បីពិនិត្យសម្រេច។ អគ្គលេខាធិការ គ.ជ.ប ត្រូវ៖

- ១១.១៦.៦.១ លើកយោបល់ស្នើសុំការយល់ព្រមតាមសេចក្តីសម្រេចរបស់ គជ.ខប ដែលព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រសិនបើមានភាពមិនប្រក្រតីធ្ងន់ធ្ងរនាំឱ្យប៉ះពាល់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់។

១១.១៦.៦.២ លើកយោបល់ស្នើសុំការបដិសេធសេចក្តីសម្រេចរបស់ គធ.ខប ដែលព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ដោយត្រូវយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រសិនបើកម្រិតនៃភាពមិនប្រក្រតីមិននាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទេ។

១១.១៦.៧ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមសេចក្តីសម្រេចរបស់ គធ.ខប ដែលបានព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ហើយដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ៖

១១.១៦.៧.១ ចារយល់ព្រមលើសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលបានបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

១១.១៦.៧.២ ចារយល់ព្រមលើរបាយការណ៍លើកស្នើយោបល់របស់ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប និងចារបដិសេធលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) ដូចមានចែងក្នុងចំណុច ១១.១៦.៦ និងចំណុច ១១.១៦.៦.១ ខាងលើនេះ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

១១.១៦.៧.៣ ជានាថាមន្ត្រីជំនាញបានបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដោយបញ្ជាក់ច្បាស់អំពីមូលហេតុនៃការយល់ព្រមផង ហើយត្រូវចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ដោយមន្ត្រីជំនាញ និងប្រធាន គ.ជ.ប។

១១.១៦.៧.៤ ជានាថាសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតដូចមានចែងក្នុងចំណុច ១១.៦.៧.៣ ខាងលើនេះ ត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់ សម្រាប់ប្រគល់ជូនអ្នកប្តឹង ឬ តំណាង ១ (មួយ) ច្បាប់ជូនគ្រប់តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ

សង្កាត់ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ៣ក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ៣ក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១១.១៦.៧.៥ ប្រកាសថាសេចក្តីសម្រេចរបស់ គ.ជ.ប បដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ជាសេចក្តីសម្រេចចុងក្រោយ ហើយ គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់នៃឃុំ សង្កាត់នោះមិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេចបដិសេធ។

១១.១៦.៧.៦ ប្រគល់របាយការណ៍លើកស្ទើយោបល់ តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលមានចំណារប្រធាន គ.ជ.ប និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ក្នុងមួយមុខ ១ (មួយ) ច្បាប់ តាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ទទួលបន្ទុក ដាក់ក្នុងស្រោមសំបុត្រធំ រួចដាក់ទៅក្នុងកញ្ចប់ "ឃ ពិសេស" នៃរាជធានី ខេត្ត៣ក់ព័ន្ធ។

១១.១៦.៧.៧ ធានាថាក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប បានវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ៣ក់ព័ន្ធដាក់ក្នុងស្បោង "ខ" និងក្នុងស្បោង "គ" នៃឃុំ សង្កាត់នោះ តាមលំនាំដើម រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ដើម្បីរក្សាទុកនៅកន្លែងដើមវិញ។

១១.១៦.៨ យោងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប យល់ព្រមតាមសេចក្តីសម្រេចរបស់ គធ.ខប ដែលបានព្យួរលទ្ធផលដូចមានចែងក្នុងចំណុច ១១.១៦.៧.៣ ខាងលើនេះ គ.ជ.ប ត្រូវចាត់ចែង និងណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ៣ក់ព័ន្ធដែលលទ្ធផលនៃការបោះឆ្នោតទាំងនោះត្រូវបានបដិសេធ ដោយត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ១២ នៃ

ប.ន.ឃ.ស នេះ។ ការបោះឆ្នោតសាជាថ្មីនេះត្រូវអនុវត្តដោយផ្អែកលើបញ្ជីបោះឆ្នោតដដែល បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដដែល និងសន្លឹកឆ្នោតដែលមានទម្រង់ និងខ្លឹមសារដដែល ប៉ុន្តែត្រូវបោះពុម្ពថ្មីលើក្រដាសពណ៌ផ្សេង។

១១.១៦.៩ ប្រសិនបើ គ.ជ.ប សម្រេចមិនយល់ព្រមតាមសេចក្តីសម្រេចរបស់ គធ.ខប ដែលព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ដោយបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ៖

- ១១.១៦.៩.១ ចារបដិសេធលើសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលបានព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។
- ១១.១៦.៩.២ ចារយល់ព្រមលើរបាយការណ៍លើកស្នើយោបល់របស់ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប និងចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) ដូចមានចែងក្នុងចំណុច ១១.១៦.៦ និងចំណុច ១១.១៦.៦.២ ខាងលើនេះ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។
- ១១.១៦.៩.៣ ជានាថាមន្ត្រីជំនាញបានបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដោយបញ្ជាក់ច្បាស់អំពីមូលហេតុនៃការបដិសេធរបស់ គ.ជ.ប ចំពោះសេចក្តីសម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់ គធ.ខប ហើយត្រូវចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ដោយមន្ត្រីជំនាញ និងប្រធាន គ.ជ.ប។
- ១១.១៦.៩.៤ ជានាថាសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតដូចមានចែងក្នុងចំណុច ១១.១៦.៩.៣ ខាងលើនេះ ត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់សម្រាប់ប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១១.១៦.៩.៥ ប្រកាសថាសេចក្តីសម្រេចរបស់ គ.ជ.ប ដែលបដិសេធសេចក្តីសម្រេចរបស់ គធ.ខប និងយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះជាសេចក្តីសម្រេចចុងក្រោយ។

១១.១៦.៩.៦ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលមានចំណាររបស់ប្រធាន គ.ជ.ប និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះមួយមុខ ១ (មួយ) ច្បាប់ ព្រមទាំងឯកសារក្នុងស្រោមសំបុត្រធំ តាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីមុខការ។

១១.១៦.៩.៧ ធានាថាក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ទទួលបន្ទុកបានវេចខ្ចប់កញ្ចប់សុវត្ថិភាព “ក” ពាក់ព័ន្ធដាក់ក្នុងស្បោង “ខ” និងស្បោង “គ” លំនាំដើម រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារឯកសារបោះឆ្នោតនៃ គ.ជ.ប ដើម្បីរក្សាទុកនៅកន្លែងដើមវិញ។

១១.១៦.១០ នៅពេលទទួលបានសំណុំឯកសារដូចមានចែងក្នុងចំណុច ១១.១៦.៩.៦ ខាងលើនេះ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែង៖

១១.១៦.១០.១ កំណត់បែងចែកអាសនៈផ្អែកតាមលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ដោយទាញទិន្នន័យលទ្ធផលពីតារាងត្រួតពិនិត្យលទ្ធផលក្នុងឃុំ សង្កាត់ (ទ.១១១៧តព) តាមរយៈមុខងារប្រតិបត្តិការបែងចែកអាសនៈក្នុងកម្មវិធីត្រួតពិនិត្យផ្ទៀងផ្ទាត់ និងគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត និងដោយគណនាតាមការធ្វើប្រមាណវិធីតាមរូបមន្តដែលកំណត់ដោយច្បាប់ និងដូចមានចែងក្នុងជំពូកទី៤ នៃ ប.ន.ឃ.ស នេះ។

១១.១៦.១០.២ បោះពុម្ពតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈសម្រាប់ឃុំ សង្កាត់នោះ ដែលគណបក្សនយោបាយនីមួយៗត្រូវទទួលបានរួចផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធផលនៃការបែងចែកអាសនៈដែលគណនាតាមការធ្វើប្រមាណវិធីដោយដៃ បន្ទាប់មកទាញយកឈ្មោះបេក្ខជនដាប់ឆ្នោត

ជាសមាជិក កបយ.ស តាមចំនួនអាសនៈ និងលំដាប់លេខរៀងពីក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលត្រូវទទួលបានអាសនៈទៅក្នុងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) និងដោយមានបញ្ជាក់សមាជិក កបយ.ស ជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ផង។

១១.១៦.១០.៣ រៀបចំតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈដែលបានគណនាឃើញតាមរូបភាពទាំងពីរក្នុងមួយមុខ ១ (មួយ) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយអនុប្រធានក្រុម និងប្រធានក្រុម និងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) ចំនួន ៥ (ប្រាំ) ច្បាប់ ព្រមទាំងតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតនានា រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យសម្រេចជាផ្លូវការ។

១១.១៦.១១ ក្នុងការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលត្រូវបាន គធ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ន ប៉ុន្តែត្រូវបាន គ.ជ.ប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ប្រសិនបើមានករណីលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើនដែលនឹងត្រូវទទួលបានអាសនៈ ឬ/និងមានករណីលទ្ធផលសំឡេងឆ្នោត និងចំនួនអាសនៈស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើនដែលមានសមាជិក កបយ.ស នឹងត្រូវទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ គ.ជ.ប ត្រូវប្រគល់សិទ្ធិអំណាចជូនអគ្គលេខាធិការ គ.ជ.ប ដើម្បីអនុវត្តការចាប់ឆ្នោត ដោយត្រូវផ្អែកតាមលំនាំនីតិវិធីស្តីពីការចាប់ឆ្នោតនៅ គធ.ខប ដូចមានចែងក្នុងប្រការ៤.៩ នៃ ប.ន.ឃ.ស នេះ។

ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប

ប្រការ១១.១៧.

យោងតាមការកំណត់របស់ គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.១៥.១ ខាងលើនេះ ប្រសិនបើឃុំ សង្កាត់ដែលនឹងត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញស្ថិតក្នុងករណីឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប អគ្គលេខាធិការ

គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ដែលទទួលបន្ទុក និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ឱ្យធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមនីតិវិធីដូចខាងក្រោម៖

១១.១៧.១ ក្នុងករណីខាងលើនេះ ជាដំបូងផ្អែកតាមការណែនាំរបស់អគ្គលេខាធិការ គ.ជ.ប ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធចំណុះរាជធានី ខេត្តដែលក្រុមទទួលបន្ទុកដោយឡែកពីគ្នាម្តងមួយឃុំ សង្កាត់ៗ ដោយផ្អែកលើរាល់ឯកសារពាក់ព័ន្ធដែលមាននៅក្នុងកញ្ចប់ “យ ពិសេស” ប៉ុណ្ណោះ និងមិនត្រូវបើកកញ្ចប់សុវត្ថិភាព “ក” ណាមួយ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ។ ក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ចំណុះរាជធានី ខេត្តណាមួយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ត្រូវ៖


- ១១.១៧.១.១ ចាត់សមាជិកក្រុម ២ (ពីរ) រូបឱ្យទៅនាំយកកញ្ចប់ “យ ពិសេស” នៃរាជធានី ខេត្ត ដែលក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ទទួលបន្ទុកម្តងមួយរាជធានី ខេត្តៗពីកន្លែងរក្សាស្តុកមកដាក់នៅលើតុមុខគាត់។
- ១១.១៧.១.២ ចាត់លេខាធិការឱ្យបញ្ជាប់ចូល (Login) ទៅក្នុងប្រព័ន្ធ ដើម្បីទាញយកទិន្នន័យដែល គធ.ខប បានបញ្ជូនមកសេវ៉ូបកណ៍ (Server) របស់ គ.ជ.ប ឬយូអេសប៊ីផ្លាសដ្រាយ (USB Flash Drive) រក្សាទុកទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដើម្បីបង្ហាញលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់លើឧបទស្សន៍កុំព្យូទ័រ (Monitor) ដើម្បីឱ្យភាគីពាក់ព័ន្ធដែលមានវត្តមានបានមើលឃើញទាំងអស់គ្នា។
- ១១.១៧.១.៣ បើកកញ្ចប់ “យ ពិសេស” រួចដកយករាល់ស្រោមសំបុត្រដាក់ក្រដាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយ គធ.ខប (ទ.១១០៥ធខ) តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ទ.១១១០) និងតារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) មកដាក់នៅលើតុ។
- ១១.១៧.១.៤ រក្សាទុកនៅក្បែរខ្លួនគាត់នូវកញ្ចប់ “យ ពិសេស” ដែលមានតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦ត៣)

កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩)។

១១.១៧.១.៥ ចាត់ចែងសមាជិកក្នុងក្រុមឱ្យត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នីមួយៗ ដោយផ្អែកលើសំណុំឯកសារលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ដូចមានចែងក្នុងចំណុច ១១.១៧.១.២ ខាងលើនេះ ហើយត្រូវផ្ទៀងផ្ទាត់បន្ថែមជាមួយឯកសារផ្សេងទៀតដូចមានចែងក្នុងចំណុច ១១.១៧.១.៣ ខាងលើនេះ ធៀបនឹងទិន្នន័យដែលមានក្នុងកម្មវិធីកុំព្យូទ័រ។

១១.១៧.១.៦ ធានាថារបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យខាងលើនេះ ចំនួន ១ (មួយ) ច្បាប់ សម្រាប់ឃុំ សង្កាត់នីមួយៗត្រូវបានបំពេញ និងចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ដោយត្រូវបញ្ជាក់ច្បាស់នូវខ្លឹមសារដូចខាងក្រោមនេះ ប្រសិនបើបានរកឃើញថា៖

- តួលេខនៃលទ្ធផលដែលបានត្រួតពិនិត្យមានភាពត្រឹមត្រូវ
- គធ.ខប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ហើយកំហុសនោះត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប។ ក្នុងការកែតម្រូវកំហុសនេះ ប្រធានក្រុមត្រូវគូសឆូតលើតួលេខដែលខុស ដោយរក្សាឱ្យឃើញតួលេខដែលខុស រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានហត្ថលេខារបស់ប្រធានក្រុមផង
- ក្នុងការបោះឆ្នោតនៅឃុំ សង្កាត់មានសំឡេងឆ្នោតគាំទ្រស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើនដែលមានសមាជិក កបយ.ស នឹងត្រូវបានទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ (ប្រសិនបើមាន)។



១១.១៧.១.៧ ធានាថាតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) ចំនួន ១ (មួយ) ច្បាប់ ត្រូវបញ្ជាក់ច្បាស់នូវឈ្មោះ និងលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ និងត្រូវចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ។

១១.១៧.១.៨ ធានាថារបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) ដូចមានចែងក្នុងចំណុច ១១.១៧.១.៦ និងចំណុច ១១.១៧.១.៧ ខាងលើនេះ ដែលអមដោយសំណុំឯកសារដូចមានចែងក្នុងចំណុច ១១.១៧.១.២ ខាងលើនេះ ព្រមទាំងកំណត់ហេតុរបស់ គធ.ខប ស្តីពីលទ្ធផលនៃការចាប់ឆ្នោត (ប្រសិនបើមាន) ត្រូវបានដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

១១.១៧.១.៩ ធានាថាទម្រង់បែបបទដូចបានបញ្ជាក់ក្នុងចំណុច ១១.១៧.១.៣ ខាងលើនេះ ដែលបានប្រើក្នុងការត្រួតពិនិត្យលទ្ធផលនេះ ត្រូវតែបានច្រកក្នុងស្រោមសំបុត្រដូចដើម និងដាក់ទៅក្នុងកញ្ចប់ “ឃ ពិសេស” វិញ។

១១.១៧.២ ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលគ្មានពាក្យបណ្តឹងទាំងអស់ចំណុះរាជធានី ខេត្ត ដោយត្រូវត្រួតពិនិត្យម្តងមួយឃុំ សង្កាត់រហូតដល់អស់ និងត្រូវអនុវត្តតាមនីតិវិធីដូចមានចែងចាប់ពីចំណុច ១១.១៧.១.១ រហូតដល់ចំណុច ១១.១៧.១.៨ ខាងលើនេះ។

១១.១៧.៣ អគ្គលេខាធិការ គ.ជ.ប ត្រូវពិនិត្យរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) របស់ក្រុមត្រួតពិនិត្យលទ្ធផលបោះឆ្នោតឡើងវិញនៃ គ.ជ.ប និងសំណុំឯកសារភ្ជាប់ជាមួយដែលបានដាក់ជូនដូចមានចែងក្នុងចំណុច ១១.១៧.១.៨ ខាងលើនេះ។ ប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយ អគ្គលេខាធិការ គ.ជ.ប ត្រូវលើកយោបល់ស្នើសុំការយល់ព្រមពី គ.ជ.ប រួចចុះហត្ថលេខា ឈ្មោះ បោះត្រា អគ្គលេខាធិការដ្ឋាន គ.ជ.ប និងកាលបរិច្ឆេទលើរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យ និងលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) និងដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។

១១.១៧.៤ ប្រសិនបើ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ប្រធាន គ.ជ.ប ត្រូវចារយល់ព្រមលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) ដូចមានចែងក្នុងចំណុច ១១.១៧.៣ ខាងលើនេះ រួចចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងកាលបរិច្ឆេទ បន្ទាប់មកប្រគល់របាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយតាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីមុខការ។

១១.១៧.៥ នៅពេលទទួលបានសំណុំឯកសារត្រួតពិនិត្យលទ្ធផលពីអគ្គលេខាធិការ គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.១៧.៤ ខាងលើនេះ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងអនុវត្តការទទួលខុសត្រូវ និងការកិច្ចរបស់ខ្លួនដូចមានចែងក្នុងចំណុច ១១.១៣.៥ នៃ ប.ន.ឃ.ស នេះ និងចំណុច ១១.១៧.៦ ខាងក្រោមនេះ ដើម្បីធ្វើងផ្ទាត់បញ្ជាក់អំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវរបស់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបយ.ស ដែល គធ.ខប បានត្រួតពិនិត្យ ធ្វើងផ្ទាត់ម្តងរួចហើយ។

១១.១៧.៦ ក្នុងដំណើរការនៃការធ្វើងផ្ទាត់បញ្ជាក់អំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវរបស់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបយ.ស ដែល គធ.ខប បានត្រួតពិនិត្យ ធ្វើងផ្ទាត់ម្តងរួចហើយ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងធ្វើកុំព្យូទ័រកម្មលទ្ធផលនៃការបោះឆ្នោត និងធ្វើប្រមាណវិធីនានា ដើម្បីគណនា ឬ/និងធ្វើងផ្ទាត់ចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទទួលបានឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបយ.ស និងឈ្មោះសមាជិក កបយ.ស ដែលត្រូវទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២។ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងសមាជិកក្រុមឱ្យបំពេញកិច្ចការដូចខាងក្រោម៖

- ១១.១៧.៦.១ បញ្ជាកម្មវិធីឱ្យដំណើរការគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ ត្រូវផ្អែកលើទិន្នន័យដដែល គណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈដោយការអនុវត្តប្រមាណវិធីដោយដៃតាមរូបមន្តដែលកំណត់ដោយច្បាប់ និងដូចមានចែងក្នុងជំពូកទី៤ នៃ ប.ន.ឃ.ស នេះ។ ត្រូវធានាថាលទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈតាមរូបភាពទាំងពីរមានលក្ខណៈត្រឹមត្រូវដូចគ្នា។
- ១១.១៧.៦.២ ទាញយកឈ្មោះបេក្ខជនដែលត្រូវជាប់ឆ្នោតជាសមាជិក កបយ.ស និងឈ្មោះសមាជិក កបយ.ស ដែលត្រូវទទួលតំណែងជាប្រធាន កបយ.ស ជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ពីបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលទទួលបានអាសនៈបញ្ចូលទៅក្នុងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨)។
- ១១.១៧.៦.៣ ពិនិត្យ ធ្វើងផ្ទាត់បន្ថែមកំណត់ហេតុពាក់ព័ន្ធស្តីពីលទ្ធផលនៃការចាប់ឆ្នោតដែល គធ.ខប បានអនុវត្តដូចមានចែងក្នុងចំណុច ១១.៩.៦ និងចំណុច ១១.៩.៧ នៃ ប.ន.ឃ.ស នេះ។

១១.១៧.៦.៤ បោះពុម្ព ឬរៀបចំឯកសារលទ្ធផលនៃការអនុវត្តចំណុច ១១.៧.៦.២ និងចំណុច ១១.១៧.៦.៣ ខាងលើនេះ ក្នុងមួយមុខ ១ (មួយ) ច្បាប់ ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់បន្ថែមជាមួយនឹងបញ្ជីបេក្ខជនផ្លូវការ និង តារាងលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជន ជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១១) ពាក់ព័ន្ធ។

១១.១៧.៦.៥ អនុវត្តនីតិវិធីដូចមានចែងចាប់ពីចំណុច ១១.១៧.៦.២ រហូតដល់ ចំណុច ១១.១៧.៦.៤ ខាងលើនេះឡើងវិញម្តងទៀត ប្រសិនបើ លទ្ធផលនៃការផ្ទៀងផ្ទាត់ដូចមានចែងក្នុងចំណុច ១១.១៧.៦.៤ ខាងលើនេះមានភាពខុសគ្នាពីលទ្ធផលដែល គឧ.ខប បានត្រួតពិនិត្យ ម្តងហើយ។ ក្នុងករណីលទ្ធផលនៃការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនេះ នៅតែមានភាពខុសគ្នា ត្រូវយកតាមលទ្ធផលដែលក្រុមកំណត់ បែងចែកអាសនៈនៃ គ.ជ.ប បានគណនា និងផ្ទៀងផ្ទាត់។

១១.១៧.៦.៦ បន្ទាប់ពីការផ្ទៀងផ្ទាត់ឃើញលទ្ធផលត្រឹមត្រូវហើយ ប្រធានក្រុម ត្រូវធានាថាតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈដោយកុំព្យូទ័រ ១ (មួយ) ច្បាប់ និងតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈតាមការធ្វើ ប្រមាណវិធីដោយដៃ ១ (មួយ) ច្បាប់ ត្រូវបានចុះហត្ថលេខាដោយ លេខាធិការ អនុប្រធានក្រុម និងប្រធានក្រុម ហើយលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) ចំនួន ៥ (ប្រាំ) ច្បាប់ ដែលភ្ជាប់ជាមួយនូវសំណុំឯកសារពាក់ព័ន្ធ ដែលក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប បានទទួលដូចមានចែង ក្នុងចំណុច ១១.១៧.៤ ខាងលើនេះ ត្រូវបានដាក់ជូន គ.ជ.ប តាមរយៈ អគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

១១.១៧.៦.៧ ស្តែនតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) និងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) ដែលប្រធាន គ.ជ.ប បានចុះ ហត្ថលេខាយល់ព្រមរួចហើយចូលក្នុងកម្មវិធីកុំព្យូទ័រ។

ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គយ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ហើយដែលមានកញ្ចប់សុវត្ថិភាព "ក" មួយ ឬច្រើនត្រូវបានបើកត្រួតពិនិត្យ ផ្ទៀងផ្ទាត់

ប្រការ១១.១៨.-

យោងតាមការកំណត់របស់ គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.១៥.១ នៃ ប.ន.ឃ.ស នេះ ប្រសិនបើឃុំ សង្កាត់ដែលនឹងត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ស្ថិតក្នុងករណីឃុំ សង្កាត់ដូចមានចែងក្នុងចំណុច ១១.១៥.២.៣ អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ នៃ គ.ជ.ប ទទួលបន្ទុក និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ឱ្យធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមនីតិវិធីដូចខាងក្រោម៖

១១.១៨.១ ផ្អែកតាមការសម្រេចរបស់ គ.ជ.ប មិនឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុក ត្រូវពិនិត្យជាមុននូវសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ និងត្រូវធានាថាផ្អែកលើរាល់ឯកសារដែលមាននៅក្នុងកញ្ចប់ "ឃ ពិសេស" ដូចមានចែងក្នុងចំណុច ១១.១១.២ ខាងលើនេះ នីតិវិធីក្នុងដំពូកនេះចាប់ពីចំណុច ១១.១៧.១.១ រហូតដល់ចំណុច ១១.១៧.១.៨ ខាងលើនេះ ត្រូវតែបានអនុវត្ត។

១១.១៨.២ បន្ទាប់ពីបានអនុវត្តរាល់នីតិវិធីដូចមានចែងក្នុងចំណុច ១១.១៨.១ ខាងលើនេះរួច អគ្គលេខាធិការ គ.ជ.ប ត្រូវពិនិត្យរបាយការណ៍ តារាងត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារភ្ជាប់ជាមួយ ដែលក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប បានដាក់ជូនដូចមានចែងក្នុងចំណុច ១១.១៧.១.៦ ចំណុច ១១.១៧.១.៧ ខាងលើនេះ។ ប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយ អគ្គលេខាធិការ គ.ជ.ប ត្រូវចារលើកយោបល់ស្នើសុំការយល់ព្រមពី គ.ជ.ប រួចចុះហត្ថលេខា ឈ្មោះ បោះត្រាអគ្គលេខាធិការដ្ឋាន គ.ជ.ប និងកាលបរិច្ឆេទលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) ហើយដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។

១១.១៨.៣ ផ្អែកលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយដូចមានចែងក្នុងចំណុច ១១.១៨.២ ខាងលើនេះ ទោះបីមានពាក្យបណ្តឹងដាក់នៅ គយ.សប ឬ/និង គធ.ខប ក្តី ប៉ុន្តែគ្មានពាក្យបណ្តឹងដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវពិនិត្យ សម្រេចយល់ព្រមតាមយោបល់របស់អគ្គលេខាធិការ គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.១៨.២ ខាងលើនេះ។

ក្នុងករណីមានពាក្យបណ្តឹងដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធ។ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ៖

១១.១៨.៣.១ ចារយល់ព្រមលើសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ឧប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

១១.១៨.៣.២ ចារយល់ព្រមលើរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យ និងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

១១.១៨.៣.៣ ធានាថាមន្ត្រីជំនាញបានបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ហើយត្រូវចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ដោយមន្ត្រីជំនាញ និងប្រធាន គ.ជ.ប។

១១.១៨.៣.៤ ធានាថាសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមខាងលើត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់សម្រាប់ប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ (សម្រាប់ពាក្យបណ្តឹងដាក់នៅ គ.ជ.ប) ជូនគ្រប់តំណាង ឬភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ឧប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១១.១៨.៣.៥ ប្រកាសថាសេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ជាសេចក្តីសម្រេចចុងក្រោយ។

១១.១៨.៣.៦ ប្រគល់របាយការណ៍ តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) និងសេចក្តីសម្រេចរបស់ គធ.ឧប ដែលមានចំណាររបស់ប្រធាន គ.ជ.ប និងសេចក្តីសម្រេចរបស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់

ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់មួយមុខ ១ (មួយ) ច្បាប់ ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយ តាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមកំណត់បែងចែកអាសនៈដើម្បីមុខការ។

១១.១៨.៤ នៅពេលទទួលបានសំណុំឯកសារត្រួតពិនិត្យលទ្ធផលដែលមានចំណាររបស់ប្រធាន គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.១៨.៣.៦ ខាងលើនេះ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងអនុវត្តការទទួលខុសត្រូវ និងភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងចំណុច ១១.១៣.៥ នៃ ប.ន.ឃ.ស នេះ ហើយត្រូវធានាថារាល់នីតិវិធីដូចមានចែងក្នុងចំណុច ១១.១៧.៦ ខាងលើនេះ ត្រូវតែបានអនុវត្ត។

១១.១៨.៥ ដោយឡែក ប្រសិនបើផ្អែកតាមកម្រិតនៃភាពមិនប្រក្រតីពាក់ព័ន្ធនឹងពាក្យបណ្តឹងដែលអាចនាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ គ.ជ.ប បានសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព “ក” មួយ ឬច្រើន ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនោះ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ទទួលបន្ទុកត្រូវពិនិត្យជាមុននូវពាក្យបណ្តឹងពាក់ព័ន្ធដែលបានដាក់នៅ គ.ជ.ប និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ហើយផ្អែកលើរាល់ឯកសារដែលមាននៅក្នុងកញ្ចប់ “ឃ ពិសេស” និងស្បោង “ឃ” ពាក់ព័ន្ធដូចបានបញ្ជាក់ក្នុងចំណុច ១១.១១.២ ចំណុច ១១.១១.៥ និងចំណុច ១១.១១.៦ នៃ ប.ន.ឃ.ស នេះ ត្រូវគួបផ្សំអនុវត្តឱ្យបានត្រឹមត្រូវតាមលំដាប់លំដោយតាមលំនាំនីតិវិធីដូចមានចែងក្នុងដំពូកនេះចាប់ពីចំណុច ១១.១៦.៣ រហូតដល់ចំណុច ១១.១៦.៥ និងចាប់ពីចំណុច ១១.១៧.១.១ រហូតដល់ចំណុច ១១.១៧.១.៨ ខាងលើនេះ។

១១.១៨.៦ បន្ទាប់ពីបញ្ចប់ការអនុវត្តចំណុច ១១.១៨.៥ ខាងលើនេះ អគ្គលេខាធិការ គ.ជ.ប ត្រូវពិនិត្យ និងលើកយោបល់លើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) ដូចមានចែងក្នុងចំណុច ១១.១៧.១.៧ ខាងលើនេះ និងរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញដូចមានចែងក្នុងចំណុច ១១.១៦.៥ ខាងលើនេះ ដែលក្រុមត្រួតពិនិត្យលទ្ធផលបានដាក់ជូន រួចចុះហត្ថលេខា និងដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។ អគ្គលេខាធិការ គ.ជ.ប ត្រូវ៖



១១.១៨.៦.១ លើកយោបល់ស្នើសុំបដិសេធសេចក្តីសម្រេចយល់ព្រមទទួលយកលទ្ធផលរបស់ គធ.ខប និងសុំការយល់ព្រមតាមពាក្យបណ្តឹងដាក់

នៅ គ.ជ.ប ដោយត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រសិនបើមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ឬ

១១.១៨.៦.២ លើកយោបល់ស្នើសុំយល់ព្រមតាមសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមរបស់ គធ.ខប និងសុំបដិសេធពាក្យបណ្តឹងដាក់នៅ គ.ជ.ប ដោយត្រូវយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ប្រសិនបើកម្រិតនៃភាពមិនប្រក្រតីមិននាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទេ។

១១.១៨.៧ ផ្អែកលើសំណុំឯកសារដូចមានចែងក្នុងចំណុច ១១.១៨.៦ ខាងលើនេះ ទោះបីមានពាក្យបណ្តឹងដាក់នៅ គឃ.សប ឬ/និង គធ.ខប ក្តី ប៉ុន្តែគ្មានពាក្យបណ្តឹងដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវពិនិត្យ សម្រេចដោយផ្អែកលើសំណើរបស់អគ្គលេខាធិការ គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.១៨.៦ ខាងលើនេះ។ ក្នុងករណីមានពាក្យបណ្តឹងដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធ។ ប្រសិនបើ គ.ជ.ប សម្រេចបដិសេធសេចក្តីសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតរបស់ គធ.ខប និងយល់ព្រមតាមពាក្យបណ្តឹងដាក់នៅ គ.ជ.ប ដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ៖

១១.១៨.៧.១ ចារបដិសេធលើសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

១១.១៨.៧.២ ធានាថាមន្ត្រីជំនាញបានបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដោយបញ្ជាក់ច្បាស់អំពីមូលហេតុនៃការបដិសេធផង ហើយត្រូវចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ដោយមន្ត្រីជំនាញ និងប្រធាន គ.ជ.ប។



១១.១៨.៧.៣ ធានាថាសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធខាងលើត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់សម្រាប់ប្រគល់ជូនអ្នកប្តឹង ឬ

តំណាង ១ (មួយ) ច្បាប់ (សម្រាប់ពាក្យបណ្តឹងដាក់នៅ គ.ជ.ប) ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ៣ក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ៣ក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១១.១៨.៧.៤ ប្រកាសថាសេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ជាសេចក្តីសម្រេចចុងក្រោយ ហើយ គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់នៃឃុំ សង្កាត់នោះ មិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេចបដិសេធ។

១១.១៨.៧.៥ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧តព) និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលមានចំណារប្រធាន គ.ជ.ប និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះមួយមុខ ១ (មួយ) ច្បាប់ តាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញទទួលបន្ទុកដែលត្រូវដាក់ទៅក្នុងកញ្ចប់ "ឃ ពិសេស" នៃរាជធានី ខេត្ត៣ក់ព័ន្ធ។

១១.១៨.៧.៦ ធានាថាក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប បានវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ៣ក់ព័ន្ធដាក់ក្នុងស្បោង "ខ" និងស្បោង "គ" នៃឃុំ សង្កាត់នោះតាមលំនាំដើម រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ដើម្បីរក្សាទុកនៅកន្លែងដើមវិញ។

១១.១៨.៨ យោងសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធរបស់ គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.១៨.៧.២ ខាងលើនេះ គ.ជ.ប ត្រូវចាត់ចែង និងណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់៣ក់ព័ន្ធ

ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យទាំងនោះ ត្រូវបានបដិសេធ ដោយត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី១២ នៃ ប.ន.ឃ.ស នេះ។ ការបោះឆ្នោតសាជាថ្មីនេះ ត្រូវអនុវត្តដោយផ្អែកលើបញ្ជីបោះឆ្នោតដដែល បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដដែល និងសន្លឹកឆ្នោតដែលមានទម្រង់ និងខ្លឹមសារដដែល ប៉ុន្តែត្រូវបោះពុម្ពថ្មីលើក្រដាសពណ៌ផ្សេង។

១១.១៨.៩ ផ្អែកលើសំណុំឯកសារត្រួតពិនិត្យលទ្ធផលដូចមានចែងក្នុងចំណុច ១១.១៨.៦ ខាងលើនេះ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមសេចក្តីសម្រេចរបស់ គធ.ខប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវធានាថាបញ្ញត្តិ និងនីតិវិធីដូចមានចែងក្នុងចំណុច ១១.១៨.៣ ខាងលើនេះ ត្រូវតែបានអនុវត្ត។

១១.១៨.១០ ក្នុងការអនុវត្តចំណុច ១១.១៨.៩ ខាងលើនេះ និងនៅពេលទទួលបានសំណុំឯកសារត្រួតពិនិត្យលទ្ធផលដែលមានចំណារប្រធាន គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.១៨.៣.៧ ខាងលើនេះ ប្រធានក្រុមកំណត់បែងចែកអាសនៈត្រូវចាត់ចែងអនុវត្តការទទួលខុសត្រូវ និងភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងចំណុច ១១.១៣.៥ ខាងលើនេះ និងត្រូវធានាថារាល់នីតិវិធីដូចមានចែងក្នុងចំណុច ១១.១៧.៦ ខាងលើនេះ ត្រូវតែបានអនុវត្ត។

១១.១៨.១១ នៅពេលដែលក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ហើយដែលត្រូវបាន គ.ជ.ប សម្រេចបដិសេធ ឬយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស ទាំងនោះរួចហើយ អគ្គលេខាធិការ គ.ជ.ប ត្រូវធានាថាក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ទទួលបន្ទុកតាមរាជធានី ខេត្តនីមួយៗ និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប បានរៀបចំទុកដាក់រាល់របាយការណ៍ ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធដែលបានប្រើក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ខាងលើ ដោយត្រូវច្រកទៅក្នុងស្រោមសំបុត្រ និងដាក់ទៅក្នុងកញ្ចប់ “ឃ ពិសេស” ឬ/និងក្នុងកញ្ចប់សុវត្ថិភាព “ក” ស្បោង “ខ” ស្បោង “គ” និងស្បោង “ឃ” តាមលំនាំដូចដើម និងនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារៈឯកសារបោះឆ្នោតនៃ គ.ជ.ប ដើម្បីរក្សាទុកនៅកន្លែងដើមវិញ។

ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ហើយមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.ខប ឬ/និង គ.ជ.ប

ប្រការ១១.១៩.-

យោងតាមការកំណត់របស់ គ.ជ.ប ដូចមានចែងក្នុងចំណុច ១១.១៥.១ នៃ ប.ន.ឃ.ស នេះ ប្រសិនបើឃុំ សង្កាត់ ដែលនឹងត្រូវធ្វើការត្រួតពិនិត្យលទ្ធផលឡើងវិញស្ថិតក្នុងករណីឃុំ សង្កាត់ ដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយក្នុងករណីឃុំ សង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដូចមានចែងក្នុងចំណុច ១១.១៥.២ នៃ ប.ន.ឃ.ស នេះ អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញដែលទទួលបន្ទុក និងក្រុមកំណត់បែងចែកអាសនៈឱ្យធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមនីតិវិធីដូចខាងក្រោម៖

១១.១៩.១ ប្រសិនបើគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងករណីដូចមានចែងក្នុងប្រការ១១.១៩ ខាងលើនេះ ត្រូវបានដាក់នៅ គ.ជ.ប ដូចមានចែងក្នុងប្រការ១១.១២ នៃ ប.ន.ឃ.ស នេះ ទេនោះ គ.ជ.ប និងអគ្គលេខាធិការ គ.ជ.ប ត្រូវធានាថារាល់នីតិវិធីដូចមានចែងក្នុងប្រការ១១.១៧ ខាងលើនេះ ត្រូវតែបានអនុវត្ត។

១១.១៩.២ ប្រសិនបើមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងករណីដូចមានចែងក្នុងប្រការ១១.១៩ ខាងលើនេះ ត្រូវបានដាក់នៅ គ.ជ.ប ក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប បានធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងប្រការ១១.១៨ ខាងលើនេះ រួចហើយនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹង គ.ជ.ប ត្រូវផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យដែលអគ្គលេខាធិការ គ.ជ.ប បានដាក់ជូនដើម្បីពិនិត្យ សម្រេច ដោយមិនចាំបាច់ឱ្យធ្វើការត្រួតពិនិត្យ ឬ/និងបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ។

១១.១៩.៣ ប្រសិនបើមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងករណីដូចមានចែងក្នុងប្រការ១១.១៩ ខាងលើនេះ ត្រូវបានដាក់នៅ គ.ជ.ប ក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប បានធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងប្រការ ១១.១៧ ខាងលើនេះ រួចហើយនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹង គ.ជ.ប និងអគ្គលេខាធិការ គ.ជ.ប ត្រូវធានាថារាល់នីតិវិធីដូចមានចែងក្នុងចំណុច ១១.១៨.៥ និងចំណុច ១១.១៨.៦ ខាងលើនេះ ត្រូវតែបានអនុវត្ត។

១១.១៩.៤ ប្រសិនបើមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងករណីដូចមានចែងក្នុងប្រការ១១.១៩ ខាងលើនេះ ត្រូវបានដាក់នៅ គ.ជ.ប និងមានជាប់ទាក់ទងនឹងឃុំ សង្កាត់ដែលមិនទាន់បានត្រួតពិនិត្យលទ្ធផលនៅឡើយ គ.ជ.ប និងអគ្គលេខាធិការ គ.ជ.ប ត្រូវធានាថារាល់នីតិវិធីដូចមានចែងចាប់ពីចំណុច ១១.១៧.១.១ រហូតដល់ចំណុច ១១.១៧.១.៨ និងចាប់ពីចំណុច ១១.១៨.៥ រហូតដល់ចំណុច ១១.១៨.៦ ខាងលើនេះ ត្រូវតែបានអនុវត្ត។

១១.១៩.៥ ផ្អែកលើលទ្ធផលដោយឡែកពីគ្នានៃការអនុវត្តចំណុច ១១.១៩.២ រហូតដល់ចំណុច ១១.១៩.៤ ខាងលើនេះ គ.ជ.ប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធនីមួយៗ។

១១.១៩.៦ ប្រសិនបើផ្អែកលើលទ្ធផលនៃការអនុវត្តដូចបញ្ជាក់ក្នុងចំណុច ១១.១៩.៥ ខាងលើនេះ បង្ហាញឱ្យឃើញថាពិតជាមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះមែន គ.ជ.ប ត្រូវសម្រេចយល់ព្រមតាមពាក្យបណ្តឹងនោះ។ គ.ជ.ប ត្រូវធានាថារាល់នីតិវិធីដូចមានចែងចាប់ពីចំណុច ១១.១៨.៧.១ រហូតដល់ចំណុច ១១.១៨.៧.៦ និងចំណុច ១១.១៨.៨ ខាងលើនេះ ត្រូវតែបានអនុវត្ត។

១១.១៩.៧ ប្រសិនបើផ្អែកលើលទ្ធផលនៃការអនុវត្តដូចបញ្ជាក់ក្នុងចំណុច ១១.១៩.៥ ខាងលើនេះ បង្ហាញឱ្យឃើញថាកម្រិតនៃភាពមិនប្រក្រតីមិននាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះទេ គ.ជ.ប ត្រូវសម្រេចបដិសេធពាក្យបណ្តឹងតវ៉ានោះ។ គ.ជ.ប ត្រូវធានាថារាល់នីតិវិធីដូចមានចែងចាប់ពីចំណុច ១១.១៨.៩ រហូតដល់ចំណុច ១១.១៨.១១ ខាងលើនេះ ត្រូវតែបានអនុវត្ត។

១១.១៩.៨ នៅពេលដែលក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលមានលម្អៀងសំឡេងឆ្នោតយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គ.ជ.ប ហើយដែលត្រូវបាន គ.ជ.ប សម្រេចយល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស ទាំងនោះរួចហើយ អគ្គលេខាធិការ គ.ជ.ប ត្រូវធានាថាក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ទទួលបន្ទុករាជធានី ខេត្តនីមួយៗ និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប បានរៀបចំទុកដាក់រាល់របាយការណ៍ ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធដែលបានប្រើក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ខាងលើដោយត្រូវច្រកទៅក្នុងស្រោមសំបុត្រ និងដាក់ទៅក្នុងកញ្ចប់ “យ ពិសេស” ឬ/និងក្នុងកញ្ចប់សុវត្ថិភាព “ក” ស្បោង “ខ” ស្បោង “គ” និងស្បោង “ឃ” តាមលំនាំដូចដើម រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារៈឯកសារបោះឆ្នោតនៃ គ.ជ.ប ដើម្បីរក្សាទុកនៅកន្លែងដើមវិញ។

ការរៀបចំ និងការផ្សព្វផ្សាយសេចក្តីប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើស កបយ.ស

ប្រការ១១.២០.

បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីនៃការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើស កបយ.ស នៅ គ.ជ.ប ដូចមានចែងចាប់ពីប្រការ១១.១៦ រហូតដល់ប្រការ ១១.១៩ ខាងលើនេះ គ.ជ.ប ត្រូវធានាថា៖

១១.២០.១ ផ្អែកតាមរាល់សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់ដូចមានចែងក្នុងចំណុច ១១.១៦.៧.៣ ចំណុច ១១.១៨.៧.២ និងចំណុច ១១.១៩.៦ នៃ ប.ន.ឃ.ស នេះ គ.ជ.ប បានរៀបចំ និងចាត់ចែងការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតមួយឬច្រើន ឬនៅការិយាល័យទាំងអស់នៃឃុំ សង្កាត់ពាក់ព័ន្ធ ដោយត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី១២ នៃ ប.ន.ឃ.ស នេះ។

១១.២០.២ ផ្អែកតាមរាល់សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ហើយដែលត្រូវបានក្រុមកំណត់បែងចែកអាសនៈ រៀបចំសំណុំឯកសារពាក់ព័ន្ធដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យសម្រេចដូចមានចែងក្នុងចំណុច ១១.១៦.១០.៤ ចំណុច ១១.១៧.៦.៧ ចំណុច ១១.១៨.៤ ចំណុច ១១.១៨.១០ និងចំណុច ១១.១៩.៧ នៃ ប.ន.ឃ.ស នេះ ប្រធាន គ.ជ.ប បានចុះហត្ថលេខា បោះត្រា គ.ជ.ប និងកាលបរិច្ឆេទលើលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) និងតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នានា។ ប្រធាន គ.ជ.ប ត្រូវចាត់ចែង និងប្រើប្រាស់លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) និងតារាលទ្ធផលផ្លូវការនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នានាដូចខាងក្រោម៖

- ១១.២០.២.១ ផ្ញើជូននាយករដ្ឋមន្ត្រី ១ (មួយ) ច្បាប់។
- ១១.២០.២.២ ផ្ញើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ១ (មួយ) ច្បាប់។
- ១១.២០.២.៣ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ដើម្បីបិទផ្សាយនៅលគធ.ខប។
- ១១.២០.២.៤ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ដើម្បីបិទផ្សាយនៅទីស្នាក់ការ គយ.សប។
- ១១.២០.២.៥ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។
- ១១.២០.២.៦ ចាត់ចែងផ្សព្វផ្សាយជាសាធារណៈ។

១១.២០.៣ ផ្អែកតាមរាល់សេចក្តីសម្រេចរបស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលត្រូវបោះឆ្នោតសាជាថ្មីដូចមានចែងក្នុងចំណុច ១១.២០.១ ខាងលើនេះ ដែលប្រធាន គ.ជ.ប បានចុះហត្ថលេខា បោះត្រា គ.ជ.ប និងកាលបរិច្ឆេទលើលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ទ.១១១៨) ពាក់ព័ន្ធ និងបានចាត់ចែងប្រើប្រាស់តាមការកំណត់ដូចមានចែងចាប់ពីចំណុច ១១.២០.២.១ រហូតដល់ចំណុច ១១.២០.២.៦ ខាងលើនេះ។

ការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបានអនុវត្តសិទ្ធិបោះឆ្នោត

ប្រការ១១.២១.

ក្រោយពីបានអនុវត្តចប់សព្វគ្រប់ការប្រកាសផ្សាយលទ្ធផលផ្លូវការនៃការបោះឆ្នោតដូចមានចែងក្នុងប្រការ១១.២០ ខាងលើនេះ គ.ជ.ប ត្រូវចាត់ចែងណែនាំឱ្យអគ្គលេខាធិការដ្ឋាន គ.ជ.ប អនុវត្តការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបានអនុវត្តសិទ្ធិបោះឆ្នោត ស្របតាមគោលការណ៍ណែនាំរបស់ គ.ជ.ប។

ជំពូកទី១២
ការបិទការិយាល័យបោះឆ្នោតក្នុងគ្រាមានអាសន្ន និងការបោះឆ្នោតសាជាថ្មី

ការបិទការិយាល័យបោះឆ្នោតក្នុងគ្រាមានអាសន្ន

ប្រការ១២.១.

មុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត ប្រសិនបើការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួនស្ថិតក្នុងកាលៈទេសៈមានអាសន្នដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត គ.ជ.ប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតនោះ ឬទាំងនោះបាន។

១២.១.១ ការសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតបាន លុះត្រាតែការិយាល័យបោះឆ្នោតនោះ ឬទាំងនោះស្ថិតក្នុងកាលៈទេសៈមានអាសន្ន។ កាលៈទេសៈមានអាសន្នត្រូវបានកំណត់ក្នុងចំណោមករណីណាមួយខាងក្រោម៖

- ១២.១.១.១ អសន្តិសុខជាសាធារណៈ។
- ១២.១.១.២ ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី ឬគ្រោះធម្មជាតិផ្សេងទៀត។
- ១២.១.១.៣ ការដួលរលំអគារសម្រាប់បម្រើការបោះឆ្នោតដោយយថាហេតុណាមួយ អគ្គិភ័យ ឬការខូចខាតប្រហាក់ប្រហែលគ្នាដែលនាំឱ្យមានគ្រោះថ្នាក់។
- ១២.១.១.៤ ការរាំងស្ទះផ្នែករដ្ឋបាលដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន។
- ១២.១.១.៥ ការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ។

១២.១.២ នៅមុនថ្ងៃបោះឆ្នោត ប្រសិនបើកើតមានករណីណាមួយនៃកាលៈទេសៈមានអាសន្នដូចមានចែងក្នុងចំណុច ១២.១.១ ខាងលើនេះ ប្រធាន គ.ក.ប ត្រូវរាយការណ៍បន្ទាន់ពីស្ថានភាពជាក់ស្តែងទៅ គយ.សប។

- ១២.១.២.១ គយ.សប ត្រូវវាយតម្លៃសភាពការណ៍ជាក់ស្តែង ពិនិត្យលទ្ធភាពអាចបើកការិយាល័យបោះឆ្នោតបាន ឬមិនបាន និងរាយការណ៍បន្ទាន់ជូន គធ.ខប។
- ១២.១.២.២ គធ.ខប ត្រូវពិនិត្យ និងវាយតម្លៃសភាពការណ៍ច្បាស់លាស់ដោយផ្តល់យោបល់ និងរាយការណ៍បន្ទាន់ជូន គ.ជ.ប ដើម្បី គ.ជ.ប សម្រេចអំពីការបើក ឬមិនបើកការិយាល័យបោះឆ្នោត។

១២.១.២.៣ ក្រោយការសម្រេចបើក ឬមិនបើកការិយាល័យបោះឆ្នោត គ.ជ.ប ត្រូវជូនដំណឹងបន្ទាន់ទៅ គធ.ខប ដើម្បី គធ.ខប ចាត់ចែងបន្ត។

១២.១.២.៤ ការរាយការណ៍បន្ទាន់ និងការជូនដំណឹងបន្ទាន់ខាងលើត្រូវធ្វើតាមទូរសព្ទ ទូរសារ វិទ្យុទាក់ទង អ៊ីមែល ឬតាមមធ្យោបាយផ្សេងៗទៀត។

១២.១.៣ នៅក្នុងថ្ងៃបោះឆ្នោត នៅមុនពេល ឬក្នុងពេលដំណើរការបោះឆ្នោត ប្រសិនបើកើតមានករណីណាមួយនៃកាលៈទេសៈមានអាសន្នដូចមានចែងក្នុងចំណុច ១២.១.១ ខាងលើនេះ ប្រធាន គ.ក.ប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោត។ ប្រធាន គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់អំពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតជូន គឃ.សប ដើម្បី គឃ.សប រាយការណ៍បន្តទៅ គធ.ខប និងដើម្បី គធ.ខប រាយការណ៍បន្ទាន់ជូន គ.ជ.ប។

១២.១.៤ ការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬដែលត្រូវបានបិទនៅថ្ងៃបោះឆ្នោតដោយសារកាលៈទេសៈមានអាសន្ន ត្រូវតែបិទរហូតពេញមួយថ្ងៃ។

ប្រការ១២.២.

គ.ជ.ប ត្រូវរាយការណ៍ភ្លាមជូននាយករដ្ឋមន្ត្រីអំពីការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ណាដែលមិនត្រូវបានបើក ឬត្រូវបានបិទដោយសារកាលៈទេសៈមានអាសន្ននៅមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត។

ប្រការ១២.៣.

ក្នុងករណីមានការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទ ដោយមាន គ.ក.ប ជាជំនួយ គឃ.សប ពាក់ព័ន្ធត្រូវ៖

១២.៣.១ ជូនដំណឹងដល់អ្នកបោះឆ្នោតដែលត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះអំពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតនោះ ឬទាំងនោះដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់។

១២.៣.២ ប្រមូលសម្ភារ ឯកសារពាក់ព័ន្ធផ្សេងទៀតសម្រាប់បម្រើការបោះឆ្នោតមករក្សាទុកនៅ គឃ.សប។

១២.៣.៣ ប្រមូលសន្លឹកឆ្នោតដែលបោះរួចហើយនៅការិយាល័យបោះឆ្នោតដែលត្រូវបានបិទក្នុងអំឡុងការបោះឆ្នោត រាប់ចំនួន និងកត់ត្រាទុកក្នុងកំណត់ហេតុរួចដាក់ក្នុងស្បោងមួយដោយឡែក។ សន្លឹកឆ្នោតទាំងនេះត្រូវទុកជាមោយៈគឺមិនត្រូវរាប់បញ្ចូលក្នុងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតឡើយ។



១២.៣.៤ ធ្វើកំណត់ហេតុស្តីពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ និងរាយការណ៍ជូន គធ.ខប ដើម្បីថរាយការណ៍ជូន គ.ជ.ប។

១២.៣.៥ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខកើតមានឡើងនៅការិយាល័យបោះឆ្នោត ក្រោយពេលបិទការបោះឆ្នោត ដែលពេលនោះកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ត្រូវបានធ្វើរួចរាល់ ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចហើយនៅខាងក្នុង និងសម្ភារ ឯកសារបោះឆ្នោតនៅរក្សាបានល្អ គ.ក.ប ត្រូវវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតទាំងនោះ បញ្ជូនទៅ គឃ.សប ដើម្បីចាត់ចែងរាប់សន្លឹកឆ្នោតតាមការកំណត់នៃ ប.ន.ឃ.ស នេះ។

១២.៣.៦ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខកើតមានឡើងនៅការិយាល័យបោះឆ្នោត ក្រោយពេលបិទការបោះឆ្នោតដែលពេលនោះកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ត្រូវបានធ្វើរួចរាល់ ប៉ុន្តែហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចហើយនៅខាងក្នុង និងសម្ភារ ឯកសារបោះឆ្នោតត្រូវបានបំផ្លាញ ឬខូចខាត គ.ក.ប ត្រូវវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតទាំងនោះបញ្ជូនទៅ គឃ.សប ដើម្បីបន្តរាយការណ៍ជូន គធ.ខប និង គ.ជ.ប សុំឱ្យមានការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

ប្រការ១២.៤._

សមាសភាព គ.ក.ប នៃការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទ ត្រូវរំសាយទទួលបានប្រាក់កម្រៃស្របតាមកិច្ចសន្យា។

ប្រការ១២.៥._

គ.ក.ប នៃការិយាល័យបោះឆ្នោតដែលមិនត្រូវបានបិទត្រូវអនុវត្តដំណើរការនៃការបោះឆ្នោត ហើយការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រមូល ការប្រគល់ ការទទួលសម្ភារ ឯកសារបោះឆ្នោតធម្មតាតាម ប.ន.ឃ.ស នេះ។

១២.៥.១ គឃ.សប ត្រូវរក្សាទុក និងការពារឱ្យបានគត់មត់នូវសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងដែលមិនទាន់បានប្រើប្រាស់ លទ្ធផលនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៃការិយាល័យបោះឆ្នោតដែលមិនត្រូវបានបិទនៅទីស្នាក់ការ គឃ.សប ឬនៅកន្លែងធានាសុវត្ថិភាពណាមួយដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប រហូតដល់ពេលបញ្ចប់ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទ។

១២.៥.២ សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតដែលមិនត្រូវបានបិទអាចត្រូវប្រមូលប្រគល់ទៅឱ្យ គធ.ខប ឬត្រូវរក្សាទុកសិននៅ គឃ.សប ទៅតាមសភាពជាក់ស្តែងដែលសម្រេចដោយ គធ.ខប។



១២.៥.៣ គឃ.សប ត្រូវរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលត្រូវធ្វើការបោះឆ្នោតសាជាថ្មីក្នុងករណីកាលៈទេសៈមានអាសន្ន តាមការសម្រេចរបស់ គ.ជ.ប ប៉ុន្តែមិនត្រូវលើសពី ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីថ្ងៃសម្រេចមិនបើក ឬបិទ។

ការបោះឆ្នោតសាជាថ្មីក្នុងករណីកាលៈទេសៈមានអាសន្ន

ប្រការ១២.៦.

ការបោះឆ្នោតសាជាថ្មីក្នុងករណីកាលៈទេសៈមានអាសន្នដូចមានចែងក្នុងប្រការ១២.១ និងចំណុច ១២.៣.៦ ខាងលើនេះ ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប ស្របតាម ច.ប.ឃ.ស និងអនុលោមតាមប្រការ១២.៧ រហូតដល់ប្រការ១២.១២ នៃ ប.ន.ឃ.ស នេះ។

ការបោះឆ្នោតសាជាថ្មីក្នុងករណីបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត

ប្រការ១២.៧.

ក្នុងករណី គ.ជ.ប សម្រេចបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតសាជាថ្មីក្នុងរយៈពេលមិនលើសពី ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីថ្ងៃបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះនៅទីតាំងដដែល ឬទីតាំងណាមួយមិនឆ្ងាយពីទីតាំងចាស់នៅក្នុងឃុំ សង្កាត់ដែលមានសន្តិសុខ និងសុវត្ថិភាពល្អ។

១២.៧.១ គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទ និងទីតាំងនៃការបោះឆ្នោតសាជាថ្មី និងណែនាំ គយ.សប ឱ្យផ្សព្វផ្សាយ និងបិទផ្សាយនៅ គយ.សប និងនៅទីតាំងការិយាល័យដែលត្រូវបោះឆ្នោតសាជាថ្មីយ៉ាងតិច ២០ (ម្ភៃ) ថ្ងៃមុនថ្ងៃបោះឆ្នោតសាជាថ្មី។

១២.៧.២ ដើម្បីគ្រប់គ្រង និងចាត់ចែងការរៀបចំការបោះឆ្នោតសាជាថ្មី គ.ជ.ប ត្រូវ៖

- ១- រក្សាសមាសភាព គធ.ខប និងមន្ត្រី លគធ.ខប មួយចំនួនតាមតម្រូវការនៃការងារ។
- ២- រក្សាសមាសភាព គយ.សប ពាក់ព័ន្ធ។
- ៣- ណែនាំការជ្រើសរើស គ.ក.ប/គ.ក.រ សម្រាប់ការបោះឆ្នោតសាជាថ្មីតាមបែបបទ និងនីតិវិធីនៃការជ្រើសរើសដូចមានចែងក្នុង ប.ន.ឃ.ស នេះ។

១២.៧.៣ អាណត្តិរបស់ គធ.ខប គយ.សប និង គ.ក.ប/គ.ក.រ សម្រាប់ការបោះឆ្នោតសាជាថ្មីត្រូវបញ្ចប់តាមការកំណត់របស់ គ.ជ.ប។

១២.៧.៤ សិទ្ធិអំណាច និងការកិច្ចរបស់ គធ.ខប គយ.សប និង គ.ក.ប/គ.ក.រ ត្រូវអនុលោមតាម ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ ទៅតាមតម្រូវការជាក់ស្តែងនៃការបោះឆ្នោតសាជាថ្មី ដែលកំណត់ដោយ គ.ជ.ប។

១២.៧.៥ អ្នកបោះឆ្នោតទាំងអស់ដែលមានសិទ្ធិបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះដែលត្រូវបោះឆ្នោតសាជាថ្មីគឺអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ទោះបីជាបានបោះឆ្នោតហើយក្តី ឬមិនទាន់បានបោះឆ្នោតក្តី។

១២.៧.៦ ដើម្បីបោះឆ្នោតក្នុងការបោះឆ្នោតសាជាថ្មីបាន ប្រជាពលរដ្ឋទាំងពីរភេទត្រូវ៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនោះ
- មាន អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់កាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ។

១២.៧.៧ គយ.សប ត្រូវសហការជាមួយមេឃុំ ចៅសង្កាត់ក្នុងការចេញ ឯ.អ ជូនអ្នកបោះឆ្នោតដែលត្រូវបោះឆ្នោតសាជាថ្មីតាមសំណើសុំរបស់សាមីខ្លួន រហូតដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី នៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោតសាជាថ្មី ក្នុងករណី អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់កាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ របស់គាត់ត្រូវបាត់ ឬខូច។

១២.៧.៨ បញ្ជីបោះឆ្នោតផ្លូវការដែលប្រើនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ត្រូវបានប្រើសម្រាប់ការបោះឆ្នោតសាជាថ្មី។ បញ្ជីបោះឆ្នោតនេះត្រូវបិទផ្សាយនៅ គយ.សប និងនៅការិយាល័យបោះឆ្នោតសាជាថ្មី ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត។

១២.៧.៩ បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតផ្លូវការ និងលំដាប់លេខរៀងគណបក្សនយោបាយលើសន្លឹកឆ្នោត ដែលត្រូវបានសម្រេចជាផ្លូវការក្នុងការបោះឆ្នោតនៅឃុំ សង្កាត់នោះ ត្រូវរក្សាទុកដដែលសម្រាប់ការបោះឆ្នោតសាជាថ្មី។ បញ្ជីទាំងនេះត្រូវបិទផ្សាយជាសាធារណៈនៅ គយ.សប និងនៅការិយាល័យបោះឆ្នោតសាជាថ្មី ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃបោះឆ្នោតសាជាថ្មី។

១២.៧.១០ សមាសភាពភ្នាក់ងារគណបក្សនយោបាយដែលត្រូវសង្កេតមើលការិយាល័យបោះឆ្នោតនោះ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលទទួលស្គាល់នៅក្នុងការបោះឆ្នោតជ្រើសរើស កបយ.ស ត្រូវរក្សាទុកដដែលសម្រាប់ការបោះឆ្នោតសាជាថ្មី។

១២.៧.១១ គ.ជ.ប ត្រូវបោះពុម្ពសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតសាជាថ្មីតាមគំរូសន្លឹកឆ្នោតលើកមុននៅលើក្រដាសពណ៌ផ្សេងពីសន្លឹកឆ្នោតលើកមុន និងត្រូវឱ្យមានចំនួនគ្រប់គ្រាន់តាមតម្រូវការប្រើប្រាស់។

១២.៧.១២ គ.ជ.ប ត្រូវផ្តល់ផ្តង់សម្ភារ ឯកសារបោះឆ្នោតឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់ គធ.ខប គយ.សប និង គ.ក.ប/គ.ក.រ សម្រាប់ការបោះឆ្នោតសាជាថ្មី។

១២.៧.១៣ ក្នុងការបោះឆ្នោតសាជាថ្មី ការឃោសនាបោះឆ្នោតត្រូវធ្វើតែនៅក្នុងមណ្ឌលឃុំ សង្កាត់ដែលត្រូវធ្វើការបោះឆ្នោតសាជាថ្មី និងត្រូវអនុវត្តតាមជំពូកទី៧ នៃ ប.ន.ឃ.ស នេះ។ ការឃោសនាបោះឆ្នោតសម្រាប់ការបោះឆ្នោតសាជាថ្មី ត្រូវបើករយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃមុនថ្ងៃបោះឆ្នោត។ ការឃោសនាបោះឆ្នោតមានរយៈពេល ១៤ (ដប់បួន) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់ ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោតសាជាថ្មី។

ប្រការ១២.៨.

ការបោះឆ្នោតសាជាថ្មីត្រូវអនុវត្តដូចនីតិវិធីនៃការបោះឆ្នោតដែលបានចែងក្នុងជំពូកទី៩ នៃ ប.ន.ឃ.ស នេះ ដោយឡែកក្នុងពេលជ្រលក់ទឹកខ្មៅលុបមិនជ្រះ អ្នកបោះឆ្នោតត្រូវប្រើម្រាមចង្អុលដៃឆ្វេងរបស់ខ្លួន។ ក្នុងករណីម្រាមចង្អុលដៃឆ្វេងពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយតាមលំដាប់ដូចតទៅ ម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ឬមេដៃឆ្វេង ឬចង្អុលដៃស្តាំ ឬម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ។ ប្រសិនបើអ្នកបោះឆ្នោតនោះមិនអាចធ្វើបានតាមការកំណត់ខាងលើ រាល់ការជ្រលក់ ឬលាបត្រង់ផ្នែកណាមួយនៃអវៈយវៈរបស់គាត់ត្រូវទទួលយកជាបានការ។

ប្រការ១២.៩.

នៅពេលបញ្ចប់ការបោះឆ្នោតសាជាថ្មី គ.ក.ប/គ.ក.រ ត្រូវអនុវត្តការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការប្រមូល ការប្រគល់ និងការទទួលសម្ភារ ឯកសារបោះឆ្នោត ដូចការបោះឆ្នោតជ្រើសរើស កបឃ.ស ដែលមានចែងក្នុង ប.ន.ឃ.ស នេះ។

ប្រការ១២.១០.

បន្ទាប់ពីការបោះឆ្នោតសាជាថ្មី គឃ.សប ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងបិទផ្សាយលទ្ធផលបណ្តោះអាសន្នស្របតាម ប.ន.ឃ.ស នេះ។ គឃ.សប ត្រូវបូកសរុបលទ្ធផលទូទាំងឃុំ សង្កាត់ គឺទាំងលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបិទដូចប្រការ១២.៥ នៃ ប.ន.ឃ.ស នេះ ទាំងលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតសាជាថ្មី រួចបញ្ជូនកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គធ.ខប។

ប្រការ១២.១១.

គធ.ខប ត្រូវធ្វើការគណនាបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតតាមនីតិវិធីដូចមានចែងក្នុងជំពូកទី៤ និងប្រការ១១.១០ នៃ ប.ន.ឃ.ស នេះ ហើយធ្វើរបាយការណ៍ជូន គ.ជ.ប ដើម្បីត្រួតពិនិត្យ និងប្រកាសលទ្ធផលផ្លូវការ។

ប្រការ១២.១២.

ក្នុងដំណើរការបោះឆ្នោតសាជាថ្មី ចាប់ពីការរៀបចំដំបូងរហូតដល់ការប្រកាសលទ្ធផលផ្លូវការ ការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬ/និងសវនាការដោះស្រាយវិវាទ ត្រូវអនុវត្តតាមនីតិវិធីដូចគ្នានឹងការបោះឆ្នោតជ្រើសរើស កបឃ.ស ដែលមានចែងក្នុង ប.ន.ឃ.ស នេះ។

ជំពូកទី១៣
ការបោះឆ្នោតឡើងវិញ

ប្រការ១៣.១.

អនុលោមតាម ច.ប.ឃ.ស និង ច.គ.ឃ.ស ការរៀបចំការបោះឆ្នោតឡើងវិញ ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរ ១២០ (មួយរយម្ភៃ) ថ្ងៃ ដើម្បីធ្វើការជ្រើសរើស កបឃ.ស ក្នុងករណីណាមួយដូចខាងក្រោម៖

១៣.១.១ ឃុំ សង្កាត់ដែលបង្កើតថ្មីក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៦ នៃ ច.គ.ឃ.ស។

១៣.១.២ កបឃ.ស ត្រូវរំសាយចោលតាមលក្ខខណ្ឌដែលបានចែងក្នុងមាត្រា៥៧ និងមាត្រា៥៨ នៃ ច.គ.ឃ.ស។

ប្រការ១៣.២.

ការបោះឆ្នោតឡើងវិញត្រូវចាត់ចែងធ្វើឡើងអនុលោមទៅតាម ប.ន.ឃ.ស ដែលមានចែងក្នុង ច.ប.ឃ.ស។

ប្រការ១៣.៣.

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ កបឃ.ស មានរយៈពេលមិនលើសពី ១៨០ (មួយរយប៉ែតសិប) ថ្ងៃ។

ប្រការ១៣.៤.

អនុលោមតាម ច.ប.ឃ.ស ការបោះឆ្នោតឡើងវិញត្រូវប្រព្រឹត្តទៅក្រោមការគ្រប់គ្រង និងការចាត់ចែងដោយ គ.ជ.ប។

ប្រការ១៣.៥.

កាលបរិច្ឆេទសម្រាប់ការបោះឆ្នោតឡើងវិញត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីមានករណីតម្រូវឱ្យមានការបោះឆ្នោតឡើងវិញ។

ប្រការ១៣.៦.

គ.ជ.ប ត្រូវចាត់ចែងគ្រប់គ្រងការបោះឆ្នោតឡើងវិញដោយអនុលោមតាម ប.ន.ឃ.ស នេះ និងសេចក្តីសម្រេចរបស់ គ.ជ.ប និងពេលវេលាដែលបានកំណត់ដោយច្បាប់។

១៣.៦.១ សិទ្ធិអំណាច និងការកិច្ចរបស់ គ.ជ.ប គធ.ឧប គឃ.សប និង គ.ក.ប/គ.ក.រ ត្រូវអនុលោមតាម ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ។



១៣.៦.២ គ.ជ.ប ត្រូវចាត់ចែងការផ្សព្វផ្សាយដំណឹងអំពីការបោះឆ្នោតឡើងវិញជាសាធារណៈដោយឡែកនៅក្នុងឃុំ សង្កាត់ដែលត្រូវធ្វើការបោះឆ្នោតឡើងវិញ។

១៣.៦.៣ គ.ជ.ប ត្រូវចាត់ចែងការជ្រើសរើស និងការតែងតាំង៖

- មន្ត្រីមួយចំនួននៅ គ.ជ.ប តាមតម្រូវការនៃការងារ
- គធ.ខប ពាក់ព័ន្ធ និងមន្ត្រីមួយចំនួននៃ លគធ.ខប នោះតាមតម្រូវការនៃការងារ
- គឃ.សប ពាក់ព័ន្ធ
- គ.ក.ប/គ.ក.រ ក្នុងឃុំ សង្កាត់ពាក់ព័ន្ធ។

១៣.៦.៣.១ ការជ្រើសរើស និងការតែងតាំងត្រូវអនុលោមតាមនីតិវិធីនៃការជ្រើសរើសដូចមានចែងក្នុង ប.ន.ឃ.ស នេះ។ ប្រសិនបើអាចធ្វើបាន គួរជ្រើសរើសមន្ត្រីដែលធ្លាប់បម្រើការងារបោះឆ្នោតកន្លងមក។

១៣.៦.៣.២ រយៈពេលនៃការជ្រើសរើស និងការតែងតាំង និងរយៈពេលនៃការបណ្តុះបណ្តាលមន្ត្រីដែលជ្រើសរើសថ្មីដូចមានចែងក្នុងចំណុច ១៣.៦.៣ ខាងលើនេះ ត្រូវកាត់បន្ថយសមស្របតាមទំហំការងារ។

១៣.៦.៣.៣ ពេលវេលានៃការជ្រើសរើស និងការតែងតាំង និងអាណត្តិរបស់គណៈកម្មការគ្រប់លំដាប់ថ្នាក់ និងមន្ត្រីដែលជ្រើសរើសថ្មី ត្រូវកំណត់ដោយ គ.ជ.ប។

១៣.៦.៤ គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលត្រូវបោះឆ្នោតឡើងវិញ មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយភ្នាក់ងារពេញសិទ្ធិ ១ (មួយ) រូប និងភ្នាក់ងារគណបក្សបម្រុង ១ (មួយ) រូប នៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗទៅ គឃ.សប ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីថ្ងៃដែល គឃ.សប ត្រូវបានបង្កើតឡើង។

១៣.៦.៥ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងសង្កេតមើលដំណើរការរៀបចំការបោះឆ្នោតឡើងវិញ មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតទៅ គ.ជ.ប នៅក្រោយពេលដែល គ.ជ.ប ប្រកាសអំពីការបោះឆ្នោតឡើងវិញ។

១៣.៦.៦ ក្នុងករណីឃុំ សង្កាត់ត្រូវបង្កើតថ្មីដូចមានចែងក្នុងចំណុច ១៣.១.១ នៃ ប.ន.ឃ.ស នេះ លធ.ខប ត្រូវសហការជាមួយ កបឃ.ស ដែលបានរក្សាសៀវភៅបញ្ជីបោះឆ្នោតពាក់ព័ន្ធដើម្បីត្រួតពិនិត្យ និងលើកសំណើកែសម្រួលទីតាំងការិយាល័យបោះឆ្នោត ដោយត្រូវផ្អែកលើការិយាល័យបោះឆ្នោតចាស់ និងការប្រែប្រួលភូមិសាស្ត្រ ប្រជាសាស្ត្រ និងព្រំប្រទល់រដ្ឋបាលថ្មី។

១៣.៦.៧ គ.ជ.ប ត្រូវកំណត់ការកែសម្រួលទីតាំងការិយាល័យបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធដោយផ្អែកតាមសំណើរបស់ លធ.ខប។ បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតឡើងវិញត្រូវបិទផ្សាយជាសាធារណៈនៅ គឃ.សប និងនៅតាមការិយាល័យបោះឆ្នោតយ៉ាងតិច ១ (មួយ) ថ្ងៃមុនកាលបរិច្ឆេទនៃការចុះបញ្ជីបេក្ខជន។

១៣.៦.៨ បញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតឡើងវិញត្រូវយកបញ្ជីបោះឆ្នោតដែល គ.ជ.ប បានផ្តល់សុពលភាពចុងក្រោយ។

១៣.៦.៨.១ ក្នុងករណីឃុំ សង្កាត់ត្រូវបង្កើតថ្មីដូចមានចែងក្នុងចំណុច ១៣.១.១ ខាងលើនេះ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យ និងកែសម្រួលបញ្ជីបោះឆ្នោត ដោយផ្អែកលើបញ្ជីបោះឆ្នោតចុងក្រោយឱ្យបានត្រឹមត្រូវតាមទីតាំងនៃការិយាល័យបោះឆ្នោតដែលត្រូវបានកែសម្រួលថ្មីដូចមានចែងក្នុងចំណុច ១៣.៦.៧ និងចំណុច ១៣.៦.៨ ខាងលើនេះ។

១៣.៦.៨.២ គ.ជ.ប ត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោតដែលកែសម្រួលថ្មី។ បញ្ជីបោះឆ្នោតផ្លូវការនេះត្រូវបិទផ្សាយនៅ គយ.សប និងនៅការិយាល័យបោះឆ្នោតដែលត្រូវបោះឆ្នោតឡើងវិញនៅថ្ងៃដាមួយនឹងថ្ងៃបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងត្រូវបិទផ្សាយម្តងទៀតនៅទីកន្លែងដដែល ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត។

១៣.៦.៩ គយ.សប ត្រូវសហការជាមួយមេឃុំ ចៅសង្កាត់ពាក់ព័ន្ធចេញ ឯ.អ ជូនអ្នកបោះឆ្នោតតាមសំណើសុំរបស់សាមីខ្លួន រហូតដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទីនៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោតឡើងវិញ ក្នុងករណីគាត់គ្មាន អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល ឬលិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គលរបស់គាត់ត្រូវបាត់ ឬខូច។

១៣.៦.១០ ដើម្បីបោះឆ្នោតក្នុងការបោះឆ្នោតឡើងវិញបានប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ពាក់ព័ន្ធត្រូវ៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ដែលត្រូវបោះឆ្នោតឡើងវិញ
- មាន អ.ខ លិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល លិខិតបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល ឬ ឯ.អ។

១៣.៦.១១ ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសកបយ.ស និងការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងគណបក្សនយោបាយត្រូវដាក់លើសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតឡើងវិញ ត្រូវអនុវត្តតាមជំពូកទី៦ នៃ ប.ន.ឃ.ស នេះ។



១៣.៦.១២ គ.ជ.ប ត្រូវធ្វើគំរូសន្លឹកឆ្នោត និងបោះពុម្ពសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតឡើងវិញនៅលើក្រដាសពណ៌ផ្សេងពីសន្លឹកឆ្នោតដែលប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសកបយ.ស និងការបោះឆ្នោតសាជាថ្មី។

១៣.៦.១៣ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារបោះឆ្នោតជូន គធ.ខប គឃ.សប និង គ.ក.ប/គ.ក.រ សម្រាប់ការរៀបចំបោះឆ្នោតឡើងវិញឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា។

១៣.៦.១៤ ក្នុងការបោះឆ្នោតឡើងវិញ ការឃោសនាបោះឆ្នោតត្រូវធ្វើតែនៅក្នុងមណ្ឌលឃុំ សង្កាត់ ដែលត្រូវធ្វើការបោះឆ្នោតឡើងវិញ និងត្រូវអនុវត្តតាមជំពូកទី៧ នៃ ប.ន.ឃ.ស នេះ។ ការឃោសនាបោះឆ្នោតសម្រាប់ការបោះឆ្នោតឡើងវិញត្រូវបើករយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃមុនថ្ងៃបោះឆ្នោត។ ការឃោសនាបោះឆ្នោតមានរយៈពេល ១៤ (ដប់បួន) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវបញ្ឈប់ ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោត។

ប្រការ១៣.៧.

ការបោះឆ្នោតឡើងវិញត្រូវអនុវត្តដូចនីតិវិធីនៃការបោះឆ្នោតដែលមានចែងក្នុងជំពូកទី៩ ជំពូកទី១០ និងជំពូកទី១១ នៃ ប.ន.ឃ.ស នេះ។

១៣.៧.១ ការបោះឆ្នោតឡើងវិញត្រូវអនុវត្តតែមួយថ្ងៃចាប់ពីម៉ោង ៧:០០ (ប្រាំពីរ) ព្រឹករហូតដល់ម៉ោង ១៥:០០ (ដប់ប្រាំ)។

១៣.៧.២ នៅពេលបញ្ចប់ការបោះឆ្នោតឡើងវិញ គ.ក.ប/គ.ក.រ ត្រូវអនុវត្តការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការប្រមូល ការប្រគល់ និងការទទួលសម្ភារ ឯកសារបោះឆ្នោត ដូចការបោះឆ្នោតសកលដែលមានចែងក្នុង ប.ន.ឃ.ស នេះ។

១៣.៧.៣ គឃ.សប ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតឡើងវិញពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ និងបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់។

១៣.៧.៤ គធ.ខប ត្រូវធ្វើការគណនាបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតតាមនីតិវិធីដូចមានចែងក្នុងជំពូកទី៤ និងប្រការ១១.១០ នៃ ប.ន.ឃ.ស នេះ ហើយធ្វើរបាយការណ៍ជូន គ.ជ.ប ដើម្បីត្រួតពិនិត្យ និងប្រកាសលទ្ធផលផ្លូវការ។

ប្រការ១៣.៨.

ក្នុងដំណើរការបោះឆ្នោតឡើងវិញ ចាប់តាំងពីការរៀបចំដំបូងរហូតដល់ការប្រកាសលទ្ធផលផ្លូវការ ការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬ/និងសវនាការដោះស្រាយបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីដូចគ្នានឹងការបោះឆ្នោតជ្រើសរើស កបឃ.ស ដូចមានចែងក្នុង ប.ន.ឃ.ស នេះ។

ជំពូកទី១៤
ការជាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ចំពោះគ្រប់អំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប ពាក់ព័ន្ធនឹងការបោះឆ្នោត និងសមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការដោះស្រាយពាក្យបណ្តឹង ព្រមទាំង បែបបទ និងនីតិវិធីនៃការអនុវត្តទណ្ឌកម្មរបស់ គ.ជ.ប

ផ្នែកទី១
ការជាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់ អំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប ពាក់ព័ន្ធនឹងការបោះឆ្នោត

ប្រការ១៤.១.-

បទប្បញ្ញត្តិនៃផ្នែកនេះកំណត់អំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្រព្រឹត្តដោយជនជាមន្ត្រីបោះឆ្នោត ឬ/និងជនមិនមែនជាមន្ត្រីបោះឆ្នោត ឬ/និងគណបក្សនយោបាយ ដែលអាចនាំឱ្យមានការផាកពិន័យ ដែលអាចកើតឡើងនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើស កបឃ.ស រួមទាំងនៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។

ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ

ប្រការ១៤.២.-

ជនណាក៏ដោយដែលទទួលរងឥទ្ធិពល ឬជនដែលស្ថិតនៅកន្លែងកើតហេតុផ្ទាល់ ឬតំណាងមានសិទ្ធិដាក់ពាក្យបណ្តឹងចំពោះជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយទៅ គឃ.សប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុ។ អ្នកប្តឹង ឬតំណាងអាចបន្តប្តឹងទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬផ្សះផ្សារនៅ គឃ.សប ឬបន្តប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប។ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុងចំណុច ១៤.៦.៥ នៃ ប.ន.ឃ.ស នេះ។

ការជាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គយ.សប

ការជាក់ និងការទទួលពាក្យបណ្តឹងនៅ គយ.សប

១៤.២.១ អ្នកប្តឹងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៤ (បួន) ច្បាប់។ អ្នកប្តឹងអាចថតចម្លងពាក្យបណ្តឹង (ទ.១២០២) ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចជាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងជាក់ពាក្យបណ្តឹងជួសខ្លួនបាន។

១៤.២.២ នៅពេលបានទទួលពាក្យបណ្តឹង សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានដូចខាងក្រោម៖

- ទី១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- ទី២- កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

១៤.២.៣ បន្ទាប់មកសមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនោះ។

១៤.២.៤ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

១៤.២.៤.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ ៣(បី)ថ្ងៃបន្ទាប់ពីថ្ងៃកើតហេតុ ប្រធាន គយ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុថា “ពាក្យបណ្តឹងបានដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ១៤.២.២ នៃ ប.ន.ឃ.ស ដែលជាហេតុផ្តាច់សិទ្ធិក្នុងការប្តឹងមក គយ.សប។ ដូចនេះ គយ.សប មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យនិងដោះស្រាយបានឡើយ។” ហើយចុះហត្ថលេខាឈ្មោះ បោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គជ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

១៤.២.៤.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ១៤.៦.៥ នៃ ប.ន.ឃ.ស នេះ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ ជាអាទិ៍ សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គឃ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុថា “ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ។ ដូចនេះ គឃ.សប មិនអាចទទួលយកពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ។” ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

១៤.២.៤.៣ ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុ និងមានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ និងបោះត្រា គឃ.សប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

ការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប

១៤.២.៥ បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គឃ.សប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គឃ.សប ពិនិត្យ និងយល់ឃើញថា៖



១៤.២.៥.១ ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ គឃ.សប ត្រូវធ្វើលិខិត

ជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.២.៥.២ កម្មវត្ថុនៃបណ្តឹង និងមូលហេតុនៃការប្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធមិនពាក់ព័ន្ធទៅនឹងការបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ គយ.សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.២.៥.៣ ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គយ.សប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវដែលអាចមានសមាសភាពដូចខាងក្រោម៖

- ប្រធាន គយ.សប ឬតំណាងជាប្រធានក្រុម
- សមាជិក គយ.សប ១ (មួយ) រូប ជាសមាជិក
- សមាជិក គយ.សប ១ (មួយ) រូប ជាលេខាធិការ។

១៤.២.៦ ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះអាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្តឹង ឬតំណាង។



១៤.២.៧ បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ស៊ើបអង្កេតចប់ហើយលទ្ធផលបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់នោះមិនបានបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ

ច.វ.ច.ប និង ប.ន.ឃ.ស នេះ គឃ.សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.២.៨ ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់បានបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ គឃ.សប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ គឃ.សប។

១៤.២.៩ គឃ.សប ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ដោយឱ្យភាគីវិវាទផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ។

១៤.២.១០ ក្នុងការផ្សះផ្សា ប្រសិនបើភាគីវិវាទ៖

- ព្រមព្រៀងគ្នា គឃ.សប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថាភាគីវិវាទយល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីវិវាទផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គធ.ខប ពាក់ព័ន្ធ
- មិនព្រមព្រៀងគ្នាទេ គឃ.សប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថាភាគីវិវាទមិនព្រមសះជានឹងគ្នាទេ។ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុប្រជុំផ្សះផ្សានោះជាបន្ទាន់មក គធ.ខប ទោះបីភាគីណាមួយមិនព្រមផ្តិតមេដៃក៏ដោយ។ គឃ.សប ត្រូវជម្រាបអ្នកប្តឹងថាគាត់មានសិទ្ធិប្តឹងបន្តទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃប្រជុំផ្សះផ្សា។

១៤.២.១១ គឃ.សប ត្រូវបើកការប្រជុំផ្សះផ្សាចំពោះរាល់ពាក្យបណ្តឹងគ្រប់អំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ ប៉ុន្តែមិនមានអំណាចបើកអង្គប្រជុំសម្រេច និងចេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ឡើយ។

១៤.២.១២ សមាសភាពការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ.សប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងផ្នែកទី២ នៃជំពូកទី១៤ នេះ។

ការជាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

ការជាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប

១៤.២.១៣ ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬការផ្សះផ្សានៅថ្នាក់ គយ.សប អាចប្តឹងទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃប្រជុំផ្សះផ្សានៅ គយ.សប។

១៤.២.១៤ អ្នកប្តឹង ឬតំណាងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៤ (បួន) ច្បាប់។

១៤.២.១៥ នៅពេលបានទទួលពាក្យបណ្តឹង សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន មានដូចខាងក្រោម៖

- ទី១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- ទី២- កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃប្រជុំផ្សះផ្សានៅ គយ.សប។

១៤.២.១៦ បន្ទាប់មកសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់រួចឱ្យអ្នកប្តឹង ឬតំណាងចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុសាកសួរនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនោះ។

១៤.២.១៧ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

១៤.២.១៧.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃប្រជុំផ្សះផ្សានៅ គយ.សប ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុថា “ពាក្យបណ្តឹងដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ១៤.២.១៣ នៃ ប.ន.ឃ.ស ដែលជាហេតុផ្លាស់សិទ្ធិក្នុងការប្តឹងមក គធ.ខប។ ដូចនេះ គធ.ខប មិនអាចទទួលពាក្យបណ្តឹងនេះ មកពិនិត្យ និងដោះស្រាយបានឡើយ។” ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

១៤.២.១៧.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ១៤.៦.៥ នៃ ប.ន.ឃ.ស នេះ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ ជាអាទិ៍ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបជិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុថា “ពាក្យបណ្តឹងនេះ មិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ។ ដូចនេះ គធ.ខប មិនអាចទទួលពាក្យបណ្តឹងនេះ មកពិនិត្យ និងដោះស្រាយបានឡើយ។” ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

១៤.២.១៧.៣ ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃប្រជុំផ្សះផ្សានៅ គឃ.សប មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ និងបោះត្រា គធ.ខប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប



១៤.២.១៨ បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គធ.ខប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គធ.ខប ពិនិត្យ និងយល់ឃើញថា៖

១៤.២.១៨.១ ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើទោសប្បញ្ញត្តិ នៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ គជ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គជ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.២.១៨.២ កម្មវត្ថុនៃបណ្តឹង និងមូលហេតុនៃការប្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធមិនពាក់ព័ន្ធទៅនឹងការបំពានលើទោសប្បញ្ញត្តិ នៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ គជ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គជ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.២.១៨.៣ ពាក្យបណ្តឹងដែលត្រូវបានភាគីវិវាទសះជានឹងគ្នារួចហើយនៅថ្នាក់ គឃ.សប គជ.ខប ត្រូវពិនិត្យ សម្រេចថាត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ។ ក្នុងករណីបដិសេធ គជ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គជ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។



១៤.២.១៨.៤ ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គជ.ខប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវដែលអាចមានសមាសភាពដូចខាងក្រោម៖

- ប្រធាន គធ.ខប ឬតំណាងជាប្រធានក្រុម
- សមាជិក គធ.ខប ១ (មួយ) រូប ជាសមាជិក
- មន្ត្រីផ្នែកសៀវភៅបច្ចាប់វិវាទកម្ម និងសន្តិសុខបោះឆ្នោត ១ (មួយ) រូប ជាលេខាធិការ។

១៤.២.១៩ ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះអាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្តឹង ឬតំណាង។

១៤.២.២០ បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវស៊ើបអង្កេតចប់សព្វគ្រប់ហើយ លទ្ធផលបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់នោះមិនបានបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា បោះត្រា គធ.ខប និង ចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.២.២១ ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់បានបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ គធ.ខប ត្រូវអញ្ជើញភាគីវិវាទទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់ កំណត់ដោយ គធ.ខប។

១៤.២.២២ គធ.ខប ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ដោយឱ្យភាគីវិវាទផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ។

១៤.២.២៣ ក្នុងការផ្សះផ្សា ប្រសិនបើភាគីវិវាទ៖

- ព្រមព្រៀងគ្នា គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីវិវាទយល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីវិវាទផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុប្រជុំផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប

- មិនព្រមព្រៀងគ្នាទេ គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីវិវាទមិនព្រមសះជានឹងគ្នាទេ។ គធ.ខប ត្រូវកំណត់ពេលវេលា និងកាលបរិច្ឆេទបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ១ (មួយ) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃប្រជុំផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែងបើកសវនាការតែម្តង។

១៤.២.២៤ គធ.ខប ត្រូវបើកសវនាការជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងដោយមានកំណត់ហេតុសវនាការ សេចក្តីសម្រេច និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៥ (ប្រាំ) ច្បាប់ ដោយមានការចុះហត្ថលេខា ឈ្មោះរបស់លេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនចុងចម្លើយ ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.២.២៥ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងផ្នែកទី២ នៃជំពូកទី១៤ នេះ។

ការជាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

ការជាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

១៤.២.២៦ ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្តីសម្រេចរបស់ គធ.ខប អាចប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប។

១៤.២.២៧ អ្នកប្តឹង ឬតំណាងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៤ (បួន) ច្បាប់។

១៤.២.២៨ នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍ដូចខាងក្រោម៖

- ទី១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- ទី២- កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប។

១៤.២.២៩ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុសាកសួរនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនោះ។

១៤.២.៣០ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

- ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុថា “ពាក្យបណ្តឹងដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ១៤.២.២៦ នៃ ប.ន.ឃ.ស ដែលជាហេតុផ្តាច់សិទ្ធិក្នុងការប្តឹងមក គ.ជ.ប។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្តឹងនេះ មកពិនិត្យ និងដោះស្រាយបានឡើយ។” ហើយចុះហត្ថលេខាឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។
- ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ១៤.៦.៥ នៃ ប.ន.ឃ.ស នេះ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ ជាអាទិ៍ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងនោះដោយបញ្ជាក់អំពីមូលហេតុថា “ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្តឹងនេះ មកពិនិត្យ និងដោះស្រាយបានឡើយ។” ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។
- ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប និងមាន

ព័ត៌មានចាំបាច់ លិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

១៤.២.៣១ បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គ.ជ.ប ពិនិត្យ និងយល់ឃើញថា៖

- ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។
- កម្មវត្ថុនៃបណ្តឹង និងមូលហេតុនៃការប្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ សុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។
- ពាក្យបណ្តឹងដែលត្រូវបានភាគីវិវាទសះជានឹងគ្នារួចហើយនៅ គធ.ខប គ.ជ.ប ត្រូវពិនិត្យ សម្រេចថាត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ។ ក្នុងករណីបដិសេធ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។
- ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ដូចបានកំណត់ក្នុងចំណុច ១៤.៦.៥ នៃ ប.ន.ឃ.ស នេះ គ.ជ.ប ត្រូវកំណត់នីតិវិធីដោះស្រាយ។

១៤.២.៣២ គ.ជ.ប អាចបើកការស៊ើបអង្កេតជាបន្ទាន់ចំពោះករណីណាដែលយល់ថាជាការចាំបាច់ និងស្មុគស្មាញ។

១៤.២.៣៣ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ គ.ជ.ប មានសិទ្ធិមិនយកពាក្យបណ្តឹងនោះមកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថាពាក្យបណ្តឹងផ្ទុយនឹងទម្រង់ ឬគតិច្បាប់ ឬ/និងមិនមានអំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្តឹងដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងមិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវរបស់ គ.ជ.ប ឃើញថាផ្ទុយពីការអះអាងក្នុងពាក្យបណ្តឹង។ ការបដិសេធមិនទទួលដោះស្រាយរបស់ គ.ជ.ប ត្រូវធ្វើតាមរយៈលិខិតជូនដំណឹងបដិសេធតាមបែបបទរដ្ឋបាល ក្នុងរយៈពេលសមស្របមួយទៅអ្នកប្តឹង ឬតំណាង ដើម្បីជូនជ្រាបថាពាក្យបណ្តឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនចុងចម្លើយ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.២.៣៤ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ប្រសិនបើ គ.ជ.ប រកឃើញភស្តុតាងពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្តឹង គ.ជ.ប ត្រូវដោះស្រាយពាក្យបណ្តឹងតាមពេលវេលាសមស្របជាបន្ទាន់។

១៤.២.៣៥ ប្រសិនបើ គ.ជ.ប សម្រេចបើកសវនាការសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹង សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្តីសម្រេចនេះត្រូវស្រង់ជាក់ក្នុងសម្រង់សេចក្តីសម្រេច (ទ.១២០៣) ហើយត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចគណៈលេខាធិការសវនាការត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនចុងចម្លើយ ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.២.៣៦ សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

១៤.២.៣៧ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងផ្នែកទី២ នៃជំពូកទី១៤ នេះ។

១៤.២.៣៨ ដំណើរការនីតិវិធីដើម្បីចេញសេចក្តីសម្រេចរបស់ គ.ជ.ប មិនរារាំងដល់ដំណើរការនៃនីតិវិធីព្រហ្មទណ្ឌរបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីដែលអំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប ជាបទល្មើសដែលបានបញ្ញត្តក្នុងក្រមព្រហ្មទណ្ឌ ឡើយ។

ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

ប្រការ១៤.៣.

គ្រប់ពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើបំពានលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្តឹង គ.ក.ប/គ.ក.រ ឬ គឃ.សប ឬ គធ.ខប ឬមន្ត្រីបោះឆ្នោត ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុ។

១៤.៣.១ ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព គ.ក.ប/គ.ក.រ ដំបូងត្រូវប្តឹងទៅ គឃ.សប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងប្រការ១៤.២ រហូតដល់ចំណុច ១៤.២.៣៧ ខាងលើនេះ។

១៤.៣.២ ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព គឃ.សប ត្រូវប្តឹងទៅ គធ.ខប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ១៤.២.១៣ រហូតដល់ចំណុច ១៤.២.៣៧ ខាងលើនេះ។

១៤.៣.៣ ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព គធ.ខប ឬមន្ត្រី លគធ.ខប ឬមន្ត្រី គ.ជ.ប ត្រូវប្តឹងទៅ គ.ជ.ប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ១៤.២.២៦ រហូតដល់ចំណុច ១៤.២.៣៧ ខាងលើនេះ។

១៤.៣.៤ ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព គ.ជ.ប ត្រូវប្តឹងទៅរដ្ឋសភា ដោយអនុលោមតាម ច.គ.ជ.ប។

១៤.៣.៥ ពាក្យបណ្តឹងពាក់ព័ន្ធនឹងការប្រព្រឹត្តកំហុសផ្នែករដ្ឋបាល ដែលអាចនាំឱ្យផ្ទុយពីបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប រួមមានការចោទប្រកាន់សមាជិក ឬមន្ត្រីដែលបដិសេធមិនទទួលពាក្យបណ្តឹងដោយគ្មានមូលហេតុ និងគតិច្បាប់ត្រឹមត្រូវ ឬ/និងមិនព្រមដោះស្រាយពាក្យបណ្តឹងដែលសមាជិក ឬមន្ត្រីនោះបានទទួលពាក្យបណ្តឹងរួចហើយ ជាអាទិ៍ អ្នកប្តឹងត្រូវដាក់ពាក្យបណ្តឹងទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃប្រព្រឹត្តកំហុស។ ក្នុងករណីដែលរកឃើញថា៖

- សមាជិក ឬមន្ត្រីនោះពិតជាបានប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប្រាកដមែន សមាជិក ឬមន្ត្រីនោះត្រូវទទួលទណ្ឌកម្មផ្នែកវិន័យស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប
- សមាជិក ឬមន្ត្រីនោះបានគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ត្រឹមត្រូវហើយ ត្រូវបដិសេធពាក្យបណ្តឹងនោះ ហើយពាក្យបណ្តឹងដែលត្រូវបានបដិសេធ និងមិនដោះស្រាយនោះ ក៏ត្រូវបានបដិសេធផងដែរ។

ផ្នែកទី២
សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច
និងសវនាការដោះស្រាយពាក្យបណ្តឹង

សមត្ថកិច្ចដោះស្រាយពាក្យបណ្តឹងក្នុងការបោះឆ្នោត

ប្រការ១៤.៤.–

គយ.សប គធ.ខប និង គ.ជ.ប មានសិទ្ធិអំណាច និងការកិច្ចសម្រេចលើពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើស កបយ.ស។ គយ.សប បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច គធ.ខប បើកការប្រជុំផ្សះផ្សា ឬ/និងបើកសវនាការ និង គ.ជ.ប ពិនិត្យ សម្រេច ឬបើកសវនាការលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោតនេះ លើកលែងតែពាក្យបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

- ១៤.៤.១ នីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹងដូចបានចែងក្នុងផ្នែកនេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការបោះឆ្នោតជ្រើសរើស កបយ.ស ដែលរួមមានដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោត បិទផ្សាយបញ្ជីបេក្ខជនដំបូង ឃោសនាបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។
- ១៤.៤.២ ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ។
- ១៤.៤.៣ សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

ប្រការ១៤.៥.–

ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាដែលត្រូវបានចាត់តាំងឱ្យចូលរួមដោយ គយ.សប ឬ គធ.ខប ឬ គ.ជ.ប។

- ១៤.៥.១ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចដែលចាត់តាំងដោយ គយ.សប ត្រូវអនុវត្តការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេចរបស់ខ្លួន ស្របតាមនីតិវិធីដោះស្រាយពាក្យបណ្តឹង ដូចមានចែងក្នុងប្រការ១៤.១១ នៃ ប.ន.ឃ.ស នេះ។
- ១៤.៥.២ ប្រធាន អនុប្រធាន និងសមាជិក គយ.សប ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សាហៅថា ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំសម្រេចហៅថា ក្រុមប្រឹក្សាប្រជុំសម្រេច។

១៤.៥.២.១ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច នៃ គឃ.សប រួមមាន៖

- ប្រធាន គឃ.សប ឬតំណាងជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច
- អនុប្រធាន និងសមាជិក គឃ.សប ជាសមាជិក
- សមាជិក គឃ.សប ១ (មួយ) រូបទទួលភារកិច្ចបន្ថែមជាលេខាធិការ។

១៤.៥.២.២ កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាត។

១៤.៥.២.៣ រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប មិនត្រូវមានសំឡេងអនុបវាទឡើយ។

១៤.៥.២.៤ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប មានអំណាចកោះហៅភាគីវិវាទឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច។ ដោយឡែកការប្រជុំសម្រេចអាចកោះហៅសាក្សីបាន។

១៤.៥.៣ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គធ.ខប ត្រូវអនុវត្តការប្រជុំផ្សះផ្សា ឬសវនាការ និងការសម្រេចរបស់ខ្លួន ស្របតាមនីតិវិធីដោះស្រាយពាក្យបណ្តឹងដូចមានចែងក្នុងប្រការ១៤.១១ នៃ ប.ន.ឃ.ស នេះ។

១៤.៥.៤ ប្រធាន អនុប្រធាន និងសមាជិក គធ.ខប ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សា ហៅថាក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមសវនាការហៅថាក្រុមប្រឹក្សាជំនុំជម្រះ។

១៤.៥.៤.១ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប រួមមាន៖

- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គធ.ខប ជាសមាជិក
- មន្ត្រី លគធ.ខប ដែលត្រូវបានចាត់តាំងជាលេខាធិការ។



១៤.៥.៤.២ កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិក គធ.ខប ទាំងមូល។

១៤.៥.៤.៣ រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មិនត្រូវមានសំឡេងអនុបវាទឡើយ។

១៤.៥.៤.៤ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មានសិទ្ធិអំណាចកោះហៅភាគីវិវាទឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការ។ ដោយឡែកសវនាការអាចកោះហៅសាក្សីបាន។

១៤.៥.៥ សមាសភាពក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គ.ជ.ប ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប អនុលោមតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

១៤.៥.៦ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលត្រូវបានចាត់តាំងឱ្យចូលរួមធ្វើសវនាការដោះស្រាយពាក្យបណ្តឹងហៅថាក្រុមប្រឹក្សាជំនុំជម្រះ។

១៤.៥.៦.១ សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប រួមមាន៖

- ប្រធាន គ.ជ.ប ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គ.ជ.ប ជាសមាជិក
- មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំងជាគណៈលេខាធិការសវនាការ។

១៤.៥.៦.២ លក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវគោរពតាមបទប្បញ្ញត្តិនៃមាត្រា៥០ នៃ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

១៤.៥.៦.៣ រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មិនត្រូវមានសំឡេងអនុបវាទឡើយ។

១៤.៥.៦.៤ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅភាគីវិវាទ និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ។

ការប្តឹងតវ៉ា ឬការប្តឹងជំទាស់

ប្រការ១៤.៦.-

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់តាមឋានានុក្រមទៅ គឃ.សប ឬ គធ.ខប ឬ គ.ជ.ប អំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងការបោះឆ្នោត ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានភាពមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប និង ប.ន.ឃ.ស នេះ ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប លើកលែងតែការប្តឹងតវ៉ា និងការប្តឹងជំទាស់ទាក់ទងនឹងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោត ដែលត្រូវប្តឹងដោយគណបក្សនយោបាយសាមី ការបិទផ្សាយបញ្ជីបេក្ខជនដំបូងដែលត្រូវប្តឹងដោយប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតដែល

ត្រូវប្តឹងដោយមន្ត្រីការិយាល័យបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតដែលត្រូវប្តឹងដោយជនគ្រប់រូបដែលបានចុះឈ្មោះបោះឆ្នោតនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅឃុំ សង្កាត់ ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ។

១៤.៦.១ ពាក្យបណ្តឹងអនាមិកពុំត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយឡើយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា។

១៤.៦.២ ពាក្យបណ្តឹងប្តឹងពីអញ្ញាតជន ត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងត្រូវបានសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត ដើម្បីស្វែងរកអត្តសញ្ញាណរបស់អ្នកប្រព្រឹត្តល្មើសនោះ និងពង្រឹងការការពារ និងទប់ស្កាត់បន្ថែម។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណអញ្ញាតជនមិនឃើញ គយ.សប គធ.ខប ឬ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងទៅអ្នកប្តឹងវិញអំពីករណីនេះក្នុងរយៈពេលសមស្រប។

១៤.៦.៣ ពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ចំពោះពាក្យបណ្តឹងតវ៉ា) ឬចំនួន ៤ (បួន) ច្បាប់ (ចំពោះពាក្យបណ្តឹងជំទាស់)។ អ្នកប្តឹងអាចថតចម្លងទម្រង់បែបបទដែលខ្លួនបានបំពេញរួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹងជួសខ្លួនបាន។

១៤.៦.៤ គយ.សប ឬមន្ត្រីបោះឆ្នោតត្រូវប្រគល់ពាក្យបណ្តឹង (ទ.១២០២) ដល់អ្នកប្តឹងដើម្បីប្តឹង ឬប្តឹងបន្ត ប្រសិនបើមានការស្នើសុំ។

១៤.៦.៥ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

- ១៤.៦.៥.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង។
- ១៤.៦.៥.២ កម្មវត្ថុនៃបណ្តឹង។
- ១៤.៦.៥.៣ មូលហេតុនៃការប្តឹង។
- ១៤.៦.៥.៤ ប្រភេទនៃអំពើល្មើស។
- ១៤.៦.៥.៥ ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង។
- ១៤.៦.៥.៦ បើអាចធ្វើបាន បញ្ជាក់អំពីមាត្រានៃ ច.ប.ឃ.ស ឬ ច.វ.ច.ប ឬប្រការនៃ ប.ន.ឃ.ស ដែលត្រូវបានរំលោភ។
- ១៤.៦.៥.៧ អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់។
- ១៤.៦.៥.៨ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)។
- ១៤.៦.៥.៩ កស្តុតាងផ្សេងៗទៀត (ប្រសិនបើមាន)។

១៤.៦.៦ ពាក្យបណ្តឹង (ទ.១២០២) ត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ហើយជាបន្ទាន់។

ការដកពាក្យបណ្តឹង

ប្រការ១៤.៧.

អ្នកប្តឹងអាចដកពាក្យបណ្តឹងទាំងមូល ឬមួយផ្នែកបាន រហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា នៃ គឃ.សប ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គធ.ខប បញ្ចប់កំណត់ហេតុប្រជុំផ្សះផ្សា ឬរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ចាយទៅពិភាក្សាពិចារណា។

១៤.៧.១ ការដកពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនទៅ គឃ.សប គធ.ខប ឬ គ.ជ.ប លើកលែងតែនៅពេលកំពុងប្រជុំផ្សះផ្សា កំពុងប្រជុំសម្រេច ឬកំពុងសវនាការ នោះការដកពាក្យបណ្តឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន។

១៤.៧.២ ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹងធ្វើឡើងមុនពេលដំណើរការប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ គឃ.សប គធ.ខប ឬ គ.ជ.ប ត្រូវសម្រេចលើកពាក្យបណ្តឹងនោះចោល ហើយត្រូវជូនដំណឹងទៅភាគីចុងចម្លើយ។

១៤.៧.៣ ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹងធ្វើឡើងនៅពេលកំពុងប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សាថា ភាគីដើមបណ្តឹងដកពាក្យបណ្តឹង ហើយពាក្យបណ្តឹងនោះត្រូវបានលើកចោលតាមការស្នើសុំ។

១៤.៧.៤ ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹងធ្វើឡើងនៅពេលកំពុងប្រជុំសម្រេច ឬកំពុងសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចលើកពាក្យបណ្តឹងចោលដោយចេញសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

ការរួមបញ្ចូលរឿងក្តី

ប្រការ១៤.៨.

គ.ជ.ប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប អាចបញ្ចូលរឿងក្តី ក្នុងករណីដែលមានពាក្យបណ្តឹងច្រើន ប៉ុន្តែកម្មវត្ថុនៃបណ្តឹងតែមួយ អ្នកប្រព្រឹត្តល្មើសជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ហើយអ្នកប្តឹងជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ទោះទីកន្លែងប្រព្រឹត្តល្មើសមាននៅទូទាំងប្រទេសក៏ដោយ។ ប៉ុន្តែក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះចេញសេចក្តីសម្រេចជាស្ថាពរ ប៉ុន្តែអ្នកប្រព្រឹត្តល្មើសមិនរាងចាលដោយនៅតែប្រព្រឹត្តល្មើសដដែលបន្តទៀត ហើយបើមានពាក្យបណ្តឹងថ្មីទៀតនោះ គ.ជ.ប នឹងត្រូវលើកយកមកដោះស្រាយដោយចាត់ទុកជាករណីថ្មីទៀត។

សិទ្ធិ និងភាតព្វកិច្ចរបស់ភាគីវិវាទ ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ប្រការ១៤.៩.

ក្នុងករណីភាគីវិវាទមានមេធាវី ឬតំណាងដើម្បីធ្វើជាតំណាង ឬសាក្សី ឬអ្នកដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងដែលត្រូវចូលរួមបំភ្លឺក្នុងអង្គប្រជុំសម្រេច ឬសវនាការនោះ ត្រូវសុំការអនុញ្ញាតជាមុនពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ មុនពេលបើកការប្រជុំសម្រេច ឬសវនាការ។ ចំពោះការប្រជុំផ្សះផ្សា ភាគីវិវាទអាចមកចូលរួមដោយផ្ទាល់ ឬចាត់តំណាងដែលត្រូវបានប្រគល់សិទ្ធិ តែមិនតម្រូវឱ្យមានសាក្សីទេ។

១៤.៩.១ ភាគីវិវាទត្រូវធ្វើលិខិតប្រគល់សិទ្ធិជូនមេធាវី ឬតំណាងដោយមានចុះហត្ថលេខា ឬផ្តិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និងបោះត្រាពីមេធាវី ឬស្នាមមេដៃនៃតំណាងនោះ (តំណាងត្រូវតែជានីតិជន)។

១៤.៩.២ លិខិតប្រគល់សិទ្ធិត្រូវបញ្ជាក់ច្បាស់ពីសិទ្ធិរបស់មេធាវី ឬតំណាង ហើយត្រូវដាក់ជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ តាមរយៈលេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការយ៉ាងតិច ២ (ពីរ) ម៉ោងមុនពេលបើកការប្រជុំផ្សះផ្សា បើកការប្រជុំសម្រេច ឬបើកសវនាការ។

១៤.៩.៣ មេធាវី ឬតំណាងមិនអាចប្រគល់សិទ្ធិបន្តទៅមេធាវី ឬតំណាងដទៃទៀតដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកប្រគល់សិទ្ធិដំបូងបានឡើយ។

១៤.៩.៤ ដើមបណ្តឹងអាចវាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហាដែលកើតមានឡើងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិ។

១៤.៩.៥ ដើមបណ្តឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារកស្តុតាង ឬសាក្សីដើម្បីជាសំអាងក្នុងរឿងក្តីរបស់ខ្លួន។

១៤.៩.៦ ដើមបណ្តឹង ឬ/និងជនរងគ្រោះមានវិសមិតភាពរវាងហានៈជាដើមបណ្តឹង ឬជនរងគ្រោះនិងហានៈជាសាក្សី។ ដើមបណ្តឹង ឬ/និងជនរងគ្រោះមិនអនុញ្ញាតឱ្យផ្តល់ចម្លើយក្នុងហានៈជាសាក្សីបានទេ។

១៤.៩.៧ ចុងចម្លើយអាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហានានាដែលទាក់ទងនឹងពាក្យបណ្តឹងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិ។

១៤.៩.៨ ចុងចម្លើយត្រូវបង្ហាញឯកសារកស្តុតាង ឬសាក្សីដើម្បីជាសំអាងការពាររឿងក្តីរបស់ខ្លួន។

១៤.៩.៩ ចុងចម្លើយអាចបង្ហាញកស្តុតាងជាទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ដើមបណ្តឹង។

១៤.៩.១០ នៅក្នុងនីតិវិធីប្រជុំសម្រេច ឬសវនាការតទល់ ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើមបណ្តឹងអាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយ។ ចុងចម្លើយក៏អាចចោទសំណួរទៅដើមបណ្តឹង ឬសាក្សីរបស់ដើមបណ្តឹង។

១៤.៩.១១ មុនពេលក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា ភាគីវិវាទអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថាមានប្រយោជន៍ដល់ខ្លួនជូនទៅក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិចារណា។

១៤.៩.១២ ភាគីវិវាទមានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះតាមការកំណត់ក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ។

១៤.៩.១៣ មធ្យោបាយបង្ហាញភស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជំនុំជម្រះក្តីក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកប្រើប្រាស់ក្នុងអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការនេះ។ ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ និងត្រូវគោរពតាម ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ។

១៤.៩.១៤ ជនណាបានប្រព្រឹត្តអំពើក្លែងលិខិត ឬឯកសារដោយក្លែងហត្ថលេខា ឬស្នាមមេដៃ ឬតាមមធ្យោបាយណាក៏ដោយ និងជនណាដែលបានប្រើប្រាស់ដោយដឹងខ្លួននូវលិខិត ឬឯកសារក្លែងនោះ ជននោះនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

១៤.៩.១៥ ដើមបណ្តឹង និងចុងចម្លើយមិនតម្រូវឱ្យធ្វើសម្បថទេ។

១៤.៩.១៦ ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាងរបស់ភាគីអាចស្នើសុំឱ្យ គឃ.សប គធ.ខប ឬ គ.ជ.ប ចាតចម្លងសំណុំរឿងពាក់ព័ន្ធឱ្យខ្លួនដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ។ ការចាតចម្លងត្រូវធ្វើដោយមន្ត្រីបោះឆ្នោតដែលត្រូវបានចាត់តាំង។

សិទ្ធិ និងភាតព្វកិច្ចរបស់សាក្សី

ប្រការ១៤.១០.-

សាក្សីត្រូវធ្វើសម្បថជាមុនហើយត្រូវឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅចំពោះមុខក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ និងសន្យាទទួលខុសត្រូវនៅចំពោះមុខច្បាប់អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីកម្មកូតកុហក ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត។ ទម្រង់នៃសម្បថត្រូវធ្វើដូចមានកំណត់នៅក្នុងនីតិវិធី និងខ្លឹមសារនៃសម្បថ។

១៤.១០.១ សាក្សីមានសិទ្ធិឆ្លើយបំភ្លឺនូវការពិតដែលខ្លួនបានឃើញ បានដឹង បានឮ និងបានចាំ ដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ។

១៤.១០.២ សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយត្រូវស្ថិតក្នុងបន្ទប់ផ្សេងគ្នា រង់ចាំការអញ្ជើញឱ្យមកបំភ្លឺដោយក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

១៤.១០.៣ សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយមិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នា ទោះតាមមធ្យោបាយណាក៏ដោយក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមប្រជុំសម្រេច ឬសវនាការ។

១៤.១០.៤ សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្តាប់ការសួរដេញដោលនៅក្នុងបន្ទប់ប្រជុំសម្រេច ឬបន្ទប់ជំនុំជម្រះឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

នីតិវិធីប្រជុំផ្សះផ្សា នីតិវិធីប្រជុំសម្រេច ឬនីតិវិធីសវនាការ

ប្រការ១៤.១១.

ដំណើរការប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការត្រូវដឹកនាំនិងចាត់ចែងដោយប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង (មានចែងក្នុងបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង)។

ប្រភេទសវនាការ

១៤.១១.១ ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការសង្ខេប សវនាការតទល់ ឬសវនាការសួរដេញដោល។

១៤.១១.១.១ សវនាការសង្ខេប ជាសវនាការដែលគ្មានទម្រង់ការច្រើន។ ក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតប នៅពេលយល់ឃើញថាមានតែចំណោទខាងច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ។

១៤.១១.១.២ សវនាការតទល់ ជាសវនាការដែលបើកឱ្យភាគីទំនាស់ជជែកតទល់គ្នាអំពីរឿងពាក្យបណ្តឹង។ ភាគីវិវាទកំណត់អំពីអង្គហេតុ និងត្រូវប្រមូលកស្តុតាង ដើម្បីដាក់ជូនសវនាការ។

១៤.១១.១.៣ សវនាការសួរដេញដោល ជាសវនាការដែលក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីយ៉ាងសំខាន់ក្នុងការសួរដេញដោលរកហេតុផលក្នុងរឿងក្តី។ ក្នុងសវនាការប្រភេទនេះទាំងក្រុមប្រឹក្សាជំនុំជម្រះ ទាំងគូក្តី ជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលភស្តុតាងផ្សេងៗ ដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីទទួលខុសត្រូវសំខាន់ជាអ្នកតាំងសំណួរដល់សាក្សី ចំណែកឯគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ។ ការចោទសួរដេញដោលនេះអាចធ្វើទៅបានដោយមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ

១៤.១១.២ ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការគឺភាសាខ្មែរ។ ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយខ្លួនឯង។

ការរៀបចំកន្លែង និងរៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

១៤.១១.៣ នៅថ្ងៃប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវអញ្ជើញចូលអង្គុយតាមទីកន្លែងដែលបានរៀបចំទុក។ ប្រធានអង្គុយនៅកណ្តាល សមាជិកអង្គុយអមសងខាង និងលេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការត្រូវអង្គុយនៅនឹងតុដែលនៅខាងឆ្វេងដៃ ឬស្តាំដៃនៃក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

១៤.១១.៣.១ ក្រោយពីបានអញ្ជើញអង្គុយតាមទីកន្លែងរួចមក ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវ៖

- ប្រកាសសមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ
- ប្រកាសសំណុំរឿង និងប្រកាសបើកការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ
- បង្គាប់លេខាធិការអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការឱ្យរាយការណ៍អំពីវត្តមានដើមបណ្តឹង ចុងចម្លើយ និងសាក្សី (ករណីប្រជុំសម្រេច ឬសវនាការ)។

១៤.១១.៣.២ មុននឹងចាប់ផ្តើមផ្សះផ្សា ឬសួរដេញដោលប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរទៅដើមបណ្តឹងថាតើលោក ឬលោកស្រីនៅតែបន្តប្តឹងដូចមានចែងក្នុងកម្មវត្ថុនៃបណ្តឹង ឬមានការកែប្រែឬទេ ? ប្រសិនបើ៖

- ដើមបណ្តឹងឆ្លើយថាខ្លួនដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបង្គាប់លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការឱ្យកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សា កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ហើយឱ្យដើមបណ្តឹងផ្តិតមេដៃលើកំណត់ហេតុនោះ។ បន្ទាប់មកក្រុមប្រឹក្សាប្រជុំផ្សះផ្សាអាចផ្សះផ្សារឿងក្តីផ្សេងទៀត (ប្រសិនបើមាន) ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចបន្តទៅពិភាក្សា ពិចារណា ឬបន្តទៅប្រជុំសម្រេច ឬសវនាការរឿងក្តីផ្សេងទៀត (ប្រសិនបើមាន)
- ដើមបណ្តឹងនៅតែបន្តប្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាប់ផ្តើមដំណើរការប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ។

១៤.១១.៣.៣ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវសួរដេញដោលទៅដើមបណ្តឹងមុន រួចត្រូវសួរទៅចុងចម្លើយ។ បន្ទាប់មក ប្រធានត្រូវសួរសាក្សីដើមបណ្តឹង សាក្សីចុងចម្លើយ និងអ្នកពាក់ព័ន្ធ រួចឱ្យភាគីដើមបណ្តឹង និងភាគីចុងចម្លើយធ្វើសំណូមពរចុងក្រោយ។

១៤.១១.៣.៤ ប្រសិនបើមានមេធាវីការពារក្តី ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវផ្តល់ពេលវេលាឱ្យមេធាវីនិយាយការពារកូនក្តីសួរភាគី និងធ្វើសេចក្តីសន្និដ្ឋានចុងក្រោយមុនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះចេញទៅពិភាក្សាពិចារណា

១៤.១១.៣.៥ ក្នុងពេលដំណើរការប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ ប្រសិនបើដើមបណ្តឹងសុំដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបញ្ចប់ការផ្សះផ្សា ឬសួរដេញដោលនោះភ្លាម រួចត្រូវអនុវត្តដូចគ្នានឹងករណីដើមបណ្តឹងដកពាក្យបណ្តឹង ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះសួរពេលដំបូងដែរ។

១៤.១១.៣.៦ ក្រោយពីបានដំណើរការប្រជុំសម្រេច ឬសវនាការតាមលំដាប់លំដោយ រួចហើយក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវថ្លែងទៅពិភាក្សាពិចារណានៅក្នុងបន្ទប់សម្ងាត់។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់។

តួនាទីរបស់លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ

១៤.១១.៤ លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ មានតួនាទីដូចខាងក្រោម៖

- បិទផ្សាយ និងអានបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការឱ្យអ្នកចូលរួមបានជ្រាប
- នាំសាក្សីទៅស្បថ (ករណីប្រជុំសម្រេច ឬសវនាការ)
- ប្រាប់ទៅអ្នកចូលរួមទាំងអស់ ឱ្យក្រោកឈរនៅពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអញ្ជើញមកដល់
- ពិនិត្យ និងស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ដែលត្រូវចូលរួមប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ លើកលែងតែការប្រជុំសម្រេច ឬសវនាការ ដែលត្រូវស្រង់វត្តមានសាក្សី
- រាយការណ៍អំពីវត្តមាន ឬអវត្តមានភាគីពាក់ព័ន្ធជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ
- ត្រូវសរសេរដោយដៃ ឬដោយវាយកុំព្យូទ័រនូវកំណត់ហេតុប្រជុំផ្សះផ្សា កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ក្នុងពេលប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ។ ការកត់ត្រាកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការមិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ ពាក្យឆូតលុបចោល និងពាក្យសរសេរយោងត្រូវមានសេចក្តីបញ្ជាក់ និងមានហត្ថលេខារបស់លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ ប្រធាន និងសមាជិកក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ និងភាគីពាក់ព័ន្ធ
- អានឯកសារផ្សេងៗដែលពាក់ព័ន្ធតាមការបង្គាប់ពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ

- រៀបចំសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចចុះហត្ថលេខា ហើយដាក់ជូនប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះចុះហត្ថលេខា ឈ្មោះ បោះត្រា និងចុះកាលបរិច្ឆេទ
- អញ្ជើញភាគីផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សា កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ក្នុងករណីដែលភាគីណាមួយមិនព្រមផ្តិតមេដៃ លេខាធិការអង្គប្រជុំផ្សះផ្សា លេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការត្រូវចុះនិទ្ទេសអំពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ។

ពេលវេលាដោះស្រាយពាក្យបណ្តឹង

១៤.១១.៥ ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ អាចធ្វើជារៀងរាល់ថ្ងៃចាប់ពីម៉ោង ៨:០០ (ប្រាំបី) ព្រឹក រហូតដល់ម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទីថ្ងៃត្រង់ និងរសៀលចាប់ពីម៉ោង ១៤:០០ (ដប់បួន) រហូតដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី។ ក្នុងករណីចាំបាច់ ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការអាចបន្តធ្វើទៅតាមស្ថានភាពជាក់ស្តែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ។ ក្នុងកម្មវិធីមួយពេលនៃការបើកប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការលើពាក្យបណ្តឹងអាចកំណត់ធ្វើការប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការច្រើនករណីនៃពាក្យបណ្តឹងបាន។

ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា បើកអង្គប្រជុំសម្រេច ឬបើកសវនាការ

ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេចនៅ គឃ.សប

១៤.១១.៦ គឃ.សប ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីកំណត់ប្រតិទិនសម្រាប់ប្រជុំផ្សះផ្សា ឬ/និងប្រជុំសម្រេចនៅថ្នាក់របស់ខ្លួនទៅតាមករណីនៃពាក្យបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ និងត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការប្រជុំផ្សះផ្សា ឬប្រជុំសម្រេចដល់ភាគីវិវាទបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច។

ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការនៅ គធ.ខប

១៤.១១.៧ គធ.ខប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយពាក្យបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គធ.ខប ទៅតាមករណីនៃពាក្យបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ។ លគធ.ខប ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកការប្រជុំផ្សះផ្សា ឬបើកសវនាការដល់ភាគីវិវាទឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលបើកការប្រជុំផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងប្រជុំផ្សះផ្សា (ករណីផ្សះផ្សាមិនសះជា) ទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងបើកសវនាការតែម្តង។

ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប

១៤.១១.៨ គ.ជ.ប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយពាក្យបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គ.ជ.ប ទៅតាមករណីនៃពាក្យបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស នេះ។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកសវនាការដល់ភាគីវិវាទឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលបើកសវនាការ។

ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ

១៤.១១.៩ ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សាទេ នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវសម្រេចលើកពាក្យបណ្តឹងចោលដោយធ្វើលិខិតជូនដំណឹងទៅភាគីដើមបណ្តឹង។

១៤.១១.១០ ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការទេ នោះក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចកំបាំងមុខដើមបណ្តឹង ប៉ុន្តែចាត់ទុកជាចំពោះមុខដោយបញ្ជាក់អំពីមូលហេតុលើសេចក្តីសម្រេច។

១៤.១១.១១ ប្រសិនបើភាគីដើមបណ្តឹងស្លាប់នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

១៤.១១.១២ ប្រសិនបើភាគីចុងចម្លើយស្លាប់មុនពេលបើកប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវលុបពាក្យបណ្តឹងចេញពីបញ្ជី ហើយត្រូវជូនដំណឹងទៅភាគីដើមបណ្តឹងឱ្យបានជ្រាប។

១៤.១១.១៣ ប្រសិនបើចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែមិនមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សា ថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

១៤.១១.១៤ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយមិនបានបង្ហាញខ្លួននាថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាត់លេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ព្រមទាំងស្នើសុំកិច្ចសហការពីអាជ្ញាធរឃុំ សង្កាត់អមដំណើរជាមួយ ដើម្បីបញ្ជូនសម្រង់សេចក្តីសម្រេច (ទ.១២០៣) ទៅជូនដើមបណ្តឹង ឬចុងចម្លើយនៅអាសយដ្ឋានរបស់ដើមបណ្តឹង ឬចុងចម្លើយ ឬទីស្នាក់ការគណបក្សនយោបាយរបស់ដើមបណ្តឹង ឬចុងចម្លើយនោះ។ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយបដិសេធមិនទទួលយកសម្រង់សេចក្តីសម្រេច (ទ.១២០៣)

នោះលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសាលានាការ ឬមន្ត្រី គ.ជ.ប ត្រូវចារលើសម្រង់សេចក្តីសម្រេច (ទ.១២០៣) នោះ ដោយបញ្ជាក់ឱ្យបានច្បាស់ថា "អ្នកប្តឹង ឬតំណាង ឬចុងចម្លើយ ឬតំណាងមិនព្រមទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)" ហើយចុះកាលបរិច្ឆេទ និងហត្ថលេខា និងមានហត្ថលេខារបស់អាជ្ញាធរឃុំ សង្កាត់ដែលអមដំណើរទៅជាមួយ ដើម្បីបញ្ជាក់ថាភាគីនៃពាក្យបណ្តឹងពិតជាមិនព្រមទទួលយកសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចបិទសម្រង់សេចក្តីសម្រេច (ទ.១២០៣) នោះនៅមុខលំនៅឋាន ឬទីសំណាក់ ឬទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនៃពាក្យបណ្តឹង ហើយចាត់ទុកថាភាគីនៃពាក្យបណ្តឹងបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចហើយ។

ការប្រកាសសេចក្តីសម្រេច

១៤.១១.១៥ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវប្រកាសសេចក្តីសម្រេចភ្លាមបន្ទាប់ពីពិភាក្សាគ្នារួចរាល់។ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះរឿងពាក្យបណ្តឹងដែលមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត ប៉ុន្តែមិនត្រូវឱ្យហួសរយៈពេលកំណត់នៃការដោះស្រាយពាក្យបណ្តឹងឡើយ។ ការប្រកាសសេចក្តីសម្រេចត្រូវធ្វើឡើងដោយប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេច ដោយផ្អែកលើច្បាប់ដើមនៃសេចក្តីសម្រេច។ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចចាត់តាំងសមាជិកក្រុមប្រឹក្សាប្រជុំសម្រេច ឬសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាម្នាក់អានជំនួសបាន។

ការបំពេញ និងប្រើប្រាស់សម្រង់សេចក្តីសម្រេច (ទ.១២០៣)

១៤.១១.១៦ សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប ត្រូវធ្វើឡើងផ្អែកតាមកំណត់ហេតុប្រជុំសម្រេច ហើយចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច។ ការបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) នៅ គឃ.សប ត្រូវធ្វើជា ៣ (បី) ច្បាប់សម្រាប់ពាក្យបណ្តឹងតវ៉ា ឬ ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្តឹងជំទាស់ដើម្បី៖

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះពាក្យបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.១១.១៧ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្តីសម្រេចនេះត្រូវស្រង់ជាក់ក្នុងសម្រង់សេចក្តីសម្រេច (ទ.១២០៣) ហើយត្រូវចុះហត្ថលេខាដោយលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយត្រូវធ្វើឡើងតាមចំនួននិងកម្មវត្ថុនៃបណ្តឹង ឬចំនួនផ្សេងទៀតតាមការចាំបាច់។

១៤.១១.១៨ ការបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) នៅ គធ.ខប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្តឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់ពាក្យបណ្តឹងជំទាស់ដើម្បី៖

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះពាក្យបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.១១.១៩ ការបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) នៅ គ.ជ.ប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្តឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់ពាក្យបណ្តឹងជំទាស់ដើម្បី៖

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះពាក្យបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ការបញ្ជូនសម្រង់សេចក្តីសម្រេច (ទ.១២០៣)

១៤.១១.២០ គ.ជ.ប ត្រូវចាត់តាំងមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ១ (មួយ) រូប ឱ្យទទួលបន្ទុកជាមន្ត្រីប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣)។ សម្រង់សេចក្តីសម្រេច (ទ.១២០៣) ត្រូវប្រគល់ជូនភាគីវិវាទភ្លាមៗ បន្ទាប់ពី គ.ជ.ប បញ្ចប់សវនាការ ហើយការប្រគល់ និងការទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) នេះ ត្រូវមានកំណត់ហេតុដែលបញ្ជាក់អំពីពេលវេលា និងកាលបរិច្ឆេទនៃការប្រគល់ និងការទទួលឱ្យបានច្បាស់លាស់។

កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប និងហត្ថលេខារបស់អ្នកទទួលជាក់ស្តែង។ ករណី៖

១៤.១១.២០.១ ភាគីវិវាទណាមួយបដិសេធមិនព្រមទទួលយកសម្រង់សេចក្តីសម្រេច (ទ.១២០៣) មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមទទួលយកឱ្យបានច្បាស់លាស់។

១៤.១១.២០.២ ភាគីវិវាទជាភ្នាក់ងារ ឬតំណាងគណបក្សនយោបាយ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវបញ្ជូនសម្រង់សេចក្តីសម្រេច (ទ.១២០៣) ដោយមានដីកាអមទៅទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនោះ។ កាលបរិច្ឆេទនៃការទទួលដីកាអម ត្រូវចាត់ទុកជាកាលបរិច្ឆេទទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

ទម្រង់បែបបទផ្សេងៗទៀតសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ

១៤.១១.២១ គយ.សប គធ.ខប និង គ.ជ.ប មានទម្រង់បែបបទផ្សេងៗទៀតសម្រាប់ប្រើប្រាស់ក្នុងការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ មានជាអាទិ៍លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ កំណត់ហេតុសាកសួរ និងកំណត់ហេតុប្រជុំផ្សះផ្សា កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប។

១៤.១១.២១.១ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ ត្រូវបំពេញតាមចំនួនជាក់ស្តែងនៃអ្នកពាក់ព័ន្ធ ដែលត្រូវអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការរួចប្រគល់ជូនភាគីពាក់ព័ន្ធ ១ (មួយ) ច្បាប់ៗ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១៤.១១.២១.២ កំណត់ហេតុសាកសួរអាចធ្វើឡើងដោយដៃ ឬដោយវាយកុំព្យូទ័រ។

១៤.១១.២១.៣ កំណត់ហេតុប្រជុំផ្សះផ្សាត្រូវបំពេញដោយលេខាធិការអង្គប្រជុំផ្សះផ្សា ចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្តឹង និងលទ្ធផលនៃការផ្សះផ្សា។

១៤.១១.២១.៤ កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការត្រូវបំពេញដោយលេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្តឹង ព្រមទាំងការឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

១៤.១១.២១.៥ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវសរសេរនូវចំណុច (១) រដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជា និងនីតិវិធីពាក់ព័ន្ធនឹងការបោះឆ្នោត ពាក្យបណ្តឹង លិខិតប្រគល់សិទ្ធិ ឬ/និងកំណត់ហេតុ ឬ/និងរបាយការណ៍ផ្សេងៗ (២) ការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។ ច្បាប់ចតចម្លងនៃសេចក្តីសម្រេចនេះ អាចផ្តល់ជូនភាគីវិវាទបានប្រសិនបើមានការស្នើសុំ។

ការបញ្ជូនសំណុំរឿង

១៤.១១.២២ គឃ.សប ត្រូវបញ្ជូនសំណុំរឿងច្បាប់ដើមទាំងអស់ជាបន្ទាន់មក គធ.ខប បន្ទាប់ពីថ្ងៃបានដោះស្រាយពាក្យបណ្តឹងចប់សព្វគ្រប់។

១៤.១១.២៣ គធ.ខប ត្រូវបញ្ជូនសំណុំរឿងច្បាប់ដើមទាំងអស់ជាបន្ទាន់មក គ.ជ.ប បន្ទាប់ពីថ្ងៃបានដោះស្រាយពាក្យបណ្តឹងចប់សព្វគ្រប់។

ផ្នែកទី៣
បែបបទ និងនីតិវិធីនៃការអនុវត្តទណ្ឌកម្មគ្រប់អំពើល្មើស លើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប

ប្រការ១៤.១២.

បទប្បញ្ញត្តិនៃផ្នែកនេះ កំណត់អំពីសមត្ថកិច្ច និងនីតិវិធីនៃការអនុវត្តទណ្ឌកម្មចំពោះគ្រប់អំពើល្មើសលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប ដែលត្រូវបាន គ.ជ.ប ឬ/និង គធ.ខប សម្រេចដាក់ទណ្ឌកម្មបានចូលជាស្តាពរ ក្នុងគោលដៅជានាឱ្យបាននូវការអនុវត្តវិធានច្បាប់របស់ គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម និងមន្ត្រីបោះឆ្នោតពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ស្របតាមគោលការណ៍ ច.ប.ឃ.ស ឬ ច.វ.ច.ប។

ប្រភេទនៃទណ្ឌកម្មចំពោះគ្រប់អំពើល្មើសច្បាប់បោះឆ្នោត

ប្រការ១៤.១៣.

ទណ្ឌកម្មដែលត្រូវអនុវត្តចំពោះគ្រប់អំពើល្មើសច្បាប់បោះឆ្នោត ត្រូវបានកំណត់រួមមានទណ្ឌកម្មរដ្ឋបាល ទណ្ឌកម្មផាកពិន័យជាប្រាក់ ទណ្ឌកម្មដកហូតសិទ្ធិបោះឆ្នោត និងការបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាចំពោះជនបរទេស។



១៤.១៣.១ ទណ្ឌកម្មរដ្ឋបាលរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ

- ការលុបឈ្មោះចេញពីមន្ត្រីបម្រើការងាររបោះឆ្នោត
- ការស្នើទៅក្រសួង ស្ថាប័នរបស់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិដោយការរបោះឆ្នោតដាក់ទណ្ឌកម្មវិន័យ។

១៤.១៣.២ ទណ្ឌកម្មផាកពិន័យជាប្រាក់។

១៤.១៣.៣ ទណ្ឌកម្មដកហូតសិទ្ធិបោះឆ្នោតរួមមាន៖
- ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយ
- ការលុបបេក្ខភាពរបស់បេក្ខជន ឬការលុបបេក្ខភាពគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត។

១៤.១៣.៤ ការបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាចំពោះជនបរទេស។

សមត្ថកិច្ច និងនីតិវិធីនៃការអនុវត្តទណ្ឌកម្មចំពោះគ្រប់អំពើល្មើសច្បាប់បោះឆ្នោត ប្រការ១៤.១៤.

ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ឬ/និងក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មានសមត្ថកិច្ចដាក់ទណ្ឌកម្មចំពោះគ្រប់អំពើល្មើសលើទោសប្បញ្ញត្តិនៃ ច.ប.ឃ.ស ឬ ច.វ.ច.ប។ អគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលមានអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសជាសេនាធិការ តាមសំណើរបស់នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវទទួលខុសត្រូវចាត់ចែង រៀបចំ និងអនុវត្តទណ្ឌកម្មដូចមានចែងក្នុងប្រការ១៤.១៣ ខាងលើនេះ ដែលបានចូលជាស្ថាពរ ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេច។ លើកលែងតែការអនុវត្តទណ្ឌកម្មរដ្ឋបាលដោយការព្រមានជាលាយលក្ខណ៍អក្សរនៅថ្នាក់រាជធានី ខេត្ត ត្រូវធ្វើឡើងដោយ គធ.ខប។

ការអនុវត្តទណ្ឌកម្មរដ្ឋបាល

១៤.១៤.១ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ឬ/និងប្រធានអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប ត្រូវរៀបចំលិខិតព្រមានចំពោះបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តល្មើសនឹង ច.ប.ឃ.ស ឬ ច.វ.ច.ប រួចដាក់ជូន គ.ជ.ប ឬ/និង គធ.ខប តាមហានានុក្រម ពិនិត្យ និងសម្រេច ស្របតាមសេចក្តីសម្រេចស្តាពរ។

១៤.១៤.២ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវសហការជាមួយនាយកដ្ឋានរដ្ឋបាលនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អនុវត្តការលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីមន្ត្រីបម្រើការងាររបោះឆ្នោត និងមិនឱ្យចូលបម្រើការងាររបោះឆ្នោត ក្នុងរយៈពេលកំណត់ ស្របតាមសេចក្តីសម្រេចស្តាពរ។

១៤.១៤.៣ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរៀបចំបែបបទដាក់ជូន គ.ជ.ប តាមហានានុក្រម ដើម្បីស្នើសុំទៅក្រសួង ស្ថាប័នសាមីពាក់ព័ន្ធ ដើម្បីដាក់វិន័យរដ្ឋបាលចំពោះអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិដោយការបោះឆ្នោតដែលបានប្រព្រឹត្តល្មើសនឹង ច.ប.ឃ.ស ឬ ច.វ.ច.ប ស្របតាមទណ្ឌកម្មដែលបានដាក់ចេញ។

ការអនុវត្តទណ្ឌកម្មផាកពិន័យជាប្រាក់

១៤.១៤.៤ គ.ជ.ប ត្រូវចាត់វិធានការជូនដំណឹងទៅជនដែលត្រូវផាកពិន័យឱ្យចូលខ្លួនមកអនុវត្តសេចក្តីសម្រេចដាក់ទណ្ឌកម្មផាកពិន័យជាប្រាក់ ស្របតាមសេចក្តីសម្រេចស្តាពរដោយស្មគ្រចិត្តក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសេចក្តីបង្គាប់។

១៤.១៤.៥ ករណីដល់ពេលកំណត់ហើយ ជនដែលត្រូវផាកពិន័យមិនព្រមបង់ប្រាក់ពិន័យតាមសេចក្តីបង្គាប់ទេនោះ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវរៀបចំរបាយការណ៍ និងលើកសំណើតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស និងអគ្គលេខាធិការ គ.ជ.ប ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេចចាត់វិធានការបន្ទាន់។

១៤.១៤.៦ ប្រសិនបើ គ.ជ.ប យល់ឃើញថាគ្មានស្ថានភាពចាំបាច់ណាមួយដែល គ.ជ.ប ត្រូវអនុគ្រោះ គ.ជ.ប អាចស្នើសុំស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីសម្រេចស្តាពរទារប្រាក់ពីជនដែលត្រូវផាកពិន័យជូន គ.ជ.ប ស្របតាមមាត្រា១៩៣ នៃ ច.ប.ឃ.ស។

១៤.១៤.៧ ប្រាក់ផាកពិន័យដែលទទួលបាន ត្រូវដាក់ចូលជាថវិការដ្ឋ។

ការអនុវត្តទណ្ឌកម្មលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពបេក្ខជន ឬលុបបេក្ខភាពគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

១៤.១៤.៨ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវសហការជាមួយនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត អនុវត្តការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតក្នុងរយៈពេលកំណត់ ស្របតាមសេចក្តីសម្រេចស្តាពរ។

១៤.១៤.៩ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវលុបបេក្ខភាពបេក្ខជន ឬលុបបេក្ខភាពគណបក្សនយោបាយឈរឈ្មោះ ស្របតាមសេចក្តីសម្រេចស្តាពរ។

ការបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាចំពោះជនបរទេស

១៤.១៤.១០ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរៀបចំបែបបទស្នើសុំ គ.ជ.ប តាមហានុក្រមដើម្បីស្នើសុំទៅក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីបណ្តេញជនបរទេសចេញពីព្រះរាជាណាចក្រកម្ពុជាតាមបែបបទដូចមានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

ប្រការ១៤.១៥.

ដើម្បីធានាឱ្យគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ/និងមន្ត្រីបោះឆ្នោតអនុវត្តសេចក្តីសម្រេចស្តាពរឱ្យបានពេញលេញ និងមានប្រសិទ្ធភាពក្នុងសម័យបោះឆ្នោត ឬ/និងដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ស្របតាមសេចក្តីសម្រេចស្តាពរ។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវទទួលខុសត្រូវផ្តល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ពាក់ព័ន្ធនឹងការលុបឈ្មោះជនប្រព្រឹត្ត

អំពើល្មើសចេញពីបញ្ជីបោះឆ្នោត និងការលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីមន្ត្រីបម្រើការងារបោះឆ្នោត និងមិនឱ្យចូលបម្រើការងារបោះឆ្នោតក្នុងរយៈពេលកំណត់ ដោយជូនដល់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ/និងមន្ត្រីបោះឆ្នោតដែលមានសមត្ថកិច្ចក្នុងរយៈពេលនៃការអនុវត្តទណ្ឌកម្ម។

ការទទួលបានឥទ្ធិឆ្ងួតសិទ្ធិពេញលេញដោយពេញច្បាប់

ប្រការ១៤.១៦.

ជនដែលទទួលរងឥទ្ធិពលពីទណ្ឌកម្មលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបឈ្មោះចេញពីមន្ត្រីបម្រើការងារបោះឆ្នោត បានអនុវត្តទណ្ឌកម្មចប់សព្វគ្រប់ក្នុងរយៈពេលកំណត់រួចហើយ ជននោះទទួលបានវិញនូវសិទ្ធិពេញលេញដោយពេញច្បាប់ ហើយអាចអនុវត្តសិទ្ធិ និងករណីយកិច្ចជាពលរដ្ឋក្នុងដំណើរការបោះឆ្នោតស្របតាមច្បាប់ស្តីពីការបោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។

បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា អង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ជនគ្រប់រូបដែលមានវត្តមានក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការត្រូវគោរព និងអនុវត្តបទបញ្ជាដូចតទៅ៖

១- ហាមជក់បារីក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

២- ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការដូចជា៖
- ការដើរឆ្លងកាត់ ឬដើរចេញ ចូលរហេតរហូត ដោយគ្មានការអនុញ្ញាត
- ការជជែកគ្នាខ្លាំងៗ ស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ។

៣- ហាមក្មេងអាយុក្រោម១៨ឆ្នាំ ចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

៤- ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៥- ហាមថតរូប និងថតសំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

៦- ហាមប្រើប្រាស់ទូរសព្ទដៃ វិទ្យុទាក់ទង សម្ភារ បរិក្ខារអេឡិចត្រូនិកដែលអាចថតរូប វីដេអូ និងសំឡេងផ្សេងៗក្នុងបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៧- ក្នុងករណីជនណាម្នាក់ ឬច្រើននាក់បង្កសកម្មភាពណាមួយដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ធ្វើឱ្យមានការប៉ះពាល់ដល់របៀបរៀបរយការប្រជុំផ្សះផ្សា ការប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចបណ្តេញជននោះ ឬទាំងនោះចេញពីបន្ទប់ប្រជុំផ្សះផ្សា បន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលប្រជុំផ្សះផ្សា ប្រជុំសម្រេច ឬសវនាការ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

នីតិវិធី និងខ្លឹមសារនៃសម្បថ

ការធ្វើសច្ចាប្រណិធានត្រូវដឹកនាំធ្វើឡើងដោយលេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬ គណៈលេខាធិការសវនាការ ហើយត្រូវធ្វើនៅចំពោះមុខវត្ថុស័ក្តិសិទ្ធិនៅទីកន្លែងបើកអង្គប្រជុំសម្រេច ឬសវនាការនីមួយៗ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូបបូជានៅចំពោះមុខវត្ថុស័ក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មកលេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្តាប់រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម។

ក្រោយពីធ្វើសម្បថរួច លេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការត្រូវធ្វើកំណត់ហេតុនៃការធ្វើសម្បថនោះ ដោយបញ្ជាក់ថាបានធ្វើត្រឹមត្រូវ ហើយសេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណាត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិ មានព្រះអង្គដងកើ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដៃក លោកតាដំបងគ្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គជីវិតបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាជើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ដ្បិតភាគីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់តាមការណ៍ពិត។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិបំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនាអស់ប្រាំរយជាតិ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនកូតកុហក មិនលម្អៀង ព្រោះជាញាតិសាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រឡាញ់រាប់អាន លុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ប្តុំប្តើង រុងរឿង សមដូចសេចក្តីបំណងប្រាថ្នា កុំបីអាក់ខានឡើយ។

ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។

បើខ្ញុំឆ្លើយមិនពិតដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិទាំងអស់បរាមុខខ្ញុំឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូនកូនចៅ ញាតិផៅសន្ដានជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ។

ឧបសម្ព័ន្ធទី១
ក្រមសីលធម៌
សម្រាប់
មន្ត្រីបោះឆ្នោត

១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី របស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ បោះឆ្នោតជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និង អន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អនាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌ បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿ ទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់មន្ត្រីបោះឆ្នោត ទាំងអស់អនុវត្តក្នុងដំណើរការបោះឆ្នោត ដើម្បីធានាបានប្រសិទ្ធភាពការងារ អព្យាក្រឹតភាព និងជំនឿទុកចិត្ត លើការបោះឆ្នោត។

២- គោលបំណង

ក្រមសីលធម៌នេះមានគោលបំណងកំណត់វិធានសំខាន់ៗ ដើម្បីគ្រប់គ្រងសកម្មភាពមន្ត្រីបោះឆ្នោត ក្នុងការអនុវត្តសមត្ថកិច្ច ភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ដើម្បីពង្រឹងអព្យាក្រឹតភាព ភាពមិនលម្អៀង សេចក្តីថ្លៃថ្នូរ សីលធម៌បុគ្គល និងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ដោយឈរលើគោលការណ៍គោរពច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប ច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ដោយមិនត្រូវទទួលរងនូវឥទ្ធិពលផ្សេងៗ និងធានាឱ្យដំណើរការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជាប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

ការគោរពបានល្អនូវក្រមសីលធម៌នេះ រួមចំណែកផ្តល់លទ្ធភាពឱ្យ គ.ជ.ប និងមន្ត្រីបោះឆ្នោតទាំងអស់សម្រេចបាននូវ៖

- ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតដែលធ្វើឡើងទៅតាមច្បាប់ស្តីពីការបោះឆ្នោត
- ការបោះឆ្នោតដែលមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលទទួលយកបានដោយប្រជាពលរដ្ឋកម្ពុជា ដោយគណបក្សនយោបាយចូលរួមបោះឆ្នោត និងដោយសហគមន៍អន្តរជាតិ
- ការបោះឆ្នោតដែលប្រព្រឹត្តទៅដោយគ្មានការគំរាមកំហែង គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ គ្មានការបំភិតបំភ័យ ឬការផ្ចាញ់ផ្ចាល។

៣- វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីបោះឆ្នោតដែលបំពេញការងាររៀបចំការបោះឆ្នោត ក្នុងដំណើរការបោះឆ្នោត នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ឬលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លគធ.ខប) និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។ មន្ត្រីបោះឆ្នោតទាំងអស់ត្រូវប្រតិបត្តិក្រមសីលធម៌នេះនៅពេលបំពេញការកិច្ចរបស់ខ្លួនទាំងក្នុងម៉ោងធ្វើការ ទាំងក្រៅម៉ោងធ្វើការ។

៤- និយមន័យ

វាក្យសព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **មន្ត្រីបោះឆ្នោត** សំដៅដល់៖

- អ្នករាជការនៃ គ.ជ.ប
- សមាជិកគ្រប់រូបនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីជាប់កិច្ចសន្យាដែលត្រូវបានជ្រើសរើសឱ្យបំពេញការងារបោះឆ្នោតតាមដំណាក់កាល
- មន្ត្រីដែលត្រូវបានធ្វើប្រតិភូកម្មអំណាចឱ្យដោយ គ.ជ.ប តាមច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ និងស្ថិតក្នុងម៉ោងបំពេញការងារចុះឈ្មោះបោះឆ្នោត។

៤.២- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៣- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥- សិទ្ធិ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវដាក់លាក់ក្នុងការអនុវត្តសមត្ថកិច្ច ភារកិច្ចរបស់ខ្លួនក្នុងដំណើរការបោះឆ្នោត។

៥.១- សិទ្ធិរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានសិទ្ធិដូចខាងក្រោម៖

៥.១.១ អនុវត្តនូវគោលការណ៍ច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

៥.១.២ អនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនដោយជំហរអព្យាក្រឹត ឥតលម្អៀងដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

៥.១.៣ ផ្តល់ជំនួយតាមសំណូមពរសម្រាប់ប្រជាពលរដ្ឋដែលមានពិការភាព ឬមិនចេះអក្សរ មានបំណងសុំចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោតដែលមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន។

៥.១.៤ ទទួលបានការការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន នៅក្នុងពេលដែលកំពុងបំពេញការងាររៀបចំការបោះឆ្នោតក្នុងករណីចាំបាច់។

៥.២- តារកិច្ចរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានភារកិច្ចដូចខាងក្រោម៖

៥.២.១ ការអនុវត្តច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាមច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោតដែលនៅជាធរមាន។

៥.២.២ លក្ខខណ្ឌការងារ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាមអាណត្តិ និងលក្ខខណ្ឌការងាររបស់ខ្លួនដែលកំណត់ដោយ គ.ជ.ប ដោយរាប់បញ្ចូលទាំងក្រមសីលធម៌នេះផងដែរ។

៥.២.៣ ការអនុវត្តក្រមសីលធម៌

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាម គាំទ្រ និងអនុវត្តក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត។

៥.២.៤ ការគាំទ្រ និងការផ្សព្វផ្សាយ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តផ្តល់ការគាំទ្រ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោតដែលនៅជាធរមាន និងក្រមសីលធម៌នេះ។

៥.២.៥ ការថ្កោលទោសចំពោះអំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យ

ក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តថ្កោលទោស រារាំង និងទប់ស្កាត់នូវរាល់អំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យណាមួយទាក់ទងដល់ដំណើរការបោះឆ្នោត។

៥.២.៦ បរិយាកាសការងារ

ក- ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវបង្ក និងរក្សាភាពមិនលម្អៀងការបោះឆ្នោតជាសម្ងាត់ និងសេចក្តីថ្លៃថ្នូរ។

ខ- មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវត្រៀមលក្ខណៈចាត់វិធានការសមស្របទៅតាមស្ថានភាពជាក់ស្តែងដែលកើតមានឡើងក្នុងដំណើរការបោះឆ្នោត។ មន្ត្រីបោះឆ្នោតត្រូវ៖

- អនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ទោះក្នុងកាលៈទេសៈលំបាកយ៉ាងណាក៏ដោយ
- អនុវត្តកិច្ចការផ្សេងទៀតដែលត្រូវបានប្រគល់ជូន និងដែលសមស្របតាមសមត្ថភាពរបស់ខ្លួន ទោះបីកិច្ចការនោះមិនមែនជាភារកិច្ចរបស់ខ្លួនក៏ដោយ។

គ- ក្នុងករណីមានការជ្រៀតជ្រែក ឬការរំខាន មន្ត្រីបោះឆ្នោតត្រូវ៖

- បន្តអនុវត្តភារកិច្ចរបស់ខ្លួនដោយប្រុងប្រយ័ត្ន និងខ្ជាប់ខ្ជួន
- រក្សាសុវត្ថិភាពសម្ភារ បរិក្ខារបោះឆ្នោតទាំងអស់ដែលខ្លួនទទួលខុសត្រូវ
- រាយការណ៍ជាបន្ទាន់តាមឋានានុក្រម
- ធ្វើសកម្មភាពជាបន្ទាន់ទៅតាមសេចក្តីណែនាំផ្សេងៗពីមន្ត្រីថ្នាក់លើរបស់ខ្លួន។

៥.២.៧ ជំនួយពិសេស

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវផ្តល់ជំនួយពិសេសក្នុងសមត្ថកិច្ចរបស់ខ្លួនតាមសំណូមពរដល់បុគ្គលដែល៖

- មិនចេះអក្សរ (ក្នុងពេលចុះឈ្មោះបោះឆ្នោត) ឬមានពិការភាព
- មិនដឹងថាខ្លួនត្រូវធ្វើអ្វី ឬមិនប្រាកដអំពីអ្វីដែលខ្លួនត្រូវធ្វើ ដើម្បីចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត
- មិនដឹងពីរបៀបដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់
- មិនមានឯកសារតាមលក្ខខណ្ឌតម្រូវសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត ឬឈ្មោះរបស់គាត់បានបាត់ចេញពីបញ្ជីបោះឆ្នោត ឬសិទ្ធិចុះឈ្មោះបោះឆ្នោត ឬសិទ្ធិបោះឆ្នោតរបស់គាត់ត្រូវបានបដិសេធ។

៥.៣- ការទទួលខុសត្រូវរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតត្រូវមានការទទួលខុសត្រូវចំពោះភារកិច្ចខ្លួនតាមទីកន្លែង និងករណីដូចខាងក្រោម៖

៥.៣.១ នៅការិយាល័យចុះឈ្មោះបោះឆ្នោត

ក- មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តភារកិច្ចដាក់លាក់របស់ខ្លួនដើម្បីធានាបានថាប្រជាពលរដ្ឋគ្រប់រូប ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោតអាចអនុវត្តសិទ្ធិ និងភារកិច្ចរបស់ខ្លួនដោយសេចក្តីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្របក្នុងការសុំចុះឈ្មោះបោះឆ្នោត។

ខ- មន្ត្រីបោះឆ្នោតត្រូវយកចិត្តទុកដាក់ជាអាទិ៍ចំពោះប្រជាពលរដ្ឋខ្មែរដែលមានពិការភាពណាម្នាក់មិនមាំមួន មានជំងឺ ចាស់ជរា ឬស្ត្រីមានផ្ទៃពោះ ឬទើបឆ្លងទន្លេ ឬមិនចេះអក្សរមានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយ ឬកម្រិតណាមួយដែលខ្លួនត្រូវការ ដើម្បីជាជំនួយក្នុងការចុះឈ្មោះបោះឆ្នោត។ មន្ត្រីបោះឆ្នោតដែលត្រូវបានចាត់ឱ្យជួយអ្នកសុំចុះឈ្មោះបោះឆ្នោតនោះត្រូវធ្វើទៅតាមកម្រិតដែលបានស្នើសុំតែប៉ុណ្ណោះ។

៥.៣.២ នៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

ក- នៅការិយាល័យបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារបោះឆ្នោតត្រូវអនុវត្តភារកិច្ចដាក់លាក់របស់ខ្លួន ដើម្បីអនុញ្ញាតឱ្យអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទាំងអស់អាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតជាសម្ងាត់ ដោយសេចក្តីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្របនិងធានាថាសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោតទាំងអស់ ត្រូវតែមានសុវត្ថិភាព ត្រឹមត្រូវ និងគ្រប់ចំនួន។

ខ- មន្ត្រីបោះឆ្នោតត្រូវផ្តល់ជំនួយសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាពមិនអាចបោះឆ្នោតដោយខ្លួនឯងបាន តាមសំណូមពរ ដោយត្រូវធ្វើទៅតាមកម្រិតដែលបានស្នើសុំដោយអ្នកបោះឆ្នោតរូបនោះតែប៉ុណ្ណោះ និងទៅតាមការកំណត់នៃបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។ កិច្ចការនេះតម្រូវឱ្យមន្ត្រីបោះឆ្នោតដែលត្រូវបានតែងតាំងនោះសួរទៅអ្នកបោះឆ្នោតអំពីគណបក្សនយោបាយណាមួយដែលគាត់ចង់បោះឆ្នោតឱ្យ និងត្រូវគូសលើសន្លឹកឆ្នោតក្នុងនាមអ្នកបោះឆ្នោតរូបនោះ ហើយត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតនេះ។

គ- មន្ត្រីបោះឆ្នោតត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធាន គ.ក.ប នូវសកម្មភាពរបស់បុគ្គលណាម្នាក់ដែលធ្វើឱ្យប៉ះពាល់ដល់ការសម្ងាត់នៃការបោះឆ្នោត។

ឃ- នៅការិយាល័យរាប់សន្លឹកឆ្នោត មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយ ត្រូវអនុវត្តការកិច្ចជាក់លាក់របស់ខ្លួនដែលបានកំណត់នៅក្នុងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ដើម្បីធានាថាសន្លឹកឆ្នោតទាំងអស់ត្រូវតែមានសុវត្ថិភាព ត្រឹមត្រូវ និងគ្រប់ចំនួន។

៥.៣.៣ ទំនាក់ទំនងជាមួយគណបក្សនយោបាយ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត

ក- សកម្មភាព និងទំនាក់ទំនងរបស់មន្ត្រីបោះឆ្នោតជាមួយគណបក្សនយោបាយ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវបានកំណត់ដូចខាងក្រោម៖

- គ្រប់ពេលវេលាមន្ត្រីបោះឆ្នោតម្នាក់ៗត្រូវមានទំនាក់ទំនងជិតស្និទ្ធ និងមិនលម្អៀងជាមួយបេក្ខជន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតទាំងអស់។ មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវទទួលស្គាល់តួនាទីត្រឹមត្រូវតាមច្បាប់របស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែល៖
  - មានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនេះ ដើម្បីសង្កេតមើលដំណើរការបោះឆ្នោត
  - ធ្វើការតវ៉ា ឬដំទាស់ ឬធ្វើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងដំទាស់អំពីភាពមិនប្រក្រតីនៃការអនុវត្តច្បាប់ បទបញ្ជា និងនីតិវិធី ទៅមន្ត្រីបោះឆ្នោតដែលមានសមត្ថកិច្ច (សម្រាប់ភ្នាក់ងារគណបក្សនយោបាយតែប៉ុណ្ណោះ)។
- មន្ត្រីបោះឆ្នោតដែលមានភារកិច្ចទទួល និងដោះស្រាយពាក្យបណ្តឹងត្រូវយកចិត្តទុកដាក់អនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។

ខ- មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវដឹងថា៖

- គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍បោះឆ្នោតមិនមានសិទ្ធិផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬរំខាន ឬជ្រៀតជ្រែកក្នុងដំណើរការបោះឆ្នោតឡើយ
- មិនត្រូវប្រតិបត្តិតាមការណែនាំណាមួយរបស់គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍បោះឆ្នោតណាម្នាក់ឡើយ។

៦- បម្រាមចំពោះមន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតត្រូវប្រតិបត្តិឱ្យបានម៉ឺងម៉ាត់នូវបម្រាមដូចខាងក្រោម លើកលែងតែការអនុវត្តការកិច្ចរបស់ខ្លួន។

៦.១ ការបំភិតបំភ័យ ការធ្វើឱ្យខូចខាត និងការរាំងស្ទះ

មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវជៀសវាងសកម្មភាពពាក់ព័ន្ធទៅនឹង៖

- ការគំរាមកំហែង
- អំពើហិង្សា ការបង្ខិតបង្ខំ ឬការបំភិតបំភ័យដល់បុគ្គលណាម្នាក់ ឬប្រឆាំងទៅនឹងបុគ្គលណាម្នាក់
- ការបដិសេធមិនចុះឈ្មោះបោះឆ្នោតឱ្យអ្នកដែលមានសិទ្ធិគ្រប់គ្រាន់ចុះឈ្មោះបោះឆ្នោត
- ការចុះឈ្មោះបោះឆ្នោតឱ្យអ្នកដែលគ្មានសិទ្ធិគ្រប់គ្រាន់ ឬបញ្ចូលឈ្មោះអ្នកដែលគ្មានសិទ្ធិពេញលេញចូលក្នុងបញ្ជីបោះឆ្នោតដោយផ្ទាល់ ឬដោយប្រយោល
- ការអនុញ្ញាតឱ្យអ្នកគ្មានសិទ្ធិគ្រប់គ្រាន់ធ្វើការបោះឆ្នោត ឬអនុញ្ញាតឱ្យអ្នកដែលមិនបានចុះឈ្មោះបោះឆ្នោតធ្វើការបោះឆ្នោតដោយផ្ទាល់ ឬដោយប្រយោល
- ការធ្វើឱ្យខូចខាតដល់បរិវេណខាងក្នុង បរិវេណខាងក្រៅ និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ
- ការធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញសម្ភារ បរិក្ខារ ឬឯកសារបម្រើការបោះឆ្នោតណាមួយ
- ការបង្អាក់ ឬការរារាំងអ្នកមានសិទ្ធិណាម្នាក់មិនឱ្យទៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការផ្សព្វផ្សាយព័ត៌មានសម្ងាត់ទាក់ទងនឹងការងាររបស់ខ្លួនទៅកាន់តតិយជនដោយគ្មានការអនុញ្ញាត។

៦.២ ការជក់បារី និងការបង្ហាររភ្លើង អគ្គិភ័យ

មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប លជ.ខប ឬ លគជ.ខប គយ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

- ការគូសឈើគូស កេះដៃកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.៣ ការហូបចុក

មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវបរិភោគអាហារនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតឡើយ លើកលែងតែមានការអនុញ្ញាតពីមន្ត្រីថ្នាក់លើរបស់ខ្លួន។

៦.៤ ការប្រើប្រាស់គ្រឿងស្រវឹង និងសារធាតុញៀន

មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវមានភេសជ្ជៈដែលមានផ្ទុកជាតិស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀនណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ ឬនៅក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យទាំងនេះឡើយ។

៦.៥ អាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ

មន្ត្រីបោះឆ្នោតគ្រប់រូបមិនត្រូវយកអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលក្នុងទីស្តីការ គ.ជ.ប លធ.ខប ឬ លគធ.ខប គយ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតឡើយ។

៦.៦ ល្បែង

មន្ត្រីបោះឆ្នោតគ្រប់រូបមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងកន្លែងធ្វើការឡើយ។

៦.៧ ភាពលម្អៀងចំពោះគណបក្សនយោបាយ

មន្ត្រីបោះឆ្នោតម្នាក់ៗ៖

ក- មិនត្រូវលម្អៀងជាដាច់ខាត និងមិនត្រូវធ្វើសកម្មភាពសម្តែងអាកប្បកិរិយា ឥរិយាបថ ឬពោលពាក្យសម្តី ឬថ្លែងសុន្ទរកថា ឬថ្លែងការណ៍អ្វីមួយដែលបង្ហាញឱ្យឃើញនូវភាពលម្អៀង ឬការចូលចិត្ត ឬមិនចូលចិត្តចំពោះគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយណាមួយ ក្នុងពេលអនុវត្តការកិច្ចរបស់ខ្លួន។

ខ- មិនត្រូវធ្វើអ្វីមួយដែលជះឥទ្ធិពលទៅលើអ្នកបោះឆ្នោតដែលអាចធ្វើឱ្យមានការបោះឆ្នោតគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

គ- មិនត្រូវពាក់ ឬបង្ហាញនូវផ្លាកសញ្ញាណាមួយ និមិត្តសញ្ញា ឬពាក្យស្លោកជាប់នឹងសម្លៀកបំពាក់ដែលមានជាប់ពាក់ព័ន្ធទៅនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយឡើយ។

ឃ- មិនត្រូវរើសអើងគ្រប់ទម្រង់ ដូចជាការរើសអើងពូជសាសន៍ តេទ កុលសម្ព័ន្ធ ឋានៈ ឬសាសនាដែលពាក់ព័ន្ធនឹងការបោះឆ្នោត និងសកម្មភាពនយោបាយផ្សេងៗ។

៦.៨ បម្រាមនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវចងចាំបម្រាមចាំបាច់ពិសេសដូចខាងក្រោម៖

ក- ការប៉ះពាល់សម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត

- មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតមិនត្រូវប៉ះពាល់សៀវភៅសន្លឹកឆ្នោត សន្លឹកឆ្នោត បញ្ជីបោះឆ្នោត សោឃ្លុំ ត្រាសម្ងាត់ ត្រា គ.ក.ប ទម្រង់បែបបទ ឬសម្ភារបោះឆ្នោតផ្សេងទៀត ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ ទោះបីជាភារកិច្ចរបស់ខ្លួនក៏ដោយ
- ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើមិនត្រូវ៖
  - ស្រាយចំណង ឬបើកសោឃ្លុំ សៀវភៅសន្លឹកឆ្នោតហិបឆ្នោតកញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុកសម្ភារបោះឆ្នោត
  - យកចេញនូវសៀវភៅសន្លឹកឆ្នោត ហិបឆ្នោត ឬកញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុកសម្ភារបោះឆ្នោតនៅខាងក្នុង
  - យកសម្ភារបោះឆ្នោតណាមួយចេញពីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬជួយឱ្យអ្នកណាម្នាក់ផ្សេងទៀតឱ្យធ្វើដូច្នេះ
  - គូសសម្គាល់ ឬសរសេរលើសម្ភារបោះឆ្នោតណាមួយ ឬលុបគំនូស ឬលុបសំណេរណាមួយចេញពីសម្ភារបោះឆ្នោតណាមួយ។

ខ- ការប៉ះពាល់សន្លឹកឆ្នោត និងហិបឆ្នោត

- ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ មន្ត្រីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយមិនត្រូវ៖
  - ផ្តល់សន្លឹកឆ្នោតទៅជនណាម្នាក់
  - បោះត្រាសម្ងាត់ផ្លូវការនៅលើសន្លឹកឆ្នោតណាមួយ
  - ផ្លាស់ប្តូរ ឬបំផ្លាញត្រាសម្ងាត់ផ្លូវការនៅលើសន្លឹកឆ្នោត
  - ផ្លាស់ប្តូរ ឬបំផ្លាញសន្លឹកឆ្នោត
  - គូសនៅលើសន្លឹកឆ្នោត
  - ចាប់យក ឬប៉ះពាល់ហិបឆ្នោត
  - ដាក់សន្លឹកឆ្នោត ឬរបស់ផ្សេងទៅក្នុងហិបឆ្នោត
  - យកសន្លឹកឆ្នោតចេញពីហិបឆ្នោតឡើយ។

គ- ការរក្សាការសម្ងាត់នៃការបោះឆ្នោត

- មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោតមិនត្រូវព្យាយាម៖
  - ចង់ដឹងពីបំណងដែលអ្នកបោះឆ្នោតចង់បោះឆ្នោត ឬបានបោះឆ្នោត
  - ធ្វើឱ្យអ្នកបោះឆ្នោតបង្ហាញ ឬប្រាប់ឱ្យដឹងអំពីរបៀបដែលអ្នកបោះឆ្នោតបានបោះឆ្នោត
  - គូសសញ្ញាសម្គាល់ណាមួយនៅលើសន្លឹកឆ្នោត ដែលអាចធ្វើឱ្យគេស្គាល់ដល់អត្តសញ្ញាណនៃអ្នកបោះឆ្នោត
  - ប្រើឥទ្ធិពលទៅលើ ឬជួយអ្នកណាម្នាក់ដើម្បីបានបោះឆ្នោតដោយដឹងថា អ្នកនោះមិនមានសិទ្ធិបោះឆ្នោត
  - ដើរទៅជិតធ្វើជាសញ្ញា ឬនិយាយទៅកាន់អ្នកបោះឆ្នោតណាម្នាក់ដោយគ្មានការកិច្ចអនុញ្ញាត ចាប់ពីពេលដែលអ្នកបោះឆ្នោតដើរចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោតរហូតដល់អ្នកបោះឆ្នោតចាកចេញពីបរិវេណខាងក្នុងការិយាល័យបោះឆ្នោត
  - ដើរចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោតដោយគ្មានការកិច្ច។
- មន្ត្រីបោះឆ្នោតម្នាក់ៗនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោតដែលគ្មានការកិច្ចអនុញ្ញាតឱ្យធ្វើមិនត្រូវព្យាយាមលាតត្រដាង៖
  - សន្លឹកឆ្នោតណាមួយដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ
  - លទ្ធផលនៃការត្រួតពិនិត្យ និងការគណនាណាមួយធ្វើឡើងដោយមន្ត្រីបោះឆ្នោត
  - ចំនួនសន្លឹកឆ្នោតមិនបានការដែលកំពុងមានវិវាទ
  - ចំនួនសំឡេងឆ្នោតដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ។

ឃ- ការទទួលសំណូក ឬរង្វាន់

- មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវទទួលយកទោះដោយផ្ទាល់ ឬដោយប្រយោលក្តីនូវចំនួនទឹកប្រាក់ រង្វាន់ ឬសម្ភារផ្សេងៗទៀត ឬការសន្យាណាមួយពីគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍បោះឆ្នោតណាម្នាក់ឡើយ។

ង- វិសមិតភាពការងារ

- មន្ត្រីបោះឆ្នោតម្នាក់ៗនៅក្នុងអំឡុងពេលបោះឆ្នោតមិនត្រូវ៖
  - មានឈ្មោះជាបេក្ខជននៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ

- ជាកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសជាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ។

៧- សំណូមពរ និងការអនុវត្ត

ក្នុងការបំពេញតួនាទី និងការកិច្ចរបស់ខ្លួន មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

៧.១- សំណូមពរ

- ក្នុងការងាររៀបចំការបោះឆ្នោត មន្ត្រីបោះឆ្នោតទាំងអស់ត្រូវប្រតិបត្តិតាមក្រមសីលធម៌នេះ នៅពេលដែលមន្ត្រី បុគ្គលិកទាំងនោះកំពុងស្ថិតនៅទីកន្លែងបំពេញការងាររបស់ខ្លួន ឬកំពុងបំពេញការកិច្ចរបស់ខ្លួន
- មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវចូលរួមរៀនសូត្រគ្រប់វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាទាំងអស់តាមការអញ្ជើញរបស់ គ.ជ.ប។

៧.២- ការអនុវត្ត

ក្រមសីលធម៌នេះមានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោតដែលរៀបចំឡើងដោយ គ.ជ.ប។

សម្រង់ទោសប្បញ្ញត្តិ

ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា១៤០.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម៖

- ចេញបង្គាន់ដៃបញ្ជាក់ការចុះឈ្មោះប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់ អាចបោះឆ្នោតបាន។

មាត្រា១៤៥.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀលទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះសមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត។

មាត្រា១៤៦.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ចូលក្នុងតំបន់ហាមឃាត់ និងក្នុងអំឡុងពេលដូចបានបញ្ញត្តក្នុងមាត្រា៥២ និងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោតដូចបានបញ្ញត្តក្នុងមាត្រា១១២ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៥០.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀលឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្កាប់ បញ្ឆាលួងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១0 (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៥១.-

ត្រូវផាកពិន័យជាប្រាក់ពី ១0.000.000 (ដប់លាន) រៀល ទៅ ២៥.000.000 (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់ការពារសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១0 (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

ខ- សម្រាប់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា១៦៩.-

ត្រូវដាក់ពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម៖

- ចេញបង្គាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់ អាចបោះឆ្នោតបាន។

មាត្រា១៧៤.-

ត្រូវដាក់ពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះសមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិច ដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត។

មាត្រា១៧៥.-

ត្រូវដាក់ពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ដោយបំពានលើបញ្ញត្តិនៃមាត្រា២៨ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៧៧.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀលឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោត បង្កាប់បញ្ជាលួងលោម បោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១0 (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៧៨.-

ត្រូវផាកពិន័យជាប្រាក់ពី ១0.000.000 (ដប់លាន) រៀល ទៅ ២៥.000.000 (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះជនណាដោយចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់ក្បាសុវត្ថិភាពហិបឆ្នោតឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១0 (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

ឧបសម្ព័ន្ធទី២
ក្រមសីលធម៌
សម្រាប់
គណបក្សនយោបាយ បេក្ខជន
និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត

១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់ សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អនាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អនុវត្តក្នុងដំណើរការបោះឆ្នោតតាមសិទ្ធិ និងភារកិច្ចរបស់ខ្លួនតាមការកំណត់នៃច្បាប់។

២- គោលបំណង

ក្រមសីលធម៌នេះមានគោលបំណងកំណត់វិធានសំខាន់ៗសម្រាប់គណបក្សនយោបាយ បេក្ខជនដែលឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយយកចិត្តទុកដាក់អនុវត្តតួនាទី និងការកិច្ចរបស់ខ្លួនដើម្បីឱ្យ៖

- ការបោះឆ្នោតប្រព្រឹត្តទៅស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត
- ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ និងគ្មានការបំភិតបំភ័យ។

៣- វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះគណបក្សនយោបាយ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយដែលបានចុះឈ្មោះ ហើយត្រូវបានទទួលស្គាល់ដោយ គ.ជ.ប។

៤- និយមន័យ

វាក្យសព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **គណបក្សនយោបាយ** សំដៅដល់គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ហើយត្រូវបានប្រកាសទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃ។

៤.២- **គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត** សំដៅដល់គណបក្សនយោបាយដែលត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ និងបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតនៅ គ.ជ.ប ឬនៅគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ហើយត្រូវបានទទួលស្គាល់ជាផ្លូវការ។

៤.៣- **បេក្ខជន** សំដៅដល់អ្នកដែលត្រូវបានគណបក្សនយោបាយតែងតាំងឱ្យឈរឈ្មោះជាបេក្ខជនក្នុងបញ្ជីបេក្ខជនតាមមណ្ឌលបោះឆ្នោត និងត្រូវបានទទួលស្គាល់ជាផ្លូវការ។

៤.៤- **ភ្នាក់ងារគណបក្សនយោបាយ** សំដៅដល់ភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងដែលជាតំណាងរបស់គណបក្សនយោបាយ ដើម្បីចូលរួមសង្កេតការណ៍មើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត និងត្រូវបានទទួលស្គាល់ជាផ្លូវការ។

៤.៥- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៦- **ដំណើរការបោះឆ្នោត** សំដៅដល់ៈ

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥- សិទ្ធិ តារកិច្ច និងការទទួលខុសត្រូវរបស់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយមានសិទ្ធិសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិពេញលេញ ស្មើភាពចូលរួមប្រកបដោយការទទួលខុសត្រូវក្នុងដំណើរការបោះឆ្នោត ជាអាទិ៍ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ការប្តឹងជំទាស់ ឬប្តឹងតវ៉ា និងការទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត។

បេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងកងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយសង្កេតការណ៍មើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ។

៥.១- សិទ្ធិ និងតារកិច្ចរបស់គណបក្សនយោបាយ និងបេក្ខជន

គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិ និងការកិច្ចដូចខាងក្រោមៈ

៥.១.១ គណបក្សនយោបាយមានសិទ្ធិៈ

- ប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ តវ៉ាចំពោះការសម្រេចរបស់ គ.ជ.ប បដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ប្តឹងតវ៉ាទៅ គ.ជ.ប ចំពោះការសម្រេចរបស់ គធ.ខប បដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

- ប្តឹងតវ៉ាទៅ គធ.ខប និងប្តឹងបន្តទៅ គ.ជ.ប ចំពោះការសម្រេចរបស់ គយ.សប បដិសេធការសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៥.១.២ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានសិទ្ធិលើកស្លាកគណបក្សនយោបាយនៅទីសាធារណៈដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ។

៥.១.៣ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនមានសិទ្ធិសុំជួលរោងមហោស្រពមណ្ឌលកីឡា ឧទ្យានសាធារណៈ ឬទីធ្លាសាធារណៈ ឬសាលសាធារណៈ ពីអ្នកគ្រប់គ្រងទីកន្លែងនោះដើម្បីប្រើប្រាស់សម្រាប់បម្រើការឃោសនាបោះឆ្នោតដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់មុនក្រោយ។

៥.១.៤ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនមានសិទ្ធិធ្វើសកម្មភាពឃោសនាបោះឆ្នោតនៅលើទីធ្លាឯកជន ឬសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ តែត្រូវជូនដំណឹងទៅគណៈកម្មការរៀបចំការបោះឆ្នោតពាក់ព័ន្ធ។

៥.១.៥ ក្នុងការឃោសនាបោះឆ្នោត គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោត។

៥.១.៦ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ត្រូវទទួលខុសត្រូវផ្នែកលើខ្លឹមសារ និងសកម្មភាពឃោសនាបោះឆ្នោតរបស់ខ្លួន។

៥.១.៧ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប អាជ្ញាធរដែនដី អ្នកសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

៥.១.៨ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ត្រូវយកចិត្តទុកដាក់គោរពឱ្យបានល្អនូវគ្រប់កម្មវិធីឃោសនាទាំងអស់ ដែលសម្របសម្រួលដោយអាជ្ញាធរដែនដី។

៥.១.៩ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់មានសិទ្ធិធ្វើសកម្មភាពឃោសនាបោះឆ្នោតដោយសេរីក្នុងទីស្នាក់ការគណបក្សនយោបាយរបស់ខ្លួនទូទាំងប្រទេស។

៥.១.១០ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានសិទ្ធិសុំផ្លាស់ប្តូរភ្នាក់ងារពេញសិទ្ធិ ឬ/និងភ្នាក់ងារបម្រុងរបស់ខ្លួនទៅតាមកាលកំណត់ចុងក្រោយរបស់ គ.ជ.ប។

៥.១.១១ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់មានសិទ្ធិប្តឹងជំទាស់ ឬប្តឹងតវ៉ាទៅតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញ និងមានភស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងដំណើរការបោះឆ្នោត។

៥.១.១២ គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅ គ.ជ.ប ឬទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្ទាល់ក៏បាន ដោយបញ្ជាក់ពីភាពមិនប្រក្រតីនៃគណៈកម្មការ ឬសមាជិកគណៈកម្មការដែលបានធ្វើខុសពីកាលបរិច្ឆេទ ដែលធ្វើខុសពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោត បណ្តោះអាសន្នក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ។

៥.១.១៣ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់មានសិទ្ធិស្មើភាពគ្នាក្នុងការទទួលបានការការពារសន្តិសុខ សុវត្ថិភាព ក្នុងអំឡុងពេលធ្វើសកម្មភាពនានាក្នុងដំណើរការបោះឆ្នោត។

៥.១.១៤ គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវបណ្ណប្រកាស ឬបណ្ណបិទផ្សាយ បដា ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត។

៥.២- សិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោតភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

៥.២.១ មានវត្តមាននៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដែលខ្លួនបានទទួលការអនុញ្ញាតតាមទីកន្លែង និងពេលវេលាដែលបានកំណត់ដោយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប និងត្រូវចុះបញ្ជីវត្តមាន។

៥.២.២ ចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតបានតែម្នាក់ប៉ុណ្ណោះ។ ភ្នាក់ងារបម្រុងត្រូវរង់ចាំនៅក្រៅការិយាល័យ ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីមានការផ្លាស់ប្តូរ។

៥.២.៣ តវ៉ា ឬ/និងដំទាស់រាល់ការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធីដែលខ្លួនបានឃើញផ្ទាល់។ ការដំទាស់ត្រូវធ្វើឡើងទៅប្រធាន ក.ច.ប ប្រធាន គ.ក.ប ប្រធាន គ.ក.រ។ នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ការដំទាស់អាចលើកឡើងដោយផ្ទាល់មាត់ ឬ/និងទៅតាមទម្រង់បែបបទរបស់ គ.ជ.ប។ នៅក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត ប្រសិនបើភ្នាក់ងារគណបក្សនៅតែតវ៉ា ឬដំទាស់ ប្រធាន ក.ច.ប អាចអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយនោះកត់ត្រា ឬថតយកទិន្នន័យ ឬឯកសារដែលជាកម្មវត្ថុនៃពាក្យបណ្តឹង។

៥.២.៤ ចុះហត្ថលេខាលើរបាយការណ៍ ឬកំណត់ហេតុផ្សេងៗដែលកំណត់ដោយ គ.ជ.ប។

៥.២.៥ ចុះហត្ថលេខា ឬផ្តិតមេដៃនៅលើកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។

៥.២.៦ ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិទទួលបានកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។

៥.២.៧ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប អាជ្ញាធរដែនដី អ្នកសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

៥.២.៨ ប្តឹងដំទាស់ ឬប្តឹងតវ៉ាស្របតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញថាមានកស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងដំណើរការបោះឆ្នោត។

៥.២.៩ ទទួលបានដោយស្មើភាពគ្នាក្នុងការការពារសន្តិសុខ សុវត្ថិភាពក្នុងអំឡុងពេលធ្វើសកម្មភាពនានាក្នុងដំណើរការបោះឆ្នោត។

៥.២.១០ ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិកត់ត្រា និងថតយករូបភាពទូទៅនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដោយមិនត្រូវរំខាន ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការចុះឈ្មោះបោះឆ្នោត ឬ/និងរំលោភលើការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតឡើយ។

៥.៣- ការឧទ្ធរណ៍ខុសត្រូវរបស់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជនឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះ។

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលបេក្ខជន និងភ្នាក់ងារគណបក្សនយោបាយរបស់ខ្លួនឱ្យមានការយល់ដឹងត្រឹមត្រូវអំពីការបោះឆ្នោត អំពីតួនាទី និងភារកិច្ចរបស់ខ្លួនចូលរួមក្នុងការបោះឆ្នោត។

៦- បម្រាមចំពោះគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន ភ្នាក់ងារគណបក្សនយោបាយមិនត្រូវ៖

៦.១ ប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.២ ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀត។

៦.៣ និយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរដោលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន អ្នកគាំទ្រ ឬលើបុគ្គលណាមួយ។

៦.៤ រិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ។

៦.៥ ធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ។

៦.៦ ផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជាវង្វាន់លើកទឹកចិត្ត ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោតក្នុងរយៈពេលឃោសនាបោះឆ្នោត ថ្ងៃស និងថ្ងៃបោះឆ្នោត។

៦.៧ ធ្វើសកម្មភាពឃោសនាបោះឆ្នោតនៅចន្លោះពីម៉ោង ១០:០០ (ដប់) យប់ ដល់ម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក។

៦.៨ ធ្វើសកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ចាប់ពីម៉ោង ១២:០០ (ដប់ពីរ) ថ្ងៃត្រង់ រហូតដល់ម៉ោង ២:០០ (ពីរ) រសៀល។

៦.៩ ជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.១០ រារាំងដល់សកម្មភាពរបស់ភ្នាក់ងារគណបក្សនយោបាយដទៃទៀត។

៦.១១ ប្រើកម្លាំង ឬអំពើហិង្សាណាមួយ ដើម្បីរារាំងអ្នកមានសិទ្ធិបោះឆ្នោតមិនឱ្យទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន។

៦.១២ រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់របស់ គ.ជ.ប។

៦.១៣ ប្រើកម្លាំង អំពើហិង្សា អំពើរំលោភ បំភិតបំភ័យ ឬប្រើពាក្យសម្តីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាច ការគាន់ច្រឡំធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

៦.១៤ បង្កការរំខានផ្សេងៗ ដែលធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបាន។

៦.១៥ បង្កការរំខានដល់ការងាររាប់សន្លឹកឆ្នោត។

៦.១៦ ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

៦.១៧ ទិញសន្លឹកឆ្នោត ដោយសម្ភារ ឬដោយប្រាក់កាស។

៦.១៨ បង្ហាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត។

៦.១៩ ធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬហែក ឬរបូតសោឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់សុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

៦.២០ ទាមទារ ឬចូលទៅក្នុងការិយាល័យ ដើម្បីពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតបន្ថែមលើភ្នាក់ងារគណបក្សនយោបាយដែលបានអនុញ្ញាតជាផ្លូវការរួចហើយ។

៦.២១ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត។

៦.២២ ជ្រៀតជ្រែកដល់ដំណើរការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀត ដែលទាក់ទងនឹងការងារបោះឆ្នោត។

៦.២៣ ញុះញង់ឱ្យមានការរើសអើងប្រកាន់បក្ខពួក កេទ ឋានៈក្នុងសង្គម សមាជិកនៃជាតិពន្ធុ ក្រុមជាតិពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ និងតាមគ្រប់រូបភាពទាំងអស់។

៦.២៤ រារាំង រំខាន ឬបង្កើតពាក្យចចាមអារ៉ាមនាំឱ្យមានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាពលរដ្ឋមិនឱ្យចូលរួមការប្រជុំ ការហែក្បួនណាមួយរបស់គណបក្ស ឬបេក្ខជនដទៃទៀត។

៦.២៥ ប្រើប្រាស់ភាសា ពាក្យសម្តីដែលស្តែងចេញពីការសេពសុរា ឬគ្រឿងញៀនជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំ បំភិតបំភ័យណាមួយ។

៦.២៦ ដាក់តាំង ឬបង្ហាញ ឬចែកចាយខិត្តបណ្ណ ដែលពិពណ៌នាអំពីការវាយប្រហារដោយពាក្យសម្តី ឬដោយអាវុធ។

៦.២៧ ប្រើភាសា ឬរូបភាពរំលោភបំពាន ខ្វះសីលធម៌ ដែលមានលក្ខណៈអុជអាល បង្កជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬជាងនេះទៀតបង្កឱ្យកើតមានអំពើហិង្សាតាមរយៈសេចក្តីថ្លែងការណ៍ សេចក្តីប្រកាស ខិត្តបណ្ណ រូបភាពបិទផ្សាយ និងសម្ភាររោសនាបោះឆ្នោតផ្សេងទៀត។

៦.២៨ ចាក់ផ្សាយព័ត៌មាន ឬការប្រើប្រាស់ឧបករណ៍បំពងសំឡេងតាមផ្លូវសាធារណៈណាមួយ ដែលមានសំឡេងខ្លាំងៗលុបលើសំឡេងរោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.២៩ ធ្វើសកម្មភាពរោសនាដោយឧបករណ៍បំពងសំឡេង នៅក្បែរមន្ទីរពេទ្យ ឬក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានា ក្នុងពេលម៉ោងសិស្សកំពុងសិក្សា។

៦.៣០ ប្រើប្រាស់ព្រះនាយាលក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រីព្រះវររាជមាតា ស្លាកសញ្ញា គ.ជ.ប ទៅប្រើប្រាស់ ដើម្បីរកសំឡេងឆ្នោត។

៦.៣១ ចម្លងយកសញ្ញាសម្គាល់របស់គណបក្សនយោបាយដទៃទៀតមកប្រើប្រាស់ បម្រើឱ្យផលប្រយោជន៍គណបក្សនយោបាយរបស់ខ្លួន។

៦.៣២ បិទបណ្ណ ខិត្តបណ្ណ រូបភាពរោសនា សេចក្តីថ្លែងការណ៍នយោបាយ ឬឯកសាររោសនាដទៃទៀតពីលើឯកសារផ្សេងៗរបស់អ្នកដទៃ ឬគណបក្សនយោបាយដទៃ។

៦.៣៣ បក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោលនូវបណ្ណបិទផ្សាយ ខិត្តបណ្ណ សេចក្តីប្រកាសនយោបាយ ឬឯកសាររោសនា ឬសេចក្តីណែនាំផ្សេងៗរបស់គណបក្សនយោបាយដទៃ ក្រសួង ស្ថាប័ននានា ឬអាជ្ញាធរដែនដី។

៦.៣៤ បិទបណ្ណផ្សព្វផ្សាយរូបភាពរោសនា សេចក្តីប្រកាសនយោបាយ ចងបដា ឬឯកសាររោសនាបោះឆ្នោតដទៃទៀតក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោតក្នុងចម្ងាយតិចជាង ១០០ (មួយរយ) ម៉ែត្រ លើកលែងតែទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ។

៦.៣៥ ចងបដា ឬរូបសញ្ញាឃោសនាណាមួយឆ្លងកាត់ផ្លូវសាធារណៈ។

៦.៣៦ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនារបស់គណបក្សនយោបាយមិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ។

៦.៣៧ ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដូចជារថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ផ្លាកសញ្ញារដ្ឋ រាជរដ្ឋាភិបាល នគរបាល ឬ ន.ប ខេមរភូមិន្ទ ឬ ខ.ម ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។

៦.៣៨ ផ្តល់វិភាគទាន ជូនសគុណ ឬផ្តល់រង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ដើម្បីទទួលបានសំឡេងឆ្នោត ទោះបីតាមមធ្យោបាយណាក៏ដោយក្នុងអំឡុងពេលឃោសនាបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត។

៦.៣៩ ប្រើប្រាស់តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិ ឥទ្ធិពល ឬសិទ្ធិអំណាចខាងមេបា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទម្លាប់ ដើម្បីបង្ខំ ឬគំរាមកំហែងក្នុងគោលបំណងទទួលបានការគាំទ្រ។

៦.៤០ ក្លែងបន្លំ បំផ្លាញ ឬគូសសញ្ញាសម្គាល់ណាមួយលើសន្លឹកឆ្នោត។

៦.៤១ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗ នៅក្នុងការិយាល័យបោះឆ្នោត។

៦.៤២ នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៦.៤៣ ការដក់បារី និងការបង្ករភ្លើង អគ្គិភ័យ

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយត្រូវជៀសវាង៖

- ការដក់បារីនៅក្នុងទីស្តីការ គ.ជ.ប លជ.ខប ឬ លគជ.ខប គយ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.៤៤ ល្បែង

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប លជ.ខប ឬ លគជ.ខប គយ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៧- សំណូមពរ និងការអនុវត្ត

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

៧.១- សំណូមពរ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយត្រូវគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះឱ្យបានខ្ជាប់ខ្ជួន។

៧.២- ការអនុវត្ត

ក្រមសីលធម៌នេះមានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

សម្រង់ទោសប្បញ្ញត្តិ

ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា១៤២.- ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោត ប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៤៣.- ថ្មី

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌជាទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៤២ថ្មី ខាងលើនេះ។

បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសដូចបានចែងក្នុងមាត្រា១៤២ថ្មី ខាងលើ អាចត្រូវបានដកសិទ្ធិមិនឱ្យចូលរួមការបោះឆ្នោតសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

មាត្រា១៥០.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១០.000.000 (ដប់លាន) រៀលឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្គាប់ បញ្ជាលួងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្សេងក្រៅពីឆន្ទៈរបស់ជននោះ។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៥១.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.000.000 (ដប់លាន) រៀលទៅ២៥.000.000 (ម្ភៃប្រាំលាន) រៀលឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដោយមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៥២.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១០.000.000 (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថដាសាធារណៈ

ចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលជនប្រព្រឹត្តអំពើល្មើសនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

មាត្រា១៥៣.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀលទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា១៥២ ខាងលើនេះ។

មាត្រា១៥៥.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា៧២ នៃច្បាប់នេះ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

មាត្រា១៥៦.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀលទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា១៥៥ ខាងលើនេះ។

មាត្រា១៥៧.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា៧២ នៃច្បាប់នេះ។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៦០.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

មាត្រា១៦២.-

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ។

អង្គការ ឬអ្នកតំណាងរបស់គណបក្សនយោបាយសំដៅដល់អង្គការ ឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ។

ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា១៧១.- ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។

- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការគាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៧២.- ថ្មី

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៧១ថ្មី ខាងលើនេះ។

បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសដូចបានចែងក្នុងមាត្រា១៧១ថ្មី ខាងលើ អាចត្រូវបានដកសិទ្ធិមិនឱ្យចូលរួមការបោះឆ្នោតសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

មាត្រា១៧៧.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្គាប់ បញ្ជាលួងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៧៨.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀលទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៨១.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលជនប្រព្រឹត្តអំពើល្មើសនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

មាត្រា១៨២.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀលទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា១៨១ ខាងលើនេះ។

មាត្រា១៨៤.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា៧០ នៃច្បាប់នេះ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

មាត្រា១៨៥.-

ត្រូវផាកពិន័យជាប្រាក់ពី ១0.000.000 (ដប់លាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា១៨៤ ខាងលើនេះ។

មាត្រា១៨៨.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.000.000 (មួយលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

មាត្រា១៩0.-

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ។

អង្គការ ឬអ្នកតំណាងរបស់គណបក្សនយោបាយសំដៅដល់អង្គការ ឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ។

ឧបសម្ព័ន្ធទី៣
ក្រមសីលធម៌
សម្រាប់
អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត

១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី របស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់ សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ បោះឆ្នោតជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និង អន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អនាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌ បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿ ទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់អ្នកសង្កេតការណ៍ បោះឆ្នោតជាតិ និងអន្តរជាតិ អនុវត្តក្នុងការសង្កេតមើលដំណើរការបោះឆ្នោតក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងតម្លាភាពនៃការបោះឆ្នោត។

២- គោលបំណង

ក្រមសីលធម៌នេះមានគោលបំណងកំណត់វិធានសំខាន់ៗសម្រាប់ឱ្យសមាគម អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសង្កេតការណ៍បោះឆ្នោតអនុវត្តក្នុងការបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយជំហរអព្យាក្រឹត មិនលម្អៀង ដើម្បីធានាឱ្យ៖

- កិច្ចសង្កេតការណ៍បោះឆ្នោតត្រូវធ្វើឡើងដោយសុចរិត និងតម្លាភាព
- អ្នកសង្កេតការណ៍បោះឆ្នោតបំពេញការងារដោយពុំមានការជ្រៀតជ្រែក។

៣- វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការមិនមែនរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និងអង្គការអន្តរជាតិ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលត្រូវបាន គ.ជ.ប អនុញ្ញាតជាផ្លូវការឱ្យសង្កេតការណ៍បោះឆ្នោត។

៤- និយមន័យ

វាក្យសព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **អ្នកសង្កេតការណ៍បោះឆ្នោតជាតិ** គឺជាជនជាតិខ្មែរ ឬជនបរទេសដែលជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ និងអនុញ្ញាតដោយ គ.ជ.ប។

៤.២- **អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ** គឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានាដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនឹងអនុញ្ញាតដោយ គ.ជ.ប។

៤.៣- **អ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័ត** សំដៅដល់ថ្នាក់ដឹកនាំ ឬមន្ត្រីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលអង្គភាពសាមីស្នើសុំ និងត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការបោះឆ្នោតទូទាំងប្រទេស។

៤.៤- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៥- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោត

បន្ទាប់ពី គ.ជ.ប បានទទួលស្គាល់ជាផ្លូវការហើយ អ្នកសង្កេតការណ៍បោះឆ្នោតទាំងឡាយមានសិទ្ធិធ្វើសកម្មភាពសង្កេតការណ៍បោះឆ្នោត ដោយឯករាជ្យពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង គ.ជ.ប ព្រមទាំងទទួលនូវកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងពីអាជ្ញាធរដែនដី គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោតមានដូចខាងក្រោម៖

៥.១- សិទ្ធិរបស់អ្នកសង្កេតការណ៍បោះឆ្នោត

នៅពេលត្រូវបានទទួលស្គាល់ជាផ្លូវការ និងទទួលបានបណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតរួចហើយ អ្នកសង្កេតការណ៍បោះឆ្នោតទាំងឡាយមានសិទ្ធិដូចខាងក្រោម៖

- ៥.១.១ អ្នកសង្កេតការណ៍បោះឆ្នោតជាតិអាចធ្វើដំណើរសង្កេតការណ៍ក្នុងរាជធានី ខេត្ត ដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួនបានស្នើសុំប៉ុណ្ណោះ លើកលែងតែអ្នកសង្កេតការណ៍បោះឆ្នោតជាតិចល័តដែលត្រូវបានអនុញ្ញាត និងផ្តល់បណ្ណសម្គាល់ខ្លួនដោយ គ.ជ.ប។
- ៥.១.២ អ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិអាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ។
- ៥.១.៣ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ អ្នកសង្កេតការណ៍បោះឆ្នោតត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោត និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីជួយដោះស្រាយទាន់ពេលវេលា។
- ៥.១.៤ អមដំណើរដោយក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) គណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប) លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) និង គ.ជ.ប នៅរាល់ពេលដឹកជញ្ជូនសម្ភារបរិក្ខារចុះឈ្មោះបោះឆ្នោត ហិបឆ្នោត និងសម្ភារបោះឆ្នោត។
- ៥.១.៥ សង្កេតការណ៍នូវរាល់សកម្មភាពរបស់ លធ.ខប ក.ច.ប ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ឬ គ.ក.ប ឬ គឃ.សប ឬ គធ.ខប និង គ.ជ.ប នៅមុនពេល ក្នុងពេល និងក្រោយពេលចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត តាមប្រតិទិនកំណត់ដោយ គ.ជ.ប។
- ៥.១.៦ ចេញ ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដោយមិនត្រូវបង្កការរំខាន។
- ៥.១.៧ ជួប ឬនិយាយ ឬលើកសំណួរជាមួយបេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោតនៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ហើយកម្មវត្ថុនៃការជជែកនោះមិនទាក់ទងនឹងការគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

៥.២- តារកិច្ចរបស់អ្នកសង្កេតការណ៍បោះឆ្នោត

អ្នកសង្កេតការណ៍បោះឆ្នោតទាំងឡាយមានភារកិច្ចដូចខាងក្រោម៖

៥.២.១- ត្រូវគោរពច្បាប់ដែលមានជាធរមាននៅព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលស្គាល់ និងគោរពអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។

៥.២.២ ត្រូវយល់ដឹងពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។ ក្នុងករណីមានការរំលោភច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី ត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវ ព្រមទាំងកស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន។

៥.២.៣ ត្រូវមានជំហរអព្យាក្រឹត និងមិនត្រូវប្រកាន់បក្ខពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេឃើញតាមរយៈឯកសណ្ឋានពណ៌ ឬវត្ថុដទៃទៀត ដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

៥.២.៤ រក្សាការសម្ងាត់នៃការបោះឆ្នោត។

៥.២.៥ ត្រូវបង្ហាញកស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចដែលបានសាកសួរខ្លួន ហើយត្រូវពាក់បណ្ណសម្គាល់ខ្លួនដែលត្រូវបានសម្រេចទទួលស្គាល់ និងចេញឱ្យដោយ លធ.ខប ឬ គធ.ខប ឬ គ.ជ.ប។

៥.២.៦ ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និងនីតិវិធី ដែលបានកំណត់ដោយ គ.ជ.ប និងការណែនាំរបស់មន្ត្រីបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោម ហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការបោះឆ្នោត ក្នុងអំឡុងពេលចុះសង្កេតការណ៍នៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ។

៥.២.៧ ធ្វើរបាយការណ៍ស្តីពីការរកឃើញ ការកត់សម្គាល់ និងសេចក្តីសន្និដ្ឋានរបស់ខ្លួនឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ ឬអង្គការរបស់ខ្លួន។

៥.២.៨ ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធី ដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងអាចធ្វើរបាយការណ៍អំពីបញ្ហាធ្ងន់ធ្ងរនានាជាបន្ទាន់ជូនគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងត្រូវជូនរបាយការណ៍នេះ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ផង។

៥.២.៩ ត្រូវគោរពតាមការកំណត់របស់ប្រធាន ក.ច.ប ឬ គ.ក.ប/គ.ក.រ ដែលតម្រូវឱ្យផ្លាស់ប្តូរគ្នាចូលសង្កេតការណ៍ម្តង ៤ (បួន) នាក់ ក្នុងករណីមានអ្នកសង្កេតការណ៍បោះឆ្នោតច្រើនលើសពី ៤ (បួន) នាក់ សម្រាប់ការិយាល័យមួយ។

៥.៣- ការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោត

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬ/និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនទៅតាមច្បាប់ជាធរមាន។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬ/និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវទទួលបន្ទុកចំណាយរបស់ខ្លួននៅក្នុងអំឡុងពេលនៃបេសកកម្មសង្កេតការណ៍របស់ខ្លួន។

៦- បម្រាមចំពោះអ្នកសង្កេតការណ៍បោះឆ្នោត

ក្នុងការសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានានៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោតអ្នកសង្កេតការណ៍បោះឆ្នោតមិនត្រូវ៖

- ៦.១ ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា។
- ៦.២ ជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយ ជាមួយនឹងអ្នកចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោត។
- ៦.៣ យកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួន។
- ៦.៤ បញ្ចុះបញ្ចូល ឬប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- ៦.៥ ចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- ៦.៦ ចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- ៦.៧ ចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។
- ៦.៨ ស្នង់មតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- ៦.៩ សរសេរដោលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- ៦.១០ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរដោលាយលក្ខណ៍អក្សរ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- ៦.១១ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរដោលាយលក្ខណ៍អក្សរ ក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។
- ៦.១២ ដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៣ ផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៤ ផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋ សម្រាប់ចូលរួមក្នុងសកម្មភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៥ ផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ដង្ហែក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៦ រំខាន ឬជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយ នៅពេលដំណើរការនៃការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតកំពុងប្រព្រឹត្តទៅ។

៦.១៧ ប៉ះពាល់ឯកសារ ឬសម្ភារ បរិក្ខារបោះឆ្នោត ក្នុងនោះរួមទាំងសន្លឹកឆ្នោតផង។

៦.១៨ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗ នៅក្នុងការិយាល័យបោះឆ្នោត។

៦.១៩ នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៦.២០ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត និងបង្អាក់ដំណើរការបោះឆ្នោត។

៦.២១ រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់បោះឆ្នោត ឬបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

៦.២២ ចូលរួមជជែកវែកញែក ក្នុងដំណើរការដោះស្រាយបណ្តឹងណាមួយក្នុងអំឡុងពេលបោះឆ្នោត ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយពាក្យបណ្តឹងនេះបាន។

៦.២៣ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

អ្នកសង្កេតការណ៍បោះឆ្នោតត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប លធ.ខប ឬ លគធ.ខប គយ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.២៤ ល្បែង

អ្នកសង្កេតការណ៍បោះឆ្នោតមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប លធ.ខប ឬ លគធ.ខប គយ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៧- សំណូមពរ និងការអនុវត្ត

សមាគម អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវយកចិត្តទុកដាក់អនុវត្ត ដូចខាងក្រោម៖

៧.១- សំណូមពរ

បន្ទាប់ពីដំណើរការបោះឆ្នោតបានចប់សព្វគ្រប់ហើយ អង្គការសង្កេតការណ៍បោះឆ្នោតទាំងឡាយត្រូវ ផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងដំណើរ ការបោះឆ្នោត ផ្ញើជូន គ.ជ.ប។ គ.ជ.ប មានសិទ្ធិផ្តល់យោបល់លើរបាយការណ៍នេះ។ អង្គការសង្កេតការណ៍ បោះឆ្នោតអាចធ្វើការកែតម្រូវ ឬមិនកែតម្រូវតាមយោបល់របស់ គ.ជ.ប។ ក្នុងករណីមិនធ្វើការកែតម្រូវតាម យោបល់របស់ គ.ជ.ប ត្រូវភ្ជាប់យោបល់នេះ នៅក្នុងផ្នែកចុងក្រោយនៃរបាយការណ៍របស់ខ្លួនដែលត្រូវផ្សព្វផ្សាយ។

៧.២- ការអនុវត្ត

ក្រមសីលធម៌នេះមានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្ត គ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

សម្រង់ទោសប្បញ្ញត្តិ

ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា១៤២.- ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៤៨.-

ត្រូវផាកពិន័យជាប្រាក់ពី ១0.000.000 (ដប់លាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម

ក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោល បំពានលើបញ្ញត្តិនៃមាត្រា៨៤ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

មាត្រា១៤៩.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា តាមបែបបទដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

មាត្រា១៥៩.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា១៣៧ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

មាត្រា១៦០.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា១៧១.- ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការគាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៧៩.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀលទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក

និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលបំពានលើបញ្ញត្តិនៃមាត្រា៧៤ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

មាត្រា១៨០.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀលទៅ ១0.000.000 (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាតាមបែបបទដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

មាត្រា១៨៧.-

ត្រូវផាកពិន័យជាប្រាក់ពី ១0.000.000 (ដប់លាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា១៥៩ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

មាត្រា១៨៨.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.000.000 (មួយលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ឧបសម្ព័ន្ធទី៤
ក្រមសីលធម៌
សម្រាប់
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត

១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់ សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អនាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអនុវត្តក្នុងដំណើរការបោះឆ្នោត ដើម្បីលើកកម្ពស់ថែមទៀតនូវប្រសិទ្ធភាពនៃការផ្សព្វផ្សាយអំពីការបោះឆ្នោតប្រកបដោយវិជ្ជាជីវៈ ត្រឹមត្រូវ និងតម្លាភាព។

២- គោលបំណង

ក្រមសីលធម៌នេះមានគោលបំណងកំណត់វិធានសំខាន់ៗ ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មាន អនុវត្តសេរីភាពសារព័ត៌មាន និងសេរីភាពខាងការផ្សព្វផ្សាយព័ត៌មាន ផ្តល់ព័ត៌មាន

អំពីការបោះឆ្នោតបានត្រឹមត្រូវ ច្បាស់លាស់ ទាន់ពេលវេលា ចូលរួមធានាឱ្យដំណើរការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

៣- វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ ដែលធ្វើការផ្សព្វផ្សាយព័ត៌មាន និងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោត។

៤- និយមន័យ

វាក្យសព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន** សំដៅដល់អង្គភាពទាំងឡាយដែលធ្វើសកម្មភាពនៃការផ្សព្វផ្សាយព័ត៌មាន ដែលត្រូវធ្វើឡើងជាទៀងទាត់ តាមរយៈការបោះពុម្ព ការផ្សព្វផ្សាយរួមមានសារព័ត៌មានទស្សនាវដ្តី និងតាមរយៈវិទ្យុ ទូរទស្សន៍ និងតាមរយៈអាសយដ្ឋានវេប និងបណ្តាញសង្គម។

៤.២- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៣- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥- សិទ្ធិ តារកិច្ច និងការទទួលខុសត្រូវរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់មានសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវក្នុងការយកព័ត៌មាន និងផ្សព្វផ្សាយអំពីការងារបោះឆ្នោត។

៥.១- សិទ្ធិរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់មានសិទ្ធិដូចខាងក្រោម៖

៥.១.១ សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានគ្មានអង្គភាពដែលមានបំណងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោត មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានដោយផ្ទាល់ទៅ គ.ជ.ប។

៥.១.២ អាចទាញយកពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានពីអាសយដ្ឋានវេប www.nec.gov.kh បានដោយឥតគិតថ្លៃ។

៥.១.៣ បំពេញបែបបទនៃការស្នើសុំចុះឈ្មោះជាអ្នកសារព័ត៌មាន ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតនីមួយៗ។

៥.១.៤ ថត និងយកព័ត៌មានអំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥.១.៥ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិដែលមានបំណងថតយករូបភាពក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវដម្រាបជូនដំណឹងទៅប្រធាន ក.ច.ប ឬ គ.ក.ប/គ.ក.រ នោះជាមុន។

៥.១.៦ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ ត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោតពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីជួយដោះស្រាយឱ្យបានទាន់ពេលវេលា។

៥.២- តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវផ្សព្វផ្សាយព័ត៌មានដល់សាធារណជន អ្នកបោះឆ្នោតឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ ក្នុងន័យនេះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

៥.២.១ ចូលរួមក្នុងការអប់រំអ្នកបោះឆ្នោត ដើម្បីឱ្យអ្នកបោះឆ្នោតមានការយល់ដឹងត្រឹមត្រូវពីការបោះឆ្នោត។

៥.២.២ ផ្តល់ព័ត៌មាន និងការអប់រំអំពីការបោះឆ្នោតដែលងាយយល់សម្រាប់អ្នកបោះឆ្នោត រួមមានសិទ្ធិចុះឈ្មោះបោះឆ្នោត សិទ្ធិបោះឆ្នោត និងសិទ្ធិចូលរួមក្នុងសកម្មភាពផ្សេងៗទៀតនៃការបោះឆ្នោតតាមច្បាប់កំណត់។

៥.២.៣ ស្វែងរក និងផ្សព្វផ្សាយព័ត៌មានអំពីទស្សនៈ និងគំនិតផ្សេងៗគ្នារបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការបោះឆ្នោត។

៥.២.៤ ផ្សព្វផ្សាយព័ត៌មានអំពីសារៈសំខាន់នៃការចូលរួមរបស់ព្រះសង្ឃ យុវជន យុវនារី ស្ត្រី ជនជាតិភាគតិច និងជនមានពិការភាព ក្នុងជីវភាពសង្គម និងនយោបាយដើម្បីបង្កើនការយល់ដឹង។

៥.២.៥ ចូលរួមលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីដំណើរការបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ ដើម្បីឱ្យអ្នកបោះឆ្នោតបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយ។

៥.២.៦ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋត្រូវមានអព្យាក្រឹតភាព យុត្តិធម៌ និងភាពត្រឹមត្រូវក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត។ ដោយឡែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជន ត្រូវចូលរួមសហការធ្វើការផ្សព្វផ្សាយព័ត៌មានប្រកបដោយអព្យាក្រឹតយុត្តិធម៌ និងត្រឹមត្រូវ។

៥.២.៧ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន គោរពច្បាប់ស្តីពីរបបសារព័ត៌មាន គោរពច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះ។

៥.២.៨ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ ត្រូវខិតខំប្រឹងប្រែងឱ្យអស់សមត្ថភាពក្នុងការចូលរួមធ្វើឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

៥.៣- ការទទួលខុសត្រូវ និងភាពឯកច្ឆរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនទៅតាមច្បាប់ជាធរមាន និងមានភាពឯកច្ឆគោរពគោលការណ៍ចាំបាច់ដូចតទៅ៖

៥.៣.១ គោរពសច្ចធម៌ និងគោរពសិទ្ធិយល់ដឹងនូវសច្ចធម៌របស់សាធារណជន។

៥.៣.២ គោរពសិទ្ធិ និងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល។

៥.៣.៣ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវបានលើកទឹកចិត្តក្នុងលក្ខណៈជាដៃគូជាមួយ គ.ជ.ប ដើម្បីធ្វើការផ្តល់ព័ត៌មាន និងអប់រំអ្នកបោះឆ្នោតអំពីការបោះឆ្នោត។

៥.៣.៤ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ត្រូវបង្ហាញនូវកម្រិតគុណភាពខ្ពស់នៃវិជ្ជាជីវៈអ្នកសារព័ត៌មាន និងត្រូវផ្តល់ព័ត៌មាន និងហេតុការណ៍ថ្មីៗឱ្យបានសមរម្យពិតប្រាកដ និងឥតលម្អៀង ដើម្បីធានានូវយុត្តិធម៌ និងតុល្យភាពព័ត៌មានសម្រាប់គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោត។

៥.៣.៥ ពង្រឹង និងណែនាំអ្នកសារព័ត៌មាន មិនត្រូវបោះបង់គោលជំហរ ឬក្រមសីលធម៌របស់ខ្លួនដោយសារតែអំណោយ ផលប្រយោជន៍ ឬចំណង់ចំណូលចិត្តពិសេសទេ។

៥.៣.៦ ត្រូវផ្ទៀងផ្ទាត់អំពីប្រភពព័ត៌មាន ភាពសុក្រឹត និងភាពច្បាស់លាស់នៃហេតុការណ៍ និងព្រឹត្តិការណ៍ដែលខ្លួនត្រូវរាយការណ៍។

៥.៣.៧ ត្រូវរាយការណ៍តែតាមហេតុការណ៍ ដែលខ្លួនដឹងពីប្រភពដើមតែប៉ុណ្ណោះ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមិនត្រូវបំបាត់ចោលនូវព័ត៌មានសំខាន់ៗ ឬកែបន្លំឯកសារផ្សេងៗឡើយ។

៥.៣.៨ ប្រើវិធីសុចរិត ត្រឹមត្រូវ ដើម្បីស្វែងរកដំណឹង រូបថត និងឯកសារផ្សេងៗ។

៥.៣.៩ ត្រូវផ្សាយដំណឹងទាំងឡាយដោយសុចរិត ព្រមទាំងធ្វើអត្ថាធិប្បាយ ឬវិនិគន់ឱ្យបានត្រឹមត្រូវ និងសមស្របតាមគោលការណ៍គតិយុត្តិធម៌ និងសីលធម៌។

៥.៣.១០ ប្តឹងផ្តែងឱ្យបានត្រឹមត្រូវ មានប្រភពឯកសារច្បាស់លាស់ និងទទួលខុសត្រូវខ្ពស់ក្នុងការផ្សព្វផ្សាយលទ្ធផលនៃការបោះឆ្នោត។

៥.៣.១១ ត្រូវផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ មិនលម្អៀង និងដោយមានការប្តឹងផ្តែងឱ្យមានតុល្យភាព។

៥.៣.១២ ផ្តល់ឱកាសស្មើគ្នាដល់គណបក្សនយោបាយ ឬបេក្ខជនដែលចូលរួមក្នុងការបោះឆ្នោត ឱ្យមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

៥.៣.១៣ ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ និងឯកជនត្រូវបែងចែកឱ្យបានច្បាស់ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពជាផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោតដែលធ្វើឡើងក្នុងនាមគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រ។

៥.៣.១៤ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានត្រូវធ្វើការបែងចែកឱ្យបានច្បាស់លាស់រវាងហេតុការណ៍ជាក់ស្តែង និងទស្សនៈយោបល់។ ការផ្សព្វផ្សាយព័ត៌មានត្រូវឆ្លុះបញ្ចាំងពីហេតុការណ៍ជាក់ស្តែង។

៥.៣.១៥ ត្រូវជៀសវាងការផ្សព្វផ្សាយព័ត៌មាន ដែលញុះញង់ឱ្យមានការរើសអើង ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត។

៥.៣.១៦ ត្រូវធ្វើការកែតម្រូវនូវព័ត៌មានណាដែលចេញផ្សាយរួចហើយៗមានលក្ខណៈមិនជាក់លាក់ និងនាំឱ្យមានការយល់ច្រឡំ។

៦- បម្រាមចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ត្រូវបានហាមឃាត់ចំពោះសកម្មភាពដែលត្រូវបានចាត់ទុកថាជាការរំលោភធ្ងន់ធ្ងរខាងផ្នែកវិជ្ជាជីវៈអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចខាងក្រោម៖

៦.១ ការផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យមានការភាន់ច្រឡំ នាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

៦.២ ការបន្លំឱ្យគេយល់ខុស ដូចជាការសរសេរបញ្ឆិតបញ្ឆៀង ដើម្បីឱ្យសាធារណជនមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ក្រុមបក្សណាមួយ។

៦.៣ ការផ្សព្វផ្សាយព័ត៌មានដោយសំអាងលើពាក្យចចាមអារ៉ាម ឬព័ត៌មានដែលពុំមានភស្តុតាងបញ្ជាក់។

៦.៤ ការផ្សព្វផ្សាយដែលមានលក្ខណៈមួលបង្កាច់ បរិហារកេរ្តិ៍ និងជេរប្រមាថដល់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ។

៦.៥ ការប្រើប្រាស់ភាសាញុះញង់ ឬវាយប្រហារ ដែលអាចបង្កភាពគ្មានសណ្តាប់ធ្នាប់ ឬអាចឱ្យមានអំពើហិង្សា។

៦.៦ ការបោះពុម្ពផ្សាយ ឬចែកចាយព័ត៌មានណាដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបង្កឱ្យមានការភ័យខ្លាច ឬបង្កជាអំពើហិង្សាណាមួយកើតឡើង។

៦.៧ ការផ្សព្វផ្សាយព័ត៌មានដែលញុះញង់ឱ្យមានការរើសអើង ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើត ឋានៈ សង្គម ធនធាន ឬស្ថានភាពដទៃទៀត។

៦.៨ ការបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មានដែលបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ ស្ថិរភាពនយោបាយ និងស្ថិរភាពសង្គម។

៦.៩ ការបោះពុម្ពផ្សាយ ឬផ្សាយបន្តហេតុការណ៍ ឬព្រឹត្តិការណ៍មិនពិតដែលជាការដេរប្រមាថការមើលងាយដល់ស្ថាប័នជាតិ។

៦.១០ ការផ្សព្វផ្សាយមានលក្ខណៈរើសអើងប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១១ ការសម្តែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថ តាមរយៈកាយវិការ ឬឥរិយាបថជាក់ស្តែងផ្សេងទៀត។

៦.១២ ការបញ្ចេញ បញ្ចូលនូវទស្សនៈផ្ទាល់ខ្លួន ឬក៏ធ្វើបុរេនិច្ឆ័យនៅក្នុងហេតុការណ៍កំពុងកើតមានដែលខ្លួនធ្វើសេចក្តីរាយការណ៍។

៦.១៣ ការជ្រៀតជ្រែក ឬរំខានដល់ការងារចុះឈ្មោះបោះឆ្នោត បោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៦.១៤ ការផ្សព្វផ្សាយមិនឱ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត។

៦.១៥ ការទទួលសំណូក អំណោយក្នុងបែបណាមួយ ឬការជំរិតយកប្រាក់ ដើម្បីជាថ្នូរនឹងការផ្សព្វផ្សាយ ឬមិនផ្សព្វផ្សាយនូវព័ត៌មានណាមួយ។

៦.១៦ ការធ្វើសម្ភាសន៍នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៦.១៧ ការប្រើប្រាស់តួនាទីរបស់ខ្លួន (ទោះឯកជន ឬរដ្ឋ) ដើម្បីគាបសង្កត់លើមន្ត្រីចុះឈ្មោះបោះឆ្នោត ឬសមាជិក កបយ.ស មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬគាបសង្កត់លើអ្នកសង្កេតការណ៍ ឬបេក្ខជន ឬភ្នាក់ងារគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោត ឬអ្នកបោះឆ្នោតឡើយ។

៦.១៨ ការជក់បារី និងការបង្ហាររភ្លើង អគ្គិភ័យ

អ្នកសារព័ត៌មានត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប លជ.ខប ឬ លគជ.ខប គយ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.១៩ ល្បែង

អ្នកសារព័ត៌មានមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប លជ.ខប ឬ លគជ.ខប គឃ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៧- សំណូមពរ និងការអនុវត្ត

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

៧.១- សំណូមពរ

ដើម្បីជានាឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានត្រូវគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ច្បាប់ស្តីពីរបបសារព័ត៌មាន និងក្រមសីលធម៌នេះ។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានអំពីដំណើរការបោះឆ្នោតឱ្យមានប្រសិទ្ធភាពប្រកបដោយវិជ្ជាជីវៈ ឯករាជ្យ ត្រឹមត្រូវ និងមិនលម្អៀង។

៧.២-ការអនុវត្ត

ក្រមសីលធម៌នេះមានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

សម្រង់ទោសប្បញ្ញត្តិ

ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា១៤២.- ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា១៧១.- ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀលទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការគាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

ឧបសម្ព័ន្ធទី៥
ក្រមសីលធម៌
សម្រាប់
យោធិនឯកភាពយោធពលខេមរភូមិន្ទ នគរបាលជាតិ
និងភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងដំណើរការបោះឆ្នោត

១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី របស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់ សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ បោះឆ្នោតជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និង អន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អនាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌ បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿ ទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់យោធិននៃ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតចូលរួមក្នុងការបោះឆ្នោត ពិសេស ក្នុងការការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល។

២- គោលបំណង

ក្រមសីលធម៌នេះមានគោលបំណងកំណត់វិធាន និងគោលការណ៍សំខាន់ៗសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ពិសេសភ្នាក់ងារសន្តិសុខបោះឆ្នោតអនុវត្តនូវសិទ្ធិ តួនាទី និងភារកិច្ចរបស់ខ្លួនចូលរួមក្នុងដំណើរការបោះឆ្នោត ដើម្បី៖

- ធានាឱ្យដំណើរការនៃការរៀបចំការបោះឆ្នោតទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ គ្មានអំពើហិង្សាផ្សេងៗ និងសម្រេចបានជោគជ័យ
- ការពារសន្តិសុខ និងសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋអ្នកចុះឈ្មោះបោះឆ្នោត អ្នកបោះឆ្នោត បេក្ខជន យោសនិក និងភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងរក្សាស្ថិរភាពសម្រាប់សង្គមជាតិទាំងមូល
- ចាត់វិធានការបង្ការ រារាំង ទប់ស្កាត់ និងបង្ក្រាបរាល់អំពើល្មើស អំពើវិទ្ធង្សនា និងអំពើភេរវកម្មផ្សេងៗ ដែលអាចបង្កឱ្យមានការរាំងស្ទះដល់ដំណើរការបោះឆ្នោត។

៣- វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ក្នុងការចូលរួមក្នុងការបោះឆ្នោត ពិសេសភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល ទៅតាមមុខសញ្ញា និងទីតាំងជាក់លាក់។

៤- និយមន័យ

វាក្យសព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **យោធិននៃកងយោធពលខេមរភូមិន្ទ** គឺជាពលទាហាន នាយទាហានរង និងនាយទាហាន ក្នុងនេះមានកងរាជអាវុធហត្ថ។

៤.២- **នគរបាលជាតិ** គឺជាមន្ត្រីនគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា។

៤.៣- **ភ្នាក់ងារសន្តិសុខបោះឆ្នោត** គឺជាយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខសម្រាប់ការបោះឆ្នោត។

៤.៤- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៥- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត

- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥- សិទ្ធិ តារកិច្ច និងការទទួលខុសត្រូវរបស់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវអនុវត្តសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

៥.១- សិទ្ធិរបស់យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ

យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិមានសិទ្ធិចូលរួមក្នុងការបោះឆ្នោត ដូចជាប្រជាពលរដ្ឋទូទៅដែរ ហើយសិទ្ធិនេះត្រូវបានកំណត់ដោយច្បាប់បោះឆ្នោត និងច្បាប់ពាក់ព័ន្ធដែលនៅជាធរមាន។

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ។

៥.២- តារកិច្ចរបស់មេបញ្ជាការ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

មេបញ្ជាការ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវអនុវត្តភារកិច្ចដូចខាងក្រោម៖

៥.២.១ មេបញ្ជាការ ឬតំណាងនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងនគរបាលជាតិ មានភារកិច្ច៖

- ត្រូវចូលរួមប្រជុំជាមួយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីចាត់វិធានការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល
- ត្រូវចេញសេចក្តីណែនាំ ឬបទបញ្ជាទៅដល់មន្ត្រីនៅក្រោមឱវាទ ដើម្បីពិនិត្យមើលសកម្មភាពរបស់មន្ត្រីនៃអង្គភាពរៀងៗខ្លួនពាក់ព័ន្ធទៅនឹងគណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រគណបក្សនយោបាយ និងប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងកិច្ចការពារសិទ្ធិសេរីភាពជាមូលដ្ឋានដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ត្រូវសហការ និងត្រៀមលក្ខណៈសហការជាមួយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ក្នុងការចាត់ចែងកម្លាំងសន្តិសុខបោះឆ្នោត ដើម្បីផ្តល់ការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោត។

៥.២.២ ភ្នាក់ងារសន្តិសុខបោះឆ្នោតមានការកិច្ច៖

- រក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈក្នុងពេលចុះឈ្មោះបោះឆ្នោត បិទផ្សាយបញ្ជីបោះឆ្នោតដំបូង បញ្ជីបោះឆ្នោតផ្លូវការ បញ្ជីទីតាំងការិយាល័យបោះឆ្នោត បញ្ជីបេក្ខជន ពេលឃោសនាបោះឆ្នោត ពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត
- នៅថ្ងៃបោះឆ្នោតភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួន ៣ (បី) នាក់ ការពារបរិវេណសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងឱ្យបានត្រឹមត្រូវ និងមានពាក់ប្រឡង់ដៃសន្តិសុខបោះឆ្នោតរបស់ គ.ជ.ប
- ចូលរួមចំណែកការពារការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ដែលជាបរិវេណរដ្ឋបាល និងសន្តិសុខ
- ស្ថិតនៅជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីត្រៀមបំពេញភារកិច្ច ក្នុងករណីមានសំណូមពរពីប្រធាន គ.ក.ប/គ.ក.រ ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងការិយាល័យណាមួយនោះ។

៥.៣- ការទទួលខុសត្រូវរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត

ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវមានការទទួលខុសត្រូវដូចខាងក្រោម៖

៥.៣.១ ប្រកាន់ជំហរអព្យាក្រឹត មិនលម្អៀង និងមិនត្រូវបង្ហាញការគាំទ្រ ឬប្រឆាំងចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងត្រូវដឹងថា៖

- ប្រជាពលរដ្ឋ អ្នកសុំចុះឈ្មោះបោះឆ្នោត និងអ្នកបោះឆ្នោតគ្រប់រូបមានសិទ្ធិទទួលបានសន្តិសុខ សុវត្ថិភាព ដើម្បីឱ្យដំណើរការចុះឈ្មោះបោះឆ្នោត និងដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌
- បេក្ខជន វាគ្មិន ឬឃោសនិក តំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតមានសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងគ្រប់សកម្មភាពស្របច្បាប់។

៥.៣.២ ធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយពាក់ព័ន្ធទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពនៅក្នុងសម័យបោះឆ្នោត។

៥.៣.៣ យាម និងត្រួតពិនិត្យគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតយ៉ាងតឹងរ៉ឹងបំផុតនៅក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៥.៣.៤ ហាមឃាត់ជនណាម្នាក់ដែលប្រដាប់ដោយអាវុធ ឬមានលាក់អាវុធជាតិផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងខ្លួនចូល ឬឈរក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងតែជននោះជាយោធិននៃកងយោធ

ពលខេមរភូមិន្ទ ឬនគរបាលជាតិដែលមានការកិច្ច និងត្រូវបានស្នើសុំដើម្បីដោះស្រាយបាតុភាពដែលកើតមានក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬ/និងបរិវេណខាងក្នុង ឬ/និងបរិវេណខាងក្រៅ។

៥.៣.៥ ជួយការពារការដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោត សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោត ពីគោលដៅមួយទៅកាន់គោលដៅមួយ តាមការកំណត់របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ តាមការស្នើសុំ។

៥.៣.៦ ត្រូវមានស្មារតីប្រុងប្រយ័ត្ន ពង្រឹង និងកសាងសមត្ថភាព ស្វែងយល់ឱ្យបានច្បាស់អំពីគោលការណ៍ច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត ផែនការអន្តរស្ថាប័នមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប ក្រមសីលធម៌ រួមទាំងសេចក្តីណែនាំផ្សេងៗ ស្តីពីកិច្ចការពារសន្តិសុខបោះឆ្នោតសម្រាប់ធ្វើជាមូលដ្ឋាននៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន។

៦- បម្រាមចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវបាន៖

៦.១ ហាមប្រើឥទ្ធិពល អំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ។ ការគំរាមកំហែងការបំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន៖

- ការវាយតប់លើបុគ្គលណាម្នាក់
- ការរំលោភដោយពាក្យសម្តីថា នឹងធ្វើទារុណកម្មដល់រាងកាយ
- ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដោយយោងទៅលើព្រឹត្តិការណ៍ពីអតីតកាល មានជាអាទិ៍ឃាតកម្ម ការវាយដំ ឬការបង្ករបួសស្នាម ការរំលោភ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់
- ការបាញ់ ការផ្ទុះអាវុធគំរាមបុគ្គលណាម្នាក់ ទោះតាមរូបភាពណាមួយក៏ដោយ
- ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូន គ្រួសាររបស់ពួកគេ

- ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសាររបស់ពួកគេ
- ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង
- ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង និងផលប្រយោជន៍ផ្សេងទៀត។

៦.២ ហាមប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោត ឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៣ ហាមចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ក្នុងពេលម៉ោងធ្វើការ ឬពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ។ ការចូលរួមសកម្មត្រូវបានកំណត់ដូចតទៅ៖

- ការចូលរួមជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ
- ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការដាក់តាំងរូបភាពផ្សាយ ឬឯកសារផ្សេងៗ ដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ និងតាមយានជំនិះផ្ទាល់របស់ខ្លួន ឬ/និងអង្គភាព
- ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការធ្វើសកម្មភាពចែកចាយសម្ភារឃោសនាបោះឆ្នោតដល់អ្នកបោះឆ្នោត ក្នុងគោលបំណងគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការចេញសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការចូលរួមក្នុងសកម្មភាពឃោសនាជាសាធារណៈណាមួយ ក្នុងសម្លៀកបំពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ។



៦.៤ ហាមចូលរួមក្នុងសកម្មភាពឃោសនាណាមួយ ក្នុងពេលបំពេញភារកិច្ច។

៦.៥ ហាមដើរ ឬឈរកៀកពេកទៅនឹងមធ្យោបាយ ឬទីកន្លែងដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោត លើកលែងតែមានការស្នើសុំដោយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

៦.៦ ហាមជ្រៀតជ្រែកក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត។

៦.៧ ហាមយកអាវុធជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ព្រមទាំងការស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត ព្រមទាំងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងក្នុងករណីចាំបាច់ និងមានការស្នើសុំអន្តរាគមន៍ពីប្រធាន គ.ជ.ប ប្រធាន លធ.ខប ឬប្រធាន គធ.ខប ប្រធាន គឃ.សប ឬ កបឃ.ស ឬប្រធាន ក.ច.ប ឬពីប្រធាន គ.ក.ប/គ.ក.រ។

៦.៨ ភ្នាក់ងារសន្តិសុខបោះឆ្នោតមិនត្រូវចូលទៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងក្នុងករណីចាំបាច់ និងមានការស្នើសុំអន្តរាគមន៍ពីប្រធាន គ.ជ.ប ប្រធាន លធ.ខប ឬប្រធាន គធ.ខប ប្រធាន គឃ.សប ឬពីប្រធាន គ.ក.ប/គ.ក.រ។

៦.៩ ការដក់បារី និងការបង្ហារភ្លើង អគ្គិភ័យ

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវជៀសវាង៖

- ការដក់បារីនៅក្នុងទីស្តីការ គ.ជ.ប លធ.ខប ឬ លគធ.ខប គឃ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.១០ ល្បែង

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប លធ.ខប ឬ លគធ.ខប គឃ.សប ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៧- សំណូមពរ និងការអនុវត្ត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត រួមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការងារសន្តិសុខត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

៧.១- សំណូមពរ

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហការដល់ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព ក្នុងរយៈពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងសម្រាប់ដំណើរការបោះឆ្នោតនីមួយៗឱ្យទទួលបានជោគជ័យ។

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាព ការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌ ឬសកម្មភាពបំពារបំពានច្បាប់ផ្សេងៗទៀតដែលជាហេតុបង្កឱ្យមានការភ័យខ្លាច និងប៉ះពាល់ដល់បរិយាកាសនយោបាយ និងសន្តិសុខជាតិទាំងមូល។

តាមសំណើរបស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវយកចិត្តទុកដាក់ការពារសុវត្ថិភាពសម្រាប់ទីតាំងរោងពុម្ពផលិតសន្លឹកឆ្នោត ទីកន្លែងរក្សាទុក ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងគ្រឿងសង្ហារិមចាំបាច់ផ្សេងៗដែលបម្រើការងារបោះឆ្នោត ការដឹកជញ្ជូនសន្លឹកឆ្នោត និងឯកសារបោះឆ្នោតនៅគ្រប់ដំណាក់កាល ប្រកបដោយប្រសិទ្ធភាពខ្ពស់ សុវត្ថិភាព និងគ្មានការអាក់រអួល។

យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិទាំងមូល ជាពិសេសកងកម្លាំងដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខសម្រាប់ការបោះឆ្នោត គឺភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវប្រមូលផ្តុំកម្លាំងសហការឱ្យបានល្អ និងប្រើប្រាស់តាមគ្រប់វិធានការជំនាញគ្រប់មធ្យោបាយ និងសម្ភារ លើកកម្ពស់ស្មារតីប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ក្នុងកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសម្រាប់ការបោះឆ្នោត។

៧.២- ការអនុវត្ត

ក្រមសីលធម៌នេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

សម្រង់ទោសប្បញ្ញត្តិ

ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា១៤២.- ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៤៦.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់

គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដៃនអនុវត្តរបស់មាត្រា៤៨៩ (បទផលិត ឬធ្វើចរាចរណ៍ អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ចូលក្នុងតំបន់ហាមឃាត់ និងក្នុងអំឡុងពេលដូចបានបញ្ញត្តក្នុងមាត្រា៥២ និងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត ដូចបានបញ្ញត្តក្នុងមាត្រា១១២ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិកឬជាសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៤៧.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលល្មើសនឹងមាត្រា៨៧ នៃច្បាប់នេះ។

មាត្រា១៥៨.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ខ- សម្រាប់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា១៧១.- ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។

- បង្កការអុកឡុក ឬរាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សា ទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រាំរាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រាំរាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៧៥.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដៃនអនុវត្តរបស់មាត្រា៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ដោយបំពានលើបញ្ញត្តិនៃមាត្រា២៨ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១0 (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៧៦.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលល្មើសនឹងមាត្រា ១០ នៃច្បាប់នេះ។

មាត្រា១៨៦.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ឧបសម្ព័ន្ធទី៦

សម្ភារ ឯកសារបោះឆ្នោតដែលត្រូវប្រគល់ជូន គធ.ខប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល

១- បណ្ណសម្គាល់សមាសភាព គ.ក.ប ចំនួន ៦ (ប្រាំមួយ) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនទុកបម្រុងមុន)។

២- បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយចំនួន ១០ (ដប់) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនទុកបម្រុងមុន)។

៣- បណ្ណសម្គាល់អ្នកសង្កេតការណ៍បោះឆ្នោតជាតិចំនួន ២ (ពីរ) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុន)។

៤- កញ្ចប់សន្លឹកឆ្នោតបម្រុង។

៥- ទឹកខ្មៅលុបមិនជ្រះបម្រុង។

៦- ទម្រង់បែបបទលេខ ១០០២ សម្រាប់បំពេញកិច្ចសន្យាបម្រើការងាររបស់សមាសភាព គ.ក.ប ចំនួន ១២ (ដប់ពីរ) សន្លឹក គុណនឹងការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (សម្រាប់បំពេញដោយ គឃ.សប និងអ្នកដែលត្រូវតែងតាំងក្នុង គ.ក.ប/គ.ក.រ) (ត្រូវបញ្ជូនមុន)។

៧- ទម្រង់បែបបទលេខ ១០០៤ សម្រាប់បំពេញបញ្ជីវត្តមាន និងប្រាក់កម្រៃសមាសភាព គ.ក.ប ចំនួន ៣ (បី) ច្បាប់ (បំពេញដោយ គឃ.សប និង គធ.ខប) (ត្រូវបញ្ជូនមុន)។

៨- ទម្រង់បែបបទលេខ ១១០៥ធខ សម្រាប់បំពេញក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប ចំនួន ៣ (បី) ច្បាប់ គុណនឹងចំនួនឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (បំពេញដោយ គធ.ខប និងអនុគណៈកម្មការបច្ចេកទេស)។

៩- ទម្រង់បែបបទលេខ ១១០៦ ចំនួន ៦ (ប្រាំមួយ) ច្បាប់ សម្រាប់កត់ត្រាការត្រួតពិនិត្យការបែងចែក និងបញ្ជូនសន្លឹកឆ្នោត (សម្រាប់បំពេញដោយ គធ.ខប និង គឃ.សប)។

១០- ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត ចំនួន ១២ (ដប់ពីរ) ច្បាប់ គុណនឹងចំនួនឃុំ សង្កាត់ក្នុងរាជធានី ខេត្ត។

១១- ទម្រង់បែបបទលេខ ១១១០ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ចំនួន ៣ (បី) ច្បាប់ (សម្រាប់បំពេញដោយ គធ.ខប និងអនុគណៈកម្មការបច្ចេកទេស)។

១២- ទម្រង់បែបបទលេខ ១១១១ សម្រាប់បំពេញលទ្ធផលនៃការបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិក កបយ.ស ចំនួន ៣ (បី) ច្បាប់ (សម្រាប់បំពេញដោយ គធ.ខប និងអនុគណៈកម្មការបច្ចេកទេស)។

១៣- ទម្រង់បែបបទលេខ ១១១៦តព សម្រាប់បំពេញតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ចំនួន ៦ (ប្រាំមួយ) ច្បាប់ គុណនឹងចំនួនឃុំ សង្កាត់ ក្នុងរាជធានី ខេត្ត) (សម្រាប់បំពេញដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប)។

១៤- ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ចំនួន ៥ (ប្រាំ) ក្បាល ក្នុងមួយក្បាលមាន ២០ (ម្ភៃ) ច្បាប់។

១៥- ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញសម្រង់សេចក្តីសម្រេចលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ចំនួន ៥ (ប្រាំ) ក្បាល ក្នុងមួយក្បាលមាន ២០ (ម្ភៃ) ច្បាប់។

១៦- ស្រោមសំបុត្រធំចំនួន ៣ (បី) គុណនឹងចំនួនឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ស្រោមសំបុត្រមធ្យមចំនួនចំនួន ២ (ពីរ) និងបន្ថែមស្រោមសំបុត្រមធ្យម ចំនួនគិតសមាមាត្រនឹងស្បោង "ឃ" ដែលត្រូវប្រើនៅ គធ.ខប និងស្រោមសំបុត្រតូចចំនួន ១។

១៧- យូអេសប៊ីផ្លាសដ្រាយសម្រាប់រក្សារូបភាព និងទិន្នន័យពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោត (ផ្ញើជូន គ.ជ.ប)។

១៨- ម៉ាស៊ីនគិតលេខបែងចែកតាមរាជធានី ខេត្តតូច ឬធំ។

១៩- ប៊ិកហ្វឺធំលុបមិនជ្រះ បែងចែកតាមរាជធានី ខេត្តតូច ឬធំ។

២០- ប៊ិកហ្វឺតធំខៀវ បែងចែកតាមរាជធានី ខេត្តតូច ឬធំ។

២១- កញ្ចប់ "ឃ ពិសេស" បែងចែកតាមរាជធានី ខេត្តតូច ឬធំ។

២២- ស្បោង "ឃ" បែងចែកតាមរាជធានី ខេត្តតូច ឬធំ។

២៣- សោឃ្លុំដំរធំមានលេខ សម្រាប់ឃ្លុំស្បោង "ឃ" ចំនួនស្មើនឹងស្បោង "ឃ"។

២៤- ស្បោងដាក់បញ្ជីបោះឆ្នោតនៃរាជធានី ខេត្ត បែងចែកតាមរាជធានី ខេត្តតូច ឬធំ។

២៥- បន្ទប់សម្ងាត់បម្រុង បែងចែកតាមរាជធានី ខេត្តតូច ឬធំ។

២៦- ហិបឆ្នោតបម្រុង បែងចែកតាមរាជធានី ខេត្តតូច ឬធំ។

ឧបសម្ព័ន្ធទី៧

សម្ភារ ឯកសារបោះឆ្នោតដែលត្រូវប្រគល់ជូន គយ.សប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល

១- បណ្ណសម្គាល់សមាសភាព គ.ក.ប ចំនួន ៦ (ប្រាំមួយ) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (ត្រូវបញ្ជូនមុន)។

២- បណ្ណសម្គាល់ភ្នាក់ងារនៃគណបក្សនយោបាយ ចំនួន ១៦ (ដប់ប្រាំមួយ) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (ត្រូវបញ្ជូនមុន)។

៣- ស្លាកសម្គាល់ទីស្នាក់ការ គយ.សប ចំនួន ១ (មួយ)។

៤- ត្រា គយ.សប ចំនួន ១ (មួយ) (ត្រូវបញ្ជូនមុន)។

៥- ត្រាសម្ងាត់ចំនួន ១ (មួយ) គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (បែងចែកបន្តជូន គ.ក.ប)។

៦- ត្រា គ.ក.ប ចំនួន ២ (ពីរ) (បម្រុងតាមឃុំ សង្កាត់)។

៧- ត្រាសម្ងាត់ចំនួន ២ (ពីរ) (បម្រុង)។

៨- តាំប៉ុងក្រហមចំនួន ២ (ពីរ) ប្រអប់ និងទឹកតាំប៉ុងពណ៌ក្រហមចំនួន ២ (ពីរ) ដប (ត្រូវបញ្ជូនមុន)។

៩- បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ចំនួន ៣ (បី) ច្បាប់ (ត្រូវបញ្ជូនមុន)។

១០- បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ចំនួន ១ (មួយ) ច្បាប់។

១១- កញ្ចប់សន្លឹកឆ្នោតចំនួន ១ (មួយ) កញ្ចប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (បែងចែកបន្តជូន គ.ក.ប)។

១២- ទម្រង់បែបបទលេខ ១១០៣ សម្រាប់បំពេញកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ចំនួន ៥ (ប្រាំ) ច្បាប់ (សម្រាប់បំពេញដោយ គយ.សប)។

១៣- ទម្រង់បែបបទលេខ ១១០៦ សម្រាប់កត់ត្រាការត្រួតពិនិត្យការបែងចែកសន្លឹកឆ្នោតចំនួន ៣ (បី) ច្បាប់ (សម្រាប់បំពេញដោយ គធ.ឧប ឬ គយ.សប)។

១៤- ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតចំនួន ៦ (ប្រាំមួយ) ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់។

១៥- ទម្រង់បែបបទលេខ ១១០៩ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ចំនួន ៤ (បួន) ច្បាប់ (សម្រាប់បំពេញដោយ គយ.សប) និងបន្ថែមចំនួនគិតសមាមាត្រជាមួយគណបក្សឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់។



១៦- ទម្រង់បែបបទលេខ ១១១៣ សម្រាប់បំពេញការវាយតម្លៃសមាសភាពនៃ គ.ក.ប ចំនួន១២ (ដប់ពីរ) ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (សម្រាប់បំពេញដោយ គយ.សប)។

១៧- ទម្រង់បែបបទលេខ ១១២១ សម្រាប់បំពេញកំណត់ហេតុនៃការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលត្រូវដាក់លើសន្លឹកឆ្នោតក្នុងឃុំ សង្កាត់ ចំនួន ៤ (បួន)ច្បាប់។

១៨- ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ចំនួន ៣ (បី) ក្បាល ក្នុង ១ក្បាលមាន ២០ (ម្ភៃ) ច្បាប់។

១៩- ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញសេចក្តីសម្រេចលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ចំនួន ៥ (ប្រាំ) ក្បាល ក្នុង ១ក្បាលមាន ២០ (ម្ភៃ) ច្បាប់។

២០- ស្រោមសំបុត្រធំចំនួន ២ (ពីរ) និងបន្ថែមស្រោមសំបុត្រមធ្យមចំនួនគិតសមាមាត្រនឹងស្បោង "គ" ដែលត្រូវប្រើនៅ គឃ.សប និងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ និងស្រោមសំបុត្រតូចចំនួន ១។

២១- យូអេសប៊ីផ្លាសដ្រាយសម្រាប់រក្សារូបភាព និងទិន្នន័យលទ្ធផលនៃការបោះឆ្នោត (ផ្ញើជូន គធ.ខប)។

២២- ម៉ាស៊ីនគិតលេខ ១ (មួយ) គ្រឿង។

២៣- ក្រដាសរ៉ាមចំនួន ៥០ (ហាសិប) សន្លឹក សម្រាប់ប្រើប្រាស់ការងារផ្សេងៗ និងបន្ថែមតាមចំនួនសមស្របសម្រាប់បម្រើឱ្យការងារចេញ ឯ.អ។

២៤- ប៊ិកខៀវចំនួន ៨ (ប្រាំបី) ដើម។

២៥- ប៊ិកហ្វឺតធំលុបលាងមិនជ្រះចំនួន ២ (ពីរ) ដើម។

២៦- ប៊ិកហ្វឺតធំពណ៌ខៀវចំនួន ២ (ពីរ) ដើម។

២៧- ស្កុតថ្លាធំចំនួន ១ (មួយ) ដើម។

២៨- កញ្ចប់ "គ ពិសេស" ចំនួន ១ (មួយ)។

២៩- ស្បោង "គ" ចំនួនគិតតាមសមាមាត្រនឹងចំនួនការិយាល័យបោះឆ្នោតតិច ឬច្រើនក្នុងឃុំ សង្កាត់។

៣០- សោឃ្លុំដែរធំមានលេខសម្រាប់ឃ្លុំស្បោង "គ" ចំនួនស្មើនឹងស្បោង "គ"។

៣១- ស្បោងដាក់បញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ គិតតាមសមាមាត្រនឹងចំនួនការិយាល័យបោះឆ្នោតតិច ឬច្រើនក្នុងឃុំ សង្កាត់។

៣២- បន្ទប់សម្ងាត់ចំនួន ១ (មួយ) កញ្ចប់មានចំនួនពីរផ្ទាំង គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (បែងចែកបន្តជូន គ.ក.ប)។

៣៣- ហិបឆ្នោតចំនួន ១ (មួយ) គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (បែងចែកបន្តជូន គ.ក.ប)។

ឧបសម្ព័ន្ធទី៨

សម្ភារ ឯកសារបោះឆ្នោតដែលត្រូវប្រគល់ជូន គ.ក.ប/គ.ក.រ សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល

១- ក្រដាសលេខកូដការិយាល័យបោះឆ្នោតចំនួន ៣ (បី) សន្លឹក សម្រាប់បិទនៅមុខការិយាល័យ និងបិទនៅជញ្ជាំងនៃហិបឆ្នោត។

២- ស្លាកសម្គាល់ការិយាល័យបោះឆ្នោតបោះពុម្ពលើប្លាស្ទិកចំនួន ១ (មួយ)។

៣- បណ្ណប្រកាសហាមប្រើទូរសព្ទដៃ និងម៉ាស៊ីនថតចំនួន ២ (ពីរ) សន្លឹក។

៤- ទឹកខ្មៅលុបមិនជ្រះចំនួន ២ (ពីរ) ដប។

៥- ត្រា គ.ក.ប ចំនួន ១ (មួយ)។

៦- ត្រាសម្ងាត់ចំនួន ១ (មួយ)។

៧- តាំប៉ុងពណ៌ក្រហមចំនួន ១ (មួយ) ប្រអប់ និងទឹកតាំប៉ុងក្រហមចំនួន ១ (មួយ) ដប។

៨- បិកមានខ្សែចងសម្រាប់គូសសន្លឹកឆ្នោត និងបិកធម្មតាសម្រាប់ គ.ក.ប សរុបទាំងពីរមុខចំនួន ៩ (ប្រាំបួន) ដើម។

៩- បិកហ្វឺតធំលុបមិនជ្រះ ចំនួន ២ (ពីរ) ដើម។

១០- បិកហ្វឺតធំចំនួន ១ (មួយ) ដើម។

១១- បន្ទាត់ជ័រចំនួន ១ (មួយ) ដើម។

១២- ប្រដាប់ចោះសន្លឹកឆ្នោតចំនួន ១ (មួយ)។

១៣- ជ័រការ៉ាវចំនួន ១ (មួយ) ដប។

១៤- កៅស៊ូកងមួយចំនួនសម្រាប់ចងសន្លឹកឆ្នោតតាមគណបក្ស។

១៥- ស្កុតថ្លាធំចំនួន ១ (មួយ)។

១៦- ស្រោមសំបុត្រធំចំនួន ១ (មួយ) មធ្យមចំនួន ៩ (ប្រាំបួន) និងតូចចំនួន ២ (ពីរ)។

១៧- ក្រដាសស្តើងសម្រាប់បិទពាសសន្ទះបិទប្រឡោះសិកសន្លឹកឆ្នោតចំនួន ៦ (ប្រាំមួយ) សន្លឹក។

១៨- ក្រដាសវ៉ាមសម្រាប់សរសេរសម្គាល់លេខការិយាល័យបោះឆ្នោតបិទលើហិបឆ្នោត និងសម្រាប់ប្រើប្រាស់ការងាររផ្សេងៗចំនួន ២០ (ម្ភៃ) សន្លឹក។

១៩- ផ្ទាំងក្រដាសសម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ចំនួន ២ (ពីរ) ផ្ទាំង។

២០- ផ្ទាំងក្រដាសធំសម្រាប់កត់ត្រាសំឡេងឆ្នោតចំនួន ១ (មួយ) ឬ ២ (ពីរ) សន្លឹក។

២១- ទម្រង់បែបបទលេខ ១១០១ ចំនួន ៦ (ប្រាំមួយ) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត (សម្រាប់បំពេញដោយ គ.ក.ប)។

២២- ទម្រង់បែបបទលេខ ១១០២ ចំនួន ៦ (ប្រាំមួយ) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (សម្រាប់បំពេញដោយ គ.ក.រ)។

២៣- ទម្រង់បែបបទលេខ ១១០៧ ចំនួន ៦ (ប្រាំមួយ) ច្បាប់ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (សម្រាប់បំពេញដោយ គ.ក.រ)។

២៤- ទម្រង់បែបបទលេខ ១១០៨ ចំនួន ៣ (បី) ច្បាប់ សម្រាប់កត់ត្រាសំឡេងឆ្នោត (សម្រាប់បំពេញដោយ គ.ក.រ)។

២៥- ទម្រង់បែបបទលេខ ១១១២ ចំនួន ២ (ពីរ) ច្បាប់ សម្រាប់បំពេញតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតដែល គ.ក.ប បានទទួល (សម្រាប់បំពេញដោយ គ.ក.ប)។

២៦- ទម្រង់បែបបទលេខ ១១១៥ ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ស្រង់វត្តមានភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលនៃការរាប់សន្លឹកឆ្នោត (សម្រាប់បំពេញដោយ គ.ក.រ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត)។

២៧- ទម្រង់បែបបទលេខ ១១២០ ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ស្រង់វត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្លោត (សម្រាប់បំពេញដោយ គ.ក.ប/គ.ក.រ និងអ្នកសង្កេតការណ៍បោះឆ្នោត)។

២៨- ទម្រង់បែបបទលេខ ១២០២ ចំនួន ២ (ពីរ) ក្បាល ក្នុងមួយក្បាលមាន ២០ (ម្ភៃ) ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់។

២៩- ថង់ប្លាស្ទិកដាក់សម្ភារ ឯកសារការិយាល័យរាប់សន្លឹកឆ្នោតចំនួន ១ (មួយ)។

៣០- ស្បោងប្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតដែលមិនទាន់ប្រើ និងគល់សន្លឹកឆ្នោតដែលប្រើហើយចំនួន ១ (មួយ)។

៣១- ស្បោងប្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការចំនួន ១ (មួយ)។

៣២- កញ្ចប់សុវត្ថិភាព "ក" សម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតចំនួន ១ (មួយ)។

៣៣- ស្បោង "ខ" សម្រាប់ដាក់កញ្ចប់សុវត្ថិភាព "ក" និងសម្ភារ ឯកសារបោះឆ្នោតចំនួន ១ (មួយ)។

៣៤- សោឃ្លុំដំរីតូចមានលេខសម្រាប់បិទគម្របខាងក្នុង និងខាងក្រៅនៃហិបឆ្នោតចំនួន ៣ (បី)។

៣៥- សោឃ្លុំដំរីមធ្យមមានលេខសម្រាប់ឃ្លុំបិទមាត់ស្បោង "ខ" ចំនួន ១ (មួយ)។

ឧបសម្ព័ន្ធទី៩
រូបមន្តរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់កម្រិតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនពីរ ឬច្រើន

ប្រការ១ : ការរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ២ (ពីរ) ឬច្រើន ត្រូវអនុវត្តតាមរូបមន្តដូចប្រការ៣ និងប្រការ៤ ខាងក្រោមនេះ។

ប្រការ២ : ក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ត្រូវអនុវត្តរូបមន្តដើម្បីរកកម្រិតលម្អៀងសំឡេងឆ្នោតដូចមានចែងក្នុងប្រការ១ ខាងលើនេះតាមការសម្រេចរបស់ គជ.ខប។ រីឯក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញនៃ គ.ជ.ប ត្រូវអនុវត្តរូបមន្តដើម្បីរកកម្រិតលម្អៀងសំឡេងឆ្នោតដូចមានចែងក្នុងប្រការ១ ខាងលើនេះ តាមការសម្រេចរបស់ គ.ជ.ប។

ប្រការ៣ : ក្នុងការរកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជន ២ (ពីរ) ក្រុមត្រួតពិនិត្យលទ្ធផលត្រូវ៖

៣.១ ស្រង់ចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងពីរដែលមានពាក្យបណ្តឹងថាមានលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយ។

ឧទាហរណ៍ទី១៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** មាន ១ ០០៥ សំឡេង
- បញ្ជីបេក្ខជននៃគណបក្ស **ខ** មាន ១ ០០០ សំឡេង។

៣.២ កំណត់យកសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលទាបជាងគេធ្វើជាភាគបែងសម្រាប់ប្រៀបធៀបរកភាគរយ។

ឧទាហរណ៍ទី២៖

ប្រៀបធៀបបញ្ជីបេក្ខជននៃគណបក្ស **ក** ដែលមាន ១ ០០៥ សំឡេង និងបញ្ជីបេក្ខជននៃគណបក្ស **ខ** ដែលមាន ១ ០០០ សំឡេង ដូចក្នុងឧទាហរណ៍ទី១ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវកំណត់ចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្ស **ខ** ដែលមានចំនួន ១ ០០០ សំឡេង ធ្វើជាភាគបែងសម្រាប់រកកម្រិតលម្អៀង។

៣.៣ យកចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្ស **ក** ដកនឹងចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្ស **ខ** គុណនឹង ១០០ ចែកនឹងភាគបែង (ចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្ស **ខ**) តាមរូបមន្តខាងក្រោម៖

$$ល = \frac{(ស_{ប}ក - ស_{ប}ខ) \times ១០០}{ស_{ប}ខ \text{ (ភាគបែង)}}$$

ក្នុងនោះ៖

- ល : តាងឱ្យចំនួននៃកម្រិតលម្អៀងរវាងបញ្ជីបេក្ខជននៃគណបក្ស **ក** និងបញ្ជីបេក្ខជននៃគណបក្ស **ខ** (គិតជាភាគរយដល់ ២ (ពីរ) ខ្ទង់ក្រោយក្បៀស)
- $ស_{ក}$: តាងឱ្យចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្ស **ក**
- $ស_{ខ}$: តាងឱ្យចំនួនសំឡេងឆ្នោតរបស់បញ្ជីបេក្ខជននៃគណបក្ស **ខ** និងជាភាគបែង។

អនុវត្តតាមរូបមន្តខាងលើ ចំពោះឧទាហរណ៍ទី១ យើងបាន៖

$$ល = \frac{(១\,００៥ - ១\,０００) \times ១００}{១\,０００} = ０,៥$$

ដូចនេះ កម្រិតលម្អៀងរវាងបញ្ជីបេក្ខជននៃគណបក្ស **ក និង**បញ្ជីបេក្ខជននៃគណបក្ស **ខ** គឺ **ល** ស្មើនឹង ០,៥ ភាគរយ។

ប្រការ៤ : ក្នុងការកកម្រិតលម្អៀងសំឡេងឆ្នោតដើម្បីកំណត់សំឡេងឆ្នោតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយ រវាងបញ្ជីបេក្ខជនច្រើន ក្រុមត្រួតពិនិត្យលទ្ធផលត្រូវ៖

៤.១ ជ្រើសរើសយកបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរដែលមានចំនួនសំឡេងឆ្នោតខុសគ្នាតិចជាងគេពីក្នុងចំណោមបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងឡាយដែលមានពាក្យបណ្តឹងថាមានសំឡេងឆ្នោតលម្អៀងរវាងគ្នានឹងគ្នាយ៉ាងច្រើន ០,៥ ភាគរយ។

ឧទាហរណ៍ទី៣៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** មាន ១ ００៥ សំឡេង
- បញ្ជីបេក្ខជននៃគណបក្ស **ខ** មាន ១ ０００ សំឡេង
- បញ្ជីបេក្ខជននៃគណបក្ស **គ** មាន ១ ００២ សំឡេង។

ផ្អែកតាមសម្មតិកម្មក្នុងឧទាហរណ៍ទី៣ យើងពិនិត្យឃើញថា៖

- រវាងបញ្ជីបេក្ខជននៃគណបក្ស **ក និង**បញ្ជីបេក្ខជននៃគណបក្ស **ខ** មានសំឡេងឆ្នោតខុសគ្នា ៥ សំឡេង
- រវាងបញ្ជីបេក្ខជននៃគណបក្ស **ក និង**បញ្ជីបេក្ខជននៃគណបក្ស **គ** មានសំឡេងឆ្នោតខុសគ្នា ៣ សំឡេង
- រវាងបញ្ជីបេក្ខជននៃគណបក្ស **ខ** និងបញ្ជីបេក្ខជននៃគណបក្ស **គ** មានសំឡេងឆ្នោតខុសគ្នា ២ សំឡេង។

ដូចនេះ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវកំណត់យកបញ្ជីបេក្ខជននៃគណបក្ស **ខ និង**បញ្ជីបេក្ខជននៃគណបក្ស **គ** ដែលមានសំឡេងឆ្នោតខុសគ្នាតិចជាងគេ (២ សំឡេង) មកគណនារកកម្រិតលម្អៀងសំឡេងឆ្នោតរវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងពីរ។

៤.២ ការគណនារកកម្រិតលម្អៀងសំឡេងឆ្នោត (ល) រវាងបញ្ជីបេក្ខជននៃគណបក្ស នយោបាយទាំងពីរដែលមានសំឡេងឆ្នោតខុសគ្នាតិចជាងគេក្នុងចំណោមបញ្ជីបេក្ខជន នៃគណបក្សនយោបាយពាក់ព័ន្ធ ត្រូវអនុវត្តតាមរូបមន្តដូចបានកំណត់ក្នុងចំណុច ៣.៣ ខាងលើនេះ។

បោះពុម្ពផ្សាយដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត